# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

COMMISSION DES MŒURS & COUTUMES



វិហារវត្តឧណ្ណាលោម រាជធានី ភ្នំពេញ មើលចំពីមុខ (រូបថត HBF)

ឆ្នាំទី ៥៤ លេខ ១

ខែ មករា - កុម្ភៈ - មីនា

ព.ស. ២៥៤៣

គ.ស. ២០០០

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

គ.ស. ២០០០

# ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

## ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : **ខួន ស៊ាន់ចន្ធី**

និពន្ធនាយក : **ឌិម ខែម**

និពន្ធនាយករង : **អាំ ឆន**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាច**, លោក **ម៉ែន ឫទ្ធាច**, លោក **ខច់ សុធារ៉ា**, លោក **ធន់ ហ៊ិន**, លោក **ម៉ៀច ប៉ុណ្ណ**, លោក **ខៀច បញ្ញាឧត្តម**, លោក **ពេជ ប៊ុន្នីន**

គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **នេខ ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុក ណារ៉ាខ** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សារឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា
- លោក បណ្ឌិតសាស្ត្រាចារ្យ **ឡុខ សៀម** នាយកវិទ្យាស្ថានជាតិខាងភាសា
- លោក បណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាខ** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិត្យ-សភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ

---

- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ ។

- The publication of this issue has been made possible by selling books published by the Buddhist Institute which are funded by the World Conference on Religions and Peace ( WCRP/Japan ) .

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា


- មិត្តកថា ការសំដែងពីជនដែលគួរ និងមិនគួរសេពគប់ ( ឱម ខៃម ) ..... ១
- ទស្សនៈព្រះពុទ្ធសសនា ( សម្តេច អ៊ុម ស៊ុម ) ..... ៧
- គុណាសីល ( សម្តេច អ៊ុម ស៊ុម ) ..... ១៦
- សុខរបស់អ្នករក្សាសីល ( សម្តេច អ៊ុម ស៊ុម ) ..... ១៧


## III. អក្សរសាស្ត្រទូទៅ និងអក្សរសិល្ប៍ខ្មែរ


- ជីវប្រវត្តិសម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម ..... ១៨
- ទង់ពុទ្ធសាសនា និងចម្រៀងសូត្របង្ហូត និងដាក់ទង់ ( ឱម សុមេធា ) ..... ២៩
- សុចរិត ៨ ប្រការ ជាមង្គលរបស់ស្រី ( ឱម ខៃម ) ..... ៣៦
- សិលាចារឹកថ្មី ១ Ka 64 នៅភូមិមេលប់ ក្បែរស្នាយពល និង បញ្ហាជាតិពន្ធនាមពីរ គឺ « ខ្មែរ » និង « មលេង » (វង់ សុធារ៉ា) ..... ៤១
- អំពីការបន្តចំណេះដឹងពីជំនាន់មួយទៅជំនាន់មួយ តាមរយៈ បណ្ណាល័យ ( យី ធន់ ) ..... ៥៩
- ដើមកំណើតនៃស្លា-ម្លូ-កំបោរ ( មៀច ប៉ុណ្ណ ) ..... ៦៦
- ចិត្តមិនព្រមចាស់ ( ញ៉ូង សឿង ) ..... ៧៣
- មនុស្សលោកថ្ងៃត្រៃលក្ខណ៍ ( មៀច ប៉ុណ្ណ ) ..... ៧៧
- ក្លិនវប្បធម៌ប្រហុកខ្មែរ ( គង្គ ប៊ុនឈឿន ) ..... ៨១

## IV. កំណត់ និង ប្រវត្តិការណ៍

• ពិធីទទួលសៀវភៅពីគណៈប្រតិភូ WCRP / Japan ..................... ៨២
• ការជួបប្រជុំការងារជាមួយអង្គការ WCRP / Japan ..................... ៨៩
• គណៈកម្មការទស្សនាវដ្តីកម្ពុជសុរិយា ..................... ៩១
• សេចក្តីជូនដំណឹង ..................... ៩៥

# មិត្តកថា

## ការសំដែងអំពីជនគួរសេពគប់ និង ជនដែលមិនគួរសេពគប់

**ឌិម ខែម**

រៀបរៀង និងនិពន្ធ

**ជីវិត** គឺការរស់នៅ ។ ដើម្បីរស់នៅបាន ត្រូវមានវត្ថុធាតុ និងសម្ភារៈសំរាប់ទ្រទ្រង់ ។ ជីវិតមនុស្ស ត្រូវការបរិក្ខារផ្គត់ផ្គង់ច្រើនជំពូក ស្ទើររាប់មិនអស់ ប៉ុន្តែជាមូលដ្ឋាន មនុស្សត្រូវការអាហារ, សម្លៀកបំពាក់, ជម្រក និងថ្នាំកែរោគ ។ បច្ច័យទាំង ៤ យ៉ាងនេះ ជាវត្ថុចាំបាច់សំរាប់មនុស្សដោយពិត, ប៉ុន្តែ ចំណីអាហារជាបច្ច័យមួយដែលនៅផ្ទាល់នឹងរាងកាយ ធ្វើអោយរូបកាយមានជីវិតរស់នៅ មានកម្លាំងពលំ និងមានពណ៌សម្បុរល្អវិសេសជាងបច្ច័យឯទៀតៗ ប្រសិនបើវាមានអនាម័យ, មានគុណភាព និងមានជីវជាតិ ។ ដូចគ្នានេះដែរ ជីវិតមនុស្សគ្រប់រូប ក៏ត្រូវការមានមិត្តភក្តិមានចិត្តល្អ ដូចអាហារដែលមានគុណភាព ដូច្នោះដែរ ។

តាំងពីព្រេងនាយមក ជីវិតមនុស្សគ្រប់រូបត្រូវការមិត្តភក្តិដែលមានចិត្តល្អជាទីពំនាក់ ខានមិនបាន ដូចត្រូវការភោជនាហារ ខានមិនបានដូច្នោះដែរ ។ នេះជាចំណោទសំខាន់ ។ បុគ្គលដទៃ ក្រៅពីមាតា បិតា ស្វាមីភរិយា បុត្រធីតា និងញាតិសន្តានរបស់ខ្លួនចេញ គឺមានតែមិត្តភក្តិនេះហើយ ដែលអាចជួយគាំទ្រដំណើរជីវិតយើងអោយប្រព្រឹត្តទៅបានស្រួល និងបានសំរេចប្រយោជន៍សមបំណង ។ តាមដំណើរនេះ គេឃើញថា សេចក្តីត្រូវការរបស់មនុស្សគ្រប់រូប ក្រៅពីបច្ច័យទាំង ៤

សំរាប់ទ្រទ្រង់ជីវិត គេត្រូវមានមិត្តចិត្តល្អជាដៃគូ ថែមទៀត ។ នៅត្រង់គាថាទី ១២៦ នៃការគប់មិត្ត ក្នុងច្បាប់ស្រីហិតោបទេស ភាគ ១ ថា « *ផ្ទះអ្នកមិនមានកូនជាផ្ទះសោះសូន្យ, នរជនមិនមានមិត្តចិត្តល្អ ជាបុគ្គលសោះសូន្យ ...* » ។

មែនពិត, បុគ្គលគ្មានមិត្ត ទុកដូចជាមនុស្សជរាពិការគ្រប់យ៉ាងគឺ មានភ្នែកភ្លឺ តែមើលអ្វីៗមិនឃើញឆ្ងាយ, មានត្រចៀកស្តាប់ឮ តែស្តាប់ការណ៍អ្វីមិនបានសព្វគ្រប់, មានដៃមាំមួន តែធ្វើការងារមិនបានល្បីឈ្មោះ និងមានជើងល្អជា តែធ្វើដំណើរទៅឆ្ងាយមិនរួច ។ ដោយហេតុនេះ មនុស្សម្នាក់ៗ ត្រូវមានមិត្តភក្តិជាចាំបាច់ ប៉ុន្តែ ត្រូវស្គាល់មិត្តអោយច្បាស់តាមសណ្តាប់ និងតាមតម្រាគប់មិត្តអោយបានម៉ត់ចត់ជាមុនសិន ទើបការគប់រកមិត្តអាចប្រព្រឹត្តទៅបានដោយប្រពៃ ពីព្រោះ ក្នុងច្បាប់បណ្តាំឪពុកប្រាប់ថា « *មិត្តមួយសោតណា៎ ទៅមកកាន់គ្នា បង្កើតអោយសុខ មិត្តមួយអោយទោស បង្កើតជាទុក្ខ មិត្តមួយអោយឆុក អោយបង់ទ្រព្យ* » ។

យោងតាមបណ្តាំខាងលើនេះ មុននឹងទទួលយកជនណាមួយធ្វើជាមិត្តជិតដិត គួរស្គាល់ជននោះអោយច្បាស់ ។ តើស្គាល់របៀបណា ? តាមពាក្យទំនឹមបុរាណថា មនុស្សគេយកសំដី, សំដីជាឯក, លេខជាទោ, អក្សរជាត្រី, ... ។

មែនហើយ, មនុស្សគេយកសំដី, ចេះសំដីទុកជាទី១ ចេះវិជ្ជាលេខទុកជាទី២ ចេះសរសេរអក្សរល្អទុកជាទី ៣ គឺថា ពូកែសំដីប្រសើរជាងការពូកែវិជ្ជាលេខ និងការពូកែសរសេរអក្សរល្អ ; តែតាមតម្រាគប់មិត្តថា នឹងដឹងថាអ្នកនេះជាមិត្តល្អ អ្នកនោះជាមិត្តអាក្រក់នោះ លោកអោយមើល « អំពើដែលគេប្រព្រឹត្ត » ។ សំដីល្អ សំដីពិរោះ សំដីទន់ភ្លន់ មិនទាន់អាចកំណត់បានថាជាមិត្តល្អ-អាក្រក់នោះទេ, លោកមិនអោយយកសំដីនោះជាហេតុ ដើម្បីធ្វើសេចក្តីស្និទ្ធស្នាល ឬទុកចិត្តបានទេ ព្រោះ សំដីល្អ សំដីពិរោះ ប្រៀបដូចទឹកឃ្មុំដែលជាប់នៅចុងអណ្តាត តែចិត្តគំនិតវិញ ពេញដោយពិសពុល ត្រូវនឹងពាក្យទំនឹមបុរាណថា « *ចិត្តជាទេវទត្ត មាត់ជាទេវតា* »

សេចក្ដីថា ចិត្តអាក្រក់ប្រហែលនឹងចិត្តទេវទត្ត ប៉ុន្តែ សំដីដែលចេញពីមាត់ ទន់ផ្អែម ពិរោះគួរនឹងអោយទុកចិត្តពិតប្រាកដ ដូចទេវតា ។

តាមធម្មតា, មនុស្សដែលបានប្រស្រ័យទាក់ទងគ្នា កផ្ដុំបានជាក្លើ-ម្រាក់មិត្តភក្តិ បក្សពួក មានច្រើនសណ្ឋាន ច្រើនបែបណាស់ តែចិត្តគំនិតអធ្យាស្រ័យមិនដូចគ្នាទេ, អ្នកខ្លះមានចិត្តសប្បុរស, អ្នកខ្លះមានចិត្តអសប្បុរស, អ្នកខ្លះស្លូត អ្នកខ្លះកាច ជាដើម ។ តែទោះច្រើនម្ដេចម្ដា ក៏គង់រួមមកនៅត្រឹមតែពីរពួក គឺ :

. មិត្តណាដែលសេពគប់ទៅមកកាន់គ្នា នាំអោយកើតសេចក្ដីសុខសេចក្ដីចំរើន, ចេះយោគយល់គ្នា ជួយយកអាសាគ្នា ស្មោះត្រង់នឹងគ្នា មិនក្បត់ចិត្តគ្នា, មិត្តនោះ ហៅថា « កល្យាណមិត្ត » ។

. មិត្តណាដែលសេពគប់ទៅមកកាន់គ្នា នាំអោយកើតទុក្ខទោស មានគ្រោះថ្នាក់ ខាតទ្រព្យសម្បត្តិ, មិត្តនោះ ហៅថា « បាបមិត្ត » ។

នៅក្នុងច្បាប់សិង្គាលោវាទសូត្រ គម្ពីរទីឃនិកាយ សុត្តន្តបិដក ដែលមានសេចក្ដីពន្យល់ពីរបៀបរស់នៅនៃសង្គមមនុស្ស និងពីទិដ្ឋភាពគ្រប់យ៉ាងនៃជីវិតប្រចាំថ្ងៃរបស់មនុស្សទូទៅ, ជាពុទ្ធវចនៈដែលព្រះពុទ្ធអង្គទ្រង់បានសំដែងប្រាប់ដល់មនុស្សក្នុងពិភពលោក, មានសេចក្ដីបញ្ជាក់ពីការគប់មិត្ត ដែលហៅ កល្យាណមិត្ត និងបាបមិត្ត ដូចតទៅនេះថា :

## ក) កល្យាណមិត្ត មាន ៤ យ៉ាង

*១) មិត្តឧបត្ថម្ភក៍ ( មិត្តដែលជាទីពឹងពំនាក់ ) :*

- ជួយយើង ក្នុងពេលដែលយើងគ្មានអ្នកជួយថែទាំ,
- ជួយថែរក្សាសម្បត្តិយើង ក្នុងពេលយើងមិននៅ,
- ជាទីពឹងរបស់យើង ក្នុងពេលដែលយើងមានភ័យ,
- ជួយរំលែកការងារលំបាកៗ បើយើងត្រូវការពឹងពាក់ ។

*២). មិត្តរួមសុខរួមទុក្ខ ( មិត្តប្តូរស្លាប់-រស់ជាមួយគ្នា ) :*

- ប្រាប់យើង នូវរឿងអាថិកំបាំងរបស់គេ,
- បិទបាំង នូវរឿងអាថិកំបាំងរបស់យើង,
- មិនបោះបង់យើងចោល នៅពេលមានការលំបាក,
- ហ៊ានលះបង់ សូម្បីជីវិតរបស់ខ្លួន ចំពោះជីវិតរបស់យើង ។

*៣). មិត្តមគ្គុទ្ទេសក៍ ( មិត្តប្រាប់ផ្លូវល្អ-អាក្រក់ ) :*

- ហាមឃាត់យើង មិនអោយធ្វើអំពើខុស,
- រួបរួមជាមួយយើង ក្នុងអំពើត្រូវ,
- ប្រាប់យើង នូវរឿងរ៉ាវដែលយើងមិនធ្លាប់បានឮ,
- បង្ហាញយើង នូវផ្លូវទៅរកសេចក្តីសុខ ។

*៤. សមានមិត្ត ( មិត្តចិត្តបាន ) :*

- មិនត្រេកអរចំពោះគ្រោះថ្នាក់របស់យើង,
- រីករាយចំពោះការចំរុងចំរើនរបស់យើង,
- ហាមឃាត់អ្នកណាមួយដែលនិយាយអាក្រក់ពីយើង,
- សរសើរបុគ្គលណាដែលនិយាយល្អពីយើង ។

កល្យាណមិត្ត មិត្តមានអធ្យាស្រ័យល្អ ដូចបានពណ៌នាមកនេះ ជាមិត្តពិតប្រាកដ, ជាមិត្តកម្រនឹងរកបានដោយងាយណាស់, ដូច្នេះ ត្រូវតែខំប្រឹងធ្វើខ្លួនឯងអោយបានជាមិត្តរបៀបនេះ ។ មិត្តពិតប្រាកដតែងតែដើរតាមគន្លងផ្លូវសុចរិត, មិត្តល្អ ភ្លឺថ្លៃងថាំងក្នុងសង្គម ដោយសារអំពើល្អរបស់គេ ។

ការសេពគប់កល្យាណមិត្ត តែងបានអានិសង្សខ្ពង់ខ្ពស់ ដូចយ៉ាងព្រះរាធត្ថេរ ដែលបានសេពគប់នឹងព្រះសារីបុត្រ ជាកំពូលកល្យាណមិត្ត, មិនយូរប៉ុន្មានក៏បានសំរេចអរហត្ត កំចាត់កិលេស ឥតសេសសល់ឡើយ ( ខុ.ធ. ) ។

## ខ) បាបមិត្ត មាន ៤ យ៉ាងគឺ :

*ក. មិត្តល្មោភ :*

មិត្តនេះគិតតែប្រយោជន៍ខ្លួន, ចាយបន្តិចបន្តួច តែសម្លឹងយកប្រយោជន៍ច្រើនឥតអៀនខ្មាស, ល្មោភមិនចេះល្មម, ល្មោភមិនចេះស្កប់ស្កល់ ដូចច្បាប់ពាក្យចាស់ថា « *បានហើយចង់បានបានទៀត ឆ្អៀតហើយឆ្អៀតពុំគិតល្វេង មើលយល់តែមុខឯង មិនឃើញគេឯទៀតផង* » ។

*ខ. មិត្តបានតែមាត់ :*

គឺមិត្តល្អតែវាចា ផ្អែមល្ហែមតែសំដី ។ មិត្តនេះមានសំដីសំដៅរៀបរយល្អ និយាយពាក្យបាទ ចាស ជានិច្ច, តែពេលមានការពឹងពាក់ម្តងម្កាល តែងនិយាយដោះដៃថាយ៉ាងនេះ យ៉ាងនោះ, បានត្រឹមតែថា មិនអីទេ, កុំព្រួយ ! ចាំមើលបន្តិចទៀតទៅ ! ទៅភ័យអី ! ... ។ មិត្តបែបនេះ លោកសន្មតថា « *មនុស្សឆ្អិនក្រៅ ឆៅក្នុង* » ចាត់ជាមនុស្សមិនបានការ យកជាគ្នាមិនកើត ។ មនុស្សឆ្អិនក្រៅ ឆៅក្នុង គឺមនុស្សបានតែមាត់, ពេលមានអាសន្នរត់រកគេជួយ ពេលផុតព្រួយធ្វើព្រងើយ ។ មិត្តបែបនេះ មិនចេះយកអាសានរណាទេ, មិនចេះជួយទុក្ខធុរៈនរណាទេ ។ មិត្តបានតែមាត់ ជាមិត្តមានសំដីក្រៅផ្អែម មានចិត្តខាងក្នុងល្វីងជូរចត់ មានទំនងត្រូវគ្នានឹងសុភាសិតច្បាប់ពាក្យចាស់ថា « *ចូលព្រៃសត្វសាហាវ ស្រែកអំពាវគ្នាមកជុំ ដល់បានស្ករទឹកឃ្មុំ ពួនសំងំស៊ីម្នាក់ឯង* » ។

*គ. មិត្តចាក់បណ្តោយ :*

មិត្តនិយាយចាក់បណ្តោយ គឺនិយាយតម្រូវអធ្យាស្រ័យ តម្រូវចំណុច, មិនទទឹង មិនប្រឆាំង មិនជំទាស់ ។ មិត្តនេះ បើមានកិច្ចការអ្វីគួរពិគ្រោះប្រឹក្សាជាមួយ ចេះតែអ៊ីអើ, ចេះតែហែអើ ទោះត្រូវក៏ដោយ ខុសក៏ដោយ មិនរារាំងទទឹងទាស់ឡើយ, ជាមិត្តផ្សំយកលាភ, និយាយសរសើរយើងតែនឹងមុខ និយាយ

ដើមយើងប្រាប់អ្នកដទៃពីក្រោយខ្នង ។

*ឃ. មិត្តស្រឡាញ់តែផ្លូវវិនាស :*

គឺមិត្តដែលចូលចិត្តប្រព្រឹត្តអបាយមុខ ។ ពុទ្ធសាសនាប្រាប់ថា អបាយមុខ ( ប្រធាននៃសេចក្ដីវិនាស ), ដោយសង្ខេបមាន ៤ យ៉ាងគឺ : លេងស្រី *(ឥត្ថីធុត្ត)*, លេងស្រា *(សុរាធុត្ត)* លេងល្បែងភ្នាល់ ឬល្បែងស៊ីសង *(អក្ខធុត្ត)* និងសេពគប់ជនអាក្រក់ជាមិត្ត *(បាបមិត្ត)* ។

មិត្ត ៤ ពួក ដែលរៀបរាប់មកនេះ ជាមិត្តមិនត្រូវសេពគប់ មិនត្រូវរាប់អាន, លោករាប់បញ្ចូលក្នុងបាបមិត្ត ព្រោះជាមិត្តនាំអោយកើតទោសទុក្ខ, នាំអោយខូចខាតទ្រព្យសម្បត្តិ ។ មិត្តបែបនេះ កុំសេពគប់ស្និទ្ធស្នាល គ្រាន់តែរាប់អានតាមធម្មតាបានហើយ ។ បើអ្នករកមិត្តល្អមិនបានទេ សូវនៅម្នាក់ឯងល្អជាង ។

ដូចបានពោលមកខាងដើមហើយថា មនុស្សរស់នៅបានដោយសារចំណីអាហារ ។ ចំណីអាហារ : បាយ ទឹក ត្រី សាច់ បន្លែ ផ្លែឈើ . ល . ដែលត្រូវបរិភោគនោះ មិនគ្រាន់តែជួយទ្រទ្រង់ជីវិតអោយគង់វង្សប៉ុណ្ណោះទេ វាថែមទាំងជួយផ្ដល់សុខភាព ផ្ដល់កម្លាំងពលំ និងធ្វើអោយប្រាជ្ញាប៉ាធិដុះដាលទៀតផង ប្រសិនបើវាមានអនាម័យ, មានគុណភាព និងមានជីវជាតិ ។ ជីវិតមនុស្សគ្រប់រូប ក៏ត្រូវការមិត្តភក្ដិដូចត្រូវការចំណីអាហារដូច្នោះដែរ តែត្រូវការតែមិត្តដែលមានចិត្តល្អ មិត្តស្មោះត្រង់ ចេះជួយគ្នា ពិសេស ក្នុងគ្រាមានវិបត្តិ ។

សំដែងអំពីកល្យាណមិត្ត មិត្តមានអធ្យាស្រ័យល្អ និងបាបមិត្ត មិត្តដែលមានអធ្យាស្រ័យអាក្រក់ ដោយសង្ខេបមកនេះ, គួរយុវជនទាំងឡាយ គួរកុំសេពគប់បាបមិត្ត, គួរសេពគប់តែកល្យាណមិត្ត, ប៉ុន្តែ គួរប្រយ័ត្នកុំធ្វើអោយបាបមិត្តក្លាយជាសត្រូវឡើយ ៕

# ទស្សនៈព្រះពុទ្ធសាសនា

រៀបរៀងដោយ

សម្ដេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម**

*ក.ក.ន.. អត្ថបទស្ដីពី « ទស្សនៈព្រះពុទ្ធសាសនា » នេះ គឺជាស្នាព្រះហស្ដនៃសម្ដេចព្រះមង្គលទេពាចារ្យ* ***អ៊ុម ស៊ុម*** *អគ្គាធិការនៃពុទ្ធិកសិក្សា ។ ខ្ញុំបានទទួលអត្ថបទនេះពីសម្ដេច នៅខែមករា ឆ្នាំ ២០០០ ក្នុងឱកាសដែលខ្ញុំបានទៅថ្វាយបង្គំសម្ដេច នៅឯកុដិវត្តមហាមន្ត្រី ដើម្បីសុំពិគ្រោះយោបល់អំពីការផ្សាយអក្សរសាស្ត្រពុទ្ធសាសនា តាមទំព័រទស្សនាវដ្ដីកម្ពុជសុរិយា របស់ពុទ្ធសាសនបណ្ឌិត្យ និងសុំសម្ដេចជួយផ្ដល់អត្ថបទពុទ្ធសាសនា សំរាប់ចុះផ្សាយរៀងរាល់លេខ ចាប់ពីឆ្នាំ ២០០០ តទៅ ។*

*សម្ដេចបានមានពុទ្ធដីកាថា « លោកខែម, អាត្មាមានសេចក្ដីសប្បាយរីករាយនឹងការចេញផ្សាយឡើងវិញនៃទស្សនាវដ្ដីនេះណាស់ ពីព្រោះទស្សនាវដ្ដីនេះជាកម្លាំងឃោសនិកដ៏សំខាន់របស់ពុទ្ធសាសនបណ្ឌិត្យ, តែដូចខែមឯងដឹងស្រាប់, ការងារអាត្មា នៅឯអគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា កាន់តែច្រើន, វ័យក៏ចាស់, សុខភាពក៏មិនទៀងទាត់ មិនសង្ឃឹមថាមានពេលជួយសរសេរអត្ថបទពុទ្ធសាសនា សំរាប់កម្ពុជសុរិយានេះបានគ្រប់លេខទេ, តែនៅតែតាំងចិត្តខិតខំជួយ បានប៉ុណ្ណាយកប៉ុណ្ណឹង ដើម្បីរួមចំណែកលើកស្ទួយសីលធម៌ពុទ្ធសាសនាក្នុងសង្គម តាមរយៈទំព័រទស្សនាវដ្ដីនេះ ។ ជាមួយនេះ, អាត្មាសុំធ្វើការកត់សំគាល់ថា អត្ថបទដែលយើងបានចុះផ្សាយរួចហើយ ទាំង*

*អត្ថបទអក្សរសាស្ត្រពុទ្ធសាសនា ទាំងអត្ថបទអក្សរសាស្ត្រទូទៅ សុទ្ធសឹងតែជាអត្ថបទមានតម្លៃដល់អ្នកសិក្សាស្រាវជ្រាវ ផ្តល់ចំណេះដឹងល្អៗណាស់ តែក៏មានឃ្លាខ្លះពិបាកស្តាប់ ព្រោះពាក្យបាលី និងពាក្យមានអាថ៌ជាលជ្រៅ ។ អាត្មាយល់ថា គួរគណៈកម្មការបោះពុម្ពផ្សាយពិនិត្យកែលំអការងារនិពន្ធ គ្រប់បទនិពន្ធនីមួយៗអោយដំណើរពាក្យមានសេចក្តីគ្រប់គ្រាន់ ឃ្លាប្រយោគងាយស្តាប់ ងាយយល់ ហើយអត្ថបទនីមួយៗមានអត្ថន័យ អត្ថរូប និងអត្ថរសពេញលេញ ដើម្បីប្រែក្លាយទស្សនាវដ្តីនេះអោយទៅជាកម្លាំងឃោសនិកដ៏មានភក្តីភាព និងបានទទួលការនិយមពីគ្រប់មជ្ឈដ្ឋានសង្គមខ្មែរ ។*

*អត្ថបទស្តីពី « ទស្សនៈព្រះពុទ្ធសាសនា » ដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីនេះ ពិតជាធម្មទេសនាបំភ្លឺផ្លូវយ៉ាងវិសេស ឆ្ពោះទៅរកសេចក្តីសុខក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ។ សូមនិមន្ត-អញ្ជើញសិក្សា និងពិចារណា ដូចតទៅ :*

ព្រះពុទ្ធសាសនា ជាសាសនាមួយសម្បូរពាក្យប្រៀនប្រដៅ ដែលប្រកបដោយខ្លឹមសារ មានប្រយោជន៍ មានតម្លៃខ្ពង់ខ្ពស់ច្រើនណាស់ ។ មានពាក្យប្រៀនប្រដៅខ្លះ ត្រូវគ្នានឹងពាក្យប្រៀនប្រដៅរបស់អ្នកប្រាជ្ញទាំងឡាយអំពីបុរាណ ដែលមនុស្សលោកគេបានចេះចាំរៀងៗមក តាំងអំពីមុនពុទ្ធកាលក៏មាន ។ មានពាក្យប្រៀនប្រដៅខ្លះខ្ពង់ខ្ពស់បំផុត ហួសពីគំនិតរបស់មនុស្សបុថុជ្ជនទាំងអស់ ដែលក្រៅអំពីព្រះសម្ពុទ្ធចេញ ឥតមានអ្នកណាមួយ មានគំនិតគិតឃើញ មានសមត្ថភាព យង់យល់ចាក់ធ្លុះដឹងច្បាស់នូវអាថិកំបាំងដ៏ជ្រាលជ្រៅបានឡើយ ។

ព្រះពុទ្ធសាសនា មានកំណើតនៅមជ្ឈិមប្រទេស ( ឥណ្ឌា ) ។ មុនដែលព្រះពុទ្ធសាសនាមិនទាន់កើតឡើង មនុស្សទូទៅនៅអាស្រ័យក្នុងប្រទេសនោះបាននាំគ្នាប្រព្រឹត្តប្រតិបត្តិតាមលទ្ធិសាសនាព្រាហ្មណ៍ខ្លះ តាមសាសនាដទៃទៀតខ្លះ ដែល

ជាផ្លូវប្រតិបត្តិតឹងពេកក៏មាន ធូរពេកក៏មាន ដូចជាប្រព្រឹត្តអត់អាហារ ធ្វើអោយលំបាកវេទនារាងកាយខ្លួនឯងឥតអំពើ, ដេកលើបន្លា, ចុះត្រាំទឹកដើម្បីលាងជម្រះបាប, អាំងភ្លើងនៅវេលាថ្ងៃក្នុងគិម្ហរដូវ ជាដើម ។

ទោះបីប្រព្រឹត្តបែបនេះដែលគ្មានបានផល គ្មានឃើញកើតប្រយោជន៍សូម្បីបន្តិចបន្តួចក៏ដោយ ក៏ឥតមានជនណាភ្ញាក់រលឹក មានគំនិតគិតឃើញ ហើយនាំគ្នាវិវរលាស់ខ្លួនងាកទៅប្រតិបត្តិតាមបែបថ្មីទៀតសោះឡើយ ។

លុះមកដល់សម័យព្រះសម្ពុទ្ធបានត្រាស់ដឹងឡើង ទ្រង់បានសំដែងធម៌ជាលើកដំបូងប្រោសភិក្ខុចំនួន ៥ រូប ហៅថា *ធម្មចក្កប្បវត្តនសូត្រ* ដើម្បីកែប្រែវិធីប្រតិបត្តិដ៏សៅហ្មង គ្រោតគ្រាត ទាំងនោះចោលចេញ ហើយអោយកែប្រែចិត្តគំនិតខុសទាំងនោះ អោយប្រព្រឹត្តតាមគន្លងធម៌ ដែលព្រះអង្គយល់ជ្រាបច្បាស់ថាមានប្រយោជន៍វិញ ។

ធម៌ទេសនាជាបឋមនោះ ទ្រង់ត្រាស់សំដែងថា *ទ្វេ មេ ភិក្ខវេ អន្តា បព្ពជិតេន ន សេវិតព្វា* ម្នាលភិក្ខុទាំងឡាយ ធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមក អាក្រក់ទាំងឡាយពីរប្រការនេះ បព្វជិតមិនគួរសេពគប់, មិនគួរប្រព្រឹត្តធ្វើឡើយ ៖

១. *អត្តកិលមថានុយោគ* ៖ ការប្រព្រឹត្តធ្វើខ្លួនអោយលំបាក ។ ធម៌នេះគឺជាឈ្មោះនៃទ្រឹស្តីទាំងមូលរបស់សាសនាព្រាហ្មណ៍ បានជាព្រះសម្ពុទ្ធត្រាស់ដូច្នេះពីព្រោះ សាសនាព្រាហ្មណ៍ គេបានប្រព្រឹត្តធម៌ពីរយ៉ាង គឺ ៖

ក. *តបៈ* គឺជាកិច្ចការ ឬជាវិន័យ ដែលពួកអ្នកកាន់សាសនាព្រាហ្មណ៍ ត្រូវតែធ្វើ ដូចជាពួកអចេលក៍ មិនស្លៀកពាក់ខោអាវ អាំងភ្លើង ឈរហាលថ្ងៃ ចុះត្រាំទឹក ប្រព្រឹត្តអត់អាហារ ។ ដូច្នេះ ជាពិធីដើម្បីហាត់ពត់ចិត្តរបស់គេអោយអស់កិលេស ។ ព្រះសម្ពុទ្ធទ្រង់រិះគន់ថា ធម៌នេះជាធម៌លាមក ថោកទាប ដែលមនុស្សទូទៅមិនគួរនឹងយកខ្លួនទៅលាយឡំទេ ។ នៅក្នុងលទ្ធិសាសនាព្រាហ្មណ៍ ក្នុងសម័យ

ព្រាហ្មណ៍ គេមានធម៌ជាពិធីទូន្មានខាងផ្លូវកាយ ។

ខ. *យោគៈ* ពួកអ្នកកាន់សាសនាព្រាហ្មណ៍ ដោយយល់ឃើញថា *តបវិធី* ជាវិធីគ្រាន់តែទូន្មានផ្លូវកាយ មិនមានប្រសិទ្ធភាពដល់ទៅផ្លូវចិត្តផងទេ គេក៏នាំគ្នាធ្វើពិធីមួយទៀត ដែលហៅថាយោគៈ សំរាប់អប់រំផ្លូវចិត្ត ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ការអប់រំផ្លូវចិត្តនេះ នៅតែមិនអាចធ្វើចិត្តអោយជ្រះស្រឡះរកមោក្សៈ ឬនិព្វានបានឡើយ ។

២. *កាមសុខល្លិកានុយោគ :* នេះជាទ្រឹស្តីរបស់ពួកសាសនាព្រាហ្មណ៍ដែរ គ្រាន់តែផ្ទុយនឹងទស្សនៈខាងដើម ។ ទស្សនៈនេះនាំអោយយល់នូវគោលគំនិត និងបុព្វហេតុដែលនាំអោយគេបានទទួលនូវសុភមង្គល មានជាអាទិ៍ថា បុព្វហេតុនៃសុភមង្គល ស្ថិតនៅលើបុគ្គលម្នាក់ៗ ដែលចេះលៃលកយ៉ាងណាអោយសម្បូរដោយគ្រឿងកាម គ្រឿងសប្បាយ ដូចជាស៊ីផឹកឆ្ងាញ់ពិសា ស្លៀកពាក់ហ៊ឺហា ទីលំនៅឧដុង្គឧត្តមប្រសើរឡើង ។ ការស៊ីឆ្ងាញ់ ការដេកស្រួល ការប្រើប្រាស់នូវវត្ថុល្អ នឹងនាំអោយគេបានសុខចំរើនគ្រប់វិស័យ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់រិះគន់នូវគោលនៃលទ្ធិនេះថាជាគំនិតថោកទាប អពមង្គល ឈមមុខឆ្ពោះទៅរកសេចក្តីវិនាសទាំងអស់ ។

ដោយគោលគំនិតពីរខាងលើជាគោលគំនិតឆ្វេងបំផុត និងស្តាំបំផុត ទើបព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រកាន់យកផ្លូវកណ្តាលវិញ សំរាប់ធ្វើជាមធ្យោបាយដឹកនាំមនុស្សអោយប្រព្រឹត្តទៅបានដោយស្រួល ។ ករណីទាំងពីរខាងលើនេះ បើប្រៀបធៀបទៅនឹងជីវភាពរបស់ព្រះអង្គកាលពីខាងដើម ក៏មានការស្របគ្នាដែរ :

- ខណៈទីមួយ គឺព្រះអង្គទ្រង់គង់នៅក្នុងរាជសម្បត្តិ ដែលជារយៈពេលសប្បាយដោយកាមគុណ ។
- ខណៈទីពីរ គឺរយៈពេលដែលព្រះអង្គចេញសាងផ្នួស ធ្វើទុក្ករកិរិយាយ៉ាងតឹងរ៉ឹងពេក ។

រយៈពេលទាំងពីរនេះ លុះព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គទ្រង់រិះគន់ថា ជាអំពើថោកទាប មិនមែនជាផ្លូវប្រតិបត្តិ មិនមានប្រយោជន៍សំរាប់អ្នកប្រតិបត្តិទេ ព្រះអង្គក៏ជ្រើសរើសយកផ្លូវប្រតិបត្តិកណ្តាលវិញ ។

ឯផ្លូវកណ្តាលនោះ មាន ៨ យ៉ាង :

១. *សម្មាទិដ្ឋិ* ការយល់ឃើញត្រូវ ១

២. *សម្មាសង្កប្បៈ* សេចក្តីត្រិះរិះត្រូវ ១

៣. *សម្មាវាចា* សំដីត្រូវ ១

៤. *សម្មាកម្មន្តៈ* ការងារត្រូវ ១

៥. *សម្មាអាជីវៈ* ការចិញ្ចឹមជីវិតត្រូវ ១

៦. *សម្មាវាយាមៈ* ព្យាយាមត្រូវ ១

៧. *សម្មាសតិ* សេចក្តីរលឹកត្រូវ ១

៨. *សម្មាសមាធិ* ការតម្កល់ចិត្តអោយនឹងត្រូវ ១ ។

ផ្លូវកណ្តាលនេះ ហៅថា *អដ្ឋង្គិកមគ្គ* ជាផ្លូវប្រសើរខ្ពង់ខ្ពស់ស្អាតត្រង់ដែលព្រះអរហន្តទាំងឡាយ មានព្រះសម្ពុទ្ធជាដើម ព្រះអង្គបានដើរប្រកបដោយសុខស្រួល ហើយចង្អុលបង្ហាញប្រាប់ដល់ពុទ្ធបរិស័ទទាំងឡាយថា នែ អ្នកទាំងឡាយ ! ចូរអ្នកដើរទៅតាមផ្លូវនេះចុះ ។

នៅមានធម៌ដែលជាពុទ្ធសាសនាមួយយ៉ាងទៀត ដែលហៅថា *សច្ចៈ* ជាធម៌ប្រកាសនូវពាក្យពិត ពាក្យមែន ។

បញ្ហាសច្ចៈនេះ បានចោទឡើងនៅក្នុងសង្គមមនុស្សគ្រប់មជ្ឈដ្ឋាន បាននាំអោយអ្នកប្រាជ្ញទាំងឡាយក្នុងលោកចោទ និងដោះស្រាយទៅវិញទៅមក មិនឈប់ឈរ ដើម្បីស្វះស្វែងរកសច្ចៈនេះ ។ យើងអាចចោទសួរថា *សច្ចៈ* ជាអ្វី ? អ្នកណាបង្កើតពាក្យសច្ចៈ ? សច្ចៈនេះ មាននៅក្នុងលោកនេះ ឬក្នុងលោកខាងមុខ ?

ស្ថិតនៅក្នុងសង្គមមនុស្ស ឬនៅលើបុគ្គលម្នាក់ៗ ? ឬក៏ស្ថិតនៅក្នុងវត្ថុធម្មជាតិគ្រប់បែបយ៉ាង ? ដរាបណា មានបញ្ហានេះចោទឡើងនោះ យើងត្រូវតែខំប្រឹងប្រើមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីវែកញែកឆ្លុះមើលសច្ចះនេះអោយឃើញច្បាស់ ។

មជ្ឈដ្ឋានសាសនា « ពួកពាហិរសាសនា » គេបានអះអាងថា សច្ចះស្ថិតនៅលើព្រះអាទិទេព ។ អាទិទេព គឺជាតួព្រះបរិបុណ្ណសច្ចះ គេខំប្រឹងប្រតិបត្តិគ្រប់បែបយ៉ាង គឺដើម្បីមើលអោយឃើញព្រះអាទិទេពនេះឯង ។ ដរាបណា គេមើលឃើញព្រះអាទិទេព គេក៏បានទទួលនូវសច្ចះដែរ គឺបានសុខសំរេចដល់មោក្ខះ ។

មជ្ឈដ្ឋានអ្នកទស្សនះវិទូភាគខ្លះ ដែលមិនទាក់ទងទៅនឹងសាសនា បានខំពន្យល់ថា *សច្ចះ* ស្ថិតនៅក្នុងសង្គមមនុស្សនេះឯង ។ ដរាបណា គេខំរចនាសង្គមមនុស្សអោយបានស្អាតបរិសុទ្ធ ប្រាសចាកអំពើអយុត្តិធម៌ សម្របសម្រួលនូវជីវភាពរបស់មនុស្សអោយបានស្រួល ដរាបនោះឯង សច្ចះ នឹងកើតឡើងភ្លាម ។ មូលដ្ឋាននៃសច្ចះក្នុងសង្គមមនុស្សនេះ ពោលគឺ ចរិយា សីលធម៌ នេះឯង ។ ទស្សនវិទូប្រភេទនេះ សង្កត់ខ្លាំងទៅលើសង្គមមនុស្ស ជីវភាពមនុស្សធម្មតា ដោយគេខំពន្យល់តែអំពីវិបត្តិគ្រប់បែបយ៉ាងដែលប៉ះពាល់សង្គមមនុស្ស បើគេដកចេញ នូវអ្វីដែលជាវិបត្តិនេះហើយ ពេលនោះ គេនឹងរកឃើញនូវអ្វីដែលជាសុខ ។

មជ្ឈដ្ឋានអ្នកវិទ្យាសាស្ត្រ ដើម្បីទាញយកសច្ចះបាន គេត្រូវធ្វើការពិសោធន៍ ។ ក្រោយពីការពិសោធន៍ គេបានលទ្ធផលយ៉ាងណា លទ្ធផលនោះឯងជាសច្ចះ ។ ពួកអ្នកវិទ្យាសាស្ត្រសម្ភារនិយម គេអោយតម្លៃដាច់ខាតទៅលើការពិសោធន៍ជាក់ស្តែង ។ ដរាបណា គេធ្វើការពិសោធន៍ទៅ អោយផលមិនទៀងទាត់ម្តងយ៉ាងនេះ ម្តងយ៉ាងនោះ គេមិនទទួលថាសច្ចះឡើយ ។ នឹងទទួលជាសច្ចះបានលុះត្រាតែមានសភាពពិត ដូចជា ២ x ២ = ៤ ។

ចំណែកសច្ចះ នៅក្នុងព្រះពុទ្ធសាសនា ដែលហៅថាសច្ចធម៌ដែរ ព្រះពុទ្ធ

បរមគ្រូនៃយើង បានស្រាវជ្រាវរកអស់រយៈពេល ៦ ឆ្នាំ ទើបឃើញនោះ មាន ៤ ប្រការ គឺ :

- *ទុក្ខសច្ចៈ* ទុក្ខ គឺជារបស់ពិត ពីព្រោះចេះតែតាមបៀតបៀន,
- *សមុទយសច្ចៈ* តណ្ហានាំអោយកើតទុក្ខ គឺជាសេចក្តីពិត ពីព្រោះចេះតែនាំអោយស្ពន់ស្លោ, អន្ទះសានៅពុំសុខ,
- *និរោធសច្ចៈ* ព្រះនិព្វានជាកន្លែងរំលត់ទុក្ខ គឺជាសេចក្តីពិត ពីព្រោះវាអស់ពួជបន្ត,
- *មគ្គសច្ចៈ* ផ្លូវទៅកាន់ទីរំលត់ទុក្ខ គឺជាសេចក្តីពិត ពីព្រោះផ្លូវនោះត្រង់ ហើយស្អាតពិសេស ។

សច្ចធម៌ទាំង ៤ ប្រការនេះ ជាធម៌មានអាថ៌ជ្រាលជ្រៅ កំបាំងនឹងគំនិតប្រាជ្ញារបស់មនុស្សបុថុជ្ជនធម្មតាទាំងអស់ ។ ពេលដែលមិនទាន់មានព្រះពុទ្ធសាសនា ឥតមានអ្នកណាមួយស្រាវជ្រាវរាវរកឃើញសច្ចៈនេះឡើយ ។ លុះដល់ព្រះពុទ្ធបានត្រាស់ដឹងឡើងក្នុងលោក ទើបទ្រង់សំដែងសច្ចធម៌នេះអោយមនុស្សទាំងអស់បានស្គាល់ច្បាស់ប្រាកដក្នុងខ្លួន ។

សច្ចៈទាំង ៤ ប្រការនេះហើយ ដែលអ្នកមានប្រាជ្ញាទាំងឡាយបានឮ បានស្គាល់ ហើយគិតពិនិត្យតាមធម៌នេះទៅ ក៏យល់ដោយប្រត្យក្សថាជាធម៌ពិតមែន ។

នៅមានទស្សនៈពុទ្ធសាសនាម្យ៉ាងទៀត ដែលសំរាប់អប់រំមនុស្សអោយចេះគិតគូរពិចារណាដល់រូបរាងកាយ អោយឃើញថាមិនទៀង ជាទុក្ខ និងមិនមែនជារបស់ខ្លួន ដែលមានឈ្មោះថា *ព្រះត្រៃលក្ខណ៍* ដើម្បីកុំអោយមានសេចក្តីស្រឡាញ់ក្នុងរូបកាយខ្លាំងពេក ។

ម្យ៉ាងទៀត ពុទ្ធសាសនាប្រៀនប្រដៅមនុស្សអោយឃើញប្រយោជន៍អោយបានសេចក្តីសុខ ពុំមែនតែក្នុងអនាគតខាងមុខដែលយើងមើលមិនឃើញប៉ុណ្ណោះទេ គឺក្នុងបច្ចុប្បន្ន ធ្វើអោយយើងរឹតតែឃើញជាក់ច្បាស់លាស់ ដូចជា

ទ្រង់ប្រដៅមនុស្សមិនអោយប្រព្រឹត្តនូវអបាយមុខ ៦ យ៉ាង គឺ :

- មិនអោយផឹកសុរា ១,
- មិនអោយដើរលេងតាមច្រកល្ហកនៅវេលាយប់ ១,
- មិនអោយដើរលេងមើល ល្បែងមហោស្រពឥតប្រយោជន៍ ១,
- មិនអោយលេងល្បែងភ្នាល់ មានបៀរប៉ោ ជាដើម ១,
- មិនអោយសេពគប់មនុស្សខូចយកធ្វើជាមិត្តភក្តិ ១, មិនអោយខ្ជិលធ្វើការងារបង្កបង្កើនផល ១ ។

ប៉ុណ្ណេះជាដើម សុទ្ធតែនាំមនុស្សអ្នកប្រព្រឹត្តតាមអោយបានប្រយោជន៍ដ៏ខ្ពង់ខ្ពស់ និងសេចក្ដីសុខគួរជាទីប្រាថ្នានៅក្នុងបច្ចុប្បន្ននេះឯង ។

ជាពិសេសទៅទៀត គួររលឹកនឹកដល់ : កាលព្រះសក្យមុនីសម្ពុទ្ធជិតនឹងចូលកាន់ខន្ធនិព្វាន ទ្រង់មានព្រះពុទ្ធបណ្ដាំអោយចងចាំរាល់គ្នាថាៈ « *សង្ខារធម៌ទាំងឡាយដែលកើតឡើងហើយ តែងតែវិនាសទៅវិញជាធម្មតា អ្នកទាំងឡាយចូរបំពេញនូវភារកិច្ចរៀងៗខ្លួនអោយសំរេចជាស្ថាពរចុះ ដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ចុះ* » ; ទ្រង់ផ្ដាំតែប៉ុណ្ណេះហើយក៏ចូលបរិនិព្វានទៅ, គួរពុទ្ធមាមកជននឹកដល់ព្រះបណ្ដាំនេះរឿយៗ !

បច្ឆិមពុទ្ធវចនៈនេះ ជាទស្សនៈពុទ្ធសាសនាមួយ៉ាង ដែលមានប្រយោជន៍ប្រកបដោយខ្លឹមសារជាទីបំផុត ។ ព្រះពុទ្ធដីកានេះ ព្រះអង្គចង់បញ្ជាក់ថា យើងដែលមានជាតិជាមនុស្ស មិនត្រូវដេកស្ងៀម ឈរឱបដៃមើល ដកដង្ហើមចោលទទេគ្មានស្មារតីប្រុងប្រយ័ត្នទេ គឺត្រូវក្រោកឡើងខំប្រឹងប្រកបការងារផ្សេងៗ ដើម្បីជាប្រយោជន៍សំរាប់ខ្លួន រៀងៗខ្លួន កុំបង្អែបង្អង់ឡើយ ។

ការងារទាំងនេះ បើជនណាបានធ្វើ បានជួយឧបត្ថម្ភគ្នាទៅវិញទៅមកតាមកំលាំង និងសមត្ថភាពរបស់ខ្លួននោះ បើទុកជាស្លាប់ទៅ គ្រាន់តែអស់ខ្យល់ដក

ដង្ហើមចេញចូលប៉ុណ្ណោះ ក៏ប៉ុន្តែ ទុកដូចជាមានជីវិតរស់នៅដែរ ពីព្រោះ :

- *អប្បមាទោ អមតំ បទំ* ការមិនប្រមាទ គឺមានស្មារតីប្រុងប្រយ័ត្នជានិច្ច ជាមូលដ្ឋាននៃការមិនស្លាប់ អ្នកណាមានស្មារតីប្រុងប្រយ័ត្នជានិច្ច អ្នកនោះឈ្មោះថាមិនចេះស្លាប់ ។ បើទុកជាស្លាប់ហើយ ក៏ដូចជាមានជីវិតរស់នៅដែរ ។ ចំណែកអ្នកដែលគ្មានស្មារតីប្រុងប្រយ័ត្ន បើទុកជារស់នៅ ក៏ដូចជាស្លាប់ទៅហើយ ពីព្រោះសេចក្តីប្រមាទ គឺការមិនប្រុងប្រយ័ត្នស្មារតី ជាមូលដ្ឋាននៃសេចក្តីស្លាប់ ។

- *អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ* អ្នកប្រាជ្ញ តែងតែរក្សាទុកនូវការប្រុងប្រយ័ត្ន ដូចជារក្សាទុកទ្រព្យដ៏ប្រសើរ ។

•

## សុភាសិត :

* កល្យាណមិត្ត ស្មោះស្មើគំនិត រកបានកម្រ លុះតែសេពគប់
ទើបយល់ខ្មៅស សុចរិតអាក្រក់ល្អ ដោយរួមការងារ ។
* ការឈ្លោះទាស់គ្នា ញាតិផៅមិត្តភ្ញា យើងអ្នកដទៃ មិនត្រូវជ្រៀតជ្រែក
ជជែកបំភ័យ អោយម្ខាងមានជ័យ កើតទាស់គ្នាខ្លាំង ។
* កាឈ្លោះប្រកែក គ្រួសារបាក់បែក ដោយឡែកពីគ្នា សាច់ញាតិសន្តាន
បែកសាមគ្គី ត្រូវតែផ្សះផ្សារ ដោយស្វាត់កំបាំង ។

# គុណសីល

សាធុជនទាំងឡាយ ចូរខ្វល់ខ្វាយសម្អាតសីល
ជម្រះអស់មន្ទិល សព្វសុរិល(*) ឱ្យផូរផង់ ។
គឺសង្រួមប្រយ័ត្ន ហាត់ពត់ចិត្តប្រព្រឹត្តផ្ចង់
វាចាកាយត្រង់ ឱ្យដើរត្រង់ផ្លូវសុចរិត ។
នឹងបានសំរេចផល អានិសង្សផ្តល់ពិតប្រាកដ
អ្នកមានសីលបរិសុទ្ធ ឆាប់ចំហុតទាំងថ្ងៃយប់ ។
ព្រោះអ្នកដែលទៅកើត នាកំណើតសុគតិភព
ជាស្ថានសំរេចគ្រប់ សម្បត្តិទិព្វច្រើនប្រការ ។
គឺបានដោយសារគុណ សីលដែលខ្លួនខំរក្សា
ព្យាយាមសាងវាចា កាយចេតនាស្អាតម៉ត់ចត់ ។
អ្នកដែលបានកាក់កប ដោយភោគទ្រព្យសម្បូរក្តាត់
ស្តុកស្តម្ភសក្តិសមផុត ព្រោះសីលសុទ្ធនោះឯងនែ ។
អ្នកដែលដល់និព្វាន សុខក្សេមក្សាន្តគ្មានទុក្ខភ័យ
ដោយសារតែបច្ច័យ សីលថ្លាថ្លៃនេះប្រាកដ ។
ហេតុនេះអ្នកទាំងឡាយ ប្រុងប្រៀបកាយវាចាចិត្ត
ញ៉ាំងសីលឱ្យបរិសុទ្ធ ស្អាតម៉ត់ចត់សព្វៗកាល ។

សម្តេចព្រះមង្គលទេពាចារ្យ

**អ៊ុំ សុម**

---

(*) សរិល ( សរីរៈ ) ប្រើក្លាយជា សុរិល មានន័យថា រាងកាយ, ខ្លួនប្រាណ

# សុខរបស់អ្នករក្សាសីល

សប្បុរសអ្នករក្សាសីល ជ្រះមន្ទិលស្អាតម៉ត់ចត់
វាចាកាយបរិសុទ្ធ គ្មានវិបត្តិដាច់ធ្លុះធ្លាយ ។
រមែងចំរើនសុខ ចាកទោសទុក្ខភ័យអន្តរាយ
សុខសាន្តបានសប្បាយ ធំទូលាយប្រាំប្រការ ។
• ទីមួយបានសុខសាន្ត ដោយពុំមានទោសផ្គន្ធា
ចាក់កាប់សម្លាប់គ្នា នាំមានពៀរយូរអង្វែង ។
• ទីពីរបានសុខសាន្ត ដោយពុំមានទោសកំហែង
សម្បត្តិទ្រព្យគេឯង តែបំប្លែងដោយទុច្ចរិត ។
• ទីបីបានសុខសាន្ត ដោយពុំមានទោសប្រព្រឹត្ត
កាមេរអំពើក្បត់ ចិត្តស្វាមីប្រពន្ធគេ ។
• ទីបួន បានសុខសាន្ត ពុំដែលមានទោសព្រោះតែ
ភូតភរកុហកកែ នាំឱ្យគេខូចប្រយោជន៍ ។
• ទីប្រាំបានសុខសាន្ត ពុំដែលមានទោសធំតូច
វិនាសទ្រព្យហិនហោច ស្មារតីខូចព្រោះសុរា ។
នេះគឺជាលទ្ធផល រក្សាសីលរាល់វេលា
បានសុខគ្រប់ៗគ្នា ទោះនៅនាលោកនេះក្តី ។
លុះដល់ខ្លួនស្លាប់ហើយ បានទៅសោយសុខជាថ្មី
ក្នុងភពលោកដទៃ ព្រោះបច្ច័យសីលនេះណា ។
នឹងបានសម្រេចគុណ អានិសង្សមានប្រាំប្រការ
ខាងមុខប្រាកដជា ដូចប្រាថ្នាពុំខានឡើយ ។

# ជីវប្រវត្តិ សង្ខេប

## សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម** សង្ឃត្ថេរោ



សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម** ប្រសូតនៅថ្ងៃ សុក្រ ១២ កើត ខែមាឃ ឆ្នាំមមែ ព.ស. ២៤៦២ ត្រូវនឹងថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ១៩១៨ នៅភូមិជំនាប់ ឃុំជីរោ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ បិតានាម **មាស អ៊ុម** មាតានាម **សុខ ម៊ីះ** ជាកសិករ ប្រកបរបរធ្វើចំការ ។ សម្តេចមានបងប្អូនបង្កើត ១២ នាក់ ប្រុស ៧ នាក់ ស្រី ៥ នាក់, សម្តេចជាកូនទី ១២ ។

### អំពីកុមារភាព

កាលនៅពីកុមារ ដោយលក្ខណសម្បត្តិធម្មជាតិ គួបផ្សំនឹងការអប់រំពីឪពុកម្តាយ ចាស់ទុំ ជាបន្តបន្ទាប់, កុមារ **អ៊ុម ស៊ុម** បានក្លាយជាក្មេងមានកិរិយាមារយាទមិនដូចកុមារទាំងពួងនៅស្រុកស្រែចំការឡើយ គឺជាក្មេងមានអាកប្ប-កិរិយាសុភាពរាបសា ទន់ភ្លន់ រម្យទម ស្លូតបូត ចេះគោរពកោតក្រែងឪពុកម្តាយ ចាស់ព្រឹទ្ធាចារ្យ គួរឱ្យស្រឡាញ់រាប់អាន និងមាននិស្ស័យធ្ងន់ក្នុងព្រះពុទ្ធសាសនា ។

លុះអាយុល្មមដល់ការសិក្សា ឪពុកម្តាយក៏បាននាំយកទៅឱ្យសិក្សាអក្សរសាស្ត្រ លេខនព្វន្ត នៅវត្តនទីរង្សី ហៅវត្តជីរោ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ កុមារ អ៊ុម ស៊ុម បានខិតខំព្យាយាមរៀនសូត្រ រហូតដល់ចេះអាន ចេះសរសេរស្ទាត់ជំនាញ

គួរឱ្យសរសើរ ។ ជាមួយនឹងការរៀនអក្សរ លេខនព្វន្ត, កុមារ **អ៊ុម ស៊ុម** បានរៀនធម៌មនមស្សការព្រះរតនត្រ័យ រៀនច្បាប់បុរាណខ្មែរ មានច្បាប់ក្រម ច្បាប់ កេរកាល ច្បាស់ប្រុស ច្បាប់ស្រី ច្បាប់បណ្តាំឪពុក ច្បាប់បណ្តាំក្រមង៉ុយ ‑ ល ‑ និងរៀនអានសាស្ត្រាទេសន៍ ចេះចាំរត់មាត់ ស្ទាត់ជំនាញ ។

## អំពីជីវភាពផ្នួស

អាយុបាន ១៦ ឆ្នាំ, ឪពុកម្តាយបានអនុញ្ញាតឱ្យកុលបុត្រ **អ៊ុម ស៊ុម** បួសជាសាមណេរ នៅក្នុងវត្តនទីរង្សី ឃុំជីរោ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ក្នុងសំណាក់លោកគ្រូនាម **ខែក មាស** ជាព្រះឧបជ្ឈាយ៍ ។ លុះអាយុ ២១ ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុ ក្នុងពទ្ធសីមាវត្តនទីរង្សី ក្នុងសំណាក់ព្រះនាគមុនី ជាព្រះឧបជ្ឈាយ៍ ។ ព្រះឧបជ្ឈាយ៍បានដាក់នាមបញ្ញត្តិថា « **សច្ចត្ថេរោ** » ។

ក្រោយបានបំពេញឧបសម្បទាហើយ ភិក្ខុ **អ៊ុម ស៊ុម** បានយកអស់ពិកម្លាំងកាយចិត្តខិតខំរៀនទន្ទេញភិក្ខុបាតិមោក្ខបាលី ចេះចាំស្ទូត្រមាត់ទទេបាន និងប្រតិបត្តិធម៌វិន័យយ៉ាងខ្ជាប់ខ្ជួន ។ បន្ទាប់មក ភិក្ខុ **អ៊ុម ស៊ុម** បានបន្តការសិក្សាព្រះបរិយត្តិធម៌ នៅវត្តកោះគល់ ស្រុកកំពង់សៀម ខេត្តកំពង់ចាម រួចបន្តការសិក្សានេះ នៅវត្តសារាវ័នតេជោ ទីក្រុងភ្នំពេញ ដរាបដល់បានប្រឡងជាប់សាលាបាលីរង និងបានប្រឡងចូលជាប់ រៀននៅសាលាបាលីជាន់ខ្ពស់ ជាបន្តទៀត ។

## អំពីចំណេះវិជ្ជា, កិច្ចការបំរើព្រះពុទ្ធសាសនា និងប្រទេសជាតិ

ឆ្នាំ ១៩៥០ ភិក្ខុ **អ៊ុម ស៊ុម** ក៏បានប្រឡងជាប់សញ្ញាប័ត្រសាលា

បាលិជាន់ខ្ពស់ បច្ចុប្បន្ន « ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត » ។ ក្រៅពីភាសាខ្មែរ និងភាសាបាលិ ភិក្ខុ **អ៊ុម ស៊ុម** បានសិក្សាភាសាបារាំង និងភាសាអង់គ្លេស ដែលអាចប្រើការបានជាបន្ទាប់បន្សំ ។

អាស្រ័យដោយសមត្ថភាព ចំណេះវិជ្ជា ទាំងផ្លូវលោក ទាំងផ្លូវធម៌នេះ ទើបភិក្ខុ **អ៊ុម ស៊ុម** ត្រូវបានទទួលនាទីជាអាចារ្យបង្រៀនភាសាបាលីច្រើនឆ្នាំ នៅវត្តសារាវ័នតេជោ, វត្តសំពៅមាស ក្រុងភ្នំពេញ និងវត្តនទីរង្សី ខេត្តកំពង់ចាម ។

ចាប់តាំងពីបានទទួលភារៈជាអាចារ្យបង្រៀនមក លោកគ្រូអាចារ្យ **អ៊ុម ស៊ុម** បានបំពេញតួនាទីរបស់ខ្លួន ដោយសេចក្តីព្យាយាមយ៉ាងជ្រាលជ្រៅ ទាំងការស្រាវជ្រាវចំណេះដឹងទូទៅ ទាំងកិច្ចបង្រៀនសិស្សានុសិស្ស ដែលធ្វើឱ្យសិស្សានុសិស្សជាច្រើនបានទទួលការចេះដឹង និងអាចបន្តការសិក្សា នៅកម្រិតថ្នាក់មធ្យមថ្នាក់ឧត្តម ជាបន្តបន្ទាប់ ។

ជាមួយនឹងការសិក្សាស្រាវជ្រាវវិជ្ជាព្រះពុទ្ធសាសនា និងកិច្ចការបង្រៀន, លោកគ្រូអាចារ្យ **អ៊ុម ស៊ុម** នៅបានជួយបណ្តុះបណ្តាល ឧបត្ថម្ភ ទំនុកបំរុងដល់វត្តជាច្រើន ឱ្យបានបើកសាលាបាលីរង, សាលាធម្មវិន័យ ដើម្បីបានអនុគ្រោះដល់ភិក្ខុ-សាមណេរ បានសិក្សារៀនសូត្រ ដូចជា វត្តជីរោ ខេត្តកំពង់ចាម, វត្តកែវព្រះភ្លើង, វត្តសារាវ័នតេជោ ក្រុងភ្នំពេញ ជាដើម ព្រមទាំងជួយជ្រើសរើសរកលោកគ្រូអាចារ្យទៅបង្រៀននៅវត្តនោះៗ ទៀតផង ។

ក្រៅពីការយកព្រះទ័យទុកដាក់ក្នុងការពង្រីកការសិក្សា និងការគោរពប្រតិបត្តិធម៌-វិន័យព្រះពុទ្ធសាសនា, លោកគ្រូអាចារ្យ **អ៊ុម ស៊ុម** តែងបានចាប់អារម្មណ៍ខ្ពស់ក្នុងការណែនាំព្រះសង្ឃ ពុទ្ធបរិស័ទ ឱ្យយល់ និងចេះថែរក្សានូវតម្លៃពិតនៃព្រះពុទ្ធសាសនា និងការកសាងវត្តអារាម ទីសេនាសនៈ ពោធិ៍ព្រះវិហារ កុដិ

សាលា ជាដើម សម្រាប់បំរើវិស័យព្រះពុទ្ធសាសនា ដូចជា វត្តនន្ទិរង្សី ហៅវត្តជីរោ, វត្តសំរោងប្ញូរី ក្នុងខេត្តកំពង់ចាម, វត្តឧត្តរាវតី, វត្តសារាវ័នតេជោ, វត្តមហាមន្ត្រី, វត្តឃ្លាញ នៅក្រុងភ្នំពេញ ជាដើម ។

ទន្ទឹមនឹងការកសាងសំណង់ជាប្រយោជន៍ពុទ្ធសាសនា លោកគ្រូអាចារ្យ **អ៊ុំម ស៊ុម** ក៏បានយកព្រះទ័យទុកដាក់ចំពោះប្រទេសជាតិ ដូចជា ការកសាងសាលារៀន មន្ទីរពេទ្យ ២ ខ្នង ផ្លូវថ្នល់ អណ្តូងទឹក ស្រះទឹក ជាដើម ជាច្រើនកន្លែង និងវិស័យសង្គមកិច្ច ជួយសង្គ្រោះអ្នកក្រខ្សត់ ជនពិការ អ្នកជំងឺ របួស សម្រាកមន្ទីរពេទ្យ ព្រមទាំងបានទេសនាអប់រំពីសីលធម៌សង្គម និងពីជីវភាពរស់នៅថ្លៃថ្នូរ ចំពោះព្រះសង្ឃ គ្រហស្ថ ជាបន្តបន្ទាប់ នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីបានជាឯកសារសិក្សាស្រាវជ្រាវទៅអនាគត, លោកគ្រូអាចារ្យ **អ៊ុំម ស៊ុម** បានឆ្លៀតពេលវេលាដ៏មមាញឹក ខិតខំស្រាវជ្រាវនិពន្ធអត្ថបទចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា របស់ ពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ និងសាសនា និងនិពន្ធអត្ថបទធម៌ជាច្រើនបោះពុម្ពជាសៀវភៅ មាន :

- សៀវភៅ បបញ្ចធម៌
- សៀវភៅ ត្រៃលោកគោកត្រៃលក្ខណ៍
- សៀវភៅ រកព្រះធម៌
- សៀវភៅ បំភ្លឺបុណ្យ
- សៀវភៅ ដុំរិញបញ្ហាបួស
- សៀវភៅ ព្រះសទ្ធម្ម ៣
- សៀវភៅ ទស្សនៈព្រះពុទ្ធសាសនា,
- សៀវភៅ កុរុធម៌, និងអត្ថបទសិក្សាស្រាវជ្រាវពុទ្ធសាសនា ជាពាក្យរាយ និងពាក្យកាព្យ ជាច្រើនទៀត ដូចជា បញ្ហាឧបាសក, គុណសីល, អានិសង្សសីល, ...

# អំពីតួនាទី និង សមណសក្តិ

ដោយព្រះទ័យធ្ងន់ក្នុងព្រះពុទ្ធសាសនា និងដោយសមត្ថភាព ចំណេះវិជ្ជា ព្រមទាំងបុគ្គលិកលក្ខណសម្បត្តិដ៏ល្អប្រពៃ, លោកគ្រូអាចារ្យ **អ៊ុម ស៊ុម** ក៏ត្រូវបានទទួលតួនាទី និងសមណសក្តិ ជាបន្តបន្ទាប់ នៅក្នុងជីវភាពផ្នួស ។

## អំពីតួនាទី

• ឆ្នាំ ១៩៥៧ បានទទួលតួនាទីជាចៅអធិការស្តីទី ទទួលខុសត្រូវក្នុងការគ្រប់គ្រងភិក្ខុ-សាមណេរ នៅវត្តកែវព្រះភ្លើង រាជធានីភ្នំពេញ និងធ្វើជាអាចារ្យបង្រៀននៅវត្តនោះផង ។

• ឆ្នាំ ១៩៦០ បានទទួលតួនាទីជាគ្រូសូត្រស្តាំ នៅវត្តសារាវ័នតេជោ រាជធានីភ្នំពេញ ។

• ឆ្នាំ ១៩៥៦ បានទទួលតួនាទីជាសមាជិកក្រុមជំនុំប្រែព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ។

• ឆ្នាំ ១៩៦៩ បានទទួលតួនាទីជាសមាជិកថេរសភា, ជាលេខាធិការបោះពុម្ពវចនានុក្រមខ្មែរ លើកទី ៥ អមសម្តេចព្រះសង្ឃរាជ **ជួន ណាត** និងជាសមាជិកសកម្ម របស់ ពុទ្ធិកសមាគមកម្ពុជរដ្ឋ ផ្នែកការងារធម្មទូត ។

## អំពីសមណសក្តិ

ចាប់ពីឆ្នាំ ១៩៥៧ រៀងមក លោកគ្រូអាចារ្យ **អ៊ុម ស៊ុម** បានទទួលសមណសក្តិទីឋានានុក្រម និងទីរាជាគណៈ ដូចតទៅ :

- ជាព្រះបាឡាត់ភទ្ទបាល ( ទីឋានានុក្រម ) ។
- ជាព្រះវិន័យធរ ( ទីឋានានុក្រម ) ។
- ជាព្រះបិដកធម្ម ( ទីរាជាគណៈ ថ្នាក់ចត្វា ) ។

- ជាព្រះញាណវង្ស ( ទីរាជាគណៈ ថ្នាក់ត្រី ) ។
- ជាព្រះសាសនមុនិ ( ទីរាជាគណៈ ថ្នាក់ទោ ) ។

## អំពីការបាត់បង់ភាពផ្នួស នាឆ្នាំ ១៩៧៥-៧៨

ឆ្នាំ ១៩៧៥ សភាពការណ៍ប្រទេសជាតិ បានជួបប្រទះនូវគ្រោះមហន្តរាយនៃរបបប្រល័យពូជសាសន៍ ដែលបង្កឡើងដោយខ្មែរក្រហម ប៉ុល ពត ។ ព្រះសង្ឃគ្រហស្ថ នៅរាជធានីភ្នំពេញ ក៏ដូចជានៅតាមទីប្រជុំជនខេត្ត ក្រុងនានា ក្នុងទូទាំងប្រទេស ត្រូវជម្លៀសឱ្យទៅនៅតាមជនបទព្រៃភ្នំ ក្រំថ្ម និងបង្ខំឱ្យធ្វើការជាទម្ងន់ ។ ព្រះសង្ឃរាប់ម៉ឺនអង្គត្រូវផ្សឹក និងសម្លាប់ ។ វត្តអារាម ព្រះវិហារ កុដិ សាលា ត្រូវបានប្រើប្រាស់ក្នុងទិសដៅផ្សេងៗ និងត្រូវគេកំទេច ។

ព្រះសង្ឃត្ថេរ **អ៊ុម ស៊ុម** ក៏ត្រូវបានជម្លៀសចេញពីវត្តសារាវ័នតេជោ និងបានទៅគង់នៅវត្តនានា ក្នុងខេត្តកំពង់ចាម ។ ការគង់នៅទីនោះ ព្រះសង្ឃត្ថេរ **អ៊ុម ស៊ុម** ត្រូវបានទទួលការគាបសង្កត់ខាងផ្លូវចិត្ត និងខាងផ្លូវប្រតិបត្តិយ៉ាងធ្ងន់ធ្ងរពីពួកអង្គការខ្មែរក្រហម ។ ក្រោយមក ពួកវាក៏បានបង្ខំឱ្យព្រះសង្ឃត្ថេរ **អ៊ុម ស៊ុម** លាចាកសិក្ខាបទ ដើម្បីធ្វើពលកម្ម ។ ដោយទ្រាំទ្រនឹងការគំរាមគំហែងជារៀងរាល់ថ្ងៃ របស់ពួកខ្មែរក្រហមមិនបាន ព្រះសង្ឃត្ថេរ **អ៊ុម ស៊ុម** ក៏សំរេចព្រះទ័យលាចាកសិក្ខាបទទៅជាគ្រហស្ថ ហើយស្នាក់នៅក្នុងវត្តសំរោងបុរី ។

ពេលនោះ ព្រះអាចារ្យ **អ៊ុម ស៊ុម** ពិតមែនបានក្លាយខ្លួនទៅជាគ្រហស្ថ ប៉ុន្តែ លោកអាចារ្យពុំបានលះបង់ចិត្តគំនិតជាអ្នកបួសឡើយ ។ លោកតែងឆ្លៀតឱកាសថ្វាយបង្គំព្រះរតនត្រ័យដោយលួចលាក់ ទាំងអារម្មណ៍បានស្ងប់ស្ងៀម មិនបានទទួលទានអាហារពេលល្ងាច មិនលេកគ្រឿងស្រវឹង ទោះបីគេបង្ខំយ៉ាងណាក៏ដោយ

ហើយខិតខំបំពេញការងារតាមការកំណត់ និងការបង្គាប់បញ្ជារបស់អង្គការ ។

## អំពីជីវភាពផ្នួសលើកទី ២

ថ្ងៃ ៧ មករា ១៩៧៩ ប្រជាពលរដ្ឋខ្មែរ ត្រូវបានរំដោះសង្គ្រោះឱ្យរស់រានមានជីវិត រួចចាកផុតពីគ្រោះប្រល័យពូជសាសន៍ ដោយអង្គការរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ អ្វី១ដែលជាប្រពៃណី ទំនៀមទម្លាប់ និងចរិតរបស់ជាតិ ក៏ត្រូវបានអង្គការរណសិរ្សយកចិត្តទុកដាក់ និងរៀបចំឡើងវិញ ។ ព្រះពុទ្ធសាសនា ដែលជាសាសនាផ្សារភ្ជាប់នឹងជីវិតសង្គម និងប្រជាពលរដ្ឋខ្មែរ ក៏ត្រូវបានគោរពបូជាឡើងវិញ យ៉ាងផុលផុស ។

ដើម្បីរៀបចំព្រះពុទ្ធសាសនា ឱ្យមានដំណើរការប្រព្រឹត្តទៅរៀបរយ និងបានសមស្របតាមគន្លងធម៌-វិន័យព្រះពុទ្ធសាសនា, រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានស្រាវជ្រាវរកអតីតបព្វជិតដែលជាពហុស្សូត្រ មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនា យកមកឱ្យបំបួសឡើងវិញ ។ លោកអាចារ្យ **អ៊ុម ស៊ុម** ក៏ត្រូវបានរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា អញ្ជើញពីវត្តសំរោងបុរី ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម មកបំពេញឧបសម្បទា នៅវត្តឧណ្ណាលោម នៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ១៩៨០ ដោយបានទទួលនាមបញ្ញត្តិជា **សុខៀវភ្លៀវ** ដូចនាមបញ្ញត្តិ កាលបួសពីលើកមុន ។

ក្រោយបានបំពេញឧបសម្បទាជាថ្មីហើយ ភិក្ខុសង្ឃត្ថេរ **អ៊ុម ស៊ុម** បានគង់នៅវត្តឧណ្ណាលោម និងបានយកព្រះទ័យទុកដាក់បំរើកិច្ចការព្រះពុទ្ធសាសនា និងការងារប្រទេសជាតិ ដោយឥតគិតពីការនឿយហត់ ។ ជាពិសេស ការតម្រង់ទិសប្រតិបត្តិធម៌-វិន័យពុទ្ធសាសនារបស់ភិក្ខុ-សាមណេរ ត្រូវបានរដ្ឋចាត់តាំងឱ្យរៀបចំ

និងដឹកនាំព្រះពុទ្ធសាសនា ជាមួយព្រះវិន័យធរ **ឆោ ខង៉ា** ព្រោះថា នៅពេលរំដោះភ្លាម មានបព្វជិតជាច្រើន ដែលបានបួសដោយចេតនាកម្ម ក៏ត្រូវបានសម្រួលឱ្យបួសឡើងវិញតាមបញ្ញត្តិកម្ម គឺឱ្យស្របតាមពុទ្ធានុញ្ញាត និងពុទ្ធប្បញ្ញត្តិ ។

ភិក្ខុ **អ៊ុំ ស៊ុម** រួមសហការជាមួយព្រះមហាថេរជាច្រើនអង្គទៀត បានខិតខំព្យាយាមយ៉ាងមុតមាំ ដើម្បីរៀបចំ ដឹកនាំ និងគ្រប់គ្រងវិស័យព្រះពុទ្ធសាសនាឱ្យមានដំណើរការល្អជាប្រក្រតីឡើងវិញ ។ ក្រៅពីនេះ ព្រះសង្ឃត្ថេរ **អ៊ុំ ស៊ុម** បានរួមចំណែកយ៉ាងសកម្មក្នុងការជួយដល់ចលនាបង្រួបបង្រួមជាតិ គឺការអនុវត្តគោលនយោបាយសាមគ្គីរួបរួមគ្នា ក្នុងក្របខ័ណ្ឌនៃការបញ្ចប់សង្គ្រាមរ៉ាំរ៉ៃ និងស្វែងរកសន្តិភាព សម្រាប់ប្រទេសជាតិ និងប្រជាពលរដ្ឋខ្មែរ ។

• ឆ្នាំ ១៩៨១ ព្រះសង្ឃត្ថេរ **អ៊ុំ ស៊ុម** បានទទួលនាទីជាអនុប្រធានរណសិរ្ស រដ្ឋធានីភ្នំពេញ និងជាសមាជិកនៃក្រុមប្រឹក្សាជាតិរណសិរ្សសាគម្គីកសាងការពារមាតុភូមិកម្ពុជា ។ បន្ទាប់មក, ព្រះអង្គបានទទួលនាទីជាប្រធានសង្ឃ រដ្ឋធានីភ្នំពេញ ទទួលបន្ទុកដឹកនាំគ្រប់គ្រងព្រះសង្ឃទាំងអស់នៅក្នុងក្រុង និងបានទទួលឋានៈជាសមាជិកគណៈអធិបតីកិត្តិយស នៃក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា និងជាសមាជិកសង្ឃនាយករងទី ២ នៃគណៈមហានិកាយ ។

• ឆ្នាំ ១៩៨៨ ចុងខែមិថុនា តាមសំណូមពរ និងសេចក្តីជ្រះថ្លារបស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី, ភិក្ខុសង្ឃត្ថេរ **អ៊ុំ ស៊ុម** បានស្រាវជ្រាវរកឃើញព្រះសារីរិកធាតុ ព្រមទាំងសម្ភារះរបស់ព្រះសក្យមុនីចេតិយខ្លះទៀត យកទៅធ្វើបុណ្យពុទ្ធាភិសេក និងដង្ហែទៅតម្កល់ទុកនៅព្រះសក្យមុនីចេតិយវិញ យ៉ាងមហោឡារិក នៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ ១៩៨៩ ។

• ថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែទុតិយាសាឍ ឆ្នាំមមែ ត្រីស័ក ព.ស.

២៥៣៥ ត្រូវនឹងថ្ងៃទី ២៥ ខែមិថុនា ១៩៩១ ភិក្ខុសង្ឃត្ថេរ **អ៊ុំ ស៊ុម** ត្រូវបានតែងតាំងជាចៅអធិការវត្តបញ្ញាមន្ត្រី រាជធានីភ្នំពេញ និងជាអនុគណ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ នាឆ្នាំ ១៩៩១ ដែរ ។

ចាប់តាំងពីមកគង់នៅវត្តមហាមន្ត្រីភាម, ព្រះអង្គបានរៀបចំវត្ត ទាំងសណ្ដាប់ធ្នាប់ភិក្ខុ-សាមណេរ ទាំងសមិទ្ធិផ្សេងៗ កសាងផ្លូវថ្នល់ក្នុងបរិវេណវត្ត, ដាក់បណ្ដាញលូបង្ហូរទឹកស្អុយពេញក្នុងវត្ត, កសាងសាលាបាលី ១ ខ្នង មន្ទីរពេទ្យ ២ ខ្នងបណ្ណាល័យ ១ ខ្នង, ជួសជុលសាលាបុណ្យ, ជួសជុលសាលាបាលីចាស់ធ្វើជាកុដិសំរាប់ព្រះសង្ឃគង់នៅ ក្នុងវត្តមហាមន្ត្រី ។

• ថ្ងៃ សុក្រ ២ កើត ខែកត្តិក ឆ្នាំមមែ ត្រីស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ១៩៩១ ភិក្ខុសង្ឃត្ថេរ **អ៊ុំ ស៊ុម** ត្រូវបានតែងតាំងជាព្រះមង្គលទេពាចារ្យ, សមណសក្តិទីរាជាគណៈ ថ្នាក់ទី ១ ( ថ្នាក់ឯក ) ។

• ថ្ងៃ ពុធ ៧ រោច ខែផល្គុន ត្រូវនឹងថ្ងៃទី ២៥ ខែមីនា ឆ្នាំ ១៩៩២ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតែងតាំងព្រះមង្គលទេពាចារ្យទីជា **សម្ដេចព្រះមង្គលទេពាចារ្យ** ។

• ឆ្នាំ ១៩៩៣ សម្ដេចព្រះមង្គលទេពាចារ្យ **អ៊ុំ ស៊ុម** ត្រូវបានតែងតាំងជាអគ្គាធិការនៃព្រះពុទ្ធិកសិក្សា ទទួលបន្ទុកការងាររៀបចំ និងពង្រីកវិស័យពុទ្ធិកសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ទំនាក់ទំនងការងារក្រៅប្រទេស

ទន្ទឹមនឹងការងារព្រះពុទ្ធសាសនា និងការងារប្រទេសជាតិ ដែលសម្ដេច

បានរួមចំណែកយ៉ាងខ្លាំងក្លានៅក្នុងប្រទេស, សម្ដេចនៅបានបំពេញការ ងារជាប្រ-យោជន៍ពុទ្ធសាសនា និងប្រទេសជាតិ នៅក្រៅប្រទេសជាច្រើនថែមទៀត គឺ :

• ថ្ងៃ ២៣ ឧសភា ១៩៨០ សម្ដេចបាននិមន្តទៅធ្វើទស្សនកិច្ចការងារនៅសហរដ្ឋអាមេរិក លើកទី ១ រយៈពេល ១ ខែកន្លះ បានចំនួន ៨ រដ្ឋ ។

• ថ្ងៃ ៩ កក្កដា ១៩៨២ សម្ដេចបាននិមន្តទៅបំពេញទស្សនកិច្ចការងារលើកទី ១ នៅសាធារណរដ្ឋបារាំង ។ ថ្ងៃ ៩ សីហា ១៩៨២ បានបន្តដំណើរពីប្រទេសបារាំង ទៅសហរដ្ឋអាមេរិកម្ដងទៀត នៅទីក្រុងវ៉ាស៊ិនតោន ដើម្បីពិភាក្សាអំពីដំណើរការងារពុទ្ធិកមធ្យមសិក្សា ជាមួយព្រះភិក្ខុចន្ទវណ្ណោ **អ៊ុខ មាន** ។

• ថ្ងៃ ២១ មករា ១៩៨៣ សម្ដេចបាននិមន្តទៅធ្វើទស្សនកិច្ចនៅប្រទេសចិនប្រជាមានិត លើកទី ១ ។

• ថ្ងៃ ៦ មីនា ១៩៨៣ សម្ដេចបាននិមន្តទៅធ្វើទស្សនកិច្ចប្រទេសចិនលើកទី ២ ។

• ឆ្នាំ ១៩៨៤ សម្ដេចបាននិមន្តទៅប្រទេសចិនលើកទី ៣ ។

• ថ្ងៃ ២៧ ឧសភា ១៩៨៣ សម្ដេចបាននិមន្តទៅក្រុង កណ្ឌមណ្ឌូ ប្រទេសនេប៉ាល ដើម្បីចូលរួមធ្វើសិក្ខាសាលា ។

• ថ្ងៃ ២៧ ឧសភា ១៩៨៤ សម្ដេចបាននិមន្តទៅទីក្រុង ព្យុងយ៉ាង ប្រទេស កូរេខាងជើង ដើម្បីប្រជុំដោះស្រាយបញ្ហាជម្លោះខ្មែរ ។

• ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ សម្ដេចនិមន្តទៅចូលរួមសន្និសីទពុទ្ធ-សាសនា នៅក្រុងកូឡុំបូ ប្រទេសស្រីលង្កា ។

• ក្រៅពីនេះ សម្ដេចបាននិមន្តទៅធ្វើទស្សនកិច្ចនៅសហភាពសូវៀត ៣ ដង, ប្រទេសម៉ុងហ្គោលី ៣ ដង, សាធារណរដ្ឋសង្គមនិយមវៀតណាម ៧ ដង, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ៤ ដង និងប្រទេសផ្សេងៗ ជាច្រើនដង ។

ការងារជាបន្ទុកដ៏ធ្ងន់ធ្ងរ របស់ សម្តេចព្រះមង្គលទេពាចារ្យ គឺការរៀបចំ និងពង្រីកវិស័យពុទ្ធិកសិក្សា ទាំងថ្នាក់បឋម ទាំងថ្នាក់មធ្យម និងទាំងថ្នាក់ឧត្តម ព្រមទាំងការងារពង្រឹង និងតម្រង់ទិសការប្រតិបត្តិធម៌-វិន័យឱ្យបានត្រឹមត្រូវតាមពុទ្ធានុញ្ញាត ពុទ្ធ-ប្បញ្ញត្តិ និងអភិសមាចារ របស់ព្រះសង្ឃ និងពុទ្ធបរិស័ទ ទូទាំងប្រទេស ។

សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម** ត្រូវបានព្រះសង្ឃ និងគ្រហស្ថពុទ្ធបរិស័ទទូទៅ ទាំងជាសិស្សគណ ទាំងមិនមែនជាសិស្សគណ គោរពប្រណិបតន៍ស្រឡាញ់ និងទទួលយកដំបូន្មានគ្រប់ៗគ្នា ។ សម្តេចត្រូវបានបជ្ឈដ្ឋានទូទៅចាត់ទុកថាជាព្រះមហាថេរពហុស្សុតមួយព្រះអង្គ ដែលមានចំណេះ និងបទពិសោធន៍ចាស់ទុំក្នុងផ្លូវសាសនា និងផ្លូវលោក ។

តែគួរឱ្យស្តាយពន់ពេកណាស់ ដែលធម្មជាតិមិនអាចមិនប្រែប្រួល ។ ជីវិតដែលកើតឡើងហើយ ត្រូវតែស្លាប់ទៅវិញ ។ ជីវិតសម្តេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម** ក៏ពុំមានករណីពិសេសដែលធម្មជាតិលើកលែងបានដែរ ។ នៅក្នុងឆ្នាំទី ៨២ នៃព្រះជន្មាយុ ដែលត្រូវនឹងថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០០០ វេលាម៉ោង ១ និង ៣០ នាទី រំលងអធ្រាត្រ សម្តេចបានទទួលអនិច្ចធម្មដោយស្ងប់ស្ងៀម ក្នុងកណ្តាលព្រះសក្ខីភាពរបស់ព្រះអង្គ ក្រោយពីទ្រង់អាពាធតែ ៣៥ ថ្ងៃប៉ុណ្ណោះ ដែលធ្វើឱ្យព្រះសង្ឃ និងពុទ្ធបរិស័ទទាំងឡាយ មានសេចក្តីអាឡោះអាល័យ សោកស្តាយ និងក្រៀមក្រំជាទីបំផុត ។

**ជា គាន**

អ្នករៀបរៀងជីវប្រវត្តិ

បំពេញបន្ថែមអត្ថន័យដោយ **ឱម ខែម**

# ទង់ពុទ្ធសាសនា, ចម្រៀងសូត្រ
# បង្ហូតទង់ និង ដាក់ទង់ពុទ្ធសាសនា

ឱម សុមេធា
ប្រមូលរៀបរៀង និងនិពន្ធ

## I. ប្រវត្តិសង្ខេបអំពីទង់ពុទ្ធសាសនា

ទង់ពុទ្ធសាសនា ដែលកំពុងប្រើប្រាស់នៅក្នុងវត្តអារាមទាំងឡាយនៃប្រទេសកម្ពុជា និងនៅក្នុងប្រទេសនានាកាន់ពុទ្ធសាសនាក្នុងពិភពលោក, មានកំណើតចេញមកពីប្រទេសស្រីលង្កា ។ ដំបូង, គេបានច្នៃបង្កើតទង់សាសនានេះឡើងទុកជានិមិត្តសញ្ញា ឬជានិមិត្តរូបរបស់ពុទ្ធសាសនិកជនស្រីលង្កា ។ ទង់នោះ ត្រូវបានបង្កើតជារូបរាងប្រាកដឡើង នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៨៨៥ ហើយត្រូវបានបង្ហូតឡើង ដើម្បីប្រើប្រាស់ជាសាធារណៈជាលើកដំបូង និងយ៉ាងឧឡារិក នៅវត្តទិបទុត្តរារាម, ស្រុកកោតហេន ( ស្រីលង្កា ) ដោយព្រះថេរៈ មិគេត្តុវត្តេ គុណានន្ទៈ ក្នុងថ្ងៃវិសាខបូជា ត្រូវនឹងថ្ងៃទី ២៨ ខែមេសា ឆ្នាំ ១៨៨៥ ។

ទង់ពុទ្ធសាសនា ត្រូវបានគេទទួលស្គាល់ជាផ្លូវការ ទុកជាទង់របស់ពុទ្ធ-សាសនិកពិភពលោក តាមសេចក្ដីស្នើសុំរបស់សពលោកសាស្ត្រាចារ្យ ម៉ាឡាឡ្សេកេរៈ និងត្រូវបានសម័យប្រជុំបង្កើតពុទ្ធិកសមាគមពិភពលោក នៅទីក្រុងកូឡុមបូ ក្នុងឆ្នាំ ១៩៥០ អនុម័តយល់ព្រមប្រើផង ដោយហៅទង់នោះថា « ទង់ពុទ្ធិកសមាគមពិភពលោក » ហើយចែងនៅក្នុងមាត្រាទី ២៦ នៃលក្ខន្តិកៈពុទ្ធិក-សមាគមពិភពលោកថា « ទង់របស់ពុទ្ធិកសមាគមពិភពលោក ជាទង់មានពណ៌ប្រាំមួយ តម្រូវនឹងឆព្វណ្ណរង្សីរបស់ព្រះសម្ពុទ្ធជាម្ចាស់ទុកជាមូលដ្ឋាន តាមគម្រូដែល

ក្រុមប្រឹក្សាប្រតិបត្តិបានធ្វើហើយ » ។

គួរគប្បីរំលឹកថា នៅក្នុងសម័យប្រជុំបង្កើតអង្គការពុទ្ធិកសមាគមពិភពលោក ក្នុងឆ្នាំ ១៩៥០ នាក្រុងកូឡុម្បូ មានសមាជិកចំនួន ២៩ ប្រទេស រួមទាំងប្រទេសកម្ពុជាផង ដែលកាលនោះ សម្តេចព្រះសង្ឃរាជ **ជ. ណាត** ជាប្រធានទៅរួមប្រជុំ ។

ឥឡូវនេះ ទង់ពុទ្ធសាសនា បានទទួលឋានៈជានិមិត្តរូបសកលរបស់ពុទ្ធសាសនាអន្តរជាតិហើយ ។ ប្រទេសកម្ពុជា បានទទួលយកទង់ពុទ្ធសាសនាមកប្រើចាប់ពីឆ្នាំ ១៩៥០ រៀងមក ។

## II. សណ្ឋាន និង ពណ៌របស់ទង់ពុទ្ធសាសនា

ទង់ព្រះពុទ្ធសាសនា មានសណ្ឋាន ៤ ជ្រុងទ្រវែង តាមខ្នាតទង់អន្តរជាតិ មានប្រាំមួយពណ៌គឺ ខៀវ (នីលៈ), លឿង (បីតៈ), ក្រហម (លោហិតៈ), ស (ឱទាតៈ), ហង្សបាទ (មញ្ជេដ្ឋៈ) និងផ្លេក (ប្រភស្សរៈ) គឺពណ៌ចម្រុះទាំងប្រាំ ដែលតាងពណ៌ផ្លេកដូចពន្លឺពេជ្រ ។ ដើមកំណើតពណ៌ទាំងនោះ ត្រូវបានគេយកតាមពណ៌រស្មីទាំងប្រាំមួយ (ឆព្វណ្ណរង្សី) ដែលគេធ្លាប់បានឃើញនៅក្នុងរង្វង់ចាំងចេញផ្សាយពីព្រះកាយព្រះពុទ្ធ បង្កើតជាមណ្ឌលមូល ទំហំប្រមាណ ១,៨០ម ។

ព្រះសម្ពុទ្ធមានរស្មីប្រាំមួយពណ៌ ផ្សាយចេញពីព្រះកាយព្រះអង្គ ដោយលទ្ធផលនៃបារមីទាន ដែលព្រះអង្គបានសាងពីអតីតជាតិជាមហាស្ចារ្យ ហើយដែលពុំមានអ្នកណាអាចធ្វើដូចព្រះអង្គបាន ។

រីឯពណ៌រស្មីមួយៗ ជាតំណាងព្រះជាតិមួយៗ គឺ :

១. *រស្មីពណ៌ខៀវ* ( នីលៈ ) ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិ ជាព្រះបាទស្រីភិរាស្រ្ត ។ កាលណោះ ព្រះឥន្ទ្រាធិរាជ និម្មិតខ្លួនជាព្រាហ្មណ៍ចាស់

ម្នាក់ចូលមកសូមព្រះនេត្រព្រះអង្គទាំងគូ ព្រះអង្គទ្រង់ឆ្កៀលព្រះនេត្រទាំងពីរ អោយទៅឥន្ទព្រាហ្មណ៍ ។

២. *រស្មីពណ៌លឿង* ( បីតៈ ) ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាវិរិយបណ្ឌិត ។ កាលណោះ ព្រះឥន្ទ្រាធិរាជនិម្មិតខ្លួនជាយក្សធ្វើជាងមាស ។ វិរិយបណ្ឌិតបានអារសាច់ខ្លួនអោយជាងមាស ដើម្បីដំផែធ្វើជាមាសបិទព្រះពុទ្ធរូប ។

៣. *រស្មីពណ៌ក្រហម* ( លោហិតៈ ) ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាបទុមមាណព ។ គ្រានោះ មានពស់មួយប្រកបដោយពិសដ៏ពន្លឹក ចឹកមាតាព្រះអង្គ ។ ព្រះអង្គទ្រង់យកកាំបិតពុះទ្រូង លូកយកបេះដូងមកផ្សំថ្នាំព្យាបាលមាតាអោយគង់ជីវិត ។

៤. *រស្មីពណ៌ស* ( ឱទាតៈ ) ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាព្រះបាទវេស្សន្តរ ។ កាលនោះ ព្រះអង្គទ្រង់ប្រទានដំរីមង្គលមួយ ជាសត្វសំរាប់រាជ្យដ៏មានអវយវៈសសុទ្ធ ដល់ពួកព្រាហ្មណ៍កលិង្គរដ្ឋ ; ពួកអ្នកនគរនាំគ្នាខឹង ហើយបំបរបង់ព្រះអង្គអោយទៅនៅព្រៃភ្នំ ឈ្មោះវង្កតបពិត ។

៥. *រស្មីពណ៌ហង្សបាទ* ( មពោដ្ឋៈ ) ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាវិជ្ជាធរ ។ មាតាព្រះអង្គត្រូវយក្សចាប់យកបាន ព្រះអង្គទ្រង់អារសាច់អោយយក្សបរិភោគជំនួសជីវិតមាតាជាវិជ្ជាធរ ។

៦. *រស្មីពណ៌ផ្លេក* ( ប្រភស្សរៈ ) ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាទន្សាយឈ្មោះ សោមបណ្ឌិត ។ ព្រះអង្គមានព្រះសទ្ធាចង់បំពេញទាន, ព្រះឥន្ទ្រាធិរាជបាននិម្មិតខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់អត់អាហារដើរចូលមក ។ ទន្សាយសោមបណ្ឌិត បានរលាស់ខ្លួន ៧ ដង រួចលោតចូលក្នុងភ្នក់ភ្លើង ដើម្បីចំអិនសាច់ព្រះអង្គអោយដល់ឥន្ទព្រាហ្មណ៍បរិភោគ ។

រស្មីទាំងប្រាំមួយពណ៌នេះ បានផ្សាយចេញពីព្រះវរកាយព្រះអង្គ ក្នុងពេល

ត្រាស់ដឹងសម្មាសម្ពោធិញាណ, ក្នុងពេលសំដែងបាដិហារ្យដើម្បីបំបាក់អស្មិមានះនៃព្រះញាតិរបស់ព្រះអង្គ ដែលសំគាល់ថាព្រះអង្គជាមនុស្សនៅក្មេង មិនគួរគោរព និងក្នុងពេលដែលព្រះអង្គទ្រង់ធ្វើយមកបាដិហារ្យផ្កាញ់ពួកតិរ្ថិយ លើដើមគណ្ឌមព្រឹក្ស ( ដើមស្វាយរបស់នាយគណ្ឌៈ ) ។

## III. បទចម្រៀងសរភញ្ញ សូត្របង្ហូតទង់ និង ដាក់ទង់ពុទ្ធសាសនា

ចម្រៀងទាំងពីរបទ សំរាប់សូត្របង្ហូតទង់ និងដាក់ទង់ព្រះពុទ្ធសាសនា គឺជាព្រះរាជនិពន្ធនៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** ( ជោតញ្ញាណោ ) ព្រះសង្ឃរាជគណៈមហានិកាយ ( កាលនៅជាព្រះសង្ឃនាយក ) ។ សម្តេចបាននិពន្ធបទចម្រៀងនេះ នៅក្នុងឆ្នាំ ១៩៥១ សំរាប់ប្រើនៅក្នុងកម្មវិធីសិក្សាអប់រំសីលធម៌ និងអភិសមាចារសង្គម ចំពោះយុវជនដែលស្នាក់អាស្រ័យនៅក្នុងវត្ត ។

កាលណោះ នៅវត្តឧណ្ណាលោម កម្មវិធីអប់រំនេះបានរៀបចំ និងប្រព្រឹត្តទៅទៀងទាត់ នៅរៀងរាល់ថ្ងៃពុធ និងថ្ងៃសៅរ៍ រៀងរាល់សប្តាហ៍ ក្នុងខែនីមួយៗ ក្រោមព្រះរាជកិច្ចដឹកនាំផ្ទាល់របស់សម្តេច គឺ :

- រៀងរាល់យប់ថ្ងៃពុធ ចំពោះយុវជន រៀននៅថ្នាក់បឋមសិក្សា,
- រៀងរាល់យប់ថ្ងៃសៅរ៍ ចំពោះយុវជន រៀននៅមធ្យមសិក្សា ។

## III. 1 បទចម្រៀង សំរាប់
## សូត្របង្ហូតទង់ពុទ្ធសាសនា

មុនពេលផ្តើមសូត្រនមស្ការព្រះរតនត្រ័យ សមាទានសីល ៥ និងស្តាប់មេរៀនជាពុទ្ធឱវាទបន្តបន្ទាប់ យុវជនទាំងនោះឈរលើកដៃប្រណម្យឡើងបែរមុខ

ត្រង់ឆ្ពោះទៅរកទង់ ។ គេសូត្របទចម្រៀងបង្ហូតទង់ថា :

| | |
|---|---|
| *សូមមើលទង់ជ័យ* | *ឆព្វណ្ណរង្សី* |
| *ដែលមានរស្មី* | *ភ្លឺស្រស់ល្អ* |
| *ខៀវ-លឿង-ក្រហម* | *ព្រមទាំងពណ៌ស* |
| *ហង្សបាទនិងពណ៌* | *ដ៏ភ្លឺផ្លេក ។* |
| *ប្រទេសតូចធំ* | *បានសូត្រស្វាគម* |
| *ជំនុំគ្នា* | *ច្រើនអនេក* |
| *ព្រមយករស្មី* | *ព្រះពុទ្ធគួរព្រេក* |
| *ប្រសើរពន់ពេក* | *ក្រៃកន្លង ។* |
| *ធ្វើជាសញ្ញា* | *ទង់ជ័យសាសនា* |
| *នៃសម្ពុទ្ធ* | *ធំចម្បង* |
| *ចូរយើងរាល់គ្នា* | *យកចិត្តចាំចង* |
| *នឹកដល់ព្រះអង្គ* | *ជាអម្ចាស់ ។* |
| *ទោះជាតិផ្សេងគ្នា* | *ក៏ត្រូវដឹងថា* |
| *សុទ្ធសឹងតែ* | *ជាពុទ្ធសាសន៍* |
| *ត្រូវមានសាមគ្គី* | *ទាំងក្មេងទាំងចាស់* |
| *ប្រឹងប្រែងឱ្យណាស់* | *គ្រប់ៗគ្នា ។* |
| *យើងសាសនាពុទ្ធ* | *ចុំថ្កើងខ្ពស់ផុត* |
| *រុងរឿងវិសុ-* | *ទ្ធិថ្លៃថ្លា* |
| *ហើយមានជ័យជោគ* | *ផ្សាយពេញលោកា* |
| *ដល់ជនជ្រះថ្លា* | *រាប់ច្រើនលាន ។* |
| *មានចិត្តស្នេហា* | *គោរពបូជា* |

| | |
|---|---|
| *ចំពោះព្រះធម៌* | *ដ៏កល្យាណ,* |
| *ទាំងមនុស្សទេវតា* | *ស្នេហាគ្រប់ប្រាណ* |
| *ប្រាថ្នាចង់បាន* | *សេចក្ដីសុខ ។* |
| *យើងខេមរជាតិ* | *នាំគ្នាខ្មីឃ្មាត* |
| *កាន់ធម៌នឹង* | *បានផុតទុក្ខ* |
| *រួបរួមសាមគ្គី* | *ពីនេះទៅមុខ* |
| *ជាតិយើងបានសុខ* | *ក្សេមក្សាន្តត្រាណ ។* |
| *ព្រមព្រៀងប្រព្រឹត្ត* | *កាន់ធម៌សុចរិត* |
| *ឆ្ពោះទៅកាន់* | *ឋាននិព្វាន* |
| *ជាទីផុតទុក្ខ* | *បានសុខក្សេមក្សាន្ត* |
| *ជាតិយើងនឹងបាន* | *សោយសុខា ៕* |

*

## III. 2 បទចម្រៀង សំរាប់ សូត្រដាក់ទង់ពុទ្ធសាសនា

នៅពេលកម្មវិធីសិក្សាអប់រំត្រូវបានបញ្ចប់, យុវជនទាំងអស់គ្នាឈរលើកដៃប្រណម្យឡើងបែរមុខត្រង់ឆ្ពោះទៅរកទង់ម្ដងទៀត ហើយសូត្របទចម្រៀងដាក់ទង់ ដូចតទៅនេះថា :

| | |
|---|---|
| *ក្រុមយើងអ្នកកាន់សាសនា* | *ត្រូវដឹងច្បាស់ថា ព្រះពុទ្ធជិនស្រី* |
| *ទ្រង់មានឆព្វណ្ណរង្សី* | *គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។* |
| *ផ្សាយចេញពីព្រះកាយទ្រង់* | *រុងរឿងឫទ្ធិរុង ប្រសើរបវរ* |
| *ឆ្មៀវឆ្មាត់កាយឆើតឆាយល្អ* | *ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។* |

| | |
|---|---|
| *កំណើតនៃព្រះរស្មី* | *កើតដោយបារមីទាននៃភគវា* |
| *ធ្វើទានឥតមានរុញរា* | *កាលដែលនៅជាព្រះពោធិសត្វ ។* |
| • *រស្មីពណ៌ខៀវនោះណា* | *កាលឆ្កៀលនេត្រាទ្រង់ដោយចិត្តកាត់* |
| *ធ្វើទានដល់ឥន្ទព្រាហ្មណ៍បាត់* | *កាលនាមជាក្សត្រនាមស្រីភីរាស្ត្រ ។* |
| • *រស្មីពណ៌លឿងភ្លឺថ្លា* | *កាលដែលទ្រង់អារសាច់ផៃធ្វើមាស* |
| *បិទពុទ្ធរូបភ្លឺឱភាស* | *ព្រះឥន្ទជាងមាសទ្រង់វិយបណ្ឌិត ។* |
| • *រស្មីក្រហមនោះណា* | *កាលដែលមាតាពោះខាំស្លាប់ពិត* |
| *បទុមស៊ូប្តូរជីវិត* [(*)] | *កាត់បេះដូងបិទធ្វើថ្នាំមាតា ។* |
| • *រស្មីពណ៌សសុទ្ធសាធ* | *កាលដែលព្រះបាទវេស្សន្តរក្សត្រា* |
| *ឱ្យដីរីសសោភា* | *ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ ។* |
| • *រស្មីពណ៌ដូចជើងហង្ស* | *កាលមាតាទ្រង់យក្សឆក់យកបាន* |
| *វិជ្ជាធមិអាចិសាច់ប្រាណ* | *ឱ្យយក្សសាមាន្យស៊ីប្តូរជីវិត ។* |
| • *រស្មីពណ៌ផ្លេកពណ្ណរាយ* | *កើតជាទន្សាយឈ្មោះសោមបណ្ឌិត* |
| *អោយទានសាច់ឈាមជីវិត* | *ដល់ឥន្ទព្រាហ្មណ៍ពិតជាអត់អាហារ ។* |
| *រស្មីខៀវ-លឿង-ក្រហម* | *ស-ហង្សបាទ-ព្រមភ្លឺផ្លេកអស្ចារ្យ* |
| *ត្រូវជាប្រាំមួយប្រការ* | *ទាំងចាស់កុមារចូរចាំទុកអើយ ៕* |

*

## ពុទ្ធឱវាទ :

ការបរិច្ចាគទាននិងការប្រព្រឹត្តធម៌ និងសង្គ្រោះល្អដល់ញាតិអាត្មា

និងការទាំងឡាយមិនមានទោសា ទាំងបួននេះជាមង្គលឧត្តម ។

(*) កញ្ញា អាដេតា ក្ដុញា

# សុចរិត ៨ ប្រការ ជាមង្គលឧត្តមរបស់ស្រី

**ឱម ខែម**

ដកស្រង់រៀបរៀង និងនិពន្ធ

**សុចរិត** តាមអត្ថន័យថា ការប្រព្រឹត្តល្អ, ការប្រព្រឹត្តត្រឹមត្រូវ ។ ព្រះពុទ្ធសាសនាបានប្រាប់ថា សុចរិត ឬសុចរិតធម៌ មាន ៣ យ៉ាងគឺ ការប្រព្រឹត្តល្អដោយកាយ ហៅ *កាយសុចរិត*, ការប្រព្រឹត្តល្អដោយវាចា ហៅ *វចីសុចរិត*, ការប្រព្រឹត្តល្អដោយចិត្តសុទ្ធ ហៅ *មនោសុចរិត* ។ ដំណើរប្រព្រឹត្តអាក្រក់ដោយកាយ, វាចា, ចិត្ត ហៅ *ទុច្ចរិត* ។ ទុច្ចរិត ជាអំពើដែលពលរដ្ឋគ្រប់រូបត្រូវតែចៀសវាង ។ សុចរិត ជាអំពើដែលពលរដ្ឋម្នាក់ៗត្រូវប្រកាន់យក ។ សុចរិត ជាក្រមសីលធម៌ពុទ្ធសាសនា, ជាប្រភពនៃសុភមង្គល សំរាប់មនុស្សទូទៅ ។

រីឯសុចរិត ៨ ប្រការ ដែលបានលើកឡើងនៅក្នុងអត្ថបទនេះ គឺផ្អែកលើការឆ្លុះបញ្ចាំងចេញពីក្រឹត្យក្រម ទាក់ទងទៅនឹងចរិយាមារយាទនៃស្ត្រី ពិសេសស្ត្រីជាមេផ្ទះ (ភរិយា) ។ ស្ត្រីមេផ្ទះដែលចេះចាត់ចែងកិច្ចការក្នុងផ្ទះ ចេះរៀបចំផ្ទះសម្បែងអោយមានសណ្តាប់ធ្នាប់ មានរបៀបល្អ ស្អាតបាត មានអនាម័យ ជាផ្ទះធំទ្រនំខ្ពស់ និងរក្សាបាននូវសុខដុមភាពក្នុងជីវិតរស់នៅរបស់គ្រួសារ គឺស្ត្រីនោះមានសុចរិត មានចរិយាមារយាទជាប្រមុខ, ជាប្រធាន ។ ព្រឹទ្ធាចារ្យ លោកបានប្រៀបនាទីស្ត្រីមេផ្ទះទៅនឹងសំណាបយោងដី ស្រីយោងប្រុស ។ *សំណាបយោងដី ស្រីយោងប្រុស* មានអត្ថន័យថា សំណាបល្អតែងតែយោងដីស្រែអោយមានសន្ទូងល្អូតលាស់ល្អ, បើសំណាបអន់ ទោះបីស្រែមានជី សន្ទូងក៏តែងតែអន់ ; ប្រុសដែលមាន

ប្រពន្ធត្រឹមត្រូវ ទោះបីក្រីក្រ ក៏ទីលក្រល្អមើល, បើប្រពន្ធអន់ ទោះបីប្ដីប៉ុនរកទ្រព្យធនយ៉ាងណា ក៏ពុំអាចឡើងកាន់ឋានៈជាអ្នកគ្រាន់បើបានឡើយ ។

ក្នុងសាស្ត្រច្បាប់រាជនេតិ បញ្ជាក់ថា « *ខ្លែងហើរដ្បិតខ្យល់ នាយផ្ដើងដ្បិតពល រក្សាអោយសុខ ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុកដ្បិតភរិយាជា* » ។ ក្នុងសេចក្ដីពន្យល់ពីការប្រើពាក្យស្រីនិងប្រុស ឬស្ត្រីនិងបុរស, សម្ដេចព្រះសង្ឃរាជ ជួន ណាត លោកបានសរសេរជាពាក្យកាព្យថា « *ស្រីប្រុសទាំងទ្វី ជាគូមានពី- បូរាណព្រេងនាយ ស្រីជាប្រពន្ធ ប្រុសទោះសម្ពាយ*(*) *បណ្ឌិតទាំងឡាយ អោយឈ្មោះថាប្ដី ។ ស្ត្រីនិងបុរស ក្នុងលោកទាំងអស់ ភរិយាស្វាមី គឺប្ដីប្រពន្ធ ហ្នឹងឯងលោកស្ដី ជនក្នុងលោកិយ៍ ហៅបានតាមថ្នាក់ ។ ប្ដីជាអ្នករក ទ្រព្យធនបានមក ប្រពន្ធទុកដាក់ ចាស់ទុំបូរាណ បានពោលបញ្ជាក់ អោយនាងអោយអ្នក ចងចាំគ្រប់ប្រាណ ។ សំណាបយោងដី រីឯស្រីៗ យោងប្រុសសាមាន្យ*(**) *ទោះមារយាទខ្សោយ- ក៏ដោយបើបាន ស្រីមានសន្ដាន ខ្ជាប់ខ្ជួនមូនមាំ ។ តែងបានចំរើន ទ្រព្យកើតកើន ព្រោះស្រីថៃទាំ ចាត់ចែងទុកដាក់ ចេះលាក់សន្សំ សង្វាតខិតខំ រក្សាអោយគង់ - ល -* » ។

ដោយពាក់ព័ន្ធទៅនឹងនាទីនៃស្ត្រីជាភរិយាខាងលើនេះ ខ្ញុំសូមលើយកកាព្យច្បាប់ស្រី ជាព្រះរាជនិពន្ធនៃព្រះបាទសម្ដេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ ( ព្រះអង្គឌួង ) ថ្លែងអំពីសុចរិត ៨ ប្រការ ជាមង្គលរបស់ស្រី មកជូនអ្នកអានក្នុងទស្សនាវដ្ដីនេះ ។ ( បើពេញចិត្ត, គួរទន្ទេញអោយចាំរត់មាត់, ជាការប្រពៃពេក ) ។ ព្រះរាជនិពន្ធនោះ មិនវែងណាស់ណាទេ, ដូចតទៅនេះគឺ :

*នេះនឹងសំដែង*

*បរិយាយចារចែង ដើមបទអដ្ឋា- ហិ ឋានេហិ*

---

(*) សម្ពាយ ( សំ.ម្ពាយ ) = ប្រុសកោនចំណោះតិចអោក ។ (**) សាមាន្យ = សាមញ្ញ, ធម្មតា

សុចរិតា ឥត្ថីលក្ខណា មង្គលច្នេះពិត ។
ប្រែថាស្រីជា
កើតកបលក្ខណា ដោយនូវសុចរិត មង្គលប្រាំបី
អោយស្រីពិនិត្យ ចាំយកជាក្រឹត្យ គ្រប់រូបស្រីៗ ។
ដើមបទពណ៌នា
លោកថាស្រីជា [1] សុចរិតភក្តី ឫករាបស្រគត់
ផ្គង់ផ្គត់សំដី ការកេរ្តិ៍ខ្មាសស្រី បរិសុទ្ធមែនមួន ។
លោកថាស្រីត្រង់ [2]
កាន់សុចរិតផ្គង់ ចំនិតចេះស្ងួន អស់ទ្រព្យសម្បត្តិ
ប្រយ័ត្នថែថួន ទុកដាក់ខ្ជាប់ខ្ជួន មិនមានប្រមាទ ។
លោកថាស្រីតាប់ [3]
កាន់សុចរិតខ្ជាប់ ឧស្សាហ៍សង្វាត ធ្វើការសន្សំ
តឿនខ្ញុំអោយឃ្នាត អោយខ្មីសង្វាត មិនមានស្ញៀមដៃ ។
លោកថាស្រីប្រាជ្ញ [4]
សុចរិតអង់អាច ចេះអធ្យាស្រ័យ ញាតិព្រៀងទៅមក
រាប់រកក្លួសដៃ ទោះជនដទៃ ក៏រាប់តាមពិត ។
លោកថាស្រីស្អាត [5]
សុចរិតគ្មានឃ្លាត មែនមានចំនិត ចេះរៀបអាហារ
ភ្ញាក់ងារស្រីពិត រណ្ដាប់ផ្គាប់ចិត្ត ប្តីគ្រប់វេលា ។
លោកថាស្រីស្មោះ [6]
កាន់សុចរិតឆ្ពោះ តាំងចិត្តស្នេហា តែនឹងអង្គប្តី
ឥតបីវេរា ស្ម័គ្រស្មោះស្មើជា និត្យនៅរៀបរៀង ។

លោកថាស្រីស្លូត [7]

សុចរិតរបួត អបអត់ឥតល្បើង តាមពាក្យប្ដីផ្ដាំ
ចងចាំទុកទៀង ពោលពាក្យមិនឃ្លៀង មិនឃ្លាតសត្យា ។

លោកថាស្រីស្មើ [8]

សុចរិតសារពើ អាចរងផានា ទម្ងន់ចិត្តប្ដី
ទោះបីទុក្ខា ខ្សត់ក្រមេ្តចម្ដា អាចទទួលប្រាណ ។

សុចរិតប្រាំបី

ជាមង្គលស្រី ប្រសើរក្រមាន អ្វីមកផ្ទឹមផ្ទាល់
អោយដល់នេះបាន ស្រីណាអាចឡាន ចិត្តចាំរៀនយក៏ ។

ទាំងប្រាំបីច្បាប់

ហៅស្រីមហាគាប់ លោកីយ៍កម្រ ស្រីកាន់សុចរិត
ប្រព្រឹត្តល្អិតល្អ ស្រីណាថាក្រ ធ្វើតាមពុំបាន ។

លោកថាស្រីនោះ

ចិត្តអាក្រក់ស្មោះ ស្អប់ដឹបន្ទាន ផ្សារដោយសារចិត្ត
ទុច្ចរិតសន្ធាន បង្ហិនធនធាន បើកអាសមាយា ។

គ្គីជច្រើនកល់

ក្រដឹងចេះដល់ លែបខាយពុតវា បើចិត្តចង់ស្រោប
ចង់ស្ដាប់មាក់ជា ងាយដាយសោះសា ចេះឯងដឹងឯង ។

ឯត្រង់ច្បាប់ល្អ

តិចទេយល់ក្រ កម្រក្រៃលែង ក្រព្រោះមិនចង់
ប្រុងអង្គអោយស្ដែង ក្រដោយចិត្តល្បែង ចំណង់តណ្ហា ។

អំពើសុចរិត

អត្ថាស្រ័យចិត្ត សំអាតឧស្សាហ៍ ស្មើស្មោះស្លូតត្រង់
ផ្គត់ផ្គង់ក្រឹត្យា ប្រាំបីនេះណា សុចរិតប្រាកដ ។
ឯសុចរិតស្រី
ផ្គត់ផ្គង់ស្វាមី លោកអោយអបអត់ ឱនអៀនចិត្តទន់
ចេះអត់បែបបទ តាមតែចិត្តពត់ ម្ដេចៗតាមបាន ។
មិនមានប្រកែក
មិនមានជជែក ថាធ្វើមិនបាន ទោះអៀនអន់អត់
សង្កត់ចិត្តប្រាណ តាមចិត្តប្ដីធ្យាន ម្ដេចៗមិនថា ។
ច្បាប់នេះគួរស្រី
នៅនាលោកិយ៍ ផ្ចង់ចិត្តឧស្សាហ៍ កាន់ក្ដីសុចរិត
ជាក្រឹត្យថ្លៃថ្លា អោយខ្ជាប់ជាក់ជា ចរិតសព្វថ្ងៃ ។
កាន់បានដូច្នោះ
នឹងផ្ចុកេរ្តិ៍ឈ្មោះ ប្រសើរពេកក្រៃ នឹងបានសាន្ដសុខ
ចៀសទុក្ខចង្រៃ ដល់បរលោកថ្លៃ សោយសុខសួគ៌សិទ្ធ ។
សំដែងសេចក្ដី
ពីមង្គលស្រី ប្រសើរពេកពិត គ្រប់ទាំងប្រាំបី
ក្រឹត្យស្រីសុចរិត ថែងចប់ភាសិត តាមព្រះបាលី ៕

( សូមមើលវចនានុក្រមខ្មែរ ភាគ ២ ទំព័រ ១៤៨០
ត្រង់សេចក្ដីពន្យល់ពីការប្រើពាក្យស្រី និងប្រុស

# សិលាចារឹកថ្មី១សម័យមុនអង្គរ Ka 64 នៅភូមិមេលប់ ក្បែរស្នាយពល និងបញ្ហានៃជាតិពន្ធនាមពីរ គឺ "ខ្មែរ" និង "មលេង"

# A New Pre-Angkorean Inscriptions Ka 64 at Melop village near Snay Pol and Problems of Two Ethnonyms, 'Khmer'and 'Maleng'

**ខង់ សុធារ៉ា**
សាស្ត្រាចារ្យនៅដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២
និង **ឡឹក សាវណ្ណ**
សាស្ត្រាចារ្យនៅដេប៉ាតឺម៉ង់សង្គមវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២

ទីតាំងភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែងមានចំងាយប្រមាណ៦០គីឡូម៉ែត្រពីភ្នំពេញ ប្រសិនបើយើងធ្វើដំនើរទៅកាន់ទីនោះ តាមផ្លូវជាតិលេខ៦អា និងត្រូវឆ្លងទន្លេមេគង្គទៅត្រើយខាងកើត ត្រង់ចំនុចកំពង់ដព្រែកអញ្ចាញ-ស្វាយអាត់ រួចបន្តដំនើរតាមមាត់ទន្លេតាមទិសបញ្ច្រាសទឹកប្រមាណ២គីឡូម៉ែត្រ ទើបបត់ស្តាំត្រង់ផ្លូវបែកជាបី ហើយបន្តដំនើរកាត់តាមខាងជើងរបងវត្តវិហារសួគ៌ វត្តព្រៃបាំង កំពង់ពពិល តម្រង់ទៅស្វាយពលហួសផ្សារ និង សាលាស្រុកពារាំងបន្តិច បត់ឆ្វេងចូលតាម ភូមិឫស្សីជុក ដែល

នៅខាងត្បូងជាប់ភូមិមេលប់នេះឯង ។

ភូមិមេលប់ មានភូមិសាស្ត្រជាវាលទំនាប ដែលអាចលិចទឹកនៅរដូវវស្សា ពេលដែលទឹកជំនន់ទន្លេមេគង្គមានកំពស់ខ្ពស់ ។ នៅតំបន់ក្បែរវត្តនេះ ភាគខាងកើត និង ខាងជើង មានទួលបុរាណជាច្រើន ដែលជាអតីតទួលប្រាសាទធ្វើអំពីឥដ្ឋនៅសម័យមុនអង្គរ ។ ទួលទាំងនោះមានឈ្មោះ ទួលចក្រនារាយណ៍ ទួលប្រាសាទ ទួលចេតិយ៍ ទួលខ្ទប់....ជាដើម* ។ ក្នុងចំណោមទួលទាំងនោះ មានតែទួលប្រាសាទទេ ដែលធំជាងគេ និងបន្សល់ទុកដានប្រាសាទឥដ្ឋព្រមជាមួយកសិណទឹកព័ទ្ធជុំវិញយ៉ាងជ្រៅនៅឡើយ ។

គឺនៅលើទីទួលនេះហើយ ដែលលោកតា ឡាច ទូចអាយុ៧០ឆ្នាំ បានប្រទះសិលាចារឹកមួយផ្ទាំង នៅពេល ដែលគាត់ព្យាយាមជីកកកាយពង្រាបដីនៅលើទួលនោះ ដើម្បីធ្វើថ្នាលដាំផែថាវកាលពីឆ្នាំ១៩៩៨ បន្ទាប់មកគាត់បានយកវាមករក្សាទុកនៅក្នុងបរិវេណផ្ទះយ៉ាងស្ងៀមស្ងាត់ ។

---

* ក្រោយពីបានអាន កិច្ចការស្រាវជ្រាវសារណារបស់លោក ពិ ប៊ុន្នីន ស្ដីពី "ដំណែល និងដានខ្លះ១នៃសហគមន៍អ្នកងារ( ស្រុកពារាំងខេត្តព្រៃវែង)"តំបន់ជុំវិញស្វាយពលនាឆ្នាំ១៩៩៧ ញ៉ាំងអោយខ្ញុំមានការជក់ចិត្តចង់ដឹងអំពីបញ្ហាជាច្រើន ដែលកប់បាត់នៅទីនោះ ជាពិសេសភស្តុតាងប្រវត្តិសាស្ត្រ និងបុរាណសាស្ត្រ ។ ដោយសារតែ សំណល់សិលាចារឹកសម័យមុនអង្គរមួយផ្ទាំងនៅស្វាយពល គឺ K 66 និង បុរាណដ្ឋាន ទួលប្រាសាទ ដែលបន្សល់នូវ គំនរឥដ្ឋ ស៊ុមទ្វារ ផ្តែរធ្វើពីថ្មភក់ ព្រមទាំងសិវលិង្គ និងបដិមាបាក់បែក ។

បើចង់ជ្រាបកាន់តែច្បាស់ សូមអាន សៀវភៅខាងលើ ។

យើងបានដំណឹងដោយចៃដន្យ តាមរយៈកូនប្រុសរបស់គាត់ ដែលរស់នៅស្រុកតាខ្មៅ ខេត្តកណ្ដាល ទើបនៅថ្ងៃទី០៩ខែកញ្ញាឆ្នាំ១៩៩៩ យើងដែលមានគ្នា៦នាក់ គឺយើងទាំងពីរ(វង់ សុធារ៉ា និង ឡឹក សាវណ្ណ) កញ្ញា អ៊ួន ភគិនី ជាសាស្ត្រាចារ្យនៅដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២ កញ្ញា រ៉ុង សុគន្ធី សាស្ត្រាចារ្យប្រវត្តិវិទ្យា នៅវិទ្យាល័យតាខ្មៅ លោក ហោ ប៊ុនហុង និង លោក ឡាច ឃីម ដែលជាអ្នកនាំផ្លូវ បានធ្វើដំណើរទៅទីនោះ ដើម្បីសុំលោកតាអនុញ្ញាតផ្ដិតសិលាចារឹកនេះ ។

ភិនភាគផ្ទាំងចារឹក គឺធ្វើអំពីថ្មភក់ រាងជាសន្លឹកសីមា ផ្នែកខាងលើធំទូលាយ ចុះមករាវស្ដួចតូច និង មានពន្លួញសំរាប់ដោតបញ្ឈរដោយដំណាប់ ។ ទំហំទទឹងត្រង់ផ្នែកធំ ៣៣សង្ទីម៉ែត្រ ផ្នែកតូច ២៦សង្ទីម៉ែត្រ កំពស់ចារអក្សរ ៧៣សង្ទីម៉ែត្រ កំពស់ថ្មទាំងស្រុង ៩៥សង្ទីម៉ែត្រ នៅផ្នែកខាងមុខភាគខាងលើអត្ថបទ មានចម្លាក់ក្បាច់ត្របកផ្កាឈូកប្រាំពីរស្រទាប់ ទ្រដោយក្បាច់ភ្ញីលំអជារង្វង់ស្នែងក្របី ក្នុងកំពស់ ៨សង្ទីម៉ែត្រ និងទទឹង ២០សង្ទីម៉ែត្រ ។

គេចារអក្សរលើផ្ទៃទាំងសងខាង ដែលផ្នែកខាងមុខ(ក) មាន ២៣បន្ទាត់ ភាសាសំស្ក្រឹត ១២បន្ទាត់ខាងដើម និងបន្ទាប់ជាភាសាខ្មែរ១១បន្ទាត់ ផ្នែកខាងខ្នង(ខ) មាន៣៥បន្ទាត់ ២បន្ទាត់ខាងលើ ភាសាសំស្ក្រឹត និង បន្ទាប់ជាភាសាខ្មែរ ៣៣បន្ទាត់ ។

សិលាចារឹកនេះ ចារឡើងនៅក្នុងរាជ្យព្រះបាទភវវម៌្មទី២(៦៣៩-៦៥៧

គ.ស.)[១] ។ លើសពីនេះ អត្ថបទជាភាសាខ្មែរ ផ្នែក"ក"បង្ហាញអំពីចំនួនអ្នកបំរើប្រាសាទ ទាំងក្មេងនិងមនុស្សចាស់សរុប ២១៥នាក់ ជាជនជាតិខ្មែរចំនួន ១៣៨នាក់[២] បុរស ចំនួន៣៣នាក់ ស្ត្រីចំនួន៤៧នាក់ ក្មេងប្រុស២២នាក់ ក្មេងស្រី២៧

---

[១] see, Mahesh Kumar Sharan, *Studies in Sanskrit Inscriptions of Ancient Cambodia*, New Delhi, 1974, pp.29-34.

គឺព្រះបាទភវវរ្ម័នទី២ ។ តើពាក្យ "វរ្ម័ន" ភ្ជាប់នៅខាងចុងព្រះនាមព្រះមហាក្សត្រខ្មែរបុរាណបែបនេះ ផ្អែកលើមូលដ្ឋានអ្វី? បើនៅលើគ្រប់សិលាចារឹកជាភាសាខ្មែរ ស្មេរតែងតែសរសេរពាក្យថា"វម៌្ម ឬ វម៌"(អានថា : វ៉ាក់ រ មាក់) បែបនេះនៅខាងចុងជានិច្ច ។ ពោលគឺ មិនមែនលោកសរសេរ"វរ្ម័ន"បែបនេះទាល់តែសោះ ។ យើងជឿជាក់ថា ស្មេរសិលាចារឹកនៅសម័យនោះ ពិតជាអ្នកចេះភាសាសំស្ក្រឹតយ៉ាងចំណានបំផុត សូម្បីតែ អ្នកប្រាជ្ញសំស្ក្រឹតជាតិឥណ្ឌាសព្វថ្ងៃ (ភត្តចរយៈ)ក៏ទទួលស្គាល់ថា អត្ថបទទាំងនោះ មានគុណភាពល្អវិសេសលើសជនជាតិឥណ្ឌា ដែលជាម្ចាស់ភាសានៅសម័យនោះដែរ ។ នៅទីនេះ ពេលនេះ ក្នុងបំណងពញ្ញាក់ស្មារតីរបស់អស់លោកអ្នកអានទាំងអស់(ជាលើកទី២) អោយជួយពិចារណាក្នុងការផ្ទៀងផ្ទាត់ពាក្យពេចន៍ចាំបាច់មួយចំនួន ដែលខ្មែរយើងទាំងអស់គ្នា យកមកប្រើប្រាស់ដោយភ័ន្តច្រឡំដោយមិនដឹងឫសគល់ និងហេតុបច្ច័យពិតប្រាកដរបស់វា ។ យើងសរសេរពាក្យនេះ គឺ អនុឡោមតាមសំនេរដើមទាំងស្រុង ។ ជាការពិតហើយពាក្យនេះ គឺជាពាក្យសំស្ក្រឹត ប៉ុន្តែអ្នកប្រាជ្ញបុរាណមិនបានបន្ថែមវិភត្ត(វិភត្តិ)"ន"នៅខាងចុង ដូចជនជាតិខ្មែរប្រើរត់មាត់គ្រប់ៗគ្នា នាសម័យបច្ចុប្បន្ននេះទេ ។ បើតាមលោក ព្រហ្មចារី អតីតសាស្ត្រាចារ្យភាសាសំស្ក្រឹតនៅសាកលវិទ្យាល័យមហាឫសីវេទ ប្រាប់ខ្ញុំថា ពាក្យ"វម៌្ម"នេះ អានថា "វ៉ា រ៉ុម" ប៉ុន្តែ នៅពេលណាគេសរសេរវាជា Roman trasliteration គឺ Varman ដោយមានបន្ថែមវិភត្ត "-ន /-n" នៅខាងចុងបែបនេះ។

នាក់ អកម្មិសីល(?)៩នាក់ ជាជនជាតិមលេង បុរសចំនួន ១៨នាក់ ស្ត្រីចំនួន៣០ នាក់ ក្មេងប្រុស៧នាក់ ក្មេងស្រី២០នាក់ អកម្មិសីល ២នាក់ ជាមួយនិងបរិមាណ ក្របី គោ ដើមស្លា ដើមដូង និងស្រែ ព្រមទាំងឈ្មោះរបស់វា ។

នៅផ្នែក"ខ"ប្រាប់ថា ជាអំណោយរបស់ស្តេចត្រាញ់ ឬមន្ត្រីជាន់ខ្ពស់ ឈ្មោះ ម្រតាញ កម្រតាង ច្រង្គោស នៅឯ"យនប?"ដោយមានរៀបរាប់ឈ្មោះ ក្ញុំបំរើម្នាក់ៗយ៉ាងលំអិត មានក្ញុំក្មេរ(ក្ញុំបំរើ ជាជនជាតិខ្មែរ) ប្រុស ស្រី ចាស់ ក្មេង ដែលយើងរាប់ឃើញចំនួន១៣៨នាក់ និងក្ញុំមលេង(ក្ញុំបំរើជាជនជាតិម្លេង) ប្រុស ស្រី ចាស់ ក្មេងចំនួន៧៧នាក់ ។

ពតិមានដ៏សំខាន់បំផុត ដែលសិលាចារឹកនេះផ្តល់អោយ គឺជាតិពន្ធនាម ពីរ (Two Ethnonyms) ទី១ គឺ"ក្មេរ"(Kmer) ទី២ គឺ"មលេង"(Maleṅ) ដែលជនជាតិក្មេរ និងមលេង ទាំងពីរក្រុមនេះ ត្រូវបានគេដាក់ជាក្ញុំបំរើប្រា-សាទ ឬពលប្រាសាទ ។

អំពីពាក្យ "**ក្មេរ**" កន្លងមកតែងឃើញមានប្រើនៅលើសិលាចារឹក សម័យមុនអង្គរ ក្នុងទំរង់ជាឈ្មោះរបស់មនុស្សស្រី ឬប្រុស(នរនាម) ដែល ភាគច្រើនអ្នកទាំងនោះជាក្រុមជនស្រទាប់ក្រោម ។ ដូចជា សិលាចារឹក K 11 សម័យមុនអង្គរសតវត្សទី៧ នៅវត្តពោធិវង្សលើស្រុកគីរីវង្សខេត្តតាកែវ មាន

[២] លេខដែលគេបានសរសេរគឺពិតជា ១៣៧ នាក់ ប៉ុន្តែបើបូកចំនួន ដែលគេបានរៀបរាប់ ឃើញ ១៣៨នាក់ ។

ឈ្មោះ "វ ក្មេរ"(៣) (មានន័យថា លោក ក្មេរ) ។ សិលាចារឹក K18 សម័យមុនអង្គរឆ្នាំ៧២៦គ.ស. នៅព្រៃមៀនស្រុកទ្រាំងខេត្តតាកែវដែរ មានពាក្យថា "ក្ញុំកន្តែ កុ ក្មេរ ១ កោន ៤" (មានន័យថា ក្ញុំបំរើភេទស្រី នាង ឬ អ្នកស្រី ក្មេរម្នាក់ និងកូន ៤នាក់) ។ សិលាចារឹក K786 សម័យមុនអង្គរសតវត្សទី៧ នៅទួលវត្តចាស់ ស្រុកលង្វែកខេត្តកំពង់ឆ្នាំង មានឈ្មោះ "កុ ក្មេរ"(៤) (មានន័យថា នាង ក្មេរ) ។ សិលាចារឹកថ្មី១ ទើបរកឃើញនៅភូមិដូង ឃុំឈើទាល ស្រុកបាណន់ខេត្តបាត់ដំបង(៥) នៅក្នុងចំណោមក្ញុំបំរើជាង១៤០នាក់ប្លាយ ដែលត្រូវបានស្តេចត្រាញ់ ឬជាអភិបាលនៃខេត្តភីមបុរ ថ្វាយជាក្ញុំបំរើប្រាសាទនៅទីនោះ ក៏មានបុរសម្នាក់ ឈ្មោះ "ក្មេរ"នេះដែរ ។ នៅសម័យអង្គរសិលាចារឹក K 366A ឆ្នាំ១១៣៩គ.ស. នៅវត្តភូ ខេត្តបាសាក់ ប្រទេសឡាវ មានឈ្មោះ "តៃសៅខ្មែរ កូនតៃអ្នស"(៦) (មានន័យថា នាងសៅខ្មែរជាកូនរបស់នាងអ្នស) ចំណែកសិលាចារឹកK 227 សតវត្សទី១២ នៅប្រាសាទបន្ទាយឆ្មារ មានពាក្យថា "ស្តចនាំអ្នកខ្មែរ" (បានន័យថា: *ស្តេចនាំមនុស្សខ្មែរ* ឬជនជាតិខ្មែរ) ។

---

(៣) លោក សឺដេស សន្និដ្ឋានថា ជាជនជាតិខ្មែរ(Cambodgien), voir, Coedès, G. *Inscriptions du Cambodge,* vol. II, Paris 1942, p. 7, 146.

(៤) voir, Coedès, G. *op cit,* vol. VII, Paris 1964, p. 107.

(៥) សូមមើល. អ៊ុន ភគិនី "សិលាចារឹកភូមិដូង" ក្នុង*ទស្សនាវដ្តី អក្សរសាស្ត្រ-មនុស្សសាស្ត្រ* សាកលវិទ្យាល័យភូមិន្ទភ្នំពេញ លេខ តុលា-វិច្ឆិកា-ធ្នូ ១៩៩៨ ទំព័រ ៣៩-៤៣ ។

(៦) voir, Coedès, G. *op cit,* vol. V, Paris 1953, p.291.

ម្យ៉ាងទៀត ដោយសារក្នុងភាសាខ្មែរ ព្យញ្ជនៈ"ក" និង"ខ"គេអាចយកមកប្រើជំនួសគ្នាបានយ៉ាងច្របូកច្របល់ ហេតុនេះហើយ ទើបអ្នកស្រាវជ្រាវផ្នែកសិលាចារឹកទាំងឡាយធ្វើសេចក្តីសន្និដ្ឋាន នរនាម "ក្មេរ"ថាជាឈ្មោះរបស់ជនជាតិខ្មែរសព្វថ្ងៃនេះឯង ។

ម្យ៉ាងទៀត មានអ្នកស្រាវជ្រាវបរទេស និងជនជាតិខ្មែរជាច្រើននាក់បានខិតខំរិះរកអំណះអំណាងរៀងៗខ្លួន ខុសៗពីគ្នា ដើម្បីរាវរកដើមកំណើតនៃពាក្យ"ខ្មែរ" តាមរយៈភាសាវិទ្យាផង តាមគ្រាមភាសាអំបូរ មន-ខ្មែរផងតាមប្រពៃណីនិយមផង ជាដើម ។ ក្នុងនោះដូចជាលោក ហ្សក សឺដេស ថា "ក្មេរ ឬ ខ្មែរ <កម្ពុ + មេរា"តាមរយៈសិលាចារឹកបក្សីចាំក្រុងសតវត្សទី១០។ លោក ឈឹម ក្រសេម ថា"ក្មេរ ឬខ្មែរ < កុមេរុ" គឺជាឈ្មោះរដ្ឋឥណ្ឌាមួយនៅភាគខាងត្បូងនៃប្រទេស ដែលជាកន្លែងដើមនៃជនជាតិខ្មែរ មុនពេលធ្វើចំណាកស្រុកមករស់នៅតំបន់ដីសណ្តទន្លេមេគង្គ និងមេណាមសព្វថ្ងៃ ។ ដូច្នេះគាត់ចង់អះអាងថា ខ្មែរគឺជាឥណ្ឌា (ដែលបានធ្វើចំណាកស្រុក) ។ លោក កេង វ៉ាន់សាក់ ថា "ក្មេរ ឬ ខ្មែរ < ក + មេ" តាមទស្សនៈមាតាធិបតេយ្យគោរពមេជាធំនៅក្នុងសង្គម និងគ្រួសារ[៧] ។ ចំណែកលោក ហ្សេរ៉ាដ ឌីហ្វឡូស្មើថា "ក្មេរ ឬ ខ្មែរ < កេរ ឬ កែរ(=កៀវប្រហុក ឬធ្វើប្រហុកទុកហូប ឬជួញដូរ) + [-ម-](ផ្នត់ជែក-ម-: សំរាប់សំគាល់មនុស្សដែលធ្វើអំពើ)" មាន

[៧] សូមមើល. ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ* ភាគ១ ភ្នំពេញ ១៩៧២ ទំព័រ ១៧-៣៤ ។

ន័យថា ខ្មែរជាជនជាតិមួយប្រភេទ ដែលជាអ្នកធ្វើប្រហុក(ឬម្ហូប ដែលធ្វើអំពីសាច់ត្រី?) ដោយផ្ទុកក្នុងជាលដាក់រទេះយកមកផ្ទះទុកហូប ឬយកទៅលក់នៅក្នុងទូទាំងចក្រភពខ្មែរបុរាណ[៨] ។

តាមពិត ការខិតខំពន្យល់របស់អ្នកស្រាវជ្រាវល្បីៗទាំងអស់ អំពីពាក្យ "ក្មេរ ឬ ខ្មែរ" ដែលខាងលើ យើងលើកយកមកបង្ហាញតែមួយចំនួនតូចប៉ុណ្ណោះ ឃើញថាវាសុទ្ធតែសមរម្យម្យ៉ាងម្នាក់ ។ មិនតែប៉ុណ្ណោះ ការអះអាងថ្មីៗជាច្រើនទៀត ក៏នឹងអាចមានគេលើកឡើងមកបង្ហាញជាបន្តបន្ទាប់ទៀត មិនឈប់ឈរដោយគ្រាន់តែលើកកិរិយាស័ព្ទ "កេឬកែ" ដែលមានបន្សល់នៅភាសាខ្មែរបុរាណ ឬសព្វថ្ងៃ ឬបណ្ដាគ្រាមភាសានៃអំបូរមន-ខ្មែរដទៃទៀត យកមកបន្ថែមផ្នត់ជែក-ម- ធ្វើជាមូលដ្ឋានពន្យល់ ។

លើកលែងតែលោកត្រឹង ងាម្នាក់ ដែលមិនបានពន្យល់ ទាញរកឫសគល់ ឬសាវតារនៃពាក្យ "ក្មេរ ឬ ខ្មែរ" ដូចអ្នកស្រាវជ្រាវដទៃ ។ ដោយគាត់ទាញយកភស្តុតាងនៃពាក្យនេះលើសិលាចារឹក មកធ្វើជាមូលដ្ឋានថា ពាក្យ "ខ្មែរ" ពិតជាមកពីពាក្យ "ខ្មែរ" នៅសម័យអង្គរ ហើយពាក្យនេះ មកពីពាក្យ "ក្មេរ" នៅសម័យមុនអង្គរ ដែលគេស្គាល់ថា ជាជាតិពន្ធុនាមនៃជនជាតិខ្មែរ

---

[៨] see, Diffloth, G. "History of the Word KHMER" in *KHMER STUDIES: Knowledge of the Past and Its Contributions to the Rehabilitation and Reconstruction of Cambodia*, 26-30 August 1996, edited by Sorn Samnang, Phnom Penh 1998, pp. 644-651

សព្វថ្ងៃ ។

មកដល់ពេលនេះ វាក៏រឹតតែច្បាស់ថែមទៀត តាមរយៈសិលាចារឹក ដែលទើបរកឃើញថ្មីនៅភូមិមេលប់នេះ ដើម្បីបញ្ជាក់ថា ពាក្យ"ក្មេរ" ដែល កាលពីដើម(សម័យមុនអង្គរ)មានប្រើតែនៅក្នុងទំរង់ជា នរនាមនោះ គឺជា ឈ្មោះរបស់ជនជាតិ"**ខ្មែរ**"យ៉ាងប្រាកដ ដែលនៅសម័យនោះ គឺជាជនជាតិ មួយក្រុមធំ នៃអំបូរមន-ខ្មែរ ហើយរស់នៅក្នុងរាជាណាចក្រភ្នំ និងចេនឡា ។

ចំណែកពាក្យ"**មលេង**" ក៏ជាឈ្មោះរបស់ជនជាតិមួយទៀត ដែល រួមរស់នៅលើទឹកដីអតីតរាជាណាចក្រភ្នំ ឬហ្វូណន និងចេនឡា នាពេលនោះ ដែរ ។ តាមសិលាចារឹក K 451 ប្រាសាទព្រៃថ្នល់ត្បូង ចុះកាលបរិច្ឆេទឆ្នាំ ៦៨០គ.ស. បានអោយដឹងថា"កុរុងមលេង"(=*ស្តេចមលេង* ដែលគ្រាន់តែជា ស្តេចត្រាញ់) បានធ្វើអំណោយក្ញុំបំរើ និងភោគទ្រព្យផ្សេងៗ ដល់អាទិទេព កេទារេស្វរ ដែលប្រតិស្ឋាននៅប្រាសាទព្រៃថ្នល់ត្បូង ដែលស្ថិតនៅតាមមាត់ ស្ទឹងព្នាំងផ្អែកខាងឆ្វេងក្នុងស្រុកពួក ខេត្តសៀមរាបសព្វថ្ងៃនោះឯង[៩] ។

នៅសម័យអង្គរ មានភូមិភាគមួយឈ្មោះថា *មល្យាង* (អានថា: មលៀង ឬ មលីង ព្រោះសម័យបុរាណជើង "្យ" គេប្រើជំនួសស្រៈ "ី" និង "ៀ" ចំពោះអត្ថបទភាសាខ្មែរ) ប្រហែលជានៅភាគអាគ្នេយ៍ ខេត្តបាត់ដំបង និងខាងជើងខេត្តពោធិសាត់សព្វថ្ងៃនេះ ។ នៅភូមិភាគ *មល្យាង* កាលពីក្នុង

[៩] voir, Coedès, G. *op cit*, vol. V, pp. 49-52.

រាជ្យព្រះបាទជយវរ្ម័នទី៧ បានកើតមានការបះបោរ ។ ពេលនោះ ព្រះមហាក្សត្របានប្រើព្រះអង្គម្ចាស់ចាម ឈ្មោះវិទ្យានន្ទន៍ (កូនស្តេចចាម) ដែលជាបុត្រធម៌ លើកទ័ពទៅបង្ក្រាបប្រកបដោយជោគជ័យ[១០] ។

ចំណែកតាមរយ:ឈ្មោះខេត្តមួយ ដែលជីវ តាក្វាន់ បានសរសេរនៅក្នុង "កំនត់ហេតុអំពីប្រពៃណីនៃអ្នកស្រុកចេនឡា" បន្ទាប់ពីគាត់បានមកទស្សនាចក្រភពអង្គរនាឆ្នាំ១២៩៦គ.ស. ក៏ពិតជាឈ្មោះ ខេត្ត *មល្យាង* (គាត់សរសេរ : មុងលាង) នេះដែរ[១១] ។ យើងអាចសន្និដ្ឋានថាភូមិភាគ ឬខេត្តនេះ ពិតជាតំបន់រស់នៅដ៏សំខាន់មួយរបស់ជនជាតិ "មលេង" ។ ត្បិតភស្តុតាងនៃសិលាចារឹកសម័យមុនអង្គរ និង អង្គរ ព្រមទាំងឯកសារចិន បង្ហាញអោយឃើញនូវពាក្យស្រដៀងៗគ្នា ដែលបញ្ហានេះបណ្តាលមកពីអ្នកសរសេរមានការបន្លឺសូរសំនៀងអំណានខុសៗគ្នា ហេតុនេះការកត់ត្រាសំនួរពាក្យ មានការល្បៀងខុសពីគ្នាបន្តិចដែរ ។

- ក្រៅពីនេះ នាពេលបច្ចុប្បន្ន យើងកត់សំគាល់ឃើញមានស្ថាននាមមួយចំនួនស្រដៀងគ្នានេះដែរ ដូចជា ភូមិមេលប់(កន្លែងរកឃើញសិលាចារឹក) ភូមិមេលោង(ស្ថិតនៅខាងត្បូងមេលប់ប្រមាណ៤គីឡូម៉ែត្រ) ស្ថាន

---

[១០] សូមមើល, ត្រឹង ងា ឯកសារដដែល ទំព័រ ១៦៣ ។

[១១] សូមមើល, លី ធាមតេង *"កំណត់ហេតុរបស់ជីវ តាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា"* បោះពុម្ពលើកទី៣ (៨១ទំព័រ) ភ្នំពេញ ១៩៧៣ ទំព័រ ៦២ ។

នាម មលេងឃុំទ្រានស្រុកបារាយណ៍ នៅខាងត្បូងពីទីរួមខេត្តកំពង់ធំប្រហែល ៦០គីឡូម៉ែត្រ ជាដើម ។ មិនដឹងថា តើកន្លែងទាំងនេះ ពិតជាមានការទាក់ទង នឹងវត្ថុមានរបស់ជនជាតិ"មលេង" ឬអត់នោះទេ ។ ប៉ុន្តែ ជាការគួរអោយស្តាយ ដោយសារក្រុមជនជាតិ"មលេង"នៅកម្ពុជាសព្វថ្ងៃ មិនត្រូវបានគេស្គាល់នៅក្នុងចំណោមក្រុមជនជាតិជាច្រើនទៀតនៃអំបូរមន-ខ្មែរ ដែលយើងជឿថា ជនជាតិនេះពិតជាបានរលាយពូជពង្សជាមួយជនជាតិខ្មែរអស់ហើយ ។ ផ្ទុយទៅវិញ សព្វថ្ងៃនេះ គេឃើញសហគមន៍ជនជាតិ"មលេង" ដែលមានចំនួនសមាជិករាប់ម៉ឺននាក់ កំពុងរស់នៅយ៉ាងសុខសាន្តក្នុងប្រទេសឡាវ ។

ខាងក្រោមជាអត្ថបទសិលាចារឹកទាំងស្រុង :

## អត្ថបទផ្នែក "ក"

| | | |
|---|---|---|
| ១ | ហេ( មា) ន្ទយនភគ្ខន្ទ្រះ | កាន្ត្យា( សោ) ម្យោបិតេជសា |
| ២ | ទ្វីបន្នារីមុខេទៃន្យៀ | ប្រតាបំយ[-]ក្រាគយត |
| ៣ | ត្រីមតោរាជរាជស្យ | រាជ្ញត្រ្រីភវវម៌្មណះ |
| ៤ | តស្យាក្ស៊ែរភ្យោវ( ណ) ឡក្ស | គ្លិរង្សោមបតិ( ត្ត) តះ ឬ |
| ៥ | អនន្យលញ្ឆមហាតឹ | គ្នេតចត្រាទិសំបទ- |
| ៦ | គជាគ្នយោធសំវាណាំ | លប្ធវាន្យា--ក្តិតះ |

៧ គ្យាមោឃ្ឋណីលម្ទវាហុ វ្ទិរ(ញ្ញា)-នហង្ក--ប្ញ

៨ (និ)វ្ទត្តព្យោណិហិង្សយា មុក្ខាសមរសង្ក(ម៖)

៩ ក-មេស្យាទ្ធតីរិតិ បរលោកេ(គុ)ភោទយា

១០ ---រិ------ន ប្រ-ទប្រ៉-ប្រ------ស៖

១១-----------  --ទេន--ផ្ន------

១២ ែ--------ែ្រ--  --------រ---

១៣ ក្ញុំក្មេរឃោដ២០.១០.៣កន្ទ្រៃ២០.២០.៧ទេរសិ២

១៤ ទេរតៃ៨លាងសិ៩លាងតៃ៩បៅសិ១១

១៥ បៅតៃ១០អកម្មិសីល៩គេ១០០.២០.១០.៨ (១២) ។

១៦ ក្ញុំមលេងឃោដ១០.៨កន្ទ្រៃ២០.១០ទេរសិ១ទេ

១៧ រតៃ៨ លាងសី៤ លាងតៃ៨ បៅសិ២

១៨ បៅតៃ៤ អកម្មិគីល២ គេ២០.២០.២០.១០.៧ ។

១៩ សរ្វិបិណ្ឌសវាលវ្ទទ្ធគេ១០០.១០០.១០.៥ ក្របិ

(១២) ច្បាប់ដើមសរសេរ ៣ុន្ទ៣ៗ (៧៤×៣) គឺ ១០០.២០.១០.៧ =១៣៧

២០ ២០.១០ ។ត្មុរ២០.២០ ស្លាតំស្លិក១ ១០០.․តោងតំ

២១ ១០០.៧ ។ ស្រេ(ត្មោ) លទមីសរេ៤(មាស)

២២ ស្រេថលាបុរវ្នាកស្រុក សរេ-----

២៣ ស្រេ-តយេ សររេ៨ -មាស១ បិណ្ឌស្រេ---

## អត្ថបទផ្នែក "ខ"

១ ក(ញ្ញ)សខ្សេយសំម្ភារ បុណ្យជ្ញានវិវទ្ធិតះ

២ វិដៃតាមារសៃទ្យានាំ -យតិគ្រីយនោនយះ ។

៣ អំនោយម្រតាញ្ញកម្រតាងច្រង្កោស(តតុ-វ)រអាយយនប

៤ ក្នុំឃោដអំរះសោ១(ទ្មុ)កវ៉ាកំវៅ១វ៉ាព្រៅ១វ៉ាត្បោញ១វ៉ាត្រទៃ១
វ៉ាសេទ្ធរ១កុ(សំ)

៥ លាញ១កោនបៅតៃ១លាងសី១ទេរតៃ២កុសញ្ញី១បៅសិ១ទេរតៃ២
លាងសិ១

៦ កុបិត១កុកន្ទេន១កុវ្រេ១កុបៅតៃ១លាងសិ១កុវង១កុអរស១ ។អំរះ

៧ សង្កល១វ៉ាធលិ(យពូ)១វ៉ាសហិត១វ៉ាកំបាក១អ្នក្តន្ទៃកុស្បោក១បៅ

តៃ១

៨ កុកំបច១កុគ្រទ្វា១ប៉ៅតៃ១លាងតៃ១ទេវតៃ១កុសំសៅ១ប៉ៅសី១កុស្រ

៩ លញ្ជ១កុតងវះ១កុក្មោញ្ជ១កុវ្រៅ១ប៉ៅសី១លាងតៃ១កុតំនវ១ប៉ៅសី១

១០ លាងតៃ១កុករៅំ១ប៉ៅតៃ១លាងតៃ១ទេវតៃ១ ។អំរះសោមវីរ១

វ្វាកន្ទុង១

១១ អ្នក្តន្ទៃកុសញ្ចេ១ប៉ៅតៃ១កុករៅំ១ប៉ៅសិ១លាងតៃ១ទេវសិ១កុយខិ១

១២ កុក្ចិហ១កុអរស១កុវ្រៅ១វ្វាកំបង១វ្វាសំវោះ១កុវ្នម១ ។ អំរះ

១៣ រំបញ្ជ១វ្វាសបាយ១វ្វាខល១វ្វាត្មាង១វ្វាកញ្ចោង១អ្នក្តន្ទៃកុ

១៤ ត្យាង១ប៉ៅសិ១លាងតៃ១កុច្ហាល១ប៉ៅតៃ១កុបង្កេត១វ្វាទ្រទាស១

១៥ កុច្ហាលសិន១ប៉ៅសិ១ទេវសិ១លាងសិ១លាងតៃ១វ្វាតងត១

១៦ កុកល្បិត១លាងសិ២កុជាកុកះ១ប៉ៅតៃ១កុវ្រេស១វ្វាសាន១កុវិន១

ប៉ៅតៃ១

១៧ ទេវតៃ២កុរោក១ប៉ៅតៃ១លាងសិ១វ្វាស្រោង១បញ្ចមី១វ្វាកន្ទេន១

អ( គត) ១លា

១៨ ភ១កុថេប១កុកេ១កុវាង១កុវះ១កុចំ១កុឯត១កុអប១កុល្មោង១ប្រុត១

១៩ វាស្និង១វាត្ងរ១កុ(តភ)១វាស្ដោយ១កុអសាប១ចៅសិ១លាងតែ២វាត្ង

២០ យ១កុជា១ចៅសិ១វាលង្គះ១កុទូ១ចៅសិ១លាងតែ១កុអរសអាយ១

២១ ចៅសី១លាងសី១វាត្មេង១អកម្មិគីល៩ ។ ក្ញុំមលេង វាលកុញ្ជ១

២២ វាបនកុញ្ជ១វាវៃកុញ្ជ១វាចេកុញ្ជ១កុជ្ញិក១លាង្សិ១វាមាងកុញ្ជ១

២៣ ញ្ជ១វាលោនកុញ្ជ១វាជំនោក១វាក---ក-លាងសិ១វាលាយកុ

២៤ ញ្ជ១វាជនកុញ្ជ១វាត្មាយ១វាតចេង១វា(តសំ)១វាត្មាង១វាត្មៅ១វា

២៥ ប្លេង១វាតចេយ១កុមាងកន១កុកោយកន១បោសិ១កុយលះ១កុយ

២៦ លា១កុឌីកន១លាងតែ១បនកន១ចៅតែ១កុរោងគន១កុយាងក្បា១...

២៧ តែ២កុយលង១កុចោងកន១ចៅតែ១លាងតែ១កុចេកន១ចៅសិ១កុប

២៨ ងកន១កុក្មាស១កុវៃកន១ទេវតែ១កុយលេក១លាងតែ២ទេវតែ២

២៩ កុយបៃ១កុយធៅ១ចៅតែ១លាងសី១ទេវតែ១កុវេលកន១ចៅតែ១

៣០ កុលោញ្ជ១លាងតែ២បៃកន១លាងសី២ទេវតែ១កុលាយគន១ទេវ

៣១ តែ១កុបោញ្ជកន១លាងសិ១ទេវតែ១កុយំគន១កុចំ(ងា)យ

៣២ កន១កុលោងកន១កុ    ចេយកន១លាងតៃ

៣៣ ២ទេវសិ១កុសង្កាហ្វ    កន១កុយបះ១កុ

៣៤ យមោល១កុវេង    កន១(វា)ស្វាំ១អក

៣៥ ម្ទិឝីល២ ។០។

## អត្ថបទជាអក្សររ៉ូម៉ាំង

### Text A

1 he[mā]nmayanabhaçcandraḥ    kāntyā[so]myopitejasā
2 dvīpannārīmukhedainye    pratāpaṃya xprakāçayat
3 çrī matorājarājasya    rājñaççrībhavavarmmaṇaḥ
4 tasyārkṣabhyova[ṇa]ddhyakṣa ç[dh]iraṅghoṣa pati[t]kṛitaḥ
5 ananya labdhāṃ mahatiṃ    [ç]vetacatrādisaṃpada—
6 gajāçvayodha saṃvā[ḍhā]ṃ    lapdhavānsvā-i-[k]titaḥ
7 çyāmoghṛṇīlamvavāhu    rvvarabvā-nahaṅkṛi---
8 [ni]vṛitabprā[ṇi]hiṅsayā    muktvāsamarasaṅka[ṣaḥ]
9 ka-mesyādgatiriti    paraloke[ç]ubhodayā
10 ---vi----------------n    pra---davra----r--------saḥ
11 ----------------------    ---idena---dhn----------
12 --e------------tr----    -----------------ra--------
13 kñuṃ kmer ghoṭa 20.10.3 kantai 20.20.7 der si 2
14 der tai 8 lāṅ si 9 lāṅ tai 9 pau si 10.1
15 pau tai 10 akarmmasīla 9 ge 100.20.10.8 °
16 kñuṃ maleṅ ghoṭa 10.8 kantai 20.10 der si 1 de
17 r tai 8 lāṅ sī 4 lāṅ tai 8 pau si 2
18 pau tai 4 akarmmaçīla 2 ge 20.20.20.10.7 °
19 sar[v]va piṇḍa savālavṛiddha ge 100.100.10.5 ° krapi
20 20.10 ° tmur 20.20 slā teṃ slik 1. 100—toṅ teṃ

13 100.7 ° sre [gn]ol damī sare 4 [m]ās
14 sre thalāpura vnāk sruk sare -----
15 sre –taye sare 8 –mās 1 piṇḍa sre ----

## Text B

1 ka[ṇgh]asakhyeyasaṃmbhāra puṇyajñānavivarddhitaḥ
2 vijaitāmārasainyānāṃ -iyatiçrī[gha]nona[ghaḥ] //
3 aṃnoy mratāñ kamratāṅ craṅ gos [ta gui ve]r āẏ yanap
4 kñuṃ ghoṭa aṃraḥ so 1 [dmu]k vā kaṃvau 1 vā vrau 1 vā tpoñ 1 vā tradai 1 vā sendhava 1 ku [saṃ]
5 lāñ 1 kon pau tai 1 lāṅ sī 1 der tai 2 ku sañjī 1 pau si 1 der tai 2 lāṅ si 1
6 ku pit 1 ku kanden 1ku vrai 1 ku pau tai 1 lāṅ si 1 ku vaṅ 1 ku aras 1 ° aṃraḥ
7 saṅkal 1 vā dhali[yabū] 1 vā sahita 1 vā kaṃhāk 1 ªnak kantai ku spok 1 pau tai 1
8 ku kaṃpac 1 ku çraddhā 1 pau tai 1 lāṅ tai 1 der tai 1 ku saṃseṃ 1 pau si 1 ku sra
9 lañ 1 ku taṅvaḥ 1 ku kdoñ 1 ku vrau 1 pau sī 1 lāṅ tai1 ku taṃnar1 pau sī 1
10 lāṅ tai 1 ku karoṃ 1 pau tai 1 lāṅ tai 1 der tai 1 ° aṃraḥ somavīra 1 vā kan-oṅ 1
11 ªnak kantai ku sañje 1 pau tai 1 ku karoṃ 1 pau si 1 lāṅ tai 1 der si 1 ku yakhi 1
12 ku ckih 1 ku aras 1 ku vrau 1 vā kaṃpaṅ 1 vā saṃvoḥ 1 ku vnaṃm 1 ° aṃraḥ
13 raṃpañ 1 vā sahāy 1 vā khal 1 vā tmāṅ 1 vā kañ joṅ 1 ªnak kantai ku
14 tyāṅ 1 pau si 1 lāṅ tai 1 ku cªāl 1 pau tai 1 ku paṅket 1 vā dra dās 1
15 ku cªāl sin 1 pau si 1 der si 1 lāṅ si 1 lāṅ tai 1 vā ta et 1
16 ku kalpit 1 lāṅ si 2 ku jā ku kaḥ 1 pau tai 1 ku vres 1 vā sān 1 ku vin 1 pau tai 1

17 der tai 2 ku rok 1 pau tai 1 lāṅ si 1 vā srāṅ 1 pañcamī 1 vā kanden 1 a[gat] 1 lā
18 bha1 ku thep 1 ku ke 1 ku vāṅ 1 ku vaḥ 1 ku caṃ1 ku et 1 ku ap 1 ku lmoṅ1 prut1
19 vā sliṅ 1 vā tvar 1ku [tebha] 1 vā stoy 1 ku asāp 1 pau si 1 lāṅ tai 2 vā tva
20 y 1 ku jā 1 pau si 1 vā laṅ kaḥ 1 ku dū 1 pau si 1 lāṅ tai 1 ku aras āy 1
21 pau sī 1 lāṅ sī 1 vā tmeṅ 1 akarmmaçila 9 ° kñuṃ maleṅ vā la kuñ 1
22 vā pan kuñ 1 vā rai kuñ 1 vā ce kuñ 1 ku jvik 1 lāṅ si 1 vā māṅ kuñ 1
23 ñ 1 vā lon kuñ 1 vā jaṃ nok 1 vā ka—ek – lāṅ si 1 vā lāy ku
24 ñ 1 vā jan kuñ 1 vā tmāy 1 vā ta ceṅ 1 vā [ta saṃ] 1 vā tmāṅ 1 vā tmau 1 vā
25 pleṅ 1 vā ta cey 1 ku māṅ kan 1 ku koy kan 1 pau si 1 ku ya laḥ 1 ku ya
26 lā 1 ku au kan 1 lāṅ tai 1 pan kan 1 pau tai 1 ku roṅ gan 1 ku yāṅ kyā 1--
27 tai 2 ku ya laṅ 1 ku coṅ kan 1 pau tai 1 lāṅ tai 1 ku ce kan 1 pau si 1 ku pa
28 ṅ kan 1 ku kmās 1 ku rai kan 1 der tai 1 ku ya lek 1 lāṅ tai 2 der tai 2
29 ku ya pai 1 ku ya dhau 1 pau tai 1 lāṅ sī 1 der tai 1 ku vel kan 1 pau tai 1
30 ku loñ 1 lāṅ tai 2 pai kan 1 lāṅ sī 2 der tai 1 ku lāy kan 1 der
31 tai 1 ku poñ kan 1 lāṅ si 1 der tai 1 ku yaṃ gan 1 ku caṃ[ṅ]āy
32 kan 1 ku loṅ kan 1 ku cey kan 1 lāṅ tai
33 2 der si 1 ku saṅkāhv kan 1 ku ya paḥ 1 ku
34 ya mol 1 ku reṅ kan I [vā] svāṃ 1 aka
35 rmmaçila 2 /o/

(នៅមានត)

# អំពីការបន្តចំណេះដឹង ពីជំនាន់មួយទៅជំនាន់មួយតាមរយៈបណ្ណាល័យ



សកម្មភាពសិក្សាស្រាវជ្រាវរបស់សិស្ស នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ (រូបថត ព.ប.)

បណ្ណាល័យ ហាក់ដូចជាពាក្យថ្មីចម្លែកសំរាប់ប្រជាជនខ្មែរយើង លើកលែងតែពួកនិស្សិត ដែលបានសិក្សាដល់កំរិតថ្នាក់វិទ្យាល័យ ឬមហាវិទ្យាល័យ ទើបអាចស្គាល់ច្បាស់អំពីតម្លៃពិតរបស់វា ។ តាមពិត, បណ្ណាល័យនោះមានតម្លៃតាំងពីដើមគ្រឹស្តសតវត្សមក ។ យើងបានសង្កេតឃើញមានបណ្ណាល័យ នៅគ្រប់ប្រាសាទបុរាណទាំងឡាយ ។ បណ្ណាល័យនេះ មានការរីកចំរើននៅសម័យអង្គរ មនុស្សខ្មែរទាំងអស់ សុទ្ធតែជាអ្នកមានចំណេះចេះដឹងខ្ពស់ ។ នៅពេលពុទ្ធសាសនាមហាយានចូលមកជំនួសសាសនាព្រាហ្មណ៍ នៅសតវត្សទី ១២ នៃគ្រឹស្តសករាជ បណ្ណាល័យកាន់តែមានសារសំខាន់ណាស់ទៅទៀត ដោយសារនៅសម័យនោះ មានមហាវិទ្យាល័យជាច្រើននៅទីក្រុងអង្គរ ជាអាទិ៍ មហាវិទ្យាល័យស្រីជ័យ នៅក្នុងប្រាសាទព្រះខ័ន និងមហាវិទ្យាល័យរាជវិហារ ក្នុងប្រាសាទតាព្រហ្ម ។

នៅសតវត្សទី ១៥ នៃគ្រិស្តសករាជ ព្រះពុទ្ធសាសនាថេរវាទបានចូលមកជំនួសពុទ្ធសាសនាមហាយាន ។ ពេលនោះ វត្តអារាមមានការរីកចំរើនយ៉ាងខ្លាំង ។ នៅគ្រប់វត្ត សុទ្ធតែមានបណ្ណាល័យមួយ ។ ប៉ុន្តែពេលនោះ គេមិនហៅថាបណ្ណាល័យទេ, គេហៅថា « ហោត្រ័យ » ។ ពាក្យហោត្រ័យ មានន័យថាជាបន្ទប់តម្កល់ព្រះត្រៃបិដក ឯបណ្ណាល័យក៏មានន័យថា ជាកន្លែងដាក់សៀវភៅ ឬសន្លឹកក្រដាស ឬសាស្ត្រាស្លឹករឹត ដូច្នេះ ពាក្យទាំងពីរនេះមានន័យដូចគ្នា ។ រីឯកន្លែងរបស់បណ្ណាល័យគឺស្ថិតនៅក្នុងប្រាសាទ និងវត្តអារាមដូចគ្នា ។

តាំងពីបុរាណមក បណ្ណាល័យនេះ គឺជាកន្លែងតម្កល់ទុកនូវក្បួនខ្នាត គម្ពីរដីកាគ្រប់បែបយ៉ាង សំរាប់បំរើការសិក្សាស្រាវជ្រាវរបស់កុលបុត្ត-កុលធីតាខ្មែរ ។ អ្នកប្រាជ្ញខ្មែរបានបន្សល់ទុកនូវចំណេះដឹងពីជំនាន់មួយទៅជំនាន់មួយ តាមរយៈការកត់ត្រា ការចងក្រងជាសាស្ត្រា ជាក្រាំង ជាគម្ពីរ លើស្បែកសត្វ លើសំបកឈើ លើក្រណាត់ លើក្រដាស ជាពិសេស លើស្លឹករឹត ។ ក្នុងចំណោមសម្ភារៈទាំងឡាយដែលគេប្រើសំរាប់កត់ត្រា មានតែសាស្ត្រាស្លឹករឹតទេ ដែលអាចរក្សាទុកបានយូរជាងគេ ។ ប៉ុន្តែ វត្ថុធាតុដែលសំខាន់បំផុត សំរាប់កត់ត្រាទុកបានយូរជាងគេបំផុតនោះគឺថ្ម ។ ចាស់បុរាណ លោកមិនចង់អោយអ្វីដែលលោកបានរកឃើញ លោកបានស្ថាបនាទុកនោះបាត់បង់ទៅដោយងាយៗទេ ដោយហេតុនោះ ទើបលោកចារឹកទុកលើផ្ទាំងសិលាទុកអោយយើងជាបច្ឆាជន ( ជនជាន់ក្រោយ ) បានដឹង បានស្គាល់អំពីប្រវត្តិរបស់ខ្លួន បានស្គាល់អំពីសិល្បៈ វប្បធម៌ និងចំណេះដឹងផ្សេងៗ ដែលចាស់បុរាណបានរកឃើញ និងបង្កើតឡើង ។ នៅគ្រប់បុរាណដ្ឋាន គ្រប់ប្រាសាទបុរាណសុទ្ធតែមានសិលាចារឹកទុកជាភស្តុតាង ។ គឺដោយសារសិលាចារឹកទាំងឡាយនោះហើយ ដែលធ្វើអោយគេស្គាល់អំពីប្រវត្តិសិល្បៈដ៏ថ្កុំថ្កើងរុងរឿងរបស់ជាតិខ្មែរដែលរហូតដល់សព្វថ្ងៃ ក៏នៅតែធ្វើអោយសកលលោកទាំងមូលកោតស្ងប់ស្ងែង ។

នៅសម័យក្រោយអង្គរ ឯកសារក្បួនខ្នាតទាំងឡាយ ត្រូវបានគេកត់ត្រាលើស្លឹករឹត ដែលគេហៅថា « សាស្ត្រា » ។ សាស្ត្រា មិនសំដៅតែទៅលើឯកសារទាក់ទងនឹងព្រះពុទ្ធសាសនាទេ ប៉ុន្តែ ឯកសារអក្សរសិល្ប៍ អក្សរសាស្ត្រ និងគម្ពីរក្បួនខ្នាតផ្សេងទៀត ដែលគេចារលើស្លឹករឹត ក៏ហៅថាសាស្ត្រាដែរ ។ សាស្ត្រាទាំងឡាយគឺព្រះសង្ឃជាអ្នកនិពន្ធ ជាអ្នកចារ និងជាអ្នកថែរក្សាទុកទៅតាមវត្តអារាម ។ សាស្ត្រាទាំងអស់នោះ គេតម្កល់ទុកនៅក្នុងហោត្រ័យនោះឯង ។ ហោត្រ័យ ឬបណ្ណាល័យតាមវត្តអារាមនេះ គឺជា*ឃ្លាំងសម្បត្តិវប្បធម៌ដ៏មានតម្លៃបំផុតរបស់ខ្មែរយើង*ដែលមានកំណើតច្រើនរយឆ្នាំមកហើយ ។ បណ្ណាល័យ ពុំមែនជាកន្លែងសំរាប់តែថែរក្សាទុកនូវសៀវភៅក្បួនខ្នាតអោយនៅស្ងៀមមួយកន្លែងនោះទេ ។ ប៉ុន្តែ គឺជាសាលាទីពីរ ឬជាគ្រូទីពីរក៏បាន ព្រោះក្រៅពីរៀននៅក្នុងសាលាធម្មតា គេអាចរៀននៅក្នុងបណ្ណាល័យទៀតនៅប្រទេសចំរើនជឿនលឿន បណ្ណាល័យមានតួនាទីសំខាន់ណាស់ នៅគ្រប់ភូមិសិក្សា ចាប់តាំងពីថ្នាក់បឋម រហូតដល់មហាវិទ្យាល័យ ; នៅក្នុងសង្គម ចាប់តាំងពីនៅក្នុងផ្ទះ រហូតដល់ភូមិ-ឃុំ-ស្រុក-ខេត្ត-ក្រុង សុទ្ធតែមានបណ្ណាល័យដោយឡែករបស់គេ ។ ទោះបីមកដល់ពេលបច្ចុប្បន្ននេះ វិទ្យាសាស្ត្របានបង្កើតសៀវភៅអេឡិចត្រូនិកបណ្ណាល័យតាមអាំងទ័រណែត ( internet ) ក៏ប៉ុន្តែ បណ្ណាល័យបុរាណ នៅតែមានសារសំខាន់ដដែល ។ ពីព្រោះ មនុស្សលោកភាគច្រើន នៅលើពិភពលោក ពុំទាន់មានលទ្ធភាពប្រើប្រាស់ប្រពន្ធ័កុំព្យូទ័រ និងអាំងទ័រណែតនៅឡើយប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏យើងត្រូវតែត្រៀមខ្លួនដើម្បីប្រើប្រាស់ឧបករណ៍សម័យទំនើបនេះ នៅក្នុងសហសវត្សថ្មី ។

ប្រការដែលសំខាន់បំផុតនោះ គឺត្រូវផ្តល់ជីវិតជាថ្មីដល់បណ្ណាល័យ ត្រូវធ្វើអោយសកម្មភាពបណ្ណាល័យរស់រានមានជីវិតឡើងវិញ ។ ប៉ុន្តែ ដើម្បីអោយបណ្ណាល័យរស់ ទាំងអស់គ្នាត្រូវតែខិតខំផ្លាស់ប្តូរទម្លាប់មិនល្អមួយចោល នោះគឺ

ទម្លាប់ស្តាប់ ទៅជាទម្លាប់អានដោយខ្លួនឯង ។ នៅសម័យបុរាណ គេបានដឹងថា នៅកម្ពុជា មានអនក្ខរជនតិចតួចណាស់ ។ នៅសម័យអង្គរ ស្ត្រីក៏មានកិរិតអប់រំខ្ពស់ដែរ ។ ព្រះនាងឥន្ទ្រទេវី ទ្រង់ជាបណ្ឌិតខាងអក្សរសាស្ត្រ និងជាសកលវិទ្យាធិការនៃសកលវិទ្យាល័យ នៅក្រុងអង្គរ ។ នៅសម័យកណ្តាល រហូតដល់សម័យអាណានិគម បុរសទាំងអស់ សុទ្ធតែជាអ្នកចេះអក្សរ ព្រោះបុរសទាំងអស់ត្រូវតែបួសរៀននៅក្នុងវត្តមួយរយៈ មុនពេលលាចាកសិក្ខាបទទៅប្រកបរបររកស៊ីជាគ្រហស្ថវិញ ។ នៅពេលដែលបុរសទៅរៀននៅវត្ត ស្ត្រីភេទពុំបានរៀនសូត្រជ្រៅជ្រះទេ ។ គេអប់រំនៅតាមផ្ទះ ឬតាមត្រកូល ដែលមានលទ្ធភាពពេលចូលម្លប់ ។ យើងអាចដឹងរឿងទាំងអស់នេះបាន តាមរយៈរឿងផ្កាស្រពោនរបស់លោក នូ ហាច ។ នាងវិធាវី រៀនអក្សរនៅផ្ទះជាមួយអ្នកជិតខាង ។ ប្រការដែលសំខាន់នោះ គឺការប្រើប្រាស់ចំណេះដឹងមូលដ្ឋានខាងភាសា និងអក្សរ ដើម្បីស្រូបយកចំណេះវិជ្ជាផ្សេងៗទៀត តាមរយៈការអាន ។ អានច្រើនកាលណា ធ្វើអោយចំណេះកាន់តែទូលាយ បញ្ញាកាន់តែភ្លឺស្វាង នឹងឈានទៅរកការបង្កើតថ្មី ការសរសេរ ការកត់ត្រា ការតែងនិពន្ធថ្មី ។ ប្រទេសសម្បូរទៅដោយអ្នកប្រាជ្ញទៅបាន លុះត្រាតែមនុស្សនៃប្រទេសនោះចេះអក្សរ ដោយភាគច្រើនចូលចិត្តអាន មានការបោះពុម្ពផ្សាយរីកចំរើន មានសៀវភៅសម្បូរបែប ការចែកចាយសៀវភៅទៅដល់គ្រប់ផ្ទះ គ្រប់សាលា និងមានបណ្ណាល័យសម្បូរបែប ។ ដូច្នេះ បណ្ណាល័យមិនមែនមានតែសៀវភៅចាស់ៗទេ ត្រូវតែមានសៀវភៅថ្មីជានិច្ច ត្រូវតែមានពត៌មានថ្មីៗ សំរាប់ផ្តល់អោយអ្នកអាន ។ សៀវភៅថ្មី ឯកសារថ្មីនោះ ជាចំណីធ្វើអោយបណ្ណាល័យរស់ ។ វត្តនីមួយៗ បើមានអគារជាបោរាត្រ័យ ឬជាបណ្ណាល័យហើយ គប្បីរសន្សំសៀវភៅ ឯកសារ រាប់តាំងពីព្រឹត្តិប័ត្រ កាសែត ទស្សនាវដ្តី សៀវភៅសព្វបែបយ៉ាង ទុកក្នុងបោរាត្រ័យ និងគប្បីសន្សំទុនទុកទិញសៀវភៅដែលបោះពុម្ពថ្មីៗផង ។ បោរាត្រ័យ ឬបណ្ណាល័យវត្ត ជា

*បណ្ណាល័យពហុភាព* ត្រូវមានសៀវភៅសំរាប់បំរើអ្នកអានគ្រប់ស្រទាប់ គ្រប់វ័យ ដែលរស់នៅជុំវិញវត្ត ។ សព្វថ្ងៃ ហោត្រ័យមានសៀវភៅធម៌ សៀវភៅទាក់ទង នឹងពុទ្ធសាសនាតែមួយមុខ សំរាប់តែព្រះសង្ឃប៉ុណ្ណោះ ។ ដូច្នេះ វត្តពុំបានបំរើ អ្នកអានជាសិស្ស និស្សិត កសិករ កម្មករ និងមនុស្ស ដែលមានមុខរបរផ្សេងៗ ទៀតទេ ។ ប្រទេសយើងជាប្រទេសកសិកម្ម ដូច្នេះ វត្តត្រូវតែមានឯកសារស្តីពី កសិកម្ម សំរាប់ប្រជាជនរស់នៅជិតវត្តអាន ។

ចំណុចសំខាន់មួយទៀតនោះ ខ្មែរយើងបាត់បង់ទម្លាប់នៃការកត់ត្រា ។ ការកត់ត្រាជាដើមចមនៃការនិពន្ធ, គ្មានការកត់ត្រា គឺគ្មានការនិពន្ធ, គ្មានអ្នកនិពន្ធ គឺគ្មានសៀវភៅ គ្មានសាស្ត្រា គឺគ្មានចំណេះដឹង និងវិជ្ជា, គ្មានចំណេះដឹង និងវិជ្ជា គឺ គ្មានវប្បធម៌ អក្សរសាស្ត្រ, គ្មានវប្បធម៌ អក្សរសាស្ត្រ គឺគ្មានតម្លៃ គ្មានកេរ្តិ៍ឈ្មោះ។

ខ្មែរបុរាណមានទម្លាប់រក្សាទុកនូវពិសោធន៍អោយបច្ឆាជនណាស់ ។ លោកបានចារលើថ្ម ចារលើស្បែកសត្វ លើសំបកឈើ លើស្លឹករឹត រហូតដល់ពេល មានក្រដាស ក៏សរសេរលើក្រដាសទៀត ។ ការនិពន្ធ ការបង្កើតថ្មី ជាចរិតរបស់អ្នក និពន្ធខ្មែរពីបុរាណ ។ ប្រសិនបើមានអ្នកនិពន្ធខ្លះបកប្រែពីបរទេស និងធ្វើអនុកម្ម(*) ក៏មិនយកតាមរបស់គេទាំងដុលដែរ ។ ប្រសិនបើគ្មានការឧស្សាហ៍ព្យាយាមកត់ត្រា ម្ល៉េះសមយើងគ្មានអ្វីសំរាប់ធ្វើជាសំអាងសំរាប់រៀនដល់សព្វថ្ងៃនេះទេ ។ ប៉ុន្តែ នោះ ជាសៀវភៅ ក្បួនខ្នាត ដែលយើងមានសល់ដ៏តិចតួចបំផុត ។ យើងគួររំលឹកថា ឯកសារ ក្បួនខ្នាតរបស់យើង ត្រូវសត្រូវដុតបំផ្លាញច្រើនលើកច្រើនសាមកហើយ ទើបយើងមិនសូវមានសេសសល់អ្វីប៉ុន្មានមកដល់សព្វថ្ងៃ សូម្បីតែស្នាដៃដែលដូន តាខ្មែរយើងបានកសាងទុកអោយយើងហើយ ក៏យើងជាកូនចៅមិនយល់ មិនដឹង និងមិនជឿថា នោះជាស្នាដៃរបស់ដូនតាឯងស្ថាបនាថែមទៀត ។ តួយ៉ាងដូចជា

---

(*) អនុកម្ម = ការធ្វើតាម

ប្រាសាទអង្គរវត្ត គេនាំគ្នានិយាយថា ព្រះពិស្ណុការចុះមកកសាងថ្វាយព្រះកេតុមាលា ទេវិញ ទោះបីមានសិលាចារឹកបញ្ជាក់ថា ជាស្នាដៃរបស់ស្ថាបនិកខ្មែរ នៅក្នុងរាជ្យព្រះបាទសុរិយាវរ្ម័នទី ២ កសាងនៅដើមសតវត្សទី ១២ ក៏ដោយ ។

នៅក្នុងឆ្នាំ ១១៧៧ ឯកសារខ្មែរនៅទីក្រុងអង្គរ ត្រូវចាមដុតបំផ្លាញម្តង ។ ក្រុងអង្គរត្រូវសៀមដុតបំផ្លាញ នៅក្នុងឆ្នាំ ១៤៣០ អ្នកប្រាជ្ញជាច្រើនរបស់យើងត្រូវគេចាប់យកទៅស្រុកសៀម ។ ការដុតបំផ្លាញលើកនេះ យើងគ្មានសេសសល់អ្វីទេ ។ ឯកសារដែលនៅសល់ មាននៅតែតាមវត្តអារាម តាមខេត្តឆ្ងាយៗ ពីទីក្រុងតែប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបគេបានសម្រេចបោះបង់ចោលក្រុងអង្គរ នៅក្នុងឆ្នាំ ១៤៣២ ។ នៅក្នុងឆ្នាំ ១៤៣២ គឺឆ្នាំដែលខ្មែរធ្លាក់ចុះលែងងើបមុខរួច ជារៀងរហូតដល់សព្វថ្ងៃនេះ ។ យើងបានប្រមូលឯកសារក្បួនខ្នាតជាថ្មីម្តងទៀតមកទុកនៅក្នុងបន្ទាយឫស្សីយ៉ាងមាំមួយ នៅក្រុងលង្វែក ។ មិនយូរប៉ុន្មាន ឯកសារដែលប្រមូលបាននោះ ត្រូវសៀមដណ្តើមយកម្តងទៀត នៅក្នុងឆ្នាំ ១៥៩៣ ដោយសារតែភាពអវិជ្ជានៃប្រជាជនខ្មែរ ។ ខ្មែរយើងស្ទើរតែគ្មានសល់ឯកសារសរសេរទៀតទេ ។ សូម្បីប្រវត្តិសាស្ត្រខ្លួនឯង ក៏ខ្មែរមិនដឹងថាកើតមកពីណា ហេតុអ្វីបានជាមានឈ្មោះយ៉ាងនេះ ? អ្វីៗដែលមានជាឯកសារឡើងវិញ ដោយសារពួកអ្នកប្រាជ្ញខ្មែរ និងបារាំង បានប្រមូលចងក្រង ដោយបង្កើតអោយមានបណ្ណាល័យពុទ្ធសាសន-បណ្ឌិត្យ នៅក្នុងឆ្នាំ ១៩២១ ។ ពីឆ្នាំនោះ មកដល់ឆ្នាំ ១៩៧៥ យើងមានឯកសារទាំងបោះពុម្ពហើយ ទាំងមិនទាន់បោះពុម្ព ប្រហែល ៣០,០០០ ចំណងជើង ។ ក្នុងនោះ មានស្នាដៃសំខាន់ៗខាងអក្សរសាស្ត្រខ្មែរ ក្បួនច្បាប់ទាក់ទងនឹងប្រពៃណីទំនៀមទម្លាប់ខ្មែរ និងគម្ពីរដីកាពុទ្ធសាសនា មានគម្ពីរព្រះត្រៃបិដកបាលី-ខ្មែរជាដើម ។ ប៉ុន្តែ ឯកសារទាំងអស់នោះ ត្រូវពួកខ្មែរក្រហមបំផ្លាញខ្ទេចខ្ទីជាលើកចុងក្រោយបំផុត ។ លើកនេះ យើងគ្មានសល់អ្វីទាំងអស់ បណ្ណាល័យក៏វាបំផ្លាញគ្មាន

សល់ វត្តក៏វាបំផ្លាញ ព្រះសង្ឃក៏វាធ្វើគត់ អ្នកប្រាជ្ញក៏វាសម្លាប់ នោះគឺ អស់ទាំងគ្រូ អស់ទាំងក្បួន ។

ឥឡូវនេះ អ្នកដែលធ្លាប់បានរៀនសូត្រពីមុនៗមក ក៏ចេះតែបោចទៅៗ តើបាននរណាបន្តចំណេះដឹង និងពិសោធន៍ ពីជំនាន់មុនទៅអោយជំនាន់ក្រោយទៀត ?

បើមនុស្សជំនាន់នេះមិនកត់ត្រាទុកអោយទេ នោះសមខ្មែរយើងនឹងក្លាយទៅជាជនជាតិមួយថ្មីទៀត ជាក់ជាមិនខានឡើយ ។ ហេតុនេះហើយបានជាក្នុងពេលដែលយើងនៅមានឱកាសខ្លះនេះ វត្តនីមួយៗត្រូវតែប្រមូលផ្តុំចាស់ព្រឹទ្ធាចារ្យ ដែលចេះចាំរឿងរ៉ាវផ្សេងៗ មិនថាធម៌អាថ៌ អក្សរសាស្ត្រ អក្សរសិល្ប៍ សិល្បៈសិប្បកម្ម ភ្លេង របាំ អោយតែចេះ គប្បីប្រញាប់ប្រញាល់នាំគ្នាកត់ត្រា ចងក្រងទុកក្នុងបណ្ណាល័យ អោយបានគ្រប់ៗវត្ត ។ នៅប្រទេសជិតខាងយើង គេកំពុងសន្សំឯកសារ និងកែច្នៃប្រវត្តិសាស្ត្រ គេកែរបស់យើងអោយទៅជារបស់គេ ។ គេខំបង្កើតរឿងថ្មី តែងនិពន្ធទុកអោយកូនចៅគេ ។ ចំពោះយើង សូម្បីតែឈ្មោះភូមិស្រុក ក៏មិនដឹងប្រវត្តិដែរ ។ សិប្បកម្មខ្លះ ត្រូវគេបោះបង់ចោល ថាឥតតម្លៃ ថាហួសសម័យ ហើយគេងាកទៅរករបស់ប្រណីត ទំនើប ដែលជារបស់នាំចូលពីបរទេសទៅវិញ ។ ពោលគឺ យើងលែងអោយតម្លៃខ្លួនឯង បង្អាប់ខ្លួនឯង លែងជឿលើខ្លួនឯង ។

ដើម្បីស្តារស្មារតី ស្តារព្រលឹងខ្មែរមកវិញ មានតែវត្តអារាម មានតែព្រះសង្ឃ មានតែលោកអាចារ្យ ចាស់ទុំជំនាន់នេះទេ ទើបអាចបំពេញភារកិច្ចនេះបាន ។ គឺនាំគ្នាស្តារតាមរយៈការងារស្រាវជ្រាវ កត់ត្រា ចងក្រង និងតម្កល់ទុកក្នុងបណ្ណាល័យ ឬ បណ្ណាល័យនេះឯង ។

យី ធន់

# ដើមកំណើតនៃស្លា-ម្លូ-កំបោរ

*ភ.ភ.ន.. ដូចអ្នកផងបានជ្រាបហើយថា តាំងពីសម័យដើម ប្រជាជនខ្មែរយើង ទាំងពីរភេទនិយមហូបស្លាម្លូណាស់ ។ ប្រពៃណីហូបស្លាម្លូនេះ មានតាំងពីសម័យបុរេប្រវត្តិមកម្ល៉េះ ។ ម្លូស្លាជាវត្ថុមានតម្លៃសំរាប់ទទួលភ្ញៀវ ជាគ្រឿងសិរីមង្គលសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ, ជានិមិត្តរូបនៃចំណងមេត្រីភាពរវាងមនុស្ស ។ នៅក្នុងពិធីមង្គលភ្ជាប់សិនេហាភាពរបស់ខ្មែរ ( ពិធីមង្គលអាពាហ៍ពិពាហ៍បញ្ជាប់ពាក្យ ) គេតែងយកស្លា-ម្លូ-កំបោរ-ថ្នាំ ធ្វើជារណ្តាប់នាំមុខនៃគ្រឿងបណ្ណាការនៅក្នុងពិធីនោះ ជាប់ជាទំនៀមតាំងពីបុរមបុរាណរៀងមក ដើម្បីសំដែងសេចក្តីគោរព និងកតញ្ញូតាធម៌របស់ភាគីខាងកូនប្រុស ចំពោះជីដូនជីតា ឪពុកម្តាយ ភាគីខាងកូនស្រី ។ តើប្រវត្តិនៃការនិយមហូបស្លាម្លូនេះ មានអត្ថប្រយោជន៍អ្វីខ្លះនោះ យើងគួរតែយល់ដឹងអំពីប្រវត្តិនៃវត្ថុទាំងបីមុខគឺ ស្លា ម្លូ កំបោរ ដែលចាស់ទុំយកមករៀបចំជាគ្រឿងបណ្ណាការនៅក្នុងពិធីនានារបស់ខ្មែរ ដូចតទៅនេះ ។*

## I. ប្រវត្តិនៃការស៊ីស្លាបញ្ជាប់ពាក្យ

**បញ្ជាប់ពាក្យ** តាមអត្ថន័យនៅក្នុងទម្រង់ការអាពាហ៍ពិពាហ៍ គឺពិធីជូនទ្រព្យរបស់អ្វីនិមួយទៅមាតាបិតាខាងស្រីទុកជាភ័ស្តុតាង ជារបស់បញ្ចាំចិត្តភ្ជាប់មេត្រីក្នុងការចងសម្ព័ន្ធ ។ មានរឿងតំណាលថា កាលណោះ មានបុរសពីរនាក់បានទៅសិក្សាក្បួនវិជ្ជាសិល្ប៍សាស្ត្រក្នុងសំណាក់គ្រូអាចារ្យម្នាក់ ។ សិស្សទាំងពីរបានត្រូវគ្នាធ្វើជាមិត្តសម្លាញ់ ។ លុះរៀនចប់ហើយ ក៏លាគ្រូអាចារ្យធ្វើដំណើរវិលត្រឡប់មកស្រុកកំណើតវិញ ។ បុរសទីមួយ និយាយទៅកាន់មិត្តខ្លួនថា អំណើះតទៅ ទោះបី

យ៉ាងណា ក៏យើងត្រូវរក្សាមិត្តភាព មេត្រីភាព របស់យើងឱ្យនៅគង់វង្សជារៀងរហូត ។ ពេលខាងក្រោយមក បុរសទាំងពីរមានប្រពន្ធ-កូនតែរៀងខ្លួន ។ សម័យថ្ងៃមួយនោះ ពេលដែលគេកំពុងឃ្វាលគោនៅឯវាលស្រែ បុរសដែលមានកូនប្រុសក៏ផ្ដើមនិយាយទៅកាន់សម្លាញ់របស់ខ្លួនថា ពេលនេះ កូនប្រុសខ្ញុំចម្រើនវ័យវឌ្ឍនាការពេញកំលោះហើយ ។រីឯកូនស្រីរបស់សម្លាញ់ឯង ក៏ពេញក្រមុំហើយដែរ ។ ខ្ញុំមានបំណងចងស្ពានមេត្រីផ្សារភ្ជាប់សាច់ឈាមជាមួយសម្លាញ់ ដើម្បីបានទៅជាដន្លងនឹងគ្នា ដោយស្នើសុំដណ្ដឹងកូនស្រីសម្លាញ់មកជាគូភរិយានឹងកូនប្រុសខ្ញុំ តទៅអនាគត ។ តើសម្លាញ់មានយោបល់យ៉ាងណាដែរ ? ។ ដោយហេតុតែអ្នកទាំងពីរធ្លាប់ដឹងចិត្ត ធ្លាប់ស្រឡាញ់គ្នាយ៉ាងស្មោះស្ម័គ្រនោះ ទើបបុរសដែលមានកូនស្រីស្រដីតបមកវិញថា ឱ ! សម្លាញ់អើយ ខ្ញុំពុំមានយល់ទាស់នឹងការស្នើសុំរបស់សម្លាញ់ទេ ខ្ញុំយល់ព្រមឱ្យកូនស្រីខ្ញុំបានជាគូនឹងកូនប្រុសសម្លាញ់ឯងហើយ ។ បុរសដែលមានកូនប្រុស មានចិត្តត្រេកអរក្រៃពេក គេក៏ចាប់ឱបគ្នាសំដែងនូវសញ្ចេតនាមេត្រីជិតស្និទ្ធ ។ ហើយដើម្បីទុកជាសក្ខីភាពនៃកិច្ចព្រមព្រៀងនេះ បុរសទាំងពីរក៏ស្រាយយកស្លា[១] ពីជាយកន្សែងមក ហើយប្ដូរគ្នាស៊ីទុកជាការភ្ជាប់ពាក្យ ឥតរើរុះប្រែប្រួលទៅថ្ងៃមុខ ។ ចាស់ៗខ្លះទៀត បានតំណាលថា បុរសទាំងពីរបរិភោគបាយកញ្ចប់រួមគ្នា រួចហើយទើបបរិភោគស្លាជាកិច្ចបញ្ជាប់ពាក្យ ។ ទំនៀមនេះបានបន្សល់ទុកជាពិធីស៊ីស្លាបញ្ជាប់ពាក្យ រហូតមកដល់សព្វថ្ងៃ ។ ( នៅស្រុកគិរីវង្ស ខេត្តតាកែវ នៅក្នុងពិធីអាពាហ៍ពិពាហ៍ បន្ទាប់ពីពិធីជូនផ្លែឈើធំរួចហើយ គេធ្វើពិធីហូបបាយកញ្ចប់ ចូលរួមដោយដន្លងប្រុសស្រី ព្រមទាំងស៊ីស្លាភ្ជាប់ពាក្យ ក្រោយបរិភោគបាយរួច ផងដែរ ) ។

---

(១) ស្លឹកម្លូដែលគេច្បៀកកំពោរ ដាក់គំណើតស្លា និងស្លាជ្វា បត់រញ្ចួលជាន់សន្លឹកគ្នា ទុកទំពាបំបាត់ក្លិនមាត់ ឬជូរមាត់ គេហៅថា ស្លាថ្នាត់ ក៏បាន ។

## ៣. ដើមកំណើតនៃស្លា ម្លូ កំបោរ (*)

មានរឿងតំណាលមកថា តាំងពីយូរលង់ណាស់មកហើយ មានបងប្អូនកំព្រាប្រុសពីរនាក់នៅរួមសុខរួមទុក្ខជាមួយគ្នា ពុំដែលមានហេតុទាស់ទែងអ្វីឡើយ ។ ក្រោយមក ក៏បានទទួលដំណឹងថាមានគ្រូអាចារ្យម្នាក់ ដែលនៅនគរក្បែរនោះចេះវិជ្ជាសិល្បសាស្ត្រផ្សេងៗ ។ បុរសទាំងពីរនាក់ក៏ចាកចេញពីផ្ទះ ដើម្បីស្វែងរករៀនវិជ្ជាពីគ្រូអាចារ្យនោះ ។ ពេលនោះ បុរសជាបងមានអាយុ ១៨ ឆ្នាំ ឯប្អូនអាយុ ១៦ ឆ្នាំ ។ លុះបានទៅដល់លំនៅរបស់លោកគ្រូនោះហើយ បុរសទាំងពីរក៏ធ្វើគារវកិច្ចលំឱនកាយគោរពគ្រូអាចារ្យសុំស្នាក់នៅជាមួយ ដើម្បីបានរៀនវិជ្ជាផ្សេងៗ ។ កាលបើបានសង្កេតឃើញឫកពាសុភាពរាបសា របស់បងប្អូនទាំងពីរនាក់ នេះហើយ គ្រូអាចារ្យក៏ព្រមឱ្យនៅ និងជួយបង្រៀនចំណេះសព្វសារពើទៀតផង ។

ក្រោយពីការសិក្សាអស់រយៈពេលពីរឆ្នាំមក ដោយបានសង្កេតឃើញកិរិយាមារយាទល្អល្អះត្រឹមត្រូវ និងឧស្សាហ៍ព្យាយាម ឆ្លាតវាងវៃ របស់យុវជនទាំងពីរនាក់ លោកអាចារ្យពេញចិត្តណាស់ ហើយគាត់ក៏សុខចិត្តលើកកូនក្រមុំឈ្មោះនាង « មណី » ដែលទើបនឹងមានអាយុគម្រប់ ១៥ ឆ្នាំ ប្រកបដោយរូបឆោមលោមពណ៌ល្អ គួរជាទីចាប់ចិត្តមេត្រីនោះផ្សំផ្គុំឱ្យនាយ « សុដា » ។

ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយនាងមណីមក នាយសុដា ហាក់ដូចមិនសូវមានការរីករាយស្រស់ស្រាយជាមួយ « សុដ្ឋា » ជាប្អូនសោះ ព្រោះខ្លួនតែងតែមានមហិច្ឆតាលោភលន់គិតចង់បានបុណ្យសក្តិខ្ពង់ខ្ពស់ ។ សុដា តែងគិតជញ្ជឹងថា នៅពេលដែលបានសិក្សាចប់សព្វគ្រប់មុខវិជ្ជាទាំងអស់នោះហើយ គេនឹងបានទៅជាមនុស្សជាទីគាប់ព្រះទ័យរបស់ព្រះរាជា ។ រាល់ថ្ងៃ នៅពេលទំនេរពីការងារ

(*) ដកស្រង់ និងកែសម្រួលពីអត្ថបទ របស់លោក តៀង ឆួរ ពាក្យរឿងរបស់លោក ពៅ ធារតេង បោះពុម្ពផ្សាយក្នុងសៀវភៅ « ពីនិទាន » ។

ផ្សេងៗ គេបានដើរទៅជិតប្រពន្ធ ហើយនិយាយសាសងគ្នាដោយសំដីផ្អែមពិរោះ ។

រីឯនាយសុដ្ឋាវិញ, លុះបានឃើញអាកប្បកិរិយារបស់បងខុសប្លែកដូច្នេះ, ក៏ស្រងាកចិត្ត ហើយម្តងៗ គេស្ទើរតែអស់សង្ឃឹមនៅក្នុងឆាកជីវិត ដោយចេះតែនឹកគិតថា មិនដឹងជាប្រកបមុខរបរអ្វីមួយដើម្បីអាចរស់នៅបាន ។ ពិបាកខ្លាំងជាងនេះទៀត គឺដោយឃើញបងប្រុសរបស់ខ្លួនធ្វើព្រងើយ តោះតើយ ពុំមានសាទររាក់ទាក់ជាមួយខ្លួនដូចពីមុនឡើយ ។ កំព្រាឪពុកម្តាយហើយ ត្រូវឆ្អែតចិត្តនឹងបងទៀត នាយសុដ្ឋា ក៏សម្រេចចិត្តគេចខ្លួនចេញឱ្យផុតពីកន្លែងដែលផ្តល់តែភាពខ្មោងងឹតចំពោះខ្លួន ។ ថ្ងៃមួយ សុដ្ឋាចាកចេញពីផ្ទះពុំឱ្យអ្នកណាដឹងឡើយ ។ ទៅដល់មាត់ស្ទឹងមួយ យុវជនអភ័ព្វក៏អង្គុយយំសោកនៅក្រោមដើមជ្រៃមួយដើម ដ៏មានមែកសាខាត្រសុំត្រសាយ ដោយក្តីអស់សង្ឃឹម ។ លុះរាត្រីកាលមកដល់ យុវជនកំសត់ក៏បរិភោគអាហារបន្តិចបន្តួច រួចក៏ដេកលក់ក្រោមព្រឹក្សានោះទៅ ។ ក្នុងពេលនិទ្រា សុដ្ឋាហាក់បានឃើញមនុស្សម្នាក់មានមាឌធំសម្បើមឈរយ៉ាងសង្ហា ដៃម្ខាងកាន់ដំបងយ៉ាងធំ ហើយស្រែកគំរាមថា នែ ! អាឯងមកពីណា បានជាចូលមកស្នាក់នៅកន្លែងអញ ដោយគ្មានអុជទៀនធូបបូជាចំពោះអញសោះយ៉ាងនេះ ? ព្រោះតាមទំនៀមពីដើមរៀងមកនរណាក៏ដោយឱ្យតែមកទិនេះ ត្រូវតែគោរពបូជាអញ ។ សុដ្ឋាភ័យញាប់ញ័រ ហើយខំនិយាយអង្វរលន់តួថា ឱ ! លោកតា ជាទីគោរពអើយ សូមលោកមេត្តាប្រណីអត់ទោសឱ្យខ្ញុំផងចុះ ព្រោះខ្ញុំជាមនុស្សមានទុក្ខ លំបាកវេទនាណាស់ បើលោកម្ចាស់ដឹងរឿងខ្ញុំ លោកមុខជាអាណិតខ្ញុំមិនខាន ។ អ្នកតានោះតបថា អញគ្មានមេត្តាអ្នកណាទេ បើអ្នកណាមកកាន់ទីនេះហើយ ខ្វះការគោរពចំពោះអញ អ្នកនោះនឹងត្រូវអស់ជីវិត ។ ពោលដូច្នេះហើយ អ្នកតាកំណាចក៏លើកដំបងចង្អុលទៅសុដ្ឋា ដោយសែកមន្តគាថា ធ្វើឱ្យសុដ្ឋាក្លាយទៅជាថ្មមួយដុំមានពណ៌សស្អាតស្ថិតនៅត្រង់ទីដែលនាយសុដ្ឋាដេកនោះទៅ ។ ឯអ្នកតាចិត្តឃោរឃៅនោះ ក៏

អន្តរធានបាត់ក្នុងពេលនោះដែរ ។

ថ្លែងពីនាយសុជា ជាបង កាលបើបានដឹងថាប្អូនកំសត់រត់បាត់ពីផ្ទះ មិនដឹងទៅទីណាដូច្នេះ គេក៏កើតទុក្ខមុខស្រពោនសៅ នឹករអាណិតប្អូនដែលធ្លាប់កំសត់កម្រជាមួយគ្នា ក្នុងនាមជាកូនកំព្រាឪពុកម្ដាយ គ្មានទីពំនឹង ។ ដោយមិនអាចទ្រាំនៅបានតទៅទៀត នាយសុជា ក៏លាប្រពន្ធ និងឪពុកក្មេក ធ្វើដំណើរតាមរកប្អូន ។ ទោះបុរសនោះខំស្វះស្វែងរកប្អូនសព្វទីកន្លែង ក៏នៅតែរកមិនឃើញ ។ ទីបំផុត នាយសុជាបានទៅដល់ដើមជ្រៃធំនោះទៀត ។ អាស្រ័យដោយការធ្វើដំណើរផ្លូវឆ្ងាយអស់រយៈពេលជាច្រើនថ្ងៃ នាយសុជា ក៏ប្រះខ្លួនដេកផ្អែកលើដុំថ្មលង់លក់ក្រោមដើមជ្រៃនាមាត់ស្ទឹងនោះទៅ ហើយក៏បានជួបនឹងឧបទ្ទវហេតុ ដូចសុដ្ឋាជាប្អូនដែរ ។ អ្នកតាកំណាចស្រែកកំហែងគំរាមទៅសុជាថា អាក្មេងចង្រៃ ឯងមកពីណា ហើយទៅណាបានជាមកស្នាក់នៅកន្លែងអញ ដោយឥតបានស្នើសុំអញជាមុនដូច្នេះ ? សុជាភិតភ័យស្ទើរបាត់ស្មារតី អង្វរអ្នកតាកំណាចថា ឱ ! លោកតាអើយ ខ្ញុំមកតាមរកប្អូនប្រុសម្នាក់ មិនដឹងជាទៅឯណាបាត់អស់ចំនួនច្រើនថ្ងៃមកហើយ បើលោកតាបានឃើញ មេត្តាជួយប្រាប់ខ្ញុំផង ។ ម្យ៉ាងទៀត ខ្ញុំបានជាជ្រុលខ្លួនចូលមកដល់ទីកន្លែងលោកតាទៅហើយ សូមលោកមេត្តាអនុញ្ញាតឱ្យជ្រកកោនបានមួយយប់ផង, ថ្ងៃស្អែក ខ្ញុំនឹងធ្វើដំណើរទៅមុខទៀត ។ អ្នកតាព្រៃនោះ ក៏ពោលពាក្យទ្រគោះបោះបោកតបមកវិញថា បើអាឯងចង់ជួបនឹងប្អូនអាឯងមែន, មិនអីទេ អញធានាឱ្យជួបបាន ។ ន៉ុះន៏ ! ថ្មសស្ដុសមួយដុំនេះហើយ ដែលជាប្អូនរបស់ឯង ចូរអាឯងទៅជួបវាចុះ ។ ថាតែប៉ុណ្ណោះ អ្នកតាកំណាចក៏សែកមន្ត-អាគម រួចលើកដំបងចង្អុលទៅរកសុជា ធ្វើឱ្យសុជាក្លាយទៅជាស្លាមួយដើម ដុះនៅប្របដុំថ្មនោះទៅ ។ ឯរូបអ្នកតា ក៏រលាយបាត់ក្នុងពេលនោះដែរ ។

ចំណែកឯនាង ចណី ជាប្រពន្ធ, ក្រោយពីបាត់ប្ដីអស់រយៈពេលជាច្រើន

ថ្ងៃ ពុំឃើញត្រឡប់មកផ្ទះវិញ ទាំងពុំបានទទួលដំណឹងថាគេទៅដល់ទីណា រកប្អូន ឃើញ ឬពុំឃើញនោះ, នាងមានកង្វល់យ៉ាងខ្លាំង ។ ដោយទឹកចិត្តអាឡោះអាល័យ ស្រឡាញ់ប្តីសំណព្វចិត្ត និងដោយក្តីអាណិតស្រឡាញ់ប្អូនថ្លៃ, ទោះបីឪពុកម្តាយ ឃាត់យ៉ាងណា ក៏នាងសម្រេចចិត្តទៅតាមរកបុរសបងប្អូនទាំងពីរនាក់ទាល់តែបាន ។ ដោយសារដំណើរផ្លូវឆ្ងាយ, ណាមួយខ្លួនជាស្រី កម្លាំងក៏ខ្សោយ នាងក៏បានទៅដល់ ដើមជ្រៃធំនៅមាត់ស្ទឹង នៅពេលពន់ព្រលប់ ។ គ្រាន់តែទម្លាក់ខ្លួនប្រះដេកលក់ភ្លាម នៅក្បែរដុំថ្ម និងដើមស្លា អ្នកតាចិត្តខ្មៅ ក៏បានមកគំហកគំរាមកំហែងយ៉ាងនេះថា អ្នកដែលមករំលោភឈ្លានពានទីកន្លែងអញ ដោយគ្មានការអនុញ្ញាត នឹងត្រូវវិនាស ។ នាងមណី ក៏អង្វរអ្នកតាកំណាចថា ឱ ! លោកតាអើយ មុនលោកតាសម្លាប់ខ្ញុំ យ៉ាង ហោចណាស់ សូមឱ្យខ្ញុំបានឃើញមុខប្តី និងប្អូនថ្លៃសិន ។ អ្នកតាឆ្លើយចំអកឱ្យ នាងថា បាន, អញឱ្យនាងឯងជួបគេទាំងពីរតាមបំណង ។ នុ៎ះ ! ដុំថ្មពណិសរលីងនេះ គឺជាប្អូនថ្លៃឯងឈ្មោះសុដ្ឋា ឯដើមស្លាដែលនាងឯងដេកផ្អែកទៅលើនេះ គឺជា ប្តីរបស់នាង ។ ឥឡូវ ចូរនាងទៅជួបជុំគ្នាចុះ ។ ថាតែប៉ុណ្ណោះ ដោយអំណាចសិល្ប៍ គាថារបស់អ្នកតាដើមជ្រៃ នាងមណីក៏ក្លាយទៅជាទងម្លូខ្ចីល្អក់ វារឡើងដើមស្លា នោះ ព្រមជាមួយនឹងការរលាយបាត់រូបអ្នកតានោះដែរ ។

ក្នុងកាលជាចំណោរតមក មានព្រះរាជាមួយអង្គបានកែនរេហ៍ពលទៅ ប្រពាតព្រៃ បានយាងដល់ដើមជ្រៃបែកមែកសាខា ហើយទ្រង់ទតឃើញដុំថ្មពណិ សស្អាត ដើមស្លា និងម្លូ ដុះប្រពាក់ប្រព័ន្ធគ្នា គួរឱ្យកើតក្តីងឿងឆ្ងល់ពន់ពេក ។ ព្រះអង្គទ្រង់ត្រាស់សួររកអ្នកដែលដឹងអំពីប្រវត្តិនៃវត្ថុទាំងបីមុខនេះ ។ អ្នកស្រុកនៅ ជិតខាងនោះ ដែលបានដឹង និងឃើញហេតុការណ៍ច្បាស់ ក៏ក្រាបទូលព្រះរាជា តាម ដំណើរសាច់រឿង ។ ដើម្បីជាការពិសោធន៍ ព្រះអង្គទ្រង់ត្រាស់បង្គាប់ឱ្យសេវកា-មាត្យយកផ្លែស្លា ស្លឹកម្លូ ទៅដាក់លើដុំថ្មនោះ រួចចាក់ស្រាពីលើវត្ថុទាំងបី ។ គ្រានោះ

វត្ថុទាំងបី ក៏រលាយក្លាយទៅជាទឹកមានពណ៌ក្រហមដូចឈាម ហូរធ្លាក់ទៅលើព្រះធរណី ។ ព្រះរាជាទ្រង់ទតយល់អំពីបាតុភូតនេះហើយ ទ្រង់ក៏ល្ងើងយល់ថា កាលពីជាតិមុន អ្នកទាំងបីនាក់នេះស្រឡាញ់គ្នាស្និទ្ធស្នាល ចិត្តមួយថ្លើមមួយ បានជាពេលបានមកកើតជាធាតុសិលា និងរុក្ខជាតិហើយ នៅតែរួមផ្សំផ្សារសាច់ឈាមជាមួយគ្នាបែបនេះទៀត ។

ដោយព្រះអង្គចង់រក្សាបាតុភូតដ៏ចម្លែកនេះអោយមានអនុស្សាវរីយ៍ចងចាំនៅក្នុងព្រះទ័យឥតភ្លេច, ព្រះអង្គក៏បានដាក់បញ្ញត្តិឱ្យអស់អាណាប្រជានុរាស្ត្រយកវត្ថុទាំងបីមុខ ពោលគឺ ម្លូ ស្លា និងកំបោរ ធ្វើជាសិរីមង្គលក្នុងពិធីនានា មានពិធីបង្កក់កូនខ្ចី ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីចូលម្លប់-ចេញពីម្លប់ ពិធីកោរជុក ពិធីសែនព្រេន និងពិធីលៀងអារក្ស ជាដើម ។

## III. អត្ថប្រយោជន៍នៃការហូបស្លាម្លូ

ស្លឹកម្លូ និងផ្លែស្លា មានជ័រជាតិវីតាមីនសេ (vitamine c), កំបោរមានជាតិកាល់ស្យូម (calcium) បានមកពីការដុតថ្ម សម្បកលៀស ឱ្យឆេះសុស ។ ហេតុនេះ ម្លូ ស្លា និងកំបោរ គឺជាថ្នាំពិសិដ្ឋ សម្រាប់ធ្វើជាចំណីទំពាបំបាត់ក្លិនមាត់ ធ្វើឱ្យធ្មេញមានពណ៌ខ្មៅ រឹងមាំ និងធ្វើឱ្យបបូរមាត់មានព័ណ៌ក្រហមស្រស់ ។ ម្លូស្លាជាវត្ថុមានតម្លៃសម្រាប់ទទួលភ្ញៀវ ជានិមិត្តរូបនៃចំណងមេត្រីភាពរវាងមនុស្ស ។ បច្ចុប្បន្ន ទោះបីប្រជាជនភាគច្រើនមិននិយមហូបម្លូស្លា តែវត្ថុទាំងបីនេះ នៅតែមានអត្ថិភាព និងមានវត្តមាននៅក្នុងពិធីមង្គលផ្សេងៗរបស់ខ្មែរ ដែលឆ្លុះបញ្ចាំងនូវនិរន្តរភាពនៃទំនៀមទម្លាប់ខ្មែរ ។

រៀបរៀងដោយ **មៀច ប៉ុណ្ណ**

កែសម្រួលដោយ **ឱម ខែម**

# ចិត្តមិនព្រមចាស់

និយាយពីចិត្តមិនព្រមចាស់ ចិត្តនេះខូចណាស់ក្រាស់មុខរឹង
សាំងជ្រកពួនក្នុងខ្លួនហ្នឹង យកជាទីពឹងអាស្រ័យនៅ ។
ខ្លួនធ្លាក់ក្នុងភ័យវ័យជរា ទ្រុឌទ្រោមគ្រាំគ្រាយ៉ាប់យ៉ឺនទៅ
សាច់ស្បែកជ្រួញជ្រីវអ៊ីវជាតិជៅ ភ្នែកក្រូងខូងជ្រៅដូចរន្ធឡូ ។
ធ្មេញបាក់សក់ស្កូវផ្លូវអីទៀត តែចិត្តមានស្នៀតឆ្លៀតកក្កូរ
នៅឆ្លៀតកកាយស្តាយជាយថ្ងូ ចង់ណាស់បោះឡូដូចក្មេងក្មាង ។
ខ្ញុំមិននិយាយទាយចិត្តស្រី មិនកើតទេរ៉ឺអស់ទីអាង
តែស្រីៗខឹងប៉ឹងតឹងតាង អីវ៉ាន់ខេងខាងចាក់សោក្រឹប ។
និយាយតែចិត្តប្រុសគ្នាយើង មិនសូវនាំភ្លើងដើងដើរខ្សឹប
កិច្ចការជ្រៅរាក់លាក់លបឡឹប ឡកលេងកេងកឹបគ្នាយើងស្រាប់ ។
ធម្មតាចិត្តប្រុសមានខុសគ្នា មានខូចមានជាក្រៅក្នុងច្បាប់
ប៉ុន្តែរឿង « ចាស់ » ចិត្តមិនស្តាប់ លុះតែរូបស្លាប់ទើបអស់ផ្លូវ ។
សម្រុកសព្វថ្ងៃថ្មៃយ៉ាងណា បានតាមប្រាថ្នារឿងសក់ស្កូវ
មានថ្នាំក្រូមេកែតម្រូវ លាបលនលុបផ្លូវខ្មៅរលោង ។
ឱ្យខ្មៅលង់តង់ភាពដើម ប្រេងផ្សៀមប្រោះផ្សំខំឃើតយោង
ទោះធ្មេញបាក់ទៀតឆ្លៀតលៃលោង មានគ្រឿងជ្រែងជ្រោងគ្រប់សណ្ឋាន ។
ឧបករណ៍ជំនួយជួយវ័យចាស់ មានច្រើនម៉ាកណាស់ផ្លាស់ប្តូរបាន
សម្រាប់តុបតែងលំអប្រាណ ឱ្យតែលុយមានគ្មានក្រអ្វី ។
តែទុកជាចិត្តឥតគ្រឿងអាង ទាំងប៉ុន្មានយ៉ាងដូចពោលស្តី
ក៏ចិត្តប្រុសយើងក្នុងលោកិយ ឥតបីព្រមចាស់ក្រឡាស់ប្រែ ។

មានតាខ្ញុំម្នាក់ធ្លាក់វ័យចាស់ ចិត្តសិបប្លាយច្បាស់ក៏ប៉ុន្តែ
ក្មេងៗហៅតាជេរដល់ម៉ែ ចូនពិតហួរហៅតាមតែថា ។
អាចោរខ្មោចក្មេងលេងមើលងាយ តើអញយកយាយឯងកាលណា
ក៏មកហៅអញថា តា តា អាចោរមោហាប្រយ័ត្នផ្លោង ។
ពាក្យសល់ឯទៀតមិនឆ្ងៀតហៅ ម៉ែចនាំកំដៅអាតែហោង
អាចោរតែហឹតក្រអឹតកោង ក្រោយៗឯងពោងដឹងឱ្យច្បាស់ ។
តាខ្ញុំគាត់ខិលរឿងមួយទៀត គាត់ខំប្រឹងឆ្ងៀតពែងខ្លួនណាស់
ចូលចិត្តតែលេងល្បែងផ្ដាំចាស់ ប្ដូរផ្លាស់គិតតែលៃរឿងហ៊ុំង ។
មានស្រីខូចខិលគីលត្រង់ណា ទោះនៅទីផ្សារឬក្រៅក្រុង
គាត់ញៀនញីកញាប់ជាប់ចិត្តស្លុង វិលក្បុងផុងខ្លួនពួនត្រង់នោះ ។
ស្រីខូចឃើញតាពីចម្ងាយ ស្រស់ស្រោយរាក់ទាក់យាក់ចិត្តស្មោះ
ហ៊ឺះនុ៎ះមកហើយបងកំឡោះ ខ្ញុំអរដូចហោះបានជួបបង ។
នាំគ្នាស្ទុះចុះទៅទទួល បបួលគ្នីគ្នាគ្រាហ៊ីអែបអង
អួសដាក់លើពួកល្ងូនកេះខ្នង ផ្សៀងផ្អងផ្ដេកផ្ដិតកិតកៀកកាយ ។
ខ្លះគក់ច្របាច់កាច់ជើងដៃ ខ្លះចាប់សរសៃស្ទាបនាយអាយ
បញ្ចោរបញ្ចើចសើចក្អាកក្អាយ តាខ្ញុំសប្បាយព្រើបេះដូង ។
យកអីយកទៅពៅបងអើយ ដល់ថ្នាក់ហ្នឹងហើយតាយល់ស្លូង
យល់សព្វឃើញគាត់ធ្លាក់អណ្ដូង ជ្រោះជ្រៅស្រឡូងខ្វងភ្នែកស្លឹង ។
មិនមែនតែតាខ្ញុំមួយទេ ទោះទាំងតាគេរឿងត្រង់ហ្នឹង
យាយជេរម្ដេចក្ដីមិនខ្លីខឹង តាប្រឹងលៃលងព្រួយពួយអស់ដៃ ។
គាត់ថាដូចជារបស់ទ្រព្យ កាលណាគាត់ងាប់ជីវិតក្ស័យ
កូនចៅផ្ទុងឱ្យដោយច្រើនក្រៃ ចង្រៃរឿងហ៊ុំងផ្ទុងមិនបាន ។

ដូច្នេះទើបតាគាត់ខំប្រឹង បំពេញកិច្ចហ្នឹងកុំឱ្យខាន
ទោះអស់សោហ៊ុយលុយប៉ុន្មាន ប្រថុយប្រថានប្រាណផ្ដាំចាស់ ។
ជួនកាលតាខ្ញុំជួបមិត្តភក្តិ បើគេភក់ទាក់តាត់ជោរណាស់
ឮពាក្យថា « យើ ! ម្ដេចក្រចាស់ ? ដូចជាអត់ផ្លាស់នៅដដែល ។
ខានបានជួបគ្នាប៉ុន្មានឆ្នាំ សាច់នេះហៅចាំអាយុព្រៃល
តែដូចកំឡោះស្មោះដដែល រកមនុស្សប្រហែលធីនេះក្រ » ។
ពាក្យគេបញ្ជោរលើកបញ្ជើច តាខ្ញុំគាត់សើចមាត់ច្រហ
ញញឹមបីថ្ងៃជាប់បន្ត អរអើយសែនអរនេះតាខ្ញុំ ។
ឱ្យតែអ្នកណាចេះបញ្ជោរ គុយទាវពោះគោចាយលុយដុំ
បើទៅទីណាមានក្រមុំ ញ៉េះញ៉ោះចេះសុំតាឱ្យម៉ត់ ។
ការីមីឆាស្រោបង្អែម ចៅពីតតែព្លែមតាស៊ូអត់
យាយនៅឯផ្ទះធ្វើការបាត់ តាខ្ញុំគាត់ក្បត់អត់បានឆ្ងាញ់ ។
កាលយាយខ្ញុំដឹងខឹងច្រឡោត កញ្ចាស់នៅឆោតឯងក្បត់អញ
ឃើញមុខកាលណាផ្សាក្ដៅក្នាញ់ ឱ្យគេចំរាញ់ចាញ់បោកគេ ។
ចាស់ឡើងព្រើលឡើងដូចឆែយ៉ាំ ភ្លេងនេះបានផ្ដាំចាំឬទេ ?
មរណៈចូលជិតរីតខ្លួនទ្វេ ចាស់ចើកខុសគេចាស់ចំកួត ។
តាខ្ញុំខំអត់អំណត់ដែរ ប៉ុន្តែយាយខ្ញុំផ្តុំរឿងត្រួត
តានឹកខឹងខ្លាំងតាំងប្រកួត « មេចោរឆ្កែឆ្កួតអួតពូកែ ។
ឃើញអញស្ងៀមឈឹងរឹងរឹតណាស់ ខ្មោចមេកញ្ចាស់មិនមែនម៉ែ
តិចអត់មិនបានថាននៅក្បែរ បោកក្បាលបែកបែរចេញឈាមរ៉ាវ » ។
យាយខឹងខ្លួលឆេវឆ្លេវប្រញាប់ ស្ទុះភ្លែតលេងផ្ដាប់ចាប់កអាវ
កញ្ជក់បោកក្ដោបឱបក្រសាវ តារើចំប្រាវលោតឡើងផាក់ ។

យាយគេចរួចខ្លួនពួនក្បែរពាង តាដួលចង្ក្រានរាងដូចយក្ស
ស្មារតីយាយរឹងប្រឹងឥតអាក់ យាយស្ទុះភ្លែតពាក់ជិះលើតា ។
តាទីខ្វៃ-ខ្វៃដៃប្រឡេះ យាយប្រឹងកកេះខ្វេះក្តិចខ្វារ
តាដួលក្រឡាប់វិលផ្កាប់ផ្ងារ យាយសាត្រឡប់តប់តាម៉ាំង ។
តាទីខ្លួនរួចក្ដួចបួងដៃ « ខ្មោចមេចង្រៃចៃចោរខ្លាំង »
តាភ្លែតទៅទៀតឆ្លៀតពតពាំង យាយយឺតប្រឆាំងរាំងទទួល ។
តាចាប់យាយបានច្រានគ្រវាត់ ហើយស្ទុះទៅទាត់ភ្លាត់ជើងដួល
យាយមានទំនងរងយ៉ាងស្រួល ផែលអៀវចាប់មួលពងតាជាប់ ។
តាខ្ញុំខំស្រែកភ្អែកស្លោស្លឹង កុំលេងធមិតឹងមេត្រូវគ្រាប់
អែយ៉េះប៉ះចក់កន្លែងងាប់ ហាងផ្លាប់ដឹងទេមេចង្រៃ ។
លែងអញឱ្យឆាប់ប្រញាប់ភ្លាម តិចអញពួយថ្នាមហាងមួយដៃ
យាយថាកុំបាច់គិតសង្ស័យ បានដៃប៉ុណ្ណេះកេះមិនបាន ។
អញមួលត្របាច់ផ្តាច់អាយ៉ូស ឱ្យផុតខ្យល់ស្រួសប្រុសចែកឋាន
ឱ្យអស់ពុតខូចដូចតិរច្ឆាន ម៉េចនៅក្លាហានយ៉ាងណាទៀត ?
តាទីយាយរឹតមឹតមួលខ្លាំង តាឈប់តតាំងច្បាំងអស់ស្មៀត
វិះៗដាច់ខ្យល់ខ្វល់ចង្អៀត បែរបៀតស៊ុំចុះចំណុះយាយ ។
រឿងយើងប្រុសៗ ឈ្មោះនឹងស្រី មិនស្រួលទេវ៉ីកុំមើលងាយ
ប្រយ័ត្នប្រយែងស្មែងមួយផ្លាយ កុំទុកវាត់វាយយាយលេងម៉ត់ ។
ដំណាលពីចិត្តមិនព្រមចាស់ វាវែងឆ្ងាយណាស់សរសេរហត់
បែកដល់រឿងតាសង្កាក្បត់ យាយអៀវសង្កត់តាវិះងាប់ ។
ខ្ញុំសូមសន្មតកំណត់ស្លេះ បញ្ចប់ត្រឹមណេះឈប់រៀបរាប់
ចាំមានដំណើរប្រសើរគាប់ នឹងលែតភ្ជាប់រឿងទៅទៀត ។

ញ៉ូច សៀង

# មនុស្សលោកថ្មៃត្រៃលក្ខណ៍

( បទព្រហ្មគីតិ )

*យោងតាមពុទ្ធដីកា*
*ព្រះសាស្តាដ៏មានឫទ្ធិ　អ្វីៗតែងមានពិត　ទៅតាមក្រឹត្យក្រមសាកល ។*
*តួយ៉ាងដូចត្រៃលក្ខណ៍*
*ទាំងបីជាក់កុំងឿងឆ្ងល់　តែងតែកើតមានដល់　រាល់ៗរូបជាធម្មតា ។*
*ទីមួយអនិច្ចំ*
*ពីរទុក្ខំបីអនត្តា　ទាំងបីនេះហៅថា　ធម៌ត្រៃលក្ខណ៍ប្រចក្សក្រៃ ។*
*អនិច្ចំថាមិនទៀង*
*តែងតែល្អៀងប្រែកាឡៃ　កើតចាស់ឈឺរុំរ៉ៃ　រួចក្សិណក្ស័យអសារបង់ ។*
*ពីក្មេងសក់នៅខ្មៅ*
*រូបស្រងៅល្អផូរផង់　ភ្នែកភ្លឺថ្លាត្រចង់　ដំហារត្រង់សង្ហាក្រៃ ។*
*ចូលវ័យចាស់ជរា*
*កាយគ្រាំគ្រាប្រែក្រាស់ក្រៃ　រូបរាងសាច់សរសៃ　ស្បែកជ្រីវជ្រួញសាច់យុរយារ ។*
*ភ្នែកស្រែស្រវាំងព្រឹល*
*កើតមន្ទិលអស់អង្គា　អត្តភាពខ្សោយពុំជា　ជរាជាន់ឱ្យទ្រុឌទ្រោម ។*
*សក់ស្កូវត្រចៀកថ្លង់*
*ធ្មេញបាត់បង់បាក់ទាំងព្រម　បាក់រូបនិងបាក់នោម　រាងកញ្ជ្រោមបាត់សម្រស់ ។*

ពីមុនធ្លាប់ប្រិមប្រិយ
តែឥឡូវលែងល្អស្រស់ សោភ័ណបាត់បង់អស់ ធ្លាក់ថ្លោះធ្លោយទាំងប្រាជ្ញា ។
ភ្លឹកភ្លាំងភ្លេចមុខក្រោយ
គេប្រាប់ញយទើបដឹងការណ៍ ង៉េះង៉ោះខុសធម្មតា មិនក្លៀវក្លាដូចនៅក្មេង ។
ជរាចូលរុករាន
មានទាំងរោគាផ្សេងៗ ឈឺចាប់សោកសង្រេង រមែងមានក្តីទុក្ខា ។
ទុក្ខកើតពីមានកាយ
រូបអន្តរាយសូន្យអសារ មិនអាចមានជនណា រួចអាត្មាពីទុក្ខំ ។
អនត្តាមិនមែនខ្លួន
មិនខ្ជាប់ខ្ជួនអចិរំ (*) ប្រែប្រួលវិវត្តខ្លាំង មិនអាចតាំងស្ថិតស្ថេរនៅ ។
ប៉ុន្តែបុថុជ្ជន
គេគិតគន់មិនត្រឹមត្រូវ គេចង់កែតម្រូវ បំបែរផ្លូវទៅផ្តេសផ្តាស ។
ខ្លះខិតខំស្រាវជ្រាវ
រាវរិះរកវិទ្យាសាស្ត្រ ចង់កែកុនប្រែផ្លាស់ បញ្ច្រាសតបនឹងត្រៃលក្ខណ៍ ។
ផ្សែផ្សំខំបង្កើត
ផលិតថ្នាំសម្ភារៈ លាបសក់ខ្មៅដូចម្រ័ក្សណ៍ ចាស់ច្រើននាក់កើតចិត្តចង់ ។
ឱ្យខ្លួនក្លាយជាក្មេង
ព្រោះវង្វេងធមិពុទ្ធអង្គ មិនជឿមិនស្មោះត្រង់ ចង់ឱ្យសក់ប្រែជាខ្មៅ ។
ទិញថ្នាំមកលាបលន
សក់ពីមុនបាត់ពណ៌ទៅ បាត់អស់ពណ៌សស្គូវ ប្រែជាខ្មៅដូចសក់ក្មេង ។

---

(*) អចិរំ ( អ_ចិ_រ៉ាំង ) = មិនឋិតថេរ

ប៉ុន្តែគួរផ្អើលភ្ញាក់
សក់ខ្មៅដាក់រីសំឡេង មិនល្អដូចពីក្មេង ស្បែកនោះឯងរឹងជ្រួញយារ ។
ខ្នងកោងឥតប្រែត្រង់
គ្រចៀកថ្លង់កាយគ្រាំគ្រា មិនអាចមានវិទ្យា- សាស្ត្រឯណាកែកុនបាន ។
អន់ចិត្តនឹងធ្មេញបាក់
រត់ទៅដាក់ឱ្យបាត់ដាន ស្មាដៃជាងចំណាន បានដាក់ជួសធ្មេញកំណើត ។
បានសក់បានធ្មេញថ្មី
ទើបកែច្នៃឱ្យល្អឆើត ភ្លេចគិតថាកំណើត កែមិនកើតដូចចិត្តចង់ ។
មានថ្នាំកែសម្ផស្ស
ឱ្យស្បែកស្រស់ល្អផូរផង់ មានក្រែមលាបទ្រទ្រង់ ទឹកដោះគោគ្រាំផ្សាំស្បែក ។
កែទាំងមាត់ច្រមុះ
ឱ្យប្រែខុសឱ្យល្អប្លែក ទោះបីងងឹតភ្នែក មានវ៉ែនតាពាក់ភ្លឺវិញ ។
សង្ខារពាក់តែងហើយ
អស់លោកអើយកុំទោម្នេញ ជួសជុលពុំបានវិញ ដូចចិត្តប៉ងនោះឡើយណា ។
កែបានតែរូបភាព
តែពុំអាចកែខ្លឹមសារ ខាងក្នុងនោះយ៉ាងណា នៅយ៉ាងនោះឥតកែបាន ។
កែសក់លាបខ្មៅស្រស់
ចេញពណ៌អស់ឥតសល់ខាន គល់សក់ទាំងប៉ុន្មាន ឡើងពណ៌សដូចដើមវិញ ។
រីអ្នកមានស្បែកខ្មៅ
ចង់លាបម្សៅផ្សំបំពេញ មុខសតែទោម្នេញ កនោះមិញខ្មៅគគ្រាត ។
កែធ្មេញកែច្រមុះ
លុះយូរលង់បន្តិចទៀត អ្វីៗក៏ប្រែឃ្លាត អស់អសារទៅប្រាកដ ។

*យើងរស់ក្នុងព្រៃលោក*
*រងទុក្ខសោកសែនជូរចត់ ព្រៃលក្ខណ៍មកកំណត់ ឱ្យកើតរូបកើតសង្ខារ ។*
*មូលហេតុនោះមកពៃ*
*ពីអវិជ្ជាជាកត្តា ធ្វើឱ្យកើតសង្ខារ ទើបអាត្មាជាប់ភក់ផុង ។*
*គួរលះលាភពបី*
*កុំតប្បីភ្លេចស្លន់ស្លុង ទ្រាំទ្រូវរស់នៅក្នុង សង្សារវដ្តវិលកើតស្លាប់ ។*
*តម្រង់ទិសឆ្ពោះទៅ*
*ត្រើយនិព្វានជាប្រញាប់ ព្រះពុទ្ធទេសនាប្រាប់ ថាជាឋានសុខអមតៈ ។*

ដោយ **មៀច ប៉ុណ្ណ**
កាវិយាល័យទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ
កែសម្រួលដោយ **ឱម ខែម**

*

**សុភាសិត :**

« ការបោត់ច្បាប់ប្រាណេ ស្វាធ្យាយលំអាន គិតគួរច្បាប់ចិត្ត
កែប្រែចំរើន ច្បាប់ជាតិក្រមក្រឹត្យ រួមចូលមូលមិត្ត គិតច្បាប់សាសនា » ។

# ក្លិនវប្បធម៌ប្រហុកខ្មែរ

( ពាក្យ ៣ )

* ឈ្ងុយប្រហើរ ដើររវៀងអាយ ភាយមកដល់
ក្លិនវិលវល់ ខ្យល់ជាប់ជាតិ ជ្រៀតនាសា
ទោះទៅទល់ ដល់ក្រហែង ជើងមេឃណា
ក៏ឆ្លែឆ្លា ប្រាថ្នាជួប ចង់បានក្លិន ។

* មិនក្រអូប តែខានស្រូប ក៏មិនបាន
ឈ្ងុយជាប់ចាន ចង្ក្រានឆ្នាំង ទាំងនៅឆ្អិន
បើចំហុយ ក្លិនឈ្ងុយជាប់ ក្នុងសុបិន
នេះគឺក្លិន ព្រហុកខ្មែរ កេរ្តិ៍ដូនតា ។

* ក្លិនជ្រួតជ្រាប លាបជីវិត ប្រពៃណី
ក្លិនគ្មានពីរ ក្លិនសាមគ្គី ជាតិខេមរា
ក្លិនសន្តិភាព ជ្រាបមុតក្នុង ពង្សាវតារ
ក្លិនបានក្លា ស្លាបនាប្រា- សាទអង្គរ ។

* កើតជាខ្មែរ គួរតែចាំ ក្លិនជាតិឯង
កុំវង្វេង តាមហ្វ្រូម៉ាស្ស ឬតាមបឺរ
តាមកាពិ ឬនៀកម៉ាំ ពិជាំកស្ល
ក្លិនអង្គរ ក្លិនវប្បធម៌ ប្រហុកខ្មែរ ។

គន្ធ ប៊ុនឈឿន

# ពិធីទទួលសៀវភៅពុទ្ធសាសនា បោះពុម្ពឆ្នាំ ១៩៩៩ អំណោយរបស់ WCRP/Japan



ឯកឧត្តម ជា សាវឿន ទទួលសៀវភៅជានិមិត្តរូប ពីគណៈប្រតិភូ WCRP (pGhdc SVA)

ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ វេលាម៉ោង ៩ ព្រឹក, ពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ បានរៀបចំពិធីទទួលសៀវភៅពុទ្ធសាសនា និងសៀវភៅវប្បធម៌ទូទៅ បោះពុម្ពឆ្នាំ ១៩៩៩ ចំនួន ២០.០២២ ក្បាល ពីគណៈប្រតិភូនៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព នៃប្រទេសជប៉ុន (WCRP/Japan) ។

ចូលរួមក្នុងពិធីនេះ ខាងភាគីកម្ពុជា មាន : ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា, ឯកឧត្តម ឈន អៀម រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា, ឯកឧត្តម ក្រូច សារី អនុរដ្ឋលេខាធិការក្រសួងធម្មការ និង

សាសនា, លោក ឱម ខែម ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា, លោក ងួន វ៉ាន់ចន្ទី នាយកពុទ្ធសាសនបណ្ឌិត្យ, លោក ង៉ែត ចន្ទប្ញ ប្រធានមន្ទីរធម្មការ រាជធានីភ្នំពេញ និងមន្ត្រីបុគ្គលិករាជការនៃក្រសួងធម្មការ ជាច្រើនរូប ។

ខាងភាគីជប៉ុន មាន : ព្រះតេជព្រះគុណ តាគី ហ៊ីសាកាស៊ី ប្រធានគណៈប្រតិភូអង្គការ WCRP, លោក ម៉ាស្សាតូស៊ី កូណូ អគ្គលេខាធិការនៃអង្គការ WCRP, លោកស្រី ហ៊ីរ៉ូកូ គុយរ៉ូហ្សុយមិ សមាជិកាគណៈកម្មាធិការនៃអង្គការ WCRP, លោក តេស៊ូកា កូជី អគ្គលេខាធិការរងនៃអង្គការ (SVA/) នៅតូក្យូ, លោក កាតូ កាសាអេ នាយកអង្គការ (SVA) ប្រចាំនៅកម្ពុជា, លោក យី ធន់ ទីប្រឹក្សាវប្បធម៌របស់អង្គការ (SVA) និងសហការី ។

បន្ទាប់ពីបានឧទ្ទេសនាមភ្ញៀវចូលរួមរួចមក, លោក ងួន វ៉ាន់ចន្ទី បានថ្លែងសង្កថាសំដែងស្វាគមន៍ និងអំណរគុណ ចំពោះគណៈប្រតិភូនៃអង្គការ WCRP ដែលបានជួយឧបត្ថម្ភបោះពុម្ពសៀវភៅពុទ្ធសាសនា និងសៀវភៅវប្បធម៌ផ្សេងៗ ជាច្រើន ចាប់តាំងពីឆ្នាំ ១៩៩២ រៀងរហូតមក ។ លោកសន្យាថា នឹងប្រើប្រាស់អោយបានត្រឹមត្រូវបំផុត នូវជំនួយទាំងអម្បាលម៉ាណ ដែលអង្គការ WCRP បានផ្តល់ដល់ពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ ។

បន្ទាប់មក, លោក ឱម ខែម បានរាយការណ៍ជូនគណៈប្រតិភូអំពីស្ថានភាពទូទៅនៃពុទ្ធសាសនា និងពុទ្ធិកសិក្សា ព្រមទាំងពុទ្ធសាសនបណ្ឌិត្យបច្ចុប្បន្ន ដោយបញ្ជាក់ថា ពុទ្ធសាសនាបានចូលមកកម្ពុជាក្នុងអំឡុងពុទ្ធសតវត្សទី៣ ហើយបន្តជីវិតរហូតដល់សព្វថ្ងៃ ។ លោកបានរំលឹកថា មុនឆ្នាំ ១៩៧០ ប្រទេសកម្ពុជា មានវត្ត ៣៣៦៩ និងមានព្រះសង្ឃចំនួន ៦៥០៦២ អង្គ ។ ពុទ្ធសាសនា ព្រះសង្ឃពុទ្ធសាសនិក និងវត្តអារាម គឺជាកម្លាំងរស់ដ៏សំខាន់របស់សង្គមជាតិ ។ នៅក្នុងការកសាងសង្គមជាតិកម្ពុជា គេពុំអាចខ្វះកម្លាំងចលកររបស់ពុទ្ធសាសនាបានឡើយ ។ យ៉ាងណាមិញ,

រាល់សកម្មភាពសង្គម ដូចជា ការសាងសង់សាលារៀន ធ្វើផ្លូវ ធ្វើស្ពាន ធ្វើមន្ទីរពេទ្យ ជីកស្រះ ... គឺព្រះសង្ឃជាអ្នកដឹកនាំធ្វើ ។ លោក ឱម ខៃម បានបញ្ជាក់ថា ការលុបបំបាត់ពុទ្ធសាសនា ក្នុងអំឡុងឆ្នាំ ១៩៧៥ . ១៩៧៩ គឺជាការបំផ្លាញរាល់តម្លៃខាងស្មារតី និងខាងសម្ភារះរបស់ព្រះពុទ្ធសាសនា យ៉ាងធ្ងន់ធ្ងរបំផុត ដែលធ្វើអោយព្រលឹង និងអត្តសញ្ញាណជាតិ ត្រូវរង្គោះរង្គើយ៉ាងខ្លាំង ។

ចាប់ពីដើមឆ្នាំ ១៩៧៩ អ្វីៗដែលបាត់បង់នោះ ក៏ចាប់ផ្តើមរស់ឡើងវិញ, ព្រះពុទ្ធសាសនាត្រូវបានស្តារ ហើយរីចំរើនឡើងវិញ តាមស្ថានភាព និងលទ្ធភាពជាក់ស្តែង ដោយបានទទួលការឧបត្ថម្ភពីសប្បុរសជន ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ។ រហូតមកដល់ពេលនេះ យើងមាន :

- វត្តចំនួន ៣៦៨៥ និងមានព្រះសង្ឃចំនួន ៥០០៨១ អង្គ,
- សាលាពុទ្ធិកបឋមសិក្សា ២៧១, មានសមណសិស្ស ៨៤៦៣ អង្គ,
- ពុទ្ធិកវិទ្យាល័យ ០៧, មានសមណសិស្ស កំ.I ១៦១១ អង្គ, និងសមណសិស្ស កំ.II ១២៦ អង្គ
- សាលាធម្មវិន័យ ៤០០, មានសមណសិស្ស ៧៩៨៥ អង្គ ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក៏បានបំពេញតួនាទីជាស្នូលមួយយ៉ាងសំខាន់ ក្នុងការស្តារវិស័យពុទ្ធសាសនា និងសីលធម៌សង្គម តាមរយៈការបោះពុម្ពផ្សាយ ចាប់តាំងពីវិជ្ជាស្ថាននេះ ត្រូវបានអនុញ្ញាតអោយដំណើរការឡើងវិញ នៅឆ្នាំ ១៩៩២ មក ។

ស្តីពីការងារបោះពុម្ព, ការចែកផ្សាយ, ការប្រើប្រាស់សៀវភៅ, លោក ឱម ខៃម បានបញ្ជាក់ថា :

*ក) ការងារបោះពុម្ព :*

សៀវភៅធម៌អាថ៌ ក្បួនច្បាប់ ព្រមទាំងសៀវភៅអក្សរសាស្ត្រ វប្បធម៌ដែលទាក់ទងដល់ការយល់ដឹងពុទ្ធសាសនា យល់ដឹងប្រពៃណី ទំនៀមទម្លាប់ជាតិ ត្រូវ

បានបោះពុម្ពឡើងវិញ ដោយអង្គការ JSRC (SVA) នៅភ្នំពេញ និងដោយមានការឧបត្ថម្ភថវិកាបោះពុម្ពពីអង្គការ រីស្សូ កូសី-កៃ ( RKK ), ពីក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) ចាប់តាំងពីឆ្នាំ ១៩៩២ រៀងមក ។

ក្នុងឆ្នាំ ១៩៩៩ នេះ សៀវភៅដែលឧបត្ថម្ភថវិកាបោះពុម្ពដោយ WCRP តាមរយៈអង្គការសន្តិស្ម័គ្រចិត្តជប៉ុន ( SVA ) នៅភ្នំពេញ គឺ :

- ឱវាទបាតិមោក្ខ 3.000 ក្បាល
- ប្រស្នាត្រៃគុណ 2.50 0 -
- សីលនិទ្ទេស 2.000 -
- អានិសង្ស ៣០ 3.522 -
- ទស្សនាវដ្ដីកម្ពុជសុរិយា លេខ ១ /៩៩ 3.000 -
- ទស្សនាវដ្ដីកម្ពុជសុរិយា លេខ ២ /៩៩ 3.000 -
- ទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៣ /៩៩ 3.000 -

ក្នុងឆ្នាំ ១៩៩៩ នេះដែរ ពុទ្ធសាសនបណ្ឌិត្យក៏បានសាកល្បងបោះពុម្ពដោយខ្លួនឯង នូវសៀវភៅ ២ ចំណងជើងផង ដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែល WCRP បានឧបត្ថម្ភ គឺ :

- មហាសង្ក្រាន្ត ឆ្នាំរោង ព.ស. ២៥៤៣ ចំនួន ៣.០០០ ក្បាល
- កម្ពុជសុរិយា លេខ ៤ /១៩៩៩ ចំនួន ១៥០០ ក្បាល ។

*ខ) ការចែកផ្សាយ :*

ពុទ្ធសាសនបណ្ឌិត្យ បានអនុវត្តតាមគោលការណ៍ពីរគឺ :

- មួយចំនួន ចែកដោយឥតគិតថ្លៃ តម្កល់ទុកនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ, នៅសាខាបណ្ណាល័យតាមបណ្ដាខេត្ត-ក្រុង, នៅបណ្ណាល័យជាតិ, ទីតម្កល់ទុកឯកសារ និងបណ្ណាល័យសំខាន់ៗ ក្នុងក្រុង និងនៅសាលាពុទ្ធិកសិក្សា

មួយចំនួន ក្នុងប្រទេស ។

- មួយចំនួនទៀត ដាក់លក់ជូនសាធារណជន នៅក្រុងភ្នំពេញ និងផ្ញើទៅលក់នៅតាមវត្តនានា ដើម្បីសន្សំទុនទុកបោះពុម្ពខ្លួនឯង នៅពេលអនាគត ។

ថវិកាដែលបានពីការលក់សៀវភៅ ឧបត្ថម្ភដោយអង្គការ WCRP តាំងពីឆ្នាំដំបូង១មក រហូតមកដល់ដំណាច់ឆ្នាំ ១៩៩៩ នេះ មានចំនួន ៥៩.៩៤០.៣០០៖០០ ( ហាសិបប្រាំបួនលានប្រាំបួនរយសែសិបពាន់បីរយរៀល ) ។ ប្រាក់នេះផ្ញើទុកនៅធនាគារភ្នំពេញ ។

*គ) អំពីផលប្រយោជន៍នៃសៀវភៅ :*

- បានផ្តល់ចំណេះដឹងជាមូលដ្ឋានក្នុងចំណោមព្រះសង្ឃ ក៏ដូចជាក្នុងចំណោមប្រជាពលរដ្ឋទូទៅ ។

- បានលើកកំពស់ការយល់ដឹង និងតម្រង់ទិសការប្រតិបត្តិរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ។

- បានរួមចំណែកយ៉ាងធំធេងដល់ការបណ្តុះបណ្តាលបញ្ញាស្មារតី និងលើកស្ទួយសីលធម៌ និងអភិសមាចារសង្គម ដោយពិតប្រាកដ ។

មានពុទ្ធដីកា នាឱកាសនោះ, ព្រះតេជព្រះគុណ តាគី ហ៊ីសាកាស៊ី បានសុំការអធ្យាស្រ័យចំពោះការអាក់ខានមិនបានមកចូលរួមពីសំណាក់ព្រះតេជព្រះគុណ យ៉ាម៉ាដា ដែលជាប្រធាននៃអង្គការ WCRP នៅក្នុងពិធីនេះ ដោយមានភារកិច្ចចាំបាច់ ។ ព្រះតេជព្រះគុណបានបញ្ជាក់ថា ការជួយឧបត្ថម្ភរបស់ WCRP គឺផ្តោតទៅលើការជួយបណ្តុះបណ្តាលខាងបញ្ញាស្មារតី និងសីលធម៌ អោយមានភាពល្អប្រសើរឡើង ដោយពិតប្រាកដ ។

នៅទីបញ្ចប់, ព្រះតេជព្រះគុណប្រធានគណៈប្រតិភូ បានកោតសរសើរ និងសំដែងការរីករាយចំពោះពុទ្ធសាសនបណ្ឌិត្យ ដែលបានប្តេជ្ញាថានឹងធានាបាន នូវ

ការបោះពុម្ពទស្សនាវដ្ដីកម្ពុជសុរិយា ដោយខ្លួនឯង ចាប់ពីឆ្នាំ ២០០០ នេះតទៅ ។ ចំពោះការបោះពុម្ពសៀវភៅធម៌ និងសៀវភៅវប្បធម៌ទូទៅនោះ ព្រះតេជព្រះគុណបានមានសង្ឃដីកាថា WCRP នឹងពិនិត្យលទ្ធភាពជួយជាបន្តទៅទៀត ។

មានប្រសាសន៍ឆ្លើយតប នាឱកាសនោះដែរ, ឯកឧត្ដម ជា សាវឿន រដ្ឋ-មន្ត្រីក្រសួងធម្មការ និងសាសនា បានសំដែងនូវអំណរគុណ និងការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះវិភាគទានដ៏ធំធេងរបស់ WCRP ក្នុងការជួយស្រោចស្រង់អោយរស់ឡើងវិញ នូវវប្បធម៌ពុទ្ធសាសនា និងវប្បធម៌ខ្មែរ នៅកម្ពុជា និងបានជួយអោយពុទ្ធសាសនបណ្ឌិត្យ ដំណើរការបានល្អ ។ ឯកឧត្ដមបានមានប្រសាសន៍សង្កត់ធ្ងន់ថា បើគ្មាន ជំនួយឧបត្ថម្ភទាន់ពេលវេលាពីសប្បុរសជននៃប្រទេសជប៉ុន ជាពិសេស ពីអង្គការ WCRP នោះយើងពុំអាចស្ដារវិស័យពុទ្ធសាសនា និងសីលធម៌សង្គមរបស់យើងអោយមានការរីកចំរើនឆាប់រហ័ស ដូចសព្វថ្ងៃនេះបានទេ ។ ឯកឧត្ដមបានប្រសិទ្ធិពរ សូមអោយបេសកកម្មរបស់ WCRP ទទួលបានជោគជ័យគ្រប់ប្រការក្នុងបុព្វហេតុសន្តិភាព សេចក្ដីសុខក្សេមក្សាន្ត និងសុភមង្គលនៃមនុស្សជាតិ !

ពិធីនេះបានបញ្ចប់ ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល ។

*

នៅវេលារសៀលម៉ោង ២ ថ្ងៃនេះ គណៈប្រតិភូបានអញ្ជើញទៅវត្តវាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដើម្បីចូលរួមក្នុងពិធីប្រគេនសៀវភៅធម៌ និងសៀវភៅវប្បធម៌ទូទៅ ចំពោះសាលាពុទ្ធិកសិក្សា ក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង, ក្នុងស្រុកពញាឮ ខេត្តកណ្ដាល, និងក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដែលនៅទីនោះ គណៈប្រតិភូបានទទួលបដិសណ្ឋារកិច្ចយ៉ាងរាក់ទាក់ពីលោក ឱម ខែម ទីប្រឹក្សាអមក្រសួងធម្មការ, ពីលោកស្រីប្រធានមន្ទីរធម្មការ ខេត្តកំពង់ស្ពឺ, ពីលោកប្រធានមន្ទីរធម្មការ ខេត្តកំពង់ឆ្នាំង, ពីមន្ត្រីសង្ឃស្រុកទាំង ៣ និងពុទ្ធបរិស័ទចូលរួម

អបអរ ប្រមាណជាង ៣០០ នាក់ ។ សៀវភៅដែលបានយកទៅប្រគេនក្នុងឱកាសនោះ គឺ : ឱវាទបាតិមោក្ខ , ប្រស្នាត្រៃគុណ, សីលនិទ្ទេស, អានិសង្ស ៣០, ទស្សនាវដ្ដីកម្ពុជសុរិយា លេខ ១ លេខ ២ និងលេខ ៣ ឆ្នាំ ១៩៩៩ ។

បន្ទាប់ពីព្រះតេជព្រះគុណចៅអធិការវត្តវាំងចាស់ ថ្លែងសង្កថាសំដែងស្វាគមន៍ចំពោះគណៈប្រតិភូ និងរបាយការណ៍របស់លោក ឱម ខែម រួចមក, គណៈប្រតិភូបានប្រគេនសៀវភៅទាំងនោះ ចំពោះវត្តនានានៅក្នុងស្រុកទាំង ៣ ដែលមានសាលាពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យ គឺ :

- ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចំនួន ៩៨ ក្បាល
- ស្រុកពញាឮ ខេត្តកណ្ដាល ចំនួន ៨៤ ក្បាល
- ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចំនួន ១៤៣ ក្បាល



( រូបថត SVA )

បន្ទាប់មកទៀត, គណៈប្រតិភូបានចូលមើលការសិក្សារបស់ព្រះសង្ឃ, ទស្សនាបណ្ណាល័យ និងទស្សនាទិដ្ឋភាពទូទៅនៃវត្តវាំងចាស់ ស្រុកឧដុង្គ ។

# ការជួបប្រជុំពិភាក្សាលើគំរោងការងារមួយចំនួន ជាមួយគណៈប្រតិភូនៃអង្គការ WCRP /Japan



( រូបថត SVA )

ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០០ វេលាម៉ោង ១០ និង ១៥ នាទី នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ មានការជួបប្រជុំពិភាក្សាជាមួយអង្គការ WCRP លើគំរោងការងារមួយចំនួន សំរាប់ឆ្នាំ ២០០០ និងឆ្នាំបន្ទាប់ ។

- ចូលរួមក្នុងឱកាសនោះ ខាងភាគីកម្ពុជា ៖
  - ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
  - ឯកឧត្តម ឈន អៀម រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា
  - លោក ឱម ខែម ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា,
  - លោក ងួន វ៉ាន់ចន្ធី នាយកពុទ្ធសាសនបណ្ឌិត្យ,
  - លោក ខៀវ បញ្ញាវុឌ្ឍ ប្រធានការិយាល័យរដ្ឋបាល នៃពុទ្ធសាសនបណ្ឌិត្យ

- លោក ស៊ុន ដានី គណនេយ្យ នៃពុទ្ធសាសនបណ្ឌិត្យ,
- កញ្ញា លី គិមលីន លេខាធិការការិយាល័យ នៃពុទ្ធសាសនបណ្ឌិត្យ ។

• ខាងភាគីជប៉ុន មាន ៖

- ព្រះតេជព្រះគុណ តាគី ហ៊ីសាកាស៊ី ប្រធានគណៈប្រតិភូ WCRP
- លោក ម៉ាស្សាតូ កូណូ អគ្គលេខាធិការ នៃអង្គការ WCRP
- លោកស្រី ហ៊ីរ៉ូកូ គុយ៉ូហ្សុមិ សមាជិកគណៈកម្មាធិការ WCRP
- លោក តេស៊ូការ កូជី អគ្គលេខាធិការរង នៃអង្គការ SVA, តូក្យូ
- លោក កាតូ សាកាអេ នាយកអង្គការ SVA ប្រចាំនៅកម្ពុជា
- លោក យី ធន់ ទីប្រឹក្សាវប្បធម៌នៃអង្គការ SVA នៅភ្នំពេញ
- លោក ស៊ិន ចំរើនវ័យ អ្នកសម្របសម្រួលការងារ SVA ជាមួយព.ប.
- លោក ហាម វិចិត្រ បុគ្គលិកវប្បធម៌របស់អង្គការ SVA ភ្នំពេញ

• កម្មវត្ថុនៃកិច្ចប្រជុំនោះគឺ ៖

១. សេចក្តីជូនដំណឹងអំពីពេលវេលា នៃការឈប់បន្តជំនួយឧបត្ថម្ភបោះពុម្ពរបស់ WCRP ចំពោះពុទ្ធសាសនបណ្ឌិត្យ នៅដំណាច់ឆ្នាំ ២០០១ ។

២. សុំអោយមានគណៈកម្មការចម្រុះមួយ ដើម្បីត្រួតពិនិត្យការងារបោះពុម្ព, ការចែកផ្សាយ, ការលក់សៀវភៅ និងការប្រើប្រាស់ថវិកា ដែលបានមកពីការលក់សៀវភៅ និងធ្វើរបាយការណ៍ពីលទ្ធផលការងារ ផ្ញើជូនទៅ RKK/Japan និង WCRP/Japan នៅតូក្យូ ។

៣. អនុញ្ញាតអោយពុទ្ធសាសនបណ្ឌិត្យប្រើប្រាស់ថវិកា ដែលបានមកពីការលក់សៀវភៅ ឧបត្ថម្ភដោយ (WCRP) ចំនួន 12.000.000៛00 ដើម្បីធ្វើជាទុនបង្វិលលើការបោះពុម្ពទស្សនាវដ្ដីកម្ពុជសុរិយា ចាប់ពីឆ្នាំ ២០០០ តទៅ ។

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងធម្មការ និង សាសនា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៨៩ ក.ធ.ស.៣.ក

-------

ភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០

## សេចក្តីសំរេច

ស្តីពីគណៈកម្មការទស្សនាវដ្តីកម្ពុជសុរិយា

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ,
- បានឃើញព្រះរាជក្រមលេខ នស. រកម. ០១៩៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ,
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក. ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា ,
- បានឃើញអនុក្រឹត្យលេខ ៤០២ អនក្រ.កត. ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា,
- បានឃើញលិខិតលេខ ៤១៧ សជណ.ផក របស់ទីស្តីការនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៣ ស្តីពីការអនុញ្ញាតអោយចេញផ្សាយទស្សនាវដ្តីកម្ពុជសុរិយា,
- បានឃើញសេចក្តីសំរេច ស្តីពីការកែសំរួលខ្លឹមសារ.រូបភាព របស់ទស្សនាវដ្តី កម្ពុជសុរិយា
- អនុលោមតាមការងារចាំបាច់របស់ក្រសួង,

## សំរេច

**ប្រការមួយ :** តែងតាំងគណៈកម្មការបណ្ណាធិការ របស់ ទស្សនាវដ្តីកម្ពុជសុរិយា ដែលមាននាម និងភារកិច្ច ដូចខាងក្រោម :

ក) តែងតាំងលោក ងួន វ៉ាន់ចន្ធី អោយទទួលជានាយកការផ្សាយ នៃ

ទស្សនាវដ្តីកម្ពុជសុរិយា,

ខ) តែងតាំងលោក ឱម ខែម ជានិពន្ធនាយក នៃទស្សនាវដ្តីកម្ពុជសុរិយា,

គ) តែងតាំងលោក អាំ ឆន ជានិពន្ធនាយករងនៃទស្សនាវដ្តីកម្ពុជសុរិយា,

ឃ) តែងតាំងលោកបណ្ឌិត ឆយ យីប៉ាង, លោកម៉ែន ប្រាង, លោក វង់ សុធារ៉ា, លោក ធន់ ហ៊ិន, លោក មៀច ប៉ុណ្ណ, លោក ខៀវ បញ្ញារុឡ្ស, និង លោក ពេជ ប៊ុន្នីន ជាសមាជិកគណៈកម្មការនិពន្ធ របស់ ទស្សនាវដ្តីកម្ពុជសុរិយា ។

**ប្រការ ២** : តែងតាំងឥស្សរជន ដូចមាននាមខាងក្រោម ជាសមាជិកគណៈកម្មការពិគ្រោះយោបល់ របស់ ទស្សនាវដ្តីកម្ពុជសុរិយា គឺ :

១. លោកព្រឹទ្ធាចារ្យ ឆេង ផុន ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា,

២. ឯកឧត្តម នុត ណារ៉ាង ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ,

៣. ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា,

៤. ឯកឧត្តម ឈេន អៀម រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

៥. លោកបណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម នាយកវិជ្ជាស្ថានជាតិខាងភាសា,

៦. លោកបណ្ឌិតទស្សនវិជ្ជា ឆយ យីប៉ាង ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងារបណ្ឌិត្យសភាកម្ពុជា,

៧. លោកបណ្ឌិត នេត បារ៉ុម សកលវិទ្យាធិការរងនៃសកលវិទ្យាល័យ ភ្នំពេញ,

**ប្រការ ៣** : អស់លោកដែលមានចែងក្នុងប្រការមួយ ចំណុច ក.ខ.គ.ឃ. ត្រូវបំពេញភារកិច្ចថ្មីបន្ថែមលើភារកិច្ចដែលមានមកហើយ ។

**ប្រការ ៤** : គណៈកម្មការទស្សនាវដ្តីកម្ពុជសុរិយា មានភារកិច្ច :

ក) <u>គណៈកម្មការបណ្ណាធិការ</u>

- ប្រជុំគ្នាដើម្បីបែងចែកភារៈទទួលខុសត្រូវនិពន្ធតាមខ្លឹមសារអោយត្រូវតាមមុខជំនាញរៀងៗខ្លួន,

- ទទួលខុសត្រូវលើរូបភាព និងខ្លឹមសារគ្រប់បទនិពន្ធ ធ្វើយ៉ាងណាធានាបាននូវអត្ថន័យ អត្ថរូប អត្ថរស ដែលមានផលប្រយោជន៍ពិតប្រាកដ សំរាប់សង្គមកម្ពុជាទាំងមូល,

- ត្រួតពិនិត្យការបោះពុម្ព ដោយផ្អែកតាមខ្លឹមសារនៃសេចក្តីសំរេចលេខ ៨៩ ក.ធ.ស-ពប ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការកែសំរួលខ្លឹមសារ និងរូបភាពនៃទស្សនាវដ្តីកម្ពុជសុរិយា ហើយចាត់ចែងចែកផ្សាយអោយបានទៀងទាត់ និងទាន់ពេលវេលា,

- និពន្ធនាយក មានភារកិច្ចដាស់តឿនអំពីពេលវេលា បច្ចេកទេសនិពន្ធ និងបញ្ហាមួយចំនួន ដល់ការនិពន្ធ ដល់សមាជិករបស់ខ្លួន ។ និពន្ធនាយកត្រូវត្រួតពិនិត្យគ្រប់អត្ថបទរបស់សមាជិក និងកែសំរួលអោយបានសមស្រប មុននឹងបញ្ជូនទៅនាយកការផ្សាយ សំរេចជាចុងក្រោយ ។ ដើម្បីជាភស្តុតាងក្នុងការត្រួតពិនិត្យ និពន្ធនាយកត្រូវចុះហត្ថលេខាលើសំណៅ ។

- គ្រប់អត្ថបទសំណៅ ដែលត្រូវអនុញ្ញាតអោយចេញផ្សាយ ត្រូវមានហត្ថលេខាយល់ព្រមអំពីនាយកការផ្សាយ ។

- សមាជិកគណៈកម្មការបណ្ណាធិការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំផ្សេងៗ តាមការអញ្ជើញរបស់នាយកការផ្សាយ ។

ខ) <u>គណៈកម្មការពិគ្រោះយោបល់</u>

- កោះប្រជុំជាលើដំបូង និងជាបន្តបន្ទាប់ តាមការចាត់អញ្ជើញរបស់នាយកការផ្សាយនៃទស្សនាវដ្តីកម្ពុជសុរិយា ។

- ការកោះប្រជុំដែលត្រូវធ្វើជាបន្តបន្ទាប់ ត្រូវយោលទៅតាមពេលចាំបាច់ របស់គណៈកម្មការបណ្ណាធិការ ឬតាមការស្នើសុំរបស់សមាជិកណាម្នាក់ របស់ គណៈកម្មការពិគ្រោះយោបល់ ។

• ខ្លឹមសារនៃកិច្ចប្រជុំ :

១. ការប្រជុំជាលើកដំបូង ត្រូវផ្តោតទៅលើ :

- ខ្លឹមសារសំរាប់ការនិពន្ធ,

- គោលដៅ និងមុខសញ្ញា សំរាប់ការនិពន្ធ,

- វិធានការនានា ដើម្បីរកអត្ថបទចុះផ្សាយ និងវិធានការសំរាប់ចែកផ្សាយ

២. ការប្រជុំជាបន្តបន្ទាប់ ត្រូវផ្តោតទៅលើ :

- ភាពខ្វះខាតដែលមានក្នុងការនិពន្ធ ទាំងរូបភាព ទាំងខ្លឹមសារ ។

- ផ្តល់យោបល់ ដើម្បីដោះស្រាយភាពខ្វះខាត ។

- រកវិធានការដើម្បីអោយការនិពន្ធ ការបោះពុម្ព និងការចែកផ្សាយ ដំណើរការប្រសើរជាងមុន ។

គ) សមាជិកឆ្លើយឆ្លង មានភារកិច្ច :

- ផ្តល់ពត៌មានតាមរយៈអត្ថបទ ស្តីពីការស្រាវជ្រាវក្នុងតំបន់សមត្ថកិច្ចរបស់ខ្លួនទៅបណ្ណាធិការដ្ឋាននៃទស្សនាវដ្តីកម្ពុជសុរិយា តាមកាលកំណត់ ។

- ចូលរួមរាល់ការអញ្ជើញប្រជុំដកពិសោធន៍ និងបំពាក់បំប៉នរបស់បណ្ណាធិការដ្ឋាន ។

**ប្រការ ៥** : ខុទ្ទកាល័យ, អគ្គនាយកដ្ឋានធម្មការ, នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុពុទ្ធសាសនបណ្ឌិត្យ, នាយកដ្ឋានធម្មការ, អធិការដ្ឋានពុទ្ធិកសិក្សា, ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការមួយ និងប្រការ ២ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីពេលចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា **ជា សាវឿន**

# សេចក្តីជូនដំណឹង

----

សូមជូនដំណឹងដល់សាធារណជនអោយបានជ្រាបថា « កម្ពុជសុរិយា » ជាទស្សនាវដ្តីមួយ ដែលមានកម្មវត្ថុផ្សព្វផ្សាយអំពីអក្សរសាស្ត្រសាសនា អក្សរ-សាស្ត្រទូទៅ និងវប្បធម៌សង្គម ។ ទស្សនាវដ្តីនេះ ត្រូវបានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការពីមុន បោះពុម្ពផ្សាយប្រចាំខែ តាំងពីឆ្នាំ ១៩២៦ រហូតដល់ដើមឆ្នាំ ១៩៧៥ ។ ក្នុងរយៈពេលជាង ៤០ ឆ្នាំ នៃសកម្មភាពរបស់ខ្លួន ទស្សនាវដ្តីនេះបានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការអប់រំសីលធម៌ បណ្តុះបញ្ញាស្មារតីស្រឡាញ់អក្សរសាស្ត្រ ប្រពៃណីជាតិ និងបើកទូលាយការយល់ដឹងអំពីវប្បធម៌ទូទៅ ទាំងខាងផ្លូវធម៌ ទាំងខាងផ្លូវលោក ហើយបានទទួលការរាប់អានយ៉ាងកក់ក្តៅពីសាធារណជនគ្រប់មជ្ឈដ្ឋាន ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ។

បន្ទាប់ពីត្រូវបានបាត់ឈ្មោះ បាត់សំឡេង អស់ជិតពីរទស្សវត្សកន្លងទៅ, នៅដើមឆ្នាំ ១៩៩៤, ទស្សនាវដ្តីកម្ពុជសុរិយា ត្រូវបានរស់រានចេញមុខបន្តបេសកកម្មផ្សព្វផ្សាយចំណេះដឹងផ្នែកសាសនា អក្សរសាស្ត្រ វប្បធម៌ បំរើសាធារណជន ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ជាថ្មីឡើងវិញ ដោយបានទទួលការឧបត្ថម្ភថវិកាបោះពុម្ពពីក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព នៃប្រទេសជប៉ុន (World Conference on Religion and Peace " WCRP ") តាមរយៈអង្គការជំនួយសូតូស៊ូជប៉ុន (JSRC = SVA) នៅភ្នំពេញ ក្នុងគោលបំណង :

- ជួយរក្សា និងផ្សព្វផ្សាយការគោរពប្រតិបត្តិពុទ្ធសាសនា អក្សរសាស្ត្រជាតិអោយបានល្អ និងរីកចំរើន,

- ជួយសាធារណជនពង្រីកការយល់ដឹងសីលធម៌ក្នុងការរស់នៅ និងវប្ប-ធម៌សង្គមដោយខ្លួនឯង ពោលគឺ ផ្តល់ចំណេះចេះដឹងថ្មីៗ ពត៌មានថ្មីៗ ស្តីពីការស្រាវ

ជ្រាវ ទស្សនៈយល់ដឹង និងវិជ្ជាឯទៀតៗ ក្នុងសាធារណជន ។

- ជួយពង្រឹង និងពង្រីកវប្បធម៌សង្គម ប្រពៃណី ទំនៀមទម្លាប់ជាតិ ដ៏ល្អប្រសើរ របស់ប្រទេសជាតិយើង ។

រហូតមកដល់ដំណាច់ឆ្នាំ ១៩៩៩ ទស្សនាវដ្ដីកម្ពុជសុរិយា បានចេញមុខបំរើសាធារណជន អស់រយៈពេល ៦ ឆ្នាំហើយ ហើយនឹងនៅតែចេញមុខបន្តបេសកកម្មផ្សព្វផ្សាយចំណេះដឹងផ្នែកសាសនា អក្សរសាស្ត្រ វប្បធម៌ បំរើសាធារណជន តទៅឆ្នាំ ២០០០ ទៀត ។ នៅក្នុងរបត់ផ្លូវថ្មីនេះ ពុទ្ធសាសនបណ្ឌិត្យបានទទួលរ៉ាប់រងចាត់ចែងបោះពុម្ពផ្សាយដោយខ្លួនឯង, ដោយប្រើប្រាស់ថវិកាដែលបានមកពីការលក់សៀវភៅនានា ឧបត្ថម្ភដោយអង្គការ WCRP ដើម្បីធ្វើជាទុនបង្វិលលើការបោះពុម្ពទស្សនាវដ្ដីនេះ ចាប់ពីឆ្នាំ ២០០០ តទៅ ។ ប៉ុន្តែ ដោយយោលទៅលើមធ្យោបាយ និងលទ្ធភាពខាងថវិកា, នាពេលបច្ចុប្បន្ន, ក្នុងដំបានបន្តការងារនេះ ពុទ្ធសាសនបណ្ឌិត្យនឹងបោះពុម្ពផ្សាយប្រចាំត្រីមាស ( ៤ លេខ ក្នុងមួយឆ្នាំ ), បន្ថយទំព័រនៅត្រឹម ៨០ ឬ ១០០ ទំព័រ និងកំរិតចំនួនបោះពុម្ពតិច-ច្រើន គិតតាមចំនួនអ្នកត្រូវការ ។ រីឯរូបភាព និងខ្លឹមសារនៃទស្សនាវដ្ដី ក៏ត្រូវបានកែសំរួលអោយស្របនឹងតថភាពសង្គមជាតិបច្ចុប្បន្ន ផងដែរ ។

ហេតុនេះ សូមសាធារណជន មេត្តាជួយឧបត្ថម្ភជាអត្ថបទ ឬជាថវិកា និងជួយជាវ ដើម្បីជួយអោយទស្សនាវដ្ដីនេះ បានសំរេចតាមគោលបំណងរបស់ខ្លួន ។

អស់លោកអ្នកដែលមានបំណងចង់ជាវទស្សនាវដ្ដីនេះ សូមផ្ញើលិខិតបញ្ជាទិញ ឬជាវដោយត្រង់ទៅពុទ្ធសាសនបណ្ឌិត្យ ដែលមានទីស្នាក់ការនៅអគារថ្មីទល់មុខមន្ទីរពិព័រណ៍ជាតិ ( ក្បែរសួនច្បារសម្ដេច ហ៊ុន សែន ) តែម្ដង ។ បណ្ណាធិការដ្ឋាននៃទស្សនាវដ្ដី នឹងរង់ចាំបំរើអស់លោកអ្នក ដោយរីករាយ ។

ពុទ្ធសាសនបណ្ឌិត្យ

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ទិដ្ឋភាពរួមក្នុងសិក្ខាសាលាអនុតំបន់អាស៊ីអាគ្នេយ៍ (រូបថត អាជ្ញាធរជាតិ)

ឆ្នាំទី ៥៤ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស. ២៥៤៤ គ.ស. ២០០០

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :


នាយកការផ្សាយ : **ខួន ហ៊ាន់ចន្ទី**

និពន្ធនាយក : **ឱម ខែម**

និពន្ធនាយករង : **អាំ ឆន**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង**, លោក **ម៉ែន ប្រាង**,

លោក **ចង់ សុផារ៉ា**, លោក **ធន់ ហ៊ិន**, លោក **មៀច ប៉ុណ្ណ**,

លោក **ខៀវ បញ្ញាវុឌ្ឍ**, លោក **ពេជ ប៊ុន្ទិន**

គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **ឈន សៀម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា
- លោក បណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោក បណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិត្យ. សភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ

---


• បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ ។

• The publication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា


• ពុទ្ធសាសនា និងតម្លៃសីលធម៌ចំពោះស្វាមី-ភរិយា ( ឱម ខែម ) ............ ១
• តើអ្វីជាមង្គលរបស់មនុស្សគ្រប់រូប ( ឱម ខែម ) ............ ៩


## III. អក្សរសាស្ត្រទូទៅ និងអក្សរសិល្ប៍ខ្មែរ


• ស្មារតីសន្តិភាព និងប្រជាធិបតេយ្យ ( បណ្ឌិត ឆយ យីហ៊ាង ) ............ ១៦
• ឥទ្ធិពលពុទ្ធសាសនា នៅកម្ពុជា ( អ្នកស្រីបណ្ឌិត ខ្លូត ធីតា ) ............ ២២
• សិលាចារឹកថ្មី ១ Ka 64 នៅភូមិមេលប់ ក្បែរស្ពាយពល និងបញ្ហា
ជាតិពន្ធនាមពីរ គឺ «ខ្មែរ» និង «មលេង» ត-ចប់ (វង់ សុធារ៉ា) ............ ៣១
• រាជធានីចាស់នៃសន្តិវង្ស ចេន ឡា ( បណ្ឌិត បាម ឆាយលើ ) ............ ៤៨
• ប្រវត្តិស្តេចព្រះនាគវ័ន វរពោធិ ( សំបុក ) ក្រចេះ ( ជួប ឃាន
លោកស្រី ទួន សោភ័ណ ) ............ ៥៥
• រឿងនាងកែវប្រាំពីរពណ៌ ( សួរ ឆេង និង ឡាំ សុភក្ត្រ ) ............ ៦១
• អំពីព្រះបាទធម្មិក ( ក្បួនពុទ្ធទំនាយ ) ( ធន់ ហ៊ិន ) ............ ៧០
• បុណ្យខ្មោច បុណ្យរនោច ( បណ្ឌិត ថោង ផៃល ) ............ ៧៦
• ជាវខាន់ស្លា ( យក់ គុណា ) ............ ៧៨
• គ្រឿងផ្សំសំរាប់ស៊ីស្លា ( មៀច ប៉ុណ្ណ ) ............ ៨៤
• អំពីក្បុង ( មៀច ប៉ុណ្ណ ) ............ ៩១


## IV. កំណាត់ និង ប្រវត្តិការណ៍


• សិក្ខាសាលាអនុតំបន់ ស្តីពី តួនាទីព្រះសង្ឃពុទ្ធសាសនិកក្នុងការងារ
អប់រំបង្ការ និងថែទាំអ្នកជំងឺអេដស៍ ............ ៩៦

# ពុទ្ធសាសនា និង
# តម្លៃសីលធម៌ចំពោះស្វាមី-ភរិយា

**ឱម ខែម**
ដកស្រង់រៀបរៀង និងនិពន្ធ

សុភមង្គលនៃជីវិតគូស្វាមីភរិយា តាមទស្សនៈពុទ្ធសាសនា គឺស្ថិតនៅលើសេចក្តីសុខ នៅក្នុងគ្រួសាររបស់ខ្លួន ដែលហៅថា សុខកាយ សប្បាយចិត្ត ។ សុខកាយ គឺការដែលមិនមានជំងឺតម្កាត់ផ្សេងៗ រាងកាយរឹងប៉ឹង អវៈយវៈទាំងអស់មានសុខភាពមាំមួន ធ្វើការងារបានគ្រប់យ៉ាងទាំងអស់ ។ សុខកាយម្យ៉ាងទៀត គឺការដែលមានបច្ច័យ ៤ គ្រប់គ្រាន់ គឺមានម្ហូបអាហារត្រឹមត្រូវតាមក្បួនអនាម័យ, មានសំលៀកបំពាក់, មានផ្ទះសម្បែង, និងមានថ្នាំសំរាប់ព្យាបាលជំងឺ ។ សេចក្តីសុខខាងកាយនេះ ជាសេចក្តីសុខដែលគេស្គាល់គ្រប់គ្នា ហើយដែលគ្រួសារនីមួយៗតែងប្រាថ្នា ។ តែសេចក្តីសុខប្រភេទនេះ មិនទាន់គ្រប់គ្រាន់ទៅនឹងសេចក្តីត្រូវការរបស់សុភមង្គលទេ, ហេតុបានជាដូច្នោះ ព្រោះថា បើគ្រួសារ ( ស្វាមីភរិយា ) នោះ មានបច្ច័យ ៤ គ្រប់គ្រាន់មែន តែអ្នកជាមនុស្សដែលខ្វះសីលធម៌ ខ្វះការកក់ក្តៅក្នុងក្រុមគ្រួសារ ប្តីប្រពន្ធកូនប្រព្រឹត្តតែអំពើអបាយមុខ ដែលលោកហៅថា ផ្កូតស្រា ផ្កូតស្រី ផ្កូតល្បែងពាលា ... នោះជីវិតស្វាមីភរិយានឹងមិនមានសេចក្តីសុខឡើយ ។ អ្នកមានទ្រព្យច្រើន តែជួនកាលអ្នកមិនមានសេចក្តីសុខ ដេកលក់ស្រួលស្មើនឹងជីវិតគូស្វាមីភរិយាខ្លះដែលក្រទ្រព្យសម្បត្តិ តែចេះស្រឡាញ់គ្នាល្អកល្អើន រស់នៅជាមួយ

គ្នាក្នុងសុខដុមភាពនោះឡើយ ។ ដូច្នេះ សេចក្ដីសុខខាងផ្លូវចិត្ត ទើបជាសេចក្ដីសុខដែលសំរាប់បន្ថែមទៅលើសេចក្ដីសុខខាងផ្លូវកាយ ដើម្បីអោយសុភមង្គលខាងជីវិតគូស្វាមីភរិយាមានតុល្យភាព ។

អត្ថបទតទៅនេះ គឺជាកម្រងទស្សននៈពុទ្ធសាសនា ដែលបានដកស្រង់យកអន្លើខ្លះពីគម្ពីរទីឃនិកាយ សុត្តន្តបិដក, អន្លើខ្លះទៀត ពីសៀវភៅ « ជីវិតអាពាហ៍ពិពាហ៍ » របស់លោកធម្មបណ្ឌិត ហេង មណីចិន្តា និងពីច្បាប់ផ្សេងៗ មករៀបរៀង និងពន្យល់សេចក្ដីទុកជាគតិ ក្នុងដំណើរលើវិថីជីវិតដែលសែនលំបាក ។

តម្លៃសីលធម៌ចំពោះស្វាមីភរិយា មានអ្វីខ្លះដែលគួរសិក្សា និងអនុវត្ត ?

## I. នាទី និងសីលធម៌ស្វាមី ចំពោះភរិយា :

ភរិយា, តាមអត្ថន័យ, គឺស្ត្រីដែលស្វាមីត្រូវចិញ្ចឹម, ត្រូវអនុគ្រោះ ។ ការអនុគ្រោះរបស់ស្វាមីចំពោះភរិយា លោកបានចែកធម្មៈ ៥ ប្រការ សំរាប់អនុវត្តគឺ :

១. ស្រឡាញ់ភរិយាដ៏ស្មោះ ដោយប្រើសំដីទន់ភ្លន់ ផ្អែមល្ហែម ទៅកាន់ភរិយា, មិនប្រើពាក្យសំដីគ្រោតគ្រាតទៅកាន់ភរិយា ។

២. មិនបៀតបៀន, មិនមើលងាយមើលថោកភរិយា ។

៣. មិនប្រព្រឹត្តកន្លងចិត្តភរិយា ( មិនក្បត់ចិត្តភរិយា )(*) ។

៤. ប្រគល់កិច្ចការសព្វយ៉ាងនៅក្នុងផ្ទះ អោយទៅភរិយាកាន់កាប់ ។

៥. ផ្ដត់ផ្ដង់សំលៀកបំពាក់ គ្រឿងអលង្ការសមគួរដល់ភរិយា ។

ស្វាមីក៏ត្រូវយល់ដឹង និងជួយរំលែកសេក្ដីទុក្ខលំបាករបស់ភរិយា ក្នុងឋានៈជាស្រី និងជាភេទទន់ខ្សោយ គឺ : ទុក្ខខាងផ្លូវកាយ និងផ្លូវចិត្ត នៅពេលមាន

---

(*) ខ្មែរមានដំបូន្មានថា « បើស្រឡាញ់ខ្លួនអោយស្ងួនចំណើ, បើស្រឡាញ់ស្រីអោយស្ងួនចិត្ត គឺអោយស្ងួនការប្រព្រឹត្តរក្សជាប្ដូយស្រីខាងក្រៅ » ។

គភ៌ មិនអាចប្រើឥរិយាបថទាំង ៤ ( ដេក ដើរ ឈរ អង្គុយ ) និងប្រកបកិច្ចការបាន ស្រួល, ទុក្ខនៅពេលឆ្លងទន្លេប្រសូតបុត្រ, ... ។

## II. នាទី និងសិលធមិភរិយា ចំពោះស្វាមិ :

• ក) ក្នុងឋានៈជាភរិយា

គប្បីយល់ដឹងសិលធមិ ៥ ប្រការ សំរាប់អនុវត្តចំពោះស្វាមីខ្លួន គឺ :

១. ចាត់ចែងការងារក្នុងផ្ទះ-ក្រៅផ្ទះ មានបាយទឹកជាដើម ដោយផ្ចិតផ្ចង់, មើលរៀបចំឥវ៉ាន់ ទ្រព្យសម្បត្តិ រៀបចំផ្ទះសម្បែង អោយមានសណ្តាប់ធ្នាប់រៀបរយ ស្អាតបាត មានអនាម័យ ដូចសុភាសិតថា " *ដំណេកដេកជាខ្នាត អែាយសំអាតសំអាងជា ទើបទេវតារក្សា ចំរើនសុខស្រីសួស្តី* "។

២. សង្គ្រោះញាតិខាងស្វាមី និងញាតិខាងខ្លួន អោយបានស្មើមុខគ្នា រួមទាំងបដិសណ្ឋារកិច្ចចំពោះបុគ្គលដែលស្វាមិរាប់អាន ពេលដែលជននោះមកផ្ទះ ។

៣. ថែទាំទុកដាក់ទ្រព្យសម្បត្តិដែលស្វាមីរកបានមក, របស់បាត់ត្រូវតាមរក, របស់ចាស់ត្រូវជួសជុលប្រើ, និងចេះប្រមាណក្នុងការប្រើទ្រព្យសម្បត្តិ ។

ត្រង់នាទី ទី៣ នេះ នារីជាភរិយាត្រូវចងចាំពាក្យបុរាណថា : « *ប្តីជាអ្នករក ទ្រព្យធនបានមក ប្រពន្ធទុកដាក់ ចាស់ទុំបុរាណ បានពោលបញ្ជាក់ អោយនាងអោយអ្នក ចងចាំគ្រប់ប្រាណ ។ សំណាបយោងដី រីឯស្រី១ យោងប្រុសសាមាន្យ ( សាមញ្ញ ) ទោះមារយាទខ្សោយ- ក៏ដោយបើបាន ស្រីមានសន្តានខ្ជាប់ខ្ជួនមួនមាំ ។ តែងបានចំរើន ទ្រព្យាកើតកើន ព្រោះស្រីថែទាំ ចាត់ចែងទុកដាក់ ចេះលាក់សន្សំ សង្វាតខិតខំ រក្សាអោយគង់* » ។ « *ខ្លែងហើរដ្បិតខ្សល់ នាយថ្កើងដ្បិតពល រក្សាអោយសុខ ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក ដ្បិតភរិយាជា* » ។

៤. មិនប្រព្រឹត្តកន្លងចិត្តស្វាមី ( មិនក្បត់ចិត្តស្វាមី ) ។

៥. ឈ្លាសវៃ ប៉ិនប្រសប់ និងប្រឹងប្រែងជានិច្ចក្នុងកិច្ចការគ្រប់យ៉ាង ព្រោះខ្លួនមាននាទីជា « *មេផ្ទះ, មេកិច្ចការជាធំក្នុងគ្រួសារ* » ។

• ខ) របៀបរស់នៅរបស់ស្រី (*)

នារីពេលមានស្វាមី គប្បីចងចាំ គឺ :

១) ភ្លើងក្នុងកុំនាំចេញក្រៅ,

២) ភ្លើងក្រៅកុំនាំចូលក្នុង,

៣) ត្រូវអោយបុគ្គលដែលអោយ,

៤) មិនត្រូវអោយដល់បុគ្គលដែលមិនអោយ,

៥) ត្រូវអោយដល់បុគ្គលដែលអោយក្តី មិនអោយក្តី,

៦) ត្រូវអង្គុយដោយស្រួលបួល,

៧) ត្រូវបរិភោគដោយស្រួលបួល,

៨) ត្រូវដេកដោយស្រួលបួល,

៩) ត្រូវបូជាភ្លើង ឬបំរើភ្លើង,

១០) ត្រូវថ្វាយបង្គំទេវតាក្នុងផ្ទះ ។

សេចក្តីពន្យល់ :

• *ភ្លើងក្នុងកុំនាំចេញក្រៅ* ។ មានន័យថា រឿងរ៉ាវណាដែលសៅហ្មង ក្តៅក្រហាយ មិនល្អ អាក្រក់ ដែលជារឿងផ្ទៃក្នុងរបស់គ្រួសារខ្លួន, មាតាបិតាខ្លួន មិនត្រូវនាំចេញទៅផ្សាយ ដើរប្រាប់គេប្រាប់ឯង ដោយហោចទៅ សូម្បីតែសាច់

---

(*) ឱវាទ ១០ យ៉ាង របស់ធនញ្ជ័យសេដ្ឋី ដែលផ្តាំចំពោះនាងវិសាខា នៅពេលដែលធ្វើដំណើរ ទៅនៅខាងស្វាមីនាង, ជាឱវាទទាក់ទងទៅនឹងចរិយារបស់ភរិយា, សូមនាំមកចុះជាគតិជូន ព្រោះជារបស់មានសារសំខាន់ ហើយក៏ជាទីនិយមបំផុតនៃវប្បធម៌ និងអរិយធម៌របស់ខ្មែរ ។

ញាតិខ្លួនឡើយ ។

• *ភ្លើងក្រៅកុំនាំចូលក្នុង* ។ មានន័យថា រឿងណាដែលមិនល្អ មិនមានប្រយោជន៍ ជារឿងក្តៅក្រហាយ ហើយមិនទាក់ទងទៅនឹងសាច់រឿងរបស់គ្រួសារខ្លួនទេ មិនគប្បីនាំចូលមកក្នុងផ្ទះ អោយក្រុមគ្រួសារបានទទួលការក្តៅក្រហាយ ផងដែរនោះទេ ។ បើទោះជារឿងក្តៅក្រហាយនោះ ទាក់ទងទៅនឹងកេរ្តិ៍ឈ្មោះ និងផលប្រយោជន៍របស់គ្រួសារ ឬស្វាមីខ្លួនក្តី ក៏ត្រូវរកឱកាសនិយាយដែរ ដើម្បីកុំអោយក្តៅទាំងរឿង ហើយក្តៅទាំងមនុស្សទៀត ។ មានភរិយាខ្លះ ឃើញស្វាមីមកពីធ្វើការហត់នឿយ ឬមានរឿងមុខមិនស្រួល មកដល់ផ្ទះមិនទាន់ទាំងដាក់គូថអង្គុយផង ក៏ស្រាប់តែនាំយករឿងអាក្រក់ រឿងក្តៅក្រហាយ ទៅពិតទូលបញ្ចេះ ធ្វើអោយស្វាមីដែលកំពុងស្រួលៗនោះ ក្តៅក្រហាយឆេះភ្លាមមួយរំពេច ។ ប្រការនេះ នាងជាភរិយាគួរយល់ដឹង ។

• *ត្រូវអោយបុគ្គលដែលអោយ* ។ មានអ្នកមកខ្ចីទ្រព្យ បើជឿទុកចិត្តថានឹងសងវិញ សឹមអោយខ្ចី ។

• *មិនត្រូវអោយដល់បុគ្គលដែលត្រូវអោយ* ។ បើមានអ្នកមកខ្ចីទ្រព្យនោះ មិនគួរទុកចិត្តថាសងវិញទេ, មិនត្រូវអោយខ្ចីទេ ។ បើអោយខ្ចី ត្រូវគិតថារបស់នោះទុកដូចបោះចោលទៅក្នុងទឹកទន្លេ ។

• *ត្រូវអោយដល់បុគ្គលដែលអោយក្តី មិនអោយក្តី* ។ ត្រូវតែអោយដោយសង្ឃឹមថាសងវិញ ឬមិនសង ដូចជាបងប្អូនដែលយើងត្រូវតែជួយដោះទុក្ខធុរៈមួយទៀត បានដល់ការដាក់ទានដល់ស្មូមយាចក រួមទាំងការធ្វើបុណ្យទាន ដែលត្រូវធ្វើជាប្រពៃណីរបស់យើង ។

• *ត្រូវអង្គុយដោយស្រួលបួល* ។ ត្រូវអង្គុយដឹងខ្ពស់ ដឹងទាប, អង្គុយប្រយ័តប្រយែង មិនច្រងេងច្រងាង យះដៃយះជើង. ... ។

• *ត្រូវបរិភោគដោយស្រួលបួល* ។ ត្រូវមានសុជីវធម៌ក្នុងការបរិភោគអាហារ គឺបរិភោគអោយដឹងមុនក្រោយ, បរិភោគជាមួយអ្នកណា ពេលណាគួរបរិភោគ .... ។

• *ត្រូវដេកដោយស្រួលបួល* ។ គឺការរៀបចំដំណេកអោយបានសមរម្យស្រួលបួល រួមទាំងការត្រៀមវត្ថុចាំបាច់ខ្លះពេលចូលដេក កុំអោយពិបាកងើបដើរឆ្ងាយទៅយក ។ ទំនៀមខ្មែរពីដើម មុនដេក ភរិយាត្រូវម្ចុរបារី អប់ទឹកផ្កាលដាក់ចុងជើង ។ ក្នុងរឿងសិរី ៣ ប្រការ របស់ធម្មបាលមាណព ដែលដោះប្រស្នាជាមួយកបិលមហាព្រហ្ម បានអធិប្បាយថា : ពេលព្រឹក សិរីនៅមុខ ដូច្នេះត្រូវលុបមុខ, ពេលថ្ងៃ សិរីនៅទ្រូង ត្រូវលាបស្រឡាបដើមទ្រូង, ពេលល្ងាច សិរីនៅជើង ត្រូវលាងជើងមុនពេលចូលដេក ។ ម្យ៉ាងទៀត :

- មិនត្រូវកន្លងខ្លួនប្តី ឬជើងប្តី ព្រោះខ្មែរប្រកាន់ថា ប្រុសៗមានគ្រូបាធ្យាយកំណើតកាន់ ឬបើ ប្តីជាអ្នករៀនមន្តអាគម ក៏នឹងសាបអស់ ។

- ត្រូវដេកនៅខាងឆ្វេងស្វាមី ឯក្បាលដំណេក គួរដាក់នៅទិសខាងត្បូង ព្រោះ « ត្បូង » ប្រែថាក្បាល ។

- គួរមើលអោយបានច្បាស់ពេលដេក មិនត្រូវបែរជើងទៅរកស្វាមី មាតាបិតា ឬព្រះពុទ្ធរូបទេ ព្រោះដូចជាយើងយកជើងទៅធាក់លោកអញ្ចឹង ។

- ត្រូវដេកប្រយ័ត្នប្រយែង ក្រែងលេចកេរ្តិ៍ខ្មាស ឬពេលងើបពីដេករបូតសំពត់ជាដើម ។ ខ្មែរមានទំនៀមថា *" ប្រពន្ធត្រូវដេកក្រោយប្តី និងភ្ញាក់មុនប្តី "* ព្រោះលោកយល់ថា ប្តីធ្វើការនឿយហត់ពីថ្ងៃ ហើយឯប្រពន្ធនៅផ្ទះ ដូច្នេះត្រូវមើលខុសត្រូវ រៀបចំទុកដាក់ចានក្បានអោយហើយ, មើលទ្វារបង្អួច ក្រែងបិទមិនជិត, មើលភ្លើងក្រែងរាលឆេះ ។ ល ។ លុះដល់ភ្ញាក់ ត្រូវភ្ញាក់មុន ព្រោះម្យ៉ាង ដើម្បីកុំអោយឃើញសភាពមិនរៀបរយរបស់សំពត់ខោអាវខ្លួនពេលដេក និងរៀបចំអាហារ

ពេលព្រឹកសំរាប់ស្វាមីផង ព្រមទាំងបោសច្រាសផ្ទះសម្បែងអោយបានស្អាតបាត ស្រេចបាច់ ហើយម្យ៉ាងទៀត ក៏មិនគប្បីដេកកណ្តាលវាលដែរ ត្រូវមានអ្វីបិទបាំង ឬជាទីកំបាំងភ្នែកអ្នកផង ។

• *ត្រូវបូជាភ្លើង ឬបំរើភ្លើង* ។ ភ្លើងក្នុងទីនេះ បានដល់ស្វាមីដែលភរិយា ត្រូវគោរពបំរើ ប្រណិប័តន៍ ថ្នាក់ថ្នម រួមទាំងការបំពេញសេចក្តីត្រូវការខាងភេទ ផងដែរ ។ ភ្លើងនេះ បើយើងបូជា ឬបំរើមិនល្អ វានឹងអាចរលាក ឬឆេះដល់នាងជា ភរិយាពិតប្រាកដ ។

• *ត្រូវថ្វាយបង្គំទេវតាក្នុងផ្ទះ* ។ ទេវតាក្នុងផ្ទះនេះ បានដល់មាតាបិតា របស់ខ្លួនក្តី របស់ស្វាមីក្តី ដែលយើងនៅជាមួយ, និងមួយទៀត បានដល់គ្រឿង សក្ការបូជាក្នុងផ្ទះដែលយើងជឿគោរពបូជា ។ ការបំរើមាតាបិតា ការគោរពប្រណិ-ប័តន៍លោក ថ្វាយបង្គំលោក រមែងបាននូវអានិសង្ស និងសេចក្តីសុខជាពន់ប្រមាណ ព្រោះព្រះសម្មាសម្ពុទ្ធលោកបានមានពុទ្ធដីកាថា : *មាតាបិតាជាព្រះព្រហ្មរបស់កូន ផង ជាទេវតាដើមផង ជាគ្រូផង និងជាអាហុនេយ្យបុគ្គលរបស់កូនផង កូនណា គោរពបូជា បុណ្យរមែងកើតដល់កូនប្រុសស្រីនោះមិនដាច់* ។

ក្រៅពីឱវាទទាំង ១០ នេះ នៅមានឱវាទផ្សេងៗទៀតជាច្រើន ដែល សុទ្ធសឹងជាពាក្យទូន្មានចំពោះស្រី ដែលនឹងត្រូវមានស្វាមី ។ ជាពិសេស នៅក្នុង រឿងវិធូរបណ្ឌិតជាតក នៅពេលដែលព្រះនាងវិមលា ដែលជាមហេសីស្តេចនាគ ផ្តាំ ដល់បុត្រី គឺនាងឥរន្ទតី មុននឹងធ្វើដំណើរទៅជាមួយស្វាមី គឺបុណ្ណកយក្ស ។ អ្នក ប្រាជ្ញបណ្ឌិតយើងបានរៀបរៀងតែងពាក្យកាព្យឡើង ឈ្មោះថា " ច្បាប់ស្រី " (*) មានលំនាំជាបទភុជង្គលីលា ដែលខ្មែរយើងនិយមអោយកូនស្រីទន្ទេញណាស់ ។

ដំណើររួមរស់នៃស្វាមីភរិយា មិនមែនសំរាប់តែសេចក្តីសុខស្រួល ទាំង ផ្លូវកាយ ទាំងផ្លូវចិត្ត នៅក្នុងផ្ទះមួយជាមួយគ្នាប៉ុណ្ណោះទេ ។ គូស្វាមីភរិយា ត្រូវចេះ

ឆ្លៀតទាញយកប្រយោជន៍អំពីភាពស្និទ្ធស្នាលនៃការរួមរស់ជាមួយគ្នានេះ ជួយណែនាំ រំលឹកដាស់តឿនគ្នា អោយបណ្តុះចិត្តគំនិតមានជំនឿក្នុងព្រះសាសនា, អោយចេះប្រយ័ត្ន មិនបណ្តោយអោយធ្លាក់លង់ទៅក្នុងអបាយមុខណាមួយ មាន : ស្រី ស្រា ល្បែងភ្នាល់ ការសេពគប់រកមនុស្សអាក្រក់ជាមិត្ត ជាដើម ដែលជាហេតុនាំអោយវិនាសទាំងទ្រព្យ ទាំង ខ្លួនប្រាណ ។

មានស្វាមីភរិយាចំណាស់មួយគូ ដែលជាប់ឈ្មោះថាជាស្វាមីភរិយាឧត្តម បានទៅថ្វាយបង្គំព្រះពុទ្ធ ហើយទូលសួរថា : បពិត្រព្រះអង្គដ៏ចំរើន, យើងខ្ញុំព្រះករុណាបានគ្នាជាប្តីប្រពន្ធ ក្រោយពេលដែលបានស្គាល់គ្នាតាំងពីនៅក្មេងៗដូចគ្នា ហើយយើងខ្ញុំស្គាល់តែសេចក្តីសុខ ពុំដែលមានរឿងហេតុមោះហ្មងអ្វីនឹងគ្នាម្តងណាទេ ។ សូមព្រះអង្គមេត្តាពន្យល់ប្រាប់យើងខ្ញុំផង ថាតើយើងខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីអាចនឹងបានជួបគ្នាទៀត នៅជាតិក្រោយ ។

ព្រះពុទ្ធទ្រង់ត្រាស់តបប្រកបដោយគតិបណ្ឌិតថា : បើអ្នកទាំពីរមានជំនឿសាសនាដូចគ្នាបេះបិទ ( សមសទ្ធា ), បើអ្នកទាំងពីរទទួលយកសេចក្តីទូន្មាននៃព្រះសាសនាតាមរបៀបដូចគ្នាបេះបិទ ( សមសីលា ), បើអ្នកទាំងពីរសាងកុសលទានដូចគ្នា ( សមចាគា ), បើអ្នកទាំងពីរមានការសិក្សាអប់រំ និងវៃឆ្លាតប្រហាក់ប្រហែលគ្នា ( សមបញ្ញា ) ... ទៅជាតិក្រោយទៀត អ្នកទាំងពីរនឹងបានប្រកបដោយចិត្តដូចគ្នាទៀត ពោលគឺ នឹងអាចជួបគ្នាគ្រប់ៗជាតិ ជាមិនខាន ។

*

## សុភាសិត

*ជីវិតគ្មានសាសនា គឺជីវិតគ្មានគោលការណ៍*

*ហើយជីវិតគ្មានគោលការណ៍ ទុកដូចនាវាគ្មានចង្កូត ។*

( មហាត្មៈគន្ធី )

# តើអ្វីខ្លះជាមង្គល របស់មនុស្សគ្រប់រូប

**ឱម ខែម**
ដកស្រង់រៀបរៀង និងនិពន្ធ

ក្នុងពុទ្ធសាសនា មានពាក្យទូន្មានប្រៀនប្រដៅច្រើន ដែលទាក់ទងនឹងបញ្ហាជីវិត, បញ្ហាសីលធម៌សង្គម ដែលព្រះសម្មាសម្ពុទ្ធលោកបានសំដែងប្រាប់ពន្យល់ចំពោះមនុស្សទូទៅ អោយដឹងការខុស-ត្រូវ អាក្រក់-ល្អគ្រប់យ៉ាង ។ ឧត្តមគតិ និងតម្លៃសីលធម៌របស់ពុទ្ធសាសនា ដែលបានបង្ហាញជាភស្តុតាងនៅក្នុងសូត្រនានា មានបរាភវសូត្រ, សិង្គាលោវាទសូត្រ និងមង្គលសូត្រ ជាដើម មានប្រយោជន៍ណាស់ មិនត្រឹមតែចំពោះជំនាន់មនុស្សក្នុងអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែ ឧត្តមគតិ និងតម្លៃសីលធម៌នេះ របស់ពុទ្ធសាសនា នៅតែបន្តនិរន្តរភាពទៅអោយជំនាន់មនុស្សប្រុសស្រី នៅក្នុងពិភពលោកនេះ សំរាប់សិក្សា និងយកមកអនុវត្តបាន គ្រប់កាលៈទេសៈទាំងអស់ ។

តទៅនេះ យើងនឹងលើកយកឧត្តមគតិ និងតម្លៃសីលធម៌របស់ពុទ្ធ-សាសនា នៅក្នុងព្រះសូត្រដែលសំដែងនូវ « មង្គលដ៏ឧត្តម » មកសិក្សា និងពិចារណា ។ តើអ្វីទៅហ្ន៎ ជាមង្គល ? រូបដែលបានឃើញហើយឬ ជាមង្គល ? សំឡេងដែលបានស្តាប់ហើយឬ ជាមង្គល ? អារម្មណ៍ដែលបុគ្គលបានដឹងហើយឬ ជាមង្គល ? តើនរណាដឹងនូវមង្គលនោះ ?

សំណួរនេះ មិនបានទទួលចម្លើយព្រមព្រៀងគ្នាទេ ។ ការសួរដេញដោល

រកខុស-ត្រូវ និងរកសេចក្ដីពិតអំពីមង្គលនេះ បានបង្កើតអោយមានព្រឹត្តិការណ៍រំជើបរំជួលមួយ អូសបន្លាយពេលវេលា ជាមួយនឹងទំនាស់ដោយពាក្យសំដីឆ្លើយឆ្លងគ្នាអស់ ១២ ឆ្នាំ ទើបចប់ ។

គួររំលឹកត្រួសៗថា នៅក្នុងពុទ្ធកាល, ការដណ្ដឹងសួររកនូវ « មង្គល » ត្រូវបានមហាជនក្នុងជម្ពូទ្វីបលើកយកមកធ្វើជាប្រធានបទពិភាក្សានៅក្នុងអង្គប្រជុំនៃសាកច្ឆាមួយ ដោយមានអ្នកចូលរួមស្ដាប់ច្រើនរូប និងមានបុរសជាវាគ្មិនសំខាន់ ៣ រូបគឺ លោក *ទិដ្ឋមង្គលិក*, លោក *សុតមង្គលិក* និងលោក *មុតមង្គលិក* ជាអ្នកអធិប្បាយបកស្រាយពន្យល់ ។

- ទស្សនៈរបស់វាគ្មិន ទិដ្ឋមង្គលិក ថា រូបដែលបុគ្គលមើលឃើញហើយជាអភិមង្គលក្នុងលោក, ដូចជា ក្រោកពីព្រលឹមឃើញសត្វត្រដាងស្លាបហើរតាមខ្យល់ខ្លះ, ឃើញស្ត្រីមានផ្ទៃពោះខ្លះ, សេះអាជានេយ្យខ្លះ ... យ៉ាងនេះជាដើម ។

- វាគ្មិន សុតមង្គលិក ថាមិនមែនអញ្ចឹងទេ, តាមធម្មតា, ភ្នែកនេះរមែងឃើញរូបស្អាតខ្លះ មិនស្អាតខ្លះ, ប្រសើរខ្លះ មិនប្រសើរខ្លះ, ... មិនចាត់ជាមង្គលបានទេ, មានតែសំឡេងដែលបុគ្គលស្ដាប់ហើយប៉ុណ្ណោះឯង ទើបជាមង្គលឧត្តម ដូចជា ក្រោកពីព្រលឹមបានឮថា « ចំរើនឡើងហើយ » ថា « ចិត្តល្អ » ថា « ចំរើនដោយសិរី » ថា « ថ្ងៃនេះ ឫក្សល្អ, យាមល្អ, ថ្ងៃល្អ, មង្គលល្អ » ដូច្នេះជាដើម ។

- ឯទស្សនៈរបស់វាគ្មិន មុតមង្គលិក ថា « អារម្មណ៍ដែលបុគ្គលដឹងហើយ ទើបជាមង្គលដ៏ឧត្តម » ។ តាមធម្មតា, ត្រចៀកនោះ រមែងស្ដាប់សំឡេងពីរោះខ្លះ មិនពីរោះខ្លះ, ពេញចិត្តខ្លះ មិនពេញចិត្តខ្លះ, ... មិនគួរចាត់ជាមង្គលបានទេ, គឺអារម្មណ៍ដែលបុគ្គលបានដឹងហើយប៉ុណ្ណោះឯង គឺជាមង្គល, ក្លិន រស និងផោដ្ឋព្វៈ គេសន្មតថាជាមង្គលដ៏ខ្ពង់ខ្ពស់ ក្នុងលោក ដូចជាក្រោកពីព្រលឹមបានទទួលនូវក្លិនផ្កា ពានផ្កាបទុមខ្លះ, ទំពាឈើស្ទន់ជម្រះធ្មេញខ្លះ, ប៉ះពាល់វត្ថុខ្លះ ... យ៉ាងនេះ

ជាដើម ។

ការជជែកគ្នាអំពីមង្គលមិនចេះចប់ ដោយបុរសជាវាគ្មិនទាំង ៣ នាក់នោះ មិនអាចនិយាយសម្រុល ឬសម្រុបសំដីគ្នាបាន ។ ពេលនោះ ពួកមនុស្សទាំងអស់ រួមទាំងទេវតារក្សាមនុស្សលោកផង លើកលែងតែព្រះអរិយសាវ័កចេញ បានបែកគ្នាជា ៣ ក្រុម ដោយអំណាចទិដ្ឋមង្គល សុតមង្គល និងមុតមង្គល ។ ក្រុមសំឡេងគាំទ្ររបស់ក្រុមមនុស្សចំពោះទស្សនៈរបស់វាគ្មិននីមួយៗ បានបង្កកើតចេញជាពាក្យសំដីគ្រោតគ្រាតសាសងគ្នា ខ្វះការទទួលខុសត្រូវ ។ ទំនាស់ពាក្យសំដីរបស់ក្រុមមនុស្សទាំង ៣ បណ្តាលអោយកើតជាកោលាហល វឹកវរ ជ្រួលច្របល់ពេញទាំងសកលជម្ពូទ្វីប ទាំងពិភពចក្រវាឡ រាលដាលនាំអំពល់រហូតដល់ពិភពជាទីនៅនៃព្រហ្មអស់ពេល ១២ ឆ្នាំ ។ ប៉ុន្តែ ទំនាស់ពាក្យសំដីទាំងប៉ុន្មាន និងការរំជើបរំជួលទាំងនោះត្រូវបានដោះស្រាយ និងបញ្ចប់ដោយស្ងប់សុខសាន្ត តាមរយៈធម្មទេសនារបស់ព្រះពុទ្ធសក្យមុនី ។

ក្រោយព្រះពុទ្ធបរិនិព្វានទៅ សាវ័ករបស់ព្រះអង្គបានកោះប្រជុំគ្នាជាមហាសង្គាយនាមួយ នៅរាជគហៈ ដើម្បីប្រមូលចងក្រងសេចក្តីប្រៀនប្រដៅរបស់ព្រះអង្គ ដោយខ្លាចក្រែងពាក្យប្រៀនប្រដៅទាំងនោះ ត្រូវភ្លេចភ្លាំង ឬបកស្រាយខុសនៅពេលខាងមុខ ។ សម័យប្រជុំពេញអង្គ ដែលភិក្ខុទាំងអស់សុទ្ធតែជាព្រះអរហន្តបានរួមប្រជុំដើម្បីរៀបចំកិច្ចការដ៏ឧត្តមនេះ យ៉ាងកុះករ ក្រោមអធិបតីភាពព្រះមហាកស្សបៈ ជាព្រឹទ្ធសាវ័ក ។ អានន្ទ, និងភិក្ខុជាច្រើនអង្គឯទៀត ដែលបានបំរើព្រះពុទ្ធដោយផ្ទាល់ និងបានត្រងត្រាប់ស្តាប់ពាក្យប្រៀនប្រដៅព្រះអង្គដោយផ្ទាល់ ក៏មានវត្តមាននៅឱកាសនោះដែរ ។

ពាក្យប្រៀនប្រដៅទាំងអស់ មានប្រភេទ ៨៤.០០០ ចាត់ដោយធម្មក្ខន្ធតាមផេវវាចា ដែលព្រះអានន្ទបានប្រកាសនោះ ត្រូវបានចារនៅលើស្លឹករឹត ហើយ

ប្រមូលផ្ដុំដាក់នៅក្នុងកញ្ជើមួយ ។ ក្រោយពេលចប់មហាសង្គាយនា, សំណេរទាំងអស់ត្រូវបានរំលែកដាក់ក្នុងកញ្ជើបី គឺ :

• កញ្ជើទីមួយ : វិនយបិដក មាន ២១.០០០ ធម្មក្ខន្ធ ( ជាគម្ពីរស្ដីពីក្រឹត្យក្រមដែលអង្គព្រះសម្ពុទ្ធទ្រង់បញ្ញត្តិ និងទ្រង់អនុញ្ញាតទុក សំរាប់ការប្រព្រឹត្តរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា និងវត្តអារាម ) ។ គម្ពីរវិន័យនេះ មានសេចក្ដីពិស្ដារណាស់ ជាកញ្ចក់ឆ្លុះមើលជីវប្រវត្តិអង្គព្រះសម្ពុទ្ធ ក្នុងកាលដែលទ្រង់គង់ធរមាននៅឡើយ ព្រមទាំងហេតុការណ៍ផ្សេងៗ នៅប្រទេសឥណ្ឌាសម័យព្រះអង្គ ដូចប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ការរចនា និងវិទ្យាសាស្ត្រផ្សេងៗ ‐ ល ‐ ។

• កញ្ជើទីពីរ : សុត្តន្តបិដក មាន ២១.០០០ ធម្មក្ខន្ធ ( ជាគម្ពីរស្ដីពីសូត្រ, គឺឱវាទ ឬធម៌ទេសនារបស់ព្រះពុទ្ធ និងសាវ័កសំខាន់ៗរបស់ព្រះអង្គ ដែលទ្រង់បានសំដែងនៅក្នុងឱកាសផ្សេងៗ ឬក្នុងឱកាសជាច្រើន ចំពោះមនុស្សផ្សេងៗគ្នា ប្រាប់ពន្យល់អោយដឹងការខុស‐ត្រូវ អាក្រក់‐ល្អ គ្រប់យ៉ាង, តែទ្រង់មិនបញ្ញត្តិ ទ្រង់មិនអនុញ្ញាតទេ ។

• កញ្ជើទីបី : អភិធម្មបិដក មាន ៤២.០០០ ធម្មក្ខន្ធ ( ជាគម្ពីរប្រាប់ពន្យល់អំពីបរមត្ថវិជ្ជានៃព្រះធម៌ គឺ ចិត្ត ចេតសិក រូប និព្វាន ដែលជាធម៌ល្អិតសុខុមគម្ភីរភាព, តែមិនមានបញ្ញត្តិ ឬអនុញ្ញាតទេ ) ។

ប្រជុំពុទ្ធវចនៈទាំង ៣ ចំណែកនេះគឺ ព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ហៅដោយរួបរួមថា ព្រះត្រៃបិដក ព្រោះទុកដូចជាកញ្ជើ ឬល្អី ឬក៏ភាជនៈ ដែលដាក់វត្ថុ ៣ ចំណែក អោយស្ថិតនៅ មិនរាត់រាយខ្ចាត់ខ្ចាយ ។ ប្រទេសកម្ពុជាយើងបោះពុម្ពជាសៀវភៅខ្នាតធំ មានចំនួន ១១០ សៀវភៅ ជាចំនួនដែលលើសផុតគណនា បើប្រៀបធៀបទៅនឹងពាហិរសាសនាទាំងអស់ក្នុងលោក ។

នៅក្នុងព្រះបរិត្ត ឈ្មោះមង្គលសូត្រ ដែលព្រះអានន្ទលោកបានសំដែង

ប្រាប់អំពីមង្គល ៣៨ ប្រការ នៅក្នុងសម័យប្រជុំពេញអង្គនៃមហាសង្គាយនានោះថា *« ឯវម្មេ សុតំ ... »* សូត្រនេះ គឺខ្ញុំឈ្មោះអានន្ទបានស្តាប់មក យ៉ាងនេះថា :

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងយប់មួយ, កាលដែលវេលារាត្រីបឋមយាមកន្លងទៅ ទេវតាមួយអង្គបានចូលក្រាបបង្គំគាល់ និងទូលសួរព្រះអង្គថា ទេវតា និងមនុស្សទាំងឡាយជាច្រើនប្រាថ្នានូវសួស្តី បានស្វែងរកនូវមង្គលទាំងឡាយ សូមព្រះអង្គសំដែងប្រាប់នូវមង្គល ដ៏ឧត្តមនោះ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងតបពាក្យទេវតានោះ ដោយពុទ្ធភា-សិតជាគាថា(*) ( កម្រងពុទ្ធវចនៈ ) មានសេចក្តីដូចតទៅនេះ :

• ពុទ្ធភាសិតទីមួយ- *ការមិនសេពគប់បុគ្គលពាលទាំងឡាយ ១, ការសេពគប់បុគ្គលជាបណ្ឌិតទាំងឡាយ ១, ការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១, ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីពីរ- *ការនៅក្នុងប្រទេសដ៏សមគួរ ១, ភាពនៃបុគ្គលបានធ្វើ បុណ្យទុកក្នុងកាលមុន ១, ការតម្កល់ខ្លួនដោយប្រពៃមួយ ១, ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីបី- *ពាហុសច្ចៈ ( ភាពនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន ) ១, សិល្បសាស្ត្រ ( គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួសនិងគ្រហស្ថ ១ ), វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១, វាចាដែលបុគ្គលពោលត្រឹមត្រូវ ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីបួន- *ការបំរើមាតា ១, ការបំរើបិតា ១, សេចក្តីសង្គ្រោះ*

---

(*) សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ភាគទី ៥២ ទំព័រ ៤, និងខុទ្ទកនិកាយ សុត្តនិបាត, ភាគទី ៥៤ ពីទំព័រ ៨៥ ។

*បុត្តនិងភរិយា ១, ការងារមិនច្របូកច្របល់ ១, ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីប្រាំ. *ទាន ១, ការប្រព្រឹត្តធម៌ ១, សេចក្តីសង្គ្រោះពួកញាតិ ១, ការងារមិនមានទោស ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីប្រាំមួយ. *ការមិនត្រេកអរក្នុងបាប និងការវៀរចាកបាប ១ , ការមិនផឹកនូវទឹកស្រវឹង ១, សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១, ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីប្រាំពីរ. *សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព ១, ការប្រព្រឹត្តបន្ទាបខ្លួន ១, សេចក្តីត្រេកអរចំពោះរបស់ដែលមាន ១, ភាពនៃបុគ្គលអ្នកដឹងឧបការៈដែលអ្នកដទៃធ្វើដល់ខ្លួន ១, ការស្តាប់ធម៌តាមកាល ១, ទាំង ៥ នេះ ជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីប្រាំបី. *សេចក្តីអត់ធន់ ១, ភាពនៃបុគ្គលដែលប្រដៅងាយ ១, ការបានឃើញបានជួបសមណៈទាំងឡាយ ១, ធម្មសាកច្ឆា ( ការសន្ទនាធម៌ ) តាមកាល ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីប្រាំបួន. *សេចក្តីព្យាយាមដុតបាបធម៌ ១, ការប្រព្រឹត្តធម៌ដ៏ប្រសើរ ១, ការឃើញអរិយសច្ចទាំងឡាយ ១, ការធ្វើអោយជាក់ច្បាស់នូវព្រះនិព្វាន ១, ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។*

• ពុទ្ធភាសិតទីដប់. *ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១, មិនមានសេចក្តីសោក ១, មានធូលីគឺរាគៈទៅប្រាសហើយ ១, ចិត្តក្សេមក្សាន្ត ១, ទាំង ៤នេះ ជាមង្គលដ៏ឧត្តម ។*

ទេវតា(*) និងមនុស្សទាំងឡាយធ្វើនូវមង្គលប្រាកដដូច្នេះហើយ ជាអ្នក

(*) ទេវតាមានន័យ ២ យ៉ាងគឺ សម្មតិទេព ( ទេវតាដោយសន្មត ) បានដល់ថ្នាក់អ្នកដឹកនាំ មានក្សត្រ ជាដើម និង ឧប្បត្តិទេព ( ទេវតាដោយកំណើត ) បានដល់ទេវតានៅឋានសួគ៌ ។

មិនចាល់ចាញ់ក្នុងទីទាំងពួង តែងដល់នូវសួស្តីក្នុងទីទាំងពួង ( ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា ) មង្គលទាំង ៣៨ ប្រការ មានការមិនមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតា និងមនុស្សទាំងអម្បាលនោះ ជាមង្គលដ៏ឧត្តម ។

ពុទ្ធភាសិតសំដែងពីមង្គលទាំង ៣៨ ប្រការនេះ ងាយស្តាប់ ងាយយល់ និងមានភាពស្របទៅនឹងទិដ្ឋភាពគ្រប់យ៉ាងនៃជីវិតរបស់មនុស្សទូទៅ ។

បញ្ហាគ្រប់យ៉ាងរបស់មនុស្សលោកបច្ចុប្បន្ននេះ អាចកាត់បន្ថយបាន ប្រសិនបើមនុស្សទាំងអស់គ្នាសិក្សាក្នុងពុទ្ធវចនៈនេះ ហើយប្រតិបត្តិតាមដោយម៉ត់ចត់ ។ មង្គលដ៏ឧត្តម ៣៨ ប្រការនេះ ជាធម៌សំរាប់ដោះស្រាយបញ្ហាជីវិត បញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច និងបញ្ហាសីលធម៌ ។

សូមអនុមោទនា !

*

## សុភាសិត

- ព្រះអាទិត្យធ្វើអោយដើមឈូកនៅក្នុងបឹងលូតលាស់ស្រស់ឡើងក្នុងវេលាថ្ងៃ,
- ព្រះចន្ទធ្វើអោយផ្កាឈូករីកឡើងក្នុងវេលាយប់,
- មហាមេឃបង្អុរភ្លៀងមិនបាច់មានគេបន់ស្រន់,
- អ្នកប្រាជ្ញតែងមានធម៌សង្គ្រោះ ដោយធ្វើអោយអ្នកដទៃបានចំរើនសតិបញ្ញា,

ល្វី-ហ្វីណូត៍

( ស្រង់យកពីពាក្យព្រេងជាភាសាសំស្ក្រឹត )

# ស្មារតីសន្តិភាព និង ប្រជាធិបតេយ្យ
## SPIRIT OF PEACE AND DEMOCRACY

**ឆយ យីហ៊ាង**
បណ្ឌិតទស្សនវិជ្ជា

យើងបានរស់នៅជាច្រើនសតវត្សមកហើយ ដែលលិចលង់នៅក្នុងវប្បធម៌សង្គ្រាម ក្នុងវប្បធម៌កាប់សំលាប់បង្ហូរឈាម ក្នុងវប្បធម៌ដែលហេតុផលនៃការប្រើកំលាំងបាយឈ្នះលើកំលាំងដែលស្វែងរកហេតុផល ( in the culture that the reason of power has prevailed over the power of reason ) ។ នោះមិនមែនជាការពន្យល់អោយយល់គ្នាទៅវិញទៅមកទេ តែគឺដើម្បីឈ្នះ ។ ឈ្នះដោយសារករប្រើគ្រប់មធ្យោបាយ ។ ទោះបីមធ្យោបាយនោះអាក្រក់យ៉ាងណាក៏ដោយ ក៏យើងយកវាមកប្រើប្រាស់ដែរ ព្រោះគោលបំណងធំបំផុតគឺដើម្បីឈ្នះ ។

ក្នុងការរស់នៅបែបនោះ តើយើងបានបំពេញអ្វីខ្លះ ? គឺជាហេតុផលមួយ ដែលតាមការពិត យើងបានខាតបង់ទាំងអស់គ្នា ( In fact, it is a reason that we have lost together ) ។ យើងអាចនិយាយថា យើងបានចំណាយរាប់សតវត្សមកហើយនូវថ្លៃសង្គ្រាម ជាពិសេស ថ្លៃជីវិតរបស់មនុស្សដែលជាថ្លៃខ្ពស់បំផុត ។ ស្ត្រី យុវជន កុមារ ទារក ត្រូវបានបាត់បង់ជីវិតដោយគ្មានទោសកំហុស ។ ហេតុអ្វីបានជាពួកគេត្រូវបាត់បង់សិទ្ធិមានជីវិត ? នេះជាការបាត់បង់មួយដ៏ធំ ដែលមិនសមហេតុផលសោះឡើយ ។

ក្នុងការបំបាត់សង្គ្រាម និងការកសាងសន្តិភាព លោក សាពួរ រ៉ាស៊ិច ( Shapour Rassekh ) ពោលថា « ឥឡូវនេះ យើងត្រូវចេះចំណាយទៅលើ

ថ្លៃសន្តិភាពម្តងវិញ ( Il nous faudra maintenant savoir payer le prix de la paix Ì ) ។ គ្មានហេតុផលណាមួយដែលអះអាងថា យើងមិនអាចចំណាយទៅលើថ្លៃសន្តិភាពបានទេ ។ លោក ពីយ៉េរ-វ៉ី ( Pierre Weil ) ក៏បានពោលដែរថា « សង្គ្រាមចាប់កំណើតពីក្នុងស្មារតីរបស់មនុស្ស ។ គឺក្នុងស្មារតីរបស់មនុស្សនោះហើយ ដែលអាចបង្កើតបាននូវការការពារសន្តិភាពវិញដែរ » ( Les guerres prenant naissance dans l'esprit des hommes, c'est dans leur esprit que doivent être érigées les défenses de la paix ) ។

ដើម្បីបណ្តុះស្មារតីសន្តិភាព គួរជ្រើសរើសវិធីល្អៗមកអនុវត្តនៅក្នុងលទ្ធិប្រជាធិបតេយ្យ ។ ប្រជាធិបតេយ្យ ជាអ្វី ? លោក អង់តូនី-ហ្គីដិន ( Anthony Giddens ) យល់ថា « ប្រជាធិបតេយ្យ គឺជាប្រព័ន្ធមួយ ដែលក្នុងនោះមានការប្រណាំងប្រជែងប្រកបដោយប្រសិទ្ធភាព រវាងគណៈបក្សនយោបាយនានាដើម្បីដណ្តើមតួនាទីកាន់អំណាច ។ នៅក្នុងប្រជាធិបតេយ្យមួយ មានការបោះឆ្នោតធម្មតា និងត្រឹមត្រូវ ដែលនៅក្នុងនោះ មានការចូលរួមពីសមាជិកទាំងអស់នៃប្រជាជន ។ សិទ្ធិស្តីពីការចូលរួមប្រកបដោយប្រជាធិបតេយ្យ ដើរទន្ទឹមនឹងសេរីភាពពលរដ្ឋ ពោលគឺ សេរីភាពនៃការបញ្ចេញយោបល់ និងការពិភាក្សាទាំងអស់គ្នា ជាមួយនឹងសេរីភាពបង្កើត និងសេរីភាពចូលរួមជាមួយក្រុម ឬសមាគមនយោបាយ ( Democracy is a system involving effective competition between political parties for positions of power. In a democracy, there are regular and fair elections, in which all member of the population may take part. These rights of democratic participation go along with civil liberties - freedom of expression and discussion together with the freedom to form and join political groups

or associations ). ។

វិធីល្អបំផុតនៅក្នុងលទ្ធិប្រជាធិបតេយ្យ គឺជាវិធីប្រើគំនិតដើម្បីពិភាក្សាគ្នា ។ គឺមានតែការពិភាក្សាគ្នានេះទេ ទើបយើងអាចដឹងច្បាស់ពីចំណុចព្រមព្រៀង និងចំណុចមិនព្រមព្រៀង ទើបយើងអាចវាស់បាននូវការខិតជិតគ្នា និងការឃ្លាតឆ្ងាយពីគ្នា ។ លោក ហ្វេដេរីកូ-ម៉ៃយ័រ ( Federico Mayor ) ពោលថា « និយមន័យពីរបែបស្ដីពីមនុស្សដែលអារីស្តូត ( Aristote ) បានផ្ដល់អោយយើងថា *មនុស្សជាសត្វចេះធ្វើនយោបាយ* និងជា*ភាវៈដែលមានសម្បទាពីកំណើតខាងការនិយាយស្ដី* បានផ្ដល់អោយយើង នូវតថភាពមួយដូចគ្នាគឺ : ជីវិតក្នុងសង្គមអាចប្រព្រឹត្តទៅបាន លុះត្រាតែការងាររួម ត្រូវបានលើកយកមកជជែកវែកញែក និងដោះស្រាយដោយសារការចរចា និងការស្រុះស្រួលគ្នា តែមិនមែនដោយសារមធ្យោបាយកំលាំងបាយឡើយ » ( Les deux définitions que nous donnent aristote de l'homme « animal politique » et « être doué de parole » nous renvoient vers une même réalité : la vie ... dans la société n'est possible que si les affaires en commun sont discuteés et résolues grâce au dialogue et l'arrangement et non au moyen de la force ) ។

នៅក្នុងលទ្ធិប្រជាធិបតេយ្យ អ្វីៗទាំងអស់ សុទ្ធតែស្ថិតនៅក្នុងគោលការណ៍សមភាព ដែលក្នុងនោះមានសិទ្ធិស្មើគ្នា និងមានទំនួលខុសត្រូវដូចគ្នា ជាពិសេសគឺ ការគោរពគ្នាទៅវិញទៅមក ។ សន្ដានចិត្ត ជាកម្មសិទ្ធិចំបងនៃប្រជាធិបតេយ្យ ។ គ្មានប្រជាធិបតេយ្យណាមួយ ដែលអាចប្រព្រឹត្តទៅបានដោយខ្វះតម្លាភាព និងសច្ចភាពទេ ។ សិទ្ធិ សេរីភាព និងប្រជាធិបតេយ្យ ត្រូវដើរស្របច្បាប់ ។ រីឯ ប្រជាធិបតេយ្យដែលមិនដើរស្របច្បាប់ ជាប្រជាធិបតេយ្យអនាធិបតេយ្យ ។

ប្រជាធិបតេយ្យអានាធិបតេយ្យ តែងបំពុលបរិយាកាសសង្គម, បណ្ដាលអោយសង្គមរិលរល់នៅក្នុងសភាពច្របូកច្របល់មួយ ។ ប្រជាធិបតេយ្យអនាធិបតេយ្យខុសអំពីអំណាចផ្ដាច់ការ ។ ប្រជាធិបតេយ្យអនាធិបតេយ្យ ធ្វើអោយអំណាចធ្លាក់ទៅក្នុងដៃពលរដ្ឋ តែអំណាចនោះត្រូវបានគេយកទៅប្រើប្រាស់ដោយឥតគោរពច្បាប់ ដោយប្រព្រឹត្តតាមអំពើចិត្តរបស់បុគ្គល ។ ចំណែកអំណាចផ្ដាច់ការវិញ វាជាមូលដ្ឋានសំរាប់អោយបុគ្គល ឬបក្សពួក មានតួនាទីខ្ពស់ហួសមហាជន ធ្វើអោយមហាជនស្ថិតនៅក្នុងសភាពស្ងប់ស្ងៀមបាត់សិទ្ធិ សេរីភាព ។ ទាំងអំណាចផ្ដាច់ការទាំងប្រជាធិបតេយ្យអនាធិបតេយ្យ សុទ្ធសឹងត្រូវចៀសវាង ហើយជំរើសផ្លូវដែលត្រូវទទួលយកនោះ គឺប្រជាធិបតេយ្យ ដូចពោលខាងលើ ។

ដើម្បីកសាងបុគ្គលខ្លួនអោយរីកចំរើនគ្រប់វិស័យ ត្រូវចាប់ផ្ដើមកសាងស្មារតីរបស់ខ្លួន ដោយខ្លួនឯងជាមុនសិន គឺការកសាងស្មារតីសន្ដិភាព និងស្មារតីប្រជាធិបតេយ្យ ។ នេះជាការតស៊ូ អប់រំខ្លួន ដោយខ្លួនឯង ឆ្លុះបញ្ចាំងមើលខ្លួនឯងក្នុងឋានៈខ្លួនជាប្រធានវិស័យភាពផង និងជាវត្ថុវិស័យភាពផង ។ ក្នុងដំណើរឆ្លុះបញ្ចាំងនេះ នៅក្នុងស្មារតី កត្តាសកម្មកាន់តែកើនឡើងជាលំដាប់ ឯកត្តាអសកម្មកាន់តែថយចុះទៅវិញ ។ គួរចងចាំថា គ្មានអ្វីដែលធ្លាក់ក្នុងកណ្ដាប់ដៃយើង ដោយគ្មានការតស៊ូឡើយ ។ ដំណើរជំនះគ្រប់ឧបសគ្គ ដើម្បីស្មារតីសន្ដិភាព និងស្មារតីប្រជាធិបតេយ្យ ជាកត្តាជំរុញអោយបុគ្គល គ្រួសារ និងសង្គម ប្រកបដោយសេចក្ដីថ្លៃថ្នូរ រុងរឿង ។ ប្រការដែលគួរអោយចងចាំមួយទៀត គឺសកម្មភាពខ្វះសណ្ដាប់ធ្នាប់ សកម្មភាពហឹង្សា និងសកម្មភាពសង្គ្រាម សុទ្ធសឹងស្ដែងចេញមកពីស្មារតីខ្វះសណ្ដាប់ធ្នាប់ ស្មារតីហឹង្សា និងស្មារតីសង្គ្រាម ដូចដែលលោក ពីយ៉េរ វ៉ី ( Pierre Weil ) បានអះអាងខាលើ ។ ហេតុនេះ ការឆ្លុះបញ្ចាំងបុគ្គលខ្លួន ដោយខ្លួនឯង ដើម្បីជំរុះចោលកត្តាអវិជ្ជមានទាំងអស់នេះ ជាកត្តាចាំបាច់ និងបន្ទាន់ នៅក្នុងស្ថាន.

ភាពកម្ពុជា សព្វថ្ងៃ ។



ឯកសារពិគ្រោះ :

1. Anthony Giddens : *Runaway World*, Profille Books Ltd, London, 1999

2. Ingomar Hauchler and Paul M. Kennedy : *Global Trends,* a Development and Peace foundation Book, Continnuum, New Year, 1994.

3. Pierre Weil : *L'Art de vivre en Paris*, vers une nouvelle conscience de la paix, UNESCO, Paris, 1990

4. Shapour Rasseckh : *Éducation et Culture de la Paix*, IBE data, UNESCO, 1996

*

# ឥទ្ធិពលព្រះពុទ្ធសាសនានៅកម្ពុជា

ដោយបណ្ឌិត **ខូក ធីតា**
នាយិការងមហាវិទ្យាល័យទស្សនវិជ្ជា
( សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ ២ )

ឥទ្ធិពលពុទ្ធសាសនា បានចាក់គ្រឹះយ៉ាងមាំក្នុងចិត្តគំនិតកូនខ្មែរ សង្គមខ្មែរ ទំនោរខ្មែរ មនោគមវិជ្ជាខ្មែរ តាំងពីយូរអង្វែងណាស់មកហើយ ។ មានវត្តអារាមជាច្រើន ប្រកបទៅដោយស្ថាបត្យកម្មខ្មែរ មានវិហារ កុដិ សាលា ដ៏ល្អៗ ត្រូវបានពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លា កសាងឡើងធ្វើជាសេនាសនៈសំរាប់ព្រះសង្ឃ ដែលនិមន្តមកអំពីទិសទាំង ៤ គង់នៅ និងជាទីសំរាប់ធ្វើបុណ្យទាន សមាទាន រក្សាសីលជាដើម ។ ប្រជាជនខ្មែរទាំងប្រុស ទាំងស្រី ភាគច្រើន ដែលបានថ្វាយខ្លួនជាឧបាសកឧបាសិកា តែងតែបំពេញកិច្ចការកុសល ធ្វើបុណ្យ ឱ្យទាន រក្សាសីល ៥ សីល ៨ សីល ១០ និងធ្វើសមាធិកម្មដ្ឋានជាដើម នៅទីនោះ ។ កាលសម័យបុរាណ ក្មេងៗកូនចៅអ្នកស្រុក តែងបានចូលទៅសិក្សារៀនសូត្រវិជ្ជាអក្សរសាស្ត្រ នព្វន្តសាស្ត្រ សិល្បៈ និងវិជ្ជាគុណដំបង គុណដាវ ជាដើម នៅក្នុងទីវត្តអារាម ដែលមានព្រះសង្ឃជាគ្រូបាធ្យាយ ។ អ្នកខ្លះក៏បានសុំផ្នួសបួសជាសាមណេរ ឬជាភិក្ខុ សិក្សារៀនសូត្រធម៌អាថ៌ ក្នុងព្រះពុទ្ធសាសនា ។

ឥទ្ធិពលពុទ្ធសាសនា ដែលបានចូលស៊ប់ចាក់ឫសយ៉ាងមាំក្នុងសង្គមខ្មែរ ចិត្តគំនិតខ្មែរ មានជាអាទិ៍ :

- ជំនឿ

. ប្រពៃណី ទំនៀមទម្លាប់

. សិល្បៈ

. អក្សរសិល្ប៍

## ក. ជំនឿ

ឥទ្ធិពលពុទ្ធសាសនាបានបង្កើតឱ្យមាន :

១. ជំនឿ បុណ្យ បាប

២. ជំនឿ កម្ម ផល

៣. ជំនឿ សច្ចៈ សុចរិត យុត្តិធម៌

៤. ជំនឿ ស្ថានសួគ៌ ស្ថាននរក ។ ល ។ ដែលបានជាកត្តាដ៏ធំមួយ ជួយលើកស្ទួយសង្គមខ្មែរ មនុស្សខ្មែរ ឱ្យមានសីលធម៌ មនុស្សធម៌ ស្គាល់បុណ្យបាប ហើយខំប្រឹងធ្វើ ខំប្រឹងកសាងអំពើល្អ គ្រប់ៗគ្នា ។

## ខ. ប្រពៃណី ទំនៀមទម្លាប់

មានប្រពៃណី និងទំនៀមទម្លាប់ជាច្រើន ស្ទើរតែគ្រប់ផែកផាងនៃវប្បធម៌ អរិយធម៌ខ្មែរ សុទ្ធតែមានទំនាក់ទំនងនឹងព្រះពុទ្ធសាសនា ដោយបញ្ចូលលទ្ធិពុទ្ធសាសនាធ្វើជាបង្គោលទាំងអស់ ដូចជា :

១. ពិធី ចំរើនជន្មាយុ ( ចំរើនអាយុ )

២. ពិធី អាពាហ៍ពិពាហ៍

៣. ពិធី បែសព បូជាសព

៤. ពិធី កោរជុក

៥. ពិធី អភិសេកព្រះពុទ្ធរូប

នៅមានប្រពៃណីខ្លះទៀត ជាបែបពុទ្ធសាសនាសុទ្ធៗ ដូចជា ៖

៦. ពិធី ចូលវស្សា

៧. ពិធី ចេញវស្សា

៨. ពិធី បុណ្យកឋិន

៩. ពិធី បុណ្យផ្កា

១០. ពិធី ភ្ជុំបិណ្ឌ

១១. ពិធី បុណ្យបច្ច័យ ៤

១២. ពិធី បុណ្យឆាកមហាបង្សុកូល

១៣. ពិធី បុណ្យទេសនាមហាជាតក៍ ។ ល ។

ប៉ុន្តែ ដោយហេតុថា ខ្មែរបានទទួលឥទ្ធិពលសាសនាព្រាហ្មណ៍ផង ម៉្លោះហើយ នៅក្នុងប្រពៃណី ទំនៀមទម្លាប់ខ្មែរ ក៏មានលាយចំរុះដោយធាតុទាំងពីរ ៖ ព្រាហ្មណ៍និយម ពុទ្ធនិយម ជាមួយនឹងខ្មែរនិយម ។

ហេតុនេះ ពិធីបុណ្យទានផ្សេងៗដែលជាប្រពៃណី ច្រើនតែមានធាតុទាំង ៣ លាយគ្នា ដូចជា ៖

១. ពិធី បុណ្យចំរើនបរិត្ត ៖ គេនិមន្តព្រះសង្ឃចំរើនព្រះបរិត្តផង ធ្វើស្លាធម៌ បាយសី ឬស្លាធម៌ដូងផង តាមបែបបុរាណ ។

២. ពិធី ស្រោចទឹករំដោះគ្រោះ ៖ គេនិមន្តព្រះសង្ឃសូត្រមន្ត ង ធ្វើពិធី រំដោះគ្រោះ ( បែបព្រាហ្មណ៍ មានសែនព្រេន ជាដើម ) ផង ។

ហេតុនេះ យើងអាចសន្និដ្ឋានថា ប្រពៃណី ទំនៀមទម្លាប់ណា ដែលគេធ្វើហើយមានតម្កល់ព្រះពុទ្ធរូបជាសក្ការបូជា មានចំរើនបរិត្ត ទេសនា ជាដើម

ទាំងអស់នេះ គឺជាបែបពុទ្ធនិយមក្នុងប្រពៃណី ទំនៀមទម្លាប់ខ្មែរ ។

## គ. សិល្បៈ

១. គំនូរ.ចម្លាក់

មានគំនូរចម្លាក់ជាច្រើន ដែលគេគូរឆ្លាក់យកលំនាំតាមជីវប្រវត្តិ និងសកម្មភាពព្រះពុទ្ធ ដូចជា :

. ការប្រសូត

. ការឡើងសោយរាជ្យ

. ការចេញបួស

. ការធ្វើទុក្ករកិរិយា

. ការត្រាស់ដឹង

. ការផ្ចាញ់មារ

. ការសំដែងធម្មចក្រ

. ការបរិនិព្វាន ។ ល ។

គំនូរចម្លាក់ខ្លះ គេគូរ ឆ្លាក់ ជាបដិមាតាមបែបមុទ្រះ គឺ :

- ធ្យានមុទ្រះ ព្រះពុទ្ធធ្វើឈាន : រូបគង់ពែនភ្នែន ព្រះហស្ថទាំងពីរលាផ្ងា ដាក់ត្រួតលើគ្នា នៅលើភ្នែន ។

- ភូមិនស្បស៍មុទ្រះ ព្រះពុទ្ធផ្ចាញ់មា : រូបគង់ពែនភ្នែន ព្រះហស្ថឆ្វេងដាក់ផ្ងា លើភ្លៅឆ្វេង ព្រះហស្ថស្តាំដាក់លើភ្លៅស្តាំ មានចុងម្រាមព្រះហស្ថ ចង្អុលទៅរកផែនដី ។

- អភយមុទ្រះ ព្រះពុទ្ធឱ្យអភ័យដល់មនុស្សសត្វ : រូបឈរលាបាតព្រះហស្ថ ទាំងពីរទៅមុខ ចុងម្រាមព្រះហស្ថឡើងលើទាំងអស់ ។

- ធម្មចក្រមុទ្រៈ ព្រះពុទ្ធសំដែងធម្មចក្រ : រូបគង់ពែនភ្នែនក៏មាន គង់សំយុង
 ព្រះបាទក៏មាន ព្រះហស្តទាំងពីរដាក់លើទ្រូងធ្វើដូចជាកងចក្រ ។
- វរទមុទ្រៈ ព្រះពុទ្ធប្រទានពរ : រូបឈរ លាបាតព្រះហស្តទាំងពីរទៅមុខ
 ម្រាមសំយុងចុះ ។
- បាតទានមុទ្រៈ ព្រះពុទ្ធទ្រង់បាត្រ : រូបឈរ ព្រះហស្តទាំងពីរឱបបាត្រ ។
- វិតក្កមុទ្រៈ ព្រះពុទ្ធត្រិះពិចារណា : រូបឈរ លាបាតព្រះហស្តទាំងពីរទៅ
 បត់ម្រាមកណ្តាល ជារង្វង់ភ្ជាប់នឹងមេដៃ ។
- ទុក្ករកិរិយាសមុទ្រៈ ព្រះពុទ្ធធ្វើទុក្ករកិរិយា : រូបគង់ពែនភ្នែន ឬក៏ផ្ទំ មានរូប
 កាយស្គាំងស្គម ឃើញតែឆ្អឹង ។
- សយនាមុទ្រៈ ព្រះពុទ្ធផ្ទំ ឬបរិនិព្វាន ។

## សង្កេត :

លក្ខណៈពិសេសនៃកាយវិការបែបមុទ្រៈក្នុងសិល្បៈខ្មែរ គេបានកត់សំគាល់ឃើញ :

១. ព្រះភក្រ្ត (ទឹកមុខ) ញញឹមជាដរាប ហាក់ដូចជារកឃើញនូវអាថិកំបាំងអ្វីមួយ ដ៏ជ្រាលជ្រៅ ។

២. ទ្រង់គ្រង ឬឃ្លុំចីពរ គង់ពែនភ្នែនលើបល្ល័ង្ក ឬលើផ្កាឈូក ។

៣. មានព្រះមោលី (ផ្នួងសក់) ក្តួចមូលនៅលើព្រះសិរសា ហើយមានកេសារួញប្រទាក់គ្នាដូចគូថខ្យង ឬដូចបន្លាសំបកខ្នុរ ។

៤. ព្រះកាណ៌ (ត្រចៀក) វែង និងមានឆព្វណ្ណរង្សីចេញពីព្រះកាយ ដូចរស្មីព្រះអាទិត្យ ។

## ២. ប្រាសាទ ( Ruines )

នៅប្រទេសខ្មែរ មានប្រាសាទថ្មជាច្រើន ដែលគេសង់ឧទ្ទិសថ្វាយព្រះពុទ្ធសាសនា គឺ :

- ប្រាសាទ **បាយ័ន** ចុងសតវត្សទី ១២ នៃគ្រឹស្តសករាជ
- ប្រាសាទ **តាព្រហ្ម** គ្រឹស្តសករាជ ១១៨៦
- ប្រាសាទ **ព្រះខ័ន** គ្រឹស្តសករាជ ១១៩១
- ប្រាសាទ **នាគព័ន្ធ** ដើមពាក់កណ្តាលសតវត្សទី ១២
- ប្រាសាទ **បន្ទាយក្តី**
- ប្រាសាទ **បន្ទាយឆ្មារ** ។ល។

ការសង់ប្រាសាទតាមបែបពុទ្ធសាសនាជាពុទ្ធនិយម ច្រើនសង់នៅលើទីដីរាបស្មើ ពុំសូវមានជាន់ថ្នាក់ខ្ពស់ៗ ដូចជាប្រាសាទបែបព្រាហ្មណ៍និយមទេ ។ ការណ៍នេះបញ្ជាក់ប្រាប់ឱ្យដឹងថា : -ព្រះពុទ្ធជាមនុស្សឋិតនៅលើលោកនេះ ជាមួយនឹងមនុស្សគ្រប់គ្នា ដទៃទៀត គឺព្រះពុទ្ធពុំមែនឋិតនៅលើមេឃ ដាច់ឆ្ងាយអំពីមនុស្សដូចជាអាទិទេពនៃសាសនាព្រាហ្មណ៍ឡើយ ។ ប៉ុន្តែ ព្រះពុទ្ធជាមនុស្សភ្ញាក់រឭកមុនគេ មានការតស៊ូ ព្យាយាម វើបំរះ រំដោះខ្លួនឱ្យរួចផុតពីទុក្ខ និងច្បាប់ធម្មជាតិ ។

## ៣. ស្តូប

ស្តូបជាកន្លែងសំរាប់តម្កល់អដ្ឋិធាតុនៃមនុស្សដែលស្លាប់ ដែលមានសណ្ឋានរាងមូល ដូចលោកខែពាក់កណ្តាល ឬដូចពាក់កណ្តាលរង្វង់មូល ( អឌ្ឍ-មណ្ឌល Demi-cercle) ដែលមានន័យថាជាអនិច្ចំ (Impermance) នៃវត្ថុទាំងអស់ក្នុងលោកមិនឋិតថេរ ។ ស្តូបគេច្រើនសង់លើខឿនខ្ពស់ល្មម មានរបងព័ទ្ធជុំវិញ ។

## ៤. ចេតិយ

ចេតិយ ច្រើនសង់មានរាង ៤ ជ្រុង ឬរាងមូល មិតត្រួតលើគ្នាជាជាន់ថ្នាក់ ។ បាតក្រោមរីកធំ ហើយរៀវតូចបន្តិចម្តងៗ រហូតដល់កំពូលមានរាងជាឆត្រ រូត ។ តាមធម្មតា គេតែងសាងចេតិយឱ្យមាន ៣ ថ្នាក់ ដែលមានន័យតំណាងព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

ចេតិយក្នុងពុទ្ធសាសនាមាន ៤ បែប គឺ :

ក. ធាតុចេតិយ : ចេតិយសំរាប់តម្កល់ដាក់ ឬ បញ្ចុះអដ្ឋិធាតុព្រះពុទ្ធ ឬមាតាបិតា ជាដើម ។

ខ. បរិភោគចេតិយ : ចេតិយសំរាប់ដាក់វត្ថុប្រើប្រាស់របស់ព្រះពុទ្ធ មានវត្តព័ន្ធ និងតម្រងទឹក ជាដើម ។

គ. ធម្មចេតិយ : ចេតិយសំរាប់តម្កល់ក្បួនច្បាប់ សាស្ត្រា គម្ពីរពុទ្ធវចនៈ មានព្រះត្រៃបិដក ជាដើម (បុរាណ : ហោត្រៃ ) ។

ឃ. ឧទ្ទេសិកចេតិយ : ចេតិយឧទ្ទិសថ្វាយ បូជាចំពោះព្រះពុទ្ធ ព្រះរតនៈត្រៃ ឬអ្នកមានគុណ មានមាតាបិតា គ្រូឧបជ្ឈាយ៍ ជាដើម ។

## ៥. វិហារ

ព្រះវិហារ ឬឧបោសថាគារ ជាកន្លែងសំរាប់ពួកបព្វជិតពុទ្ធសាសនិក ធ្វើសង្ឃកម្មផ្សេងៗ មានឧបោសថកម្ម ឧបសម្បទាកម្ម ជាដើម ។ ក្នុងព្រះវិហារមានតម្កល់ព្រះពុទ្ធបដិមា ដែលមានមួយព្រះអង្គធំជាងគេ(*) ។ វិហារតាំងនៅចំកណ្តាល

(*) បុរាណហៅព្រះពុទ្ធបដិមាអង្គធំក្នុងវិហារថា ព្រះជីវ៍ ។

ទីវត្តនៅលើដីខ្ពស់ មានខឿនបាំងពីខាងជុំវិញ ។ វិហារទាំងអស់ សុទ្ធតែបែរមុខឆ្ពោះទៅទិសខាងកើត ដែលជាតំណាងទិសព្រះពុទ្ធត្រាស់ដឹង ក្រោមដើមពោធិព្រឹក្ស បែរព្រះភក្ត្រទៅទិសខាងកើត ។

## ឃ. អក្សរសិល្ប៍

រឿងរ៉ាវអត្ថបទអក្សរសិល្ប៍ជាច្រើន អ្នកនិពន្ធបានដកស្រង់ចេញមកពីគម្ពីរពុទ្ធសាសនា មានគម្ពីរព្រះត្រៃបិដក និងគម្ពីរអដ្ឋកថា មានធម្មបទ វិសុទ្ធិមគ្គ មង្គលត្ថទីបនី ទសជាតក និងបញ្ញាសជាតក ជាដើម មករៀបរៀងចងក្រងជាវណ្ណកម្មរបស់ខ្លួន ។ អក្សរសិល្ប៍បែបនេះ ជាចលនាពុទ្ធនិយម ដែលអ្នកនិពន្ធបានលើកយកសកម្មភាពព្រះពោធិសត្វក្នុងការកសាងបារមី ឬលើកយកទស្សនៈសំខាន់ៗ ក្នុងពុទ្ធសាសនា មានបញ្ហាកម្ម ផល បុណ្យ បាប ជាដើម មកអធិប្បាយពន្យល់ ។

អក្សរសិល្ប៍ចលនាពុទ្ធនិយម អាចចែកជាពីរប្រភេទគឺ :

១. អក្សរសិល្ប៍ តំណាងចលនាពុទ្ធនិយមពិតៗ ដែលអ្នកនិពន្ធបានដកស្រង់ចេញមកពីទសជាតក គឺ :

- តេមិយជាតក បំពេញ នេក្ខម្មបារមី
- ជនកជាតក បំពេញ វិរិយបារមី
- សុវណ្ណសាមជាតក បំពេញ មេត្តាបារមី
- នេមិរាជជាតក បំពេញ អធិដ្ឋានបារមី
- មហោសថជាតក បំពេញ បញ្ញាបារមី
- ភូរិទត្តជាតក បំពេញ សីលបារមី
- ចន្ទកុមារជាតក បំពេញ ខន្តីបារមី
- នារទជាតក បំពេញ ឧបេក្ខាបារមី

- វិធូរបណ្ឌិត បំពេញ សច្ចបារមី
- វេស្សន្តរជាតក បំពេញ ទានបារមី

២. អក្សរសិល្ប៍តំណាងចលនាពុទ្ធនិយមក្លាយ ដែលអ្នកនិពន្ធបានដកស្រង់ចេញមកពីបញ្ញាសជាតក ជាគម្ពីរអដ្ឋកថា កើតមានឡើងនៅប្រទេស ឡាវក្រុងឈៀងម៉ៃ ប្រហែល ៥០០ ឆ្នាំ ប៉ុណ្ណោះ ។

អក្សរសិល្ប៍បែបនេះ មាន ៖

- រឿង សុភមិត្រ
- រឿង ព្រះសុធន
- រឿង ភោគកុលកុមារ
- រឿង លោកន័យជាតក
- រឿង ព្រះសមុទ្រ
- រឿង សព្វសិទ្ធិ
- រឿង មរណមាតា
- រឿង វិមានចន្ទ
- រឿង ស្រទបចេក
- រឿង ខ្យងស័ង្ខ ។ ល ។

ឯកសារពិគ្រោះ

១) ទាវ ឆៃសុក, វប្បធម៌ អរិធម៌ខ្មែរ-ឥណ្ឌា ១៩៧២

២) គង់ នឿន, វប្បធម៌ ឥណ្ឌា-ខ្មែរ ១៩៧១

៣) លី ធាមតេង, អារ្យធម៌ខ្មែរ ១៩៦៥

៤) ឡាយ គ្រី, ទ្រព្យប្រសើររបស់មនុស្ស ១៩៩១

៥) ផាច់ ណាង ( ធម្មប្បញ្ញោ ), គតិសាគរនានៃពលរដ្ឋ ១៩៥១

# សិលាចារឹកថ្មី១សម័យមុនអង្គរ Ka 64 នៅភូមិមេលប់ ក្បែរស្ពាយពល និងបញ្ហានៃជាតិពន្ធុនាមពីរ គឺ "ខ្មែរ" និង "មលេង"

## A New Pre-Angkorean Inscriptions Ka 64 at Melop village near Snay Pol and Problems of Two Ethnonyms, 'Khmer'and 'Maleng'

**ចង់ សុធារ៉ា**
សាស្ត្រាចារ្យនៅដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២
និង **ឡឹក សាវណ្ណ**
សាស្ត្រាចារ្យនៅដេប៉ាតឺម៉ង់សង្គមវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២

## សេចក្តីបកប្រែ

### ផ្នែក "ក"

១-១២ អត្ថបទកំណាព្យសំស្ក្រឹត

(១៣-១៥) អ្នកបំរើជាជនជាតិខ្មែរ[១៣] ចំនួនបុរស៣០នាក់ និងស្ត្រី៤៧នាក់ (ព្រម ទាំងកូន១ របស់ពួកគាត់មាន) កុមារា២នាក់ កុមារី៨នាក់ លាងសិ៩នាក់

---

[១៣] "ក្ញុំក្មេរ" មានន័យថា "ក្ញុំបំរើជាជនជាតិខ្មែរ" ហើយ "ក្ញុំមលេង" ក៏មានន័យថា "ក្ញុំបំរើជនជាតិមលេង" ប្រៀបដូចគ្នានឹងពាក្យ "ក្ញុំមិញ" ដែលលោកសឺដេស បកប្រែថា "ក្ញុំបំរើជាតិមន" តាមសិលាចារឹកភ្នំហួរព្នៅK76 ខាងជើងត្រាំខ្នារ ក្នុងស្រុកគងពិសីខេត្តកំពង់ស្ពឺ ។cf, Coedès, G. *Inscriptions du Cambodge,* Vol. V, p. 7-8. និងពាក្យ "ក្ញុំទ្រៅ" ដែលលោក ហ្សក

លាងតៃ៩នាក់ ក្មេង(នៅបៅ)ប្រុស១១នាក់ ក្មេង(នៅបៅ)ស្រី១០នាក់ អកម្ម សីល៩នាក់ ពួកគេទាំងអស់ ១៣៨នាក់ ។

(១៦-១៨) អ្នកបំរើជាជនជាតិមលេង ចំនួនបុរស១៨នាក់ និងស្ត្រី៣០នាក់ (ព្រមទាំងកូន៧របស់ពួកគេ) ក្មេងប្រុសម្នាក់ ក្មេងស្រី៨នាក់ លាងសិ៤នាក់ លាងតៃ៨នាក់ ក្មេងនៅបៅប្រុស២នាក់ ក្មេងនៅបៅ ស្រី៤នាក់ អកម្មសីល ២នាក់ ពួកគេទាំងអស់ ៧៧នាក់ ។

(១៩-២១) សរុបមនុស្សទាំងក្មេងទាំងចាស់ ចំនួន២១៥នាក់ ក្របី៣០ក្បាល ។ គោ៤០ក្បាល ដើមស្លា ៥០០ដើម...(ប្លាយ) ដើមដូង១០៧ដើម ។ស្រែង (ត្នោ)លទមី ចំនួន៤ (មាស?) (២២) ស្រែថលាបុរ ព្លាក់ស្រុកចំនួន.... (២៣) ស្រែ..តយេ ចំនួន៨ ...មាស ១ សរុបស្រែចំនួន...

**ផ្នែក "ខ"**

(១-២)សំស្ក្រឹត (នៅខាងចុងគាថាអាចជានាម១នៃព្រះពុទ្ធ"ស្រីឃនះ[១៤]"?

---

សីដេស បកប្រែថា "អ្នកបំរើ ជាជនជាតិព្រៅ ឬ ប្រៅ" ដែលជាប្រជាជាតិដើមមួយនៃកម្ពុជា Les esclaves Vrau qui désigne une population aborigène du Cambodge ពាក្យ"ក្ញុំវ្រៅ"នេះ នៅក្នុងប្រយោគមួយនៃសិលាចារឹកលង្វែក K137 ថា "អាជ្ញាវ្រះកម្រតាងអញប្រេបុនេងសេវការ នំ*ក្ញុំវ្រៅ* មោយស្ទិច្ចឱយអាយតវ្រះម្រតាញកម្រតាង ទំទំ" មានន័យថា "ព្រះមហាក្សត្រចេញ អាជ្ញាប្រើ*បុនេង សេវការ* អោយនាំក្ញុំបំរើជាតិព្រៅចំនួន៤០០នាក់ ទៅអោយ*ព្រះម្រតាញ កម្រតាង ទំទំ*" ។ cf, Coedès, G. *op cit*, vol. II, pp. 115-118.

[១៤] cf, Coedès, G. *op cit*, vol. V, pp. 164-7; និង ប៉ាង ខាត់ *"ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ"* ក្នុង *កម្ពុជសុរិយា* ឆ្នាំ១៩៥៨ ភ្នំពេញ ទំព័រ៥៨៥-៥៨៦ ។

ក្នុង ពាក្យ "គ្រឹយនោនយះ")

(៣) អំណោយរបស់ម្រតាញកម្រតាង ច្រង្គោស[១៥] ....នៅឯយនប

(៤-២១) បញ្ជីឈ្មោះអ្នកបំរើ(ជាជនជាតិខ្មែរ) ភេទប្រុស(ឃោដ) ដែលប្រកប ដោយឋានន្តរនាម "អំរះ" ៤នាក់ និង"វ៉ា" ២៩នាក់ ភេទស្រី(កន្ញែ ឬ អ្នកកន្ញែ) "កុ"៤៧នាក់ កុមារា(ចេះដើរ)"ទេវសិ"២នាក់ កុមារី(ចេះដើរ)"ទេវតៃ"៨នាក់ លាង សិ៩នាក់ លាងតៃ ៩នាក់ ក្មេងនៅបៅប្រុស "បៅសិ" ១១នាក់ ស្រី"បៅតៃ" ១០នាក់ និងអកម្មិសីល៩នាក់ ។

(២១-៣៥) បញ្ជីឈ្មោះអ្នកបំរើជាជនជាតិមលេង ភេទប្រុសដែលមាន ឋានន្តរ នាម "វ៉ា"១៨នាក់ ភេទស្រី "កុ"៣០នាក់ កុមារា"ទេវសិ"ម្នាក់ កុមារី "ទេវតៃ"៨នាក់ "លាងសិ"៤នាក់ "លាងតៃ"៨នាក់ ក្មេងនៅបៅ ប្រុស"បៅសិ" ២នាក់ ស្រី"បៅតៃ" ៤នាក់ អកម្មិសីល២នាក់ ។

តាមរយៈការរៀបរាប់ឈ្មោះក្ញុំបំរើទាំងអស់នេះ នាំអោយមានការកត់-

---

[១៥] ឋានន្តរនាម "ម្រតាញ កម្រតាង" នៅពីមុខឈ្មោះ "ច្រង្គោស" សំរាប់សំគាល់មន្ត្រី ដែលមានឋានខ្ពស់បំផុតរបស់ព្រះរាជា នៅសម័យនោះ ។ ព្រោះគ្រាន់តែ "ម្រតាញ"(Mratāñ détermine la signification de 'grand seigneur') គឺបញ្ជាក់ថាជា មន្ត្រីធំស្រេច ទៅហើយ នៅមានបន្ថែមឋានន្តរ "កម្រតាង"ទៀតនោះ ឃើញថាកម្រមានណាស់នៅក្នុងសិលា ចារឹកសម័យមុនអង្គរ ។ ដូច្នេះ ម្រតាញកម្រតាង ច្រង្គោស គឺពិតជាមន្ត្រីធំម្នាក់របស់ព្រះបាទ ភវវម្មទី២ ។ គាត់អាចជាស្តេចត្រាញ់ ឬ មហាសេនាបតី ឬជាអភិបាលដែនដីដ៏ធំទូលាយមួយ នៅទីនោះ ។ យើងបានបង្ហាញរួចហើយពីសិលាចារឹកលង្វែកK 137 នូវឈ្មោះមហាមន្ត្រីម្នាក់ ដែលមានឋានន្តរនាមដូចគ្នានេះ ។voir, Coedès, G. op cit.

សំគាល់ឃើញថា អ្នកបំរើជាជនជាតិខ្មែរ មិនត្រូវបានគេបញ្ជាក់ជាលើកទីពីរឡើយ ផ្ទុយគ្នាពីជនជាតិមលេង ដែលស្មេរបានបញ្ជាក់ម្តងទៀត មុននឹងគេចាប់ផ្តើមសរសេរឈ្មោះ ។ ម្យ៉ាងទៀត បណ្តាក្ញុំបំរើទាំងនោះ ជាពិសេសប៉ែកខាងបុរស គ្មានអ្នកណាម្នាក់មានឋានៈ"អំរះ"(មេតម្រួត ឬមេក្រុម) ដូចបុរសអ្នកបំរើជាជនជាតិខ្មែរសោះ ។ ទោះបី នៅក្នុងឋានៈជាអ្នកបំរើប្រាសាទ ដូចគ្នា ។

ប្រការនេះ សរអោយឃើញថា ជនជាតិខ្មែរ គឺជាប្រជាជាតិភាគច្រើននៅសម័យនោះ អ្នកចារឹក ក៏ជាជនជាតិខ្មែរ ហើយអ្នកធ្វើអំណោយ ក៏ជាជនជាតិខ្មែរ ដែលជាម្ចាស់ប្រទេស ម្ចាស់រាជ្យ ម្ចាស់ផែនដី និងជាតិសាសន៍ ហេតុនេះហើយទើបគេមិនបញ្ជាក់ពាក្យថា "ក្មេរ"នេះ ជាច្រើនដង ។

ប្រសិនបើ ម្រតាញកម្រតាង "ច្រង្កោស" ធ្វើអំណោយក្ញុំបំរើជាតិខ្មែរទាំងអស់ ដូចសិលាចារឹកជាច្រើនដទៃទៀត ហើយគាត់មិនបានធ្វើអំណោយក្ញុំបំរើជាតិមលេងទេ នោះពាក្យ"ក្មេរ"(=ខ្មែរ នៅក្នុងទំរង់ជាជាតិពន្ធុនាម) ពិតជាមិនត្រូវបានគេចារឹកទុក ហើយភាពស្រពិចស្រពិលអំពីបញ្ហា"ថាតើខ្មែរពិតជាម្ចាស់ប្រទេស ឬក៏គ្រាន់តែជាជនជាតិភាគច្រើននៅពេលនោះប៉ុណ្ណោះ?" នៅតែជាចំណោទមិនអាចដោះស្រាយរួច ក៏ព្រោះតែការគ្មានភស្តុតាងជាក់លាក់ ។

## វាក្យានុក្រម និងអត្ថន័យរបស់វា

<u>អក្សរកាត់</u> (Abravation): *ក=អត្ថបទផ្ទាំង"ក" ឬ A* *ខ=អត្ថបទផ្ទាំង"ខ" ឬ B* *ប=បន្ទាត់ សំ=សំស្ក្រឹត ស្រ- f.(female)=ឈ្មោះមនុស្សស្រី (កុ, កុឃ) ប្រ- m.(male) =ឈ្មោះមនុស្សប្រុស (អំរះ, វា, វាត) ទ.ក-l.n.(location name or toponym)= ឈ្មោះទីកន្លែង*

- កន្តៃ kantai (ក, ប.១៣, ១៦, ខ, ប. ៧, ១១, ១៣) ស្រី ឬ ស្ត្រី
- កុ ku ឋានន្តរនាមស្ត្រី ជាអ្នកបំរើ ឬ អ្នកជា ដែលមានឋានៈទាប សាមញ្ញ នៅសម័យមុនអង្គរ
- កុយ ku ya ឋានន្តរនាមស្ត្រី ជាអ្នកបំរើ ឬ អ្នកជា ដែលមានវ័យចំណាស់ (លោកយាយ ឬ យាយ)
- ក្ញុំ kñuṃ (ក, ប.១៣, ១៦, ខ, ប.៤, ២១) អ្នកបំរើ ឬ ក្ញុំបំរើ
- ក្មេរ kmer (ក, ប.១៣) (ជាតិពន្ធុនាមនៃ) ជនជាតិខ្មែរ
- ក្របិ krapi (ក, ប.១៩) សត្វក្របី
- គុិ gui (ខ, ប.៣) គឺ
- គេ ge (ក, ប.១៥, ១៨, ១៩) ពួកគេ (មនុស្ស)
- ឃោដ ghoṭa (ក, ប.១៣, ១៦, ខ, ប.៤) ប្រុស ឬ បុរស
- តោងតេំ toṅ teṃ (ក, ប.២០) ដើមដូង
- ត្មុរ tmur (ក, ប.២០) សត្វគោ(ឈ្មោល)
- ទេរតៃ der tai (ក, ប.១៤, ១៦-១៧,) កុមារី(ចេះដើរ)

- ទេរសិ der si ( ក. ប.១៣. ១៦) កុមារា( ចេះដើរ)
- ទ្មុក dmuk ( ខ. ប.៤) អ្នកទុក
- បិណ្ឌ piṇḍa ( ក. ប.១៩) សរុប
- បៅតៃ pau tai ( ក. ប.១៥. ១៨) កុមារី( នៅបៅ)
- បៅសិ pau si ( ក. ប.១៤. ១៧) កុមារា( នៅបៅ)
- មលេង maleṅ ( ក.ប.១៦.ខ.ប.២១) ( ជាតិពន្ធុនាមនៃជនជាតិមលេង)
- លាងតៃ lāṅ tai ( ក. ប.១៤. ១៧) កុមារី( វ័យមិនច្បាស់)
- លាងសិ lāṅ si ( ក. ប.១៤. ១៧) កុមារា( វ័យមិនច្បាស់)
- វា vā ឋានន្តរនាមបុរស ជាអ្នកបំរើ ឬ អ្នកជា ដែលមានឋានៈទាប សាមញ្ញ នៅសម័យមុនអង្គរ
- វាត vā ta ឋានន្តរនាមបុរស ជាអ្នកបំរើ ឬ អ្នកជា ដែលមានវ័យ ចំណាស់ ( លោកតា ឬតា)
- សវ៌? sarvva ( ក. ប.១៩) ( សំ.) សព្វ
- សវាលវ្ឫទ្ធ savālavṛddha ( ក. ប.១៩) សវាល( ក្មេងៗ)

និង ព្រឹទ្ធ(មនុស្សចាស់)

- ស្រេ sre (ក, ប.២១, ២២, ២៣) ស្រែ
- ស្លា slā (ក, ប.២០) ស្លា
- ស្លឹក slik (ក, ប.២០) ស្លឹក(១ស្លឹក=៤០០)
- អកម្មិសីល akarmmasīla (ក, ប.១៥) អកម្មសីល?
- អកម្មិឝីល akarmmaçīla (ក, ប.១៨, ខ, ប.២១, ៣៥) អកម្មសីល?
- អាយ āy (ខ, ប.៣) ឯ, ឰ, នៅ
- អំនោយ aṃnoy (ខ, ប.៣) អំណោយ
- អំរះ aṃraḥ (ខ, ប.៤, ៦, ១០, ១២) ឋានន្តរនាមភេទប្រុស សំគាល់ មេក្រុមនៃពួកក្ញុំបំរើ

**អសាធារណនាម : នៅអត្ថបទផ្នែក "ខ"**

| | | |
|---|---|---|
| កញ្ចោង(វ៉ា)(ប.១៣) | kañcoṅ (vā); (l.13) | ប្រ.- m. |
| កន្ទេន(កុ)(ប.៦) | kanden (ku); (l.6) | ស្រ.- f. |
| កន្ទេន(វ៉ា)(ប.១៧) | kanden (vā); (l.17) | ប្រ.- m. |
| កន្អង(វ៉ា)(ប.១០, ១១) | kan-oṅ (vā); (l.10,11) | ប្រ.- m. |
| ករាំ(កុ) (ប.១០) | karoṃ (ku); (l.10) | ស្រ.- f. |

| | | |
|---|---|---|
| កល្បិត(កុ)(ប.១៦) | kalpit (ku); (l.16) | ស្រ.- f. |
| កេ(កុ) (ប.១៨) | ke (ku); (l.18) | ស្រ.- f. |
| កោយកន(កុ) (ប.២៥) | koy kan (ku); (l.25) | ស្រ.- f. |
| កំបង(វា) (ប.១២) | kaṃpaṅ (vā); (l.12) | ប្រ.- m. |
| កំបច(កុ) (ប.៨) | kaṃpac (ku); (l.8) | ស្រ.- f. |
| កំវៅ(វា) (ប.៤) | kaṃvau (vā); (l.4) | ប្រ.- m. |
| កំហាក(វា) (ប.៧) | kaṃhāk (vā); (l.7) | ប្រ.- m. |
| ក្ដោញ(កុ) (ប.៩) | kdoñ (ku); (l.9) | ស្រ.- f. |
| ក្មាស(កុ)(ប.២៨) | kmās (ku); (l.28) | ស្រ.- f. |
| ខល(វា) (ប.១៣) | khal (vā); (l.13) | ប្រ.- m. |
| ខិ(កុយ)(ប.១១) | khi (ku ya); (l.11) | ស្រ.- f. |
| ចេកន(កុ)(ប.២៧) | ce kan (ku); (l.27) | ស្រ.- f. |
| ចេកុញ(វា)(ប.២២) | ce kuñ (vā); (l.22) | ប្រ.- m. |
| ចេង(វាត)(ប.២៤) | ceṅ (vā ta); (l.24) | ប.- m. |
| ចេយ(វាត)(ប.២៥) | cey (vā ta); (l.25) | ប្រ.- m. |
| ចេយកន(កុ)(ប.៣២) | cey kan (ku); (l.32) | ស្រ.- f. |
| ចោងកន(កុ)(ប.២៧) | coṅ kan (ku); (l.27) | ស្រ.- f. |
| ចំ(កុ) (ប.១៨) | caṃ (ku); (l.18) | ស្រ.- f. |

| | | |
|---|---|---|
| ចំ(ងា)យកន(កុ)(ប.៣១) cam ṅāy kan (ku); (l.31) | | ស្រ.- f. |
| ច្កិហ(កុ) (ប.១២) | ckih (ku); (l.12) | ស្រ.- f. |
| ច្រង្គោស(ម្រតាញ កម្រតាង)(ប.៣) | | |
| | craṅ gos (mratāñ kamratāṅ); (l.3) | ប្រ.- m. |
| ច្អាល(កុ) (ប.១៤) | $c_a$āl (ku); (l.14) | ស្រ.- f. |
| ច្អាលសិន(កុ) (ប.១៥) | $c_a$āl sin (ku); (l.15) | ស្រ.- f. |
| ជនកុញ(វា)(ប.២៤) | jana kuñ (vā); (l.24) | ប្រ.- m. |
| ជា(កុ) (ប.២០) | jā (ku); (l.20) | ស្រ.- f. |
| ជាកុកះ(កុ)(ប.១៦) | jā ku kaḥ (ku); (l.16) | ស្រ.- f. |
| ជំនោក(វា)(ប.២៣) | juṃnok (vā); (l.23) | ប្រ.- m. |
| ជ្វិក(កុ)(ប.២២) | jvik (ku); (l.22) | ស្រ.- f. |
| តងវះ(កុ) (ប.៩) | taṅvaḥ (ku); (l.9) | ស្រ.- f. |
| ເ(តភ)(កុ) (ប.១៩) | tebha (kū); (l.19) | ស្រ.- f. |
| តំនរ(កុ) (ប.៩) | taṃnar (ku); (l.9) | ស្រ.- f. |
| ត្បោញ(វា)(ប.៤) | tpoñ (vā); (l.4) | ប្រ.- m. |
| ត្មាង(វា) (ប.១៣, ២៤) | tmāṅ (vā); (l.13,24) | ប្រ.- m. |
| ត្មាយ(វា)(ប.២៤) | tmāy (vā); (l.24) | ប្រ.- m. |
| ត្មេង(វា) (ប.២១) | tmeṅ (vā); (l.21) | ប្រ.- m. |

| | | |
|---|---|---|
| ត្មៅ(វា)(ប.២៤) | tmau (vā); (l.24) | ប្រ.- m. |
| ត្យាង(កុ)(ប.១៤) | tyāṅ (ku); (l.14) | ស្រ.- f. |
| ត្រទៃ(វា)(ប.៤) | tradai (vā); (l.4) | ប្រ.- m. |
| ត្វយ(វា)(ប.១៩-២០) | tvay (vā); (l.19-20) | ប្រ.- m. |
| ត្វរ(វា)(ប.១៩) | tvar (vā); (l.19) | ប្រ.- m. |
| ថេប(កុ)(ប.១៨) | thep (ku); (l.18) | ស្រ.- f. |
| ទូ(កុ)(ប.២០) | dū (ku); (l.20) | ស្រ.- f. |
| ទ្រទាស(វា)(ប.១៤) | dradās (vā); (l.14) | ប្រ.- m. |
| ធលិយពុ(វា)(ប.៧) | dhaliyabu (vā); (l.7) | ប្រ.- m. |
| ធៅ(កុយ)(ប.២៩) | dhau (ku ya); (l.29) | ស្រ.- f. |
| បងកន(កុ)(ប.២៧-២៨) | paṅ kan (ku); (l.27-28) | ស្រ.- f. |
| បង្កេត(កុ)(ប.១៤) | paṅket (ku); (l.14) | ស្រ.- f. |
| បញ្មី(វា?)(ប.១៧) | pañmī (vā?); (l.17) | ប្រ.- m. |
| បនកន(កុ?)(ប.២៦) | pan kan (ku?); (l.26) | ស្រ.- f. |
| បនកុញ(វា)(ប.២២) | pan kuñ (vā); (l.22) | ប្រ.- m. |
| បិត(កុ)(ប.៦) | pit (ku); (l.6) | ស្រ.- f. |
| បៃ(កុយ)(ប.២៩) | pai (ku ya); (l.29) | ស្រ.- f. |
| បៃកន(កុ?)(ប.៣០) | pai kan (ku?); (l.30) | ស្រ.- f. |

| | | |
|---|---|---|
| ពោញកន(កុ)(ប.៣១) | poñ kan (ku); (l.31) | ស្រ.- f. |
| ពៅតៃ(កុ)(ប.៦) | pautai (ku); (l.6) | ស្រ.- f. |
| បះ(កុយ)(ប.៣៣) | paḥ (ku ya); (l.33) | ស្រ.- f. |
| ប្រុត(កុ?)(ប.១៨) | prut (ku?); (l.18) | ស្រ.- f. |
| ប្លេង(វា)(ប.២៥) | pleṅ (vā); (l.25) | ប្រ.- m. |
| មាងកន(កុ)(ប.២៥) | māṅ kan (ku); (l.25) | ស្រ.- f. |
| មាងកុញ(វា)(ប.២២) | māṅ kuñ (vā); (l.22) | ប្រ.- m. |
| មោល(កុយ)(ប.៣៤) | mol (ku ya); (l.34) | ស្រ.- f. |
| យនប (ប.៣) | yanap ; (l.3) | ទ.ក- l. n. |
| យាងក្យា(កុ)(ប.២៦) | yāṅ kyā (ku); (l.26) | ស្រ.- f. |
| យំគន(កុ)(ប.៣១) | yaṃ gan (ku); (l.31) | ស្រ.- f. |
| រេងកន(កុ)(ប.៣៤) | reṅ kan (ku); (l.34) | ស្រ.- f. |
| រៃកន(កុ)(ប.២៨) | rai kan (ku); (l.28) | ស្រ.- f. |
| រៃកុញ(វា)(ប.២២) | rai kuñ (vā); (l.22) | ប្រ.- m. |
| រោក(កុ) (ប.១៧) | rok (ku); (l.17) | ស្រ.- f. |
| រោងគន(កុ) (ប.២៦) | roṅ gan (ku); (l.26) | ស្រ.- f. |
| រំបញ(អំរះ) (ប១៣) | raṃpañ (aṃraḥ); (l.13) | ប្រ.- m. |
| លកុញ(វា)(ប.២១) | lakuñ (vā); (l.21) | ប្រ.- m. |

| | | |
|---|---|---|
| លង(កុយ) (ប.២៧) | laṅ (ku ya); (l.27) | ស្រ.- f. |
| លង្កះ(វា) (ប.២០) | laṅkaḥ (vā); (l.20) | ប្រ.- m. |
| លា(កុយ) (ប.២៥-២៦) | lā (ku ya); (l.25-6) | ស្រ.- f. |
| លាភ(វា?) (ប.១៧-១៨) | lābha (vā?); (l.17-8) | ប្រ.- m. |
| លាយកុញ(វា) (ប.២៣) | lāy kuñ (vā); (l.23) | ប្រ.- m. |
| លាយគន(កុ) (ប.៣០) | lāy gan (ku); (l.30) | ស្រ.- f. |
| លេក(កុយ) (ប.២៨) | lek (ku ya); (l.28) | ស្រ.- f. |
| លះ(កុយ) (ប.២៥) | laḥ (ku ya); (l.25) | ស្រ.- f. |
| លោងកន(កុ) (ប.៣២) | loṅ kan (ku); (l.32) | ស្រ.- f. |
| លោញ(កុ) (ប.៣០) | loñ (ku); (l.30) | ស្រ.- f. |
| លោនកុញ(វា) (ប.២៣) | lon kuñ (vā); (l.23) | ប្រ.- m. |
| ល្មោង(កុ) (ប.១៨) | lmoṅ (ku); (l.18) | ស្រ.- f. |
| វង(កុ) (ប.៦) | vaṅ (ku); (l.6) | ស្រ.- f. |
| វាង(កុ) (ប.១៨) | vāṅ (ku); (l.18) | ស្រ.- f. |
| វិន(កុ) (ប.១៦) | vin (ku); (l.16) | ស្រ.- f. |
| វេលកន(កុ) (ប.២៩) | vel kan (ku); (l.29) | ស្រ.- f. |
| វះ(កុ) (ប.១៨) | vaḥ (ku); (l.18) | ស្រ.- f. |
| វ្នំ(កុ) (ប.១២) | vnaṃ (vā); (l.12) | ប្រ.- m. |

| | | |
|---|---|---|
| វ្រេស(កុ)(ប.១៦) | vres (ku); (l.16) | ស្រ.- f. |
| វ្រៃ(កុ)(ប.៦) | vrai (ku); (l.6) | ស្រ.- f. |
| វ្រៅ(កុ) (ប.៩, ១២) | vrau (ku); (l.9,12) | ស្រ.- f. |
| វ្រៅ(វា) (ប.៤) | vrau (vā); (l.4) | ប្រ.- m. |
| ឝ្រទ្ធា(កុ) (ប.៨) | çraddhā (ku); (l.8) | ស្រ.- f. |
| សង្កល(អំរះ)(ប.៧) | saṅkal (aṃraḥ); (l.7) | ប្រ.- m. |
| សង្កាហ្វកន(កុ)(ប.៣៣) | saṅ kāhv kan (ku); (l.33) | ស្រ.- f. |
| សញ្ជី(កុ)(ប.៥) | sañjī (ku); (l.5) | ស្រ.- f. |
| សញ្ជេ(កុ)(ប.១១) | sañje (ku); (l.11) | ស្រ.- f. |
| សហាយ(វា) (ប.១៣) | sahāya (vā); (l.13) | ប្រ.- m. |
| សហិត(វា)(ប.៧) | sahita (vā); (l.7) | ប្រ.- m. |
| សាន(វា) (ប.១៦) | sān (vā); (l.16) | ប្រ.- m. |
| សេន្ធវ(វា)(ប.៤) | sendhava(vā); (l.4) | ប្រ.- m. |
| សោ (អំរះ) (ប.៤) | so (aṃraḥ); (l.4) | ប្រ.- m. |
| សោមវីរ(អំរះ) (ប.១០) | somavīra (aṃraḥ); (l.10) | ប្រ.- m. |
| សំលាញ(កុ) (ប.៤-៥) | saṃlāñ (ku); (l.4-5) | ស្រ.- f. |
| សំវោះ(វា) (ប.១២) | saṃvoḥ (vā); (l.12) | ប្រ.- m. |
| សំសេំ(កុ) (ប.៨) | saṃseṃ (ku); (l.8) | ស្រ.- f. |

| | | |
|---|---|---|
| ស្តោយ( វា) (ប.១៩) | stoy (vā); (l.19) | ប្រ.- m. |
| ស្បោក( កុ) (ប.៧) | spok (ku); (l.7) | ស្រ.- f. |
| ស្រលញ( កុ) (ប.៨-៩) | sralañ (ku); (l.8-9) | ស្រ.- f. |
| ស្រាង( វា) (ប.១៧) | srāṅ (vā); (l.17) | ប្រ.- m. |
| ស្លិង( វា) (ប.១៩) | sliṅ (vā); (l.19) | ប្រ.- m. |
| ស្វាំ( វា?) (ប.៣៤) | svāṃ (vā?); (l.34) | ប្រ.- m. |
| អគត( វា?) (ប.១៧) | agat (vā?) l.17; (l.17) | ប្រ.- m. |
| អប( កុ) (ប.១៨) | ap (ku) l.18; (l.18) | ស្រ.- f. |
| អរស( កុ) (ប.៦, ១២) | aras (ku); (l.6,12) | ស្រ.- f. |
| អរសអាយ( កុ) (ប.២០) | aras āy (ku); (l.20) | ស្រ.- f. |
| អសាប( កុ) (ប.១៩) | asāp (kū); (l.19) | ស្រ.- f. |
| ឯត( កុ) (ប.១៨) | et (ku); (l.18) | ស្រ.- f. |
| ឯត( វាត) (ប.១៥) | et (vā ta); (l.15) | ប្រ.- m. |
| ឪកន( កុ) (ប.២៦) | au kan (ku); (l.26) | ស្រ.- f. |

# ឯកសារពិគ្រោះពិសេស

1- Cœdès, Georges

- *Inscriptions du Cambodge,* Vol. 1-8 (8 volumes), Paris 1937-66.
- *Articles sur le Pays Khmer,* tome I-II (2 volumes), organisé par Claude Jacques, Paris 1989, 1992.

2- Khin, Sok

- *Les chroniques royales et l'inscription moderne d'Angkor N° 39,*dans *BEFEO t. LXIV,* Paris 1977, pp. 225-41.
- *Deux inscriptions Tardives du Phnom Bâkhêng K 465 et K 285,* dans *BEFEO t. LXV,* Paris 1978, pp.271-80.
- *L'inscription de Vatta Romlok K 27 et L'inscription de Prah Thom du Kulên K 715,* dans *BEFEO t. LXVII,* Paris 1980, pp.125-34.

3- Mahabidûr, Krassem

*Inscriptions Modernes d'Angkor,* Cedoreck, Paris 1984, 206 pages. (en Khmer)

4- POU, Saveros

- *Nouvelles des Inscriptions du Cambodge I,* Paris 1989.
- *Nouvelles des Inscriptions du Cambodge II,* Paris 1996.

# សិលាចារឹកមេលប់ ក្បែរស្វាយពល ផ្ទាំងអក្សរដើមផ្នែក "ក"



# សិលាចារឹកមេលប់ ក្បែរស្ពាយពល

## ផ្ទាំងអក្សរបទដើមផ្នែក "ខ"



# រាជធានីចាស់ នៃសន្តតិវង្ស ចេន ឡា

ប្រែសម្រួលក្រៅផ្លូវការ ដោយ **ហម ឆាយលី**

តាមរយៈសិលាចារឹក ដែលគេរកឃើញនៅឯវត្តភូ ( សព្វថ្ងៃ វត្តនេះស្ថិតនៅប្រទេសលាវ ) ហើយដែលបានតាក់តែងប្រែសម្រួលឡើង និងបានចុះផ្សាយនៅពេលថ្មីៗនេះដោយលោក ហ្វីណូ លូវី ( Louis FINOT ) បានឱ្យយើងដឹងថា " ស្រុកភទ្រេស្វរបទ " ស្ថិតនៅក្នុងវិស័យ " ស្រេស្ឋបុរៈ "(១) ។ " ភទ្រេស្វរៈ " នេះជាឈ្មោះនៃប្រាសាទឯវត្តភូនេះតែម្តង(២) ។ ដូច្នេះ ទីតាំងចាស់នៃទីក្រុង " ស្រេ-ស្ឋបុរៈ "(៣) នេះ ត្រូវស្ថិតនៅម្តុំវត្តភូនោះគឺនៅជិតក្រុងប៉ាកសេ ។ កាលអំពីដើមឡើយ នៅតំបន់ម្តុំ " ស្រេស្ឋបុរៈ " ដែលគេបានបោះពុម្ពផ្សាយពុំទាន់បានបញ្ជាក់ឱ្យច្បាស់លាស់នៅឡើយទេអំពីក្រុង" ស្រេស្ឋបុរៈ" នេះ ។ គឺជាក្រុងដែលមានអត្ថន័យសំខាន់ នៃអតីតប្រវត្តិខ្មែរសម័យ ចេន ឡា ( គឺកម្ពុជាសម័យដើម ) ។

ក្នុងសិលាចារឹកនេះ បានបរិយាយថា : ស្រេស្ឋបុរៈ គឺជាទីក្រុងដែលសាងឡើងដោយ " ព្រះបាទស្រេស្ឋវម្ម " បានសោយរាជបន្តអំពីបិតារបស់ទ្រង់ ។ គឺជាក្រុងរបស់ក្សត្រត្រិយ៍ខ្មែរដំបូងបង្អស់ ដែលជាជង្រុកនៃត្រកូលក្សត្រិយ៍ខ្មែរ

---

1- 1058 çaka ten tvan alo nu vraḥ Mūlasūtra ta putra srok Bhatreçvarāpata varṇṇā karmmāntara viṣaya çreṣthapura ... ", 1058 çaka le ten tvan Lo et vraḥ Mūlasūtra son fils, du pays de Bhatreçvarāspata, de la corporation des ouvriers du visaya de çesṭhapura .... ".

2-Aymonier, E. *Cambodge II*, p.163 ; Finot, L'inscription de Ban That, *BEFEO*., XII, II, P.7.

3- Aymonier, E. *Cambodge III*, p.463 place çesthapura " quelque part dans le Sud-Est du Cambodge ".

បានបន្សល់ទុកប្រវត្តិនេះមក ។ នៅឆ្នាំ ៧៥៧ ស័ក ( គ.ស ៨៣៥ ) ដែលសិលាចារឹកនៃប្រាសាទពោកពោធិ៍បានពណ៌នាឡើងឱ្យដឹងថា " ស្រេស្ឋបុរៈ " នេះ ជាទីសក្ការៈបូជាផង[(៤)] ។ នៅឆ្នាំ ៩២៣ ស័ក ( គ.ស. ១០០១ ) ព្រះបាទ " ស្រីឧទ្យា ទិត្យាវម៌្មទី ១" ទ្រង់បានប្រកាសបញ្ជាក់ថា ៖ មាតារបស់ទ្រង់មានដើមកំណើតមកអំពីក្រុង " ស្រេស្ឋបុរៈ "[(៥)] ។ រីព្រះបាស្រីជ័យវម៌្មទី ៧ វិញ ទ្រង់បានប្រកាសដែរថា ទ្រង់មានដើមកំណើតអំពីឆ្វាយ វង្សារបស់ទ្រង់ គឺ" ស្រេស្ឋវម៌្ម" ដែលជាក្សត្រិយ៍ល្បីល្បាញដ៏អស្ចារ្យនៅស្រេស្ឋបុរ[(៦)] ។

បើតាមរឿងនិទានមួយ ព្រះបាទស្រេស្ឋវម៌្មមានប្រវត្តិទាក់ទងនឹងរឿងនិទានផងគឺ "មហាឫសីកម្ពុ " និងប្រវត្តិនៃខ្សែស្រឡាយរបស់ " សូរិយវង្ស " ។ ព្រះមហាក្សត្រិយ៍ ដែលជាអ្នកទ្រទ្រង់ថែរក្សាផែនដីនៃកម្ពុជា គឺជាវង្សក្សត្រិយ៍ទាំងនោះហើយ ដែលអ្នកផ្សព្វផ្សាយវង្ស និងជាឫសគល់នៃក្សត្រិយ៍ក្រោយ[(៧)] ហើយក្សត្រិយ៍ស្រេស្ឋវម៌្ម ដែលអាចប្រដូចទៅនឹង" ព្រះអាទិត្យ" ក្នុងចក្រវាឡ គឺជាត្រកូលនៃវង្ស" ស្រីកម្ពុ"[(៨)] ។ " ស្រេស្ឋបុរៈ " ក៏បានក្លាយទៅជាក្រុងមួយ ជាជង្រុកនៃសន្តតិវង្សដើមនៃកម្ពុជា ។ អ្វីៗដែលធ្វើឱ្យយើងបានដឹងអំពី " សន្តតិវង្ស " (Les dynasties ) នេះ គឺតាមរយៈសិលាចារឹកមួយនៅប្រាសាទ " បក្សីចាំក្រុង " ដែលបានផ្តល់ពត៌មានច្រើនអំពីកេរ្តិ៍ល្បីល្បាញ ញាក់ឱ្យកន្ត្រាក់ក្រុមសន្តតិវង្សក្រោយ[(៩)] បានយល់ ។ តាមលោក ហ្វីណូ ល្វី បានប៉ាន់ស្មានឱ្យដឹងទៀតថា តាមរយៈ

---

4- Inv. Coedes n: 256 :. . . çresṭhapura dharmapūrṇe dharmena nirmite ( Cf. *J.A.*, 1909, 1, p.475 n.1 ).

5- *BEFEO.*, XI, p. 404.

6- Stèle de tā Prohm, st. VI-VII ( *BEFEO.*, p.50 ).

7- Inscription de Baksei Cāṃkroṅ, st. XIII ( *JA.*, 1909, 1, p.496 ).

8- Tā Prohm, loc.cit.

9- Baksei Cāmkoṅ, loc. cit.

រាជវង្សនោះហើយដែលធ្វើឱ្យនឹកគិតទៅដល់ " ក្សត្រិយ៍ទេស " (Principauté) នៃសន្តិវង្ស ហ្វូ-ណាន[១០] (Les dynasties de Fou-Nan) ។ ក្នុងសេចក្តីសន្និដ្ឋាននោះហើយ ទើបយើងដឹងថា " ព្រះបាទស្រុតវម្ម៌ " និង " ព្រះបាទស្រេស្ឋ-វម្ម៌ " គឺជាអតីតក្សត្រិយ៍ដំបូងនៃសន្តិវង្សចេនឡា (Les dynasties de Tchen La) ដែលមានពន្លកក្នុងវង្សនៃក្សត្រិយ៍ប្រទេស ហ្វូ ណាន ។ នៅសតវត្សទី ៧ ទោះញាតិវង្សជិតក្តី ឆ្ងាយក្តី ដែលគ្រងរាជ្យបន្តមក " ចិត្រសេនមហេន្ទ្រវម្ម៌ " និង " ព្រះបាទភវវម្ម៌ទី ១ ត្រូវទទួលជ័យជំនះ ហើយក្រសោបយកអាណាចក្រ ហ្វូ ណាន ( Fou-Nan ) ដែលកាលអំពីដើមឡើយ អំណាចនេះធ្លាប់បានយកក្សត្រិយ៍តូច តាចឯទៀតជាចំណុះផង ។

" ស្រេស្ឋបុរៈ " បានបញ្ជាក់ឡើងឱ្យយើងបានឃើញច្បាស់ថា សេចក្តីសន្និដ្ឋាននេះ ប្រាកដជាមានលក្ខណៈសមរម្យប្រពៃណាស់ ដោយហេតុថា គេឃើញមានការស្របឆន្ទៈនឹងឯកសារនេះ ដូចតទៅ ៖

១. តាមឯកសារនៃប្រវត្តិសាស្ត្រចិន បានបង្ហាញឱ្យដឹងថា សន្តិវង្សចេន ឡា បានវាយរាតត្បាតសន្តិវង្ស ហ្វូ ណាន ពីខាងជើង[១១] ។

២. តាមរយៈសិលាចារឹកចារឡើងក្នុងរាជព្រះបាទ " ចិត្រសេនៈ-មហេន្ទ្រវម្ម៌ " ដែលបានពង្រាយឡើងពាសពេញត្រើយខាងស្តាំ និងត្រើយខាងឆ្វេងនៃទន្លេធំ ( ដែលសព្វថ្ងៃនៅម្តុំមួយដែលហៅថា ភូ លខោន (Phu Lokhon)[១២] ថ្មគ្រែ[១៣] និងជ្រោយអំពិល[១៤] ហើយគេអាចរាប់បន្ថែមទាំងសិលាចារឹក ទាំង

10- Sur quelques tradition indochinoises, Mél. Syl. Lévi, p. 210
11- Pelliot, Le Founan, *BEFEO*., III pp. 274, 295.
12- Inv. nº 363 BEFEO., III, p. 442.
13- Inv. nº 122 BEFEO., III, p. 212.
14- Inv. nº 116 BEFEO., IV, p. 739.

នោះទៀត ជាពិសេស សិលាចារឹកវាលកន្ទេល ដែលគេចាត់ទុកសិលាចារឹកទាំងនោះ ថា គេចារឡើងនៅក្នុងសម័យតែមួយ(១៥) ។

៣. តាមសិលាចារឹកថ្មីមួយទៀតនៅប្រាសាទវត្ត ភូ បានតម្រង់តម្រូវឱ្យគេស្រាវជ្រាវរក " ស្រេស្ឋបុរៈ " នៅតំបន់ក្រុងបាសាក់នេះ ( បាសាក់ក្នុងប្រទេសលាវសព្វថ្ងៃ ) ។

នៅតាមតំបន់នេះហើយ ដែលអំពីបុព្វកាល ជាក្រុងដើមនៃរាជាណាចក្រចេន ឡា (Tchen-La) និងជាប្រភពដើមយ៉ាងប្រណិតនៃ " មាតុភូមិកម្ពុ " ដែលមានព្រះបាទ " ស្រុតវម្ម " និង " ស្រេស្ឋវម្ម " ជាក្សត្រិយ៍ដំបូងបង្អស់(១៦) ។ កវីបណ្ឌិតដែលនិពន្ធសិលាចារឹកនៅ " បានធាតុ " នោះឡើង ហាក់ដូចជាមានចេតនាចង់បញ្ចេញឱ្យយើងបានដឹងអំពីក្រុងនេះ ព្រោះថាបានបញ្ចេញអំពីបនពត " ភទ្រេស្វរៈ " គឺវត្ត ភូ ដែលស្ថិតនៅក្នុង " ប្រទេសកម្ពុ", ភទ្រេស្វរាទ្រាវ ឥឋាៈ កម្ពុទេសៈ, ( I, XXIII ) ។

ព្រះបាទភវវម្មទី ១, ព្រះបាទមហេន្ទ្រវម្ម និងក្សត្រិយ៍ដែលបានសោយរាជ្យបន្តៗមកទៀត បានអះអាងជា សម្ពហភាពថា : ទ្រង់មានពូជពង្សអម្បូរមកអំពី " ស្រេស្ឋបុរៈ " នេះ ។ តែក្សត្រិយ៍ទាំងនោះហាក់ដូចជាភ្លេចភ្លាំងថា " ស្រេស្ឋបុរៈ" "កម្ពុ" និង" សូរ្យវិស" (Suryavamça) ពុំមានកំណើតដូចគ្នានៃក្សត្រិយ៍សន្តតិវង្សហ្វូណនទេ បើប្រៀបធៀបទៅនឹង " ព្រះបាទកៅណ្ឌន្យជ័យវម្ម " និង" ច័ន្ទ្រវិស" ( សោមវិស, Somavamça ) នោះ ។

---

15- *ISCC.*, nº IV, p. 28.

16- Il en résulte que Tch'eli-t'o-pa-mo, roi du Founan, n'a rien de commun avec çresthavarmmar, roi du Tchen-la à une époque encore indéterninée. M. Pelliot avait déjà montré (BEFEO., III, p. 298 ) que cette identification proposéepar M. Aymonier n'était par satisfaisante au point de vue phonétique, et préférait restiuer çrindravarmma comme équivalent du nom chinois.

បើតាមសេចក្ដីអត្ថាធិប្បាយរបស់លោក ហ្វី ណូល្វី[១៧] វិញ បានឱ្យដឹងថា ក្សត្រិយ៍ស្រេស្ឋបុរៈទាំងនោះបានរុករានទន្ទ្រាន និងក្រសោបយក " ក្សត្រិយ៍ប្រទេស " នានា ហើយចាត់ចែងឱ្យក្សត្រិយ៍សោយរាជបន្ដៗគ្នា នៅពេលដែលទ្រង់បានដាក់ប្រទេសទាំងឡាយនោះជាចំណុះបានរួចហើយ ។ ម្យ៉ាងទៀត គេអាចបញ្ជាក់បន្ថែមថា ដោយសារនយោបាយទាំងនេះឯងហើយ ទើបសន្ដតិវង្ស ចេន ឡា ខិតខំបង្កើតបន្ថែមទៀតនូវស្ថាប័នសាសនា ៖ ប្រាសាទ, សំណង់ផ្សេងៗ, លិង្គ និងអគារសម្រាប់ខាងសាសនានេះឡើង នៅភូមិភាគខាងត្បូង ព្រោះជាក្រុងដែលនៅក្រោមឥទ្ធិពលនៃសន្ដតិវង្សប្រទេសហ្វូ ណាន ។ គេអាចក្រឡេកចោលភ្នែកទៅមើលផ្ទាំងផែនទីដើមបង្អស់របស់អាណាចក្រកម្ពុជា ដែលគេគូរឡើងតាមការតម្កល់សិលាចារឹកខ្មែរ ដែលមានចុះឆ្នាំ-ខែ-ថ្ងៃ យ៉ាងត្រឹមត្រូវ និងគ្រប់ទិសទីនោះ ដោយលោក ប៉ាម៉ងតៀ ហង់រី ( Parmentier, Henri[១៨] ) ។ គេពុំអាចសង្ស័យបានទៀតទេអំពី " រាជធានីចាស់ " នៃកម្ពុជានេះ ។

ដោយសារនយោបាយនេះហើយ ទើបពីរសតវត្សកន្លងមក គឺនៅក្នុងកំឡុង គ.ស.៨០០ ព្រះបាទជ័យវម៌្មទី ២ បានបង្រួបបង្រួមកម្ពុជាតែមួយ ព្រោះតាំងតែអំពី ៨ សតវត្សមកម្ល៉េះ ដែលមានតែ " ក្សត្រិយ៍ប្រទេស " ជាច្រើន ហើយនៅពេលជាមួយគ្នានោះទៀត ទ្រង់បានមកតាំងរាជធានីនៅម្ដុំខាងជើងនៃបឹងទន្លេសាប ដើម្បីឱ្យបានឆ្ងាយអំពីអតីតរាជធានីនៃសន្ដតិវង្ស ហ្វូ ណាន ។ បន្ទាប់មក ទ្រង់បានប្រកាសជាក្សត្រិយ៍នៃប្រទេសកម្ពុជ សះ, ជារាជបុត្រនៃប្រទេសកម្ពុ និងជាវង្សត្រកូលនៃ " ព្រះសូរ្យវិស " (Suryavamça) ។ តែបើតាមការសិក្សាស្រាវជ្រាវ

17- Mél. Silv. Lévi, pp. 210-211.

18- Parmentier, Henri, Cart de L'empire khmer d'après la situation des insriptions datées, BEFEO., t.XVI-3, 1916

ខ្លះ បានសន្និដ្ឋានថា គេពុំប្រទះឃើញសិលាចារឹកទេក្នុងរាជ្យរបស់ព្រះអង្គ ( ព្រះបាទស្រីជ័យវម្មិទី ២ ) ។ ប៉ុន្តែនៅសម័យនោះ នៅក្នុងសិលាចារឹកនៃប្រទេសចម្ប៉ា[១៩] ឯណោះទេ ដែលគេឃើញមានចារឡើងអំពីក្រុង " កម្ពុជ " ជាលើកដំបូងបង្អស់ ។ ព្រះនាមនៃព្រះបាទស្រីជ័យវម្មិទី ២ គេឃើញមានបញ្ចេញឡើងនៅក្នុងសិលាចារឹកនៃរាជ្យស្ដេចក្រោយៗ ដែលសោយរាជ្យបន្តៗមក គឺថា " ទ្រង់ជាអ្នករក្សាកិត្តិយសនៃត្រកូលរបស់អម្បូរ " ព្រះសូរ្យវិស " និងជា " ក្សត្រិយ៍ " នៃនគរ " ស្រីកម្ពុ "[២០] និងជា " ស្ដេចចក្រព័ត្តិ " លើស្ដេចឯទៀត បានន័យថា " កម្ពុជរាជេន្ទ្រ " ( Kambujarājendra )[២១] ហើយដែលមានព្រះស្នំរបស់ទ្រង់ព្រះនាម " ប្រាណ " ។ លុះទ្រង់បានគ្រងរាជ្យទ្រង់ក៏បានដំឡើងព្រះកិត្តិនាមព្រះអគ្គមហេសីទ្រង់វិញថាៈ " កម្ពុជរាជលក្ស្មី " ( Kambujarājala- smi )[២២] ។ លុះដល់រាជ្យក្សត្រិយ៍ក្រោយៗបន្តអំពីទ្រង់មកទៀត ព្រះកិត្តិនាម " កម្ពុជេន្ទ្រ ", " កម្ពុជេស្វរៈ " ក៏ស្ថិតនៅជាព្រះកិត្តិនាមជាផ្លូវការនៃក្សត្រិយ៍ក្រោយមកៗ ជាពិសេសព្រះបាទយសោវម្មិទី ១[២៣] ដែលទ្រង់ស្រឡាញ់ព្រះកិត្តិនាមនេះណាស់ មិនតែប៉ុណ្ណោះ ក្នុងរាជ្យរបស់ទ្រង់ ទ្រង់បានដាក់ឈ្មោះថា " កម្ពុជបុរី " ទៅឱ្យក្រុងមួយដែលនៅទីនោះទ្រង់បានឡើងគ្រងរាជ្យនៅត្រង់ម្ដុំអង្គរធំសព្វថ្ងៃ[២៤] ។ ក្នុងពេលជាមួយគ្នានេះដែរ គឺជា " អម្បូរ " " សូរ្យវិស " ពុំមែន " សោមវិស " ទេ ដែលក្សត្រិយ៍ក្រោយៗពីព្រះបាទជ័យវម្មិទី ២ ប្រកាសអំពីវង្សារបស់ទ្រង់នោះ[២៥] ។

19- Po Nogar, Inv. 31, C2-*ISCC.*, n° XXVIII, p. 263.
20- Baksei Cāmkoṅ, st. XIX-XX.
21- Prāsat Kév, *ISCC.*, n° XVB, st. II.
22- Prāḥ Vihar, Ibid., n° LXI A st. v ; B, st IX.
23- Inscriptions digraphique et stèles du Thnal Bārāy, *passim.*
24- Thnal Bārāy, ISCC., n° LX A, st XXI.
25- Cf. Finot, Mél. Sylv, Lévi, p. 209.

សេចក្តីសន្និដ្ឋានអំពីទំនៀមនៃវង្សារបស់ " ក្សត្រិយ៍សម័យអង្គរ " ត្រូវបានពង្រឹងឡើងក្រោយរាជ្យព្រះបាទស្រីជ័យវម៌្មទី២ ក្តី ក៏រាជធានីនៃព្រះបាទ " ស្រេ-ស្ឋវម៌្ម " ( ស្រេស្ឋបុរៈ ) ពុំបានបាត់បង់ខ្លឹមសារអ្វីសោះឡើយ ។ តាមរយៈនៃក្រុងនោះហើយ ដែលធ្វើឱ្យយើងបានយល់ថា តើនៅតំបន់ណាទៅ ដែលក្សត្រិយ៍ខ្មែរនៅសតវត្សទី ៩ យកជាជង្រុកដំបូងបង្អស់នៃរាជវង្សរាជវាំង ដែលញាតិវង្សទាំងអស់នេះបានបែកចេញជាមែកធាង " ខ្សែ, ស្រឡាយ, ញាតិ ផៅរបស់ទ្រង់ " បន្តបន្ទាប់មក ។

កំណត់អ្នកបកប្រែ :

ខ្ញុំបាទឃើញឯកសារនេះ ខ្ញុំជឿជាក់ថាជាប្រវត្តិដ៏សំខាន់ សំរាប់ឱ្យកុលបុត្រកុលធីតាយើងបានដឹង និងត្រងត្រាប់នៃប្រវត្តិសាស្រ្តដើមរបស់ប្រទេសកម្ពុជាយើង ។ ឯកសារដើមនេះ បាននិពន្ធឡើងដោយសឺដេសស្ទ័ក មានឈ្មោះថា
COEDES, George, Etudes cambodgiennes (XII)

LE SITE PRIMITIF DE TCHEN-LA

B.E.F.E.O., 1918 : 1-3.

## សុភាសិត

*ចូរដាស់តឿនខ្លួនដោយខ្លួនឯង*
*សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធជារបស់ចំពោះខ្លួនឯង*
*អ្នកដទៃនឹងធ្វើអោយអ្នកដទៃអោយបរិសុទ្ធមិនបានទេ ។*

ធម្មបទ

# ប្រវត្តិ

## វត្តសម្តេចព្រះនាគវ័ន វរពោធិ ( សំបុក )

វត្តសំបុក ស្ថិតនៅខាងជើងភ្នំសំបុក ជាប់មាត់ទន្លេមេគង្គ នាត្រើយខាងកើត ក្នុងឃុំសំបុក ស្រុកក្រចេះ ខេត្តក្រចេះ មានចម្ងាយប្រមាណ ១០ គ.ម ពីទីរួមខេត្តក្រចេះ ។ វត្តនេះមាននាមពិតប្រាកដ ហៅថា " វត្តសម្តេចព្រះនាគវ័ន[១] វរពោធិ " សំបុក ។

តាមសាវតារវត្តសំបុក ( Dossier 695 et 694 " Fonds Adhémard Leclère. Don à la Bibliothèque Municipale fait par France Leclère en 1944 " ) បានបញ្ជាក់ថា : ព្រះបាទសិរីសារពេជ្ជ មានព្រះសទ្ធាជ្រះថ្លាចង់កសាងវត្តអារាម នៅឯលំនៅឋានជនបទ ស្រុកឆ្ងាយ ជាទ្វារព្រះនគរ ក្នុងព្រះរាជបំណងទុកជាកេរដំណែលក្នុងព្រះសាសនាផង ចំរើនសិរីសួស្តីដល់ព្រះនគរផង ជាផលប្រយោជន៍ដល់ប្រជានុរាស្ត្រអ្នកនៅជនបទស្រុកឆ្ងាយរបស់ព្រះអង្គផង ។ ព្រះអង្គបានត្រាស់ព្រះរាជឱង្ការអោយព្រះស្រីសុរិយោពណ៌ ចាត់ចែងក្នុងពិធីកសាងវត្តអារាម សំបុកនេះ ។ ពេលនោះ ព្រះស្រីសុរិយោពណ៌ បានចាត់តាំងរាជមហាមាត្យមួយរូប ងារជាឧកញ៉ាកាមាធិរាជ អោយនាំយកព្រះរាជទ្រព្យ មកកសាងវត្តអារាម . ព្រះជីវី[២] និងព្រះចេតិយ នៅស្រុកសំបុកនេះ ។ ជាមួយគ្នានេះដែរ, ទ្រង់ត្រាស់បញ្ជាអោយយកខ្ញុំកដរ ដែលស្មោះត្រង់នឹងព្រះអង្គ ចំនួន ៤០ គ្រួប្រោសទុកជាជើងកប អោយនៅថែរក្សាព្រះវិហារ ព្រះជីវី និងព្រះចេតិយ នៅទីវត្ត

---

(១) នាគវ័ន ប្រហែលជាព្រះនាមព្រះចៅអធិការមួយអង្គ ប្អូនព្រះនាគសែន វត្តអារអៀត ទេដឹង ? ព្រះនាគ-សែន ជាអំបូរស្តេចដែរ មានបងប្អូន ២ រូប គឺ ព្រះនាគសែន និងព្រះនាគវ័ន ។ (២) ព្រះជីវី : គឺព្រះពុទ្ធបដិមាធំៗ តម្កល់ក្នុងព្រះវិហារ ហាក់ដូចជាមានព្រះជន្មគង់ធរមាននៅ ។

វត្តសំបុកនេះ ។

ឯខ្ញុំកំដរទាំង ៤០ គ្រួនោះ មានឈ្មោះដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. អាគុន | ១១. អាមុំ | ២១. អាធី | ៣១. អាទាវ |
| ២. អាម៉ែន | ១២. អារត់ | ២២. អាម៉ាន់ | ៣២. អាដង |
| ៣. អាសួរ | ១៣. អាសេន | ២៣. អាសែវ | ៣៣. អារាំ |
| ៤. អាប្រីយ | ១៤. អាសីន | ២៤. អាពៅ | ៤៤. អាកុត |
| ៥. អាគេន | ១៥. អាតុង | ២៥. អាណៃ | ៣៥. អានី |
| ៦. អាម៉ាន | ១៦. អាលយ | ២៦. អាសំ | ៣៦. អារាំ |
| ៧. អាព្រំម | ១៧. អាកែប | ២៧. អាមន់ | ៣៧. អាសួរ |
| ៨. អាងួន | ១៨. អាតែរ | ២៨. អាជ័យ | ៣៨. អាសៅ |
| ៩. អាខិត | ១៩. អាសុន | ២៩. អាចាន | ៣៩. អាលី |
| ១០. អាឯក | ២០. អារស់ | ៣០. អាគុត | ៤០. អាត្រី |

វត្តសំបុកនេះ ចាប់ផ្តើមកសាងឡើងនៅថ្ងៃ ១០ រោច ខែ មាឃ ឆ្នាំ ឆ្លូវ ឆស័ក ត.ស ១៥២៣ ។ អំឡុងពេលនោះ, វត្តសំបុកនេះ ស្ថិតនៅក្នុងស្រុកមួយ គឺស្រុកសំបុក ។ គេយកនាមស្រុកតាមឈ្មោះភ្នំសំបុក មិនមែនស្រុកក្រចេះ ដូចសព្វថ្ងៃនេះទេ ។

ក្រោយពេលកសាងវត្តរួចហើយ ព្រះបាទស្រីសារពេជ្ជ[១] ត្រាស់បញ្ជាឱ្យព្រះស្រីសុរិយោពណ៌[២] ថ្វាយព្រះនាមដល់សម្តេចព្រះអរិយគាថា[៣] ថា «សម្តេចព្រះនាគវ័ន វរពោធិ បញ្ញាមហាពោធិ ជាសង្ឃនាយកមហាសង្ឃរាជ[៤] » ។

( ១ ) ព្រះស្រីសារពេជ្ជ មិនដឹងជាព្រះរាជាអង្គណា ? សោយរាជ្យនៅទីណា ? សម័យចតុមុខ ឬសម័យលង្វែក ព្រោះក្នុងអំឡុងឆ្នាំ ១៥២៣ មានតែសម័យលង្វែកទេ ឬក៏ព្រះស្រីសុរិយោទ័យ ទេដឹង ? (២) ព្រះស្រីសុរិ. យោពណ៌គ្រងរាជ្យនៅឆ្នាំ ១៦០០ ទីតាំងរាជធានីល្វាឯម ( ខេត្តកណ្តាល ) ។ (៣) ព្រះអរិយគាថា ជាងារ ឬនាមបញ្ញត្តិ របស់សម្តេចព្រះនាគវ័ន ។ ជីតាខ្ញុំគាត់ថា អរិយសត្ថា ... ។ (៤) មហាសង្ឃរាជ ស្តេចធំ (ឆ្លង)

ពេលថ្វាយព្រះនាមវត្តប្រគេនសម្តេចព្រះនាគវ័ន ព្រះសង្ឃរាជរួចហើយ ទ្រង់ក៏កំណត់ពន្ធអាករផ្សេងៗ សំរាប់បំរើសេចក្តីត្រូវការ ដែលកើតមានឡើងដល់វត្តអារាម គឺមួយភាគ បំរើវត្តអារាម មួយភាគទៀត ផ្តល់អោយចៅហ្វាយស្រុកសំបុក, ដូចសេចក្តីដើមទាំងស្រុងថា : « *បើមានឈ្មួញនាំចូលរបស់ផ្សេងៗពីប្រទេសក្រៅ ដូចជា គោក ស្លឹក ហិប ចាន សំពត់ក្តី, មួយចំណែក ត្រូវបានចំណូលសំរាប់បំរើអោយវត្តអារាម, មួយចំណែកទៀត ត្រូវបានទៅចៅហ្វាយស្រុក* » ។

- ឯដីព្រៃ ដីបឹង ដីកណ្តាលជ្រៃ ដីប្របមាត់ទន្លេ ឡើងទៅដល់ពាមកាកុត, ខាងកើតត្រឹមព្រៃស្រែរុង, ព្រៃស្រែព្រៃង, ខាងត្បូងត្រឹមត្រពាំងស្គរ ។

- ឯព្រែក : ចាប់ពីព្រែកក្រគរ ព្រែកខ្សា ព្រែកកន្ទ្បាមបាត ព្រែកកាំពិរ ទល់នឹងព្រែកកាកុត ។

- ឯបឹង : បានដល់បឹងវែ បឹងរូង បឹងឈើរលំ បឹងសំបុក បឹងក្រឡ បឹងជើងព្រះ ។

- ឯព្រៃ : បានដល់ព្រៃគគីរ ព្រៃព្រហ្មូត ព្រៃឫស្សី សម្បត្តិធម្មជាតិទាំងអស់នេះ ត្រូវបានជាតម្លៃ សំរាប់បំរើព្រះត្រៃរតនត្រ័យ ក្នុងវត្តសំបុកនេះ ។ ការដែលព្រះអង្គទ្រង់កំណត់ពន្ធ និងតម្លៃធម្មជាតិនេះ គឺស្ថិតក្នុងព្រះរាជបំណងបំរើផលប្រយោជន៍ទ្រទ្រង់ រក្សាវត្តសំបុកនេះ អោយបានគង់វង្ស ស្ថិតស្ថេរ ជាអមតៈរៀងរហូត ។

ក្រោយមក, លោកឧកញ៉ាវង្សាអន្ទិស បានប្រើពួកកំលោះៗ អោយចូលកាប់ឈើ កាប់ផ្តៅ ច្រូតស្បូវ ដើម្បីប្រក់ព្រំព្រះវិហារ និងលំអវត្តអារាម ជួយថែរក្សា

---

ខាងព្រះសង្ឃ, សម្តេចព្រះនាគវ័ន គឺស្តេចសង្ឃជំនាន់នោះ ព្រះអង្គគង់នៅវត្តសំបុកនេះ ដោយហេតុនេះបានជាវត្តនេះត្រូវបានថ្វាយព្រះនាមថា "ស្តេចព្រះនាគវ័ន វរពោធិ " ដូច្នេះ ។

ការពារកុំអោយបាក់បែក ខូចខាតក្នុងវត្តអារាម តទៅអនាគត ។

សូមបញ្ជាក់ថា ៖ សម័យនោះ ទំនាក់ទំនងស្តេចខ្មែរ និងស្តេចលាវ មានភាពជិតស្និទ្ធគ្នា ។ ស្តេចលាវច្បាំងចាញ់ស្តេចខ្មែរ ចំណុះស្តេចខ្មែរ ។ ប្រទេសលាវត្រូវចំណុះប្រទេសខ្មែរ ហើយត្រូវបាននាំយកសួយសារអាករផ្សេងៗ មកថ្វាយស្តេចខ្មែរ ដោយឆ្លងកាត់តាមខេត្តស្ទឹងត្រែង ស្រុកសំបូណ៌ ស្រុកសំបុកនេះ ។ ក្នុងសាវតារវត្តសំបុកបញ្ជាក់ថា ៖ បើព្រះរាជសារចៅសុវណ្ណ មកអំពីស្រុកលាវ អោយទទួលយកបណ្ណាការទាំងនោះទុកប្រើប្រាស់ក្នុងវត្តអារាម ដូចជា « អង្ករ អំបិល ប្លូរ កំពោរ សំពត់ អាវលំទង ម្ជុល ក្លស់ ខ្មៅយ កន្ទេល វាំងនន ស្គរ ប៉ី តាំងយូ ចានបញ្ជរង្គ ចានបាយ » ... ។

- គ្រឿងបណ្ណាការមួយចំនួន សំរាប់បូជាថ្វាយស្តេចទឹក ស្តេចភ្លើង ដែលជាអ្នកតាភ្នំថែរក្សាស្រុក ដូចជា « ពែងស្ពាន់ ពែងចាន ផ្តិត បរិក្ខារ ស្ពាន់ » ... ។

- បណ្ណាការមួយចំនួនទៀត មានរងបៀនប៉ាក់ ២, អកកំពោរ ២, ប្រ-ណាក ២, តោកបៀនប៉ាក ២, សំរាប់ស្តេចសុគតមួយ, គង់ព្រះជន្មមួយ ។

- បណ្ណាការមួយចំនួនទៀត មានដីរឈ្មោលមួយ ដីរញីមួយ ត្រូវឧកញ៉ាឯកពិធា ១, ចៅពញាទេសអន្សា ១, ចៅពញាឯកចរិយា ១[១] ទាំង ៣ នាក់នេះ នាំទៅថ្វាយដល់ព្រះរាជប្រាសាទវាំង ។

ចំណែករណ្តាប់ស្តេចទឹក-ស្តេចភ្លើង[២] ទ្រង់អោយយកទឹកសំបួរ មកកក់លាងស្រង់ជំរះអង្គកាយអ្នកនោះ ហើយទ្រង់អោយលាបប្រេងម្សៅ ជាការស្រេច ។ បន្ទាប់មក ត្រូវចៅពញាឯកចរិយា រៀបគ្រឿងរណ្តាប់បរិក្ខារ ដាក់ជាជួរ

(១) ឧកញ៉ាឯកពិធា - ចៅពញាទេសអន្សា - ចៅពញាឯកចរិយា ទាំង ៣ នេះ ប្រហែលជា ចៅថ្វាយស្រុកសំបុកនេះ ។ (២) ស្តេចទឹក-ស្តេចភ្លើង ប្រហែលជានាមអ្នកតាភ្នំសំបុក-អន្សា ស្រុកសំបុកជំនាន់នោះទ្រង់អោយតម្កល់ទុកលើកំពូលភ្នំ ។ ប្រហែលអ្នកតាដំបងដែក ទេដឹង ? បច្ចុប្បន្ន ចោរលួចយកទៅបាត់ហើយ។

សងខាង ហើយអង្គុយត្រង់ជំនុំកណ្ដាល សូត្រព្រះធម៌ប្រែបីបទ[១] ( បីដង ) ចំរើនព្រះពរជ័យថ្វាយព្រះមហាក្សត្រផែនដី និងប្រជានុរាស្ត្ររបស់ព្រះអង្គ ។ ក្នុងពេលសូត្រនោះ ទ្រង់អោយមានលេងភ្លេងភ្លាត់ប្រគំកំដរផង ។

ក្រោយមកទៀត មានព្រះរាជឱង្ការព្រះបាទសម្ដេចព្រះចៅលង្វែក ក្រុងកម្ពុជាធិបតី ស្រីឥន្ទបត្តកុរុរដ្ឋរាជធានី ចាត់អោយចៅឧកញ៉ាឯកពិធា និងចៅពញាចរិយា ទទួលនាំព្រះរាជឱង្ការ និងបណ្ណាការផ្សេងៗ.ចេញមកដល់ស្រុកអាយ៉ុន, អាប៉ាប៉ា ទ្រង់អោយប្រសិទ្ធិនាម ចំរើនព្រះពរថ្វាយក្បួនស្ដេចទឹក-ស្ដេចភ្លើង ឡើងទៅតម្កល់ទុកនៅលើកំពូលភ្នំ សំរាប់ជាអន្ទ្យាស្រុក រក្សាព្រះខ័នព្រះនគរ ។

- ទ្រង់អោយផ្សព្វផ្សាយដល់អ្នកស្រុក រដែ ចារាយ ព្នង ដែលជាអ្នកតាក់តែងរក្សាផ្លូវព្រៃ តាមលំនាំពីបុរាណរៀងៗមក ដើម្បីកុំអោយពួកសត្រូវផងមើលងាយ ។ ជាមួយនេះដែរ ទ្រង់អោយបួងសួងដល់អស់ពួកទេព្ដា ទេព្រ័ក្ស អារក្ខអ្នកតាផ្សេងៗ អោយថែរក្សាវត្តអារាម និងប្រជានុរាស្ត្រ អោយមានអាយុវែង យិនយូរ បរិបូណ៌ ស្ថិតស្ថេរចិរកាល តទៅ ។

ដោយទ្រង់មានកង្វល់ខ្លាចផ្ទៃក្រោមមានគំនិតមិនល្អ ចង់បំផ្លាញវត្តអារាមអោយខូចខាត បាត់បង់ព្រះសាសនា ទ្រង់ត្រាស់កំណត់[២] ៣ ឆ្នាំម្ដង ត្រូវឡើងមកសួរនាំដល់ប្រាសាទម្ដង ។

ចាប់តាំងពីពេលនោះមក ដល់បច្ចុប្បន្ន វត្តសម្ដេចព្រះនាគរ័ន វរពោធិបញ្ញាមហាពោធិ ( វត្តសំបុក )[៣] ដែលជាព្រះកេរដំណែល របស់សម្ដេចព្រះស្រីសារពេជ្ញ មានអាយុកាលប្រមាណ ៤៧៦ ឆ្នាំហើយ ។

---

(១) សូត្រព្រះធម៌ប្រែ ៣ ដង = ក្នុងពិធីបែបនេះ បុរាណច្រើនហៅថា សូត្រស្តុតិ គឺសូត្រ សរសើរបារមីសិរីសួស្ដីថ្វាយម្ចាស់ផែនដី និងអាណាប្រជានុរាស្ត្រ ។ (២) ជំនាន់នោះ ដោយមានវិបត្តិផ្ទៃក្រោមផង ពិបាកធ្វើដំណើរចុះឡើងផង ទើបទ្រង់កំណត់ ដូច្នេះ ។ (៣) វត្តនេះ កសាងពីឆ្នាំ ១៥២៣ គិតមកដល់ឆ្នាំ ១៩៩៩ ត្រូវជា ៤៧៦ ឆ្នាំ ។

• សំណូមពរចំពោះ ៖

ព្រះអង្គម្ចាស់ សម្តេច ឯកឧត្តម លោកជំទាវ •មន្ត្រីរាជការតូចធំ អស់លោក លោកស្រី និងពុទ្ធបរិស័ទទាំងឡាយ ទាំងក្នុងប្រទេស ទាំងនៅក្រៅប្រទេស មេត្តាជួយឧត្ថម្ភគាំទ្រវត្តនេះ អោយមានសោភណភាព សមស្របជាវត្តកេរដំណែល និងជាសម្បត្តិវប្បធម៌ ដ៏រុងរឿង របស់បុព្វបុរសយើង.។

ក្រចេះ, ថ្ងៃទី ២៨ កុម្ភៈ ១៩៩៩

ស្រាវជ្រាវ និងចងក្រងតាមសាវតារវត្តសំបុក

- លោក **ជួប យាន**

មន្ត្រីចូលនិវត្តន៍ មន្ទីរធម្មការ និងសាសនា ខេត្តក្រចេះ

- លោកស្រី **ធួន សោភ័ណ**

ប្រធានការិយាល័យអភិវឌ្ឍន៍វប្បធម៌ ខេត្តក្រចេះ

# រឿងនាងកែវប្រាំពីរពណ៌ (*)

**ភ.ភ.ន..** អត្ថបទ « រឿងនាងកែវប្រាំពីរពណ៌ » ត្រូវបានស្រង់យកពីកម្រងនិក្ខេបបទបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា ជំនាន់ទី ៤ របស់និស្សិត សួរ ឆេង និង ឡាំ តុភក្ត្រ តាមការនិពេន របស់លោក អ៊ឹង ហឿង ធ្វើការនៅអភិរក្សអង្គរ ។ គណៈកម្មការនិពន្ធទស្សនាវដ្តីកម្ពុជសុរិយា បានយកមកចុះជាគតិជូនអ្នកអាន ដោយហេតុថាជារឿងនិទានប្រជាប្រិយមួយ ដែលប្រជាជនខ្មែរបានដឹងដោយសារចាស់ទុំនិយាយប្រាប់តៗគ្នាមក ។ គណៈកម្មការនិពន្ធបានកែរួលអក្ខរាវិរុទ្ធ និងពាក្យពេចន៍ត្រង់អន្លើខ្លះ ដោយរក្សាទុកខ្លឹមសារដើមទាំងស្រុង ។

តាមរឿងតំណាលថា ក្នុងយុគសម័យអង្គរ គឺក្នុងសម័យដែលកសាងប្រាសាទដោយឥដ្ឋ និងថ្មបាយក្រៀម មានស្តេចមួយអង្គ ព្រះនាមកងចក្រ សោយរាជសម្បត្តិនៅរាជធានីអង្គរ ទ្រង់មានរាជបុត្រីមួយព្រះអង្គ ព្រះនាមនាងកែវប្រាំពីរពណ៌ ។ ហេតុដែលព្រះនាងមានព្រះនាមដូច្នោះ ពីព្រោះព្រះនាងមានរូបសម្បត្តិល្អឥតខ្ចោះ មានសម្រស់ប្រែប្រួល ផ្លាស់ប្តូរបានប្រាំពីរពណ៌ ក្នុងមួយថ្ងៃ ។

ថ្ងៃមួយ, ព្រះនាងទ្រង់បានយាងចេញទៅប្រពាតព្រៃ ទ្រង់រើសបានពងក្រពើមួយយ៉ាងធំ ខុសប្លែកពីពងក្រពើទាំងពួង ។ ព្រះនាងទ្រង់មានសេចក្តីត្រេកអរជាខ្លាំង ហើយទ្រង់យកពងក្រពើនោះទៅភ្ញាស់ ដើម្បីទុកគ្រាន់នឹងចិញ្ចឹម ។

លុះក្រពើនោះញាស់មកព្រះនាងទ្រង់ សព្វព្រះរាជហឫទ័យនឹងកូនក្រពើនោះណាស់ ។ ព្រះនាងទ្រង់បានសុំព្រះរាជានុញ្ញាតពីព្រះវររាជបិតា ដើម្បីធ្វើអាងចិញ្ចឹមក្រពើនោះ នៅក្នុងអាងបារាយណ៍ទឹកថ្លា ត្រង់កន្លែងទីទួលកោះប្រាសាទមេបុណ្យ ។ ព្រះនាងទ្រង់បានផ្តល់ចំណី


ក្រពើអាធន

(*) មានទំនាក់ទំនងនឹងបារាយណ៍ខាងកើត

ចិញ្ចឹមកូនក្រពើដោយព្រះហស្តព្រះនាងផ្ទាល់ ហើយទ្រង់បានដាក់ឈ្មោះក្រពើនោះថា « អាធន » ។ ពេលវេលាកន្លងផុតទៅមិនយូរប៉ុន្មាន ក្រពើអាធន ក៏បានធំធាត់ជាលំដាប់ រហូតដល់ធំលើសក្រពើផងទាំងពួង, វាចេះស្គាល់ និងមានភក្តីភាពចំពោះព្រះនាងជាម្ចាស់របស់វាណាស់ ។ វាតែងតែបង្ហាញនូវភាពស្លូតបូតរបស់វាចំពោះព្រះនាង ធ្វើឱ្យព្រះនាងកាន់តែស្និទ្ធស្នាលជាមួយវាជានិច្ច រហូតដល់ព្រះនាងហ៊ានយាងជិះលើក្បាលវាធ្វើជាព្រះទីនាំងលំហែព្រះកាយលើផ្ទៃទឹកបារាយណ៍ទៀតផង ។

លុះអំណើះតទៅ អាស្រ័យដោយឥទ្ធិពលនៃព្រះរូបឆោមលោមពណ៌ និងសម្ផស្សដ៏ល្អលើសលប់, នាមព្រះនាងកែវប្រាំពីរពណ៌ក៏បានឮល្បីខ្ទរខ្ទាយរន្ទឺសុះសាយរហូតដល់នគររាជគ្រឹះ បណ្តាលឱ្យរាជបុត្រស្តេចក្រុងចិនសព្វព្រះរាជហឫទ័យចំពោះព្រះនាងជាខ្លាំង ។ បន្ទាប់ពីបានទទួលព្រះរាជានុញ្ញាតពីព្រះវររាជបិតាមាតារបស់ព្រះអង្គរួចហើយ ព្រះរាជបុត្រក្រុងចិននៃនគររាជគ្រឹះ ក៏បានរៀបចំជាក្បួននាំជំនូនយ៉ាងគគ្រឹកគគ្រេងចូលចងស្ពានមេត្រី ស្តីដណ្តឹងយកព្រះនាងកែវប្រាំពីរពណ៌ធ្វើជាព្រះអគ្គមហេសី ។

ចំណែកឯព្រះបាទកងចក្រ ក៏ទ្រង់ព្រះរាជានុញ្ញាតឱ្យរៀបចំអភិសេកព្រះរាជបុត្រីនាងកែវប្រាំពីរពណ៌ ថ្វាយទៅព្រះរាជបុត្រស្តេចក្រុងចិន ទៅតាមប្រពៃណីទំនៀមទម្លាប់បរមបុរាណខ្មែរ នាសម័យនោះ ។

ព្រះនាងកែវប្រាំពីរពណ៌ ក្រោយពីទ្រង់បានដឹងថា ព្រះនាងនឹងត្រូវមានស្វាមី ហើយនឹងត្រូវឃ្លាតឆ្ងាយពីអ្វីៗនៅក្នុងព្រះរាជនគរ ទៅគង់រស់នៅជាមួយស្វាមីឯនគររាជគ្រឹះនោះ ព្រះនាងក៏ទ្រង់ព្រួយព្រះរាជហឫទ័យនឹកសោកស្តាយអាឡោះអាល័យអាធនជាខ្លាំងពន់ពេកណាស់ ។ នៅវេលាព្រឹកថ្ងៃមួយ ព្រះនាងបានទូលសុំព្រះវររាជបិតា ដើម្បីយកចំណីទៅឱ្យអាធនជាលើកចុងក្រោយ ។ ព្រះបាទកងចក្រទ្រង់បានព្រះរាជានុញ្ញាតឱ្យរាជបុត្រីដូចកាលសព្វដង ។ ព្រះនាងទ្រង់បាននាំចំណីយក

ទៅឱ្យអាធន ដោយមានភិលៀង និងស្រីស្នំក្រមការហែហមអមដំណើរជាគ្នាផង ។ ពេលដែលបានជួបនឹងអាធន ព្រះនាងឱ្យចំណីបណ្ដើរ និងមានព្រះឱស្ឋ ( សវនីយ៍ ) ទៅកាន់វាបណ្ដើរថា ៖ អាធនអើយ ! អាធន ! នេះគឺជាលើកចុងក្រោយហើយ ដែលយើងបានជួបឯង ។ ចាប់ពីពេលនេះតទៅ យើងនឹងត្រូវឃ្លាតឆ្ងាយពីឯងហើយ ពីព្រោះយើងត្រូវព្រះវររាជបិតា ទ្រង់ព្រះរាជអនុញ្ញាតឱ្យមានព្រះស្វាមី ដែលជាព្រះរាជបុត្រស្ដេចក្រុងចិន ។ ពេលរៀបអភិសេកហើយ យើងនឹងយាងទៅនៅជាមួយព្រះស្វាមី ឯនគររាជគ្រឹះឯណោះ ។ យើងហាក់ដូចជាមិនដាច់ព្រះទ័យពីឯងសោះ ហាក់បីដូចជានៅតែអាឡោះអាល័យឯងខ្លាំងណាស់ ។ តែណ្ហើយចុះ ! ចូរឯងនៅឱ្យបានសុខ យើងសូមលាឯងហើយ ! យើងនឹងត្រូវបែកពីឯងមិនដឹងជាថ្ងៃណាបានជួបគ្នាទៀតទេ ។

ចំណែកអាធន ពេលដែលបានស្ដាប់ឮបន្ទូលព្រះនាងដូច្នោះ វាក៏កាន់តែរិកិលខ្លួនចូលជិតកៀកនឹងព្រះនាង ហាក់បីដូចជាចង់បង្ហាញថា វាសូមទ្រង់យាងព្រះនាងឡើងគង់លើក្បាលវាធ្វើជាព្រះរាជទីនាំង ដើម្បីលំហែព្រះទ័យនៅអាងបា-រាយណ៍ ទឹកថ្លានោះ ។

បន្ទាប់ពីទ្រង់បានទតយល់គំនិតរបស់អាធន ដែលបង្ហាញថា វាក៏មានស្វា-មិភក្តិ និងក្ដីអាឡោះអាល័យចំពោះព្រះនាងជាម្ចាស់ខ្លាំងណាស់ដែរនោះ ព្រះនាងក៏សព្វព្រះទ័យទ្រង់យាងគង់លើក្បាលអាធន ដូចកាលសព្វដង ។

ក្រោយពីបានរៀបចំព្រះរាជដំណើរថ្វាយព្រះនាងស្រេចបាច់ហើយ អាធនក៏ថយខ្លួនបង្វិលក្បាលពីទិសខាងកើត នាំព្រះរាជធិតាកែវប្រាំពីរពណ៌ ឆ្ពោះទៅទិសខាងត្បូងក្នុងល្បឿនខុសប្លែកពីធម្មតាដ៏គួរឱ្យភ័យខ្លាច ។ ព្រះនាងមានវិតក្ក ភិតភ័យស្លន់ស្លោឥតឧបមា ទ្រង់ក៏ភ្លាត់ព្រះឱស្ឋទៅកាន់អាធនថា ៖ នែ ! អាធន, ម្ដេចក៏ឯងធ្វើដូច្នោះ ! យើងភ័យណាស់ ! ប្រយ័ត្នយើងមានគ្រោះថ្នាក់ណា ! ព្រោះយើង

ជិតដល់ថ្ងៃរៀបអភិសេកហើយ ។ គ្រាន់តែចប់ព្រះឱស្ឋភ្លាម អាធនក៏គ្រលៀសលេបព្រះរាជធីតាកែវប្រាំពីរពណ៌ គ្រានោះទៅ ។

អាធនដឹងថា គេនឹងតាមចាប់ខ្លួន វាក៏ខំប្រឹងមុជគេចចេញពីអាងបា-រាយណ៍ទឹកថ្លា តាមដងស្ទឹងដែលចេញពីបារាយណ៍ទៅទិសខាងត្បូង ឆ្ពោះទៅកាន់បឹងទន្លេសាប ដើម្បីរកទីលាក់ខ្លួនពួនអាត្មា ។

ចំណែកភិលៀង និងស្រីស្នំក្រមការ ឃើញព្រះរាជធីតាទ្រង់ទទួលនូវគ្រោះភ័យដូច្នោះ ក៏កើតមានសេចក្ដីភិតភ័យ រត់ទៅទូលព្រះរាជាភ្លាម ។

ព្រះបាទកងចក្រកើតក្ដីរន្ធត់ ក្រេវក្រោធឥតគណនា ក៏ចាត់អាមាត្យនាហ្មឺនសព្វមុខមន្ត្រី អស់ពលសេនា យោធា ឱ្យគោះគងទូងភេរី អំពាវនាវជ្រើសរើសរកអ្នកមានថ្វីដៃខ្លាំងពូកែជំនាញខាងចាប់ក្រពើ និងកៀងគរប្រមូលអស់ប្រជា-នុរាស្ត្រដើម្បីតាមរកក្រពើអាធនឱ្យឃើញ និងចាប់ឱ្យបាន ។

សេចក្ដីអំពាវនាវនោះ ក៏បានលេចឡើងនូវអ្នកស្ម័គ្រចិត្ត ជាគ្រូអាលម្ពាយម្នាក់ឈ្មោះ តាដោក ដែលជាអ្នកចេះមន្តអាគមខ្លាំងពូកែ និងស្ទាត់ជំនាញខាងចាប់ពស់ ចាប់ក្រពើ ។ ចំណែកអាណាប្រជានុរាស្ត្រ ក្រោយពីបានទទួលដំណឹងទុក្ខសោកនោះហើយ ក៏នាំគ្នាមកចោមរោមមូលមិរដេរដាស ជុំជិតត្រង់ទីកើតហេតុ នាអាងបារាយណ៍ទឹកថ្លានោះ ។

ការតាមចាប់ក្រពើ បានបែងចែកជាពីរផ្នែក គឺមួយផ្នែកតាមរកចាប់ក្រពើក្នុងអាងបារាយណ៍ និងលុបស្ទឹងដែលចេញពីបារាយណ៍កាត់តាមភូមិសណ្ដាន់ ចុះទៅក្រោម « ទៅទិសខាងត្បូង » ។ មួយផ្នែកទៀត លុបស្ទឹងពីព្រៃនាមមាត់បឹងទន្លេសាបឡើងមកខាងលើវិញ « មកទិសខាងជើង » ។ រីឯចុងស្ទឹងដែលនៅសេសសល់មិនលុប « ស្ថិតក្នុងព្រៃនាម » ចាប់ពីបឹងទន្លេសាបមកទល់នឹងដីដែលគេលុបនោះ, តរេក អ្នកស្រុកហៅថា ស្ទឹងកំបុត ។ ស្ទឹងកំបុត នេះស្ថិតនៅក្នុងព្រៃនាម

មាត់ទន្លេសាប « ភាគខាងត្បូង ឃុំកែវពណ៌ ស្រុកពួក » ។

តាមព្រះតេជព្រះគុណ លី សុខ ចៅអធិការវត្តចេតិយ មានសង្ឃដីកាតំណាលថា ៖ ក្បួនចាប់ក្រពើទាំងពីរផ្នែក មានមនុស្សច្រើនឥតគណនា គ្រាន់តែដីមួយក្តាប់ៗម្នាក់ គេអាចលុបស្ទឹងពីទិសខាងជើងទៅខាងត្បូង និងពីទិសខាងត្បូងមកទិសខាងជើងវិញ មកទល់គ្នានឹងអន្លង់មួយធំហើយជ្រៅ ស្ថិតនៅជាប់ក្បែរនឹងគោកតាសួស ។

ទីអន្លង់នេះហើយ ដែលតាដោកគាត់បានធុំចំហាយក្លិនសាក្រពើ រួចហើយក៏សន្មតថា ក្រពើអាធន ពិតជាកំពុងលាក់ខ្លួនពួនអាត្មាក្នុងទីនោះ ។ អន្លង់ដែលអាធនលាក់ខ្លួននេះ ក្រោយមកអ្នកស្រុកហៅថា អន្លង់សា ។

ទន្ទឹមនឹងការរៀបចំពិធីសែនព្រេនបន់ស្រន់លោកតាសួស តាមទំនៀមទម្លាប់ប្រពៃណីបរមបុរាណ តាដោកគាត់បានចាត់ចែងមនុស្សឱ្យរុករកបោចផ្ដៅ (១) យកមកធ្វើជាខ្សែព្រួរ ដើម្បីទាក់ចាប់ក្រពើអាធន ។

ក្បួនតាមចាប់ក្រពើដ៏តក្រឹកគគ្រេង ក៏បានមកចោមរោមនៅទីអន្លង់ដ៏ជ្រៅនេះ « អន្លង់សា » ។ គេបាននាំគ្នាបោះបង្គោល ដោយសសរធំៗ រាប់សិបដើម (២) ដើម្បីទាក់ចាប់ក្រពើដ៏កំណាចនេះ ។ មិនយូរប៉ុន្មាន តាដោកក៏ចាប់ក្រពើអាធនបានយកមកវះពោះ កាត់ក្បាលដោតឆ្កាងដាក់ថ្វាយលោកតាសួស ដែលស្ថិតនៅលើទីទួល ក្បែរអន្លង់នោះ (៣) ។

---

(១) ទីកន្លែងព្រៃដែលបោចផ្ដៅនេះ គឺជាព្រៃដែលសំបូរទៅដោយផ្ដៅជាងគេ អ្នកស្រុកទម្លាប់ហៅថាព្រៃផ្ដៅ ។ សព្វថ្ងៃ នៅទីនោះមានវត្តមួយ ហៅថាវត្តព្រៃផ្ដៅ ស្ថិតនៅក្នុងឃុំក្រវៀល ស្រុកពួក ទិសខាងកើតអន្លង់សា ។ (២) បង្គោលសសរស្រគាក់ធំៗ គេទើបតែដករួចរស់នៅក្នុងអំឡុងឆ្នាំ ១៩៧៧ ពីព្រោះគេធ្វើទំនប់ទ្វារទឹកនៅទីនោះ ។ របៀតបកដរ់ សព្វថ្ងៃនេះ ក៏នៅតែហៅថាគោកតាសួសៗ ដដែល » ។ (៣) របៀតដរ់សព្វថ្ងៃនេះ ក៏នៅតែហៅគោកតាសួសៗ ដដែល ។

ចំណែកព្រះនាងកែវប្រាំពីរពណ៌ ពេលដែលវះយកបានពីពោះក្រពើមក ព្រះនាងទ្រង់សន្លប់ស្តូកស្តឹងបាត់ដង្ហើមស្ងូនស្ងៀមឈឹង នៅសល់តែជីបចរប៉ុណ្ណោះ ។ អស់នាម៉ឺនមុខមន្ត្រី ក៏ធ្វើគ្រារៀបចំគ្រែស្នែង សែងព្រះនាងយាងមកកាន់ព្រះបរមរាជវាំង ក្រែងនឹងអាចព្យាបាលជួយសង្គ្រោះព្រះនាងបាន(៤) ។

លុះសែងព្រះនាងបានឆ្ងាយបន្តិចពីទីនោះ ព្រះនាងក៏ផុតដង្ហើមសោយទីវង្គតទៅ(៥) ។

ដោយគ្មានបង្អែរបង្អង់ ក្បួនសែងសាកសពព្រះនាង ក៏នៅតែទៅមុខចេញពីព្រៃផុតដង្ហើម សំដៅទៅកាន់ព្រះបរមរាជវាំង ។ កំពុងតែឆ្លងកាត់វាលធំមួយ ស្រាប់តែពេលនោះ មានខ្យល់ព្យុះបោកបក់យ៉ាងខ្លាំងគួរឱ្យចម្លែកណាស់ បណ្តាលឱ្យកេសារបស់ព្រះនាងកែវប្រាំពីរពណ៌ ត្រូវប៉ើងរំសាយពីលើគ្រែស្នែងទៅតាមអំណាចនៃកំលាំងខ្យល់ដែលបោកបក់នោះ ។ អស់នាម៉ឺនសព្វមុខមន្ត្រី មានសេចក្តីភិតភ័យស្លន់ស្លោ ខិតខំបន់ស្រន់បណ្តើរ រហូតទាល់តែឆ្លងផុតវាលធំនោះ ដល់មាត់ព្រៃមួយ ទើបខ្យល់ធំនោះបានស្ងប់ទៅវិញ ។ វាលធំដែលសែងសាកសពនាងកែវប្រាំពីរពណ៌ឆ្លងកាត់នោះ ហៅថា « វាលល្វើយសក់ »(៦) ។

ទន្ទឹមនឹងដល់មាត់ព្រៃ ខ្យល់ក៏ស្ងប់ សែងសាកសពតាមដងព្រៃនោះ ក្លិនអសុភក៏កាន់តែជះចំហាយខ្លាំងឡើងៗ ទើបគេហៅដងព្រៃនោះថាព្រៃស្អុយ(៧) ។

---

(៤) ទីកន្លែងដែលរក ឃើញនាងកែវប្រាំពីរពណ៌នោះ រំណើះតបក អ្នកស្រុកហៅថាកែវពណ៌ សព្វថ្ងៃកើតបានជាឃុំ កែវពណ៌ ក្នុងស្រុកពួក ខេត្តសៀមរាប ។ (៥) ទីព្រៃដែលព្រះនាងកែវប្រាំពីរពណ៌គេហៅ ទីវង្គតនោះ ហៅថា ព្រៃផុតដង្ហើម ក្រោយមកក្លាយជាព្រៃដង្ហើម ។ សព្វថ្ងៃ មានវត្តមួយ ហៅថា វត្តព្រៃដង្ហើម ស្ថិតនៅខាងជើង ឆៀងខាងកើតរន្លង់តា ក្នុងឃុំសំរោងយា ស្រុកពួក (៦) សព្វថ្ងៃ គឺជាវាលស្រែ ចាប់ពីវត្តព្រៃដង្ហើមមកទល់នឹងភូមិស្វាយ ឃុំខ្នាត ស្រុកពួក ។ ព្រៃស្អុយស្ថិតនៅខាងលិចភូមិប្របុះ ក្បែរផ្លូវគីឡូម៉ែត្រ ក្នុងឃុំទឹកវិល ស្រុកពួក ។

ចំណែកព្រះបាទកងចក្រ ពេលដែលទ្រង់ជ្រាបនូវដំណឹងថា ព្រះរាជបុត្រី បានសោយទិវង្គតទៅហើយនោះ ព្រះអង្គក៏ទ្រង់មានវិតក្ក សោកសង្រេង អាឡោះអាល័យរកអ្វីប្រៀបស្មើពុំបានឡើយ ។ ព្រះអង្គក៏ទ្រង់កើតនូវក្ដីសន្ទិះសង្កា ទើបទ្រង់មានព្រះរាជតម្រិះពិគ្រោះយោបល់នឹងហោរា ព្រមទាំងអ្នកមុខអ្នកការក្នុងព្រះបរមរាជវាំង ដើម្បីបានជាទីសណ្ដាប់ និងពិចារណា ។ ដោយព្រះអង្គទ្រង់ឈ្វេងយល់ទៅតាមគន្លងប្រពៃណី ពីបរមបុរាណរៀងមក ចំពោះមនុស្សផងទាំងឡាយដែលស្លាប់ដូច្នេះ គេហៅថា ខ្មោចតៃហោង, មិនអាចនាំយកមកចូលផ្ទះ ឬ ចូលបរមរាជ-វាំងវិញបានទេ, ព្រះអង្គចេញព្រះរាជបញ្ជាឱ្យរកដីត្រង់កន្លែងដែលល្អប្រពៃ រៀបចំធ្វើជាចេតិយ ដើម្បីបញ្ចុះសាកសពព្រះនាងឱ្យបានសមរម្យ ។

អស់មុខមន្ត្រី សេនា អាមាត្រ ចេញពីបរមរាជវាំង ធ្វើដំណើររូតរះទៅស្ទាក់ស្ទាត់ទាន់ក្បួនដង្ហែសាកសពនៅឯព្រៃស្អុយនោះ ។ ក្បួនដង្ហែសាកសព ក៏ត្រូវសម្រាកផ្អាកដំណើរ ដើម្បីទទួលព្រះរាជសាររយៈពេលមួយសន្ទុះ ។ បន្ទាប់ពីបានស្ដាប់ព្រះរាជសាររួចហើយ ក្បួនដង្ហែរសាកសពក៏បង្វែរទិសហែក្បួនឆ្ពោះទៅកាន់ទិសខាងត្បូងវិញ ដើម្បីរកទីបញ្ចុះសាកសពព្រះនាង ។

សូមបញ្ជាក់ថា កន្លែងដែលផ្អាកដំណើរទទួលព្រះរាជសារនោះ គេបានកសាងប្រាសាទចេតិយមួយដោយឥដ្ឋ មានសណ្ឋានដូចជាប្រាសាទវត្តចេតិយដែរ ប៉ុន្តែ គ្រាន់តែមានទំហំតូចជាងបន្តិចប៉ុណ្ណោះ ទាំងបរិមាណផ្ទៃដី និងតួប្រាសាទ ។ អ្នកស្រុកទម្លាប់ហៅថា ប្រាសាទព្រៃស្អុយ ។ ប្រាសាទនេះ ត្រូវបានជនខិលខូចគាស់កកាយបំផ្លាញរលាយហិនហោចអស់ហើយ ។ តាមដែលអ្នកធ្វើស្រែនៅក្បែរៗនោះបានឱ្យដឹងថា ប្រាសាទព្រៃស្អុយនេះ ទើបតែរលាយខ្ទេចខ្ទីអស់ នៅឆ្នាំ ១៩៨៤ ។

លុះក្បួនហែដល់ទីកន្លែងមួយ តាមដែលមន្ត្រីខាងភូមិសាស្ត្រ ហោរា-សាស្ត្រ ពិនិត្យគន់គូរមើលទៅឃើញថា ទីនោះជាទីប្រពៃ សមគួរជាទីបញ្ចុះសាកសព

ព្រះនាងហើយ ក៏ចាត់ចែងពិធីបុណ្យបញ្ចុះសពព្រះនាងកែវប្រាំពីរពណ៌យ៉ាងអធិកអធម ទៅតាមប្រពៃណី ។ ប៉ុន្តែ ដោយពិនិត្យឃើញថា ទីនោះជាទីវាលទំនាបទឹកលិច ទើបត្រូវបានចាត់ចែងមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ លើកដីនោះឱ្យទៅជាទីទួលខ្ពស់ផុតពីទឹកលិច ហាក់បីដូចជាផ្នូរមួយយ៉ាងធំអស្ចារ្យ ។ ជាមួយគ្នានោះ គេក៏បានកសាងចេតិយមួយយ៉ាងធំខ្ពស់ កណ្តាលព្រៃមាត់ទន្លេសាប ពីលើដីទួលនោះ ។

ចំណែកព្រះបាទកងចក្រ ព្រះអង្គទ្រង់នៅតែមានសេចក្តីសោកស្តាយអាឡោះអាល័យ និងគិតគូរដល់ព្រះរាជបុត្រីខ្លាំងណាស់ ព្រះអង្គក៏ទ្រង់មានព្រះរាជតម្រិះពិចារណាថា គប្បីរកឆ្មាំចាំថែរក្សា និងសំអិតសំអាងទីព្រះចេតិយនោះ ។ មយ៉ាងទៀត ត្រូវធ្វើឱ្យទីកន្លែងនោះបានជាទីកុះករដោយមនុស្សម្នា មានផ្លូវទៅមកស្រួល សំរាប់អ្នកស្រុក អ្នកភូមិជិតឆ្ងាយ ចូលមកធ្វើបុណ្យផង និងងាយស្រួលសំរាប់ព្រះអង្គទ្រង់យាងទៅធ្វើទានឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធព្រះរាជបុត្រីផង ។

ក្រោយពីទ្រង់មានព្រះរាជតម្រិះដូច្នោះហើយ ព្រះអង្គក៏ទ្រង់បានតែងតាំងងារជាយសសក្តិដល់តាដោក ឱ្យធ្វើជាឆ្មាំថែរក្សាការពារ និងសំអិតសំអាងទីព្រះចេតិយនោះ ។ រីឯវត្តអារាម ក៏ត្រូវបានកសាងឡើងមានព្រះសង្ឃ មានពុទ្ធបរិស័ទចេញចូលធ្វើបុណ្យទានហូរហែជារៀងរហូតមកដល់សព្វថ្ងៃនេះ ។ វត្តនេះព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យឱ្យឈ្មោះថា ៖ « វត្តកោះនាងកែវចូឡាមណីធម្មចេតិយ » ដែលក្លាយមកជាវត្តចេតិយ ( ចៃដី ) សព្វថ្ងៃ (៨) ។

លុះអំណើះពីនោះមក គឺក្រោយពីលោកតាដោក បានទទួលអនិច្ចកម្មទៅ គេក៏បានកសាងជារូបសំណាកលោកតាដោកមួយ នៅពីមុខផ្លូវចូលចេតិយ « ចម្ងាយប្រហែល ៧០ ម៉ែត្រពីព្រះចេតិយ » ជានិមិត្តរូបនៃការទទួលខុសត្រូវលើកិច្ចការពារ និងថែរក្សាទួលចេតិយនោះ ។

---

(៨) វត្តចេតិយ ស្ថិតនៅខាងត្បូង ឆៀងខាងកើតវត្តព្រៃដង្កោ » ។

តាមការតំណាលតៗគ្នាថា រូបសំណាក់តាដោកនេះ អ្នកស្រុកទម្លាប់មាត់ហៅថា អ្នកតាដោកមានឫទ្ធិខ្លាំងពូកែណាស់ សូម្បីតែសត្វក៏មិនអាចហើររំលងបានដែរ ឱ្យតែហ៊ានហើររំលង គឺត្រូវតែធ្លាក់ ។ ម្យ៉ាងទៀត ចំពោះគោក្របីណា ដែលចូលស៊ីស្មៅក្នុងស្រះ ឬលើទួលព្រះចេតិយនោះ គឺពិតជាត្រូវអ្នកតាដោកលាក់បាត់ម្ចាស់ពុំអាចរកឃើញភ្លាមៗទេ ទាល់តែបួន ឬប្រាំថ្ងៃ ទើបអាចរកឃើញវិញ ។ សព្វថ្ងៃនេះ គេពុំឃើញមានរូបសំណាក់តាដោកទេ នៅសល់តែកន្លែងដាក់រូបសំណាក់ប៉ុណ្ណោះ ។ តាមពតិមានថា អភិរក្សអង្គរបានដឹករូបសំណាក់នោះទៅទុកហើយ ។

*

**ជនពាលធុកជាអ្វី ?**

ជនពាលាប្រាជ្ញនិន្ទាថាព្រៃស្លុក
ព្រោះផ្តល់ទុក្ខអោយអ្នកស្រុកឆុកវេទនា
ថាកើតមកអោយតែធ្ងន់ពសុធា
ព្រោះតែវាគ្រារស់នៅផៅលោមក ។

យូរ អ៊ិន

# អំពីព្រះបាទធម្មិក

( ក្បួនពុទ្ធទំនាយ )

## នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ព្រះពុទ្ធសករាជព្រះសាសនា សម្ដេចព្រះមហាករុណាទិគុណ បរមពោធិ-ញាណ នាកាលព្រះអង្គយាងចូលព្រះបរិនិព្វាន នៅថ្ងៃអង្គារ នក្ខត្តឫក្សអធិកពន្លឺកនៅថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក វេលាបែកព្រឹកព្រាងស្រាងស្រេច ទើបព្រះអង្គសម្រេចព្រះនិព្វាន នាកាលអំពីល្ងាចថ្ងៃចន្ទ ១៥ កើតនោះ ព្រះអង្គមានព្រះបន្ទូលផ្ដែផ្ដាំនឹងព្រះអានន្ទត្ថេរ នូវអស់ភិក្ខុសង្ឃទាំងឡាយថា : ម្នាលអាវុសោ ភិក្ខុទាំងឡាយអើយ ! វេលាព្រឹកស្អែកនេះហើយ អញតថាគតនឹងបរិនិព្វានដ៏ជាស្ថានបរមសុខហើយ អាវុសោអើយ ! ចូរអ្នកនៅក្រោយបានជាសុខសប្បាយរាល់គ្នា ឱ្យខំចម្រើនមេត្តាភាវនាឱ្យបាននិព្វានតាមអញតថាគតទៅហោង ។ ទើបព្រះអានន្ទត្ថេរទូលថា : ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យអម្ចាស់ខ្ញុំអើយ ! បើព្រះអង្គចូលព្រះបរមនិព្វានទៅហើយ តើសាសនាព្រះអង្គអស់តែប៉ុណ្ណេះឯងហើយ ឬក៏ជានៅមានតទៅមុខទៀត ចូរព្រះអង្គសម្ដែងថ្លែងជាសណ្ដាប់ប្រាប់យើងខ្ញុំគ្រប់គ្នាក្នុងកាលឥឡូវនេះហោង ។

ទើបព្រះដ៏មានបុណ្យ ព្រះអង្គមានព្រះបន្ទូលថា : អានន្ទអើយ ! អាវុសោអានន្ទអើយ ! ចូរអាវុសោស្ដាប់អញតថាគតឱ្យបានដឹង, អាវុសោអើយ អាវុសោ ! តថាគតចូលនិព្វានទៅហើយ រីសាសនាអញតថាគតទុកឱ្យគ្រប់ ៥.០០០ ព្រះវស្សា

ឱ្យអស់អាវុសោគ្រប់គ្នាប្រោសសត្វនៅឯក្រោយ អញតថាគតចូលបរមនិព្វានទៅហោង ។ ទើបព្រះអានន្ទត្ថេរទូលថា ៖ ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យអម្ចាស់ខ្ញុំអើយ បើដូច្នោះ ព្រះអង្គនឹងតាំងពីត្រឹមណា ទើបគ្រប់ ៥.០០០ វស្សាព្រះអង្គនោះសូមថ្លែងជាសណ្ដាប់ប្រាប់នៃយើងខ្ញុំឱ្យបានដឹងគ្រប់គ្នា កាលឥឡូវនេះមែនហោង ។

ទើបព្រះដ៏មានបុណ្យ ព្រះអង្គមានបន្ទូលថា ៖ អាវុសោ អានន្ទអើយ ! ចូរអាវុសោស្ដាប់ អញតថាគតនឹងប្រាប់អាវុសោតែម្ដងប៉ុណ្ណោះទេ ។ អំណើះអំពីថ្ងៃនេះតទៅ អញតថាគតពុំបានប្រាប់អាវុសោទៀតឡើយ ។ ចូរអាវុសោស្ដាប់ អាវុសោអើយ ! ឱ្យអាវុសោរាប់ចាប់តាំងពីថ្ងៃអង្គារ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័កនេះឯងរៀងទៅ លុះដល់ឆ្នាំជូត អដ្ឋស័កនេះឯងតរៀងទៅ លុះដល់ឆ្នាំជូត អដ្ឋស័កនោះថា ពាក់កណ្ដាលព្រះសាសនាអញតថាគត ឱ្យគិតពីឆ្នាំជូត អដ្ឋស័ក ខែពិសាខ ១៥ កើត ថ្ងៃពុធនេះឯង ត្រូវជាគម្រប់ ៥.០០០ ព្រះវស្សាតថាគតនេះឯងហោង ។ ទើបព្រះអានន្ទត្ថេរទូលថា ៖ ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យអម្ចាស់ខ្ញុំអើយ ! រីព្រះសាសនាព្រះអង្គ ៥.០០០ ព្រះវស្សា តើនឹងសុខសប្បាយរៀងរាបដរាប ទៅឬនឹងមានហេតុភេទ ប្រការដូម្ដេចខ្លះ សូមព្រះអង្គទ្រង់ត្រាស់ព្រះធម៌វិសេសទេសនាប្រាប់យើងខ្ញុំឱ្យបានដឹងគ្រប់គ្នា កាលគ្រាឥឡូវនេះហោង ។

ទើបព្រះដ៏មានបុណ្យមានបន្ទូលថា ៖ អាវុសោ អានន្ទអើយ ! ចូរអាវុសោស្ដាប់ តថាគតនឹងប្រាប់អាវុសោឯងតែម្ដងប៉ុណ្ណោះទេ ។ អំណើះអំពីនេះទៅ អញតថាគតពុំបានប្រាប់ទៀតឡើយ រើអាវុសោអើយ ! អញតថាគតចូលបរមនិព្វានទៅបាន ១០០ ព្រះវស្សាទៅ ថ្កើងសប្បាយ លុះដល់ ២០០ ព្រះវស្សា នឹងបាត់នាងភិក្ខុនីផងទាំងឡាយ ក៏កើតកង្វល់ឱ្យរវល់ក្នុងសាសនាតថាគតម្ដង លុះដល់សាសនាអញតថាគតបាន ៣២០ ព្រះវស្សា ( ក្បួនខ្លះថា ២២០ ព្រះវស្សា ) កើតមានស្ដេចមួយឈ្មោះព្រះបាទស្រីធម្មាសករាជ នៅនគរឥន្ទបត្តបុរី ស្ដេចនោះបានលើកព្រះសារីរិក

ធាតុអញ្ចេតថាគត ទើបលើករណ្ដាប់ព្រះធម្មសង្គាយនា មានព្រះមហាថេរជាប្រធាន មានព្រះអនុរុទ្ធត្ថេរនោះឯងជាដើម បានថ្កើងរុងរឿងទៅ លុះដល់សាសនាអញ្ចេតថាគតបាន ៥០០ ព្រះវស្សា (ក្បួនខ្លះថា ៤២០ ព្រះវស្សា) មានស្ដេចមួយឈ្មោះថា ក្រុងមាលិនឥន្ទ្រាធិរាជ(*) កើតឯនគរសាធិលបុរី ស្ដេចនេះឯងមកផ្ចាញ់ផ្ចាលព្រះសាសនាអញ្ចេតថាគតឱ្យបាត់សាបសូន្យទៅ ទើបមានព្រះសេនទេវបុត្រច្យុតចុះមកកើតជាព្រះនាគសេនថេរ បានទៅរំដោះទម្លះទម្លាយកម្ចាត់ពាក្យមិលិន្ទ ទើបបានបាក់បបខ្លបខ្លាចឫទ្ធិអំណាច ក៏តាមទូន្មានប្រដៅបានសុខសប្បាយរៀងទៅ ។ លុះដល់សាសនាអញ្ចេតថាគតបាន ១.០០០ ព្រះវស្សា ទើបមានស្ដេចមួយមានឈ្មោះថា ព្រះកេតុមាលា មកសោយរាជ្យនៅក្នុងនគរគោកធ្លកនោះឯង បានជាស្ដេចធំឧត្ដម មានមនុស្សកុះករក្សេមក្សាន្តសប្បាយ តរៀងទៅ ។ លុះសាសនាអញ្ចេតថាគតបាន ១៤២០ ព្រះវស្សា មានទមិឡអន្យតិរ្ថិយ៍ បានមកផ្ចាលផ្ចាញ់ព្រះសាសនាអញ្ចេតថាគតឱ្យបាត់សាបសូន្យសុងទៅ ទើបមានក្សត្រាធិរាជមួយព្រះអង្គ ឈ្មោះព្រះបាទអព័យទស្សកម្មនិ បានផ្ចាលផ្ចាញ់ទមិឡតិរ្ថិយ៍ឱ្យបាក់បបខ្លបខ្លាច ទូន្មានប្រដៅ ទើបលើកតតិយសង្គាយនាឡើង មានព្រះមហាថេរជាប្រធាន មានព្រះមហាមោលិបុត្តត្ថេរជាដើម បាននាំសកវាទី ៥០០ បានថ្កើងរុងរឿងតរៀងទៅ ។ លុះដល់សាសនាអញ្ចេតថាគតបាន ១៦១៥ ព្រះវស្សា ទើបកើតមានស្ដេចមួយឈ្មោះព្រះបាទស្រីសញ្ជ័យបោរាឥសូរ គង់នៅបន្ទាយស្រះកែវ ស្ដេចនោះបានទូន្មានប្រដៅស្ដេចប្រទេសទាំងឡាយ បានសប្បាយតរៀងទៅ ។ លុះដល់សាសនាអញ្ចេតថាគតបាន ១៦៥០ ព្រះវស្សា បាត់គម្ពីរសាត្រាធម៌អាថិក្បួនច្បាប់សាបសូន្យសុងទៅ ។

លុះយូរបន្តិចទៅទើបឃោសកទេវបុត្រ ច្យុតចុះមកកើតជាព្រះពុទ្ធឃោសាចារ្យបានទៅចម្លងគម្ពីរដីកាធម៌ក្បួនខ្នាតច្បាប់ពីនគរលង្កាទ្វីប នាំយកមក

(*) មិលិន្ទឥន្ទ្រាធិរាជ

ទុកនៅនគរគោកធ្លក ក្នុងភ្នំគូលេន ទើបមានព្រះមហាក្សត្រាធិរាជមួយព្រះអង្គ ទ្រង់ព្រះនាមបទុមវង្ស ទើបលើកព្រះមហាសករាជបានថ្កើងរុងរឿងតទៅ ។ លុះដល់សាសនាអញ្ជូតថាគតបាន ២.០០០ ព្រះវស្សានោះ មានសៀមមកយកគម្ពីរពីក្នុងបន្ទាយស្រះកែវ នាំយកទៅនគរណោងស្នោអស់ទៅហោង ឯក្រោយនោះមកនគរគោកធ្លកក៏កើតកង្វល់ ទុរ្ភិក្សពុំសុខណាស់ណាអារុំសោអើយ ! ។ លុះដល់សាសនាអញ្ជូតថាគតបាន ២.០២៥ ព្រះវស្សា កើតមានស្ដេចមួយឈ្មោះព្រះបាទទស្សវង្ស ស្ដេចនោះសោយរាជ្យបន្តិចទៅក៏កើតឃ្លង់អស់ទាំងខ្លួន ទើបមានមហាឥសីមួយព្រះអង្គប្រើសិស្សឱ្យមកប្រោសស្ដេចទស្សវង្ស ក៏ស្ដេចពុំទ្រង់ជឿ ឱ្យសម្លាប់សិស្សឥសី ឥសីក៏មកប្រោសសត្វឡើងវិញ ហើយប្រទេចស្ដេចគម្លង់ឱ្យ កើតអន្តរធានវិកវរក្នុងនគរគោកធ្លកនោះឯងហោង ។ លុះដល់សាសនាអញ្ជូតថាគតបាន ២.០៣៥ ព្រះវស្សា មានព្រាយមកពីព្រៃហេមពាន្តជាងមួយម៉ឺន មកនៅក្នុងនគរ ព្រាយនោះមកបញ្ចូលចិត្តទាំងស្ដេចចាស់ ក្មេង ឱ្យកង្វល់ លោភោ ទោសោ មោហោ យកខុសជាត្រូវ យកត្រូវជាខុស ត្រឡប់វិកវរក្នុងនគរនោះ កើតសិស្សពុំខ្លាចគ្រូ កូនពុំខ្លាចឪពុកម្ដាយ ប្រពន្ធពុំខ្លាចប្ដី រាស្ត្រមិនខ្លាចនាហ្មឺន នាហ្មឺនមិនខ្លាចស្ដេច ស្ដេចទៅជារាស្ត្រ រាស្ត្រធ្វើជាស្ដេចវិញ ត្រឡប់វិកវរក្នុងនគរនោះណា៎ អារុំសោអើយ ! ។ លុះដល់សាសនាអញ្ជូតថាគតបាន ២.១០០ ព្រះវស្សា ទើបកើតមានស្ដេចមួយឈ្មោះព្រះអង្គ នន់ សោយរាជ្យនៅឧដុង្គមានជ័យ សោយរាជ្យបន្តិចទៅ ក៏ភៀសខ្លួនចូលទៅព្រៃភ្នំបាត់ទៅហោង ។ លុះដល់សាសនាអញ្ជូតថាគតបាន ២.២០០ ព្រះវស្សា ទើបមានទមិឡអន្សត្រីយ៍ វាមកសោយរាជ្យក្នុងព្រះនគរគោកធ្លកនោះឯង ។ ស្ដេចនោះតែងយកមនុស្សស្រីផងទាំងឡាយដែលមានគភ៌ ១០ ខែក្ដី ៩ ខែក្ដី ឱ្យយកទៅកាប់សម្លាប់ ដុតភ្លើងស្លាប់ចោល នឹងគណនាត្រារាប់ពុំបានឡើយ ។ លុះយូរបន្តិចទៅ បានពញាក្រែកសោយរាជ្យ បន្ទាប់មកបានតាជ័យត្រសក់ផ្អែម មកសោយ

រាជ្យជាស្ដេចក្នុងនគរគោកធ្លក បានត្រូវលើកចុល្លសករាជតរៀងទៅ នគរគោកធ្លកក៏បាននាយចម្ការធ្វើជាស្ដេច ឯនគរសៀមបានដង្វៅធ្មស់ធ្វើជាស្ដេច នគរលាវបានព្រានព្រៃសោយរាជ្យធ្វើជាស្ដេច នគរចិនបានអ្នកគង្វាលគោសោយរាជ្យធ្វើជាស្ដេច ។ តំណាតពីនេះទៅទៀត លុះដល់សាសនារអញ្ចតថាគតបាន ២.៣០០ ព្រះវស្សាកើតមានស្ដេចមួយឈ្មោះហៅថាហ្លួងព្រះរាម ស្ដេចនោះសោយរាជ្យស្លាប់តែនឹងនាហ្មឺនខ្លួនឯង ។ នោះមនុស្សទាំងឡាយក៏កើតមានទុរ្ភិក្សរត់បាយ ទាំងលោកសង្ឃក៏សឹកពុំមានគង់ នោះតថាគតសន្មតហៅថា រាលខុរាច់ស មនុស្សផងក៏ស្លាប់ច្រើនណាស់ហោង ។ លុះសាសនាតថាគតបាន ២.៣៥០ ព្រះវស្សានោះ អាវុសោអើយ ! បានទមិឡមួយ វាចូលមកសោយរាជ្យធ្វើជាស្ដេច ទៀត ។ កាលនោះ មនុស្សផងកើតទុរ្ភិក្សរត់បាយក្នុងឆ្នាំមមីនោះ ក៏រត់ចូលក្នុងព្រៃភ្នំក្រំថ្ម ទន្ទឹងរកតែព្រះដ៏មានបុណ្យ ។ លុះដល់ឆ្នាំមមែ មនុស្សផងក៏ស្លាប់ច្រើន ។ លុះដល់យូរបន្តិចទៅ មានស្ដេចមួយឈ្មោះព្រះបាទធម្មិកសាលរាជ ( ក្បួនខ្លះថា ព្រះបាទភិមសាលរាជ ) មកសោយរាជ្យក្នុងទិឧដុង្គ ជាស្ដេចធម្មិកតូច បានបំបួសលោកសង្ឃពេញពាសឡើង ស្ដេចនោះកើតឆ្នាំរោង រាងដូចយក្ស ព្រះភ័ក្ត្រដូចក្រូចសើច ។ ស្ដេចនោះមានព្រះរាជបុត្របីព្រះអង្គ សម្ដេចព្រះរៀមឆ្នាំមមែ ដំណើរទ្រង់សិង្ហ, ព្រះអនុជបន្ទាប់ឆ្នាំជូត ដំណើរចិន, ព្រះអនុជពៅឆ្នាំឆ្លូវ ដំណើរដូចសៀម ។ ព្រះបិតាសោយរាជ្យយូរបន្តិទៅ ក៏អស្តង្គតទៅ ទើបអស់មន្ត្រីប្រជារាស្ត្រទាំងឡាយមកអភិសេកសុំឱ្យព្រះរៀមឆ្នាំមមែនោះមកសោយរាជ្យ ព្រះនាមថាព្រះបាទធម្មិករាជ ទ្រង់គង់នៅក្រុងឧដុង្គមានជ័យ គម្រប់បីឆ្នាំហើយ ក៏នាំស្រីស្នំក្រមការទៅឈរនៅទន្លេបួនមុខ ។ ស្ដេចនេះសោយរាជ្យកាលណាហើយ ក៏តាំងលក់ដី លក់ទឹក លក់ព្រៃឈើទាំងអស់ពុំមានសល់ចន្លោះអ្វីឡើយ ហើយបើស្ដេចនោះគិតពីទសពិធរាជធម៌ទាំង ១០ ប្រ. ប្រការនោះ នឹងបានលើកសាសនារអញ្ចតថាគតនោះហោង ។ ធម៌ទាំង ១០ ប្រការ

នោះគឺ ៖

- កុំយកសាសន៍គេមកធ្វើជាសាសន៍ឯង នេះប្រការមួយ,
- កុំយកឫកគេមកធ្វើជាឫកឯង នេះប្រការមួយ,
- កុំយកកិរិយាគេមកធ្វើជាកិរិយាឯង នេះប្រការមួយ,
- កុំយកចិត្តគេមកធ្វើជាចិត្តឯង នេះប្រការមួយ,
- កុំយកគំនិតគេមកធ្វើជាគំនិតឯង នេះប្រការមួយ,
- កុំគិតព្យាបាទគេ នេះប្រការមួយ,
- កុំឱ្យកុហកគេ នេះប្រការមួយ,
- កុំយកត្បាល់ទៅបុកអង្រែ នេះប្រការមួយ,
- កុំយកអង្រែបុកក្បាលត្បាល់ នេះត្រូវជាដប់ប្រការ ដោយរាប់បញ្ចូលទាំងទសពិធរាជធម៌ [១] មួយទៀតផង ។

**ឈន់ ហ៊ិន**

*( នៅមានត )*

---

(១) ទសពិធរាជធម៌ គឺរាជធម៌ ១០ យ៉ាង, ឬធម៌ ១០ ប្រការ សំរាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ។ ទសពិធរាជធម៌នោះគឺ ៖ ១. ការធ្វើអំណោយ, ២. ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល ១០ តាមការគួរ, ៣. ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងព្រះនគរ, ៤. មានសេចក្ដីត្រង់, ៥. មានសេចក្ដីទន់ភ្លន់ ស្លូតបូត សុភាពរាបសា, ៦. ការរក្សាឧបោសថសីលតាមកាលកំណត់, ៧. មិនកក្ដៅអ្នកដទៃឱ្យក្ដៅក្រហាយ, ៨. មិនបៀតបៀនអ្នកដទៃ, ៩. មានសេចក្ដីអត់ធន់, ១០. មិនបំពានលើធម៌ ឬលើច្បាប់ ។

# បុណ្យខ្មែត ឬ បុណ្យរនោច

• ធ្វើបុណ្យមានពីរបែប
ខាងខ្មែតបានបុណ្យណាស់
បុណ្យខ្មែតម៉ែឪរស់
ព្រះរស់កូនថៃធ្នូន
• នេះហៅបុណ្យខាងខ្មែត
កូនចៅប្រើជាស្ពាន
លោកហៅកូនស្រែបុណ្យ
កុសលផ្តល់ទៅមុខ
• ធ្វើបុណ្យពេលរនោច
អស់សាច់ញាតិជិតឆ្ងាយ
អុជធូបបង្គំថ្វាយ
សំណែនសល់ទាំងស្តុក
• កាលម៉ែឪនៅរស់
ខ្លាចខាតតែរៀងខ្លួន
ប្រាក់កាសឪពុកម្តាយ
ខ្ជួចខាតបង់កេរ្តិ៍ឈ្មោះ

ជាសង្ខេបតាមពាក្យចាស់
ច្បាស់នឹងភ្នែកអ្នកទាំងឡាយ ៕
កូនសង្គ្រោះបច្ច័យបួន(*)
ក្បួនដីកាលោកចារទុក ៕
ច្បាស់ជាកើតកុសលទាន
ឈានទៅរកកន្លែងសុខ ៕
អ្នកស្គាល់គុណម្តាយឪពុក
សុខក្សេមក្សាន្តមានទ្រព្យធន ៕
គឺបុណ្យខ្មោចឪពុកម្តាយ
បាយសម្លអង្ករសែន ៕
ឪពុកម្តាយអញ្ជើញមក
យកមកវិញចែកគ្នាផឹ ៕
មិនគិតសោះបច្ច័យបួន
ពួនយកសុខសន្សំទ្រព្យ ៕
សល់ប្រវាយដណ្តើមឈ្មោះ
ឈ្មោះព្រោះទ្រព្យខ្មោចម៉ែឪ ៕

(*) បច្ច័យបួន : គ្រឿងតំរាក់រាត្រូវការ ៤ យ៉ាងគឺ អាហារ, គ្រឿងស្លៀកដណ្តប់, ពំនៅឋាន, ថ្នាំរំងាប់រោគ ៕

*• ម៉ែឪស្រឡាញ់កូន*
*ខ្លួនមានប្រពន្ធប្ដី*
*ក្រោយពេលម៉ែឪស្លាប់*
*កញ្ចប់ធាតុពណ៌ស*
*• ម៉ែឪស្លាប់ម្ដេចកើត*
*កាលលោកនៅរស់ឡើយ*
*កូនចៅអ្នកចងចាំ*
*បុណ្យខ្មើតកើតក្ដីសុខ*

*មិនបំពូននំចំណី*
*ឥតគិតអ្វីដល់លោកសោះ ។*
*ទើបអោយស្ដាប់នូវព្រះធម៌*
*ឥតមួលឯទីវត្ត ។*
*អស់កំណើតជាតិទៅហើយ*
*ម្ដេចកន្ដើយមិនជូនទៅ ។*
*ឪផ្ដែផ្ដាំចំណាំទុក*
*ទុក្ខទាំងឡាយរលាយបង់ ។*

ដោយបណ្ឌិត **ថោង ថៃល**

## សុភាសិត

សំដីពេលចេញ
មិនដែលវិលវិញ កាន់អ្នកចរចា ហេតុនេះត្រូវប្រុង
ប្រយ័ត្នអាត្មា កុំអោយចរចា ផ្លូវធ្លោយជាប់កុន ។

ច្បាប់ទូន្មានលោក

# ជាវខាន់ស្លា

រៀបរៀងដោយ **យក់ គុណា**

ក.ភ.ន.. អត្ថបទកំណាព្យជាវខាន់ស្លានេះ កវីនិពន្ធបានលើកយកពាក្យសាមុត្ត ( តាំងពីនិយាយ សើរើសេចក្ដីទុក្ខ ) របស់មាតាទាំងឡាយមករៀបរាប់ប្រាប់កុលបុត្តកុលធីតាស្ដាប់ ដើម្បីអប់រំ និងពិចារណា, មិនវែងណាស់ណាទេ, ដូចតទៅនេះគឺ :

*កូនមាសម្ដាយអើយកូនដឹងទេ*
*មាសមេធំហើយណ៎ះកូនណ៎ា*
*ពេញរូបពេញរាងសមសោភា*
*ស្ងួនភ្ងាសក្ដិសមជាកូនស្រី ។*
*ទំរាំកូនធំបានប៉ុណ្ណេះ*
*ខ្លួនម្ដាយខំរិះច្រើនឥតបី*
*ព្រមទាំងឪពុកទុក្ខច្រើនក្រៃ*
*យប់ក្ដីថ្ងៃក្ដីឥតស្រាកស្រាន្ត ។*
*ពេលកូនមកយោនយកកំណើត*
*រូបម្ដាយកកើតញ័រពេញប្រាណ*
*ផ្ដុំជាយណាយទឹកផឹកមិនបាន*
*ចំណីវែងឃ្លានគ្មានកម្លាំង ។*
*រហិតរហៃអស់ដៃជើង*
*ក្រោកមិនចង់ឡើងដូចអ្វីរាំង*
*មើលមិនចង់ឃើញភ្នែកស្រវាំង*
*ហាក់មានអ្វីបាំងស្ទើរគ្រប់គ្រា ។*
*ក្នុងពោះរមួលជ្រួលពេញផ្ទៃ*
*ហៅហត់ខ្លាំងក្រៃដៃស្រវ៉ា*
*ពោងក្អួតចង្អោរចេញទឹកថ្លា*
*អាហារដាក់ចូលលេបមិនបាន ។*
*ត្រចៀកម្ដាយហ៊ឹងពិបាកស្ដាប់*
*សូរស័ព្ទលាន់ឮមករំខាន*
*គេនិយាយមកស្ដាប់មិនបាន*
*វិញ្ញាណទាំងឡាយប្រែប្រួលអស់ ។*
*ក្លិនខ្លះស្រួបទៅមានកម្លាំង*
*ក្លិនខ្លះប្រឆាំងមិនត្រូវសោះ*
*គ្រាន់តែធុំក្លិនកូរក្នុងពោះ*
*ចង្អោរចេញអស់គ្មានសល់អ្វី ។*

ពេលខ្លះម៉ែឃ្លានសឹងដាច់ខ្យល់
ឪកូនខ្វាយខ្វល់រកអោយផឹ
គ្មានប្រាក់សុខចិត្តរកបុលខ្ចី
ពេលបានចំណីត្អូរអនិច្ចា ។
រស់ក្នុងមាត់ម៉ែប្រែប្រហាត
អណ្តាតបាត់ជាតិអស់ទៅណា
ព្រោះមានជ្រាំងជ្រៀតឆ្មៀបឈើផ្សា
ដាក់ដល់កាលណាពើតញ័រសាច់ ។
អស់ពេលបីខែកន្លងទៅ
ម្តាយវែងមួម៉ោមិនដែលដាច់
ឃើញគេមកជិតចង់តែគេច
បំភ្លេចចៀសចេញទៅអោយឆ្ងាយ ។
ចូលខែទីបួនខ្លួនបានធូរ
ចង់តែហូបមួរជំនួសបាយ
ចង់ហើយសែនចង់ពេលឃើញស្វាយ
ចង់តែប្រញាយមកញាត់មាត់ ។
ស្វាយខ្ចីកន្ដុតខ្ចិតអំពិល
ញាំមិនចេះខ្ពិលគ្មានជូរចត់
ជូរណាស់ឆ្ងាញ់ណាស់យ៉ាងប្រាកដ
ទោះបីគេឃាត់ក៏លបផឹ ។
កូនអើយពេលនេះពិបាកផ្សេង
ម៉ែអ៊ឹំគាត់តែងប្រដៅស្តី
អោយប្រុងប្រយ័ត្នរឿងចំណី
ញាំអ្វីអោយរើសបានល្អជា ។
ចំណីណាហិរកូនត្រូវចៀស
ជូរចត់រវៀសកុំភ្លក្សវា
ប្រែពេកផ្អែមពេកក៏ដូចគ្នា
ស្លូនភ្ជាកូនត្រូវតែខំតម ។
ទោះដេកទោះដើរកុំចំអៀក
ទោះបីពាក់ស្លៀកត្រូវតែថ្នម
កុំតឹងរឹតរួតត្រូវអោយល្មម
ទោះសមមិនសមក៏ហីចុះ ។
ពេលក្តៅមិនសូវហ៊ានងូតទឹក
ផ្សិតម៉ែរំលឹកមិនអោយខុស
ស៊ូតែពីទ្រាំទោះក្តៅស្អុះ
ងូតពេលយប់នោះហាមដាច់ខាត ។
ពិបាកទ្រាំណាស់កូនមាសម្តាយ
រកស៊ីជិតឆ្ងាយតែងសង្ខាត
តែដល់ពេលនេះលែងហ៊ានឃ្លាត
ចេញឆ្ងាយពីញាតិមិត្តផងគ្នា ។
ហាមតោងហាមទាញហាមយួកយាក់
ហាមលោតហាមធ្លាក់ក្រែងពុំជា
កើតក្តីសៅហ្មងដល់អាត្មា
ព្រោះកាចគ្រោះជានាំអាសន្ន ។

ម៉ែខំផ្ទមខ្លួនខ្លាចកូនឈឺ ផ្ទមផ្ទៃមោះគឺអាណិតកូន
កូនរើម្តងៗរមួលខ្លួន ឈឺផ្ទៃផ្ទួនៗពិបាកណាស់ ។
ចាស់ខែពោះម៉ែកាន់តែធំ ដៃឱបមិនជុំលែងរហ័ស
ចង់ងើបម្តងៗពោងតេះតះ ណាកូនបំរះពេញទាំងផ្ទៃ ។
ដេកដើរអង្គុយក៏ពិបាក រយីករយាកអស់ជើងដៃ
ទៅណាមកណាយោងតែផ្ទៃ យ៉ាប់យ៉ឺនខ្លាំងក្រៃគួរនឿយណាយ ។
ស៊ូទ្រាំអើយទ្រាំខំពុះពារ ទោះយ៉ាប់យ៉ាងណាក៏ទ្រូងម្តាយ
ខំប្រឹងប្រយ័ត្នមិនរសាយ ទ្រស្តាយពោះជាប់ចិត្តតស៊ូ ។
ថ្បិតម្តាយដឹងថាដល់ខែគ្រប់ ប្រាំបួនខែដប់ថ្ងៃមិនយូរ
គង់បានឃើញកូនម្តាយនឹងធូរ ញាតិមកឆ្លូរអោយពរជ័យ ។
លុះដល់គ្រប់ខែម៉ែឈឺពោះ ឈឺឆ្មៀបគ្មានឈោះណាអ្នកថ្លៃ
ឈឺហើយឈឺទៀតញ័រជើងដៃ ប្រឹងសព្វសរសៃស្រយុតប្រាណ ។
ឈឺណាស់ឈឺខ្លាំងហើយស្រាកវិញ ទុក្ខម្នោទោម្នេញពេញរំខាន
ដេកក៏មិនកើតស៊ីមិនបាន ឈឺស្ទើរក្ស័យប្រាណលំបាកក្រៃ ។
គេអោយម៉ែដើរពោងតិចៗ ដើរអោយវាភ្លេចកុំអោយភ័យ
បងប្អូនមកជុំជួយចាប់ដៃ ដោយក្តីអាល័យហើយអាណិត ។
ឈឺស្រាកស្រាកឈឺពេញមួយយប់ ថ្ងៃឡើងម៉ោងដប់ឈឺខ្លាំងពិត
ពេលនេះសឹងតែដាច់ជីវិត ញាតិមិត្តគ្រាហ៍ម៉ែដាក់លើគ្រែ ។
ម្តាយភ័យញ័រខ្លាចរកប្រៀបគ្មាន វិញ្ញាណរត់ជាត់ពីខ្លួនម៉ែ
កូនអើយពាក្យថាឆ្លងទន្លេ មិនមែនលេងទេពេលខ្យល់ព្យុះ ។
យាយម៉បចាស់ទុំកាន់ដៃជើង ជួយយើងអោយបានរួចរដោះ
ម៉ែឮកូនយំសែនពីរោះ កូនស្រែកវ៉ានោះម៉ែសប្បាយ ។

កម្លាំងបាក់ដូចវិលមកវិញ ចូលមកបំពេញសព្វរាងកាយ
យាយម៉ុបលើកកូនបង្ហាញម្តាយ ម៉ែតែនរិករាយអ្វីម្លេះទេ ។
បន្តិចក្រោយមកម៉ែហៅបាត់ រកបាហើបមាត់មិនរួចដែរ
បាត់មាត់បាត់កភ្នែកឡើងស្រែ ស្រវាំងហើយម៉ែបាក់និទ្រា ។
លុះដល់នឹងខ្លួនឡើងមកវិញ បងប្អូនមកពេញឈរត្រៀបត្រា
ម្តាយបែរមើលមុខគេគ្រប់គ្នា បាត្តតោងស្រវាត្រេកអរណាស់ ។
បាក់មានជីវិតសាជាថ្មី ព្រោះដ៏ត្រអ្វីៗបានប្រែផ្លាស់
កូនកើតមកជានរូបល្អណាស់ ឈើបាត់ស្រឡះពីក្នុងប្រាណ ។
បីថ្ងៃម្តាយនៅដេកអាំងភ្លើង ស៊ាំដៃស៊ាំជើងលើចង្ក្រាន
ចាក់ថ្នាំផឹងថ្នាំខ្មែរបូរាណ ម្តាយក៏ស្រាកស្រានចេញទឹកដោះ ។
ពេលនេះចាស់ក្មេងមកមើលជុំ យាយតាម៉ុងអ៊ិមកទាំងអស់
ថ្ងៃបង្កក់ឆ្មបប្រកបឈ្មោះ ពេលនោះគេដាក់នាមអោយកូន ។
ម្តាយលើកកូនបីដាក់លើភ្លៅ សម្លឹងមុខពៅកែវមាសស្ងួន
នាងល្អម្លេះទេអោយស្រលូន មុខកូនក្រហាមស្រស់ប៉ប្រៃ ។
សក់ឡើងខ្មៅស្រិលដូចភ្ញមរី ភ្នែកខ្មៅទាំងពីរដូចត្បូងថ្ងៃ
ថ្ពាល់ខួចសងខាងគួរភិសម័យ មាសថ្លៃម្តាយពេញចិត្តខ្លាំងណាស់ ។
កូនពត់ដៃជើងហើយស្រែកខ្លាំង ឮសូរង៉ាំងៗពេញទាំងផ្ទះ
ចាស់ទុំនៅក្បែរស្រែករហ័ស កូនច្បាស់គ្មានបៅហើយពុំងា ។
ម៉ែបែរមើលមុខអស់មីងអ៊ំ ដែលអង្គុយជុំទាំងអស់គ្នា
ម៉ែក៏សើយអាវអោយស្ងួនភ្ញា តែក្នុងចិន្តាអៀនអន់ក្រៃ ។
តាំងតែពីម៉ែមានដុះដោះ គ្មានគេឃើញសោះទោះយប់ថ្ងៃ
ឥឡូវបើកកេរ្តិ៍ម៉ែហើយថ្លៃ ដោយសារចរណៃកូនមាសម្តាយ ។

កូនស្រីធំធាត់ថ្លោសទ្រលុក
ឪកូនចេញរកស៊ីជិតឆ្ងាយ
ទាំងយប់ទាំងថ្ងៃម្ដាយមិនធ្វេស
ខ្លាចក្រែងស្រមោច ឬសង្ការ
ម្ដាយតមខ្លាចទាស់ឈើដល់កូន
ថ្នាក់ថ្នមគ្រប់យ៉ាងជាប្រក្រតី
កូនមុំមចាស់ខែម៉ែសប្បាយ
ម្ដាយបីចេញដើរទៅក្រៅផ្ទះ
ពុកម៉ែឥតដែលប្រកាន់ខឹង
ទោះបីកូនស្រីស្រែកជិទាល
រាល់ពេលកូនជុះនោមដាក់ម៉ែ
ទឹកនោមលាមកជោកកាយា
កូនសើចឬយំម៉ែពីរោះ
គ្រាន់តែបែកឆ្ងាយកូនបន្តិច
ចិត្តម៉ែជាប់តែនឹងរូបកូន
បេះដូងម៉ែចេញយកទៅជាត់
ពេលបានចំណីអ្វីបន្តិច
ម៉ែតែងវេចខ្ចប់គ្រប់វេលា
ម៉ែឪសុខចិត្តអត់មាត់ឯង
ចំណីដល់មាត់កែវកល្យាណ
ពាំងតែពីតូចរហូតធំ
គិតគូរតរហូតពុំមិនភ្លេចឡ

ម្ដាយផៃដាក់ទុកគ្មាននឿយណាយ
រូបម្ដាយនៅអាយផៃរក្សា ។
ថ្លោះធ្លោយប្រហែសទេជីវ៉ា
ទិចខាំឈើផ្សាដល់កូនស្រី ។
ម្ដាយស្រឡាញ់ខ្លួនស្លួនចំណី
មិនដែលហ៊ានធីអ្វីផ្ដេសផ្ដាស ។
ធូរចិត្តធូរកាយប្រាកដណាស់
បូរបរិយាកាសអោយធូរស្រាល ។
ចាប់ទោសអ្វីនឹងស្រស់ត្រកាល
យំឮពេញវាលក៏មិនថា ។
ម្ដាយនៅតែផៃឥតវាចា
នៅតែករុណាកូនជានិច្ច ។
មេត្តាស្ម័គ្រស្មោះបាក់ដូចពេជ្រ
ម៉ែដូចគេភ្ជិចទងប្រមាត់ ។
ពេលដែលឃ្លាតខ្លួនដូចគេកាត់
ម៉ែមិនចង់ព្រាត់មួយពេលណា ។
ម្ដាយមិនដែលភ្លេចស្រស់ពុំងា
ផ្ញើស្រស់ជីវ៉ាមិនដែលខាន ។
ស៊ូរងចំបែងអោយតែបាន
ខ្លាចក្រែងកូនឃ្លានមើលមុខគេ ។
មាសមុំមម៉ែឪតែងគិតគូរ
ថ្នាក់ថ្នមខំផែមិនអោយហ្មង ។

ផ្តត់ផ្តង់ជាយទឹកនឹងស្លៀកពាក់
មោសប្រាក់តិចតួចមិនអោយឆ្គង
ប្រដៅដេរស្តីអោយបានបទ
អោយមានឥរិយារក្សាកាយ
កូនគួរស្តាប់បានហើយកូនស្រី
កម្លាំងម៉ែឪដែលអាណិត
កូនបានបែបបទដូចបំណង
ជីវិតកូនស្រីបានភ្លឺថ្លា
• ពេលនេះម៉ោងនេះកូនមាសស្ងួន
ចូរកូនត្រងត្រាប់សព្វសេចក្តី
តម្លៃថ្លៃខ្លួនកូនខ្ពស់ណាស់
ថ្លៃកេរ្តិ៍ថ្លៃកាយថ្លៃស្ងួនត្រង
ម៉ែកាត់ថ្លៃខ្ពស់អោយទៅគេ
ចូរកូនទទួលដាក់ពីលើ
កាត់ថ្លៃទឹកដោះអោយអស់ចិត្ត
កាត់ចំពោះមុខប្រាប់ដូនតា
ម៉ែកាត់ថ្លៃតាមប្រពៃណី
ចូរកូនមាសម្តាយកូនកុំខឹង
លុះដល់ពេលកូនបានទៅគេ
អោយបានខ្ពង់ខ្ពស់ក្នុងសង្គម

មិនអោយអន់អាក់ពេលណាម្តង
ខ្លាចខ្មាសញាតិផងគេពេបជ្រាយ ។
ខ្លាចក្រែកូនភ្លាត់នាំអន្តរាយ
អោយញាតិជិតឆ្ងាយគេពេញចិត្ត ។
កូនស្រស់ពីសីគួរកូនគិត
ចងចិត្តលើកូននោះប៉ុនណា ។
ដែលម៉ែឪប៉ងហើយជីវ៉ា
ដូចម៉ែប្រាថ្នាហើយកូនស្រី ។
ម៉ែកាត់ថ្លៃខ្លួនហើយពិសី
កូនស្រីចូរនាងខំចាំចង ។
ខ្ពស់ជាងថ្លៃផ្ទះក្បឿងបីខ្នង
មាសពេជ្រកែវកងក៏មិនស្មើ ។
កូនស្រីមាសមេកុំស្ទាក់ស្ទើរ
សិរីសាប្រសើរណា៎កូនណា៎ ។
កាត់ថ្លៃអោយពិតជាវខាន់ស្លា
មីងមាបងប្អូនអោយបានដឹង ។
ដែលមានតាំងពីដើមមកហ្នឹង
កូនខំពង្រឹងចិត្តអោយមាំ ។
កូនរក្សាកេរ្តិ៍អោយឧត្តម
គឺកែវនាងកុំភ្លេចច្បាប់ស្រី ។

*

# គ្រឿងផ្សំសម្រាប់ស៊ីស្លា [១]

អត្ថបទ ស្តីពី « គ្រឿងផ្សំសម្រាប់ស៊ីស្លា » នឹងបានរួមចំណែកដល់ការយល់ដឹង មិនត្រឹមតែសំរាប់យុវវ័យជំនាន់នេះប៉ុណ្ណោះទេ ប៉ុន្តែ អត្ថបទនេះក៏ជាឯកសារស្រាវជ្រាវមួយ សំរាប់មនុស្សជំនាន់ក្រោយៗ ផងដែរ ។

ខ្មែរយើងចេះទទួលមានស្លា តាំងពីសម័យបុរេប្រវត្តិមកម្ល៉េះ ។ ដោយផ្អែកលើអត្ថបទសិលាចារឹកជាច្រើននៅមុនសម័យអង្គរ គេអាចសន្និដ្ឋានបានថា ព្រះមហាក្សត្រ, វរជន, ឥស្សរជន, អភិជន ដែលមានសទ្ធាជ្រះថ្លាចំពោះអាទិទេពក្នុងព្រហ្មញ្ញសាសនា ទ្រង់បានធ្វើព្រះរាជអំណោយ និងធ្វើអំណោយចំពោះប្រាសាទនានា ដែលជាបូជនីយដ្ឋានពិសិដ្ឋ នូវចម្ការដូង ចម្ការស្លា ស្រែ ព្រៃ បឹងបួរ គោ ក្របី ខ្ញុំបំរើ ។ ល ។ ការដែលគេប្រទះឃើញចម្ការស្លា នៅតាមប្រាសាទ តាមលំនៅភូមិខ្មែរ (*) នោះបញ្ជាក់អោយដឹងថា ដំណាំស្លា ពិតជាមានប្រយោជន៍សំខាន់ ដល់ការទ្រទ្រង់ជីវភាព និងសេដ្ឋកិច្ចរបស់ខ្មែរ ។

ស្លា ជាដំណាំមួយប្រភេទ ដើមមូលស្រលូតត្រង់ ផ្លែរាងមូលពងក្រពើប៉ុនៗមេជើងមានរសជាតិចត់ ប្រើការផ្សំជាមួយនឹងម្លូបៀកស៊ីស្លាជាគ្រឿងរំងាប់ក្លិនមាត់ ។ ប្រពៃណីស៊ីស្លាមិនមែនមានតែជនជាតិ ខ្មែរយើងប៉ុណ្ណោះទេ សូម្បីជាតិសាសន៍ផ្សេងៗនៅតំបន់អាស៊ីដូចជា ឥណ្ឌា យួន លាវ សៀម ឥណ្ឌូនេស៊ី ភូមា ម៉ាឡេស៊ី ... ក៏និយមស៊ីស្លាដែរ ។ ប៉ុន្តែ មកដល់សម័យនេះ ចំណូលចិត្ត និងទម្លាប់

---

(១) មិនមែនន័យថា ស៊ីតែស្លាឬម្លូតែមុខនោះទេ ប៉ុន្តែត្រូវមានវត្ថុផ្សំដទៃទៀតជាច្រើន

(*) ដំណាំដូង-ស្លា ដុះព័ទ្ធជិតជុំភូមិខ្មែរ បង្កើតបានជាទេសភាពដ៏ល្អស្រស់ គួរអោយចាប់អារម្មណ៍ ។ គេតែងតែថា ការមើលឃើញចុងដូង ចុងស្លា នោះគឺជាភូមិខ្មែរ ឬវត្តខ្មែរ ។

ស៊ីស្លាបានថយចុះស្ទើរតែចង់អស់ពីសង្គមខ្មែរទៅហើយ, ឃើញនៅមានតែចាស់ៗខ្លះប៉ុណ្ណោះ ។

ពាក្យថា « ស៊ីស្លា » ឬ « ស៊ីម្លូ », តាមពិត គេមិនមែនស៊ីតែស្លា ឬស៊ីតែម្លូមួយមុខប៉ុណ្ណោះទេ គឺមានវត្ថុច្រើនមុខទៀតផង ដែលត្រូវយកមកផ្សំ រួមគ្នាបានជាស្លាទំពាមួយម៉ាត់ ។

## ១. របៀបស៊ីស្លា និងគ្រឿងផ្សំ ៖

. ដំបូង គេយកម្លូមួយសន្លឹកពីក្នុងប្រអប់ស្លា មកលាតជូតឱ្យជ្រះផង់ធូលីចេញ, ក្តិចចុងកន្ទុយស្លឹកចោល[១] រួចទើបហែកច្រៀក[២] ស្លឹកម្លូតាមបណ្តោយសន្លឹកមួយភាគចេញ ហើយយកភាគនៃចម្រៀកនេះមកត្រួតផ្គាប់លើសន្លឹកមួយភាគធំនោះ ។ បន្ទាប់មក គេយកអកកំបោរ ( ស្ពាន់ ឬសំរិទ្ធ ) មកបើកគម្របគៀបនឹងម្រាមដៃឆ្វេងដែលកាន់ស្លឹកម្លូនោះ ហើយយកចង្កឹះមកឆ្កៀលយកកំបោរពីក្នុងអកកំបោរ មកបៀកលើស្លឹកម្លូអោយល្មម មិនច្រើនពេក ឬតិចពេក ។

. យកស្លាចំណិត ( ស្លាក្រៀម ) ឬស្លាខ្ចី មកឆាកនឹងប្រណាកឱ្យបែកជាពីរ-បី បំណែក ដាក់លើស្លឹកម្លូដែលទើបបៀកកំបោរហើយ ។ ស្លាចំណិត ឬស្លាខ្ចី គេចង់យកមួយណាក៏បាន ។ ប៉ុន្តែ ជាទូទៅ គេចូលចិត្តស្លាខ្ចីជាង ។

. យកស្លាជាប៉ុនចុងចង្កឹះ ពីឡុតមួយនៃប្រអប់ស្លា និងកាត់យកមើមប្រស់ខ្ចីល្មម[៣] ប៉ុនចុងកូនដៃ ដាក់លើស្លឹកម្លូបៀក រួចបត់ញាត់ស្លឹកម្លូបៀកនោះ

---

(១) ដោយជឿតាមរឿងព្រេងបុរាណថា មានពស់វែកមួយខ្ទាក់ពិសដាក់ត្រង់ចុងកន្ទុយស្លឹកម្លូ ហេតុនេះ គេត្រូវក្តិចផ្នែកនេះចោល ចៀសវាងការពុលដោយជាតិពិសពស់ ។ គេមិនស៊ីស្លា ឬម្លូលេបចូលទៅក្នុងពោះ ដូចចំណីឯទៀតទេ, គេគ្រាន់តែទំពាអោយម៉ដ្ឋ - ស្តោះទឹកមាត់រហូតដល់សាបជាតិស្លាម្លូ ទើបខ្ទាក់កាកស្លាចោលតែម្តង ។ (២) ពាក្យចាស់ពោលទុកមកថា « ស្លាម្លូស៊ីឱ្យច្រៀក កុំបីបៀកទាំងចូលមិញ តូចធំឱ្យច្រៀកចេញ តាមពាក្យចាស់ថាអភព្វ ។ (៣)មើមនេះដាក់សម្រាប់ធ្វើឱ្យក្រហមមាត់ ។

បញ្ចូលគ្នា បានជាកញ្ចប់តូចមួយធំជាងមេដៃ រួចដាក់ទំពាក្នុងមាត់ រហូតដល់សាបជាតិស្លាម្លូ ទើបខ្ជាក់ចោល ។ ឯទឹកមាត់ មានពណ៌ក្រហមស្រស់ដូចឈាម ។

បើអ្នកស៊ីគ្មានធ្មេញទំពា គេយកកញ្ចប់ម្លូនោះញាត់ទៅក្នុងល្បុក ( ត្បាល់បុកស្លា ) រួចយកអង្រែដែកមានចុងសំប៉ែតមកបុកជ្រិទាល់តែម៉ដ្ឋ ទើបយកចុងអង្រែល្បុកនោះទៅបុករុញឆ្នុកពិត្ធទល្បុក ដើម្បីបញ្ចេញស្លាបុកម៉ដ្ឋមកមាត់ល្បុកខាងលើ ដែលអ្នកស៊ីបាមាត់ចាំត្រងយក រួចទំពាទាល់តែសព្វ ។ មានគ្រឿងផ្សំមួយមុខទៀត នោះគឺថ្នាំ ។ គេចាប់បោចថ្នាំពីឡូតមួយនៃប្រអប់ស្លា រួចឆ្នួលលញ់ឱ្យមូល ដាកញីទៅលើធ្មេញលើ ទៅឆ្វេង ទៅស្ដាំ រួចសៀតចន្លោះបបូរមាត់លើផ្ទប់នឹងធ្មេញ ។ បបូរមាត់ត្រង់កន្លែងចុកថ្នាំ បះស្មើញឡើង មិនរាបស្មើតាមប្រក្រតីឡើយ ។ អ្នកខ្លះចុកតែថ្នាំ មិនចាំបាច់ស៊ីស្លាទេ ។ គេចុកទល់ទុកនៅលើជើងធ្មេញ រហូតទាល់តែសាបជាតិថ្នាំ ទើបខ្ជាក់ចោល ។ ក្នុងពេលរវល់ការងារ, អ្នកចុកថ្នាំខ្លះ ខ្ជាក់យកកញ្ចុកថ្នាំមកសៀតត្រចៀកទុកយ៉ាងទំនង ដល់ពេលចប់ការងារ ទើបយកមកចុកជាថ្មីទៀត ។

## ២. ស្លាថ្នាត់ :

គឺម្លូដែលបៀកបត់ញាត់បញ្ចូលមុខក្នុងស្រទាប់ ( មានគ្រឿងផ្សំគ្រប់មុខផង ) ។ កាលពីដើម ខ្មែរយើងទាំងប្រុស ទាំងស្រី និយមស្លាថ្នាត់នេះណាស់ ។ បើស្រីក្រមុំណាស្មគ្រចិត្តស្រឡាញ់ប្រុសណាម្នាក់ជាគូអនាគត ស្រីក្រមុំនោះតែងជូនស្លាថ្នាត់ទៅប្រុសសំណព្វចិត្តនោះទុកជាកិច្ចបញ្ចាំចិត្ត និងជាសក្ខីកម្មនៃទឹកចិត្តស្នេហា ។ ពេលស្រីក្រមុំនោះហុចស្លាថ្នាត់ជូន, អ្នកកំលោះនោះ ក៏ទទួលយកបៀមទំពាភ្លាម ដើម្បីបញ្ជាក់អំពីទឹកចិត្តស្មោះស្ម័គ្រចំពោះនាងជាគូស្នេហ៍ ។

ចំណងទាក់ទងគ្នាដោយស្លាម្លូនេះ ខ្មែរយើងមានបទចម្រៀងប្រជាប្រិយមួយ, គេច្រៀងរាយទំនុកឆ្លោះឆ្លងគ្នា ដូចតទៅនេះថា :

- ប្រុស ៖ *បងសុំស្លាស្រី ស្រីថាស្លាគ្មាន បងចាប់ដៃបាន ស្លាពេញទាំងថ្នក់ ។*
- ស្រី ៖ *អូនឆ្លើយថាគ្មាន បងថាកុហក ស្លាពេញទាំងថ្នក់ បញ្ញើគេទេ ។*
- ប្រុស ៖ *ត្រង់ស្លាត្រង់ម្លូ អូនថាបញ្ញើ ត្រង់ខ្លួនស្រីតើ បញ្ញើអ្នកណា ?*
- ស្រី ៖ *ត្រង់ស្លាត្រង់ម្លូ អូនជូនបងបាន ចំណែកខ្លួនប្រាណ មិនបានទេបង ។*

មានបទមួយទៀត ប្រុសច្រៀងប្រាប់ទៅស្រីថា ៖ « *បើស្រីចោលចាប ចោលនឹងដំបង បើស្រីចោលបង ចោលនឹងស្លាថ្នាត់ ចោលនឹងស្លាម្លូ ខាតចូលព្រៃបាត់ ចោលនឹងស្លាថ្នាត់ ធ្លាក់ដល់ដៃបង* » ។

ស្លាថ្នាត់នេះ គេច្រើនយកអំបោះក្រហមមកចង ដើម្បីកុំអោយរលារបូតជ្រុះគ្រឿងផ្សំនៅខាងក្នុង ។ កាលណាចងអំបោះបែបនេះ គេហៅថា ស្លាចង ឬស្លាជីប ម្លូជីប ។ ស្លាជីប ម្លូជីប ឬស្លាចងនេះ ច្រើនតែគូគ្នានឹងបារីចង ។ បារីចងគេយកសរសៃថ្នាំមកមូរជាមួយនឹងស្លឹកសង្កែ ខាងមុខរីកធំ ខាងកន្ទុយរៀវស្ដួច រួចយកអំបោះក្រហម ឬស មកចងរុំបារីស្លឹកសង្កែ កុំឱ្យសរសៃថ្នាំជ្រុះចេញពីរមូរបារីនោះ ។ ជួនកាល បើស្ត្រីនោះចង់អោយបារីចងរបស់ខ្លួន មានគុណភាពពិសេសឡើងទៀតនោះ គេយកស្លឹកពោធិ៍ក្រអូប ( បាលស្លូត ) មកមូរថ្នាំ ។ កាលណាបុរសគូស្នេហ៍ជក់បារីនោះទៅ មានផ្សែងចោលក្លិនក្រអូបភាយទៅប៉ះច្រមុះអ្នកជិត

(១) រមូរថ្នាំ ដែលគេរញ់អោយចូលក្នុងខ្ទុកនេះ ហៅថា គ្រាប់ថ្នាំ, កញ្ចុកថ្នាំ ឬថ្នាំបូរខ្ទុក ។ ចាស់ៗបាននិយាយពាក្យចំអន់លេងប្រាប់ក្មេងៗថា នៅពេលស្រុកកើតកើតខ្ទុក, កញ្ចុកថ្នាំ ឬថ្នាំ បូរខ្ទុក បានតម្លៃខ្ពស់ណាស់, ស្មើនឹងស្រីក្រមុំ ៩ នាក់ ៖ « ក្រមុំប្រាំ ថ្នាំបូរខ្ទុក » គឺក្រមុំ ៩ នាក់ ដូរបានថ្នាំបូរខ្ទុក ។

ខាងនាំឱ្យកើតអារម្មណ៍រីករាយ ។ ស្ត្រីក្រមុំដែលមានចិត្តស្មោះស្ម័គ្រមេត្រី ច្រើនជូនទាំងស្លាចង បារីចង ចំពោះបុរសជាគូស្នេហ៍របស់ខ្លួន ។

## ៣- របៀបធ្វើ ស្លាកាត់ ឬស្លាក្រក ៈ

គេជ្រើសយកផ្លែស្លាខ្ចី ដែលបកសំបកចេញ រួចកាត់ទទឹងជាកង់ស្តើងៗ ហើយហាលឱ្យស្ងួតក្រៀម, ឬផ្លែស្លាចំណាស់ល្មម មិនខ្ចីពេក មិនចាស់ពេក យកទៅស្ងោរអោយឆ្អិនត្រឹមត្រូវ រួចទើបស្រង់យកមកទុកឱ្យត្រជាក់ ហើយពុះយកគ្រាប់ស្លាចេញពីសំបក ។ គ្រាប់ស្លាស្ងោរ ត្រូវបានហាន់ជាចំណិតស្តើងៗ យកទៅរាយហាលលើចង្អេរ ឬលើកន្ទេល រហូតទាល់តែស្ងួតក្រៀមល្អ ទើបសាយកមកច្រកទុកក្នុងបាវ ឬការុង ។ អ្នកស៊ីស្លា ពេញចិត្តនឹងស្លាស្ងោរជាងស្លាឆៅ ។ នៅពេលរៀបស៊ីស្លា, គេយកស្លាកាត់ ឬស្លាក្រក ត្រាំទឹកក្នុងពែង ឬត្រឡោកអោយទន់ស្រួលទំពា ។ ស្លាកាត់ មានដាក់លក់នៅគ្រប់ទីផ្សារធំ-តូច ទូទាំងប្រទេស ។ ស្លាស្រស់ខ្ចី និងស្លាក្រក ជាមុខរបរមួយយ៉ាងសំខាន់ផងដែរ នៅទីផ្សារក្នុងស្រុក និងនាំទៅលក់នៅប្រទេសជិតខាង ។

## ៤- ស្លាជ្វា [១]

ស្លាជ្វា ជាដុំជ័រខាប់ស្អិតរឹង សម្បុរខ្មៅ រសល្វីង កើតអំពីការរំងាស់ស្លឹកជ្រៃក្រឹម ឬសំបកឈើមួយប្រភេទ ( ហៅដើម ស្លាជា ដែរ ) ស្លឹកស្រដៀងនឹងពពេលសំរាប់ប្រើការផ្សំនឹងកំបោរបៀកម្លូស៊ីស្លា ។

របៀបធ្វើស្លាជ្វា, ជាដំបូង ផលិតករកាប់មែកជ្រៃក្រឹមបេះយកតែស្លឹកមករំងាស់ក្នុងខ្ទះធំ ។ រយៈពេលប្រមាណជាពីរ ឬបីម៉ោងក្រោយមក ទឹករំងាស់ស្លឹកជ្រៃក្រឹម ចាប់ផ្តើមស្រកយ៉ាងច្រើន ហើយក្លាយទៅជាជ័រខាប់ស្អិត ពណ៌ស្វូកឡា

(១) ស្លាជ្វា ហៅតាមអក្សរគ្រាប់ថា « សាច់ជ្វា » ឬ « រាជជ្វា » ។

ក្រមៅ ។ នៅពេលនោះ គេយកកន្ទក់ដែលរែងទទាក់យ៉ាងម៉ដ្ឋទៅចាក់កូរលាយជាមួយទឹកជ័រខាប់ស្អិតនោះ ។ គេចេះតែកូររិត ដោយបន្ថយភ្លើងចង្ក្រានឱ្យនៅតែរងើក ដើម្បីបន្ថយកំដៅឱ្យនៅតិចល្មម ។ គេយកទឹកខាប់ស្អិតនេះទៅចាក់វាចនៅលើចង្អេរ ឬលើកន្ទេល សំដិលហាលខ្យល់ក្នុងម្លប់ឱ្យត្រជាក់ និងឱ្យកករឹង ។ មុនពេលជ័រមិនទាន់រឹង គេយកចុងកាំបិតមកឆូតខ្វែងជាក្រឡាចត្រង្គ ដែលមានប្រវែង ២៥ មិលីម៉ែត្រ ក្នុងមួយជ្រុង កើតបានជាដុំរាងតូបពណ៌ក្រមៅ មានរសល្វីងចត់ ។ នេះហើយគឺជាដុំស្លាជ្វា ។ ដុំស្លាជ្វាត្រូវបានច្រកទុកក្នុងស្មុក ឬល្អី សំរាប់យកទៅលក់ឱ្យឈ្មួញនៅផ្សារ ឬលក់ឱ្យអតិថិជនក្នុងភូមិជាមួយ ។

ក្នុងន័យបម្រើសេចក្តីត្រូវការរបស់អ្នកនិយមស៊ីស្លា, កំបោរ ស្លា ម្លូ ស្លាជ្វា ថ្នាំ ត្រូវបានគេដាក់លក់យ៉ាងសម្បូរនៅគ្រប់ទីផ្សារ តាំងពីក្រុងធំៗ រហូតដល់ផ្សារផ្សេងនៅតាមជនបទ ។ អ្នកនៅតាមជនបទខ្លះៗ បានឆ្លៀតធ្វើគ្រឿងផ្សំទាំងនេះជាមុខរបរទ្រទ្រង់គ្រួសារធំបង្គួរ សំរាប់បំពេញសេចក្តីត្រូវការរបស់អ្នកភូមិជាមួយ ឬយកទៅបោះលក់ឱ្យចិននៅទីផ្សារ ។

ម្យ៉ាងទៀត គេកត់សំគាល់ឃើញអ្នកស៊ីស្លានៅជនបទខ្លះ មិនប្រើស្លាជ្វាធ្វើជាគ្រឿងផ្សំទេ គេស្ទោះយកសំបកឈើមានរសចត់ ដូចជា សំបកសុព័រ, ពើត, ពពេល, ជ្រនៀង មកប្រើផ្សំជាមួយម្លូបៀកស៊ីស្លា ។ គេយកបន្ទះសំបកឈើណាមួយដែលហាលស្ងួត មកឆាកបំបែកនឹងប្រណាកជាពីរ ជាបីចំណិតដាក់លាយជាមួយគ្រឿងផ្សំឯទៀតៗ ។ បើក្នុងកាលកាលៈទេសៈខ្លះ ដែលរកម្លូមិនបានអ្នកញៀនស្លា យកស្លឹករុក្ខជាតិផ្សេងៗ មានស្លឹកដកពរ ស្មៅអាចម៍កុក ស្លឹកចាភ្លូ ... មកស៊ីជំនួសស្លឹកម្លូ ។ អ្នកស៊ីស្លាជាទូទៅច្រើនមានធ្មេញខ្មៅ ។

ការស៊ីស្លា ជាអារ្យធម៌មួយរបស់ជនជាតិខ្មែរយើង ។ កាលពីដំនាន់ដើមខ្មែរយើងឱ្យតម្លៃទៅលើអ្នកដែលមានធ្មេញខ្មៅ ជាពិសេស ទៅលើស្ត្រី ។ ស្ត្រីដែល

មានធ្មេញខ្មៅ គេចាត់ទុកជាលំអពិសេសមួយ និងជាសិរីសួស្ដីម្យ៉ាង ។ ក្នុងរឿងកាកី របស់ព្រះបាទអង្គឌួង មានការសរសើរសម្រស់ធ្មេញរបស់នាងកាកីថា « ទន្តាខ្មៅស្រិល ដូចនិលរតនា .. » ។ ធ្មេញខ្មៅអាចបណ្ដាលមកពីការលាបជ័រនៃរុក្ខជាតិម្យ៉ាង ក្រៅពីការស៊ីស្លា ។

នៅសម័យលង្វែក[*] ដែលគេឃើញធ្មេញស្ត្រីក្មេងៗ មានពណ៌ខ្មៅប្រហែលមិនមែនដោយសារការស៊ីស្លាទេ ព្រោះនៅក្នុងសង្គមខ្មែរគ្រប់សម័យ ក្មេងស្រីៗមិនស៊ីស្លាឡើយ ។ តាមការសន្និដ្ឋាន ស្រីក្រមុំដែលមានធ្មេញខ្មៅ នៅជំនាន់នោះ គឺពិជាលាបជ័ររុក្ខជាតិអ្វីម្យ៉ាងនោះហើយ ។ នៅក្នុងពិធីអាពាហ៍ពិពាហ៍ គេឃើញសកម្មភាពមួយគឺ « ធ្វើធ្មេញបំពេញល័ខ » ដោយយកល័ខស្រម៉ទៅស្ងោរឱ្យរលាយចេញជាទឹកពណ៌ក្រហមក្រមៅ ហើយយកសំឡីផ្ដិតយកទឹកល័ខនោះមកជូតធ្មេញឱ្យខ្មៅ ។ តាមពិត ជាតិជ័រល័ខស្រម៉ មិនមានពណ៌ខ្មៅទេ ប៉ុន្តែ ប្រហែលជាគេធ្វើដើម្បីជានិមិត្តរូបប៉ុណ្ណោះ ដោយសន្មតទុកល័ខថាជាវត្ថុដែលផ្ដល់នូវពណ៌ខ្មៅ សមដូចពាក្យថា « ខ្មៅដូចល័ខ » ។

តាមការយល់, ពិធីធ្វើធ្មេញ បំពេញល័ខ ក៏មានន័យរំលឹកឱ្យមនុស្សគ្រប់រូបយកចិត្តទុកដាក់គិតគូរដល់អនាម័យធ្មេញ ព្រោះធ្មេញមានសារសំខាន់ណាស់សំរាប់សុខភាពរាងកាយ ។

រៀបរៀងដោយ **មៀច ប៉ុណ្ណ**
ការិយាល័យទំនៀមទម្លាប់ខ្មែរ

(*) នៅរវាងដើមស.វ.ទី ២០ ពួកប្អូនវៀត និយមការលាបធ្មេញខ្មៅជាលំអររបស់គេដែរ ។

# អំពីក្បុង

ក្បុងគឺជាសារធាតុម្យ៉ាងបានមកពីការដុតកម្ទេចរុក្ខជាតិ ឬតិណជាតិប្រភេទខ្លះ មានផ្លែត, ដើមផ្ទីជាដើម សំរាប់យកទឹកប្រៃមកប្រើប្រាស់បានច្រើនប្រការ ។ ទឹកប្រៃដែលច្រោះត្រងយកពីក្បុងមកនោះហៅថា ទឹកក្បុង ។ ក្នុងសម័យពីដើម, ខ្មែរប្រើក្រូចសើច, ផ្លែសំបូរកក់, ផ្លែល្វេង, ... ជាគ្រឿងលាងជម្រះដុសសំអាត ។ ប៉ុន្តែទឹកក្បុងមានចំណែកសំខាន់ជាងគេ ក្នុងជីវភាពប្រចាំថ្ងៃរបស់ជនជាតិខ្មែរយើងនៅទីជនបទស្រុកស្រែចំការ ។ នៅពេលសព្វថ្ងៃនេះ ទោះបីមានសាប៊ូប្រើដុះជម្រះបោកលាងឱ្យជ្រះក្អែល ជ្រះមន្ទិលបរិបូណ៌ហើយក្តីក៏គេនៅតែត្រូវការទឹកក្បុងសំរាប់លាងជម្រះដុះសំអាតរបស់ផ្សេងៗ នៅឡើយ ។

រុក្ខជាតិសំខាន់ៗ ដែលអាចយកមកច្នៃធ្វើក្បុងប្រកបដោយគុណភាពខ្ពស់នោះ មានជាអាទិ៍ :

- សំបក និងបណ្តូលផ្លែគទុំ
- ដើមផ្ទីចាស់
- គាវត្នោត និងផ្កាត្នោតញី-ឈ្មោល
- ដើមសង្កែងាប់

១. អំពីការធ្វើក្បុង

ក. ផ្សំដោយសំបក និងបណ្តូលផ្លែគទុំ

ពេលដែលគេបេះបំបែក ឈ្លួចយកសំឡីចេញពីផ្លែគទុំនោះ គេតែងយកចិត្តទុកដាក់រក្សាបណ្តូល និងសំបក ហើយគរវាទុកមួយពំនូក ដើម្បីដុតវាឱ្យឆេះទៅជាផេះ ។

ខ. ផ្សំដោយដើមផ្ដិចាស់

គេកាប់ដើមផ្ដិពេញចំណាស់ ហាលថ្ងៃក្នុងរវាងពី ៥ ទៅ ៧ ថ្ងៃឱ្យទាល់តែស្ងួតក្រៀមល្អ ទើបប្រមូលយកមកគរធ្វើភ្នក់ដុតឱ្យឆេះទៅជាផេះ ។

គ. ផ្សំដោយគាវត្នោត និងផ្កាត្នោតញី-ឈ្មោល

នៅតាមជាយភូមិ ឬទីទួលនៅតាមវាលស្រែ គេដើររើសប្រមូលគាវត្នោត ផ្កាត្នោតញី-ឈ្មោល ដែលធ្លាក់ពោរពាសនៅក្បែរគល់នោះ យកមកគរជាភ្នក់រួចដុតអោយឆេះទៅជាផេះ ។

ឃ. ផ្សំដោយដើមសង្កែងាប់

កាលណាគេប្រទះឃើញដើមសង្កែងាប់ពុក មានប្រហោងខាងក្នុងនោះ គេយកភ្លើងទៅដុតនៅត្រង់គល់វាអោយឆេះជាផេះ រួចគេប្រមូលផេះនោះទុកមួយដុំ ។ ដើម្បីងាយស្រួលក្នុងការផ្ដុំក្បុង គេយកទឹកមកប្រោះទៅលើគំនរផេះទាំងនោះរួចហើយគេពូតប្រមុមផេះដែលផ្សើមដោយទឹកនោះជាដុំ១ប៉ុនផ្លែខ្វិត ។ ដុំក្បុងទាំងនោះត្រូវបានរក្សាទុកក្នុងជាល ឬការុងត្រៀមសំរាប់ប្រើការទៅថ្ងៃក្រោយ (១) ។

២. អំពីការច្រោះត្រងយកទឹកក្បុង

គេយកដុំក្បុងមកច្របាច់ពង្រាយ ហើយដាក់ទៅលើតម្រងមួយធ្វើពីកញ្ជើចាស់ទ្រាប់ក្រណាត់កន្ទេលព្យួរនឹងសង្រែក រួចចាក់ទឹកមួយត្រឡោកទៅលើកាកក្បុង ដោយមានចាននើងធំមួយទុកចាំត្រងពីក្រោម ។ ទឹកក្បុងដែលមានពណ៌ក្រហមថ្លា ស្រក់តក់ៗ មកលើនើង ។ កាលណាគេសង្កេតឃើញថា អស់ទឹកនៅលើតម្រងហើយនោះ គេចាក់ទឹកបន្ថែមដើម្បីឱ្យទឹកក្បុងស្រក់ជាបន្តទៀត ។ កាល

---

(១) ក្បុងដែលបានមកពីផេះនៃរុក្ខជាតិ ឬតិណជាតិដទៃក្រៅពីនេះ ពុំមានគុណភាពល្អឡើយ ព្រោះវាពុំមានជាតិប្រៃគ្រប់គ្រាន់ ។

ណាគេភ្លក្សមើលទៅឃើញថា ទឹកក្បុងសាបបន្តិចហើយនោះ គេច្របាច់ក្បុងពីរ ឬ បីដុំដាក់ទៅលើតម្រង ហើយចាក់ទឹកបន្ថែមដើម្បីរក្សាជាតិក្បុងឱ្យនៅតែប្រៃដូច មុន ។ គេច្រោះរបៀបនេះទាល់តែបានចំណុះទឹកក្បុងល្មម និងអាចយកទៅធ្វើអ្វី បានតាមការគ្រោងទុករបស់គេ ។ ទឹកក្បុងដែលមានគុណភាពល្អ មានពណ៌ក្រហម ក្រមៅ ប្រហែលនឹងពណ៌ទឹកត្រី ហើយថែមទាំងមានរស់ជាតិប្រៃល្មមៗ ។ លុះ ច្រោះបានមកហើយ គេត្រូវយកទៅប្រើការភ្លាម មិនអាចទុកអោយរំលងហួសមួយ យប់ ឬមួយថ្ងៃឡើយ ។

៣ . ប្រយោជន៍នៃទឹកក្បុង

ក. ធ្វើនំចាំង :

តាមទម្លាប់ពីយូរណាស់មកហើយក្តី និងនៅពេលបច្ចុប្បន្ននេះក្តី បងប្អូន ជនជាតិខ្មែរយើងនៅតាមជនបទស្រែចំការប្រើប្រាស់ទឹកក្បុងសំរាប់ជាជំនួយដល់ ការធ្វើនំចាំង ។ គេយកអង្ករដំណើបទៅត្រាំក្នុងទឹកក្បុងក្នុងរយៈពេលមួយយប់ ។ លុះព្រឹកឡើង គេស្រង់អង្ករដំណើបនោះយកមកវេចនឹងស្លឹកផ្អាវស្លឹកត្នោត ស្លឹក ដូង ឬស្លឹកឫស្សីស្រុកចិន ដែលធំកំប៉ាងជាងស្លឹកឫស្សីធម្មតា ។ អង្ករដំណើបដែល ត្រាំនៅក្នុងទឹកក្បុងពេញមួយយប់នោះរីកធំជាងកាលវានៅស្ងួត ហើយបន្ទាប់ពី ស្ងោរឆ្អិនហើយនោះ គ្រាប់អង្ករដំណើបរលាយស្អិតជាប់គ្នា ហើយមានពណ៌ក្រហម ក្រមៅដោយសារជាតិទឹកក្បុងប្រៃ ធ្វើអោយស្លឹកផ្អាវចេញជ័រមកលាយជាមួយនឹង គ្រាប់អង្ករដែលជិតជាប់នឹងស្លឹក ។

ខ. រុំស្រោបពងទាប្រៃ

ក្រោយពីបានត្រាំទឹកអំបិលពេញមួយយប់ហើយ គេស្រង់ពងទាយកមក រុំស្រោបដោយក្បុង ដែលគេបានផ្សើមទឹកបន្តិចៗ ដើម្បីរក្សាទុកបានយូរ ក៏ដូចជា រក្សាការពារវាកុំអោយខូចគុណភាព និងរសជាតិ ។

គ. បោកគក់ជម្រុះសម្លៀកបំពាក់

គេយកសម្លៀកបំពាក់ដែលប្រឡាក់ដោយញើស ឬដោយធូលីទៅត្រាំក្នុងទឹកមួយសន្ទុះអោយរិកក្អែល រួចហើយទើបយកទៅច្របាច់គក់ល្អិតក្នុងទឹកក្បុងដែលជួយកាត់កំចាត់បង់នូវក្អែល និងវត្ថុសៅហ្មងដទៃទៀតបាន ដូចសាប៊ូដែរ ។ ទឹកក្បុងដែលប្រៃខ្លាំងល្អ បង្កើតជាពពុះនៅពេលគេច្របាច់ជ្រិអោយចូលសព្វសាច់ក្រណាត់ ។ លុះដុសញីជម្រុះហើយ គេក៏យកទៅលាងទឹកឱ្យទាល់តែស្អាត ទើបស្រង់ពូតយកទៅហាលថ្ងៃ ជាការស្រេច ។

ឃ. កក់សក់

នៅជនបទស្រុកស្រែចំការក្នុងសម័យបុរាណ មនុស្សប្រុស-ស្រី ក្មេងចាស់ ជាទូទៅ តែងតែប្រើទឹកក្បុងកក់សក់ជម្រុះធូលី និងក្អែល ។ គេយកទឹកក្បុងដែលដាក់ក្នុងត្រឡោក មកចាក់ពីលើសក់ដែលមានផ្សើមដោយទឹកទុកជាមុន ហើយញីញក់សក់អោយបានសព្វ ។ ធ្វើយ៉ាងនេះ គេឃើញមានពពុះបែកចេញសំពោងដូចសាប៊ូដែរ បន្ទាប់ពីនោះ គេយកទឹកមកលាងជម្រុះសក់អោយអស់ជាតិទឹកក្បុង ។ ជាចុងក្រោយ គេកក់សក់ដោយផ្លែក្រូចសើចពេញចំណាស់ ឬទុំ ដើម្បីអោយសក់ទន់ ហើយភ្លឺរលោងផង ។

ង. ប្រមោកសូត្រ

ដូចបានជម្រាបនៅក្នុងអត្ថបទស្តីពីការចិញ្ចឹមដង្កូវនាង (១) សូត្រដែលទើបស្រាវចេញពីសំបុកនាងនោះមានពណ៌លឿងស្រស់ ។ មុននឹងយកទៅត្បាញជាហូល ផាមួង សារុង ក្រម៉ាផ្សេងៗនោះ ជាចាំបាច់គេត្រូវយកសូត្រទៅប្រមោកឱ្យទាល់តែក្លាយទៅជាពណ៌សជាមុនសិន ទើបគេជ្រលក់ឱ្យទៅជាពណ៌ផ្សេងៗ ។ ទោះបីគេត្រូវការសរសៃសូត្រពណ៌លឿងក្តី ក៏គេមិនប្រើរក្សាពណ៌លឿងពីធម្មជាតិ

(១) សូមមើលសៀវភៅកម្រងឯកសារស្តីពីប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ទំព័រ ៣១៦

របស់សូត្រនេះឡើយ ។ គេនៅតែយកសូត្រទៅប្រមោកឱ្យចេញពណ៌លឿងទៅជាស និងដើម្បីអោយសរសៃសូត្រទន់ស្រួលក្នុងការត្បាញរវៃ ។ ដើម្បីប្រមោកសូត្រ គេត្រូវយកសូត្រដែលពាត់កេះយកអាចម៍[១] ចេញស្អាតបាតហើយនោះ ទៅត្រាំទឹកក្បុងដែលដាក់នៅក្នុងថ្លាង ហើយដែលគេយកទៅដាក់ដាំលើភ្លើងចង្ក្រានឱ្យទាល់តែពុះអស់មួយសន្ទុះធំ ទើបគេយកឈើទៅកូរប្រលូលប្រែត្រឡប់សូត្រឱ្យបានសព្វក្នុងរយៈពេលពី ២០ ទៅ ៣០ នាទី ទើបស្រង់សូត្រចេញពីថ្លាង ។ ពេលនោះទឹកក្បុងដែលលាយដោយពណ៌ចេញពីសូត្រនោះ វាឡើងពណ៌លឿងល្អក់ ។ គេស្រង់យកសូត្រទៅលាងទឹកត្រជាក់ឱ្យអស់ជាតិក្បុង ដោយគក់ច្របាច់ជ្រឺអោយចេញពណ៌កំណើតអស់ រួចទើបលាងទឹកធម្មតាជម្រះជាចុងក្រោយបំផុត មុននឹងយកទៅហាលថ្ងៃឱ្យស្ងួត ។ សូត្រប្រែទៅជាមានពណ៌សក្បុះ សរសៃទន់ ហើយឡើងពណ៌រលើប ។

គួរអោយសរសើរដូនតាយើង ដែលចេះយករុក្ខជាតិមកកែច្នៃគួបផ្សំឱ្យកើតចេញជារូបធាតុគីមីធម្មជាតិម្យ៉ាង សំរាប់បម្រើសេចក្ដីត្រូវការទៅតាមការចាំបាច់ ។ សព្វថ្ងៃនេះ ថ្វីបើយើងមានសាប៊ូមកប្រើជំនួសទឹកក្បុងហើយក្ដីក៏ក្បុងនៅតែមានសមត្ថភាព និងបន្តនិរន្តរភាពរបស់វានៅក្នុងសង្គមខ្មែរ ដែលវត្ថុខ្លះមិនអាចប្រើសាប៊ូជំនួសបាន ។ យើងអាចវាស់វែងបាននូវគំរិតប្រាជ្ញា និងគំនិតច្នៃប្រឌិតរបស់បុព្វបុរសយើង ដែលពិតជាមិនចាញ់ជនជាតិដទៃប៉ុន្មានឡើយ ។

ដោយ **មៀច ប៉ុណ្ណ**
ការិយាល័យនៀមទម្លាប់ខ្មែរ

(១) អាចម៍សូត្រ គឺក្រ៉ាវដីករដុះដែលជិតជាប់នៅនឹងសរសៃសូត្រតាំងពីពេលព្រាវសូត្រ រកព្ញើះ ។

# សិក្ខាសាលាអនុតំបន់អាស៊ីអាគ្នេយ៍ ស្តីពី

## « តួនាទីព្រះសង្ឃពុទ្ធសាសនិកក្នុងការបង្ការ និងជួយថែទាំអ្នកជំងឺអេដស៍ »

## ២៦-៣០ / ៥ / ២០០០ នៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ



តំណាងអង្គការ UNICEF ក្នុងសិក្ខាសាលាអនុតំបន់អាស៊ីអាគ្នេយ៍ ( រូបថត អាជ្ញាធរជាតិ )

បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលមានការរាលដាលនៃជំងឺអេដស៍ខ្លាំងជាគេបង្អស់ នៅក្នុងទ្វីបអាស៊ីអាគ្នេយ៍ ។ ប្រសិនបើគ្មានអន្តរាគមន៍ដែលមានប្រសិទ្ធភាពទេនោះ ការខាតបង់ដោយផ្ទាល់ និងដោយប្រយោលដែលបណ្តាលមកពីការរាលដាលជំងឺនេះ នឹងបង្កជាវិបត្តិយ៉ាងធ្ងន់ធ្ងរដល់ប្រទេសកម្ពុជា ដោយហេតុនេះ ទាមទារអោយមានការចូលរួមអប់រំបង្ការ និងថែទាំអ្នកជំងឺនេះពីគ្រប់មជ្ឈដ្ឋានសង្គម ជាពិសេស ការចូលរួមអន្តរាគមន៍ ដ៏មានសក្តានុភាពរបស់ព្រះសង្ឃ ស្របតាមគោលការណ៍ព្រះធម៌នៃពុទ្ធសាសនា សំដៅរក្សាបាននូវសុខដុមភាព ក្នុងជីវិតរស់នៅនៃប្រជាពលរដ្ឋយើង ។

គឺនៅក្នុងស្ថានតីនេះហើយ ដែលក្រសួងធម្មការ និងសាសនា សហការជាមួយអាជ្ញធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលានេះឡើង សំដៅ ៖

• ទីមួយ ៖ ជួយអោយព្រះសង្ឃពុទ្ធសាសនិកនៅកម្ពុជា ដែលជាអង្គការចាត់តាំងមួយរបស់សង្គម បានយល់អំពីចំណេះដឹងមូលដ្ឋានអំពីជំងឺអេដស៍ ។

• ទីពីរ ៖ តាមរយៈការយល់ដឹងនេះ ព្រះសង្ឃដែលមានតួនាទីសំខាន់ក្នុងការអប់រំសីលធម៌ និងអភិសមាចារសង្គម និងជាកម្លាំងចលករដ៏សំខាន់របស់សង្គមនោះ ព្រះអង្គនឹងបន្តការចូលរួមក្នុងការងារអប់រំបង្ការ និងជួយថែទាំអ្នកជំងឺអេដស៍ ដោយបង្ហាញអំពី ៖

- ផលប៉ះពាល់មកលើបុគ្គល ដោយអ្នកជំងឺអេដស៍,
- ផលប៉ះពាល់មកលើគ្រួសារ ដោយអ្នកជំងឺអេដស៍,
- ផលប៉ះពាល់ផ្ទាល់នៃជំងឺអេដស៍, ការចំណាយក្នុងការព្យាបាលជំងឺ,
- ផលប៉ះពាល់ដោយប្រយោលនៃជំងឺអេដស៍, ផលប៉ះពាល់វិស័យសេដ្ឋកិច្ច/សង្គម . ល . និង . ល . ។



ស្តាប់សេចក្តីពន្យល់អំពីជំងឺអេដស៍ និងចំណេះដឹងមូលដ្ឋានអំពីជំងឺនេះ ( រូបថត អាជ្ញាធរជាតិ )



ព្រះសង្ឃថៃបង្ហាញបទពិសោធន៍អំពីការងាររបស់សីមេធមិក្នុងអបកជន ( រូបថត អាជ្ញាធរជាតិ )

សិក្ខាសាលានេះ បានកើតជារូបរាងឡើងដោយសារការឧបត្ថម្ភ ដ៏ថ្លៃថ្លា ទាំងថវិកា និងទាំងស្មារតី អំពីអង្គការ UNICEF ប្រចាំនៅកម្ពុជា និងដោយមាន លោកបណ្ឌិត ទា ផលា និងលោកបណ្ឌិត ម៉ី ណាយ ជាអ្នកជួយសម្របសម្រួលការ រៀបចំ និងការប្រព្រឹត្តទៅនៃសិក្ខាសាលានេះ ។

សិក្ខាសាលាអនុតំបន់ រយៈពេល ៥ ថ្ងៃនេះ មានការចូលរួមពីសំណាក់ ព្រះសង្ឃនៃប្រទេសថៃ រួមជាមួយព្រះសង្ឃខ្មែរ ដែលនិមន្តមកពីខេត្ត-ក្រុងនានា នៃ ប្រទេសកម្ពុជា ។ ដោយហេតុនេះ សិក្ខាសាលានេះ នឹងបានជាវេទិកាផ្តល់ពត៌មាន យោបល់ និងបទពិសោធន៍ សំរាប់ផែនការ និងកម្មវិធីសកម្មភាពរបស់ព្រះសង្ឃខ្មែរ ក្នុងការបង្ការ និងថែទាំអ្នកជំងឺអេដស៍នៅកម្ពុជា ។

ទស្សនាវដ្តី « កម្ពុជសុរិយា » មានសេចក្តីសោកស្តាយ ដោយពុំមាន លទ្ធភាពចុះផ្សាយខ្លឹមសាររបស់ប្រតិភូជាសមាជិកនៃសិក្ខាសាលា ។ លេខក្រោយៗ យើងនឹងខិតខំដកស្រង់ខ្លឹមសារខ្លះចុះផ្សាយក្នុងលេខជាបន្តបន្ទាប់ ៕

ពុទ្ធសាសនបណ្ឌិត្យ

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ព្រះពុទ្ធ និង ការថែទាំសុខភាព

ឆ្នាំទី ៥៤ លេខ ៣ ខែ កក្កដា - សីហា - កញ្ញា

ព.ស. ២៥៤៤ គ.ស. ២០០០

ភ្នំពេញ

• រូបក្របមុខ ៖ ព្រះពុទ្ធ និងការថែទាំអ្នកជំងឺ

ក្នុងពេលព្រះបូតិគត្តតិស្សត្ថេរ កើតរោគរមាស់ កម ដំបៅ ពុះពងពេញទាំងខ្លួន មាន ទឹករងៃហៀរសស្រាក់ មានក្លិនអសោច, ព្រះពុទ្ធអង្គផ្ទាល់បានជំរះកាយ ព្យាបាល និងគក់បោកស្បង់ចីពរ របស់ ព្រះថេរៈដោយផ្ទាល់ ដោយមានជំនួយពីព្រះអានន្ទត្ថេរ និងភិក្ខុទាំងឡាយផង លោកអ្នកឈឺ ក៏បានសះស្បើយ ទើបព្រះអង្គសំដែងគាថា ១ ថា « *អចិរំ វត យំ កាយោ . បេ .* » ចប់ លោកក៏បានសំរេចព្រះអរហត្ត ។

( ធម្មបទដ្ឋកថា ភាគ ២ )

( រូបគំនូរនេះត្រូវបានចម្លងពីកម្ពុជសុរិយា ខ្សែ២ /១៩៤០ )



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

នាយកការផ្សាយ : ខ្លួន វ៉ាន់ចន្ទី

និពន្ធនាយក : ឱម ខែម

និពន្ធនាយករង : អាំ ឆន

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា ឆយ យីហ៊ាច, លោក ម៉ែន ប្រាជ,

លោក ខង់ សុធារ៉ា, លោក ឆន់ ហ៊ុន, លោក មៀច ប៉ុណ្ណ,

លោក ខៀវ បញ្ញាវុឌ្ឍ, លោក ពេជ ប៊ុន្ធីន

គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **នេត ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា
- លោក បណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិទ្យាស្ថានជាតិខាងភាសា
- លោក បណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិត្យសភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ ។
- The publication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា


• តួនាទីពុទ្ធសាសនា សំរាប់សតវត្សទី ២១ ( ធម្មបណ្ឌិត ហ. ចណើធិន្ទា ) ........ ១

• ពុទ្ធគយា កន្លែងព្រះពុទ្ធបានត្រាស់ដឹង ( ឱម ខែម ) ........ ៨


## II. អក្សរសាស្ត្រទូទៅ និងអក្សរសិល្ប៍ខ្មែរ


• បញ្ញវន្តកម្ពុជា ( បណ្ឌិត ឆយ ឃីហ៊ាង ) ........ ១៥

• ស្មារតីខ្មែរ និងព្រះពុទ្ធសាសនា ( អ្នកស្រីបណ្ឌិត ខ្លូត ធីតា ) ........ ២៨

• សិលាចារឹកអរកព្លក K 1051 និងរាជ្យព្រះបាទមហាសិវ៌ន្ទ្រទី ១ (វង់ សុធារ៉ា) ........ ៣៧

• វិហារ « អដ្ឋរស្ស » និងប្រស្នា «៣ខ» របស់ស្តេចស្រុកចិន ( ឱម ខែម ) ........ ៤៨

• អំពី « ស្ត្រីភាព » ( ឱម ខែម ) ........ ៥៣

• សំណាបយោងដី, ... ( ឆន ឈោង ) ........ ៦១

• អំពីព្រះបាទធម្មិក ( ក្បួនពុទ្ធទំនាយ ) ( ធន់ ហ៊ិន ) ........ ៦៥

• អំពីការទាក់ដីវិវនាម ( មៀច ប៉ុណ្ណ ) ........ ៧៥

• ឈ្មោងជិត កញ្ជើជិត ( មៀច ប៉ុណ្ណ ) ........ ៨៥


## III. កំណត់ និង ប្រវត្តិការណ៍


• អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៩ ឆ្នាំ ២០០០ ........ ៩១

• សេចក្តីជូនដំណឹង ស្តីពីការកើតឡើងវិញនៃ « ពុទ្ធិកសមាគមកម្ពុជរដ្ឋ » ........ ៩៦

# តួនាទីពុទ្ធសាសនា សំរាប់សតវត្សទី ២១ នៅកម្ពុជា

ធម្មបណ្ឌិត **ហេង មណីចិន្តា**

## ១. សម្លឹងមើលតួនាទីពីអតីត

*« ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតរោ ... (*) »*

« ម្នាលភិក្ខុទាំងឡាយ ចូរអ្នកត្រាច់ទៅកាន់ចារិក ( គឺភូមិ ស្រុក និគម ជនបទ និងធានី ) ហើយសំដែងធម៌ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ; អ្នកទាំងឡាយចូរកុំទៅពីរនាក់តាមផ្លូវជាមួយគ្នាឡើយ ; ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសំដែងធម៌ឱ្យពីរោះបទដើម ពីរោះបទកណ្តាល និងពីរោះបទចុង, ចូរប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ ។ សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលី គឺកិលេសតិចក្នុងភ្នែកក៏មាន សត្វទាំង

---

(*) សុត្តន្តបិដក ទីឃនិកាយ ពតិយភាគ មហាវគ្គ - ទំព័ ៨៧

នោះនឹងធាកស្ងន្យសន្តិភាព ព្រោះមិនបានស្តាប់ធម៌ ឯសត្វទាំងឡាយដែលបំរុងត្រាស់ដឹងធម៌ ក៏មាន ... »

ពុទ្ធបញ្ញានេះ គឺជាការចេញបញ្ញាបេសកកម្ម (*) លើកដំបូងបង្អស់ ដែលព្រះពុទ្ធបានត្រាស់ដឹងឡើង ចំពោះព្រះសង្ឃចំនួន ៦០ រូប បន្ទាប់ពីព្រះអង្គបានត្រាស់ជាព្រះសម្មាសម្ពុទ្ធបាន ៥ ខែ ។ ពុទ្ធបញ្ញានេះ គ្របដណ្តប់លើប្រធានបទតួនាទីពុទ្ធសាសនា សំរាប់សហស្សវត្សថ្មី នៅកម្ពុជា ។

អត្ថបទនេះ នឹងបង្ហាញពីតួនាទីពុទ្ធសាសនាដែលមានក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធមានព្រះជន្មនៅឡើយ, ពង្រាងតួនាទីដែលគួរមាន ( តាមទស្សនៈអ្នករៀបរៀងផ្ទាល់ ) សំរាប់សម័យកាលដែលបច្ចេកវិទ្យា និងពត៌មានវិទ្យា កំពុងគ្របដណ្តប់សឹងតែគ្រប់ជ្រុងជ្រោយលើវិថីជីវិតរបស់យើង ហើយនិងដាក់ជូននូវហេតុបច្ច័យដែលគិតថា នឹងអាចនាំតួនាទីទាំងនោះឆ្ពោះទៅរកជោគជ័យបាន ។

**ក. *ភារៈប្រកាសរបស់ពុទ្ធសាសនា***

ភារៈប្រកាសរបស់ពុទ្ធសាសនា ឬហេតុអ្វីទើបបានជាមានពុទ្ធសាសនាកើតឡើងក្នុងលោកនេះ, តាមពុទ្ធដីកាខាងលើ, អាចចែកចេញជា ៣ ចំណុចគឺ :

១. *ដើម្បីអនុគ្រោះដល់សត្វលោក* ( លោកានុកម្បាយ ) ។

២. *ដើម្បីសេចក្តីចំរើន ដើម្បីជាគុណប្រយោជន៍ ជាសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ* ( អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ) ។

៣. *បើកបង្ហាញសន្តិធម៌ដល់សព្វសត្វ* ( សន្តិធ សត្ថា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស ។

---

(*) ពាក្យ « បេសកកម្ម » នេះធ្លាប់ប្រើមកជាយូរដែរហើយ, តែបើគិតដល់ន័យត្រង់របស់ពាក្យ ឃើញថាដូចជាមិនសូវសម, បើប្រើជា « បេសិតកម្ម » ដូចជាគួរជាង ព្រោះមានន័យថា « អំពើរបស់ជនដែលត្រូវគេប្រើ ឬកិច្ចការរបស់ជនអ្នកទទួលបម្រើ » . វចនានុក្រម ។

ពាក្យថា *អនុគ្រោះ* បានដល់ការជួយសង្គ្រោះសត្វលោកដែលកំពុងមានសេចក្តីទុក្ខក្នុងវាលវដ្តសង្សារនៃការកើត ចាស់ ឈឺ ស្លាប់ ។ បានសេចក្តីថា ការជួយសង្គ្រោះសត្វណាដែលកំពុងមានបញ្ហាក្នុងជីវិត តាំងតែពីកើតរហូតដល់ស្លាប់ទៅវិញ

ពាក្យថា *សត្វលោក* ( beings ) បានដល់សត្វមានជីវិតទាំងអស់ ទាំងមនុស្ស (human) ទាំងអមនុស្ស (non-human) ទាំងសត្វទាំងឡាយ រួមទាំងរុក្ខជាតិ ដែលតាមជំនឿក្នុងសម័យនោះថាជារបស់មានជីវិតដែរ ។

ពាក្យថា *ទេវតា ឬទេព* ( god ) មានន័យពីរយ៉ាង ។ ទីមួយ : បានដល់*ឧបត្តិទេព* គឺទេវតា ដែលតាមជំនឿរបស់ខ្មែរយើងថា ស្ថិតនៅក្នុងស្ថានសួគ៌ គឺជាពួជទេវតាពីកំណើត ។ ទីពីរ : បានដល់*សម្មតិទេព* គឺទេវតាកើតឡើងដោយសន្មតិ ។ តាមន័យទីពីរនេះ គឺព្រះរាជា និងថ្នាក់ដឹកនាំទាំងឡាយ ដែលគេសន្មតទុកដូចជាទេវតារបស់មនុស្ស មានឫទ្ធិអំណាចដូចទេវតាពីកំណើតដែរ ។

ពាក្យថា *មនុស្ស* គឺមនុស្សជាតិដែលស្ថិតនៅលើភពផែនដីនេះ មិនប្រ-កាន់ថានៅទីណា មានសញ្ជាតិ សាសនា ឬ ភេទអ្វីទេ ។

ឃ្លាដែលថា *បើកបង្ហាញសន្តិធម៌ដល់សព្វសត្វនោះ* ( to open peace to all beings ) មានន័យថា សត្វទាំងអស់នោះ រស់នៅក្នុងសភាវៈមួយដែលមិនមានសន្តិភាពនៅក្នុងចិត្ត ហើយដែលតែងតែបង្កមិនឱ្យមានសន្តិភាពក្នុងសង្គម ។ ការបើកបង្ហាញនូវសន្តិធម៌ ជាការបង្ហាញនូវជំរើសមួយដល់មនុស្សជាតិថា *មានសន្តិធម៌* ដែលអាចជួយមនុស្សជាតិទាំងនោះឱ្យមានសន្តិភាពបាន ។

## ខ. *គោលបំណង* :

*បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ* ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ។

ដើម្បីឱ្យភារៈប្រកាសនេះបានទទួលជោគជ័យ ព្រះពុទ្ធអង្គបានសុំឱ្យភិក្ខុដែលជាសាវ័ករបស់ព្រះអង្គចេញទៅកាន់ចារឹក គឺភូមិ និគម និងធានី ដើម្បីប្រកាស

ព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ។

ពាក្យថា *ព្រហ្មចរិយធម៌* បានដល់ធម៌ ឬគោលការណ៍ព្រះធម៌ សម្រាប់រស់នៅ ដែលផលប្រយោជន៍នៃគោលការណ៍នេះនៅត្រង់ថា បើមនុស្សណារស់នៅក្នុងគោលកាណ៍នេះហើយ មនុស្សនោះនឹងក្លាយជាមនុស្សប្រសើរ មានបុគ្គលិកលក្ខណៈដូចជាព្រះព្រហ្ម ដែលជាព្រះអាទិទេពបង្កើតផែនដីនេះ តាមនិទានរបស់សាសនាព្រាហ្មណ៍ដែរ ។

ព្រហ្មចរិយធម៌ ឬគោលការណ៍ សម្រាប់ការរស់នៅបែបពុទ្ធសាសនានេះ មានទាំងអស់ ១០ ប្រការ គឺ :

*១. ទាន* : ការឱ្យ មានធម្មទាន និងអាមិសទាន

*២. វេយ្យាវច្ចៈ* : ការចូលរួមក្នុងការងារសង្គម

*៣. បញ្ចសីល* : សីល ៥ មិនហឹង្សា (មិនសម្លាប់) មិនលួច មិនកាមនិយម មិនកុហក មិនសេពគ្រឿងញៀន

*៤. អប្បមញ្ញា* : មាន មេត្តា ករុណា មុទិតា ឧបេក្ខា

*៥. មេថុនវិរតិ* : ការវៀរចាកមេថុនធម៌

*៦. សទារសន្តោសៈ* រីករាយនឹងការមានប្រពន្ធតែមួយ

*៧. ឧបោសថង្គៈ* : រក្សាសីល ៨ តាមកាល

*៨. វិរិយៈ* : ព្យាយាមកំចាត់បាប និងព្យាយាមចំរើនបុណ្យ

*៩. អរិយមគ្គ* : ដើរតាមផ្លូវទាំង ៨

*១០. សាសនវសេន* : ឱ្យមនុស្សស្គាល់ព្រះធម៌ មានធម្មាធិបតេយ្យ គោរពធម្មជាតិ

ការប្រកាសព្រហ្មចរិយធម៌ទាំង ១០ ប្រការនេះ អាចចែកចេញជា ៣ ផ្នែកសំខាន់ៗ គឺ :

ក. *ការប្រកាសឱ្យបុគ្គលម្នាក់ៗស្គាល់ពីនាទី ដែលគប្បីធ្វើចំពោះខ្លួន*

*១. អរិយមគ្គ* : យល់ត្រូវ គិតត្រូវ និយាយត្រូវ ធ្វើត្រូវ ធ្វើអាជីវកម្មត្រូវ ព្យាយាមត្រូវ មានសតិត្រូវ និងមានការតំកល់ចិត្តត្រូវក្នុងជីវិតប្រចាំថ្ងៃ

*២. សទារសន្តោសៈ* រីករាយនឹងការមានប្រពន្ធតែមួយ

*៣. ឧបោសថង្គៈ* : សមាទានឧបោសថ តាមកាល

*៤. មេថុនវិរតិ* : ការវៀរចាកមេថុនធម៌

*៥. វិរិយៈ* : ព្យាយាមលះបង់អំពើអាក្រក់ និងកសាងអំពើល្អ

*៦. អប្បមញ្ញា* : មាន មេត្តា ករុណា មុទិតា ឧបេក្ខា ។

ខ. *ការប្រកាសឱ្យបុគ្គលម្នាក់ៗស្គាល់ពីនាទី ដែលគប្បីធ្វើចំពោះសង្គម*

*១. ទាន* : ការឱ្យ មានធម្មទាន និងអាមិសទាន

*២. វេយ្យាវច្ចៈ* : ការចូលរួមក្នុងការងារសង្គម

*៣. អប្បមញ្ញា* : មាន មេត្តា ករុណា មុទិតា ឧបេក្ខា

*៤. បញ្ចសីល* : រក្សាសីល ៥ មិនហឹង្សា (មិនសម្លាប់) មិនលួច មិនកាម-កាមនិយម មិនកុហក មិនសេពគ្រឿងញៀន

*៥. វិរិយៈ* : ព្យាយាមកំចាត់អំពើបាប និងកសាងអំពើល្អដល់សង្គម

គ. *ការប្រកាសឱ្យបុគ្គលម្នាក់ៗស្គាល់ពីនាទី ដែលគប្បីធ្វើចំពោះធម្មជាតិ*

*១. សាសនវសេន* : ឱ្យមនុស្សស្គាល់ព្រះធម៌ មានធម្មាធិបតេយ្យ គោរពធម្មជាតិ ។



## ២. សម្លឹងមើលតួនាទី សម្រាប់សតវត្សទី ២១

**(1)** *ណែនាំពុទ្ធបរិស័ទខ្មែរឱ្យប្រឹងប្រែងអភិវឌ្ឍជីវិតខ្លួន* ( បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ ) *ឱ្យក្លាយទៅជា :*

ក. *អ្នកដែលអាចពឹងលើខ្លួនឯងបាន :*

១. អ្នកដែលមានជីវិតជាមជ្ឈិមបដិបទាបែបពុទ្ធសាសនា និងដែលជាផ្លូវនាំទៅរកការអភិវឌ្ឍល្អផ្នែកសេដ្ឋកិច្ច សុខភាពផ្លូវចិត្ត ព្រឹត្តិកម្មក្នុងសង្គម និងសតិបញ្ញា ។

២. អ្នកដែលមានភក្តីភាពចំពោះស្វាមីភរិយាខ្លួន ។

៣. អ្នកដែលរស់នៅក្នុងវិថីជីវិតបែបអហឹង្សា គោរពសេចក្ដីសុខរបស់អ្នកដទៃ និងមានយុត្តិធម៌ ។

៤. មិនជ្រមុជជ្រមុលនៅក្នុងលទ្ធិវត្ថុនិយម ( sensualism ) ។

៥. ចៀសវាងពីលទ្ធិកាមនិយម ( sexualism ) ។

៦. អ្នកដែលចេះរៀបចំជីវិតខ្លួន ក្នុងបែបបទអភិបាលកិច្ចល្អ ក្នុងវិធីការពារ និងកំចាត់ឧបសគ្គជីវិតមិនឱ្យកើតឡើង និងអភិវឌ្ឍន៍ និងរក្សាសមិទ្ធផលល្អឱ្យគង់វង្ស និងរីកចំរើន ។

ខ. *អ្នកដែលអាចធ្វើជាទីពឹងដល់អ្នកដទៃបាន :*

១. អ្នកដែលមិនគិតតែប្រយោជន៍ផ្ទាល់ខ្លួន តែចេះជួយអ្នកដទៃ ទាំងផ្នែកទ្រព្យសម្បត្តិ ទាំងផ្នែកចំណេះដឹង ។

២. ចូលរួមក្នុងការងារសង្គម និងជួយដោះស្រាយបញ្ហាសង្គមដែលកើតមាន ។

៣. មិនបង្កបញ្ហាក្ដៅក្រហាយដល់សង្គម និងប្រកាន់ខ្ជាប់ក្នុងសីល ៥ ។

៤. អ្នកប្រកាន់ដំណោះស្រាយបែបអហឹង្សា និងប្រកាន់យុត្តិធម៌ ។

៥. អ្នកមានអភិបាលកិច្ចល្អក្នុងការងារ ក្នុងវិធីការពារ និងកំចាត់ឧបសគ្គជីវិតមិនឱ្យកើតឡើង អភិវឌ្ឍន៍ និងរក្សាសមិទ្ធផលល្អឱ្យគង់វង្ស និងរីកចំរើន ។

៦. លើកស្ទួយធម្មាធិបតេយ្យ និងចាត់ការរក្សាការពារ និងគ្រប់គ្រង ប្រកបដោយធមិដល់បុគ្គល សង្គម និងធម្មជាតិ ។

(2) *ចូលរួមចំណែកក្នុងការលើកស្ទួយគុណភាពជីវិតពុទ្ធបរិស័ទ ( អត្តាយ ហិតាយ សុខាយ មនុស្សានំ ) លើវិស័យ :*

- សេដ្ឋកិច្ច
- ហេដ្ឋារចនាសម្ព័ន្ធ
- សុខភាព
- សីលធមិ និងគុណតម្លៃសង្គម
- ការសិក្សា ។

(3) *ចូលរួមជួយអភិវឌ្ឍន៍នយោបាយរដ្ឋាភិបាល លើវិស័យ :*

- វប្បធមិ
- ទេសចរណ៍
- បរិស្ថាន
- អភិបាលកិច្ច
- ការអប់រំ

*

## សុភាសិត

- *ខាងក្រៅខ្មោកក្រិត ខាងក្នុងចិត្តល្អសភ្លឺង*
  *អ្នកស្រុកស្រណុកពឹង រឹងតែពាក្យសំដីក្រៅ ។*

# ពុទ្ធគយា

## កន្លែងព្រះពុទ្ធបានត្រាស់ដឹង

រៀបរៀងដោយ **ឱម ខែម**

ព្រះមហាបុរសមួយរូប អ្នកមានវិចារណញ្ញាណដ៏ជ្រាលជ្រៅ បានរាវរកឃើញសេចក្ដីប្រតិបត្តិដែលមានខ្លឹមសារវិសេស អាចធ្វើមនុស្សគ្រប់ឋានៈឱ្យបានរួចចាកភ្លើងកិលេស ហើយបានប្រកាសផ្សាយទុករហូតដល់សព្វថ្ងៃនេះ គឺ ព្រះសម្មាសម្ពុទ្ធរបស់យើងហ្នឹងឯង ។ កាលដែលព្រះសម្ពុទ្ធទ្រង់ស្វែងរកសេចក្ដីប្រតិបត្តិដែលមានខ្លឹមសារវិសេសនោះ ពុំមែនទើបនឹងស្វែងរកក្នុងមួយជាតិជាទីបំផុតនេះទេ គឺស្វែងរកអស់កាលជាច្រើនជាតិណាស់ ដូចមានប្រវត្តិដែលអ្នកប្រាជ្ញទាំងឡាយបានចារឹកក្នុងគម្ពីរជាច្រើន មានគម្ពីរបឋមសម្ពោធជាដើម ដែលមានសេចក្ដីដំណាលថា កាលព្រះបរមគ្រូនៃយើងនៅក្នុងឋានៈជាពោធិសត្វមាននាមថា សុមេធ-បណ្ឌិត បានបំពេញបារមីធម៌ទាំងឡាយ មានទានបារមីជាដើម អំណើះពីនោះមកសូម្បីសោយព្រះជាតិជាអ្វី ទោះបីជាតិជាមនុស្សក្ដី ជាអមនុស្សក្ដី ជាតិរច្ឆានក្ដី សុទ្ធតែបានបំពេញបារមីគ្រប់ៗជាតិ ដើម្បីស្វែងរកមោក្ខធម៌ ( ធម៌ចម្លងសត្វឱ្យចេញផុតចាកលោក ) តែម្យ៉ាង អស់ច្រើនអសង្ខេយ្យកប្ប រហូតដល់បច្ឆិមជាតិ ដែលមាននាមថាសិទ្ធត្ថ-គោតម ទើបបានជួបប្រទះនឹងខ្លឹមសារនៃមាគ៌ារំដោះទុក្ខ ពោលគឺមោក្ខធម៌ ។

ព្រះសិទ្ធត្ថ-គោតម ទ្រង់ប្រសូតនៅថ្ងៃសុក្រ ១៥ កើត ខែវិសាខ ឆ្នាំច ព្រះវររាជបិតាព្រះនាម សុទ្ធោទនៈ-គោតម ព្រះវររាជមាតាព្រះនាម សិរិមហាមាយា

ជាព្រះចៅក្រុងកបិលពស្តុ នៃដែនសក្កៈ ។

លុះព្រះជន្មាយុបាន ១៦ ព្រះវស្សា ព្រះសិទ្ធត្ថទ្រង់ទទួលរាជាភិសេកជាព្រះចៅក្រុងកបិលពស្តុ ដោយមានព្រះនាង យសោធរាពិម្ពាទេវី ជាព្រះអគ្គមហេសី ហើយទ្រង់មានព្រះរាជបុត្តមួយព្រះអង្គ ព្រះនាមរាហុលកុមារ ។ ដល់ព្រះជន្មាយុ ២៩ ព្រះវស្សា ក្រោយពេលដែលទ្រង់យល់នូវទេវទូតទាំង ៤ គឺ : ជរា_ព្យាធិ_មរណៈ និងអ្នកបួស ព្រះសិទ្ធត្ថទ្រង់នឿយណាយក្នុងភេទជាឃរាវាស ក៏ទ្រង់យាងចេញពីព្រះរាជវាំងទាំងអធ្រាត្រទៅបំពេញបព្វជ្ជាស្វែងរកនូវមោក្ខធម៌ នៅតំបន់ឧរុវេលា ។

ក្រោយពេលនៃការស្វែងរកសច្ចធម៌ដោយវិធីទាំង ៤ គឺ : ឈានវិធី, អត្តកិលមថានុយោគវិធី, ទុក្ករកិរិយាវិធី និងមជ្ឈិមបដិបទាវិធី អស់ពេលដ៏យូរ ៦ ឆ្នាំមក, ព្រះសិទ្ធត្ថៈបានទៅដល់គោលដៅដែលទ្រង់បានគិតទុកគឺ មោក្ខៈ ( ការរួចផុតទុក្ខ ) ឬ និព្វាន នៅថ្ងៃពុធ ១៥ កើត ខែវិសាខ ឆ្នាំរកា វេលារាត្រីទៀបភ្លឺ មុនគ្រិស្តសករាជ ៥៨៨ ឆ្នាំ ក្នុងជន្មាយុ ៣៥ វស្សា នៅពោធិមណ្ឌល គឺពុទ្ធគយានេះឯង ។

គួរគប្បីរំលឹកថា ការស្វែងរកសច្ចធម៌ដោយវិធីផ្សេងៗ ជាពិសេស វិធីទី ២ និងទី ៣ មិនបានធ្វើឱ្យសមណៈសិទ្ធត្ថបានសំរេចអ្វី សូម្បីបន្តិចបន្តួចឡើយ, ផ្ទុយទៅវិញ បានត្រឹមតែធ្វើឱ្យព្រះអង្គទទួលរងទុក្ខវេទនា, មានសរីរាវយវៈគ្រប់ចំណែកទ្រុឌទ្រោម នៅសល់តែស្បែកដណ្តប់ឆ្អឹង, ស្ទើរតែមិនយល់ថាជាសរីរៈរបស់មនុស្សផង តែទ្រង់តាំងសតិសម្បជញ្ញៈទុកបាន ។ ពេលនោះ ព្រះសិទ្ធត្ថទ្រង់យល់ច្បាស់ថា ការប្រព្រឹត្តធ្វើតបៈតឹងរ៉ឹងហួសវិស័យ ដែលគ្រាន់តែជាសេចក្តីព្យាយាមធ្វើខ្លួនឱ្យលំបាកនោះ មិនមែនជាឧបាយនាំឱ្យសំរេចបានលោកុត្តរធម៌នោះទេ ។ ព្រះសិទ្ធត្ថពោធិសត្វខំត្រដរយាងចេញពី ឧរុវេលាឆ្ពោះទៅពុទ្ធគយា ដើម្បីរកមោក្ខធម៌តាមវិធីផ្សេង ។ ព្រះអង្គទ្រង់ព្រះតម្រិះថា « *ក្នុងអតីតកាលកន្លងហើយដ៏យូរក្តី ក្នុងអនាគតដ៏យូរទៅខាងមុខក្តី ឬក្នុងបច្ចុប្បន្ននេះក្តី សមណព្រាហ្មណ៍*

*ដែលបានសោយទុក្ខវេទនាយ៉ាងឈឺចាប់ខ្លោចផ្សារ ព្រោះការបំពេញព្យាយាមយ៉ាងខ្លាំងក្លាដូចព្រះអង្គធ្វើនេះ ពុំមានទេ ព្រោះព្រះអង្គបំពេញមក ៦ ឆ្នាំហើយ ក៏មិនបាន សំរេចធម៌ ដ៏ប្រសើរបំផុត តាមរបៀបដ៏លំបាកឈឺចាប់នេះបាន »* ។ ទ្រង់គិតថា ផ្លូវនេះ ឬវិធីនេះ ពិតជាពុំអាចដើរទៅដល់ទេ ប្រាកដជាមានផ្លូវផ្សេងទៀតពុំខាន ។

ពេលនោះ សតិសម្បជញ្ញៈរបស់ព្រះអង្គ ក៏រលឹកនឹកឃើញដល់សិល្បៈនៃការប្រគំតន្ត្រី មានឧបករណ៍ពិណជាដើម ដែលទ្រង់ធ្លាប់បានជួបកាលនៅពីគ្រហស្ថថា « *ខ្សែពិណដែលរឹតធូរពេក សំឡេងមិនពីរោះ, ខ្សែពិណដែលរឹតតឹងពេក សំឡេងក៏ល្ហើយ ហើយបើរឹតតឹងថែមទៀតប្រាកដជាដាច់ ។ ឯខ្សែពិណដែលរឹតល្មម តែងមានសំឡេងពីរោះ ប្រគំទៅឮរងំជាទីគាប់ចិត្ត* » ។ ព្រះអង្គប្រៀបធៀបមកនឹងការព្យាយាមរបស់ព្រះអង្គថា ជនដែលមានរាងកាយស្គាំងស្គម និងស្រេកឃ្លានបែបព្រះអង្គនេះ នឹងពុំអាចសំរេចធម៌បានឡើយ(*) , សត្វទាំងឡាយមានរាងកាយរស់នៅ និងមានកម្លាំងពលំ ពឹងផ្អែកលើអាហារ និងយល់ថាបដិបទានិងអ្វីៗទាំងអស់ គឺគេមិនដែលបានមកដោយសារអត់អាហារ ឬដោយធ្វើឱ្យរាងកាយទ្រុឌទ្រោម ឈឺចាប់នោះទេ ហើយអ្នកដែលជ្រមុជជ្រមុលនឹងកាមបរិភោគ ក៏នឹងមិនមានថ្ងៃអាចសំរេចធម៌បានដែរ ។

ដោយព្រះតម្រិះនេះ, ព្រះអង្គក៏ផ្លាស់កម្មវិធីមកទទួលភោជនាហារ តាមប្រក្រតីវិញ លុះត្រាតែមានសុខភាពបរិបូណ៌ដូចដើម ។ ព្រះអង្គបានងាកមកតម្រង់ជីវិតរបស់ព្រះអង្គតាមផ្លូវកណ្ដាល ដែលហៅថា មជ្ឈិមបដិបទា ( គឺ អដ្ឋង្គិកមគ្គ )

---

(*) ចំណុចត្រង់នេះ បានរឭកនឹកឃើញដល់ពាក្យពោលរបស់អ្នកប្រាជ្ញគរុកោសល្យបារាំងម្នាក់ ដែលពោលថា ប្រាជ្ញាល្អប្រពៃរស់នៅក្នុងរាងកាយដែលមានសុខភាពដ៏ប្រពៃ ( Une ame saine vit dans un corps saint )

ព្រមជាមួយនឹងការដុសសំអាតចិត្តឱ្យកាន់តែស្អាតផូរផង់ថែមទៀត គឺ :

១. តម្រង់ទិដ្ឋិឱ្យបានត្រឹមត្រូវ ( សម្មាទិដ្ឋិ )

២. តម្រង់ការត្រិះរិះគិតឱ្យបានត្រឹមត្រូវ ( សម្មាសង្កប្បៈ )

៣. តម្រង់វាចាឱ្យបានត្រឹមត្រូវ ( សម្មាវាចា )

៤. តម្រង់សកម្មភាពឱ្យបានត្រឹមត្រូវ ( សម្មាកម្មន្តៈ )

៥. តម្រង់ការចិញ្ចឹមជីវិតឱ្យបានត្រឹមត្រូវ ( សម្មាអាជីវៈ )

៦. តម្រង់សេចក្ដីព្យាយាមឱ្យបានត្រឹមត្រូវ ( សម្មាវាយាមៈ )

៧. តម្រង់សតិឱ្យបានត្រឹមត្រូវ ( សម្មាសតិ )

៨. តម្រង់ចិត្តឱ្យបានត្រឹមត្រូវ ( សម្មាសមាធិ ) ។

ផ្លូវកណ្ដាល ឬវិធីទាំង ៨ នេះ ព្រះអង្គបានធ្វើសមាហរណកម្ម ឬធ្វើវិធីសំយោគច្របាច់បញ្ចូលគ្នា ជាមួយការពិសោធន៍ច្រើនលើកច្រើនគ្រា រហូតទីបំផុតក៏បានឃើញច្បាស់ថា នេះពិតជាមាគ៌ានៃជីវិតនាំឆ្ពោះទៅរកការត្រាស់ដឹងមែន ។

ថ្ងៃនោះ នៅវេលាព្រឹក ព្រះពោធិសត្វបានទទួលចង្ហាន់ជាបាយមធុបាយាស លាយដោយទឹកដោះគោ ( នំមះឡាអ៊ិ ឬ សាល្ហី របស់ឥណ្ឌាសព្វថ្ងៃ ) អំពីនាងសុជាតា ស្ត្រីអ្នកស្រុកសេនានិគម តំបន់ឧរុវេលា, ឆាន់ទាល់តែអស់មធុបាយាសទាំង ៤៩ ពំនូត ហើយក៏បណ្តែតភាជន៍ក្នុងស្ទឹងនេរញ្ជរា ( ស្ទឹងផល្គុ បច្ចុប្បន្ន ) ដែលនៅជិតទីនោះ ជាមួយនឹងវចីភេទថា « *ប្រសិនបើអាត្មាអញ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃនេះ សូមឱ្យភាជន៍នេះអណ្តែតច្រាសទឹក បើមិនបានត្រាស់ទេ សូមឱ្យភាជន៍អណ្តែតបណ្តោយខ្សែទឹកទៅ* », វេលានោះភាជន៍ក៏អណ្តែតច្រាសទឹកបានចម្ងាយ ៨០ ហត្ថ ហើយលិចទៅក្នុងទឹកចូលទៅក្នុងវិមានកាឡនាគរាជ ត្រូវលើភាជន៍ដែលព្រះពុទ្ធបានត្រាស់មុនៗ ។ បន្ទាប់មក ព្រះអង្គក៏ឆ្លងកាត់ស្ទឹងផល្គុ ត្រង់ឆ្ពោះទៅកាន់ពុទ្ធគយា ។ ទៅដល់ទីនោះ ឈើមួយដើមដែលដុះក្នុងទីទាប ហាក់ដូច

ជាស្រែកក្រាបទូលអំពិចម្ចាយថា សូមព្រះអង្គយាងមកគង់ក្នុងទិនេះ ដើម្បីសម្រេចពោធិញ្ញាណ ។ ព្រះសិទ្ធត្ថ យកស្បូវភ្លាំង ៨ ចាប់ ដែលអ្នកច្រូតស្បូវម្នាក់ឈ្មោះសោត្ថិយៈបានប្រគេន ទៅក្រាលជាកម្រាល ហើយគង់យ៉ាងស្រួលក្រោមដើមឈើនោះបែរព្រះភក្ត្រឆ្ពោះទៅទិសខាងកើត ដោយតាំងព្រះទ័យយ៉ាងមុតមាំថា « *អាត្មាអញនឹងមិនក្រោកពីអាសនៈនេះ ដរាបណាអាត្មាអញរកមិនឃើញមាគ៌ារំដោះទុក្ខទេនោះ* » ។ តាំងអធិដ្ឋានរួច ព្រះអង្គក៏សង្រួមព្រះទ័យតាំងសមាធិ ដ៏ជ្រាលជ្រៅឆ្ពោះទៅរកមោក្ខធម៌ តទៅទៀត ។

នៅដើមរាត្រីដែលស្ងប់ស្ងាត់ ក្រោមពន្លឺដួងចន្ទ និងខ្សែវាយោបក់រំភើយនៃខែឧសភា ដួងចិត្តសមណៈសិទ្ធត្ថបានស្ងប់ស្ងាត់ ស្អាត និងបរិសុទ្ធ ហើយក៏កាន់តែស្ងប់ទៅៗ ស្អាតទៅៗ បរិសុទ្ធទៅៗ ។ ពេលដែលចិត្តស្ងប់ហើយ បញ្ញាញាណក៏កើតឡើងក្នុងយាមទាំង ៣ នៃរាត្រីនោះដោយលំដាប់ គឺ :

ក/ ក្នុងបឋមយាម ( យាមទី ១ ) ព្រះសមណៈសិទ្ធត្ថ រលឹកនឹកឃើញនូវជាតិកំណើតរបស់ព្រះអង្គពីមុនៗមកទាំងអស់បាន ។ ព្រះញាណនេះ ឈ្មោះថា *បុព្វេនិវានុស្សតិញ្ញាណ* ។

ខ/ ក្នុងមជ្ឈិមយាម ( យាមទី ២ ) ព្រះអង្គជ្រាបច្បាស់នូវការកើត ស្លាប់របស់សត្វទាំងឡាយថា សត្វដែលមានជីវិតរស់នៅល្អ ឬអាក្រក់នោះៗ ក៏ព្រោះអំណាចរបស់កម្ម ។ ព្រះញាណនេះ ឈ្មោះថា *ចុតូបបាតញ្ញាណ* ; ជួនកាលហៅថា *ទិព្វញ្ញាណ* ដែលប្រែថា មានសេចក្តីដឹងដូចភ្នែកទិព្វ *( ទិព្វចក្ខុ )* ។

គ/ ក្នុងបច្ឆិមយាម ( យាមទី៣ ) ទ្រង់សំរេចបាន*អាសវក្ខញ្ញាណ* គឺជ្រាបច្បាស់នូវធម៌ ដែលមានចំណងទាក់ទងគ្នាដូចជាច្រវាក់ ( បដិច្ចសមុប្បាទ ) ដែលកើតមានឡើងដោយសារបច្ច័យទាក់ទងតៗគ្នា ដូចជា សង្ខារកើតមានឡើង ព្រោះមានអវិជ្ជាជាបច្ច័យ, វិញ្ញាណកើតមានឡើង ព្រោះមានសង្ខារជាបច្ច័យ ឬថា

អវិជ្ជា ជាបច្ច័យនាំឱ្យកើតសង្ខារ, សង្ខារជាបច្ច័យនាំឱ្យកើតវិញ្ញាណ . ល . ។

នៅទីបំផុត គឺពេលជិតភ្លឺ នៃរាត្រី ១៥ កើត ខែវិសាខនោះ ព្រះអង្គបានកំចាត់អស់អាសវក្កិលេសមិនមានសេសសល់, ព្រះអង្គបានរកឃើញដំណោះស្រាយ គឺហេតុនៃសេចក្ដីទុក្ខ និងវិធីកំចាត់ទុក្ខ ។ ព្រះអង្គបានទទួលព្រះឋានៈជាពុទ្ធៈ គឺអ្នកត្រាស់ដឹងអរិយសច្ច ៤ គឺ : សច្ចៈនៃទុក្ខ ( ទុក្ខសច្ចៈ ), សច្ចៈអំពីហេតុនៃទុក្ខ ( ទុក្ខ-សមុទយសច្ចៈ ), សច្ចៈអំពីការបញ្ចប់ទុក្ខ ( ទុក្ខនិរោធសច្ចៈ ) និងសច្ចៈអំពីផ្លូវនាំទៅរកការបញ្ចប់ទុក្ខ ( មគ្គសច្ចៈ ), ទ្រង់ជាសព្វញ្ញុពុទ្ធក្នុងលោក ក្រោមដើមអស្សត្ថព្រឹក្សក្បែរមាត់ស្ទឹងនេរញ្ជរា ( ស្ទឹងផល្គុ បច្ចុប្បន្ន ) ហើយទ្រង់បន្លឺជ័យជំនះរបស់ព្រះអង្គដោយឧទានកថា ដូចនេះថា :

*អនេកជាតិសំសារំ* *សន្ធាវិស្សំ អនិព្វិស្សំ*
*គហការំ គវេសន្តោ* *ទុក្ខា ជាតិ បុនប្បុនំ*
*គហការក ទិដ្ឋោសិ* *បុនគេហំ ន កាហសិ*
*សព្វា តេ ផាសុកា ភគ្គា* *គហកូដំ វិសង្ខតំ*
*វិសង្ខារគតំ ចិត្តំ* *តណ្ហានំ ខយមជ្ឈគា ។*

អាត្មាអញ កាលមិនទាន់បានជួបប្រទះ (ពោធិញ្ញាណ) នៅឡើយ រវល់តែស្វែងរកនូវជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ហើយអន្ទោលទៅកាន់សង្សារមានជាតិមិនតែមួយ, ជាតិគឺការកើតរឿយៗ រមែងនាំមកនូវសេចក្ដីទុក្ខ, នែជាងផ្ទះគឺតណ្ហា ( ឥឡូវនេះ ) យើងបានឃើញអ្នកច្បាស់ហើយ, អ្នកឯងនឹងធ្វើនូវផ្ទះគឺអត្តភាព ( នេះ ) ឱ្យយើងទៀត ពុំបានឡើយ, ឆ្អឹងជំនីគឺកិលេសទាំងអស់ របស់អ្នកឯង យើងបានបំបាក់ចោលហើយ ទាំងកំពូលនៃផ្ទះ គឺអវិជ្ជារបស់អ្នកឯងសោតទៀត យើងក៏បានបំបាក់ចោលហើយដែរ, ចិត្តរបស់យើងបានដល់នូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ, យើងបានដល់នូវព្រះអរហត្ត គឺការអស់ទៅនៃតណ្ហាទាំង

ឡាយហើយ ។

បន្ទាប់ពីការបំពេញករណីយកិច្ចក្នុងឋានៈជាព្រះពុទ្ធដើម្បីសត្វលោក អស់រយៈកាល ៤៥ ឆ្នាំមក ព្រះអង្គបានចាកលោកនេះដោយស្ងៀមស្ងាត់ ។ គឺនៅឆ្នាំទី ៨០ នៃព្រះជន្មាយុ ដែលត្រូវនឹងថ្ងៃអង្គារ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ នពស័ក ព្រះអង្គបានយាងចូលកាន់បរិនិព្វាន នៅក្រោមសាលព្រឹក្សទាំងគូ នៃទីក្រុងកុសិនារា មុនពុទ្ធសករាជ ១ ថ្ងៃ គិតមកដល់ឆ្នាំ ២០០០ នេះបាន ២៥៤៤ ឆ្នាំហើយ ។

ពុទ្ធគយា គឺជាសំវេជនីយស្ថានទី ២ របស់ពុទ្ធបរិស័ទទូទៅ ។ ទោះបីមានជនអ្នកបដិបក្ខជាច្រើន បានព្យាយាមបំផ្លិចបំផ្លាញជាច្រើនដងក៏ដោយ, ពោធិមណ្ឌលដែលជាកន្លែងផ្សាយចេញនៃសច្ចធម៌ ក៏នៅតែមានជីវិតរស់នៅអស់កាលជាង ២៥ សតវត្សមកហើយ ហើយនឹងនៅតែបន្តជីវិតរាប់ពាន់ឆ្នាំតទៅមុខទៀត ។

សំវេជនីយស្ថាន ៤ តំបន់ ជាទីគួរឃើញ គួរសង្វេគ គឺ :

១. តំបន់ ឬស្ថានដែលព្រះពុទ្ធសក្យមុនីទ្រង់ប្រសូត ( ឧទ្យានលុម្ពិនី ),

២. តំបន់ ឬស្ថានដែលព្រះពុទ្ធបានត្រាស់ដឹង ( ពុទ្ធគយា ),

៣. តំបន់ ឬស្ថានដែលព្រះពុទ្ធទ្រង់សំដែងធម្មចក្រ ( សារនាថ ),

៤. តំបន់ ឬស្ថានដែលព្រះពុទ្ធទ្រង់ចូលបរិនិព្វាន ( កុសិនារា ) ។

*

ឯកសារពិគ្រោះ


- ល្វី ហ្វីណូត៍ : អំពីព្រះពុទ្ធសាសនា, បោះពុម្ពលើកទី ៣ ពុទ្ធសាសនបណ្ឌិត្យឆ្នាំ ១៩៦៤
- ព្រះត្រៃបិដក : សុត្តន្តបិដក ទីឃនិកាយ, បោះពុម្ពឡើងវិញ ឆ្នាំ ១៩៩៤
- ឥន្ទបញ្ញោភិក្ខុ : មគ្គុទ្ទេសក៍ជីវិត, បោះពុម្ពផ្សាយចែកជាធម្មទាន
- បណ្ឌិត ឱម ណោត្រី : ពុទ្ធប្បវត្តិនិទាន, បណ្ណាគារ ជីងហួនហួត ភ្នំពេញ, ១៩៥៤
- សម្តេច ជ.ណាត : វចនានុក្រមខ្មែរ, បោះពុម្ពលើកទី ៥ ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧-១៩៦៨
- សម្តេច ហួត តាត ពុទ្ធសាសនាសង្ខេប, បោះពុម្ពផ្សាយដោយពុទ្ធិកសមាគមកម្ពុជរដ្ឋ

# បញ្ញវន្តកម្ពុជា

## CAMBODIAN INTELLECTUALS

## មូលន័យសង្ខេប

**ឆយ យីហ៊ាង**

បណ្ឌិតទស្សនវិជ្ជា

គ្រប់ប្រទេសទាំងអស់នៅលើពិភពលោក សុទ្ធសឹងត្រូវការបញ្ញវន្តដើម្បីរួមចំណែកកសាង និងការពារជាតិ ។ ជាពិសេស នៅក្នុងយុគសម័យសាកលភាវូបនីយកម្មនេះ *មូលធនបញ្ញា ( intellectual capital )* ត្រូវចាត់ទុកជាកត្តាផលិតកម្មយ៉ាងសំខាន់មិនអាចខ្វះបាន ។

ដោយឡែក កម្ពុជាបានស្ថិតនៅឯកោអស់រយៈពេលយូរអង្វែង ។ បញ្ហានេះបានធ្វើឱ្យកម្ពុជាជួបប្រទះនឹងសេចក្តីក្រខ្សត់ លំបាកវេទនា ។ នៅក្នុងសភាពបែបនេះ កម្ពុជាត្រូវប្រឈមមុខចំពោះបញ្ហាស្មុគស្មាញដ៏ច្រើនអនេក ទោះបីកម្ពុជាបានដណ្តើមយកសន្តិភាពមកវិញ ក៏ដោយ ។

នៅចំពោះមុខតំរូវការនៃប្រទេសជាតិបែបនេះ យើងគួរចោទសួរដូចខាងក្រោម :

- *តើបញ្ញវន្តកម្ពុជា មានតួនាទីយ៉ាងណាខ្លះ ?*
- *តើបញ្ញវន្តកម្ពុជាត្រូវមានស្មារតីបែបណា មុននឹងធ្វើសកម្មភាព ?*
- *តើធ្វើដូចម្តេចដើម្បីបង្វែរសេចក្តីព្រងើយកន្តើយរបស់គេឱ្យក្លាយជាអាកប្បកិរិយាទទួលខុសត្រូវ នៅចំពោះមុខតំរូវការនៃប្រទេសជាតិ ?*

នេះជាសំនួរដែលបញ្ញវន្តយើងគួររួមចំណែកដោះស្រាយទាំងអស់គ្នា ។

***

# បញ្ហាខ្មែរកម្ពុជា

នៅក្នុងសម័យសង្គមរាស្ត្រនិយម យើងហាក់ដូចជាមិនជឿថា យើងមានរបបនយោបាយមួយថ្មីមកប្តូរជំនួសឡើយ ពីព្រោះពេលនោះ យើងបានទទួលឯករាជ្យពេញលេញ និងឈានទៅរកដំណោះស្រាយជីវភាពពលរដ្ឋគ្រប់របឱ្យកាន់តែប្រសើរឡើងជារៀងរាល់ថ្ងៃ ។ កត្តាធំបំផុតដែលយើងមានមោទនភាពជាតិនោះ គឺអព្យាក្រឹតភាព បូរណភាពដែនដី ឯករាជ្យម្ចាស់ការ និងជៀសផុតពីភាពជាអ្នករណបអ្នកដទៃ ។ យើងមានមូលដ្ឋានសាមគ្គីជាតិរឹងមាំ ដែលជាកត្តាជំរុញឱ្យកម្ពុជាមានឈ្មោះថា « *កោះសន្តិភាព* » ។

ប៉ុន្តែ មិនយូរប៉ុន្មាន មូលដ្ឋានសាមគ្គីជាតិនោះត្រូវបានបំផ្លិចបំផ្លាញ បង្កឱ្យមានរដ្ឋប្រហារនៅឆ្នាំ ១៩៧០ ដែលធ្វើឱ្យរបបមួយថ្មីមកប្តូរជំនួសរបបសង្គមរាស្ត្រនិយម ។ នោះជារបបសាធារណរដ្ឋខ្មែរ ដែលប្រកាន់និន្នាការស្តាំនិយម ។ ពេលនោះ អព្យាក្រឹតភាពត្រូវរលាយបាត់បង់ ។ របបនេះត្រូវប្រឆាំងជំទាស់ដោយកំលាំងដែលប្រកាន់និន្នាការឆ្វេងនិយម ។ កំលាំងស្តាំនិយមកាន់កាប់អំណាចក្នុងស្រុក ឯកំលាំងឆ្វេងនិយមតស៊ូប្រឆាំងពីក្នុងព្រៃ ។ ភាគីទាំងពីរសុទ្ធសឹងមានបង្អែកបរទេសដូចគ្នា ។ ភាគីម្ខាងអូសទាញប្រជាជនឱ្យដើរតាមមនោគមវិជ្ជារបស់ខ្លួន ។ សង្គ្រាមស៊ីវិលបង្ហូរឈាមរវាងបងប្អូនគ្នាឯងពីឆ្នាំ ១៩៧០ ដល់ ១៩៧៥ មានភាពក្តៅគគុកធ្វើឱ្យ « *កោះសន្តិភាព* » ក្លាយជា « *នគរសង្គ្រាម* » ទៅវិញ ហើយក្រោយមកអំណាចបានធ្លាក់ទៅក្នុងដៃចលនាឆ្វេងនិយម ។

អ្វីដែលហៅថា *កម្ពុជាប្រជាធិបតេយ្យ មហាលោតផ្លោះ មហាអស្ចារ្យ* តាមបែបវឿរវាយ បានឈានជើងមកជាន់ឈ្លីទឹកដីដ៏បវរនេះ ។ ពេលនោះគ្មាននៅសល់ពន្លឺតិចតួចនៃសិទ្ធិមានជីវិត សិទ្ធិមានសេរីភាព សិទ្ធិមានសុភមង្គល និងប្រជាធិបតេយ្យឡើយ ។ « *អង្គការ* » ដែលជាអធិរាជនៃរបបទាសភាពមានលក្ខណៈអរូបិ

ស្មុគស្មាញ ពិបាកស្វែងយល់ ។ ក្រោមឥទ្ធិពលរបស់ « *អង្គការ* » ជីវិតរបស់ពលរដ្ឋទាសករ ជាជីវិតខ្មៅងងឹតពោរពេញដោយទុទិដ្ឋិនិយម ។ សេចក្ដីអស់សង្ឃឹមនេះកាន់តែមានកម្រិតធ្ងន់ឡើងៗក្នុងរយៈពេល ៤ ឆ្នាំ ។

ប៉ុន្តែនៅខែធ្នូ ១៩៧៨ កងទ័ពរំដោះជាតិដែលដឹកនាំដោយវីរជនភ្នាក់រលឹក បានដាស់សតិស្មារតីឱ្យប្រជាជនក្រោកតស៊ូប្រឆាំងចំពោះ « *អង្គការ* » រហូតដល់ដណ្ដើមអំណាចបានពី « *អង្គការ* » មកវិញ ។ នេះជាប្រភពនៃការរស់ឡើងវិញរបស់ពលរដ្ឋដែលនៅសល់ពីការកាប់សម្លាប់ និងសល់ពីការស្លាប់ដោយអត់ឃ្លាន ។

នៅក្នុងសង្គ្រាមបង្ហូរឈាមគ្នាឯងបែបនេះ តើនរណាជាអ្នកទទួលជោគជ័យ ? តើនរណាជាអ្នកបរាជ័យ ? គ្មាននរណាបានទទួលជោគជ័យឡើយ គឺយើងបរាជ័យទាំងអស់គ្នា ។ យើងបរាជ័យទាំងអស់គ្នា ព្រោះយើងធ្លាក់ទៅក្នុងរបបប្រល័យពូជសាសន៍ ដែលធ្វើឱ្យរចនាសម្ព័ន្ធសង្គម ទាំងរចនាសម្ព័ន្ធក្រោម ទាំងរចនាសម្ព័ន្ធលើ វិនាសអន្តរាយគ្រប់វិស័យ ។ យើងគួរចោទសួរមួយសំនួរទៀតថា តើបញ្ញវន្តកម្ពុជា ជាអ្នករួមចំណែកធ្វើឱ្យខ្មែរទទួលបរាជ័យនេះដែរឬទេ ?

ចាប់ពីថ្ងៃទី ៧ មករា ១៩៧៩ មគ្គុទ្ទេសក៍ជាតិ និងពលរដ្ឋគ្រប់ស្រទាប់សង្គមបានរួបរួមគ្នាស្តារមាតុភូមិឡើងវិញ ។ ពលរដ្ឋកម្ពុជាគ្រប់ស្រទាប់សង្គមខិតខំពង្រឹងពង្រីកការងារដោយឧស្សាហ៍ព្យាយាម អង់អាចក្លាហាន ដើម្បីធ្វើឱ្យវិស័យនានារីកចំរើន ។ បើនិយាយអំពីវិស័យនយោបាយវិញ ទោះបីមានភាពរអាក់រអួលយ៉ាងក៏ដោយ ក៏មគ្គុទ្ទេសក៍នយោបាយនានា បានធ្វើដំណើរកាន់តែជិតគ្នា កាន់តែយោគយល់គ្នា ដោយខិតខំដោះស្រាយបញ្ហាបង្រួបបង្រួមជាតិ ។

ចំណែកឯប្រទីបនៃរបបប្រល័យពូជសាសន៍បានរលាយបាត់បង់ទៅហើយ ។ ប៉ុន្តែ កត្តាអវិជ្ជមានដ៏ច្រើនសន្ធឹកសន្ធាប់នៃរបបនេះ នៅតែបន្តមកដល់សព្វថ្ងៃ ហើយអាចនឹងបន្តទៅក្នុងអនាគត ដែលយើងទាំងអស់គ្នាត្រូវប្រឈមមុខ

ដោះស្រាយ ។ បញ្ហានេះ ក៏ត្រូវធ្លាក់មកលើបញ្ញវន្តយើងដែរ ។

បញ្ញ វន្ត ត្រូវបានសុគន្ធៈរួមចំណែកដោះស្រាយបញ្ហា ដែលកំពុងចោទឡើងនៅចំពោះមុខ ។ ដើម្បីរួមចំណែកដោះស្រាយបញ្ហាអវិជ្ជមានទាំងឡាយ តើគួរបញ្ញវន្តចាប់ផ្ដើមពីស្មារតីបែបណា ? នេះជាបញ្ហាដែលយើងគួរពិចារណាទាំងអស់គ្នា ។ យើងអាចឆ្លើយថា មុននឹងចាប់ផ្ដើមធ្វើអ្វីមួយ យើងត្រូវចាប់ផ្ដើមពីស្មារតីសន្តិភាពជាមុនសិន ។ នៅក្នុងវណ្ណកម្មដែលមានចំណងជើងថា « *សិល្បៈរស់នៅក្នុងសន្តិភាព* » លោក ពីយ៉េរ វ៉ី ( PIERRE WEIL ) ពោលថា : « *សង្គ្រាមទាំងឡាយចាប់ប្រភពពីស្មារតីរបស់មនុស្ស ហេតុនេះ មនុស្សត្រូវតែការពារសន្តិភាពនៅក្នុងស្មារតីរបស់គេដែរ* » ( *Les guerres prenant naissance dans l'esprit des hommes, c'est dans leur esprit que doivent être érigées les défenses de la paix* ) ( 5 page 3 ) ។ បើតាមន័យនេះ លោកពីយ៉េរ វ៉ី ចង់បញ្ជាក់ថា រាល់ដំណោះស្រាយដែលចាប់ប្រភពពីស្មារតីសង្គ្រាម ស្មារតីហិង្សា មិនអាចប្រព្រឹត្តទៅតាមបែបរីកចំរើនបានឡើយ ។

## I. <u>*បញ្ញវន្ត និងសច្ចភាព*</u> ( Intellectuals and Verity )

បញ្ញវន្ត គឺជាអ្នកប្រើកំលាំងបញ្ញាលើសសម្បទាដទៃទៀត ដែលខ្លួនមានដើម្បីបំពេញការងារផ្សេងៗ សំរាប់ជីវិតរស់នៅផង និងសំរាប់ស្វែងរកសច្ចភាពផង។ អ្នកនិពន្ធ សាស្ត្រាចារ្យ អ្នកប្រាជ្ញ ... ជាបញ្ញវន្ត ។ ហេតុនេះ គោលដៅធំបំផុតរបស់បញ្ញវន្ត គឺការប្រកបរបរអាជីវកម្មដោយផ្អែកលើបញ្ញាពលកម្ម និងការស្វែងរកសច្ចភាព បញ្ញាពលកម្ម និងសច្ចភាព ជាចរន្តជាពីរយ៉ាងសំរាប់ជីវិតបញ្ញវន្ត ។

ការស្វែងរកសច្ចភាព មិនមែនជាការងាយស្រួលទេ ។ ឥន្ទ្រិយញ្ញាណ (Connaissance sensorielle) វិចារណញ្ញាណ (Connaissance ration-

nelle) សុទ្ធសឹងជាពុទ្ធិដែលពិបាកឈានទៅដល់សច្ចភាព ។ ព្រោះអ្វី ? ព្រោះការខិតខំគិតត្រឹមត្រូវដើម្បីឈានទៅដល់សច្ចភាព មិនមែនកើតឡើងឯកឯងតាមបែបផែនដន្យទេ តែកើតឡើងដោយមានក្បួនខ្នាតត្រឹមត្រូវ ។ បើតាមតក្កវិជ្ជា សច្ចភាពចែកចេញជាពីរបែបគឺ សច្ចភាពទំរង់ ( Formal verity ) និងសច្ចភាពរូបធាតុ ( Material verity ) ។ សច្ចភាពទំរង់ កើតឡើងដោយការគិតស្របនឹងការគិតខ្លួនឯង ។ វាស្ថិតនៅក្នុងខួរក្បាលមនុស្ស ។ ឯសច្ចភាពរូបធាតុវិញ គឺជាសច្ចភាពកើតឡើងដោយការគិតស្របនឹងតថភាព ។ វាបោះជំហានចេញពីខួរក្បាលមនុស្សទៅរកអ្វីដែលមានពិត ។ ហេតុនេះហើយបានជាតក្កវិទូអះអាងថា : គ្រប់វិទ្យាសាស្ត្រទាំងអស់ត្រូវធ្វើឱ្យដំណើរស្របគ្នា ទាំងពីរនេះមានអត្ថិភាពអមតៈ ដើម្បីជាមូលដ្ឋាននៃការពិចារណាត្រឹមត្រូវ ប្រសិនបើវិទ្យាសាស្ត្រនោះចង់ការពារតួនាទីរបស់ខ្លួន ឱ្យនៅគង់វង្ស ។ តើប្រទេសជាតិនឹងខាតបង់អ្វីខ្លះទៅ បើប្រទេសនោះសំបូរទៅដោយបញ្ញវន្តដែលមូលបង្កាច់សច្ចភាព ?



បញ្ញវន្តផ្ទុយពីបាត្តករ ព្រោះបញ្ញវន្តផ្អែកលើបញ្ញាពលកម្មជាធំ ឯបាត្តករផ្អែកលើកាយពលកម្មជាធំ ។ បញ្ញវន្តខុសពីពាណិជ្ជករ ព្រោះបញ្ញាពលកម្មរបស់បញ្ញវន្តសំរាប់ស្វែងរកសច្ចភាព ឯបញ្ញាពលកម្មរបស់ពាណិជ្ជករ សំរាប់ស្វែងរកប្រាក់ចំណេញ ។

សព្វថ្ងៃ យើងមានបញ្ញវន្តដែលត្រូវបានបណ្តុះបណ្តាលពីមជ្ឈដ្ឋានផ្សេងៗគឺ :

- បញ្ញវន្តបណ្តុះបណ្តាលក្នុងប្រទេស តាមផ្លូវពុទ្ធចក្រ ( បញ្ញវន្តបព្វជិត )
- បញ្ញវន្តបណ្តុះបណ្តាលក្នុងប្រទេស តាមផ្លូវអាណាចក្រ
- បញ្ញវន្តបណ្តុះបណ្តាលនៅឯបរទេស
- បញ្ញវន្តបណ្តុះបណ្តាលនៅក្នុងប្រទេសផង និងបានទៅបន្តការសិក្សា ឬធ្វើកម្មសិក្សាប្រតិបត្តិ នៅឯបរទេសផង ។

## II. *បញ្ញវន្ត និងការចុះកិច្ចសន្យាបំពេញការងារក្នុងសង្គម*

Intellectuals and their contract of works in society

បញ្ញវន្តកម្ពុជាទាំងអស់បានធ្វើសហប្រតិបត្តិការដោយផ្ទាល់ ឬដោយប្រយោល ដោយចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលបំពេញភារកិច្ចរៀងៗខ្លួន នៅក្នុងវិស័យនានា ដើម្បីសេចក្តីរីកចំរើននៃប្រទេសជាតិ : វិស័យនយោបាយ អប់រំ វប្បធម៌ សង្គមកិច្ច សុខាភិបាល សេដ្ឋកិច្ច វិទ្យាសាស្ត្របច្ចេកទេស យោធា អង្គការក្រៅរដ្ឋាភិបាល និងសាសនា ... ។ នៅពេលដែលចាប់ផ្តើមកសាងមាតុប្រទេសពីកំរិតទាបបំផុត ( ពីឆ្នាំ ១៩៧៩ ) បញ្ញវន្តកម្ពុជាបានលើកពាក្យស្លោកមួយថា « *អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនទាន់ចេះ* » ។ នេះជាពាក្យស្លោកដែលមានតម្លៃអប់រំ តម្លៃវប្បធម៌ និងតម្លៃនយោបាយ ដែលធ្វើឱ្យកម្ពុជា

ជឿសផុតពីភាពងងឹតសូន្យនៅគ្រានោះ ។ ដោយសារការអនុវត្តតាមពាក្យស្លោកនេះហើយ ទើបកម្ពុជាត្រូវបានស្តារជាបណ្តើរៗខាងវិស័យវិទ្យាសាស្ត្រដែលកំពុងឈាននៅរកគុណភាពដូចសព្វថ្ងៃនេះ ។ នៅក្នុងករណីយកិច្ច និងភារកិច្ចរបស់ខ្លួនបញ្ញវន្តកម្ពុជា មានគុណសម្បត្តិដ៏ច្រើនក្នុងការរួមចំណែកស្តារ កសាង និងការពារមាតុភូមិ ។ ការណ៍នោះ ផ្តើមចេញពីឆន្ទៈដ៏មោះមុត និងសកម្មភាពដ៏ល្អប្រសើរនៅក្នុងមុខរបរប្រចាំថ្ងៃរបស់ខ្លួន ក្នុងនាមជាកុលបុត្រកុលធីតាកម្ពុជា ។ ប៉ុន្តែ ដោយសារស្ថានការណ៍ដែលមានកង្វះខាតខាងផ្នែកជីវភាព បញ្ញ វន្តមួយចំនួនបានធ្លាក់ទៅក្នុងគុណវិបត្តិយ៉ាងច្រើន ហើយហាក់ដូចជាលះបង់សេចក្តីថ្លៃថ្នូរ ដើម្បីរត់ទៅរកកំលាំងសម្ភារៈ ដែលងបង្កឡើងដោយអំពើពុករលួយទៅវិញ ។ នេះជាប្រការដែលគួរឱ្យស្តាយ ដែលគួរកែលំអឡើងវិញឱ្យទាន់ពេលវេលា ។

នៅពេលដែលចាប់ផ្តើមចូលសតវត្សទី ២១ នេះ រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា មានសំណូមពរចាំបាច់ដើម្បីឱ្យបញ្ញវន្តខិតខំរួមចំណែកស្តាបនាជាតិឱ្យកម្ពុជាក្លាយជាប្រទេសជឿនលឿន ដូចដែលយើងធ្លាប់មាននៅសម័យមហានគរ ។ ដើម្បីរួមចំណែកស្ថាបនាជាតិ គួរបញ្ញវន្តយើងពិចារណាកត្តាចំបងពីរគឺ ៖ សភាពការណ៍ជាក់ស្តែងនៅក្នុងសាកលលោក និងសភាពការណ៍ជាក់ស្តែងនៅក្នុងមាតុភូមិ កត្តាទាំងពីរនេះមានអន្តរកម្ម ដែលមិនអាចកាត់ផ្តាច់បានឡើយ ។

## III. *សភាពការណ៍សាកលលោក និងសភាពការណ៍កម្ពុជា*

World situation and Cambodia situation

សាកលលោកកំពុងស្ថិតនៅក្នុងបរិវត្តន៍ ( World in mutation ) ដែលនៅក្នុងនោះមានប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសឆ្លងទៅរកអភិវឌ្ឍន៍ ។ កាសែត វិទ្យុ ទូរទស្សន៍ ខ្សែភាពយន្ត ខ្សែវីដេអូ ក្រដាសបិទ

ផ្សាយ អ៊ីមែល អ៊ិនធឺរណេត ។ល។ កំពុងតែធ្វើឱ្យពិភពលោកកាន់តែរួញតូចទៅៗ នៅត្រឹមតែជាភូមិធំមួយប៉ុណ្ណោះ ។ លោក សាពួរ រ៉ាសិច ( SHAPOUR RASSEKH ) អតីតសាស្ត្រាចារ្យនៅសាកលវិទ្យាល័យតេហេរ៉ង់ ( Université de TÉHÉRAN) ជាអ្នកផ្តល់យោបល់នៅយូណេស្កូ (UNESCO) ពោលថា : ទិដ្ឋភាពដ៏សំខាន់មួយនៃបំលាស់ប្តូរបច្ចេកវិទ្យា ដែលជាបញ្ហាលេចធ្លោឡើងគឺ បដិវត្តន៍គមនាគមន៍ ដែលកំពុងបំព្រួញពិភពលោកឱ្យនៅត្រឹមតែជាភូមិធំមួយប៉ុណ្ណោះ ( 4 page 11 ) ។ គេកត់សំគាល់ឃើញថា យុគសម័យពិភពលោក គឺជាយុគសម័យសាកលភាវូបនីយកម្ម ( The emerging age of globalization ) ដែលគ្មានប្រទេសណាមួយអាចជៀសផុតពីឥទ្ធិពលរបស់វាឡើយ ។

កម្ពុជាដែលធ្លាប់នៅឯកោជិត ៣១ ឆ្នាំ បានក្លាយជាសមាជិកនៃសបាគមន៍អាស៊ាន ( ASEAN ) ក្នុងពេលថ្មីៗនេះ ។ បើសិនកម្ពុជាស្ថិតនៅក្រៅប្រព័ន្ធសាកលភាវូបនីយកម្ម កម្ពុជានឹងរស់នៅយ៉ាងត្រដាបត្រដួសក្នុងទុគ្គតភាព ។ ប៉ុន្តែ នៅពេលដែលកម្ពុជាព្រមទទួលឥទ្ធិពលនៃប្រព័ន្ធសាកលភាវូបនីយកម្មនេះ កម្ពុជាត្រូវទទួលរងនូវឥទ្ធិពលល្អផង និងអាក្រក់ផង ។ ឥទ្ធិពលល្អ គឺឥទ្ធិពលវិទ្យាសាស្ត្របច្ចេកទេស និងវប្បធម៌ ដែលឈានទៅរកទំនោររីកចំរើន ឯឥទ្ធិពលអាក្រក់ គឺឥទ្ធិពលវិទ្យាសាស្ត្របច្ចេកទេស និងវប្បធម៌ ដែលឈានទៅរកទំនោរប្រតិកិរិយា ។

ដើម្បីរួមរស់ជាសន្តិសហវិជ្ជមាននៅក្នុងពិភពលោក យើងត្រូវការចាំបាច់នូវកត្តាមួយចំនួនគឺ :

- សន្តិភាពពិតប្រាកដ និងស្ថិរភាពសង្គម
- ធនធានមនុស្សដែលមានសមត្ថភាពបច្ចេកទេស និងសមត្ថភាពសីលធម៌ ដោយគិតតាំងពីពលករផលិតកម្មឡើងទៅ ។
- ស្មារតីលើកតំកើងផលប្រយោជន៍ជាតិ និងស្មារតីលើកតំកើងសិទ្ធិសេរី

ភាពប្រជាធិបតេយ្យ ។

ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា : ... បញ្ហាប្រឈមសំរាប់ប្រទេសទាំងអស់ក្នុងពេលបច្ចុប្បន្ននេះ គឺការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលភាពនៃសាកលភាវូបនីយកម្ម ដើម្បីកែលំអនូវកំរិតជីវភាពរបស់ប្រជាជនគ្រប់រូប ជាពិសេសគឺ កែលំអជីវភាពរបស់ជនក្រីក្រ ( 2 page 15 ) ។

## IV. *សំណូមពរចាំបាច់ដើម្បីស្ថាបនា*

Necessary proposition for development

ដើម្បីបំពេញបាននូវភារកិច្ច និងតួនាទីដ៏សំខាន់របស់ខ្លួន គួរបញ្ញវន្តយើងសម្របខ្លួនក្នុងសង្គម ដោយបញ្ចូលខ្លួនទៅក្នុងជីវភាពរស់នៅរបស់ប្រជាជន លើកតំកើងកំរិតយល់ដឹងរបស់ប្រជាជន ឱ្យប្រជាជនមានមោទនភាពជាតិចំពោះអរិយធម៌របស់យើង និងបង្ហាញគ្រប់មជ្ឈដ្ឋានឱ្យមើលឃើញ និងយល់ច្បាស់ អំពីអត្ថន័យ និងខ្លឹមសារនៃការអប់រំ និងវប្បធម៌សន្តិភាព ( Education and culture of peace ) ដែលជាប្រទីបដ៏ថ្លៃថ្លាបំផុត ដែលពិភពលោកចង់បាន ។ នៅក្នុងសន្និសីទអន្តរជាតិលើកទី ៤៤ ស្តីពីការអប់រំ នាឆ្នាំ ១៩៩៤ ដែលបានរៀបចំដោយយូណេស្កូ ( UNESCO ) គេបានលើកឡើងថា : គោលដៅសំខាន់នៃការអប់រំដើម្បីសន្តិភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ គឺអភិវឌ្ឍនៅក្នុងមនុស្សម្នាក់ៗ នូវន័យតំលៃសាកល និងគំរូអាកប្បកិរិយាដែលជាបង្អែកសំរាប់កសាងវប្បធម៌សន្តិភាព ( 4 page 13) ។ បញ្ញវន្តយើង ពិតជាមានលទ្ធភាពផ្តល់ជូនប្រជាពលរដ្ឋ នូវទស្សនៈស្តីពីសន្តិភាពនេះ ។ អេពីគួរ ( Epicure ) ដែលជាទស្សនវិទូក្រិកបុរាណសម័យមួយរូបបានពោលថា : « *នៅចំពោះភាពចាំបាច់នៃជីត វិញ្ញូត្រូវចេះផ្តល់ឱ្យអ្នកដទៃ ជាង*

*យកពីអ្នកដទៃមកវិញ* " *( Le sage confromté aux nécessités de la vie, sait plutôt donner que prendre )* ( 3 page 33 ) ។ ការផ្តល់នៅទីនេះ មិនមែនផ្តល់សម្ភារៈទេ តែជាការផ្តល់ចំណេះដឹង ។ គឺការផ្តល់ពុទ្ធិទៅដល់ប្រជា-ជន នេះហើយដែលធ្វើឱ្យគេក្លាយជាពលរដ្ឋថ្លៃថ្នូរ មានប្រយោជន៍សំរាប់សង្គមជាតិ ។

បើយើងក្រឡេកមើលប្រវត្តិដើមរបស់យើង យើងឃើញថា នៅសម័យសង្គមរាស្ត្រនិយម និងសម័យសាធារណរដ្ឋខ្មែរ បញ្ញ វន្តមាននិន្នាការនយោបាយបីយ៉ាង ដោយផ្អែកលើមនោគមវិជ្ជាអព្យាក្រឹត មនោគមវិជ្ជាសេរីនិយម និងមនោគមវិជ្ជាសង្គមនិយម ។ អំនួតមនោគមវិជ្ជាសេរីនិយម និងអំនួតមនោគមវិជ្ជាសង្គមនិយម ជាដៃគូប្រណាំងប្រជែង យោលទៅតាមការប្រណាំងប្រជែងនៃប្រព័ន្ធមូល-ធននិយម និងប្រព័ន្ធសង្គមនិយមលើពិភពលោក ។ ប្រព័ន្ធទាំងពីរនេះ ដណ្តើមអំណាចត្រួតនៅលើពិភពលោក ក្នុងវិស័យសេដ្ឋកិច្ច នយោបាយ និងយោធា ... ។ យើងបានចូលទៅក្នុងពិភពអព្យាក្រឹត ប៉ុន្តែ អព្យាក្រឹតនោះត្រូវរង្គោះរង្គើដល់ឫសគល់ ព្រោះយើងងាកទៅរកសង្គមនិយម ឬទៅរកមូលធននិយម ។ គឺពេលនោះហើយ ដែលមនោគមវិជ្ជាជាតិចុះខ្សោយយ៉ាងខ្លាំង ដោយទុកឱ្យមនោគមវិជ្ជាពីរទៀតលេចខ្ពស់ឡើង ហើយបង្កឱ្យមានសង្គ្រាមស៊ីវិលយ៉ាងល្វីងជូរចត់ ដែលគួរឱ្យខ្លាសអៀនជាទីបំផុត ។ តើនរណា ជាអ្នកធ្វើឱ្យមនោគមវិជ្ជាសេរីនិយមលេចឡើង? តើនរណា ជាអ្នកធ្វើឱ្យមនោគមវិជ្ជាសង្គមនិយមលេចឡើង ? តើនរណា ជាអ្នកទទួលយកមនោគមវិជ្ជាទាំងនោះមកអនុវត្តនៅកម្ពុជា ? យើងអាចឆ្លើយថា បញ្ញវន្តដែលជាអ្នកចេះដឹងច្រើន បានទទួលយកមុនគេនូវមនោគមវិជ្ជាទាំងនោះ តាមរយៈសំដីនិយាយ ឬតាមរយៈសំនេរ ។ នេះជាមេរៀនដែលគួរឱ្យពិចារណាឡើងវិញ ។ នេះ ក៏ជាមេរៀនដែលយុវបញ្ញវន្តគួរជៀសវាង ។

តាមពិត យើងមិនអាចស្ថិតនៅអព្យាក្រឹតដាច់ដោយឡែកបរិសុទ្ធ មិន

ទទួលឥទ្ធិពលពីសាកលភាវូបនីយកម្មបានឡើយ ។ ប៉ុន្តែ បញ្ហាសំខាន់ គឺការចេះកែច្នៃ យកកត្តាសកម្មភាពរបស់មនោគមវិជ្ជានេះ ធ្វើឱ្យមានលក្ខណៈសមស្របនឹងទំនៀម ទម្លាប់ប្រពៃណីរបស់យើង ដើម្បីដើរឱ្យចំទិសដៅនៃនិន្នាការរីកចំរើន ។ ពេលនេះ យើងវិលមករកសភាពរួបរួមវិញហើយ ។ លោក **កៅ គីមហួន** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិ និងសន្តិភាព ( CICP ) ពោលថា ៖ រាជរដ្ឋាភិបាល ថ្មីក្នុងអាណត្តិទី ២ ឆ្នាំ ១៩៩៨ - ២០០៣ មានបំណងបញ្ចប់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃ រប៉េះ រប៉ោះក្នុងទូទាំងប្រទេស ដើម្បីធានាឱ្យបាននូវស្ថិរភាព និងសន្តិភាព ទាំងពីរនេះគឺជា តំរូវការមិនអាចខ្វះបាន សំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិ និងការចូលរួមក្នុងតំបន់ អាស៊ាន ( ASEAN ) ( 1 page 6 ) ។ នេះជាសុឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុង អាណត្តិទី ២ ហើយក៏ជាឱកាសដ៏ល្អប្រសើរ សំរាប់បញ្ញវន្តកម្ពុជាទាំងអស់ ទាំងនៅ ក្នុងប្រទេស ទាំងនៅក្រៅប្រទេស ដើម្បីរួបរួមគ្នាកសាងមាតុភូមិ ស្វែងរកសុភ-មង្គលជូនជាតិ ។ សព្វថ្ងៃ មនោគមវិជ្ជាពិភពលោក គឺការអប់រំ និងវប្បធម៌សន្តិភាព ។ ប្រព័ន្ធមូលធននិយម និងប្រព័ន្ធសង្គមនិយមកាន់តែសាបរលាប ដែលធ្វើឱ្យពិភព លោកឈានទៅរកឯកភាពមួយ ។ ចំពោះយើងវិញ យើងមានអង្គការនីតិបញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងអំណាចតុលាការ យើងមានស្ថាប័នជាច្រើនដែលស្ថិតនៅ ក្រោមអង្គការកំពូល គឺច្បាប់រដ្ឋធម្មនុញ្ញ ។ យើងដណ្តើមបានសន្តិភាពមកវិញ ។ នេះជាបញ្ហាងាយស្រួលសំរាប់បំពេញការងាររបស់យើង ។ ប៉ុន្តែ មិនត្រូវភ្លេចថា ការ ដណ្តើមបានសន្តិភាពមកវិញ គឺជាការលំបាកណាស់ តែការលំបាកជាងនេះទៅទៀត គឺការការពារអ្វីដែលយើដណ្តើមបាន ជាពិសេស បញ្ហាសន្តិភាពនោះ ។ ហេតុនេះ យើងអាចនិយាយថា ពេលនេះជាឱកាសល្អប្រសើរសំរាប់បញ្ញវន្តកម្ពុជា ដើម្បីរួបរួម គ្នាកសាងប្រទេសជាតិឱ្យកាន់តែជឿនលឿន ។ ភារកិច្ចចំពោះមុខរបស់យើង គឺរួម ចំណែកកែលំអអ្វីៗដែលមិនទាន់មានលក្ខណៈសមស្រប ឱ្យមានលក្ខណៈជឿនលឿន

តាមបែបលទ្ធិប្រជាធិបតេយ្យ និងឈានទៅដល់នីតិរដ្ឋ ។ ការបង្រួបបង្រួមបញ្ញវន្ត ដើម្បីបំផុសស្មារតីជាតិ ផ្អែកលើមនោគមវិជ្ជាជាតិ តែឥតចង្អៀតចង្អល់ មានមោទនភាពជាតិ តែឥតមើលស្រាលចំពោះជាតិដទៃ ស្ម័គ្រចិត្តរួមរស់ជាមួយសហគមន៍អន្តរជាតិតាមបែបសន្តិសហវិជ្ជមាន គឺពិតជាធ្វើឱ្យប្រទេសជាតិទទួលជោគជ័យក្នុងឆាកអន្តរជាតិ ។ ឯកឧត្តម គាត ឈន់ បានគូសបញ្ជាក់ថា : *មូលធនបញ្ញា ( Intellectual capital )* បានក្លាយទៅជាកត្តាផលិតកម្មដ៏សំខាន់បំផុត ។ ... នៅក្នុងបរិការណ៍នេះ *មូលធនមនុស្ស ( Human capital )* ដែលប្រកបទៅដោយសមត្ថភាពជំនាញខ្ពស់ និងប្រកបទៅដោយនិម្មិតកម្ម គឺជាកត្តាសំខាន់បំផុត ដែលធានានូវភាពប្រជែងឈ្នះរបស់ប្រទេសជាតិ ( 2 page 5 ) ។

ជាសេចក្តីសង្ខេប យើងឃើញថា កម្ពុជាត្រូវការចាំបាច់ បន្ទាន់នូវបញ្ញវន្តជាតិ ដែលមានទស្សនៈជឿនលឿន អង់អាចក្លាហាន ពុះពារគ្រប់ឧបសគ្គ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល រួមចំណែកជាមួយពលករផលិតកម្មផ្សេងៗ ពង្រឹង និងពង្រីកស្ថិរភាពសង្គម និងសន្តិភាព ដែលកំពុងមានសព្វថ្ងៃនេះ ។ ភារកិច្ចចំពោះមុខគឺផ្សារភ្ជាប់ឡើងវិញ នូវអត្តសញ្ញាណជាតិខ្មែរ ដែលបានបែកបាក់តាំងពីក្រោយសម័យមហានគរ ដើម្បីឯករាជ្យ អធិបតេយ្យភាព និងបូរណភាពដែនដី និងលើកតំកើងកិត្តិយសនៅក្នុងឆាកអន្តរជាតិ ។ នៅក្នុងគ្រប់សន្និសីទ សិក្ខាសាលា ការប្រជុំស្តីពីបញ្ហា និងកសាងកម្ពុជាឡើងវិញ យើងតែងតែឮសូរពាក្យត្អូញត្អែរស្តាយស្រណោះចំពោះការបាត់បង់អ្វី ដែលយើងធ្លាប់រុងរឿងពីសម័យមុន ។ ការស្តាយស្រណោះនេះជាបុព្វហេតុមួយ ក្នុងចំណោមបុព្វហេតុជាច្រើន ដែលធ្វើឱ្យយើងស្វែងរកផលក្នុងការពង្រឹងពង្រីកមនោគមវិជ្ជា ដែលមិនមានលក្ខណៈចង្អៀតចង្អល់ ។ ដូចបានពោលខាងលើហើយថា កម្ពុជាមិនអាចបិទទ្វារជិតឈឹងនៅតែម្នាក់ឯងទៀតឡើយ ។ កម្ពុជាត្រូវតែបើកទ្វារចំហទៅរកពិភពខាងក្រៅ ។ ការបើកចំហបែបនេះ

កម្ពុជាត្រូវទទួលរងនូវ "*ការទ្រាំទ្រនៅក្នុងយុគសម័យនៃសាកលភាវូបនីយកម្ម* » ( *Sustainability in the emerging age of globalization* ) ។ ហេតុនេះ កម្ពុជាត្រូវឆ្លៀតប្រើប្រាស់ឱ្យអស់នូវសក្តានុពលភាព នៃសាកលភាវូបនីយកម្មផង និងខិតខំជៀសឥទ្ធិពលអាក្រក់របស់វាផង ។ ទង្វើបែបនេះ ត្រូវធ្លាក់ទៅលើបញ្ញា-ពលកម្ម ដែលក្នុងនោះបញ្ញវន្តជាអ្នកដើរតួយ៉ាងសំខាន់ ។

**ចិញ្ចមិនអះអាងពីអ្វីដែលមិនបានបញ្ជាក់ភស្តុតាងឡើយ**
**( Le sage n'affirme rien qu'il ne prouve )**

## ឯកសារពិគ្រោះ (References)


1. កៅ គីមហួន , សំរាំងកំសាន្ត : *ទស្សនៈមួយចំនួនស្តីពីការដឹកនាំរួម និងការស្ថាបនាជំនឿទុកចិត្តនៅប្រទេសកម្ពុជា* ( ១៩៩៣-១៩៩៨ អត្ថបទថ្ងៃទី ១៨ មីនា ១៩៩៨ នៅសណ្ឋាគារ សូហ្វីតែល កាំបូឌីយ៉ាណា ) ។

2- គាត ឈន់ , អ៊ួន ព័ន្ធមុនីរត្ន, វង្សី វិស្សុត : *គ្រប់គ្រងបញ្ហាប្រឈមនៃសាកលភាវូបនីយកម្ម* វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ភ្នំពេញ មករា ១៩៩៩ ។

3- Guillon (Emmanuel) : *Introduction à la philosophie,* Hatier, Paris, 1984

4- Rassekh ( Shapour ) : *Éducation et Culture de la paix,* Édition Slakine, UNESCO, 1996

5- Weil (Pierre) : *L'art de vivre en paix,* vers une nouvelle conscience de la paix, UNESCO, Paris, 1990.

# ស្មារតីខ្មែរ និង ព្រះពុទ្ធសាសនា

បណ្ឌិត **ខុត ធីភា**
នាយិការងនៃមហាវិទ្យាល័យទស្សនវិជ្ជា
( សកលវិទ្យាល័យភូមិន្ទ ភ្នំពេញ ២ )

## ១. កម្ពុជា

### ក. *ទីតាំង*

ប្រទេសកម្ពុជាស្ថិតនៅទ្វីបអាស៊ីអាគ្នេយ៍ ត្រង់ភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន ចន្លោះខ្សែស្របទី ១០ និងទី ១៥ នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្ដោយទី ១០២ និងទី ១០៨ នៃរយៈបណ្ដោយខាងកើត ។ ដូចនេះ ប្រទេសកម្ពុជានៅក្នុងតំបន់ត្រូពិក ត្រង់អឌ្ឍគោលខាងជើង ដែលជាតំបន់ដីមានជីជាតិ ហើយមានអំណោយផលដល់ការលូតលាស់នៃរុក្ខជាតិ និងដំណាំផ្សេងៗគ្រប់ប្រភេទ ។ កម្ពុជាមានរាងជាពហុកោណស្ទើរស្មើជ្រុង មានព្រំប្រទល់ខាងជើងជាប់ប្រទេសថៃ ហើយមួយភាគធំជាប់នឹងប្រទេសឡាវខាងកើត និងខាងត្បូង មួយភាគជាប់នឹងប្រទេសវៀតណាមខាងត្បូង មួយភាគទៀត ជាប់នឹងឈូងសមុទ្រថៃ ខាងលិចជាប់នឹងឈូងសមុទ្រថៃ ហើយមួយភាគទៀត ជាប់នឹងប្រទេសថៃ ។

### ខ. *ផ្ទៃដី*

ប្រទេសកម្ពុជាមានផ្ទៃក្រឡា ១៨១.០៣៥ គ.ម[២] ។

### គ. *ប្រជាជន*

ចំនួនប្រជាជននៅកម្ពុជា តាមអ្នកប្រាជ្ញខាងជាតិពន្ធុវិទ្យាបានសន្និដ្ឋានថាពួក*អូស្ត្រាឡូអ៊ីដ* និងពួក*មេឡានេស៊ី* សម្បុរខ្មៅ បានមកនៅឥណ្ឌូចិនតាំងពីច្រើន

ស.វ.មុនគ.ស.ម្ល៉េះ ។ បន្ទាប់មក មានពួកឥណ្ឌូនេស៊ី ជាជនជាតិស្បែកលឿង ចូលមកនៅលាយឡំនឹងប្រជាជនចាស់ បង្កបង្កើតឡើងជាជនជាតិសាសន៍មន-ខ្មែរ ។ ក្រោយមក មានពួកឥណ្ឌាជាអ្នកជំនួញ ជាអ្នកភៀសខ្លួនពីសង្គ្រាម និងជាអ្នកផ្សាយសាសនា បានមករស់នៅលាយឡំជាមួយម្ចាស់ស្រុកដើម បង្កបង្កើតបានជាអរិយ-ធម៌មួយ ។ តែពួកកុលសម្ពន្ធខ្លះ ពុំព្រមទទួលយកនូវបញ្ហាទាំងនេះ ពួកគេក៏ទៅរស់នៅតំបន់ដាច់ពីគេ ហើយមានសេសសល់រហូតដល់សព្វថ្ងៃនេះ ។ ក្រោយមកទៀតមានជាតិសាសន៍ផ្សេងៗ បានមករស់នៅជាបន្តបន្ទាប់ ដូចជា ជាតិជ្វា ព្រាហ្មណ៍ ( ស.វ.ទី ៨ ) ជាតិចិន ( ស.វ.ទី ១៣ ) វៀតណាម ឡាវ ចាម ភូមា ជាដើម ។ ហេតុនេះបានជាគេឃើញមានមនុស្សផ្សេងៗគ្នាជាច្រើន រស់នៅលើទឹកដីកម្ពុជា ។ ស្ថិតិប្រជាជនកម្ពុជា ក្នុងឆ្នាំ ១៩៦២ មានចំនួន ៥.៧២៨.៧៧១ នាក់ ក្នុងនោះមានជនជាតិខ្មែរ ប្រហែលជា ៥ ភាគ ៦ (*) ។

**ឃ.** *ជនជាតិផ្សេងៗ ក្រៅពីជនជាតិខ្មែរមាន*

- ពួកកុលសម្ព័ន្ធ មានច្រើនក្រុម ដូចជាពួកព័រ ស្ទូច សំរែ កួយ ស្មៀង ព្នង ។ ពួកគេរស់នៅដាច់ស្រយាលពីគេ, ប្រកបអាជីវកម្មប្រមាញ់ នេសាទ និងកសិកម្មនៅព្រៃដុត ។

- ពួកចំណូលស្រុក ឬខ្មែរចូលជាតិ ជាប្រជាជនដែលមករស់នៅក្នុងប្រទេសកម្ពុជាជាយូរយាណាស់មកហើយ មានសិទ្ធិ និងកាតព្វកិច្ចដូចខ្មែរដែរ ។ ជនជាតិទាំងនេះមានចាម ជ្វា ឡាវ វៀតណាម និងភូមា ... ។

## ២. តើខ្មែរជានរណា ?

ជាយូរយារណាស់មកហើយ អ្នកធ្វើការសិក្សាស្រាវជ្រាវខ្មែរ បានខិតខំ

(*) លោក កាន់ ក័ន ស្គាល់ ជីវប្រជាជនពិភពលោក ភ្នំពេញ ១៩៨៤ ទំព័រ ៤៨

ដោះស្រាយបញ្ហាកំណើតខ្មែរនេះ ។ ពួកគេបានបញ្ចេញយោបល់ប្លែកៗគ្នា ហើយជួនកាលផ្ទុយស្រឡះតែម្តង ។ ប៉ុន្តែ យោបល់ទាំងនោះអាចចែកជាពីរក្រុម គឺ :

*ក. យោបល់ទី ១*

ពួកគេទទួលថាជាតិខ្មែរ ជាជាតិប្រវេសន៍ ( Race Immigré ) ចេញពីប្រទេសឥណ្ឌា ហើយបានលុកលុយដណ្តើមយកទឹកដីរបស់ជាតិដើមមួយ ( Race Autochtone ) គឺជនជាតិក្នុងអំបូរម៉ាឡាយូប៉ូលីណេស៊ីយ៉េន ( Race Malayo-polynésienne ) នេះឯង ។ ទស្សនះនេះ ត្រូវបានបង្កើតឡើងមុនគេ ដោយលោក Hendrike Kerne ។ បន្ទាប់មកទៀត ក៏មានអ្នកស្រាវជ្រាវខ្លះយល់ស្របតាម ដូចជាលោក Adhémard Leclère និងលោក Pierre Gourou ជាដើម ។ លោក Pierre Gourou បានបញ្ជាក់ថា ជនជាតិខ្មែរប្រហែលជាត្រូវពួក *ទ្រាវិឌ* ឬពួក*អារ្យ* ច្រានចេញពីឥណ្ឌា ហើយដោយមានសេសសល់ក្រុមខ្លះ ដូចជាពួកមុណ្ឌ បានមកលុកលុយប្រទេសភូមា ប្រទេសសៀម និងប្រទេសកម្ពុជា ។ លោក Etienne Aymonier ដែលយល់ថាក្រុម មន-ខ្មែរ មណ្ឌមានតាំងពីដើម នៅជើងភ្នំទីបេត៍ ហើយក្រោយមកបានបំបែកជាពីរក្រុម គឺ *មន-ខ្មែរ* ចូលមកតាំងនៅភូមិភាគអាស៊ីអាគ្នេយ៍ ឯមួយក្រុមទៀតគឺមណ្ឌ ចូលទៅនៅក្នុងប្រទេសឥណ្ឌា រហូតដល់សព្វថ្ងៃ ។

*ខ. យោបល់ទី ២*

ទទួលស្គាល់ថា ជនជាតិខ្មែរជាជនជាតិមួយស្ថិតនៅក្នុងក្រុម មន-ខ្មែរ ហើយបានកើតឡើងនៅភូមិភាគអាស៊ីអាគ្នេយ៍នេះ តាំងពីបុរាណមក ។ នេះគឺជាយោបល់របស់លោក Bernard Philiffe Groslier បច្ចុប្បន្ន ជាអភិរក្សអង្គរ និងលោក Mace Talahot ជាដើម ។

លោកទាំងពីរនេះបានយល់ឃើញថា ក្នុងសម័យ ឱណ្យ ប្រវត្តិសាស្ត្រ ដ៏

យូរលង់ណាស់មកហើយ មានមនុស្សជាច្រើនក្រុមបានធ្វើដំណើរពីខាងជើងចុះមកភាគអាស៊ីអាគ្នេយ៍ ដូចពួក អូស្ត្រាឡូអ៊ីដ (Autraloïdes) មេឡានេស៊ីយាង (Mélanésiens) ។ អំបូរមន-ខ្មែរ បានកើតឡើងដោយការកាត់ផ្សំរវាងពួកឥណ្ឌូនេស៊ីយាង និងមេឡានេស៊ីយាង ហើយបានរស់នៅរាយប៉ាយលើទឹកដី ដែលលាតសន្ធឹងពីឥណ្ឌូចិនជ្រោយម៉ាឡាយូរ រហូតដល់ព្រំប្រទល់ប្រទេសឥណ្ឌា ។

គួរកត់សំគាល់ថា យោបល់នៃក្រុមទាំងពីរនេះ មានលក្ខណៈស្របទៅនឹងទស្សនៈរបស់ខ្មែរ ពីព្រោះបើយើងសំអាងទៅលើរឿងព្រេងខ្មែរ ដោយសារតែមាន *នាងនាគ* នៅស្រុកខ្មែរនេះឯងទើប *ព្រះថោង* ដែលគេថាមកពីស្រុកឥណ្ឌា បានជួបប្រភពគ្នា ហើយបានគ្រប់គ្រងស្រុក *គោកធ្លក* នេះឯង ។ បានសេចក្ដីថា លុះត្រាតែមានជនជាតិខ្មែរនៅលើកោះគោកធ្លកនេះដែរ ទើបឥណ្ឌាអាចផ្សាយអរិយធម៌របស់ខ្លួនបានខ្លះចូលស្រុកខ្មែរ ។

សេចក្ដីក្នុងរឿងព្រេងនេះសរឱ្យយើងឃើញថា ចំពោះខ្មែរយើង ជាតិខ្មែរមានប្រភពនៅស្រុកខ្មែរនេះឯង ។ ចំពោះបញ្ហាដើមកំណើតនៃជាតិសាសន៍ខ្មែរនេះ អ្នកប្រាជ្ញអន្តរជាតិបានបញ្ចេញសម្មតិកម្មច្រើនបែបយ៉ាងណាស់ ។ តែលោកបានស្របយោបល់គ្នាត្រង់ចំណុចដែលថា ខ្មែរជាជនជាតិមួយស្ថិតនៅក្នុងអំបូរពិសេសមួយ គឺអំបូរមន-ខ្មែរ ឬខម នេះឯង (*) ។

ថ្មីៗនេះ លោកបណ្ឌិត *មីសែល ត្រាណេ* លោកជាអ្នកស្រាវជ្រាវវប្បធម៌ខ្មែរ ស្នាដៃរបស់លោកសមស្របជាមួយមតិទី ២ គឺលោកបានបញ្ជាក់ថា ខ្មែរមានជីវិតលើទឹកដីខ្មែរតាំងពី ៦៨០.០០០ ឆ្នាំមុនគ.ស មកដល់ស.វ.ទី ១ នៃគ.ស ។ សម័យនេះ ជាសម័យថ្មគ្រួសបំបែក ដែលមានអាយុ ៦៨០.០០០ ដល់ឆ្នាំ ១២០.០០០

(*) លោកស្រី ត្រឹង ងា **អរិយធម៌ខ្មែរ** ភ្នំពេញ ទំព័រ ២

ឆ្នាំ មុនគ.ស ។ យុគនេះអាចជាការចាប់ផ្ដើមនៃអារ្យធម៌ខ្មែរ ហើយការចងក្រងទំព័រប្រវត្តិសាស្រ្តកម្ពុជា ត្រូវស្ថិតនៅលើសម្ភារៈវប្បធម៌កម្ពុជាដំបូងបង្អស់ ជាមូលដ្ឋាន (*) ។

វប្បធម៌ អរិយធម៌ខ្មែរ ដូចបានបញ្ជាក់ជូនខាងលើ ក៏អាចបង្ហាញឱ្យអ្នកសិក្សាស្រាវជ្រាវវិភាគបានពីប្រភពព្រះពុទ្ធសាសនា នៅកម្ពុជាដែរ ។

## ៣. ប្រភព និងកាលបរិច្ឆេទព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា

ដូចយើងបានបញ្ជាក់ខាងលើមកហើយថា ព្រះពុទ្ធសាសនា មានដើមកំណើតនៅប្រទេសឥណ្ឌា ហើយត្រូវផ្សព្វផ្សាយនៅលើបណ្ដាប្រទេសនានានៅលើពិភពលោក ជាពិសេស នៅលើបណ្ដាប្រទេសមួយចំនួននៃភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ ។

ប្រទេសកម្ពុជាយើង ព្រះពុទ្ធសាសនាបានចូលមកដល់តាំងពីយូរអង្វែងណាស់មកហើយ ហើយមានការរីកចំរើនយ៉ាងខ្លាំងក្លាព្រមទាំងជះឥទ្ធិពលយ៉ាងជ្រាលជ្រៅទៅក្នុងក្រអៅបេះដូងនៃចិត្តគំនិតទំនៀមទម្លាប់ ប្រពៃណីសិល្បៈវប្បធម៌នៃមនុស្សខ្មែរយើង ។

ចំពោះកាលបរិច្ឆេទនៃការចូលមកដល់ ឬ វត្តមានព្រះពុទ្ធសាសនាកម្ពុជាជាបញ្ហាមួយដែលអ្នកសិក្សាប្រវត្តិសាស្ត្រ ក៏ដូចជាអ្នកសិក្សាអក្សរសាស្ត្រ និងវប្បធម៌ទូទៅ តែងតែចោទសួរថា តើព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជាតាំងពីពេលណា ?

បញ្ហាបរិច្ឆេទនៃការចូលមកដល់នៃលទ្ធិពុទ្ធសាសនានេះ យើងគួរសិក្សា

---

(*) លោក ព. ត្រាណេ ចុះឡេប្រចក្ក ភ្នំពេញ ១៩៩៧

ឱ្យបានច្បាស់លាស់ ព្រោះបញ្ហានេះ វាបានឆ្លុះបញ្ចាំងទៅលើការរីកចំរើន របៀបរបបការរស់នៅ និងនិន្នាការរបស់សង្គមខ្មែរយើងនៅគ្រប់ដំណាក់កាលប្រវត្តិសាស្ត្ររបស់ខ្លួនរយៈកាលកន្លងមក ។

បញ្ហានេះ អ្នកសិក្សាជាច្រើនបានស្រាវជ្រាវឃើញកាលបរិច្ឆេទខុសៗគ្នា :

. មានអ្នកសិក្សាខ្លះបកស្រាយថា " ព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើងតាំងពី ស.វ.ទី ៣ ឬទី ២ មុនគ.ស ដោយសំអាងទៅលើប្រវត្តិសាស្ត្រនៃព្រះបាទធម្មាសោក នៃប្រទេសឥណ្ឌា ដែលព្រះអង្គជាមហាពុទ្ធសាសនិកជនមួយរូប គោរពព្រះពុទ្ធសាសនាថេរវាទ បានឧបត្ថម្ភការបញ្ជូនសមណទូតពីរអង្គគឺ សោណត្ថេរ និងឧត្តរត្ថេរ មកផ្សព្វផ្សាយព្រះពុទ្ធសាសនានៅលើដែនដីសុវណ្ណភូមិ ។

បញ្ជាក់ដោយសម្តេចព្រះមហាសុមេធាធិបតី ហួត តាត វិជិរប្បញ្ញោ ព្រះសង្ឃនាយកគណៈមហានិកាយ ក្នុងស្នាព្រះហស្តរបស់ព្រះអង្គស្តីពី " ព្រះពុទ្ធសសនានៅ កម្ពុជា សង្ខេប " បោះពុម្ពលើកទី ២ នៅ គ.ស. ១៩៧០ ទំព័រទី ១ ថា " ព្រះពុទ្ធសាសនាផ្សាយចូលមកកម្ពុជា ជាមុនដំបូង តាមគម្ពីរពុទ្ធសាសនា សាមន្តបាសាទិកាអដ្ឋកថា វិន័យបិដក ជាភាសាបាលី បានប្រាប់ពតិមានថា កាលក្រោយដែលធ្វើតតិយសង្គាយនារួចហើយនៅក្នុងជម្ពូទ្វីប គឺក្នុងប្រទេសឥណ្ឌា ក្នុងព.ស.ទី ៣ ព្រះមហាថេរមួយព្រះអង្គ នាមព្រះមហាមោគ្គល្លិបុត្តតិស្សៈបានចាត់ចែងបញ្ជូនព្រះថេរៈពីរអង្គ គឺព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរឱ្យចេញពីជម្ពូទ្វីប ( ឥណ្ឌា ) មកផ្សាយព្រះពុទ្ធសាសនា នៅសុវណ្ណភូមិ ក្នុងព្រះរាជូបត្ថម្ភនៃព្រះមហាក្សត្រនាមធម្មាសោក " ។

អ្នកសិក្សាខ្លះទៀត បានរកឃើញព្រះពុទ្ធសាសនាចូលមកដល់ប្រទេសខ្មែរយើងនៅស.វ.ទី ២ នៃគ.ស ទេវិញ ។ បញ្ហានេះ អ្នកស្រី ត្រឹង ងា បានសរសេរនៅក្នុងស្នាដៃអរិយធម៌ខ្មែរ បោះពុម្ពនៅឆ្នាំ ១៩៧៣ ទំព័រ ៨០ ថា " *តាមសិលាចារឹកវ៉ូកាញ់* ( នៅវៀតណាមខាងត្បូង ) ទំនងជាព្រះពុទ្ធសាសនាចូលមកប្រតិស្ឋានក្នុង

ស្រុកខ្មែរ នៅស.វ.ទី ២ នៃគ.ស ក្នុងរជ្ជកាលព្រះបាទស្រីមារៈ ឬ ហ្វាន់ចេម៉ាន់ ។ ទស្សនៈបែបនេះ គេបានពន្យល់ថា ព្រះពុទ្ធសាសនាមានកំណើតក្រោយព្រហ្មញ្ញសាសនា ប្រហែលនឹងអាចចូលមកដល់ប្រទេសកម្ពុជា ក្រោយការចូលមកដល់នៃលទ្ធិសាសនាព្រាហ្មណ៍ ពោលគឺ ក្រោយ ស.វ.ទី ១ នៃគ.ស. ដែលជាកាលកំណត់នៃការចូលមកដល់លទ្ធិព្រាហ្មណ៍សាសនា ។

- មានអ្នកខ្លះឱ្យយោបល់ថា ព្រះពុទ្ធសាសនា និងប្រហ្មញ្ញសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើង ក្នុងដំណាក់កាលប្រហាក់ប្រហែលគ្នា ឬក៏មុនក្រោយបន្តិចបន្តួចប៉ុណ្ណោះ ។ គេបានពន្យល់ថា បញ្ហានេះគ្មានឯកសារណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់ទេ ព្រោះគេហាក់ដូចជាពុំទាន់មានជំនឿចំពោះទស្សនៈរបស់អ្នកសិក្សា ឯទៀត ដែលយល់ថាសាសនានេះ ឬសាសនានោះមកដល់មុននោះឡើយ ។

យោបល់ស្តីពីវត្តមាននៃការចូលមកដល់នៃលទ្ធិព្រះពុទ្ធសាសនា មានច្រើនដូចខាងលើ ដែលយើងពិបាកនឹងកំណត់ឱ្យបានច្បាស់លាស់ណាស់ ។ ប៉ុន្តែពិនិត្យជារួម ទោះបីយ៉ាងណាក៏ដោយ ក៏យោបល់មតិទាំងអស់នោះជាពន្លឺនៃការសិក្សារបស់យើង ។ យើងពិនិត្យឃើញថា យោបល់ទាំងអស់ហាក់ដូចជាមានការឯកភាពគ្នាមួយនៅត្រង់ព្រះពុទ្ធសាសនា ក៏ដូចជាព្រហ្មញ្ញសាសនា បានចូលមកដល់ប្រទេសកម្ពុជាយើង តាំងពីយូរយារណាស់មកហើយ ។

ផ្អែកលើទស្សនៈខាងលើ យើងជាអ្នកសិក្សាស្រាវជ្រាវ គួរតែត្រិះរិះពិចារណារកហេតុផលឱ្យមានលក្ខណៈច្បាស់លាស់ និងសមស្រប ដើម្បីកំណត់ពីបញ្ហានេះ ។ យើងគួរលើកយកពីប្រវត្តិសាស្ត្រនៃព្រះបាទធម្មាសោក ដែលឱ្យពត៌មានថា " ព្រះពុទ្ធសាសនាបានផ្សព្វផ្សាយចូលមកដល់ដែនដីសុវណ្ណភូមិនៅ ស.វ.ទី ៣ ឬទី ២ មុនគ.ស. " យកមកត្រិះរិះពិចារណា ដើម្បីកំណត់កាលបរិច្ឆេទនៃការចូលមកដល់របស់លទ្ធិពុទ្ធសាសនានៅកម្ពុជាយើង ។ បញ្ហាចោទនោះ គឺដែនដីសុវណ្ណភូមិ

ជាដែនដីរបស់ប្រទេសណា ? ជាប្រទេសខ្មែរយើង ឬជាប្រទេសណាទៀត ?

ដែនដីសុវណ្ណភូមិនេះ ត្រូវបានគេយល់ឃើញដោយឡែក១ ហើយម្នាក់១ សុទ្ធតែអះអាងថា ដែនដីសុវណ្ណភូមិ ជាដែនដីរបស់ខ្លួនម្នាក់១ ។ ឧទាហរណ៍ដូចជា ខ្លះថាដែនដីនេះជារបស់ភូមា ខ្លះថាជាដែនដីឥណ្ឌូនេស៊ី ខ្លះថាម៉ាឡេស៊ី ខ្លះថាកម្ពុជា ខ្លះថាថៃ ខ្លះថាចាម ខ្លះថាវៀតណាម ... ។

យោបល់ដោយឡែក១ខាងលើរបស់ជនជាតិនីមួយ១ សុទ្ធតែមានការអះអាង ព្រមទាំងប្រកាន់យកនូវមហិច្ឆតាជាតិរបស់ខ្លួនជានិច្ច ។ មកដល់ត្រឹមនេះ យើងជាជនជាតិខ្មែរ ក៏ពុំទាន់ហ៊ានអះអាងថាដែនដីសុវណ្ណភូមិជាដែនដីរបស់យើងឡើយ ។ តែយើងត្រូវចោទសួរបន្តទៀត តើបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍នេះ ប្រទេសណាដែលបានទទួល និងគោរពព្រះពុទ្ធសាសនាមានចំណាស់ជាងគេ ? បើយើងពិនិត្យទៅលើប្រវត្តិសាស្ត្រ និងពិនិត្យលើការជាក់ស្តែង ឃើញថានៅអាស៊ីអាគ្នេយ៍នេះ ប្រទេសដែលគោរពព្រះពុទ្ធសាសនាមានចំណាស់ជាងគេ គឺមានតែប្រទេសកម្ពុជាយើងនេះឯង ។ ចំពោះបណ្តាប្រទេសដទៃទៀត ឃើញថាមានប្រទេសមួយចំនួន គេគោរពព្រះពុទ្ធសាសនាដូចយើងដែរ តែគេគោរពនោះស្ថិតនៅក្នុងដំណាក់កាលក្រោយយើង ។ ឧទាហរណ៍ ដូចជាករណីប្រទេសថៃ ចាប់ពី ស.វ.ទី ១ រហូតមកដល់ដើម ស.វ.ទី ៩ ក្នុងពេលដែលប្រទេសយើងបានកសាងជាប្រទេសមានអធិ.បតេយ្យ និងមានវប្បធម៌រឹងមាំរួចទៅហើយនោះ ប្រទេសនេះកំពុងស្ថិតនៅជាកុល.សម្ព័ន្ធ ឬជាជនជាតិភាគតិច ឬជាជនជាតិបញ្ចើក្អែក គ្មានឯកភាព នៅក្នុងខេត្តយូណាន់ នៃប្រទេសចិន ពោលគឺ មិនទាន់កើតជារដ្ឋនៅឡើយទេ ។ លុះមកដល់ ស.វ.ទី ៩ ទើបជនជាតិនេះបានជ្រៀតចូលមកក្នុងឥណ្ឌូចិន តាមខ្សែទឹកនៃទន្លេមេណាម ធ្វើដំណើរពីជើងចុះមករកទិសខាងត្បូង ដោយដណ្តើមទឹកដីពីជនជាតិខ្មែរយើងខ្លះ ពីជនជាតិមនខ្លះ ... រួចកសាងរដ្ឋឯករាជ្យរបស់ខ្លួនមួយ នៅស.វ.ទី ១៣ ។

ដូចនេះ ជនជាតិថៃពុំបានទទួលព្រះពុទ្ធសាសនាដោយផ្ទាល់ពីជនជាតិឥណ្ឌា ដូចជាជនជាតិខ្មែរយើងទេ ។ ព្រះពុទ្ធសាសនានៅក្នុងប្រទេសថៃ នាពេលសព្វថ្ងៃនេះ ត្រូវបាននាំបញ្ចូលពីប្រទេសកម្ពុជា ឬជាសាសនាដែលបានចាក់ឫសនៅលើទឹកដីនោះតាំងពីយូរ ពោលគឺ តាំងពីទឹកដីនោះជាទឹកដីរបស់ខ្មែរ មុនកាលចូលមកដល់នៃជនជាតិថៃម្ល៉េះ ។

ចំពោះជនជាតិវៀតណាម ក្នុងដំណាក់កាលពី ស.វ.ទី ១ ដល់ ស.វ.ទី ៩ ពុំទាន់រំដោះខ្លួនចេញពីអាណានិគមចិននៅឡើយដែរ ។ លុះមកដល់ ស.វ.ទី ១០ ទើបជនជាតិនេះរំដោះខ្លួនចេញពីអាណានិគមរួចកសាងប្រទេសរបស់ខ្លួន ។ ព្រះពុទ្ធ-សាសនាមហាយាន ដែលជនជាតិវៀតណាមគោរពនាពេលសព្វថ្ងៃនេះ ជាសាសនាដែលហូរចូលមកពីប្រទេសចិន តាំងពីនៅក្រោមអាណានិគមចិនម្ល៉េះ ។

ចំណែកប្រទេសដទៃទៀត ដែលនៅក្នុងតំបន់នេះ មានប្រទេសខ្លះគោរពព្រះពុទ្ធសាសនាដែរ តែក្នុងដំណាក់ក្រោយ ឬគេពុំគោរពពុទ្ធសាសនាតែម្តង ដោយគោរពសាសនាដទៃទៀត ។

បើសរុបមកឃើញថា ប្រទេសកម្ពុជាយើង ជាប្រទេសមួយមានអធិប-តេយ្យចំណាស់ជាងគេ ហើយទទួល និងគោរពព្រះពុទ្ធសាសនាមុតមាំជាងគេ ដែលសក្តិសមជាដែនដីសុវណ្ណភូមិ ដែលទទួលការផ្សព្វផ្សាយព្រះពុទ្ធសាសនាដោយផ្ទាល់ពីសមណទូតពីរអង្គព្រះនាម សោណត្ថេរ និង ឧត្តរត្ថេរ ក្រោមព្រះរាជូបត្ថម្ភនៃព្រះបាទធម្មាសោក នាសតវត្សទី ៣ ឬទី ២ មុនគ.ស.នេះណាស់ ។

*( នៅមានត )*

# សិលាចារឹកអកពួក K 1051 និង រាជ្យព្រះបាទហស៌វរ្ម័នទី១

## សព្វថ្ងៃរក្សាទុកនៅវត្តសម្តេច ភូមិសាស្ត្រស្រុកឯកភ្នំ ខេត្តបាត់ដំបង

## AK PUOK INSCRIPTION K 1051 AND THE REIGN OF HARSHAVARMAN I

## Currently kept at Vat Samdek in Geographical District of Ek Phnom, Battambang Province

ខង់ សុធារ៉ា
សាស្ត្រាចារ្យនៃដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

សិលាចារឹកនេះ ខ្ញុំបានដកស្រង់ចេញពីសៀវភៅ *Nouvelles des Inscriptions du Cambodge II* ទំព័រ៨៩-៩០ របស់បណ្ឌិត ពៅ សាវរស ដែលបានសិក្សា និងបកប្រែរួចហើយ ។ ប៉ុន្តែ នៅក្នុងសេចក្តីបកប្រែនោះ ខ្ញុំសង្កេតឃើញមានការភ័ន្តច្រឡំមួយទៅលើអំណានកាលបរិច្ឆេទ ដែលមាននៅក្នុងសិលាចារឹកនេះ ។ បណ្ឌិត ពៅ សាវរស អានកាលបរិច្ឆេទ **៨១៣** ថា ឆ្នាំ ៨៣៧ម.ស. គឺត្រូវនឹងឆ្នាំ ៩១៥គ.ស. ដែលតាមពិតនោះ គឺឆ្នាំ៨២១ ម.ស. ដែលត្រូវនឹងឆ្នាំ៨៩៩គ.ស.ទៅវិញទេ ហើយលោក ក្លូត ហ្សាក់ ក៏អះអាងដូចគ្នានេះដែរ ។ ដោយសារការប្រើបច្ឆាមវណានាម យើងដឹងថា អត្ថបទនេះ ពិតជាចារឹកនៅក្រោយពេលព្រះបាទហស៌វរ្ម័នទី១ចូលទីវង្គត ហើយបើតាមការសង្កេតទៅលើរូបលក្ខណៈអក្សរ និងសំណេរ យើងសន្និដ្ឋានថា អត្ថបទនេះ ចារនៅរវាងពាក់កណ្តាលសតវត្សទី១០នៃគ.ស. ។

អត្ថន័យសង្ខេបរបស់វា គឺថា នៅក្នុងរាជ្យព្រះបាទស្តេចទៅរុទ្រលោក ឬ ព្រះបាទហសិវរ្ម័នទី១ នាឆ្នាំ៨៩៥នៃគ.ស. មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះ( ព្រះកម្រតេងអញ) ចន្ទ្រសិខរព្រាហ្មណ បានស្ថាបនាប្រាសាទឥដ្ឋមួយ ឧទ្ទិស ថ្វាយអាទិទេព (ព្រះ)នារាយណ៍ ដែលមានរហស្សនាមថា *ស្រីវីរសក្តិ* ។ មិនតែប៉ុណ្ណោះ ព្រាហ្មណ៍នេះឯង បានជូនក្ញុំបំរើ ដីធ្លី អង្ករ ដល់ប្រាសាទ និងដឹកបារាយណ៍ ថ្វាយជាព្រះរាជធម្មថែមទៀតផង ហើយចុងបញ្ចប់ គាត់ដាក់បណ្តាសាដល់អ្នកទាំងឡាយណា ដែលបំបាត់សមិទ្ធផល( ធម្ម)នោះ អោយទទួលរងនូវអំពើបាបផ្សេងៗ ។

ក្នុងប្រវត្តិសាស្ត្រខ្មែរ តែងតែមានបញ្ហាចោទលើកាលបរិច្ឆេទនៃការឡើងសោយរាជ្យ និងបញ្ចប់រាជ្យរបស់ព្រះរាជាជាច្រើនអង្គ ពីព្រោះតែការខ្វះខាតឯកសាររឹង ដែលបន្សល់ទុកដោយស្មេរ ឬអ្នកចេះដឹងនៅសម័យនោះ ។ ដូច្នេះប្រវត្តិសាស្ត្រជាក់លាក់របស់កម្ពុជា ជាពិសេសនៅសម័យអង្គរ ត្រូវពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើឯកសារសិលាចារឹក ដែលត្រូវបានគេរកឃើញ និងយកមកសិក្សាជាបន្តបន្ទាប់តាំងពីចុងសតវត្សទី១៩រហូតដល់សព្វថ្ងៃ ។ ដោយពតិមានទាំងអស់នោះ មានលក្ខណៈដាច់ៗពីគ្នា មិនគ្រប់គ្រាន់ ធ្វើអោយអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រប្រើប្រាស់ សេចក្តីសន្និដ្ឋាន ដើម្បីបំពេញការខ្វះចន្លោះនៃប្រវត្តិសាស្ត្រ ជាពិសេស លើកាលបរិច្ឆេទនៃការឡើងសោយរាជ្យ និង ចុងបញ្ចប់រាជ្យរបស់ព្រះរាជាមួយចំនួន ។ ការនេះហើយដែលធ្វើអោយកាលបរិច្ឆេទនៃរជ្ជកាលស្តេចអង្គខ្លះគ្មានឯកភាពគ្នា ។

ដូចជា ករណីព្រះបាទយសោវរ្ម័នទី១ ចំពោះឆ្នាំដែលព្រះអង្គឡើងសោយរាជ្យគ្មានអ្វីចោទជាបញ្ហានោះទេ ព្រោះព្រះអង្គបានបន្សល់សិលាចារឹកជាច្រើន ដូចជានៅប្រាសាទលលៃខេត្តសៀមរាប ដែលបញ្ជាក់អោយដឹងថា ព្រះអង្គបានឡើង

សោយរាជ្យជាសកលនៅឆ្នាំ៨១១នៃមហាសករាជ គឺត្រូវនឹងគ.ស.៨៨៩ ។ ប៉ុន្តែអ្វីដែលជាចំណោទ គឺចុងបញ្ចប់នៃរជ្ជកាលព្រះអង្គ និងបញ្ហារជ្ជកាលរបស់រាជបុត្រទាំងពីរអង្គ គឺព្រះបាទ ហរិវរ្ម័នទី១ និង ឥសានវរ្ម័នទី២ ដែលជាបញ្ហាចំបងនៅពេលនេះ ហើយយើងនឹងលើកយកមកអធិប្បាយជាបន្តបន្ទាប់ មុននឹងបង្ហាញ ជូនអត្ថបទសិលាចារឹក ដែលជាភស្តុតាងថ្មីមួយទៀតក្នុងបរិបទនេះ ។

តាមសិលាចារឹកភិមានាកាស K 291 បានអោយដឹងថា នៅគ.ស.៩១០ គេស្ថាបនាអាសនអាទិទេពស្រី ត្រៃលោក្យនាថ បន្ទាប់មកមន្ត្រីឈ្មោះ សត្យាស្រយ ដែលជាស្ថាបនិកម្នាក់ បានថ្វាយក្ញុំបំរើដល់អាទិទេពនេះ តាមព្រះរាជបញ្ជាព្រះបាទស្តេចយាងទៅបរមសិវលោក គឺព្រះបាទយសោវរ្ម័នទី១ក្នុងទំរង់ជាបច្ឆាមរណនាម[១]

ចំណែកសិលាចារឹកប្រាសាទភូមិពុ K 886 នៅឃុំដំដែក ស្រុកសូទ្រនិគម អោយដឹងថា នៅគ.ស.៩០២ ព្រះបាទស្តេចទៅបរមសិវបទ ទ្រង់មានព្រះបន្ទូលបញ្ជាមន្ត្រីម្នាក់ទៅចាប់*កន្រស្យ(?)*[២] ។ តាមចារឹកនេះ ឃើញថា ពតិមាននៃការប្រើបច្ឆាមរណនាមរបស់ព្រះបាទ យសោវរ្ម័នទី១ កាន់តែចាស់ជាងពេលមុន៨ឆ្នាំ ។

ចុងក្រោយគេ គឺសិលាចារឹកទួលតាពេច ដែលជុំរុញអោយលោក ហ្សកសឺដេស ដែលមុននេះនៅស្ទាក់ស្ទើរក្នុងការកំណត់ពេលចុងបញ្ចប់រាជ្យយសោវរ្ម័នទី១ បែរជាហ៊ានអះអាងថា ភស្តុតាងពតិមាននៃសិលាចារឹកទាំងនេះ គឺជាមូលដ្ឋានសំរាប់ដាក់កាលបរិច្ឆេទចុងបញ្ចប់រាជ្យរបស់ព្រះបាទ យសោវរ្ម័នទី១ នៅមុនគ.ស.៩១០...

---

[១] cf, G. Coedès, *Inscriptions du Cambodge,* Vol. III, pp.199-204.

[២] cf, G. Coedès, *op cit,* Vol. V, pp.151-2.

ហើយ វាដូចដែលគាត់បានបង្ហាញនៅក្នុងព្រឹត្តិប័ត្រសាលាបារាំងចុងបូព៌ា លេខ ៤៣ ទំព័រ១៣ ថា ព្រះបាទយសោវរ្ម័នទី១ បញ្ឈប់ការសោយរាជ្យចាប់ពីឆ្នាំ៩០០គ.ស. គឺនៅពេលព្រះអង្គចូលទីវង្គត ។

ចំណែកលោក ក្លូត ហ្សាក់ បានធ្វើសន្និដ្ឋានមួយផ្សេងពីលោក សឺដេសទៅវិញថា ព្រះបាទយសោវរ្ម័នទី១ មិនមែនចូលទីវង្គតនៅគ.ស.៩០០ ដូចការបញ្ជាក់នៅក្នុងសិលាចារឹកទូលតាពេចនោះទេ គឺព្រះអង្គអាចសុគតនៅ ចន្លោះឆ្នាំ៩១០ទៅ៩១២ គ.ស. ។ ដោយសារគាត់អះអាងថា សិលាចារឹកទាំងនោះ អាចត្រូវបានគេចារក្រោយកាលបរិច្ឆេទ ដែលគេបានដាក់នោះទៅទៀត ជាពិសេសក្រោយពេល ដែលព្រះបាទយសោវរ្ម័នទី១ចូលទីវង្គត[៣] ។

រីឯព្រះបាទ*ហសិវរ្ម័នទី១* ដំបូងឡើង គេស្គាល់រាជ្យព្រះអង្គតាមរយៈសិលាចារឹកព្រះវិហារគុក ឬវត្តចក្រែត ខេត្តព្រៃវែង K 61[៤] ថា ជាព្រះរាជបុត្រព្រះបាទយសោវរ្ម័នទី១ ព្រះអង្គមានព្រះមហេសី៦អង្គ បានធ្វើព្រះរាជអំណោយចំពោះអាទិទេពនៅភ្នំវ្យាធបុរនាគ.ស.៩១២ ។ បន្ទាប់មក សិលាចារឹកទួលពៃស្តិតនៅមាត់ស្ទឹងស្ទោងខេត្តកំពង់ធំ K 164[៥] បានអោយដឹងថា នៅគ.ស.៩២២ ព្រះអង្គគង់នៅក្នុងរាជ្យសម្បត្តិនៅឡើយ ។ ចុងក្រោយគេ គឺសិលាចារឹកទួលតាពេច ស្រុកបារាយណ៍ខេត្តកំពង់ធំ K 834 ដែលរកឃើញនៅឆ្នាំ១៩៣៥ ។ ចារឹកនេះចារក្នុងរាជ្យព្រះបាទ

---

[៣] cf, Claude Jacques, dans *BEFEO,* t. LVIII, 1971, p. 168.

[៤] cf, G. Coedès, *op cit,* Vol. VII, pp.20-22 and A. Bergaigne, *Inscriptions Sanscrites du Cambodge,* n° LXIII, pp. 551-5.

[៥] cf. G. Coedès, op cit, Vol. VI, pp.96-8.

សូរ្យវ័រ្មនទី១ ដោយព្រាហ្មណ៍បុរោហិត នាម ភូបតិន្ទ្រវល្លភៈ និយាយលើកកិត្យា-នុភាពត្រកូលរបស់ខ្លួន ដែលមានបងប្អូនប្រុសចំនួន១២នាក់ធ្វើជាបុរោហិតរបស់ព្រះរាជាតាំងពីរាជ្យព្រះបាទជ័យវ័រ្មនទី៣ រហូតដល់ សូរ្យវ័រ្មនទី១ គឺក្នុងរយៈពេលពីរសតវត្សកន្លះ ដែលលោក សឺដេស បដិសេធថា មិនពិត ។ ប៉ុន្តែ វាជាទឡ្ហីករណ៍មួយទាក់ទិនដល់កាលបរិច្ឆេទនៃការឡើងសោយរាជ្យរបស់ព្រះរាជា៥អង្គ ក្នុងនោះក៏មានព្រះបាទហសិវ័រ្មនទី១ផងដែរ ដែលថាព្រះអង្គឡើងសោយរាជ្យនៅគ.ស.៩០០ ។

បញ្ហានេះ ធ្វើអោយលោក សឺដេស សន្និដ្ឋានដោយគ្មានរារែកថា ព្រះបាទហសិវ័រ្មនទី១ ឡើងសោយរាជ្យនៅឆ្នាំ៩០០គ.ស. ជាឆ្នាំដែលព្រះបិតាព្រះអង្គចូលទិវង្គតដែរ ដូចបាននិយាយខាងលើ ។

ប៉ុន្តែឥឡូវនេះ យើងមានពតិមានថ្មីមួយទៀត ដែលផ្តល់អោយដោយសិលាចារឹកអកពូក ដូចបានសង្ខេបពីខាងដើមហើយថា*នៅឆ្នាំ៨៩៩គ.ស. ព្រះបាទហសិវ័រ្មនទី១ បានឡើងសោយរាជ្យរួច ជាស្រេចទៅហើយ* ។ ដូច្នេះឃើញថា ព្រះអង្គមានព្រះវត្តមានក្នុងរាជ្យសម្បត្តិកាន់តែចាស់ជាងមុន១ឆ្នាំថែមទៀត ។

ម្យ៉ាងទៀតអ្វី ដែលជាចំណោទសំរាប់ការពិចារណារបស់យើងនោះ គឺថាតើព្រះបាទយសោវ័រ្មនទី១ ពិតជា សុគតនៅឆ្នាំ៨៩៩នោះដែរ ឬឆ្នាំ៩០០ ឬឆ្នាំ៩១០ ឬមួយក៏ឆ្នាំ៩១២ ?

ដូចបានអះអាងពីខាងដើម សិលាចារឹកអកពូកពិតជាចារ ក្រោយពេលព្រះ-បាទហសិវ័រ្មនទី១ចូលទីវង្គត អាចនៅរវាងពាក់កណ្តាលសតវត្សទី១០ ក្រោយកាលបរិច្ឆេទនោះប្រហែលជាង៤០ឆ្នាំ បើយោងទៅលើបុរាណ អក្ខរក្រមវិទ្យា ។ ដូច្នេះ

ស្មេរមិនបានគិតអំពីបញ្ហាបែងចែកការប្រើពាក្យហៅ ព្រះមហាក្សត្រ ពេលនៅមានព្រះជន្ម និងគ្មាន អោយបានច្បាស់លាស់ ។ ចំណែកសិលាចារឹកដទៃខ្លះទៀត ក៏ដូចគ្នានេះដែរ គឺកាលបរិច្ឆេទដែលគេចារឹកទុកនោះ មិនមែនជាឆ្នាំពិតប្រាកដ ដែលគេចារឹកនោះទេ ។ បានន័យថា គេចារឹកនៅពេលក្រោយកាលបរិច្ឆេទនោះៗ ជាពិសេសក្រោយពេលព្រះរាជាចូលទីវង្គត ដូចជា សិលាចារឹក K 291 និង K 886ជាដើម ។

អាស្រ័យហេតុនេះ យើងអាចអះអាងបញ្ជាក់ថា ព្រះបាទហសិវរ្ម័នទី១ ពិតជាឡើងសោយរាជ្យនៅឆ្នាំ៨៩៩គ.ស. ឬអាចមុននេះ១ ឬ២ឆ្នាំទៀតផង ។ ចំណែក ព្រះបាទយសោវរ្ម័នទី១ ទ្រង់ដាក់រាជ្យសម្បត្តិនៅឆ្នាំ ៨៩៩គ.ស.មែន ប៉ុន្តែព្រះអង្គគង់ព្រះជន្មនៅឡើយរហូតដល់ឆ្នាំ៩១០ ដែលក្នុងអំឡុងពេលនេះ ប្រហែលជាព្រះអង្គគង់ក្នុងឋានៈ ដូចជា ព្រះមហាឧភយោរាជនៅសម័យក្រោយអង្គរ ។

រីឯកាលបរិច្ឆេទបញ្ចប់រាជ្យរបស់ព្រះបាទហសិវរ្ម័នទី១ និងការឡើងគ្រងរាជ្យរបស់ព្រះបាទឥសានវរ្ម័នទី២ គេមិនទាន់រកឃើញឯកសារណាមួយ ដែលបញ្ជាក់អំពីរឿងនេះអោយបានច្បាស់នៅឡើយ ។ ការដែលអ្នកស្រាវជ្រាវខ្លះ អះអាងយកកាលបរិច្ឆេទឆ្នាំ៩២២គ.ស.នោះ គ្រាន់តែជាសេចក្ដីសន្និដ្ឋានប៉ុណ្ណោះ ។ ត្បិតគេរកឃើញសិលាចារឹកទាក់ទងរាជបញ្ជាព្រះបាទហសិវរ្ម័នទី១ ចុងក្រោយនៅឆ្នាំ៩២២(K 164) ហើយនៅឆ្នាំ៩២៥-៦គ.ស.(K 872, 1073) ព្រះបាទឥសានវរ្ម័នទី២ ស្ថិតនៅក្នុងរាជ្យសម្បត្តិស្រេចទៅហើយ ។

ខាងក្រោមជាអត្ថបទសិលាចារឹកអកពួកទាំងស្រុង :

## អត្ថបទ

(១) - តរាជវ្រះបាទកម្រតេងអញ

(២) - រុទ្រលោក៨២១គកវ្រះកម្រ

(៣) - តេងអញចន្ទ្រគិខរវ្រាហ្មណចោ

(៤) - ងឥត្តិកាប្រាសាទស្ថាបនាវ្រះក

(៥) - ម្រតេងអញនារាយនគ្រិវិរគក្តិជ្វ

(៦) - នខ្ញុំភូមិជ្យកទន្លេថ្វាយជាវ្រះរា

(៧) - ជធម្ម៌ វ្រះបុជារង្គោជេវ្យរបក្សណោ

(៨) - ចវាបវ្រហ្មតេងចន្ទ្រាណិកូលេត

(៩) - ប្យបិយ ។បក្សខ្នេតវាបសោ(តេ)ងសុ

(១០) - ភទ្រាកូលេតប្យបិយភូមិបូរ្វិត្រវា

(១១) - ងរទ្រាវទក្សិណស្រុកច្រលុះបត្ឆិម

(១២) - ឆ្នឹងឧត្តរត្រវាងអរិល-បាបាណ្យ

(១៣) - គុរុទ្រោះហរាជ្យាទ្រោហគិវទ្រោហវ្រ

(១៤) - ហ្មាត្យាមានអ្នក្តបំបាតធម្មនេះ។

# អត្ថបទជាអក្សររ៉ូម៉ាំង

(1) ta rāja vraḥ pāda kamrateṅ añ (2) rudraloka ₒ 821 çaka vraḥ kamra- (3) teṅ añ candraçikhara vrāhmaṇa co- (4) ṅ it ti kā prāsāda sṭhāpanā vraḥ ka- (5) mrateṅ añ nārāyana çri viraçakti jva- (6) n khñuṃ bhūmi jyak danle thvāy jā vraḥ rā- (7) ja dharmma vraḥ pujā raṅko je vyar pakṣa rṇo- (8) c vāp vrahma teṅ candrāṇi kūle ta- (9) pp piy ₒ pakṣa khnet vāp so teṅ su- (10) bhadrā kūle tapp piy bhūmi pūrvva travā- (11) ṅ vadrāva dakṣiṇa sruk craluḥ paççima (12) chdiṅ uttara travāṅ aṃvil ₒ pāpāṇya (13) guru droḥha rājyādroha çivadroha vraṃ- (14) hmātyā mān ta ^a^nak ta paṃpāt dharmma neḥ /o/

## សេចក្តីបកប្រែ

(១-៧) -កាលពីរាជ្យព្រះបាទកម្រតេងអញ*រុទ្រលោក*[១] ឆ្នាំ៨២១គក[២] ព្រះកម្រតេងអញ ចន្ទ្រគិខរព្រាហ្មណ ចង[៣] ឥដ្ឋ ក[៤] ប្រាសាទ ស្ថាបនាព្រះកម្រតេងអញ នារាយន[៥] (និង) ត្រីវិរគក្តិ[៦] ជូនក្ញុំបំរើ ដីធ្លី ជីកបារាយណ៍ ថ្វាយជាព្រះរាជធមិ ។

---

[១] ព្រះបាទ ហសិវម្មិទី១ ដែលជារាជបុត្រាព្រះបាទយសោវម្មិទី១

[២] ឆ្នាំ៨២១នៃមហាសករាជ ឬ ឆ្នាំ៨៩៩នៃគ.ស.

[៣] ចោង=ចង (=កសាង ឬ ធ្វើ) ដូចជាពាក្យ ចងសៀវភៅ=ធ្វើជាសៀវភៅ

[៤] កា ខ្ញុំយល់ថាត្រូវគ្នានិងពាក្យ "ក"= ផ្តូចផ្តើមធ្វើ ឬ ផ្តើមកសាង ។ ពិតហើយថា ការអះអាងបែបនេះ វាបង្ហាញនូវសម្មតិកម្ម បញ្ញាសត្តាជាមួយនិងពាក្យ "ករ"(=ការពារ) ដែលក្លាយមកជា"ការ" ប៉ុន្តែការផ្លាស់ប្តូរបែបនេះយើងឃើញមានច្រើននៅក្នុងភាសាខ្មែរ ។ ដូចជា នៅសម័យមុនអង្គរ គេបានហៅគោរម្យងារជនស្រទាប់ក្រោម ឬសាមញ្ញជនភេទប្រុស

(៧-១០)-(លោក)បូជាព្រះនូវអង្ករ ២ជេ(កញ្ជើ?) (ចំពោះមនុស្សដែលទទួលខុសត្រូវធ្វើកិច្ចការ) ប៉ែកខាងរនោច(មាន) វាប វ្រហ្ម តេងចន្ទ្រាណិ ព្រមទាំងក្រុមគ្រួសារ គ្នា១៣នាក់ ។ ប៉ែកខាងខ្នើត(មាន) វាប សោ តេង សុភទ្រា ព្រមទាំងក្រុមគ្រួសារ គ្នា១៣នាក់ ។

---

ម្តងថា"វ" ម្តងថា"វា" ជួនកាលនៅក្នុងអត្ថបទសិលាចារឹកតែមួយ ក៏គេនៅតែប្រើច្របូកច្របល់លាយឡំគ្នារវាង"វ" និង "វា"នេះដែរ ។ នៅសម័យអង្គរ តាមសិលាចារឹកវត្តសំរោងK 956 ខេត្តព្រៃវែង បានអោយដឹងថា កាលពីរាជ្យព្រះបាទជ័យវរ្ម័នទី៣ ព្រះអង្គបានយាងមកទីក្រុង *ហរិបុរ* ជាទីកដីអំណោយរបស់របស់ព្រះអង្គ ដល់មន្ត្រីម្នាក់នាម ម្រតាង *ប្រថិវីនរេន្ទ្រ* ដែលជាអ្នកធ្វើពិធី*កល្យានសិទ្ធិ* នៅឯបូទូល(វដ្ដូល?) ដើម្បីលើក*កម្ពុជទេស*កុំអោយចំណុះជ្វា សព្វថ្ងៃនៅតំបន់ទិសអាគ្នេយនៃខេត្ត ។ ពេលមកដល់ទីនោះ ដីរនាម*ព្រះស្រីជ័យសិក្ស្យធម្ម*របស់ព្រះអង្គដាច់(ទន្លឹង?) ទើបព្រះអង្គបញ្ញត្តិផ្លូវឈ្មោះ ហរិបុរ មកជា*សារភាចិ*វិញ ប៉ុន្តែនៅពេលនោះដែរ គេហៅតំបន់នេះថា *ស្រភាច* ជាពិសេសអ្នកដែលបានទទួលកាន់កាប់ទីកដីព្រះរាជប្រទាននេះឯង ។ បើតាមក្បួននិរុត្តិសាស្ត្រ ឈ្មោះនេះ នៅពេលគេហៅដោយខ្លី ថា *ស្រាភាច* ដោយទាញខ្យល់ព្យញ្ជនៈ"រ"មកគ្រួតនឹង"ស" ។ ហេតុអ្វីបានជាពួកគេមិនហៅថា *សារភាច* ឬ *ស្រាភាច* បែរហៅថា *ស្រភាច* បែបនេះវិញ មិនខ្លាចព្រះរាជអាជ្ញាដាក់ទោសត្បិតហៅខុសរាជបញ្ញត្តិទេឬ ?

ចំណែកនៅសម័យក្រោយអង្គរបញ្ហានេះ មិនត្រឹមតែមានចំពោះភាសាខ្មែរប៉ុណ្ណោះទេ សូម្បីភាសាបាលី ឬសំស្ក្រឹត ដែលខ្ចីមកប្រើក៏នៅតែប្រែ ប្រួលដែរ ដូចជាពាក្យ"សុពណ៌"គេសរសេរជា"សុពាណ៌" (សិលាចារឹកជ័យនន្ទ...) ។

(៥) ព្រះនារាយណ៍

(៦) ត្រីវិគក្កិ ជារហស្សនាមមួយរបស់ព្រះនារាយណ៍ ?

(១០-១២) -(ចំពោះព្រំប្រទល់) ដីធ្លី ខាងកើតនៅត្រពាំងវទ្រាវ ខាងត្បូងនៅស្រុកច្រលុះ ខាងលិចនៅស្ទឹង ខាងជើងនៅត្រពាំងអំពិល ។

(១២-១៤)- អំពើបាបច្រើនប្រការខុសៗគ្នា[៧] ចូរមានដល់ពួកមនុស្ស ដែលបំបាត់ធម៌[៨] នេះ (មាន) អ្នកប្រទូស្តរាយ[៩] ជាមួយគ្រូ ព្រះរាជា ព្រះឥសី និងពួកសមណៈព្រាហ្មណ៍ ។

## ឯកសារពិគ្រោះ


1- Abel Bergaigne,
- *Inscriptions Sanscrites du Cambodge,* fascicule II, Paris 1893.

2- *BEFEO,* t. LVIII, Paris 1971, p. 163-75.

3- Goerges Coedès,
- *Articles sur le pays Khmer,* t. I-II, Paris 1989-1992, edited by Claude Jacques.
- *Inscriptions du Cambodge,* Vol. II-VIII, (7 volumes) Paris 1942-66.

4- Monier M. William,
- *Sanskrit-English Dictionary,* (1899) Delhi 1995.

5- Saveros Pou,
- An Old Khmer-French-English Dictionary, Paris 1992.
- *Nouvelles Inscriptions du Cambodge II,* Paris 1996.


---

[៧] បាបាណ្យ < បាប + អណ្យ (= ដទៃ ផ្សេងៗទៀត ខុសៗពីគ្នា...)

[៨] សមិទ្ធិផល ដែលប្រាកដរូបរាងឡើងហើយ ១កំពុងបំរើសេចក្តីត្រូវការរបស់មនុស្សផងទាំងពួង ។

[៩] ទ្រោហ (សំ.) = ប្រទូស្តរាយ ប្រឆាំង ក្បត់ សម្លាប់ ។

## ផ្ទាំងអត្ថបទដើមនៃសិលាចារឹកអកពួក K.1051



# វិហារ " អដ្ឋរស្ស " និង ប្រស្នា " ៣២ " របស់ស្ដេចស្រុកចិន

**ឱម ខែម**

រៀបរៀង និងសម្រួលសេចក្ដីពីឯកសារ

ស្ដីពី « *សាវតារវត្តអដ្ឋារស* »

នៅប្រទេសកម្ពុជា, តាមទម្លាប់ទំនៀមខ្មែរ គេតែងសាងវត្ត និងធ្វើព្រះវិហារបែរមុខឆ្ពោះទៅទិសខាងកើត ព្រោះគេយល់ឃើញថា ព្រះពុទ្ធអង្គកាលដែលទ្រង់បានត្រាស់សម្មាសម្ពោធិញ្ញាណ ទ្រង់គង់បែរព្រះភក្ត្រឆ្ពោះទៅទិសខាងកើត ។ ប៉ុន្តែ យើងឃើញព្រះវិហារមួយធំ បែរមុខឆ្ពោះទៅទិសខាងជើង ។ នោះគឺព្រះវិហារឈ្មោះ « អដ្ឋរស្ស (*) » នៅលើភ្នំព្រះរាជទ្រព្យ ក្នុងស្រុកពញាឮ ខេត្តកណ្ដាល ។ នេះជារឿងចម្លែកមួយគួរពិចារណា ។

តាមឯកសារស្ដីពី « *សាវតារវត្តអដ្ឋារស* » ដែលអ្នករង្គម្ចាស់ក្សត្រីនរោត្ដម សុខានារី បានរៀបរៀង និងបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៩ ខែកញ្ញា ឆ្នាំ ១៩៥០ មានសេចក្ដីដូចតទៅ :

កាលនៅក្នុងសតវត្សទី ១៣ គឺនៅក្នុងសម័យអង្គរ ព្រះចៅប្រទេសចិនទ្រង់បានចាត់បេសកជនចិនជាច្រើនក្រុម ឱ្យដើរមើល ស៊ើបសួរក្នុងប្រទេសនានាថាតើបណ្ដាជននៃប្រទេសនោះៗ មានអារ្យធម៌របៀបណាខ្លះ ។ បើប្រទេសណា

---

(*) អដ្ឋរស្ស ( អានថា អាត់-ថៈ-រ៉ស់ ) ប្រាំបីជ្រុង, ឯកសារដើមសរសេរជា " អដ្ឋារស " " ១៨ " ឥតពាក្យថា " ជ្រុង " ។

មានអារ្យធមិថ្កុំថ្កើងរុងរឿង ត្រូវលួចកត់យកមកប្រតិបត្តិ និងផ្សព្វផ្សាយក្នុងប្រ-ទេសចិន, ឬប្រទេសចិននឹងសុំចងសម្ពន្ធមិត្តនឹងប្រទេសនោះ ។ បើប្រទេសណាមានអារ្យធមិឱនអាប់ ប្រទេសចិននឹងទំនុកបំរុង ឬយកធ្វើជាប្រទេសចំណុះ ។

កាលនោះ ក្រុមបេសកជនចិន ក្រោយបានចូលមកមើល និងស៊ើបសួរក្នុងប្រទេសខ្មែរសព្វគ្រប់ហើយ ក៏ត្រឡប់ទៅរាយការណ៍ទូលព្រះចៅស្រុកចិនវិញថា « *ប្រទេសខ្មែរជាប្រទេសថ្កុំថ្កើងរុងរឿង មានឥទ្ធានុភាព តែឥឡូវនេះចុះអាប់ឱនជាងកាលពីមុនបន្តិចហើយ, អ្នកស្រុកដើរជើងទទេ, បរិភោគអាហារនឹងដៃ, ពុំសូវឃើញមានឧបករណ៍អ្វីប្រើប្រាស់ឱ្យបានងាយស្រួលទេ, ប៉ុន្តែ មិនយូរប៉ុន្មានទេ ប្រទេសខ្មែរមុខជានឹងជួបប្រសព្វនឹងសេចក្តីថ្កុំថ្កើងឡើងវិញលើសដើមជាអស្ចារ្យ* » ។ ពួកបេសកជនចិនទាំងនោះរាយការណ៍ថ្វាយស្ដេចស្រុកចិនដូច្នេះ ព្រោះពួកគេបានមកឃើញទីមួយកន្លែង ដែលតាមក្បួនចិនសែថា ជាទីកន្លែងអាចនឹងឱ្យផលល្អផ្សេងៗដល់ប្រទេសខ្មែរ ។ ទីកន្លែងនោះគឺ ភ្នំព្រះរាជទ្រព្យនៅក្នុងស្រុកឧដុង្គយើងសព្វថ្ងៃ ។ ពួកបេសកជនចិនបានមើលឃើញភ្នំនេះមានរាងដូចជាសត្វមករ គឺតួខ្លួនសត្វមករ នៅត្រង់ចេតិយព្រៃត្រីង្ស, ក្បាលនិងពុកមាត់មករនៅត្រង់ចេតិយទន្ទឹម, រីឯកន្ទុយមករនៅត្រង់ព្រះពុទ្ធបដិមាចូលនិព្វាន ហើយនៅលើកំពូលភ្នំមានរូងមួយធំជ្រៅស្រឡូងចុះទៅក្រោមផង ។ ពួកចិនយល់ឃើញថា មិនយូរប៉ុន្មាន សត្វមករនឹងកម្រើកចេញតាមរូងនេះ ហើយតាមក្បួនចិនសែថា ពេលសត្វមករផុសឡើង ប្រទេសខ្មែរនឹងមានអំណាចខ្លាំងក្លា និងថ្កុំថ្កើងរុងរឿងអស្ចារ្យពុំមានប្រទេសឯណាអាចនឹងតស៊ូបានឡើយ ។ ដូច្នេះ ដើម្បីសេចក្តីសុខដល់ប្រទេសចិនទៅអនាគត មន្ត្រីចិនទាំងឡាយទូលសុំឱ្យស្តេចចិនលើកទ័ពវាយប្រទេសខ្មែរយកធ្វើជាចំណុះឱ្យហើយ ។

ស្តេចចិនទ្រង់ព្រះតម្រិះថា ធ្វើយ៉ាងនេះហើញដូចជារំលោភលើប្រទេស

ខ្មែរពេកណាស់, មួយវិញទៀត ប្រទេសខ្មែរនៅខ្លាំងពូកែថ្មីថ្មើងនៅឡើយ ប្រទេសចិនមិនអាចនឹងវាយបេកបានដោយងាយៗទេ, ប្រទេសចិនអាចច្បាំងឈ្នះប្រទេសខ្មែរ ប៉ុន្តែចំណាយអស់ពលយោធាច្រើនសន្ធឹកសន្ធាប់ណាស់ ហើយអ្នកដែលទទួលរងទុក្ខវេទនា គឺប្រជារាស្ត្រចិន និងប្រជារាស្ត្រខ្មែរ ។ ដូច្នេះ ត្រូវរកឧបាយបង្ក្រាបប្រទេសខ្មែរ ដោយវិធីផ្សេងវិញ ។ ឧបាយនោះគឺ :

• ទី១ ត្រូវយកថ្មសន្ធប់រូងភ្នំឱ្យជិត កុំឱ្យសត្វមករចេញមករួច ។ តែបើយកថ្មសន្ធប់រូងភ្នំនោះ ខ្លាចក្រែងថ្ងៃក្រោយខ្មែរបេះគំនិតនេះ គេនឹងគាស់ថ្មចេញវិញបាន ។ ពួកចិនបានស៊ើបដំណឹងច្បាស់ថា ប្រទេសខ្មែរកាន់ព្រះពុទ្ធសាសនាមុតមាំណាស់ នៅទីណាដែលមានព្រះពុទ្ធរូប, មានព្រះវិហារ ខ្មែរពុំហ៊ានកាយគាស់រំលើងទីនោះទេ ។ ដោយហេតុនេះហើយបានជាស្តេចស្រុកចិន ចាត់មន្ត្រីចិនឱ្យមកសុំសេចក្តីអនុញ្ញាតធ្វើព្រះវិហារនៅលើកំពូលភ្នំនេះ ។

ពេលបានទទួលសេចក្តីអនុញ្ញាតហើយ, ពួកចិនកសាងព្រះពុទ្ធរូបមុនគេ រួចទើបធ្វើព្រះវិហារ និងបញ្ចុះសីមាតាមទំនៀមអ្នកស្រុកជាក្រោយ ហើយរបៀបនេះត្រាប់តាមក្បួនហោរាសាស្ត្រចិនផង ។ ហេតុនេះហើយបានជាព្រះវិហារនោះធ្វើបែរមុខឆ្ពោះទៅទិសខាងជើង គឺឆ្ពោះទៅរកប្រទេសចិន ។ នាមព្រះវិហារ យើងពុំដឹងជាពួកចិនឱ្យឈ្មោះដូចម្តេចទេ តែជនជាតិខ្មែរ ដោយឃើញព្រះពុទ្ធរូបធំអស្ចារ្យមានកំពស់ ១៨ ហត្ថ ក៏នាំគ្នាហៅថា « *ព្រះវិហារ អដ្ឋារស* » ហើយហៅក្លាយមកទៀតថា « *ព្រះវិហារអដ្ឋរិស* » ខ្លះថា « *វិហារព្រះចិត្តរិស* » ។

• ឧបាយទី២ ស្តេចស្រុកចិនចាត់ឱ្យមន្ត្រីចិននាំប្រស្នា ៣ខ មកថ្វាយស្តេចស្រុកខ្មែរដោះស្រាយ បើដោះស្រាយប្រស្នាទាំង ៣ នេះពុំបានទេ នោះប្រទេសខ្មែរត្រូវទៅចំណុះប្រទេសចិន ត្រូវយកស្បៀងសារភាករទៅថ្វាយស្តេចស្រុកចិនរាល់ឆ្នាំ ។ តើប្រស្នានោះដូចម្តេចខ្លះ ? ស្តេចស្រុកខ្មែរដោះស្រាយដូចម្តេច ?

មន្ត្រីចិនម្នាក់ដែលជាអ្នកនាំប្រស្នាពីស្ដេចស្រុកចិន មកថ្វាយស្ដេចស្រុកខ្មែរដោះស្រាយនោះ ដំបូង, ក្រោកឈរឡើងចំពោះព្រះភក្ត្រព្រះរាជា នូវអស់មន្ត្រីខ្មែរទាំងឡាយ ហើយធ្វើអាការដូចតទៅនេះ :

- ប្រស្នាទីមួយ : មន្ត្រីចិនចំកោងខ្នង លាដៃទាំងពីរ ធ្វើរបៀបដូចឱបរបស់អ្វីយ៉ាងធំ ។
- ប្រស្នាទីពីរ : មន្ត្រីចិនក្ដាប់ដៃម្ខាង លើកឡើងកំពស់មុខ ។
- ប្រស្នាទីបី : មន្ត្រីចិនបោះដៃម្ខាងត្រង់ទៅមុខ ហើយលាម្រាដៃទាំង ៥ ក្រញាង ។

ហើយបានថ្វាយកាលកំណត់ថា ៧ ថ្ងៃ នឹងត្រឡប់មកគាល់សុំព្រះរាជទានសេចក្ដីដោះស្រាយប្រស្នាទាំងនោះ ។

ព្រះរាជាទ្រង់ព្រួយព្រះរាជហឫទ័យណាស់ ទ្រង់ត្រាស់បង្គាប់ឱ្យអស់នាម៉ឺនមន្ត្រីខំត្រិះរិះគិតរកប្រស្នាទាំងនោះ ។ ប៉ុន្តែ ដោយពុំមានមន្ត្រីរូបណាមួយអាចដោះស្រាយប្រស្នានោះបាន ទើបទ្រង់ត្រាស់បង្គាប់ឱ្យប៉ាវគងប្រកាសរកអ្នកមានប្រាជ្ញាដោះស្រាយ ។ នៅសម័យនោះ មានបុរសអ្នកគង្វាលគោម្នាក់បានឃើញគេប្រឹក្សាគ្នាជុំៗ ក៏ចូលទៅឈរស្ដាប់ហើយនិយាយថា « *ប្រស្នាទាំង ៣ នេះ ងាយដោះស្រាយសោះ, ប្រស្នាទីមួយដែលចិនធ្វើអាការដូច្នោះ គឺអង្រុតត្រី ; ប្រស្នាទីពីរដែលចិនក្ដាប់ដៃម្ខាង លើកឡើងកំពស់មុខ គឺស្នូផ្លែពៃមួយ ; ឯប្រស្នាទីបី ដែលចិនបោះដៃត្រង់ទៅមុខ ហើយលាម្រាមដៃទាំង ៥ ក្រញាង គឺរកបានត្រី ៥* » ។

អ្នកដែលបានស្ដាប់ឮទាំងប៉ុន្មាន ក៏នាំគ្នាពិចារណា និងជជីកសួរបុរសនោះថានិយាយលេង ឬនិយាយមែន ? ។ បុរសនោះប្រាប់ថា ប្រស្នាទាំង ៣ នេះប្រាកដជាប្រែដូច្នេះ ។ អ្នកស្រុកក៏នាំពាក្យនោះទៅជម្រាបដល់មន្ត្រីដែលប៉ាវគង, មន្ត្រីនោះក៏នាំបុរសអ្នកគង្វាលគោទៅថ្វាយស្ដេច ។ ព្រះរាជាទ្រង់មានព្រះរាជឱង្ការសួរបុរស

នោះអំពីដំណោះស្រាយប្រស្នាទាំង ៣ បុរសអ្នកគង្វាលគោក្រាបបង្គំទូលព្រះរាជាដោយស្ទាត់ថា ៖

- ប្រស្នាទី ១ ប្រែថា មានផែនដីមួយគឺ ប្រទេសខ្មែរយើង ។
- ប្រស្នាទី ២ ប្រែថា មានស្ដេចមួយព្រះអង្គសោយរាជសម្បត្តិនៅលើផែនដីនោះ ។
- ប្រស្នាទី ៣ ប្រែថា មានរដ្ឋមន្ត្រី ៥ នាក់ ធ្វើការមើលសុខទុក្ខរាស្ត្រ រងពីព្រះរាជាមក ។

ដល់ថ្ងៃកំណត់ មន្ត្រីចិនក៏ចូលមកគាល់ព្រះរាជាទូលសុំសេចក្ដីដោះស្រាយប្រស្នានោះ ។ ព្រះរាជាមានព្រះរាជឱង្ការត្រាស់ហៅបុរសអ្នកគង្វាលគោឱ្យមកដោះស្រាយប្រស្នា ។ បន្ទាប់ពីក្រាបថ្វាយបង្គំព្រះរាជារួចហើយ បុរសអ្នកគង្វាលគោ ក៏ដោះស្រាយប្រស្នាទាំង ៣ នោះ ចំពោះមុខរបស់ពួកមន្ត្រីខ្មែរ-ចិនថា ៖

* ប្រស្នាទី ១ គឺ ចក្រវាឡមួយគឺ ចក្រវាឡដែលយើងនៅសព្វថ្ងៃ ។
* ប្រស្នាទី ២ គឺ មានភ្នំព្រះសុមេរុមួយដ៏ធំក្រៃលែង ។
* ប្រស្នាទី ៣ គឺ មានព្រះត្រាស់ ៥ អង្គ ។

ដំណោះស្រាយនេះ ត្រូវបានមន្ត្រីចិនទទួលយល់ព្រមថា ត្រឹមត្រូវហើយ រួចក្រាបបង្គំលាព្រះរាជាខ្មែរត្រឡប់ទៅទូលស្ដេចខ្លួនវិញ ។ ព្រះរាជាស្រុកចិនក៏សុំចងមិត្តមេត្រីនឹងប្រទេសកម្ពុជា តាំងពីសម័យនោះដរាបរៀងមក ពុំបានរករឿងហេតុអ្វីទៀតឡើយ ។ ឯបុរសអ្នកគង្វាលគោនោះ ព្រះរាជាទ្រង់ប្រោសព្រះរាជទានសម្បត្តិទ្រព្យជាច្រើន ហើយតាំងងារជា « *ធនញ្ជ័យកោរព្យរាជ្យ* » ជាគោរមងារខ្ពស់បំផុតនៅក្នុងសម័យនោះ ដែលយើងសព្វថ្ងៃហៅថា " នាយករដ្ឋមន្ត្រី " ។

# អំពី " ស្ត្រីភាព "

សិក្សាដោយ **ឱម ខែម**

ពាក្យ « ស្រី » មួយម៉ាត់ ដែលខ្មែរយើងប្រើជាឈ្មោះមនុស្សស្រីនោះ ឃ្លាតមកពីពាក្យសំស្ក្រឹតថា « ស្ត្រី » គឺមនុស្សជាតិដែលមានភេទទីទៃពីបុរស, ទីទៃពីខ្ទើយ ។ ភាសាបាលីថា « ឥត្ថី » ប្រែតាមន័យវចនានុក្រមខ្មែរថា « មនុស្សដែលបុរសគួរចង់បាន, ដែលជាគូនឹងបុរស » ។

ពាក្យ « ស្រី » មួយម៉ាត់ទៀត ( សំ. ) ដែលខ្មែរយើងច្រើនប្រើជាពាក្យរួមពីខាងដើមស័ព្ទដទៃ, ដូចជា *ព្រះស្រីសពិជ្ញ* ( ព្រះសម្ពុទ្ធ ), *ស្រីសួស្តី* សិរីសួស្តិ, *ស្រីស្រីង្គារ* ស្រីដែលមានលំអគួរឱ្យកើតសេចក្តីស្រឡាញ់, ... ។ ភាសាបាលីថា « **សិរី** » ប្រែថា លំអដែលគួរឱ្យស្រឡាញ់, សួស្តី, មង្គល, ជោគ, សេចក្តីសុខ, សេចក្តីចំរើន, បុណ្យ, ភ័ព្វ, ព្រេងសំណាង, អំណាច, តេជះ ។

តទៅនេះ យើងនឹងលើកយក ភេទ លំអ និងករណីយកិច្ចរបស់ « ស្ត្រី-ភាព » មកពិចារណា ដូចតទៅ :

*ក) ភេទរបស់ស្ត្រី* : តាមធម្មជាតិ ជាភេទខ្សោយ សាច់ទន់ជ្រាយ កាយទន់ភ្លន់ ចិត្តទន់ ឆាប់ខឹង ឆាប់ជា, ផ្ទុយពីភេទបុរសដែលជាភេទខ្លាំង សាច់រឹង កាយរឹងប៉ឹង ចិត្តរឹង ក្រខឹង ក្រជា ។

រឿងខ្សោយ រឿងខ្លាំងនេះ មិនថាតែភេទមនុស្សជាស្រីជាប្រុសនោះទេ សូម្បីតែភេទសត្វជាញីជាឈ្មោល ក៏ដូចគ្នា ។

*ខ) លំអរបស់ស្ត្រី* : ក្នុងគម្ពីរធម្មបទខុទ្ទនិកាយ អាននិយាយពីលំអប្រាំ

ប្រការរបស់ស្ត្រី ( បញ្ចពិធកល្យាណី ) ពោលគឺ លំអរបស់នាងវិសា ។ លំអទាំង ៥ នោះគឺ :

១. កេសកល្យាណ — លំអសក់

២. មំសកល្យាណ — លំអសាច់

៣. អដ្ឋិកល្យាណ — លំអឆ្អឹង លំអធ្មេញ

៤. ឆវិកល្យាណ — លំអសម្បុរស្បែក

៥. វយកល្យាណ — លំអវ័យ ( ចាំសាច់ ) ។

លំអទាំង ៥ នេះ នាងវិសាខាមានគ្រប់វ័យ តាំងពីបឋមវ័យ រហូតដល់បច្ឆិមវ័យ[(១)] ។ ឯស្ត្រីដទៃទៀត មិនអាចរក្សាលំអទាំង ៥ នេះបានគ្រប់វ័យទេ ។

មានលំអំ ៣ ប្រការដោយឡែក ដែលគេឱ្យតម្លៃលើលំអស្ត្រីខ្មែរគឺ ល្អរូប ល្អរាង និងល្អរៅ ។ ព្រះភិក្ខុ ញ៉ែម គឹមតេង ប្រធានអង្គការសន្តិសេនា នៅខេត្តស្វាយរៀង បានមានពុទ្ធដីកាបំភ្លឺអំពីន័យនៃលំអទាំង ៣ ប្រការនេះថា :

- ល្អរូប គឺមានរូបសម្បត្តិល្អណាស់ ទាំងញញឹមក៏ស្រស់ទៀត,
- ល្អរាង គឺរូបភាព ហៅថាសណ្ឋានរាងល្អ,
- ល្អរៅ គឺសំដៅយកអាកប្បកិរិយាល្អ, មារយាទថ្លៃថ្នូរ, ចិត្តគំនិតស្លូតបូត សុភាពរាបសារ ។

*គ) ករណីយកិច្ចរបស់ស្ត្រី* : ធម្មជាតិតាក់តែងស្ត្រីមក សម្រាប់ធ្វើជាមាតារបស់លោក សម្រាប់ចិញ្ចឹមបុត្ត-ធីតា ថែរក្សាគ្រឹះស្ថាន និងទ្រព្យសម្បត្តិ ។

តាំងពីដើមបឋមកប្បមក[(២)] មនុស្សក្នុងលោកគ្រប់ប្រទេស គេនិយមទុកស្ត្រីឱ្យនៅតាមធម្មជាតិដើម គឺគេមិនឱ្យពួកស្ត្រីធ្វើការធ្ងន់, ប្រើកម្លាំងខ្លាំង ដូច

---

(១) បឋមវ័យ រាប់ពីអាយុ ១ ឆ្នាំដល់ ៣៣ ឆ្នាំ, មជ្ឈិមវ័យ រាប់ពីអាយុ ៣៤ ឆ្នាំដល់ ៦៧ ឆ្នាំ បច្ឆិមវ័យ រាប់ពីអាយុ ៦៨ ឆ្នាំដល់ ១០០ ឆ្នាំ ។ (២) បឋមកប្ប គឺសម័យដែលទើបកទឹក-កដី ជាដំបូង ។

ជាលើកដាក់ លីសែង កាប់គាស់ វាយដំ ធ្វើចម្បាំង ជាដើមនោះទេ, ភារៈទាំងនេះ គេទុកជាភារៈខាងពួកបុរស, ឯពួកខាងស្ត្រី គេប្រើតែខាងការងារស្រាលៗ ដូចជា ស្លដណ្ដាំ ដេរប៉ាក់ ថែទាំកូនចៅ ជាដើម ។ និយាយដោយខ្លីគឺ ប្រុសៗជាអ្នកធ្វើ ការនៅព្រៃ ស្រីៗជាអ្នកធ្វើការនៅផ្ទះ ។

សម័យបុរាណ, ប្រទេសខ្លះ គេថ្ពមពួកស្ត្រីដល់ទៅយកសំពត់រុំជើងតាំង ពីតូចៗ ដើម្បីកុំឱ្យដើរឆ្ងាយពីផ្ទះ ជាការទប់ភេទស្ត្រីឱ្យនៅតាមធម្មជាតិ, ប៉ុន្តែឥឡូវ ប្រពៃណីនេះរលុបបាត់អស់ទៅហើយ ។

ប្រទេសខ្មែរយើង ក៏និយមទុកពួកស្ត្រីឱ្យប្រព្រឹត្តទៅតាមធម្មជាតិដើម ដែរ ។ សម័យបុរាណ អ្នកស្រុកមិនឱ្យស្ត្រីរៀនអក្សរទេ, គេនិយាយបន្ទាចគ្នាថា « *មិនត្រូវឱ្យស្ត្រីរៀនអក្សរ ព្រោះតែរៀនចេះទៅ នឹងសរសេរសំបុត្រទៅរក ប្រុសឈ្មោលតាមអំពើចិត្ត* » ។ ពាក្យបន្ទាចនេះ បានធ្វើឱ្យស្ត្រីខ្មែរច្រើនភាគរយ មិនចេះអក្សរ, ប៉ុន្តែ សម័យបច្ចុប្បន្ន គេលែងឮពាក្យបន្ទាចនេះទៀតហើយ, គេ ត្រឡប់ជាឮនិយាយប្រាប់គ្នាថា ត្រូវតែឱ្យស្ត្រីរៀនសូត្រគ្រប់មុខវិជ្ជា ដើម្បីសេចក្ដីរីក ចំរើននៃប្រទេសជាតិ ។

ក្រោយពេលប្រទេសជាតិបានរំដោះរួចពីរបបប្រល័យពូជ សាសន៍ នាឆ្នាំ ១៩៧៩ ជាពេលដែលចាប់ផ្ដើមកសាងមាតុប្រទេសពីកំរិតទាប គេឃើញពាក្យ ស្លោកថា « *នារីជាមាតានៃពិភពលោក* », « *គ្មាននារីចូលរួម មិនអាចកសាង សង្គមបានឡើយ* » ។ នេះជាពាក្យស្លោកមានតម្លៃអប់រំ តម្លៃវប្បធម៌ និងតម្លៃ នយោបាយ ។ ដោយសារការអនុវត្តពាក្យស្លោកនេះ ទើបមានកម្លាំងនារីចូលរួមការ ងារសង្គមយ៉ាងផុលផុស ។ នៅក្នុងករណីយកិច្ច និងភារពកិច្ចរបស់ខ្លួន នារីកម្ពុជា មានគុណសម្បត្តិច្រើនក្នុងការរួបចំណែកស្ថាបនា កសាង និងការពារមាតុភូមិ ។

ពិតមែនតែធម្មជាតិពាក់តែងឱ្យស្ត្រីមានភេទខ្សោយ សាច់ទន់ជ្រាយ

កាយមិនរឹងប៉ឹង ចិត្តទន់ ប៉ុន្តែ ស្ត្រីអាចបង្ហាត់កាយរបស់ខ្លួនតាមក្បួនអនាម័យ និងអត្តពលកម្មឱ្យរឹងប៉ឹង ឱ្យរហ័សរហួន, អប់រំចិត្តតាមក្បួនសិក្សាឱ្យមានប្រាជ្ញាវាងវៃប៉ិនប្រសប់លើសធម្មតាបាន មិនអន់ជាងបុរសប៉ុន្មានទេ ជួនកាលមានគ្រាន់បើជាងបុរសខ្លះដោយអន្លើៗផង ប្រសិនជាគេព្យាយាមហ្វឹកហាត់ និងអប់រំម៉ឺងម៉ាត់ ម៉ត់ចត់មែនទែន ។ យ៉ាងណាមិញ :

• *សម័យមុនពុទ្ធកាល* : មានស្ត្រីម្នាក់ឈ្មោះនាង « អមរា »[1] ជាមហេសីនៃព្រះមហោសថពោធិសត្វ ជារាជបណ្ឌិតនៃព្រះបាទវិទេហរាជ ។ ថ្ងៃមួយអាចារ្យ ទាំង ៤ នាក់ ដែលជាគូសត្រូវនឹងព្រះមហោសថ បានលួចកែវមណីព្រះរាជទ្រព្យទៅលក់ឱ្យនាងអមរា, នាងបានទទួលទិញ ដោយកត់ទាំងឈ្មោះអ្នកលក់ ទាំងពេលទិញ, ហើយពួកអាចារ្យទូលព្រះមហាក្សត្រមួលបង្កាច់ថាព្រះមហោសថលួច ។ ព្រះរាជាទ្រង់ព្រះបញ្ជាឱ្យហៅព្រះមហោសថ ។ ព្រះមហោសថ ឃើញថាកែខ្លួនពុំបាន ក៏ប្រាប់នាងអមរាថា គួរភៀសខ្លួនសិន ។ ពេលនោះ ពួកអាចារ្យចង់បាននាងអមរាជាភរិយា ក៏ឱ្យដំណឹងថា នឹងទៅជួបនាងក្នុងវេលាយប់នៅផ្ទះនាង ។ ឯនាងអមរាឱ្យកម្មករជីករណ្តៅក្រោមផ្ទះដាក់លាមក ក្នុងរណ្តៅនោះក្រាលក្តារពីលើ ធ្វើគន្លឹះឱ្យជាន់របូត ហើយក្រាលកម្រាលដូចអាសនៈធម្មតា ។ វេលាពួកអាចារ្យមកដល់ដើរជាន់កម្រាល ក៏ធ្លាក់ទៅក្នុងរណ្តៅនោះរណ្តំក្បាលគ្នា ។ នាងអមរា ក៏ឱ្យចាប់អាចារ្យទាំង ៤ នាក់ចងភ្ជាប់គ្នានាំទៅថ្វាយព្រះរាជា ។ ព្រះអង្គទ្រង់ព្រះវិនិច្ឆ័យថាកំហុសនេះធ្លាក់ទៅលើអាចារ្យទាំង ៤ ។ ព្រះមហោសថរួចខ្លួន ដោយសារនាងអមរាជាមហេសី ដែលជាស្ត្រីបានសិក្សា មានប្រាជ្ញាច្រើនជួយដោះកុន ។

• *សម័យពុទ្ធកាល* : មានស្ត្រីម្នាក់ឈ្មោះនាង ខុជ្ជុត្តរា ជាស្ត្រីបំរើពួកព្រះស្នំរបស់ព្រះឧទេន ព្រះចៅក្រុងកោសម្ពី មានព្រះនាងសាមាវតីជាដើម ដែលព្រះរាជាទ្រង់ហាមពួកព្រះស្នំ មិនឱ្យទៅស្តាប់ព្រះធម៌ទេសនានៃព្រះសម្មាសម្ពុទ្ធ នៅក្រៅ

វាំង ។ ព្រះស្នំទាំងនោះបានចាត់ឱ្យនាងខុជ្ជុត្តរាទៅស្តាប់ធម៌ ហើយឱ្យនាំយកព្រះធម៌នោះមកសំដែងប្រាប់ព្រះស្នំ ។ នាងខុជ្ជុត្តរាបានទៅស្តាប់ និងបានសំដែងធម៌ឱ្យព្រះស្នំស្តាប់រាល់ថ្ងៃ ក៏បានទៅជាអ្នកប្រាជ្ញមួយរូប ពូកែខាងសំដែងធម៌ បានលាភសក្ការៈច្រើន ។

មានរឿងនិទានមួយទៀត ក្នុងសម័យពុទ្ធកាលដែរថា ៈ មានស្ត្រីម្នាក់ឈ្មោះនាងកុណ្ឌលកេសី ជាកូននៃរាជគហសេដ្ឋី នាងបានសុំឱ្យបិតាលោះចោរម្នាក់ដែលពេជ្ឈឃាតបណ្តើរទៅសម្លាប់យកមកធ្វើប្តី ។ ចោរមកនៅផ្ទះសេដ្ឋី តែចង់ទៅនៅព្រៃវិញ, វាល្បួងនាងឱ្យជូនវាទៅព្រៃ ដើម្បីលាបំណន់ក្បែរមាត់ជ្រោះនៅជើងភ្នំមួយ វាឱ្យនាងស្លៀកពាក់ល្អ មានគ្រឿងមាសពេជ្រជាច្រើន ដើម្បីសម្លាប់យកគ្រឿងប្រដាប់ស៊ីចាយ ។ លុះទៅដល់មាត់ជ្រោះ ចោរប្រុងសម្លាប់នាង ។ នាងកុណ្ឌលកេសីគិតថា « ធម្មតាប្រាជ្ញាដែលគេខំរៀនសូត្រមក គេមិនដែលយកវាទៅស្ងោរស៊ីជាអាហារទេ គេត្រូវតែប្រើវាដោះខ្លួនឱ្យផុតពីភ័យអាសន្ន » ។ លុះគិតហើយ នាងលួងចោរថា « *អ្នកបង ! ខ្ញុំដឹងគុណណាស់ ដែលអ្នកបានមកធ្វើជាប្តីខ្ញុំនេះ តែមុននឹងព្រាត់ចាកអ្នក ខ្ញុំសូមបូជាគុណអ្នកសិន សឹមស្លាប់* » ។ ថាហើយក៏សំពះទៅទិសទាំង ៤ ដើរប្រទក្សិណចោរ ៣ ជុំ ហើយច្រានចោរធ្លាក់ជ្រោះស្លាប់ទៅ ។

កាលដែលចោរធ្លាក់ជ្រោះ ពួករុក្ខទេវតាដែលអាស្រ័យនៅព្រៃនោះ ក៏ស្រែកបន្លឺឱ្យសព្ទសាធុការថា ៈ

*ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ*
*ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ។*

ប្រែថា ៈ បុរសមិនមែនជាបណ្ឌិតគ្រប់ហេតុទាំងពួងទេ, ស្ត្រីក៏ជាបណ្ឌិតអាចពិចារណាក្នុងហេតុនោះៗដែរ ។

គឺថា ៖ អ្នកប្រាជ្ញមិនមែនមានតែបុរសទេ, ស្ត្រីបើខំរៀនសូត្រចំណេះវិជ្ជាខាងផ្លូវលោកក្តី ខាងផ្លូវធមិក្តី ក៏បានជាអ្នកប្រាជ្ញដូចគ្នា ។

• *នៅសម័យនគរភ្នំ* ( ហ្វូណាន ) គ្រិស្តសតវត្សទី ១ ៖

យើងមានមេនាយកជាតិខេមរៈ ហើយជាស្ត្រីភាព បានតាំងខ្លួនជាស្តេចមានព្រះនាមជាក្សត្រិយ លិវយិ ឬ សោម៉ា ( កូនព្រះចន្ទ ) ដែលខ្មែរហៅថា « នាងសក់ក្រអូប » ទ្រង់សោយរាជ្យលើកោះគោកធ្លក ឬ ប្រទេសខ្មែរ ។ មានព្រះរាជាមួយព្រះអង្គទ្រង់ចាកចេញប្រទេសឥណ្ឌាភាគខាងត្បូង ចូលមកកាន់ប្រទេសខ្មែរដំបូងបំផុត ព្រះនាម « ព្រះបាទកុមេរុ » ។ ព្រះរាជាអង្គនេះបានធ្វើសង្គ្រាមនឹងព្រះរាជិនីព្រះនាមលិវយិ ។

កាលព្រះរាជិនីលិវយិចាញ់សង្គ្រាមហើយ ព្រះនាងក៏សព្វព្រះទ័យទទួលយកព្រះបាទកុមេរុជាព្រះស្វាមី អភិសេកសោយរាជ្យនៅនគរភ្នំ « ភ្នំ » ។ ព្រះមហាក្សត្រអង្គនេះហើយជាដើមព្រះរាជវង្ស គឺសន្តតិវង្សទី ១ នៃប្រទេសកម្ពុជា ។ រឿងនេះសរឱ្យឃើញថា ប្រទេសខ្មែរដំបូងបំផុត មានស្ត្រីខ្មែរជាស្តេចគ្រប់គ្រង ។

• *សម័យអង្គរ* ( គ្រិស្តសតវត្សទី ១៣ ) ៖

សិលាចារឹកនៅប្រាសាទអង្គរប្រាប់ថា « *ព្រះនាងអគ្គមហេសី នៃព្រះបាទជ័យវរ្ម័នទី ៧ ពូកែលើសលលប់ ឥតនរណាស្មើខាងវិទ្យាសាស្ត្រ និងបរមត្ថសាស្ត្រ ព្រះរាជាទ្រង់តាំងជាព្រះបរិនាយិកាក្នុងព្រះអារាមព្រះពុទ្ធសាសនាដ៏ល្បីល្បាញមួយ ព្រះនាងបានបង្រៀនពួកស្ត្រី* » គឺព្រះនាងនេះហើយ ដែលធ្វើឱ្យយើងដឹងដោយសិលាចារឹកយ៉ាងធំមួយនៅប្រាសាទភិមានអាកាស ដែលព្រះនាងតែងដោយព្រះអង្គឯងថា « *ព្រះនាងគង់នៅក្នុងទីកន្លែងមួយឈ្មោះនរេន្ទ្រាស្រមជាទីសិក្សា ដែលពួកស្ត្រីរាជបរិពារមករៀនសូត្រ ព្រះនាងមាននាមល្បីល្បាញក្នុងទីនោះ ដោយការគោរពរបស់សិស្សទាំងឡាយ ព្រះនាងក៏ធ្វើឱ្យពួកស្ត្រីទាំង*

នោះបានសេចក្ដីសុខ ឧបមាដូចជាទេវធិតាឈ្មោះសរស្វតីបែងភាគមក ... ព្រះនាងបានផ្សាយសេចក្ដីមេត្តាព្រះមហាក្សត្រ ចំពោះស្ត្រីណាដែលចូលចិត្តសិក្សា វិទ្យាសាស្ត្រ ឧបមាដូចជាទឹកទិព្វយ៉ាងប្រសើរដែលហូរចេញមកជាសេចក្ដីចេះដឹង » ។

• *សម័យព្រះរាជវាំងកោះស្លាកែត* ( គ.ស. ១៨៣៤ ដល់ ១៨៤៧ )

ប្រទេសកម្ពុជាមានស្ត្រីភាពជាព្រះរាជិនី គឺព្រះអង្គម្ចាស់ ក្សត្រីព្រះរាជបុត្រីព្រះបាទឧទ័យរាជា ( អង្គចន្ទ ) ស្ដេចឡើងសោយរាជ្យតំណពីព្រះវរបិតា គង់នៅក្នុងព្រះបរមរាជវាំងកោះស្លាកែត ( ត្រើយពោធិ៍ព្រះបាទ ) ក្នុងខេត្តកណ្ដាល ។ រជ្ជកាលនេះ ជារជ្ជកាលទី ៧៨ នៃសន្តតិវង្សប្រទេសកម្ពុជា, មុនរជ្ជកាលព្រះករុណាបរម.កោដ្ឋ ( ព្រះអង្គដួង ) ដែលគង់នៅព្រះបរមរាជវាំងឧដុង្គមានជ័យ ។

• *សម័យភ្នំពេញ* ( គ.ស. ១៩៥៥ ) :

ប្រទេសកម្ពុជា មានព្រះមហាក្សត្រ ២ ព្រះអង្គ គឺព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះនរោត្តម សុរាម្រឹត ជាព្រះរាជស្វាមី និងសម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរត្ន សិរីវឌ្ឍនា ជាព្រះអគ្គមហេសីទ្រង់ឡើងសោយរាជសម្បត្តិ ពីថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៥៥ ជារជ្ជកាលទី ៨៤ នៃព្រះសន្តតិវង្សប្រទេសកម្ពុជា តំណពីរជ្ជកាលទី ៨៣ នៃព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ជាព្រះរាជបុត្រដ៏ឆ្នើមរបស់ព្រះអង្គ ។

ការសិក្សារបស់យើងដោយសង្ខេបមកប៉ុណ្ណេះ បញ្ជាក់ឱ្យឃើញថា : ស្ត្រីភាពដែលធម្មជាតិតាក់តែងមកជាភេទខ្សោយ សាច់ជ្រាយ កាយទន់ភ្លន់ ចិត្តមិនសូវរឹងប៉ឹងនោះ បើបណ្ដោយទុកតាមធម្មជាតិ ក៏ខ្សោយតាមដើម ប៉ុន្តែបើគេបានអប់រំបន្ទំនិស្ស័យ ដោយក្បួនអនាម័យ ក្បួនវិទ្យាសាស្ត្រ និងក្បួនសិក្សាយ៉ាងម៉ឺងម៉ាត់ ក៏ទៅជាមនុស្សខ្លាំង សាចរឹង កាយរឹងប៉ឹង ចិត្តពូកែក្លាហាន មានប្រាជ្ញាប៉ាធិស្មើនឹងបុរសដែរ ឬពូកែជាងបុរសខ្លះដោយអន្លើ១ ក៏សឹងមាន ។

ព្រោះហេតុនេះបានជា មនុស្សលោកសម័យបច្ចុប្បន្ន គេនិយមឱ្យស្ត្រីធ្វើវិធិហាត់ប្រាណ ដើម្បីឱ្យស្ត្រីមានសុខភាព ឱ្យមាកម្លាំងពលរឹងប៉ឹង រហូតដល់អាចធ្វើជាទាហាន ឬជាពេទ្យទាហាន ទៅប្រតិបត្តិការក្នុងកងទ័ពបាន, ឱ្យស្ត្រីរៀនអក្សរដើម្បីឱ្យមានប្រាជ្ញាជ្រៅជ្រះ រហូតដល់ធ្វើជាសាស្ត្រាចារ្យ ជាអ្នករាជការកាន់មុខតំណែងធំៗ(*) បាន, ឱ្យរៀនសិល្បៈវិជ្ជាគ្រប់បែប ដើម្បីឱ្យបានជាសិល្បករ ជាហត្ថករ ឧស្សាហករ ពាណិជ្ជករ កសិករ និងកម្មករជំនាញៗ សម្រាប់ជំរុញសេដ្ឋកិច្ចរបស់ប្រទេសឱ្យមានវឌ្ឍនភាព ។ល។

ប្រទេសកម្ពុជាយើង ចាប់តាំងពីសម័យរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម រហូតដល់សម័យរាជរដ្ឋាភិបាលបច្ចុប្បន្ន គឺឱ្យស្ត្រីមានសិទ្ធិស្មើនឹងបុរស, អាចបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួន, អាចឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតជ្រើសតាំងខ្លួនជាតំណាងរាស្ត្រ, ឱ្យស្ត្រីហាត់ប្រាណតាមអត្តពលកម្មវិធី ឱ្យមានរាងកាយរឹងប៉ឹង មានសុខភាព, ឱ្យហាត់កាន់កាំភ្លើង, ដូចក្នុងផែនការព្រះសីហនុ ដែលតាំងស្ត្រីខ្មែរឱ្យជានារីក្លាហាន ដំណាលគ្នានឹងបុរសដែលតាំងជាកងជីវពល កាន់កាំភ្លើងប្រតិបត្តិការសាមគ្គីមានជោគជ័យ ដរាបដល់ដណ្តើមយកឯករាជ្យពេញទីជូនមាតុប្រទេសបាន ពីថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ។

ឈានចូលដល់សតវត្សទី ២១, សតវត្សនៃអរិយធម៌ខាងស្មារតី, អនាគតនៃប្រទេសកម្ពុជាយើង នឹងមានវឌ្ឍនភាពដោយសារកំលាំងស្ត្រីខ្មែរដែលមានចំណេះដឹង ចំណេះធ្វើ ហើយរួបរួមគ្នាការពារ និងអភិវឌ្ឍប្រទេសជាតិ ឱ្យបានរីកចំរើនជាអភិយោភាព ក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ស្របតាមន័យនៃគតិបណ្ឌិតថា : *ស្ត្រីជាពលភាពប្រទេសជាតិ អាចជួយប្រុសវាតសកម្មភាព ជួយជាតិសាសនាប្រាជ្ញត្រូវជ្រាប យោងដីសំណាបស្រីយោងប្រុស ។*

*

# គតិបណ្ឌិត : សំណាបយោងដី ...

« សំណាបយោងដី ស្រីយោងប្រុស
ពូថៅយោងឧស ច្រមុះយោងថ្ពាល់ »

---------

*សិល្បៈសំដី*

*បុរាណកវី ប្រៀបធៀបឧបមា*
*កំប្លុកកំប្លែង ថ្លែងរាយវោហារ*
*បង្កប់ខ្លឹមសារ មានជ្រៅមានរាក់ ។*

• *សំណាបយោងដី*

*គតិប្រពៃ ក្នុងន័យបញ្ឆាក់*
*សំណាបណាល្អ បវរពេញលក្ខណ៍*
*ទោះអស់លោកអ្នក យកស្ទូងស្រែណា ។*

*ស្រែព្រោកស្រែព្រាច*
*ស្រែវាលប៉ាចបាច ត្រង់បានផលា*
*ស្ទូងហើយលូតលាស់ បង្ហាញកាយា*
*គេតែងពោលថា ស្រែនោះដីល្អ ។*

• *ឯស្រីយោងប្រុស*

*លោកថាមិនខុស មានក្លាយជាក្រ*
*ដូចនាយសំពៅ យកពេជ្រដូរថ្ម*
*ក្បត់ចិត្តស្មោះសរ ពីស្ងួនភរិយា ។*

ឃើញនាងនារី

ស្រីអលង្ការ មានរូបសោភា
ប្រពន្ធមាណព តាមផងផលធារ
កំពុងនាំគ្នា ជញ្ជាត់ចាប់ត្រី ។

រឿងតូចតាចសោះ

បង្កើតជម្លោះ ជូរប្រពន្ធប្តី
គូដែលសប្បាយ គូលោកសេដ្ឋី
ឯគូភក្តី គឺចៅមាណព ។

ដោយសារតែស្រី

នាងគ្រប់លក្ខណ៍វៃ ឆ្លាតដឹងសព្វគ្រប់
ផ្តល់ជាយោបល់ មិនចេះឈររឈប់
ទើបចៅមាណព ស្គាល់អង្គក្សត្រា ។

មិនតែប៉ុណ្ណោះ

មង្គលរីកដុះ ពេញទាំងត្រៃសារ
កិត្តិយសរន្ទឺ សាយគ្រប់ទិសា
ឯនាយភេត្រា ធ្លាក់ខ្លួនសុំទាន ។

• ពូចៅយោងឧស

លោកអ្នកចាំចុះ ជូនតាទូន្មាន
ឧសខ្លួតសាច់ត្រង់ ឧសថ្នាំងលីបល្បឿន
សម្លឹងឈរឈាន ចង់ពុះបំបែក ។

អោយប្រើពូចៅ

មានផងត្រឹមត្រូវ ចាត់ទុកជាឯក

ផ្លែស៊ីនឹងដង មិនបោះកោងកែក
ទុកដាក់តាមផ្ទៃក លំដាប់តូចធំ ។

ពេលយកទៅពុះ

មើលប្រភេទឧស ពុះអោយចំមុំ
បើឧសសាច់ត្រង់ ប្រើពូថៅធំ
មុខវាក្រពុំ ងាយបំបែកបាន ។

ឧសសាច់កណ្តាញ់

ប្រើអាល្មមវិញ ទើបវាចំណាន
មុខវាមុតល្អ កាប់ចាំងជេះបាន
ទោះថ្នាំងប៉ុន្មាន ពុះបានទាំងអស់ ។

• ច្រមុះយោងថ្គាល់

អ្នកគិតអោយដល់ កុំធ្វើឡេះឡោះ
មិច្ឆាទិដ្ឋិ នាំអោយរងគ្រោះ
ឃើញថ្គាល់គេស្រស់ ចង់ស្រោចស្រីង្គារ ។

នទៀលផ្តេកផ្តិត

តាមវិស័យចិត្ត ស្របតន្ទមាលា
លើថ្គាល់ផ្ទូរផង់ នៃនាងពិម្ពា
ប្រតិព័ទ្ធវន្តា នាំតែចំបែង ។

តាមពិតនាសា

យោងថ្គាល់អ្នកណា គឺយោងខ្លួនឯង
ថ្គាល់អន់តិចតួច អោយតែវាខែង
ស្លូចស្រល់ចាំងចែង ដូចស្មែងភគ្គា ។

*បើផែនថ្គាល់ភ្លោះ*

*មាននាសាខ្ពស់ ហើយទ្រង់វ៉ែនតា*

*នោះរឹតតែធ្វើ អោយវង់ភក្ត្រា*

*លេចឡើងសង្ហា ដូចយាង្សបក្សី ។*

*តែផ្ទុយមកវិញ*

*ទោះថ្គាល់ប៉ោងពេញ រលោងម៉ដ្ឋខៃ*

*ចំណែកច្រមុះ ធំស្បៀតខើចខ្ចី*

*ក្រពិតអប្រិយ យោងថ្គាល់អីកើត ។*

**ឆន ឈាង**

## សុភាសិត :

- *ខែកត្តិកជាប្រធានរដូវកាល រូបវិសាលជាប្រធានសព្វភរិយា បុត្រចម្បងជាប្រធានបុត្រនានា ទិសឧត្តរជាប្រធានទិសទាំងពួង ។*

# អំពីព្រះបាទធម្មិក

## ( ក្បួនពុទ្ធទំនាយ ត-ចប់ )

កាលបើដូច្នេះ កាលឯណាឡើយនឹងលើកសាសនាអញតថាគតបាន ហើយបើបានសោយរាជ្យ ២៥ ឆ្នាំហើយ ឱ្យឆាប់ផ្ទេររាជ្យឱ្យព្រះពុទ្ធវង្សសោយរាជ្យវិញ ។ ឯព្រះពុទ្ធវង្សសោយរាជ្យកំណត់បានតែ ៥៣ ឆ្នាំ បើសោយរាជ្យបានតែ ១២ ឆ្នាំហើយ នឹងបានលើកសាសនាអញតថាគតបោង ឯស្តេចធនរាជនោះសោយរាជ្យបាន ២៥ ឆ្នាំ ហើយពុំបានផ្ទេររាជ្យទៅព្រះពុទ្ធវង្សឡើយ ។ លុះដល់សាសនាអញតថាគតបាន ២៤២៥ ព្រះវស្សា ឆ្នាំមមែ បញ្ចស័ក ខែជេស្ឋ ? រោច ថ្ងៃអង្គារ វេលាព្រឹក នោះមានទមិឡអន្សតិរ្ថិយ៍វាមកគ្របយកនគរនោះបាន ។ លុះដល់ឆ្នាំ វក ឆស័ក នោះ មនុស្សទាំងអស់កើតកោលាហល រវល់រីករវក្នុងព្រះនគរនោះ ។ លុះដល់ឆ្នាំ កុរ នពស័កនោះ ព្រះពុទ្ធរូបស្នងអញតថាគត នឹងទៅនៅក្នុងព្រៃព្រឹក្សា ដូចជាអ្នកតាអារក្ស ។ ក្នុងឆ្នាំនោះ អាចារ្យផងទាំងឡាយ ត្រូវខ្មោចព្រាយវាចូលទៅគ្រប់តែរាល់គ្នា ។ លុះដល់ឆ្នាំ កុរ នពស័កនោះ មានស្តេចមួយឈ្មោះថាអង្គុលិរាជ មកពីបស្ចិមសម្បុរចេកទុំ ដំណើរទ្រង់ចិននោះ ចូលមកផ្ចាលផ្ចាញ់ទមិឡអន្សតិរ្ថិយ៍ បានបាក់បបខ្ចបខ្ចាច បានផ្ទេររាជ្យឱ្យទៅព្រះពុទ្ធវង្សសោយរាជ្យ ។

លុះដល់ឆ្នាំរោង ចត្វាស័កនោះ មានអ្នកទាំង ៥ ប្រកាប់គ្នានៅទន្លេ ៤ មុខ នោះឯង អាវុសោអើយ ! ។

លុះដល់ឆ្នាំ កុរ នពស័កនោះ សាសនាអញតថាគតបាន ២៤៥២ ព្រះវស្សា នោះមានទមិឡវាមកសោយរាជ្យធ្វើជាស្តេចចក្រពត្រាធិរាជ ក្នុងខែវិសាខ ។ នាកាលទមិឡវាសោយរាជ្យនោះ មនុស្សផងទាំងឡាយសម្បូរក្បេមក្សាន្ត សំពត់អាវ គ្រឿង

ប្រដាប់សម្រាប់រាត្បា យកតែពីដើមព្រឹក្សា អស់ទាំងចំណីភោជនាហារ សឹងតែមានច្រើនណាស់ អានុំសោអើយ ស្ដេចនោះសោយរាជ្យទៅ ផាចង់ប្រើទឹកក៏បាន ប្រើដីក៏បាន ប្រើភ្លើងក៏បាន ប្រើខ្យល់ក៏បាន ផានឹងចង់ប្រើដែកក៏បាន ប្រើខ្មោចក៏បាន សប្បាយណាស់ កូនមិនស្គាល់ឪពុក, ឪពុកមិនស្គាល់កូន, កូនមិនស្គាល់ម្ដាយ, ម្ដាយមិនស្គាល់កូន, បងមិនស្គាល់ប្អូន, ប្អូនមិនស្គាល់បង, សិស្សមិនស្គាល់គ្រូ, គ្រូមិនស្គាល់សិស្ស, រាស្ត្រមិនស្គាល់នាហ្មឺន, នាហ្មឺនមិនស្គាល់ស្ដេច, ច្រើនយកខុសជាត្រូវ, ត្រូវជាខុស, មនុស្សប្រុសដូចស្រី, ស្រីដូចប្រុស យកតែខុសក្នុងសាសនាអញ្ជតផាគតបើកំណត់ជិតដល់ ២៥០០ ព្រះវស្សាហើយ ឱ្យមើលតែរោគមនុស្សនៅក្នុងនគរ បើស៊ីផឹកវឹកវរ លេងបៀប៉ោសព្វថ្ងៃ ព្រៃព្រឹក្សានោះ ហៅផាឧត្បាតមកបង្កើត ណ៎ាអានុំសោអើយ ! នោះរៀបដល់ព្រះបាទធម្មិកមកលើកសាសនាអញ្ជតផាគតហើយ ឱ្យមនុស្សផងទាំងឡាយកើតខ្វល់ខ្វាយនឹងទ្រព្យ មាសប្រាក់ មានចោរចេញពីព្រៃមកនៅចាក់កាប់សម្លាប់គ្នា ជំងឺរោគាក៏មានច្រើន ទាំងរាស្ត្រ ទាំងនាហ្មឺន ពុំសប្បាយមនុស្សផងទាំងឡាយក៏ទ្រឹក្សអត់បាយក្នុងព្រះនគរ តាំងពីឆ្នាំរោង សំរឹទ្ធិស័ក ហើយមនុស្សផងទាំងឡាយមើលទៅទិសខាងកើតទន្លេ ៤ មុខ បើឃើញព្រះវិហារព្រះគោព្រះកែវធ្វើឱ្យរួចហើយនោះ ឱ្យមើលផ្ទះថ្មសសរឫស្សី ឱ្យមើលចេតិយទីព្រះរាជវាំងបើតាំងស្រេចហើយ ឱ្យមើលប្រាសាទ និងផ្សារ ក្រោយបាក់ទូក បើរួចស្រេចហើយ អានុំសោ ! លុះដល់ឆ្នាំម្សាញ់ ឯកស័ក ព្រះបាទធម្មិកលោកចេញទៅនោះ ស្រទំ ៧ ថ្ងៃ រួចពីនោះភ្លៀងវស្សាដូចប្រាំង, ប្រាំងដូចវស្សា លុះគ្រាតែដល់ ៧ ឆ្នាំហោង ។ លុះដល់ឆ្នាំមមី ទោស័កនោះ មនុស្សផងទាំង ឡាយក៏កើតក្ដៅក្រហាយ ទាំងឧបាសកឧបាសិកា ក៏រឹតរអាឡាងផាត្រឹមត្រូវ ទាំងលោកសង្ឃក៏លើកសិក្ខាវិន័យ ចីវរសង្ឃាដី ក៏នឹងបាត់ខ្លួនអស់ក្នុងឆ្នាំនោះ ណ៎ាអានុំ សោ ! ។ លុះដល់ឆ្នាំវក ចត្វាស័កទើបមានស្ដេចមួយមកអំពីទិសខាងជើង មកដណ្ដើមបាវាំងសេវស ទើបស្ដេចនោះ

យកខ្លួនចេញទៅ ទើបមានស្តេចមួយមកអំពីទិសខាងលិច នោះបារាំងទៅទទួលយកមកឱ្យសោយរាជ្យ ទើបបារាំងតាំងធ្វើជាធម្មិក ៨ ទិសឡើង ។ លុះដល់ឆ្នាំរកាបញ្ចស័ក ទមិឡវានឹងផយអស់រាជ្យទៅ មនុស្សផងទាំងឡាយនឹងចេញមកអំពីព្រៃមកច្បាំងគ្នា ។ ក្នុងឆ្នាំច ឆស័កនោះ ព្រះបាទអង្គលិរាជ លើកពលមកអំពីលោងស្មោចូលច្បាំងក្នុងនគរកម្ពុជានោះ ។ ក្នុងឆ្នាំច នពស័កនោះ ព្រះបាទអង្គលិរាជនោះនាំពលចូលទៅក្នុងទន្លេ ៤ មុខ ។ ដល់មកសាសនាអញតថាគតបាន ២៥០០ ព្រះវស្សាឆ្នាំជូត អដ្ឋស័កនោះឯង ពាក់កណ្តាលព្រះសាសនាអញតថាគត ហៅថាសូន្យសុងក្នុងព្រះនគរកម្ពុជា នៅតែ ភិក្ខុ ៤ អង្គ មហាឫសី ៤ នាក់ និងអាចារ្យ ១ ទេណាំអារុំសោរអើយ ! កើតចម្បាំង តាំងអំពីបឹងស្រង់ វៀងទៅដល់កំពង់ទួល ចូលដល់ទួលព្រះស្រី ចេញទៅល្វាឯម ទើបចូលក្នុងទន្លេ ៤ មុខវិញ កើតចម្បាំង ៧ ឆ្នាំឈាមដាបពោះដីរ នៅទន្លេ ៤ មុខ នោះឯង ។ ទើបបានក្តៅដល់សម្តេចព្រះឥន្ទ្រាធិរាជ ព្រះអង្គក៏ប្រើព្រះពិស្ណុការឱ្យអាភាសជាចិន្ត លិតម្ពីរមករកព្រះបាទធម្មិកនោះ ទើបព្រះពិស្ណុការទទួលព្រះបន្ទូលហើយ ក្រាបថ្វាយបង្គំផ្លោះហោះមកកាន់ឋានមនុស្សលោកមួយរំពេច នៅទន្លេ ៤ មុខ ។ រីឯធម្មិកទាំង ៨ ទិស នោះកំពុងច្បាំងគ្នានៅទីនោះឯង ទើបធម្មិកនៅពោកធ្លករមិលមើលឃើញចិន្តលិតម្ពីរ ទើបសួរថា « ចិន្តលិតម្ពីរទៅណា អ្ហា៎ះ ! » ទើបចិន្តបន្តប្រាប់ថា « អញលិតម្ពីរនេះទៅរកធម្មិក ! » ទើបធម្មិកនៅនោះក៏ឆ្លើយថា « យើ ! ទៅឯណាវិញ អ្ហា៎ះ ! អញនេះឯងហើយជាអង្គព្រះបាទធម្មិករាជ » ។ ចិន្តថា « អ្នកឯងអង្គនេះ មិនមែនជាអង្គព្រះបាទធម្មិករាជឡើយ » ទើបដើរចេញទៅ ប្រទះនឹងអាចារ្យមួយទៀត ទើបចិន្តដណ្តឹងសួរថា « អើ អ្នកអាចារ្យអើយ ! អ្នកអាចារ្យក្រែងបានដឹងបានឮ គេថាព្រះបាទធម្មិករាជនោះ តើលោកគង់នៅឯណា ? » ទើបអាចារ្យថា « ចិន្តអើយ ! អញឮគេថា ព្រះបាទធម្មិករាជនោះគង់ ២៧ ឆ្នាំ នៅឯភ្នំពេញ » ទើបចិន្តឆ្លើយថា

« ទេ ! ឯនោះខ្ញុំដើររកពុំឃើញឡើយ » ទើបចេញពីអាចារ្យនោះទៅយូរបន្តិច ប្រទះមហាឥសីមួយព្រះអង្គ ចិន្តសួរថា « លោកតាអើយ ! លោកតាបានប្រទះព្រះបាទធម្មិករាជលោកគង់ត្រង់ឋានឯណា សូមលោកតាប្រាប់ខ្ញុំឱ្យបានដឹងផង ! » ទើបមហាឥសីប្រាប់ថា « ចិន្តអើយ ! ព្រះបាទធម្មិករាជនោះ ព្រះអង្គគង់នៅភ្នំខ្ចិងភ្នំត្បែងនោះឯង ណ៎ាចិន្តអើយ ! » ហើយចិន្តនោះក៏ដើរចេញទៅឃើញភិក្ខុមួយអង្គគង់លើថ្មនោះ មើលទៅចីពរខ្មៅដូចជាផ្សែងភ្លើងរោល មើលទៅស្បង់ ក៏ដាច់គ្មានសល់ឡើយ គង់លើថ្មនោះឯង ទើបចិន្តសួរថា « អើ, អ្នកភិក្ខុអើយ អ្នកភិក្ខុ ! អ្នកឯងនេះ ហើយជាអង្គព្រះបាទធម្មិករាជនោះ » ទើបអ្នកភិក្ខុឆ្លើយថា « ទេ ! អាចក្តីនេះ មិនមែនទេ ឯព្រះបាទធម្មិកនោះមិនដឹងជាគង់នៅឋានឯណាឡើយ អាចក្តីបួសចម្រើនមេត្តាភាវនា ចង់ឱ្យតែជួបព្រះបាទធម្មិកនោះដែរ ចិន្តឯងកុំឱ្យមាត់ថាអាចក្តីនេះ ។ ទើបចិន្តក៏ដើរពីទីនោះបន្តិចទៅហើយក៏បើកគម្ពីរឡើង ឃើញត្រូវហើយ ក៏ដើរត្រឡប់ចូលមកវិញ ហើយថា « អ្នកភិក្ខុអើយ អ្នកភិក្ខុ ! អ្នកឯងនេះហើយជាព្រះបាទធម្មិករាជនុ៎ះ » ទើបភិក្ខុឆ្លើយថា « ចិន្តអើយ ! ម្តេចអ៎ើះ មកយកអាចក្តីទៅផ្ទឹមនឹងព្រះបាទធម្មិករាជ ឯព្រះបាទធម្មិករាជនោះ គឺអង្គព្រះសិរអារ្យមេត្រីពោធិញាណ ម្តេចឡើយក៏ចិន្តឯងហ៊ានថាអាចក្តីដូច្នេះ ? » ទើបចិន្តឆ្លើយថា « បើមិនជឿខ្ញុំករុណានោះ ចូរនិមន្តក្រោកពីថ្មខាងត្បូង ទៅគង់ឯថ្មខាងជើងវិញ » ។ ទើបព្រះភិក្ខុនោះក្រោកឡើងពីថ្មខាងត្បូង ទៅគង់ឯថ្មខាងជើងវិញ ក៏ជ្រុះមកុដកែវសុវង សំពត់ទិព្វកោសេយ្យពស្ត្រអម្ពរគ្រប់យ៉ាង ទើបអ្នកភិក្ខុនោះសួរថា « ឯណាមិនឃើញព្រះឥន្ទ្រ ព្រះព្រហ្ម ? អាចក្តីដឹង » ។ ទើបព្រះឥន្ទ្រ ព្រះព្រហ្ម ក៏ឆ្លើយឡើងថា « ខ្ញុំព្រះករុណានៅនេះហើយ » ។ ទើបព្រះឥន្ទ្របើកស្វេត្រឆ័ត្របាំងមួយរំពេចឡើង ទើបអ្នកភិក្ខុនោះសួរថា « ឯណា មិនឃើញដីរបច្ច័យនាគេន្ទ្រនរេន្ទ្រគជសារ-សសុទ្ធ ភ្លុកខៀវ ខឹមខាត់ ? » ។ ទើបចិន្តឆ្លើយថា « ចូរអ្នកក្រោក

ឡើងពីថ្មខាងជើងទៅគង់នៅថ្មខាងត្បូងវិញ » ។ គ្រានោះ ក៏បានឃើញដីរមូយរំពេច ហើយទើបភិក្ខុសួរថា « ឯណាមិនឃើញព្រះចតុលោកបាលទាំង ៤ ? » ចតុលោក-បាលទាំង ៤ ក៏ឆ្លើយថា « ខ្ញុំព្រះករុណានៅនេះហើយ » ។ ទើបព្រះភិក្ខុសួរថា « ឯណាមិនឃើញព្រះសារីរិកធាតុព្រះដ៏មានបុណ្យទាំង ៣ ឋាន មកឋិតលើបាតដៃអញទាំងពីរនុ៎ះ ? » ។ ទើបចិន្តអធិស្ឋានស្រេចហើយ ទើបព្រះសារីរិកធាតុអណ្តែតគ្រប់ចក្រវាឡមកឋិតលើបាតដៃអ្នកភិក្ខុមួយរំពេច » ។ ទើបអ្នកភិក្ខុសួរថា « ឯណាមិនឃើញគម្ពីរពីបាតភ្នំព្រះប្រសិទ្ធមក ? » ។ ទើបចិន្តអធិស្ឋានបានគម្ពីរមកពីបាតភ្នំមួយរំពេចស្រេចហើយទើបព្រះភិក្ខុសួរថា « ឯណាសេនាទាំង ៣ ជំពូកនោះ ? » ទើបសេនាឆ្លើយឡើងថា « ព្រះករុណានៅនេះហើយ » ។ ទើបអ្នកភិក្ខុនោះ ក៏ទទួលថាជាអង្គព្រះបាទធម្មិកកាលគ្រានោះហោង ក៏ផ្លាស់គ្រឿងប្រដាប់សម្រាប់កាយមួយរំពេច ទើបសេនាទាំង ៣ ចូលចិត្តមកថ្វាយបង្គំ ទាំងពួកព្រះឥន្ទ ព្រះព្រហ្មចុះមកទាំងមួយសែន ទើបស្តេចកុវេរាជលើកពលចេញពីភ្នំកំចាយដង្ហែព្រះបាទធម្មិកទៅឯនគរក្រុងកម្ពុជា ទៅដល់ជ្រោយចង្វា ទើបសេនាខាងឆ្វេងដាក់តម្លោះធ្នូឮសូរដូចជារន្ទះទាំង ៧ កក្រើកអស់សោឡសឋាន ទើបធម្មិកនៅទីរាបប្រាប់ធម្មិកនៅគោកធ្លកជាធំថា រើយ ! ស័ព្ទអ្វី១ចម្លែកដូចស័ព្ទសរព្រះដ៏មានបុណ្យនោះអ្ហះ ! ។ ទើបធម្មិកនៅគោកធ្លកថា រើយ ! ស័ព្ទអ្វី១កុំស្តាប់ ចេះតែបាញ់ទៅ ។ ទើបសេនាខាងស្តាំមកតម្លោះធ្នូឡើងទៀត ឮសូរដូចរន្ទះមួយសែនកោដិ ស្ទើរភ្លូកក្រឡាមហាប្រឹថពី ទើបធម្មិកនៅទីទួលប្រាប់ទៅគោកធ្លកថា រើយ ! ឮអ្វី១ក៏ខ្លាំងដូចស័ព្ទសរព្រះដ៏មានបុណ្យនោះរ្អះ ! ទើបធម្មិកដែលនៅគោកធ្លកថា រើយ ! យើងកុំស្តាប់ស័ព្ទអ្វី១ចេះតែបាញ់ ទើបសេនាទាំង ៥០០ គ្រវី ដំបងប៉ុន១ដើមត្នោត ហើយស្រែកថា « ធម្មិកផងទាំងឡាយអើយ ឈប់សិន ! ដ្បិតព្រះបាទធម្មិកម្ចាស់យើងស្តេចមកហើយ នែ ! អ្នកទាំងឡាយឈប់សិន កុំររាល ! » ។ ទើបធម្មិកនៅក្នុងបឹង ជ្រោះ

ជ្រលេង កោះ ទិន្នលព្ទហើយ ស្រែកប្រាប់ធម្មិកដែលនៅលើគោកធ្លក ។ យក្ខ វាក៏ស្រែកថា « នែវើយ ! ព្រះបាទធម្មិកមកហើយ ! » ។ ទើបធម្មិកដែលនៅគោកធ្លកស្ដាប់ហើយឆ្លើយថា « វើយ ! យើងកុំស្ដាប់ពាក្យយក្ខនោះឡើយ ឱ្យខំតែបាញ់ៗទៅ យក្ខៗ ក៏បាញ់ដែរ ! » ម្ល៉ោះហើយក៏បាញ់ទៅពុំមានឆេះឡើយ ។ អស់ទាំងពួកពលសេនាក៏ហែពោធិសត្វយាងចូលទៅដល់ព្រះរាជវាំង ដល់ប្រាសាទហើយ ធម្មិកទាំងអស់នោះតាមបាញ់ចេញតែទឹក ហើយទើបទម្លាក់កាំភ្លើងនោះចោល ទៅយកកាំភ្លើងសិរីទ្ធិមកបាញ់វិញទៀត បាញ់ទៅក៏ឆេះឡើងកើតជាផ្កាគ្រប់ប្រការ ទើបទម្លាក់កាំភ្លើងនោះចោលចេញ ហើយថ្វាយបង្គំកាលនោះឯងហោង ទើបបានថ្វាយទឹកដីគោកធ្លកនោះ ។ ទាំងអស់គ្នាក៏ទៅថ្វាយបង្គំព្រះអង្គធ្វើជាសេនារក្សាទឹកដីគោកធ្លកនោះតទៅ ត្រាតែដល់ ៥០០០ ព្រះវស្សានោះ ទើបប្រើសេនាយក្ខទាំង ១០០០ ឱ្យទៅយកគម្ពីរពីភ្នំគូលេន ឯនគរវត្ត មកថ្វាយព្រះអង្គកាលនោះ ទើបព្រះគោ ព្រះកែវយាងត្រឡប់មកនគរគោកធ្លកវិញហោង ។ ព្រះអង្គក៏ផ្លាស់ឈ្មោះនគរក្រុងកម្ពុជា លើកឡើងហៅថា នគរវង្កតបុរី ជាធំក្រៃលែង ។ នគរផងទាំងឡាយចុះចូលមកថ្វាយបង្គំប្រណម្យព្រះអង្គ សម្ដែងថ្លែងធម៌វិសេសទេសនាប្រោសអស់ទេវតា មនុស្ស សត្វទាំងឡាយ ក៏បានសេចក្ដីសុខ សប្បាយតរៀងទៅ មនុស្សនៅក្នុងនគរក៏មើលទេវតាឃើញទៅវិញទៅមកគ្រប់សាសន៍ដូចគ្នា ជំងឺរោគាក៏សឹងតែខ្ចាត់ខ្ចាយមានតែសុខសប្បាយទាំងប្រុសទាំងស្រីរៀងទៅ មនុស្សដែលអាក្រក់នៅក្នុងសាសនា ក៏អន្តរាយអស់ទៅ នៅសល់តែមនុស្ស ល្អៗតរៀងទៅ ។ លុះដល់ ៥០០០ ព្រះវស្សា ពុំទាន់ចូនសាសនាអញ្ចតថាគត កាលនោះព្រះបាទធម្មិក ព្រះអង្គអភិសេកស្ដេចពីរព្រះអង្គឱ្យសោយរាជ្យតរៀងទៅ ស្ដេចនោះគឺ ភូមិរិន្ទធិរាជ ( ក្បួនខ្លះថា ព្រះបាទយុក្កតបនាគរាជ ភូមិរិន្ទរាជា ) និងមួយព្រះអង្គទៀត ហៅថា យស្សគន្ធអករាជ ។ ស្ដេចពីរព្រះអង្គនោះសោយរាជ្យទៅ កាន់ទសពិធ ១០ ប្រការ ត្រូវតាម

ព្រះបន្ទូលអនាគតថាគត ។ មនុស្សផងទាំងឡាយមានកំណត់អាយុបាន ២២០ ឆ្នាំ គ្រប់គ្នា ទ្រានឹងដល់មរណា គ្មានរោគអ្វីក៏នឹងមកបៀតបៀន បានតែសប្បាយ និងរកភោជនផងទាំងឡាយ សឹងតែបានដូចសេចក្តី ប្រាថ្នាគ្រប់គ្នាទាល់តែដល់ ៥០០០ ព្រះវស្សា ណ៎ាអានុសោអើយ ! បើអ្នកឯណាចង់ ទាន់ព្រះបាទធម្មិកមកលើកសាសនាអនាគតថាគតនេះ ឱ្យនឹកខ្ញុំ នឹកពៃ ពុទ្ធំ ធម្មំ សង្ឃំ និងអរហំ កុំឱ្យដាច់ ដល់ពេញបូណ៌មី ខែដាច់ ចូលទៅសូមសមាទាន ចម្រើនមេត្តាភាវនា បើខ្លួនមិនជាហើយឱ្យនឹកថា ពុទ្ធំៗ អរហំៗ តែប៉ុណ្ណោះ ក៏បានដែរ ។

ចប់ពុទ្ធទំនាយពីព្រះបាទធម្មិក

ចូលមើលសេចក្តីបន្ថែមទៀត ដូចតទៅនេះ ៖

(១) លុះដល់ឆ្នាំរកា ឯកស័ក សាសនាបាន ២៤៥៧ ឆ្នាំ ពួកទមិឡវាមកសោយរាជ្យវិញ មនុស្សផងក៏បរិបូណ៌ក្បេមក្សាន្តណាស់ហោង សំពត់អាវ គ្រឿងប្រដាប់នោះ យកចេញតែពីដើមព្រឹកព្រលឹមតាវល្លិផង បើនរណាខ្លួនតូច ក៏មានអាវតូចស្រាប់, បើនរណាខ្លួនធំ ក៏មានអាវធំស្រាប់, នោះឯង ឪពុកមិនស្គាល់កូន កូនមិនស្គាល់ឪពុក, បងមិនស្គាល់ប្អូន ប្អូនមិនស្គាល់បងទេ តែសម្បូរណាស់ រីឯចំណីអាហារ ភោជនអាហារនោះ ក្រណាស់ ណ៎ាអានុសោអើយ ។ ឯមាសប្រាក់ កែវកងពិទូរ្យស្ទូរ្យកាន្តនោះ សម្បូរហូរដូចទឹក ជម្រៅត្រឹមជង្គង់ ត្រឹមចង្កេះ ត្រឹមក បើនរណាគិតមិនល្អ នឹងលង់ទឹកប្រាក់នោះស្លាប់ទៅហោង ។

អានុសោអើយ ! អនាគតថាគតកំណត់សន្មតហៅថា ជាស្តេចចក្រពត្តិសោយរាជ្យកំណត់ ២២ ឆ្នាំ ។ ស្តេចនោះនឹងរកស្តេចឯណាមកប្រៀបផ្ទឹមឱ្យត្រឹមស្មើនោះគ្មានឡើយ នឹងចង់ប្រើទឹកក៏បាន នឹងចង់ប្រើភ្លើងក៏បាន នឹងចង់ប្រើខ្យល់

ក៏បាន នឹងចង់ប្រើខ្មោចក៏បានគ្រប់ប្រការ ។ បើផ្លូវចម្ងាយ ៦០ យោជន៍ក្តី ៥០ យោជន៍ក្តី ក៏ហោះហើរដើរលើអាកាសបាន កំណត់តែបីម៉ោងដល់ទៅមកបាន ។ លុះដល់ឆ្នាំរោង ឆស័ក ទើបឧប្បត្តិកព្រះពុទ្ធវង្សសោយរាជ្យតំណាង ។ អាវុសោអើយ ! ហ្នឹងហើយ មកដល់អង្គព្រះបាទធម្មិកមកលើកសាសនាតថាគត ឱ្យមនុស្សផងទាំងឡាយមើលទៅខាងកើត បើឃើញព្រះឱណាឡៅ ( វត្តឧណ្ណាលោម ) បាក់បែក ចេតិយបាក់ កំពូលព្រះវិហារធ្លាក់ ហើយគេធ្វើជួសជុលជាថ្មីរួចស្រេចហើយ ឱ្យមើលប្រាសាទនៅផ្សារបាក់ទូក បើរួចស្រេចហើយ ឱ្យមើលភេទក្នុងព្រះនគរ បើមនុស្សផឹកស្រា លេងបៀ ធូ តែសព្វព្រៃគម្លោតហើយ, អាវុសោអើយ ! នេះហៅឧត្បាតជិតណាស់ហើយ ។ លុះដល់ឆ្នាំវក ឯកស័កនោះ ព្រះបាទធម្មិកចេញសាងព្រីទ្ធនៅថ្ងៃអង្គារ ១ កើត ខែមិគសិរ ។ កាលដល់ព្រះបាទធម្មិកចេញទៅនោះ មេឃស្រទំ ៧ ថ្ងៃ រួចពីនោះ នឹងភ្លៀងវស្សាដូចប្រាំង ត្រាតែ ៧ ឆ្នាំទៅហោង ។

លុះដល់ឆ្នាំ ច នឹងបើកកំណត់ពីកំពូលភ្នំក្រំថ្ម ។

លុះដល់ឆ្នាំ រកា កើតទុរ្ភិក្សររាត់បាយគ្រប់ស្រុកតូចធំផងទាំងឡាយ នោះនឹងកើតមានកប្បបីប្រការ : ទុរ្ភិក្សខន្ធកប្ប ១, ភេទខន្ធកប្ប ១, សធន្តកប្ប ១ ត្រូវជាបីប្រការ ។ នោះឪពុកលក់កូន កូនលក់ឪពុក បងលក់ប្អូន កូនលក់ម្តាយ រួចពីនោះមនុស្សផងទាំងឡាយនឹងលក់កូនប្រុសកូនស្រី លក់គ្រប់សព្វអន្លើ ។

លុះដល់ឆ្នាំជូតនោះ មានចោរចេញពីគ្រប់គុម្ពោត ។ រួចពីនោះ ទើបមានស្តេចមួយមកពីទិសខាងជើង មកសុំរាជ្យពីហ្លួងពុទ្ធវង្ស និងបាំរាំងសែស សោយរាជ្យនៅទីភ្នំពេញ កំណត់ ៧ ខែ ទើបស្តេចនោះភៀសចេញទៅ ទើបមានស្តេចមួយចេញពីទិសឯលិច នោះបារាំងទៅទទួល នៅឆ្នាំមមែ សប្តស័ក សោយរាជ្យនៅទីបឹងស្រង់ កំណត់ ៧ ថ្ងៃ ទើបបារាំងតាំងធ្វើជាធម្មិកទាំង ៨ ទិសឡើង ។

លុះដល់ឆ្នាំរកា ទមិឡជយឫទ្ធិ ស្តេចយើងមានចេស្តា ។ លុះដល់ឆ្នាំច

ព្រះបាទអង្គលីរាជគិតលើកពលសាកលយោធា ចេញពីនគរណោងស្មោ មកចូលនគរក្រុងកម្ពុជាធិបតី ។ នេះក្នុងឆ្នាំ ច ព្រះបាទអង្គលីរាជនាំពលចូលទៅទន្លេ ៤ មុខ កំណត់សាសនា ២៥០០ ។ ឆ្នាំជូត អដ្ឋស័កនោះ ហោមហាពិបាកណាស់ ហៅថា សូន្យសុងក្នុងនគរ នៅតែភិក្ខុ ៤ និងមហាឫសី ៨ អង្គ និងអាចារ្យ ១ ទេ ណ៎ាអារុំសោអើយ ! ។ នោះច្បាំងតាំងតែអំពិបឹងស្រង់ រៀងដល់កំពង់ទួល ចូលដល់ទួលព្រះស្រី ចេញទៅល្វាឯម ទើបបានចូលទៅទន្លេ ៤ មុខវិញ ។

*

## ស្ពានជ្រោយចង្វា

ខ្ញុំបានឮចាស់ៗជាច្រើននាក់ ( មានទាំងជីតាខ្ញុំផង ) និយាយប្រហាក់ប្រហែលគ្នាពីទំនាយស្ពានជ្រោយចង្វា ក្នុងកាលដែលគាត់បានដឹងថា រាជរដ្ឋាភិបាលមានគម្រោងសង់ស្ពាននេះឡើង ។ គាត់បាននិទានប្រាប់ដូចតទៅនេះ

« ស្ពានជ្រោយចង្វាមាននៅក្នុងពុទ្ធទំនាយ ។ ពុទ្ធទំនាយនោះ គេចងក្រងជាពាក្យយ៉ាងពិរោះណាស់ ។ តាមទំនាយនោះ កាលណាស្ពានជ្រោយចង្វាសង់រួច ស្ពានជ្រោយតាឱកត្រូវបាក់ ។ ស្ពានហ្នឹងឥតទាន់បានសម្ពោធទេ ស្តេចត្រូវភៀសព្រះអង្គទៅនៅនគរសាមកុក ។ បន្ទាប់ពីនោះមក ស្រុកយើងនឹងត្រូវកើតកលិយុគឥតមានបានសុខ បានស្រួលទៀតទេ គឺនឹងកើតជាចម្បាំងរាំងជល់ កើតលួចប្លន់ចាក់កាប់ សម្លាប់គ្នា កើតចោរបារយ ។ ណាមួយពួកព្រាយក្បាល ៨ វានាំគ្នាហែកភ្នំចេញមកចូលសណ្ឋិតនៅក្នុងចិត្តមនុស្ស មិនថាប្រុសឬស្រី ក្មេងឬចាស់ទេ ថាបើអ្នកណាហើយជាមនុស្សល្អ ជាអ្នកកាន់ធម៌សុចរិតត្រឹមត្រូវ ជាអ្នកមានសីលមានមានបញ្ញាជាប់នៅក្នុងខ្លួន ព្រាយក្បាល ៨ ចូលជននោះមិនចុះទេ ប៉ុន្តែ បើជនណាជាអ្នកមានសន្តានចិត្តជាទុច្ចរិត ពេញចិត្តតែខាងប្រព្រឹត្តអាក្រក់ ព្រហើនកោងកាច

មិនស្គាល់ខុសត្រូវ ឃើញអាក្រក់ថាល្អ ឃើញសថាខ្មៅ ឃើញខ្មៅថាប្រាជ្ញ អួតអាង អំណាច មិនគោរពកោតខ្លាចច្បាប់ព្រាយក្បាល ៨ នឹងចូលសណ្ឋិតក្នុងចិត្តជននោះ បានដោយងាយ បណ្តាលចិត្តជននោះឱ្យកាន់តែឃោរឃៅសាហាវហ៊ានល្មួចប្លន់ ចាក់ កាប់សម្លាប់ចោលដោយឥតមានត្រាប្រណី ឥតមានញញើតដៃអ្វីបន្តិចឡើយ ។ ព្រម ជាមួយនេះ មានស្តេចមួយអង្គមិនដឹងជាចេញមកពីប្រភពណា ស្រាប់តែឡើង សោយរាជ្យ ជាស្តេចកំណាច មានចិត្តនោះសែនក្តៅ មានឫទ្ធិ ក៏អស្ចារ្យណាស់ ចង្អុលទឹករលាយទឹក ចង្អុលដីរលាយដី ចង្អុលអីរលាយហ្នឹង អ្នកណាហ៊ានរឹងទទឹង នឹងត្រូវស្លាប់ភ្លាម សូម្បីតែខ្មោចព្រាយបិសាច ក៏ខ្លាចអំណាចស្តេចហ្នឹងដែរ ។ ស្តេចហ្នឹងសោយរាជ្យមិនបានយូរប៉ុន្មាន ក៏មានទ័ពពួកអណ្ណាមកុកលើកចូលមក ដេញកម្ចាត់ស្តេចឃោរឃៅនោះចេញ ហើយក៏តាំងខ្លួនឯងនៅក្នុងនគរគោកធ្លក នោះទៅ ។ ទ័ពនេះជាទ័ពពពុះទឹក វាប្រើកិរិយាត្រជាក់ណាស់ ប៉ុន្តែ អ្នកណាហ៊ាន ទទឹង ហ៊ានជំទាស់នឹងវា ក៏ត្រូវស្លាប់ដែរ ។ ពួកអណ្ណាមកុកលើកទ័ពមកនេះ វាមាន បំណងយកស្រុកខ្មែរ ។ ប៉ុន្តែ វាពុំមានវាសនានឹងយកបានទេ ។ ដល់ក្រោយមក ស្តេចដែលភៀសព្រះអង្គទៅនៅនគរសាមកុកនោះ ព្រះអង្គនឹងយាងត្រឡប់មកវិញ ចេញពីនគរណោងស្នោ ។ ព្រះអង្គគង់លើសេះសម្បុរ-ស ដឹកនាំទ័ពពីទិសបស្ចិមមក ជាទ័ពសាសនា ធ្វើសង្គ្រាមប្រយុទ្ធដេញពួកអណ្ណាមកុក តាំងពីភាគខាងលិច រហូត ទៅដល់ហួសខាងកើតទន្លេមេគង្គ ។ លុះទ្រង់ទទួលបានជ័យជំនះហើយ ព្រះអង្គក៏ យាងចូលព្រះនគរវិញតាមស្ពានជ្រោយចង្វា ទ្រង់សម្ពោធស្ពានជ្រោយចង្វានៅ ពេលនោះឯង ។

ចប់ទំនាយ អំពីស្ពានជ្រោយចង្វា

ដោយ គោ ង្វេរ

# អំពីការទាក់ដីររនាម [១]

**ភ.ភ.ន.** ខ្ញុំបានចុះធ្វើការស្រាវជ្រាវអំពីប្រពៃណី និងទំនៀមទម្លាប់ខ្មែរ នៅខេត្តកំពង់ធំ ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០០ ហើយបានជួបសម្ភាសន៍ជាមួយលោកតា ហៃម ជួន អាយុ ៨២ ឆ្នាំ កំណើតនៅភូមិ ម្សៀវ តែបច្ចុប្បន្ន បានមករស់នៅភូមិក្លូនចំបក់ ឃុំ ស្រយូវ ស្រុកកំពង់ស្វាយ ។ ដោយធ្លាប់ចូលរួមទាក់ដីររនាមចំនួន ៩ លើក លោកតាបាននិយាយប្រាប់ខ្ញុំអំពីការទាក់ដីរនេះ ដើម្បីបានយកមកចងក្រងជាឯកសារតម្កល់ទុក នៅពុទ្ធសាសនបណ្ឌិត្យ សម្រាប់ជាប្រយោជន៍ដល់ការស្រាវជ្រាវនៃកូនចៅជំនាន់ក្រោយ តទៅ ។

### ១ . *អំពីរដូវដែលអំណោយផលសំរាប់ការទាក់ដីររនាម*

នៅរដូវទឹកស្រក ចាប់ពីខែមករាតទៅ តាមទម្លាប់ និងតាមសភាវគតិធម្មជាតិ ( Instinct naturel ) ដីរព្រៃតែងតែនាំគ្នាចុះពីព្រៃធំៗ ធ្វើដំណើរទាំងហ្វូងៗរាប់រយពាន់ក្បាល ឆ្ពោះទៅកាន់វាលក្រោម [២] ដែលសំបូរដោយខ្មៅខ្ចី ដ៏មានរសជាតិឆ្ងាញ់ ។ ក្នុងរយៈពេលពី ៦ ទៅ ៧ ខែ ហ្វូងដីរព្រៃរីករាយរស់ឯកនឹងជីវិតនៅតាមវាលទំនាប ដែលមានចំណីប្លែក និងរបៀបរស់នៅប្លែកពីព្រៃភ្នំក្រំថ្ម ។ លុះចូលដល់ដំណាច់ខែស្រាពណ៍ ( ត្រូវនឹងខែកក្កដា ឬតុលា ) ដែលទឹកជំនន់បានរាចចេញពីផ្ទៃទន្លេសាបមកពន្លិចតំបន់ទំនាបនានានៅជិតខាង ហ្វូងដីរព្រៃប្រមូលគ្នាមកជួបជុំនៅតាមទួលធំៗ ដែលទឹកនៅមានកំពស់ត្រឹមតែមួយម៉ែត្រនៅឡើយ ។ វាត្រៀមខ្លួននឹងលាចាកវាល និងដើម្បីទៅរស់នៅតាមព្រៃភ្នំជាតំបន់ខ្ពស់វិញ ។ ឆ្លៀតក្នុងឱកាសដែលដីររៀបចំផ្លាស់ប្តូរទីលំនៅនេះ បណ្តាកសិករជាទម័ក [៣] ដីរ បានប្រកួកប្រកាសប្រមូលគ្នាយ៉ាងច្រើន រហូតរាប់រយនាក់ ធ្វើដំណើរដោយទូក ដើម្បីទៅ

---

(១) ដីររស់នៅតំបន់ជើងទឹក ។ (២) វាលទំនាបកើតនៅជុំវិញតំបន់ទន្លេសាប ។ (៣) ទម័ក បាយើផា ឬអក ( ឬះអះកះ ) ខ្លះនិយាយក្លាយមកជា ទ្រម័ក ។

ទាក់ដំរីយកមកផ្សាំងប្រើ ឬយកមកលក់[១] ។

*២. ការត្រៀមដំណើរចេញទាក់ដំរី :*

សូមជម្រាបថា ទាំងការទាក់ដំរីរនាម ទាំងការទាក់ដំរីព្រៃ សុទ្ធជាដំណើរផ្សងគ្រោះថ្នាក់ជាទីបំផុត ព្រោះអ្នកទាក់ត្រូវប្រឈមមុខនឹងហ្វូងដំរីដ៏សាហាវ ។ ទម័កទាំងឡាយត្រូវតែមានបទពិសោធន៍ច្រើនក្នុងការទាក់ដំរី ។ លក្ខណសម្បត្តិដែលទម័កត្រូវមានជាចាំបាច់នោះគឺ មានកម្លាំងកាយមាំមួន ស្វាហាប់ វាងវៃ រហ័សរហួន ទាំងប្រាជ្ញាស្មារតី ស្ទាត់ជំនាញ ប៉ិនប្រសប់ មានពិសោធន៍ក្នុងការងារទាក់ដំរី សាមគ្គីជិតស្និទ្ធរវាងគ្នានឹងគ្នា ស៊ូប្តូរជីវិតដើម្បីជួយសង្គ្រោះគ្នាទៅវិញទៅមកក្នុងគ្រាមានអាសន្ន ។ ទម័កទាំងឡាយត្រូវមានច្រវាក់ដែក ៣ កន្ទុយ វេញខ្សែព្រួធំៗ ឱ្យបានច្រើនកន្ទុយ សម្រិតសម្រាំង សម្រួចចុងកង្វេរ និងផ្លែកង្វារឱ្យបានស្រួច មុតល្អ ដើម្បីទុកសម្រាប់ការ ខ្វារដំរី ។ ក្រៅពីនេះ ត្រូវត្រៀមស្បៀង មានអង្ករ អំបិល ម្ហូ ត្រីងៀត ត្រីឆ្អើ ផ្អក ប្រហុក សំរាប់រយៈពេល ២ ខែ ។ លុះសម្ភារៈដែលត្រូវការចាំបាច់ទាំងប៉ុន្មាន ត្រូវបានរៀបចំត្រឹមត្រូវគ្រប់មុខអស់ហើយនោះ ទម័កទាំងឡាយដែលប្រមូលផ្តុំគ្នាជាក្រុមៗតាមភូមិ[១] រៀងៗខ្លួននោះ រៀបចំចាត់ចែងធ្វើពិធីសែនព្រេន បួងសួងសុំម្ចាស់ទឹក ម្ចាស់ដី អារក្ស អ្នកតា និងព្រៃញគង្វាល សុំទាក់ដំរីបាន និងសុំកុំឱ្យមានគ្រោះថ្នាក់អ្វីឡើយ ។ គ្រឿងសំណែនទាំងឡាយមានជាអាទិ៍ ក្បាលជ្រូក មាន់ស្ងោរ បាយ សម្ល បង្អែម ចម្អាប ស្រា ដោយពោលពាក្យយ៉ាងនេះថា «*ថ្ងៃនេះថ្ងៃជា ពេលាល្អ យើងខ្ញុំទាំងឡាយមុនរៀបចំចេញដំណើរទៅទាក់ដំរី បានរៀបចំអាហារភោជន* មានបង្អែម ចម្អាប ចេកទុំ នំផ្អែមគ្រប់មុខច្រើនពោរពាស

---

(១) លោកតា វ៉ែន ផួន បានប្រាប់ថា កាលណោះ ដំរីស្ទាវមួយលក់បាន ៦០០ រ ស្មើនឹង មាសប្រហែល ២ ដំឡឹង ។

*ជូនចំពោះម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃព្រឹក្សា វាលទំនាប ជ្រោះជ្រងជ្រលង ផង អ្នូរ អារុក្ខ អារក្ស អ្នកតា ព្រេញគង្វាល ដែលជាអ្នកថែរក្សាដីរ សូមមេត្តាដាក់ ទានជីវិតដល់យើខ្ញុំជាកូនចៅទាំងអស់គ្នា សូមឱ្យទាក់បានជីវិដូចបំណងប៉ងប្រាថ្នា សូមគ្រោះថ្នាក់ទាំងឡាយបវៀសជៀសឆ្ងាយ សូមឱ្យសុខសប្បាយគ្រប់ៗគ្នា »។* គេសែនយ៉ាងនេះជាគម្រប់ ៣ ដងរួចហើយ ទើបចាប់ម្ហូបបន្តិចៗ ក្នុងមួយមុខដាក់ទៅលើស្លឹកចេកមួយផ្ទាំង ច្រូចទឹក ច្រូចស្រា ជាកិច្ចបញ្ចប់ពិធីសែនព្រេន ។

*៣ . ការកាន់ត្រណម :*

ដំណើរចេញទៅទាក់ជីរ រមែងតែងតែភ្ជាប់ជាមួយនឹងលក្ខខណ្ឌផ្សេងៗ ស្របទៅតាមទំនៀម ដែលធ្លាប់ធ្វើតៗគ្នាជារៀងដរាបតមក ។ ប្រពន្ធទម័កដែលនៅឯផ្ទះ ត្រូវកាន់ត្រណមប៉ុន្មានចំណុច ដូចខាងក្រោម :

- មិនឱ្យវាយកូនវាយចៅ
- មិនឱ្យបោសកន្ទេលដំណេក
- មិនឱ្យឈ្លោះប្រកែកជាមួយមនុស្សក្នុងគ្រួសារ ។

ត្រណមទាំងប៉ុន្មាននេះ មានន័យដែលអាចបកស្រាយ ដូចតទៅ :

. តមមិនឱ្យវាយកូនចៅ បានន័យថា ធ្វើចិត្តជាអ្នកមានមេត្តាអាណិតដល់កូនចៅ ក៏ហាក់ដូចជាធ្វើឱ្យជីវិអាណិតយើង មិនបង្កគ្រោះថ្នាក់ដល់យើង ។

. តមមិនឱ្យបោសកន្ទេល គឺមិនធ្វើឱ្យសំរាមបែកបាក់ ខ្ចាត ខ្ចាត់ខ្ចាយ បានន័យថា ទាក់ជីវិបានមកឱ្យនៅគង់វង្ស មិនរត់បាត់ មិនដាច់ខ្សែ ដាច់ពួរ រួចរត់ទៅបាត់ ។

(១) អ្នកស្រុកខ្មែរគេជឿទៀតថា ការកាត់ជីវិតកាត់ក្នុងរដូវនេះ ការស្រុកច្រូតផ្កាកកពិភូតិ ពាំងឡាក្នុងអុំ ត្រកូលភាំងទូក រកា កុំរឹង ល្ពៅ ពុកកុក ត្រសក់ ឆ្កែ ពន្លាជិ ។ល។

- តមមិនឱ្យឈ្លោះប្រកែកជាមួយមនុស្សក្នុងផ្ទះ មានន័យថា បើយើងអត់ធន់មិនទាស់ទែងតបទៅតបមក រវាងគ្នានឹងគ្នាក្នុងគ្រួសារនោះ ដីរវាមិនតបត រើបម្រះ ប្រឆ្វេស្ត មករកយើងវិញដែរ គឺវាបណ្តោយឱ្យយើងទាក់បានដោយស្រួល ។

លុះធ្វើពិធីជាប្រពៃណីទាំងនេះរួចសព្វគ្រប់អស់ហើយ ទម័កទាំងឡាយទាំងនៅក្នុងភូមិ ទាំងនៅភូមិជិតខាង ក៏រៀបចំចេញដំណើរចុះទូក ដោយប្រកួកផ្លុំស្នែងតគ្នាជាសញ្ញា ឮសូរក្រលួច ទ្រហឹងអឺងអាប់ គួរឱ្យព្រឺព្រួច នឹកស្រណោះពន់ពេក ។ ទម័កជាច្រើនភូមិ បានសហការប្រមូលគ្នាជាក្រុម ដែលមានពី ៤ ទៅ ៥ នាក់ក្នុងទូកនីមួយៗ ។ ពេលចេញទៅទាក់ដីរក្នុងមួយលើកៗ អាចមានក្បួនទូករហូតដល់ ៣០០ គ្រឿង ។ សំឡេងស្នែងលាន់ឮរំពងវាល ដែលមានទឹកជំនន់ល្ហល្ហាចលាតសន្ធឹងដាច់កន្ទុយភ្នែក លាយឡំនឹងចម្រៀង និងសំណើចក្អាកក្អាយ ហ៊ោកញ្ជ្រៀវទ្រហឹងអឺងអាប់ ។ គេនាំគ្នាអុំទូកចុះទៅតាមវាលទំនាប ឆ្ពោះទៅតំបន់បឹងប្រធាអាគត់ ហើយក៏តាំងរាយបណ្តាក់ហ៊ុំព័ទ្ធទួលធំៗ ដែលគេដឹងជាមុនថា ដីររនាមរាប់រយក្បាល តែងតែមកប្រមូលផ្តុំនៅទីនោះ ដើម្បីត្រៀមចេញដំណើរឡើងទៅកាន់តំបន់ព្រៃភ្នំ ។ កងទម័កឯទៀតៗ ក៏រៀបជាក្បួនខ្សែលាតសន្ធឹងចន្លោះទួលធំៗ ទាំងឡាយ និងព្រៃភ្នំ ។ ធ្វើយ៉ាងនេះ គឺមានគោលបំណងបិទបាំងរាំងផ្លូវដីរកុំឱ្យវាធ្វើដំណើរឡើងទៅកាន់ព្រៃភ្នំបាន ក៏ដូចជា រង់ចាំក្នុងរយៈពេលកន្លះខែឱ្យទឹកជំនន់បន្ថែមកំពស់មួយកំរិតទៀត ដើម្បីងាយស្រួលដល់ការទាក់ដីរ ។ លុះពិនិត្យឃើញថាទឹកជំនន់ឡើងខ្ពស់មែនទែនហើយនោះ អស់ពួកមេក្រុមទាំងឡាយក៏បានជួបប្រជុំគ្នាដើម្បីពិភាក្សាអំពីវិធានការចាំបាច់ផ្សេងៗ សម្រាប់អនុវត្តឱ្យបានល្អ នៅពេលចូលប្រឡូកក្នុងហ្វូងដីរ ។

*៤ . ឆាកទាក់ដីរ :*

ទូករាប់រយបានរៀបគ្នាជាក្បួនរង្វង់ស្នែកក្របី ទុកតែច្រកមួយឈមមុខ

ទៅរកបឹងដែលមានទឹកជ្រៅ សម្រាប់ឱ្យដំរីដោះខ្លួនចេញទៅតាមនោះ ។ លុះមេបញ្ជាការធំឱ្យសញ្ញាវាយលុក តាមរយៈសំឡេងស្នែង [១] ទម័កគ្រប់ទូកបានស្រែកហ៊ោសន្ធាប់យ៉ាងខ្លាំង ខ្លះទះដៃ ខ្លះវាយគែមទូក ឮទ្រហឹងអឺងអរាប់ស្តាប់ទិសតំបន់អ្វីលែងឮ ។ គ្រាន់តែបានឮសំឡេងគឹកកងនេះភ្លាម ហ្វូងដំរីមានការភ័យស្លន់ស្លោស្ទុះរត់ប្រសេចប្រសាចចេញពីក្នុងព្រៃទួល រកច្រកណាដែលគ្មានមនុស្សឃ្លាំចាំ ។ ពិតមែនតែដំរីជាសត្វសាហាវ មានកម្លាំងខ្លាំងក្លា អាចប្រយុទ្ធតទល់នឹងមនុស្ស ឬសត្វដូចគ្នាក្តី ក៏ប៉ុន្តែនៅពេលនេះ ដោយវាឮសូរសន្ធឹកស្រែកហ៊ោសន្ធាប់ខ្លាំងក្លាបែបនេះ ពួកវាតែងតែស្លុតស្លុងរាំងភ័ន្តស្មារតី ព្រោះដឹងច្បាស់ថា មនុស្សដែលជាអ្នកល្បាន ពានវានេះ មានចំនួនដ៏ច្រើនលើសលប់ ពុំអាចតស៊ូយកឈ្នះបានដោយងាយៗនោះឡើយ ។ ដំរីធំៗ [២] ជាពិសេស សុទ្ធតែធ្លាប់បានឆ្លងកាត់ការដេញបំភ្លុកបែបនេះជារៀងរាល់ឆ្នាំ ។ មិនយូរប៉ុន្មាន ដំរីប្រមាណ ៥០០ ក្បាលបានចេញផុតអស់ពីព្រៃ ចូលលង់ខ្លួនទៅក្នុងបឹងដែលមានទឹកជ្រៅផុតដៃផុតជើង ។ វានាំគ្នាហែលភ្លឹងភ្លុង១យ៉ាងលំបាក ។ ខ្លះទៀត ពន្លិចខ្លួនទៅក្នុងទឹក ទុកតែប្រមោយ (ដៃ) នៅលើទឹកប្រវែងប្រមាណមួយចំអាមសម្រាប់ដកដង្ហើម ។ គួរឱ្យអនិច្ចាណាស់ ! ដំរីធំៗដែលមានកម្លាំងស្ទុះបោលបានលឿន អាចរត់ចេញពីការប៉ិព័ទ្ធរបស់ទម័កបានឆ្ងាយផុតពីការភិតភ័យ ។ រីឯដំរីជំទើ១ [៣] ស្ទាវ១ ដែលខ្សោយ រត់មិនលឿន មិនសូវប៉ិនប្រសប់ខាងហែលទឹក ហែលមិនទាន់គេ ក៏ត្រូវធ្លាក់មកនៅជួរក្រោយ ។ គឺពួកកូនដំរីដ៏អភ័ព្វទាំងនេះហើយដែលជាទិដ្ឋៅរបស់ទម័កទាំងឡាយ ។ ទម័កទាំងប៉ុន្មានរុំទូកយ៉ាងលឿន

---

(១) គេផ្លុំស្នែងក្របីតែតេរប្លក ដែលគេធ្វើតាមជាគងមេបញ្ជាឱ្យវាភ្ញាក់ក្រុក ។ (២) អើក ពិន អាក់រោកដំរីពោធធំលេ ព្រោះវាមានកម្លាំងខ្លាំងក្លា ពិបាកផ្ទុំង ពិបាកពង្រាក ។ (៣) ដំរីស្ទាវ ទំរាំរ៉ុមក្រុកក លើកពក់រោក ព្រោះវាមានខ្លួនតូច កម្លាំងតិច ងាយផ្ទុំង ស្រួលពង្រាក និងក្រើការប្លូវឆ្នាំ ក្រោមពេល ៤០ ឆ្នាំ ដល់ ៥០ ឆ្នាំ ។

ប្រដេញតាមកូនដំរីដាច់ហ្វូង ។ ចំណែកឯដំរីធំៗវិញ ពេលទៅជិតដល់បឹងធំ [១] វាក្រាញមិនចង់ទៅ ព្រោះខ្លាចទឹកជ្រៅផុតជើង ពិបាកហែល ។ ពួកវាហាក់ចង់បែរមករកតទល់នឹងពួកទម័ក ។ ប៉ុន្តែ មនុស្សរាប់រយរាប់ពាន់នាក់ ដែលជិះទូកប្រមាណ ៣០០ គ្រឿង ស្រែកបោោគំរាមលើកគ្រឿងអាវុធដូចជា ព្លៅ កង្វេរ និងក្រោមសន្ទឹកស្នូរសន្ធាប់នៃបំពង់ថ្នស្អុយ ឮស្នូផ្ទុងៗ ដូចកាំភ្លើងធំ ល្មមគ្រប់គ្រាន់នឹងធ្វើឱ្យវាស្លុះបោលប្រាសយកតែអាយុរៀងៗខ្លួន ។ ពេលនោះ ភាពច្របូកច្របល់មួយបានប្រាកដឡើងនៅចំពោះមុខទម័កទាំងឡាយ : ដំរីមេ ដំរីមេហ្វូង រត់ចោលកូន ចោលបរិវារ ប្រថុយចុះហែលក្នុងទឹកបឹងដ៏ជ្រៅ ដែលវារួញរាមិនចង់ចុះ ។ លុះអុំទូកបានខិតទៅជិតកូនដំរីហើយ ទម័កម្នាក់លូកដងក្វារ [២] ដែលនៅខាងចុង មានផ្លែកង្វារយ៉ាងមុតទាញផ្ចក់ក្បាលដំរី ហើយទាញកញ្ឆក់ឱ្យមុតលិចជ្រៅទៅក្នុងសាច់ក្បាលហូរឈាមរហាម ។ ទម័កម្នាក់ទៀត លូកដងកង្វារផ្ចក់ឱ្យមុតសាច់គូថ ឬសាច់លោងដំរី អ្នកខាងក្បាលប្រទាញទៅស្តាំ អ្នកផ្ចក់ខាងគូថប្រទាញទៅឆ្វេង ធ្វើឱ្យដំរីស្រែករោទិ៍យ៉ាងខ្លាំង ដោយការឈឺចាប់មុខរបួស ទាំងខាងមុខទាំងខាងក្រោយ ។ ឆ្លៀតពេលដែលដំរីជាប់កង្វារ ទាំងខាងក្បាលទាំងខាងគូថ ទម័កម្នាក់ទៀត យកច្រវាក់ទៅរុំចងកដំរី ហើយទាញកន្ទុយច្រវាក់មកចងនៅខ្ចង់ទូក ។ ក្នុងស្ថានភាពបែបនេះ ទោះបីដំរីកាច សាហាវ ក៏វាមិនអាចតបតនឹងទម័កបានឡើយ ។ លុះទាក់ការបានស្រួលបួលហើយ ពួកទម័កទាំងនេះអុំទូកនាំដំរីទៅរកដើមរាំងដែលមានមែកទេចេញទៅខាង ជាការងាយស្រួលចងដំរីឱ្យនៅទីនោះអណ្តែតភ្លឹងភ្លុងជើងផុតពីដី កុំឱ្យរើបម្រះរបូតរួច ។ ដោយត្រូវគេឆ្លឹងជើងក្រោយ និងចាក់ទន្លឹងស្នាមុខថែមទៀត ពួកទម័កចងវាទុក នៅទីនោះបង្អន់វាឱ្យអស់កម្លាំង ឃុំឃាំងទុកក្នុងរយៈពេលពីរ ឬបីថ្ងៃ

---

(១) បឹងនោះមានប្រវែងប្រមាណ ៣០០ ម៉ែត្រ ឈ្មោះហៅថា បឹងប្រធាគត់

(២) ក្វារ ឬ កង្វារ

រួចហើយគេបានឆ្មៀតមករកទាក់ដំរីមួយ ឬពីរទៀត ហើយយកមកចងក្រៀកនៅជាប់នឹងមែករាំងដែលដុះវៀកកន្ទែកទៅខាងក្បែរដំរីចងទុកមុននោះ ។ ដើម្បីធានាកុំឱ្យដំរីព្រៃរើបម្រះរួចនោះ ពួកហ្មាតែងតែមានការប្រុងប្រយ័ត្នខ្ពស់ ។ ក្រោយពីចងក្រៀកជាប់នឹងដើមរាំង គេក៏យកខ្សែព្រួរមួយកន្ទុយចងកវា ប្រទាញយ៉ាងតឹងចងទៅភ្ជាប់នឹងដើមរាំងមួយនៅខាងមុខ ហើយយកខ្សែព្រួរមួយកន្ទុយទៀត ចងភ្ជាប់ពីកន្ទុយខ្សែកង្វារ យកទៅចងរឹតនឹងដើមរាំងមួយទៀត នៅខាងក្រោយ ។ ធ្វើយ៉ាងនេះ ខ្លួនកូនដំរីទាំងមូលត្រូវជាប់ចំណងដល់ទៅបី ជាហេតុដែលវាពុំមានលទ្ធភាពនឹងរើឱ្យរួចខ្លួនបានឡើយ ។ គេចងបង្ខាំងវា បង្អត់ស្មៅ ក្នុងស្ថានភាពបែបនេះ អស់រយៈពេលបីថ្ងៃ ក្នុងគោលបំណងធ្វើឱ្យកម្លាំងវាទ្រុឌទ្រោម ចុះខ្សោយ ហើយងាយនឹងយកទៅពង្រាប ។ បន្ទាប់មកទៀត គេបានចាត់គ្នាឱ្យមកយកដំរីធ្នាក់ពីភូមិយកទៅត្រៀមចូលរួមក្នុងការពង្រាប [១] ដំរីព្រៃដែលទើបនឹងទាក់បានមក ។

*៥ . វិធីពង្រាបដំរី :*

ដំរីធ្នាក់ត្រូវបានគេនាំមករង់ចាំនៅជើងទួលក្បែរមាត់ទឹក ។ ពួកទម័កបានទៅស្រាយកូនដំរីព្រៃ ដែលបានចងបង្ខាំងទុកនោះ នាំយកទៅកាន់ទីទួលដែលជាដីគោកដោយមានការប្រុងប្រយ័ត្នមិនឱ្យមានការធ្វេសប្រហែស ។ ទម័កទាំងប៉ុន្មានបានជិះទូករអមដំណើរដំរី មានកង្វារថ្ពក់ក្បាលថ្ពក់កន្ទុយ ទាញក្រៀកជាប់មិនឱ្យវារើរួច ។ ពេលដែលមកដល់ជើងទួល គ្រាន់តែឃើញដំរីធ្នាក់ភ្លាម ដំរីព្រៃស្ទុះមកបុករអាធ្នាក់ទាំងកំរោល ទៅតាមសភាវៈកាចសាហាវ តាមចរិតវាជាដំរីព្រៃ ។ ប៉ុន្តែ ព្រមពេលជា

---

(១) អ្នកខេត្តតាកែវ កណ្ដាល កំពត កំពង់ស្ពឺ ... ច្រើនហៅថា «ពង្រាប» ឯអ្នកខេត្តដទៃខ្លះទៀត ដូចជា ខេត្តកំពង់ធំ សៀមរាប ... ហៅថា «ប្រាប» ។ ទោះជាយ៉ាងនេះក្ដី ក៏ពាក្យទាំងពីរមានន័យដូចគ្នា គឺធ្វើឱ្យតាំង, ឱ្យចេះដឹងរបៀបប្រើការងារនៅក្នុងស្រុកភូមិ ។

មួយគ្នានោះ ហ្មដែលជិះលើអាធ្លាក់[១] ក៏ស្រែកបញ្ជាថា[២] «ទប់» ពេលនោះ អាធ្លាក់ដែលវៃឆ្លាតស្រាប់ យកប្រមោយវាក្រវេក-ក អាព្រៃរឹងដូចដង្កាប់ដែក ។ ហ្ម បញ្ជាទៀតថា « ឡើង » ! ភ្លាមនោះ អាធ្លាក់ធាក់អាព្រៃមួយជើងក្រោយ ធ្វើឱ្យវា ឈឺខ្លាំងហើយស្រែករោទិ៍ឮខ្ទរវាល ។ ទម័កក៏នាំកូនដំរីព្រៃដែលគេចងក្រវាក់វាភ្ជាប់ ទៅនឹង-កអាធ្លាក់កុំឱ្យរើបម្រះបាន ។ ចំណែកឯជើងមុខត្រូវជាប់ទន្លឹង[៣] ដែល រំខានកូនដំរីព្រៃមិនអាចឱ្យធ្វើសកម្មភាពអ្វីខ្លាំងបាន ។ គេនាំវាទៅកាន់ទួល « គោក ព្រះ » ។ នៅទីនោះ គេធ្វើសន្លងសម្រាប់បង្ហាំងដំរី ។ គេបោះបង្គោលប៉ុនខ្លួនដំរី ។ នៅខាងឆ្វេង និងខាងស្តាំ គេចងរបា ៤ ខាងមុខក៏ចងរបា ៤ រឹងមាំៗផងដែរ ។ គេនាំយកកូនដំរីព្រៃទៅបញ្ចូលក្នុងសន្លងនោះ ។ កូនដំរីក្រាញមិនព្រមចូលក្នុងសន្លង នោះឡើយ ។ ហ្មស្រែកបញ្ជាអាធ្លាក់ថា « បញ្ចូល ! » ។ ភ្លាមនោះ អាធ្លាក់ឡើង កែងមួយជើងយ៉ាងធ្ងន់ធ្វើឱ្យអាព្រៃស្តាប់បង្គាប់ ដោយឈឺនឹងទម្ងន់ជើងរបស់ អាធ្លាក់ ។ នៅក្នុងសន្លង គេទាក់ជើងមុខទាញទៅចងភ្ជាប់នឹងស្នឹងមួយ ហើយទាក់ ជើងក្រោយសន្ទឹងទៅចងភ្ជាប់នឹងស្នឹងមួយ ។ កូនដំរីព្រៃជាប់យ៉ាងរឹងក្រញង់នៅក្នុង សន្លង ងាកឆ្វេង ស្តាំ ទៅមុខ ទៅក្រោយក៏ពុំរួច ។ ទាំងជើងមុខ ជើងក្រោយ ក៏ត្រូវធ្លឹងជាប់រឹងស្តូកទាំងអស់ ។ ដូច្នេះ កូនដំរីព្រៃពុំមានផ្លូវណានឹងរើបម្រះបាន សោះឡើយ ។ ទម័កច្រូតស្មៅមកឱ្យកូនដំរីព្រៃស៊ី ដើម្បីស្តារកម្លាំងឡើងវិញខ្លះៗ ត្រៀមទុកទទួលការពង្រាប ។ ប៉ុន្តែ កូនដំរីព្រៃដែលស្ថិតក្នុងស្ថានភាពខ្វះសិទ្ធិ សេរីភាព និងរងទារុណកម្មខ្លាំងក្លាបែបនេះ វាមិនសូវល្មោភស៊ី ដូចកាលនៅក្នុងហ្វូង

(១) ដំរីដែលគេបង្ហាត់បង្វឹកឱ្យចេះគ្រប់បច្ចេកទេស យុទ្ធវិធីទុកសម្រាប់ទាក់ និងផ្សាំងដំរីព្រៃ ។ ដំរីធ្លាក់ច្រើនតែដំរីឈ្មោល ។ (២) ដំរីសុទ្ធតែបានឈ្មោះ ឧបមាថា បើអាធ្លាក់ឈ្មោះ អាប្រុកប គេបញ្ជាវាថា អាប្រុកបទប់ ។ (៣) ប្រដាប់ធ្វើដោយផ្តៅវេញពួរគ្នា ៣ ធ្នុង ធ្វើជារង្វង់ ប្លូ១ពីរសម្រាប់ស៊កចូលក្នុងជើងដំរី បង្ខាំងវាកុំឱ្យវារត់រៀនបាន ។

ឡើយ ។ ក្នុងពេលនេះ គេផ្សាំងវាដោយទម្លាប់ឱ្យវាមានការទំនាក់ទំនងស្និទ្ធស្នាលជាមួយមនុស្ស ។ រាល់ៗថ្ងៃ គេទៅលើករអាចម៍វា បោសសំអាតសន្លង ឆ្លៀតស្ទាបអង្អែលវា និយាយរកវាដោយពាក្យទន់ភ្លន់ ។ កូនដំរីព្រៃត្រូវចងបង្ខាំងទុកបែបនេះពី ៥ ទៅ ១០ ថ្ងៃ ដោយយោលទៅតាមអាកប្បកិរិយាចុះញ៉ម ឬទទឹករឹងរូស ។ លុះសង្កេតឃើញថា កូនដំរីព្រៃប្រែប្រួលចរិតពីសាហាវមកស្លូតបូតបន្តិចហើយនោះ គេក៏បញ្ចេញវាពីសន្លងទៅចងនៅមាត់ទឹក ដោយដាក់ទន្លឹងទាំងជើងមុខ ទាំងជើងក្រោយ កុំឱ្យវាធ្វើចលនាដើរ ឬរត់បានលឿន ។ នៅទីនោះ គេទម្លាប់លាងទឹកឱ្យវា ស្ទាបអង្អែល ឡើងជិះលើខ្នង ឬលើ-ក របស់វា ។ រាល់សកម្មភាពប្រតិកម្មអ្វីផ្សេងៗ គេមានដំរីធ្នាក់ជាជំនួយក្នុងការដាក់ទណ្ឌកម្ម ។ លុះដល់ម៉ោង ៤ រសៀលគេក៏បញ្ចូលវាដាក់ក្នុងសន្លងវិញ ។ ថ្ងៃជាបន្តបន្ទាប់មកទៀត គេបង្ហាត់វាឱ្យរៀនដើរត្រង់ទៅមុខ ដោយមានទម៉ែកម្នាក់នាំដើរពីខាងមុខ ។ កាលណាត្រូវឱ្យវាបត់មកឆ្វេង ទម៉ែកស្រែកបញ្ជាថា «ឆ្វេង» ដោយយកចុងកង្វេរ[១] កាវក្បាលឱ្យងាកទៅឆ្វេង ។ ដូច្នេះរាល់បញ្ជា សុទ្ធតែភ្ជាប់ជាមួយនឹងការចុចចុងកង្វេរឱ្យមុតសាច់ក្បាលដំរីជ្រៅ ឬរាក់ ទៅតាមចរិតគោរពតាម ឬរបឹង ។ ហ្មបង្ហាត់ឱ្យចេះបត់ឆ្វេងបត់ស្តាំ ឱ្យចេះថយតាមបញ្ជាថា « ថុន » ឱ្យចេះក្រាបលើដីតាមបញ្ជាថា « ដាក់ ! » ឬ « ទ្រោម » ឱ្យចេះលើកជើងស្តាំថា « ជូន ! » ឱ្យឈប់ថា « បារ » ។ លុះដំរីចេះខ្លាចហ្ម ចេះស្តាប់ពាក្យបញ្ជាសព្វគ្រប់ហើយ គេលែងប្រើធ្នាក់ទៀតហើយ ។ ទម៉ែកចេះតែបង្ហាត់ បង្វឹកវាជារៀងរាល់ថ្ងៃ រហូតទាល់តែបញ្ជាបានដោយមាត់ទទេ

---

(១) កង្វេរ គឺជាគ្រឿងប្រដាប់ក្រញ៉ាងដែលហ្មដំរីកាន់សម្រាប់បង្រ្កាបដំរីឱ្យស្តាប់បង្គាប់ ។ ដងឈើ មានប្រវែង ៨ តឹក ផ្លែកង្វេរធ្វើពីដែកថែបមានពីរផ្នែក ៖ ផ្លែកង្វេរមានរាងកូក់ខាងចុង ដែលស្រួចមុត ខាងលើរបស់វាត្រូវយកង្វេរ ចុងវាក៏ស្រួចមុតណាស់ដែរ ផ្លែកង្វេរសម្រាប់ផ្ចាក់ការដំរី ឯត្រូវវាសម្រាប់ចាក់ ។ ដំរីខ្លាចកង្វេរ ដូចខ្លាខ្លាចរំពាត់រត្តិតនីដែរ ។

មិនចាំបាច់ប្រើកង្វេ គឺបើចង់ឱ្យវាបត់ស្ដាំ គេគ្រាន់តែស្រែកបញ្ជាថា ស្ដាំ ! ហើយយកជង្គង់ឆ្វេងញាក់តិចៗទៅលើ-កឆ្វេងរបស់វាងាកមកស្ដាំ ។ ល ។ រហូតដល់ចុងក្រោយបំផុត គេគ្រាន់តែបញ្ជាតែមាត់ទទេដោយពុំចាំបាច់ញាក់នឹងជើងអ្វីទាំងអស់ ។ ការពង្រាបដំរីព្រៃ ច្រើនមានរយៈពេលមិនហួសពីមួយខែឡើយ ។ សូមជម្រាបថា នៅពេលផ្សាំងនេះ ដើម្បីជួយឱ្យដំរីឆាប់ « រាប » (១) ទម័កតែងស្ដោះដំរីរាល់ព្រឹកដោយដុតធូប ៣ សរសៃក្ងរទឹកផ្ដិល ហើយសូត្របាលីថា « សុរ សិរិអះ ! » ៣ ចប់ រួចរលាស់ទឹកទៅលើដំរី សូមឱ្យម្រេញគង្វាលជួយឱ្យដំរីឆាប់សាំង និងស្លូតបូតស្រួលប្រើ ។ ចុងក្រោយបំផុត គេបង្ហាត់វាឱ្យមានទម្លាប់ចងពៀង (២) ឬចងកូបលើខ្នងដំរី ។

ការបង្ហាត់ដំរីឱ្យចេះតាមរបៀបរបបស្រុកនេះ បានបញ្ចប់នៅរវាងខែបុស្ស រដូវចម្រូត ដែលត្រូវភ្ជាប់ជាមួយការដឹកកណ្ដាប់ស្រូវ ឬដឹកគ្រាប់ស្រូវពីស្រែមកផ្ទះ ។ ប្រសិនបើគេទាក់បានចំនួនដំរី ដែលអាចចែកបានមួយៗម្នាក់ឱ្យមនុស្សក្នុងក្រុមនោះ បានសេចក្ដីថា ម្នាក់ៗបានទទួលចំណែកជាដំរីមួយ សម្រាប់យកមកប្រើប្រាស់នៅក្នុងគ្រួសារ ។ តែផ្ទុយទៅវិញ បើក្នុងក្រុមនេះ ( ដែលមានគ្នា ៣ ឬ ៤ នាក់ ) គេទាក់បានតែមួយនោះ គេយកដំរីទាក់បាននេះលក់ចែកប្រាក់គ្នា ក្រោយពីបានបង្ហាត់បង្រៀនបានចេះដឹងសព្វគ្រប់ហើយ ។ ប្រសិនបើគេត្រូវការទុកប្រើវិញនោះ បន្ទាប់ពីបានបង្ហាត់ចេះដឹងតាមរបៀបរបបដំរីស្រុកហើយនោះ គេក៏រៀបចំ

---

(១) ចេះស្ដាប់បង្គាប់តាមបញ្ជា មិនច្រងេងច្រងាង មិនធ្វើប្រតិកម្មនាំឱ្យបាត់សណ្ដាប់ធ្នាប់

(២) ជាគ្រែតូចប្រភេទ ខាងក្រោមមានជិតាតត្រូវតាមទំនងប្រទង់ខ្នងដំរី ។ គេចងពៀងលើខ្នងដំរីដើម្បីមនុស្សជិះ ៦ នាក់បានស្រួល ។ គេយកខ្សែជង្គន់បកចងរឹតពៀង ( រយាង ) ភ្ជាប់ទៅពោះដំរីយ៉ាងតឹងកុំឱ្យរអិលក្រឡាប់ពៀងបាន ។ ជួនកាលគេចងកូបពីលើពៀងទៀតដើម្បីធ្វើជាដំបូលការពារភ្លៀង ឬកម្ដៅថ្ងៃ ។

យកវាមកចូលស្រុកភូមិរស់នៅជាមួយមនុស្សតរៀងទៅ ។

### ៦ . ពិធីសែនចាប់ជើង [១]

ពេលនាំមកដល់ស្រុកភូមិភ្លាម មុននឹងអនុញ្ញាតឱ្យវារស់នៅ ក្នុងនាមជាសត្វចំណូលថ្មី ក្នុងចំណោមសត្វពាហនៈដទៃទៀតនោះ ជាចាំបាច់ ហើយជាទម្លាប់ដែលធ្លាប់តែធ្វើជារៀងដរាបមក គេត្រូវតែធ្វើពិធីមួយ ហៅថា « ពិធីសែនចាប់ជើង » ។ ដើម្បីធ្វើពិធីនេះ គេត្រូវត្រៀមម្ហូបចំណី ប្រដាប់ប្រដាពិសេសៗ សម្រាប់រៀបចំជាសំណែនជូនចំពោះម្រេញគង្វាល ម្ចាស់ទឹក ម្ចាស់ដី អារក្ខ អារក្ស អ្នកតារក្សាទឹកដី ភូមិឋាន ដែលមានជាអាទិ៍ ក្បាលជ្រូក ឬជ្រូកខ្ទែទាំងមូល ( ទម្ងន់ប្រមាណ ៤០ ទៅ ៥០ គីឡូ ) មាន់ស្ងោរ ១ គូ បង្អែម ៤ ចាន ចំអាប ៤ ចាន ក្នុងនោះមានចេកទុំ ២ ស្និត ជម ១ គូ ស្លាធម៌ ១ គូ បាយសីប្រាំថ្នាក់ ១ គូ លាជ ១ គូ ផ្កា ទឹកអប់ ស្រា ទៀន ធូប ស្លា ម្លូ បារី ច្រមមួយមានដាក់អាវខោខ្នាតតូច ១ សម្រាប់ថ្វាយម្រេញគង្វាល ខ្មោច អារក្ស អ្នកតា អ្នកថែរក្សាដំរី ។ នៅមុនពេលសែន គេបង្ហូកប្រគំជាបទចំពោះ « សុរិន្ទខ្នងភ្នំ » ៣ បទ ទុកដូចជងោ្ហយហៅអស់អារក្សអ្នកតាព្រៃភ្នំ ម្រេញគង្វាល ឱ្យមកសណ្ឋិត និងជួយថែរក្សាដំរី ធ្វើឱ្យដំរីផ្តាច់ខ្លួនពីជីវិតជាសត្វព្រៃមកជាសត្វស្រុកវិញ ( សត្វពាហនៈ ) ។ នៅក្នុងភូមិ, បើមានដំរីច្រើនក្បាល ដែលត្រូវសែនចាប់ជើង[១] ( ឱ្យឈ្មោះ ) នោះ គេប្រមូលគ្នាមកធ្វើតែមួយកន្លែង ក្នុងថ្ងៃជាមួយគ្នាតែម្តង ។ ដូច្នេះ បងប្អូនឆ្ងាយជិត ញាតិមិត្តក្នុង និងក្រៅភូមិត្រូវបានអញ្ជើញឱ្យចូលរួមក្នុងពិធីនេះយ៉ាងច្រើន ដោយមានចាត់ចែងម្ហូបអាហារពិសេសៗ សម្រាប់ការជប់លៀងផង ។ លុះបងប្អូនញាតិមិត្តដែលត្រូវចកចូលរួម

(១) នៅពេលសែនចាប់ជើងនេះ ទាក់ក៏ធ្វើពិធីដាក់ឈ្មោះត្រូវពេលជាមួយគ្នានេះតែម្តង ។ គេច្រើនធ្វើពិធីនេះនៅពេលរសៀល ។

បានមកជួបជុំគ្នាអស់ហើយនោះ គេក៏ចាប់ផ្ដើមប្រារព្ធពិធីដាក់ឈ្មោះជាមុនសិន ។ របៀបឱ្យឈ្មោះដីរី, កាលពីបុរមបុរាណ គេសរសេរឈ្មោះ ៣ យកទៅចងផ្កាបនឹងអំពៅខ្មៅ ៣ ដើម ។ គេដឹកដីរីទៅជិតអំពៅទាំង ៣ ដើមនោះ ។ បើដីរីលូកយកដើមអំពៅណា គេយកឈ្មោះដែលសរសេរបិទនៅដើមនោះមកដាក់ធ្វើជាឈ្មោះដីរី ។ ឈ្មោះដែលគេច្រើនយកមកដាក់ឱ្យដីរី មានជាអាទិ៍ អាចំរើន អាសម្បុក អាសម្បូរ អាពេជ្រ អាកែវ អាប្រកប អាសុវណ្ណ អាប្រសើរ អាពូន អាមណី ។ ល ។ ប៉ុន្តែដល់មកពេលក្រោយៗមកទៀត គេមិនសូវផ្សងឱ្យដីរីចាប់អំពៅរើសឈ្មោះខ្លួនឯងបែបនេះទេ គេច្រើនឱ្យហ្មចាស់ៗក្នុងភូមិដាក់ដាក់ឱ្យ តាមការពេញចិត្តរបស់គាត់ រួចហើយម្ចាស់ដីរីសន្មតយកឈ្មោះដែលហ្មចាស់ទុំដាក់ឱ្យនោះ សម្គាល់ដីរីខ្លួនជារៀងរហូតទៅ ។ កាលណារកឈ្មោះឱ្យដីរីថ្មីបានហើយ ចាស់ទុំ និងអ្នកចូលរួមទាំងអស់ ក៏បានប្រារព្ធពិធីសែនព្រេន ដោយពោលយ៉ាងនេះថា : *« ឱ ! ព្រះតេជះម្ចាស់ទឹក ម្ចាស់ដី អារុក្ខ អារក្ស អ្នកតា ទេព្វញគង្វាល អ្នកសច្ចំកំបាំង បង់បត់ថ្ងៃនេះថ្ងៃជា ពេលាល្អ យើងខ្ញុំរៀបចំអាហារភោជន មានបង្អែម និងចំអាបនំនែក ផ្លែឈើ ម្លូស្លា បារី ថ្វាយចំពោះ អស់លោកទាំងអស់សេពសោយឱ្យបានសប្បាយរីករាយ ហើយជួយឱ្យដីរីយើងខ្ញុំនេះរស់នៅបានសុខចំរើន ឋិតថេរគង់វង្សនៅជាមួយនឹងម្ចាស់ថ្មីនេះ សូមជួយចម្រុងចម្រើនអស់កាលយូរអង្វែងតទៅ និងសូមជួយឱ្យពួកយើងជាអ្នកស្រុកក្នុងភូមិនេះបានសុខសប្បាយព្រមទាំងសត្វធាតុគោ ដីរី ក្របី សេះ ប្រាសចាកជំងឺតម្កាត់នានា សូមបានជោគជ័យសិរីសួស្តីតរៀងទៅ »* ។ លុះសែនព្រេនបែបនេះជាគម្រប់ ៣ ដងហើយ គេចាប់ចំណិទាំងបង្អែមទាំងចំអាបមួយមុខបន្តិចៗគ្រប់មុខដាក់លើស្លឹកចេក រួចច្រូចទឹកច្រូចស្រា ជាកិច្ចបញ្ចប់ ។ បន្ទាប់ពីពិធីសែនព្រេននេះទៅ ពិធីជប់លៀងបែបពិសេសមួយ ចាប់ផ្ដើមឡើងក្នុងបរិយាកាសសប្បាយរីករាយក្រៃលែង ។ បាយ

សាច់ជ្រូកខ្វៃ មាន់ស្ងោរ និងមុខម្ហូបផ្សេងៗទៀត គឺជាចំណីអាហារជាគ្រឿងក្លែម ដ៏ឆ្ងាញ់បំផុត ដែលគេយកមកផ្សំជាមួយនឹងភេសជ្ជៈចាំបាច់មួយមុខទៀត គឺស្រាស មួយឱទិនស្រេះ បានបង្កលក្ខណៈឱ្យគេហូបចុកបានសប្បាយរីករាយ រហូតដល់យប់ជ្រៅ ទើបចប់កម្មវិធី ។

*អវសានកថាៈ* គួរឱ្យស្តាយអ្វីម្ល៉េះទេ បច្ចុប្បន្ននេះ ការទាក់ដំរីរនាមគ្រាន់តែជាឆាកមួយដែលមានតែក្នុងសុបិនប៉ុណ្ណោះ ។ បើគេយករឿងនេះមកនិទានដោយផ្ទាល់មាត់ក្តី សរសេរជាលាយលក្ខណ៍អក្សរក្តី អ្នកស្តាប់ អ្នកអាន គិតក្នុងចិត្តថា វាមិនមែនជារឿងពិតទេ តែគឺជារឿងព្រេងនិទានមួយប៉ុណ្ណោះ ។ មូលហេតុដែលពុំមានដំរីរនាម និងពុំមានការទាក់ដំរីរនាម គឺដោយសារប្រទេសយើងកើតសង្គ្រាមដែលការប្រើគ្រាប់កាំភ្លើង គ្រាប់បែក គ្រាប់មីន ការកាប់បំផ្លិចព្រៃឈើ បានធ្វើឱ្យដំរីក្នុងព្រៃភ័យស្លន់ស្លោភ្ញាក់ផ្អើលរត់ទៅប្រទេសជិតខាងស្ទើរអស់ ។ ដូច្នេះ ចលនាចេញពីព្រៃភ្នំមករកស៊ីនៅបឹងក្នុងរដូវប្រាំង និងចលនាឡើងពីតំបន់បឹងទៅនៅក្នុងព្រៃ នៅរដូវទឹកជំនន់ ក៏លែងមានទៀត ព្រោះដំរីព្រៃរបស់យើងរត់ខ្ចាត់ខ្ចាយចេញពីស្រុកស្ទើរអស់រលីង ។

ម្យ៉ាងវិញទៀត តាំងពីយូរលង់ណាស់មកហើយ ពូជសាសន៍ខ្មែរយើងឱ្យតម្លៃសមត្ថភាពមនុស្សទៅលើការប៉ិនប្រសប់ និងសេចក្តីក្លាហាន ប្តូរស្លាប់រស់ដើម្បីចាប់ទាក់ដំរីព្រៃដែលជាសត្វចតុប្បាទសាហាវគ្រោះថ្នាក់ ហើយមានមាឌធំជាងគេបង្អស់នៅក្នុងលោកឱ្យបានទាំងរស់ ហើយយកមកផ្សាំងប្រើប្រាស់ក្នុងជីវភាពរស់នៅក្នុងស្រុកភូមិ ។ អ្នកទាក់ដំរីបានកាន់តែច្រើនកាលណា មានអ្នកផងផ្តល់កិត្តិយស និងគោរពកោតខ្លាច ទុកដូចជាមនុស្សខ្លាំងពូកែ ដែលត្រូវតែលើកតម្កើងឱ្យធ្វើជាមេធំ ។ អតីតរាជធានីពីបុរាណរបស់យើងមួយ មានឈ្មោះថា « វ្យាធបុរៈ » មានន័យថា « បុរីទាក់ដំរី » នេះ ជាភស្តុតាងឱ្យយើងយល់បានថា កាលពីដើមខ្មែរយើង

ឡុតម្លៃខ្ពស់ណាស់ទៅលើការទាក់ដីរ រហូតដល់ដាក់ឈ្មោះរាជធានីភ្ជាប់ទៅនឹងការទាក់ដីរ ។ បើយើងធ្មេចភ្នែកនឹកគិតទៅដល់អតីតកាលដ៏យូលង់របស់ដូនតាខ្មែរយើង នោះយើងនឹងអាចសន្និដ្ឋានបានថា កាលពីរយៈពេលរាប់ពាន់ឆ្នាំមកនេះ ការទាក់ដីរត្រូវគេយកមកធ្វើជាវិញ្ញាសា ជាខ្នាតសម្រាប់វាស់សមត្ថភាពមនុស្ស ដែលព្រេងវាសនាត្រូវចាត់ឱ្យបានមកធ្វើជាមេ ជាចៅហ្វាយលើអស់ពួកមនុស្សឯទៀត ។ នៅក្នុងប្រវត្តិសាស្ត្រ គេបានឮព្រះនាមព្រះរាជា នាម សុរ្យវរ្ម័នទី២ និង ជយវរ្ម័នទី៧ ដែលសុទ្ធសឹងជាមហាក្សត្រខ្លាំងបំផុតនៅលើវិញ្ញាសាទាក់ដីរនេះ ។

ដោយ **មៀច ប៉ុណ្ណ**
ការិយាល័យទំនៀមទម្លាប់ខ្មែរ
នៅពុទ្ធសាសនបណ្ឌិត្យ

## សុភាសិត

- *ខន្តីវិសេសលើសទ្រព្យធន ខន្តីមិនអន់ជាងវិទ្យា*
  *ខន្តីសម្រួលដល់កាយា ខន្តីមេត្តាដុតទុក្ខផង ។*

# ឈ្មាចជិត ភះញ្ញីជិត (១)

*អានរឿងមាយើងផ្ទើងសក្កា    មែនមានវាសនាសែនសោភី*
*មាមានប្រពន្ធដល់ទៅពីរ    មុនក្រោយទាំងទ្វីលក្ខណ៍ផ្សេងគ្នា ។*
*នាងមានសោភ័ណរូបល្អស្រស់    សែនសមឥតខ្ចោះស្រស់ពុំងា*
*ប៉ុន្តែចរិតវែងពាលា    ពុំអាចធានាបង្កើនធន ។*
*ខ្ជះខ្ជាយចាយវាយពុំស្រណោះ    នូវទ្រព្យរបស់ច្រើនពេកពន់*
*ឆ្មុងឆល្មួសឆាយឥតស្តាយទុន    ប្តីសែនទារុណធ្ងន់ឱរ៉ា ។*
*ជញ្ជាត់បានក្រឹមកំពិសត្រី    ចាក់ទៅក្នុងល្បិចកាលណា*
*លេចចេញតាមរន្ធអស់អសារ    គ្មានសល់មច្ឆាបន្តិចសោះ ។*
*ប្រពន្ធទីពីរផ្លូវបានថ្មី    ជាមួយសេដ្ឋីសោះកក្រោះ*
*ឃើញរូបនាងផ្ទុះសែនល្អស្រស់    ជាំងអស់ចរិយាពាលអប្រិយ ។*
*ចៃដន្យប្រវត្តិចត់ផ្លូវពេក    លើដីក្រោមមេឃនាលោកិយ*
*មិនដែលមានសោះប្រុសជាប្តី    ផ្លូវស្រីប្រពន្ធដូចសត្វធាតុ ។*
*នាយឈ្លើញរោត្រាខឹងពេកពិត    ព្រោះដ្បិតប្រពន្ធចេះសាវាទ*
*មេត្តាមាណពមានមារយាទ    បានស្រីជួជាតិជាប្រពន្ធ ។*
*បុរសកំសត់មិនកំសាក    តែទាស់ឋានៈខ្លួនទាបទន់*
*ឮគេកំហែងផ្លូវប្រពន្ធ    គិតគន់ថាគេចំអកឱ្យ ។*
*ប៉ុន្តែដោយគេចាប់បង្ខំ    រន្ថើនចំៗពុំបណ្តោយ*
*ឱ្យចៅមាណពប្រកែកឡើយ    ត្រូវឱ្យប្រពន្ធទុកជាថ្នូរ ។*
*វាសនាប្រែប្រាស់ត្រឡប់ចាក់    បានស្រីគ្រប់លក្ខណ៍ដោយការផ្លូវ*

(*) គត់មត់ មិនធ្មុះមិនធ្លាយ

ស្រីល្អរូបស្រស់ពុំត្រូវផ្ទូរ ទឹកចិត្តពុះពោរឡើងរាសី ។
ក្លាយទៅជា-ប្រ-ពន្ធដង្គៅ គឺម្ចាស់សំពៅអ្នកមានល្បី
មាសប្រាក់កែវកងឥតខ្វះអ្វី ក្តីក្រលំបាកលែងតាមទាន់ ។
ប៉ុន្តែចរិតពិតឥតប្រែ ធ្លាប់តែខ្ជះខ្ជាយចិត្តមោហន្ធ
ចិនខាងបំផ្លាញសព្វទ្រព្យធន ឱ្យអន្តរធានអស់អសារ ។
ចំណូលកំរៃប្តីស្វែងស្វះ បានប្រាក់ច្រើនណាស់នាយភេត្រា
ទំនិញលក់ចេញច្រើនអស្ចារ្យ តែស្រីឫស្យារំលាយហ្មត់ ។
រីឯមាយើងថ្កើងវាសនា ដូរបានភរិយាកបបែបបទ
ជាស្រីគ្រប់លក្ខណ៍ពិតប្រាកដ សំណាងកំណត់ដោតជតា ។
ពេលនេះនាងបានមកជួបអ្នក(*) បុណ្យព្រេងទុកដាក់តាមតម្រា
បុរសឈ្មោះជិតភ្ជាប់វាសនា ជាមួយភរិយាកញ្ញើជិត ។
ប្រកបទាំងពីរភប់ប្រសព្វ បានជាគូគាប់ទ្រព្យមូលមិត្ត
ប្តីរកបានមកស្រីរិះគិត សន្សំប្រឹងប្រិតរិតរក្សា ។
ធនធានកើតកើនច្រើនពេកក្តាប់ សម្បត្តិសម្បើមឆ្មើមព្រៃណា
គំនិតគិតផ្សំនឹងប្រាជ្ញា វាសនាគួបផ្សំសមត្ថភាព ។
និទានជាល្បើកលើកខ្លឹមសារ ថែងចារសិក្សានិងប្រៀបធៀប
កំណត់អត្ថន័យលៃជម្រាប រាប់រៀបរឿង-សំ-ណាបយោងដី ។
ប្រុសៗថ្កើងយសព្រោះប្រពន្ធ កបកើតទ្រព្យធន់ដោយសារស្រី
ឃិតយោងលើកមុខលើកមាត់ប្តី នេះគឺស្នាដៃស្រីគ្រប់លក្ខណ៍ ។

ដោយ **មៀច ប៉ុណ្ណ**

(១) ពាក្យចាស់ថា « នាងជួបនឹងអ្នក មេខាតលក្ខណ៍ជួបអាបាក់ទន្សា » ឆ្នាំងណាគ្រប់ហ្នឹង

# អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៩

នៅទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

ថ្ងៃ ០១ . ០២ . ០៣ កក្កដា ២០០០

## ឱម ខែម

ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៩ បានប្រកាសបើក និងបានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ក្រោមព្រះបរមរាជាធិបតីភាព និងក្រោមព្រះបរមរាជូបត្ថម្ភដ៏ថ្លៃថ្លារបស់ព្រះករុណាជាអម្ចាស់ជីវិត និងសម្តេចព្រះរាជអគ្គមហេសី ។

សម្តេចព្រះសង្ឃរាជទាំងពីរគណៈទ្រង់ជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ក្នុងអង្គមហាសន្និបាត ។

ចូលរួមជាសមាជិកនៃមហាសន្និបាត មានមន្ត្រីសង្ឃគណៈមហានិកាយចំនួន ៦០ អង្គ មន្ត្រីសង្ឃគណៈធម្មយុត្តិកនិកាយចំនួន ៣៤ អង្គ មន្ត្រីធម្មការចំនួន ៦០ រូប ដែលនិមន្ត-អញ្ជើញមកពីខេត្ត-ក្រុង ទាំង ២៤ ។

ក្នុងរយៈពេល ៣ ថ្ងៃ នៃដំណើរការងាររបស់ខ្លួន គឺពីថ្ងៃ ០១ ដល់ថ្ងៃ ០៣ កក្កដា ឆ្នាំ ២០០០ អង្គមហាសន្និបាតមន្ត្រីសង្ឃ បានស្តាប់ ៖

- សុន្ទរកថារបស់ ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា, ថ្លែងស្វាគមន៍ចំពោះព្រះរាជវត្តមានព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះព្រះរាជ អគ្គមហេសី,
- ព្រះរាជសុន្ទរកថាបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី ៩ របស់ព្រះករុណាជាអម្ចាស់ជីវិត,

• សេចក្តីថ្លែងយោបល់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ស្តីពីបន្ទុកការងារ របស់ក្រសួងធម្មការ និងសាសនា លើវិស័យទាំងបី គឺ : វិស័យធម្មការ និងសាសនា, វិស័យពុទ្ធិកសិក្សា និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

អង្គមហាសន្និបាតបានស្តាប់ព្រះយោបល់ណែនាំការពិភាក្សារបស់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ លើរបៀបវារៈ « ទាំង ៤ » ដែលជាកម្មវត្ថុនៃការប្រជុំសំដៅលើកស្ទួយកេរ្តិ៍ឈ្មោះ កិត្តិយស សេចក្តីថ្លៃថ្នូរ របស់ ព្រះសង្ឃពុទ្ធសាសនិកកម្ពុជា និងតម្លៃនៃសច្ចធម៌របស់ព្រះពុទ្ធជាបរមគ្រូ ។

លើស្មារតីសាមគ្គី ឯកភាពខ្ពស់, អង្គមហាសន្និបាតបាន :

១. បន្តពង្រឹង និងពង្រីកអភិក្រមនៃការឯកភាព សាមគ្គីភាពព្រះសង្ឃពុទ្ធសាសនិកកម្ពុជាទាំងពីរគណៈ តាមព្រះរាជតម្រិះសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គអោយបានជ្រាលជ្រៅថែមទៀត ដោយផ្អែកលើមនសិការជាតិខ្ពស់ និងលើគុណធម៌ពុទ្ធសាសនា ។

២. ទទួលស្គាល់សារសំខាន់នៃព្រះពុទ្ធសាសនា ថាជាស្នូលនៃវប្បធម៌របស់ប្រទេសជាតិ ហើយដែលត្រូវបានចារឹកក្នុងរដ្ឋធម្មនុញ្ញជាសាសនារបស់រដ្ឋ ។ ក្នុងឋានៈនេះ សាមគ្គីភាពក្នុងជួរពុទ្ធសាសនិក ជាពិសេស ក្នុងជួរព្រះសង្ឃទាំងពីរគណៈ ត្រូវតែបានជាគំរូដល់ប្រជាពលរដ្ឋយើង ។ សាមគ្គីភាពនៃនិកាយសង្ឃទាំងពីរគឺជាសរសរទ្រូងនៃភាពគង់វង្ស រុងរឿង រីកចំរើន របស់ព្រះពុទ្ធសាសនា ក៏ដូចជាភាពគង់វង្ស រុងរឿង រីកចំរើន របស់ប្រទេសកម្ពុជា ដូច្នោះដែរ ។

៣. កត់សម្គាល់ឃើញថា ប្រជាពលរដ្ឋកម្ពុជា បានយកព្រះពុទ្ធសាសនាជាទីពឹង ទីរលឹក និងជាមាគ៌ានៃជីវិតរបស់ខ្លួន ហើយធ្វើជាមូលដ្ឋានស្ថាបនាជាតិឆ្ពោះទៅកាន់សន្តិភាព លើមាគ៌ាអហិង្សា សន្តោស យោគយល់ អធ្យាស្រ័យគ្នាទៅវិញទៅមក ។

៤. ចង្អុលប្រាប់ថា ពេលណា ព្រះពុទ្ធសាសនារីកចំរើន ឋិតថេរគង់វង្ស នៅក្នុងសង្គមខ្មែរ ពេលនោះ ប្រជាពលរដ្ឋខ្មែរក៏បានរីកចំរើន សុខសាន្ត សម្បូរ សប្បាយផងដែរ ។ ពេលណា ព្រះពុទ្ធសាសនាត្រូវវិនាសអន្តរាយ ពេលនោះ សង្គមជាតិយើង និងប្រជាពលរដ្ឋ ក៏ត្រូវវិនាសអន្តរាយ និរាសព្រាត់ប្រាស ដូចដែលយើងបានទទួលរងទុក្ខសោកកន្លងមកហើយ ។

៥. បង្ហាញថា យើងនឹងអាចរកផ្លូវសុខសាន្តមួយ ដើម្បីអភិវឌ្ឍប្រទេសជាតិរបស់យើងបាន លុះត្រាតែយើងទាំងអស់គ្នាស្រុះចិត្ត មូលគំនិតយកព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធជាវិធីអប់រំកាយ-ចិត្ត ដើម្បីជម្រុះចោលនូវគំនិតគុំគួនគ្នា ច្រណែនឈ្នានីស សងសឹក ព្យាបាទ ពាមមធ្យោបាយហិង្សា ។

ផ្អែកលើការសង្កេត និងសេចក្តីសន្និដ្ឋានខាងលើនេះ អង្គមហាសន្និបាតទាំងមូលបានសំរេចជាឯកច្ឆន្ទ បន្តអនុវត្តសង្ឃប្រកាសរួមរបស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ឆ្នាំ ១៩៩៩ រួមទាំងសេចក្តីសំរេចចិត្តថ្មី នាសម័យប្រជុំមហាសន្និបាតលើកទី ៩ នេះ សំដៅ :

១. ចៅអធិការវត្តនិមួយៗ ត្រូវខិតខំពង្រឹងគុណភាពខាងអភិបាលកិច្ចគ្រប់គ្រងវត្តឱ្យបានល្អ និងមានបែបបទរដ្ឋបាលត្រឹមត្រូវ ដោយមានបញ្ជីកត់ត្រា :

ក) លិខិតចេញ-ចូល ទាក់ទងនឹងផ្លូវពុទ្ធចក្រ និងអាណាចក្រ,

ខ) ចំនួនព្រះសង្ឃក្នុងវត្ត,

គ) ចំនួនគរុភ័ណ្ឌជាចលនវត្ថុ-អចលនវត្ថុ និងបេតិកភ័ណ្ឌវប្បធម៌របស់វត្ត,

ឃ) ចំណូល-ចំណាយរបស់វត្ត,

ង) ប្រើប្រាស់ដីធ្លីវត្ត អោយមានសណ្តាប់ធ្នាប់ទៅតាមប្លង់មេ,

ច) ធ្វើរបាយការណ៍ប្រចាំឆ្នាំប្រគេនព្រះគ្រូអនុគណ ព្រះមេគណ និងចម្លងជូនមន្ទីរធម្មការ ដើម្បីជ្រាប និងធ្វើសហការ ។

២. ចាត់តាំងក្រុមអធិការកិច្ចសង្ឃ ដើម្បីចុះពង្រឹងសមត្ថភាពជំនាញខាងធម៌-វិន័យ និងខាងអភិបាលកិច្ចរបស់មន្ត្រីសង្ឃជាសហការីមេគណ - អនុគណ និងចៅអធិការវត្ត ដើម្បីពង្រឹងការងារគ្រប់គ្រងវត្តអារាម ធ្វើអោយវត្តអារាមនីមួយៗក្លាយទៅជាមណ្ឌលអភិវឌ្ឍន៍សង្គម ប្រាសចាកអធិករណ៍ ក្រោមការដឹកនាំដ៏មានប្រសិទ្ធភាពរបស់លោកគ្រូចៅអធិការវត្ត, និជាជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន រួមចំណែកដ៏សកម្មក្នុងការអភិវឌ្ឍន៍សង្គម តាមរយៈការបង្កើតឱ្យមាន :

* កសាងសាលារៀន អប់រំវប្បធម៌ និងសីលធម៌សង្គម-បង្រៀនអក្សរដល់មនុស្សចាស់, កុមារដែលមាតាបិតាខ្វះការគ្រប់គ្រង ឬកុមារកំព្រា សំដៅរួមចំណែកលុបបំបាត់អនក្ខរភាពក្នុងសង្គមជាតិ ។
* កសាងបណ្ណាល័យវត្ត ប្រកបដោយសៀវភៅ និងឯកសារផ្លូវធម៌ និងផ្លូវលោកយ៉ាងសំបូរ ។
* កសាងទីអារាមទាំងមូលឱ្យក្លាយជាឧទ្យានប្រកបដោយរុក្ខជាតិមានប្រយោជន៍ ។
* សាងសង់សំណង់ថ្មីៗ ត្រូវរក្សាឱ្យបានតម្លៃសិល្បៈ វប្បធម៌ និងស្ថាបត្យកម្មខ្មែរ ។
* ចូលរួមកាន់តែសកម្មក្នុងការថែរក្សាបរិស្ថានវប្បធម៌-សង្គម-ធម្មជាតិ និងកិច្ចការអភិវឌ្ឍន៍សង្គមតាមរយៈធ្វើផ្លូវ ជីកស្រះ សង់សាលារៀន, ដាំកូនឈើ, បណ្ដុះពូជកូនឈើ - ល - ។
* ចូលរួមចំណែកក្នុងការងារបំរើសង្គម ដូចជា ស្មគ្រព្រះទ័យធ្វើគ្រូបង្រៀន, ជាអ្នកថែទាំកុមារ, មនុស្សចាស់ជរា, អ្នកជំងឺជាដើម ដែលគ្មានទីពឹង, ផ្ដល់ជម្រកស្នាក់អាស្រ័យដល់មនុស្សប្រភេទនោះ ក្នុងស្មារតីមនុស្សធម៌ពុទ្ធសាសនា ។

៣. ពង្រឹងគុណភាពពុទ្ធិកសិក្សា និងពង្រីកជាជំហានៗ តាមស្ថានភាព និងលទ្ធភាពជាក់ស្ដែង ដើម្បី អភិវឌ្ឍធនធានបព្វជិតពុទ្ធសាសនិក ដោយរៀបចំចងក្រងជាកម្រងវត្ត និងកម្រងសាលាពុទ្ធិកបឋមសិក្សានៅមូលដ្ឋាន ។ ជាមួយគ្នានេះ

យកចិត្តទុកដាក់បង្កើតអោយមានមណ្ឌលវិបស្សនាធុរៈ សំរាប់អប់រំកាយ-វាចា-ចិត្ត នៃមហាជន ។

៤. បញ្ហាបព្វជិតពុទ្ធសាសនិក និងការបោះឆ្នោត នៅក្នុងបរិបទសង្គមវប្បធម៌ខ្មែរ ត្រូវរក្សាទុកសិទ្ធិ និងករណីយកិច្ចប្រជាពលរដ្ឋ តាមលទ្ធិប្រជាធិតេយ្យ និងគោលការណ៍នីតិរដ្ឋ ។

៥. អង្គមហាសន្និបាត បានឯកភាពគោរពរាល់សេចក្តីសំរេចទាំងឡាយរបស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃនៃគណៈសង្ឃទាំងពីរ ដែលបានប្រកាន់យករួចមកហើយ លើមូលដ្ឋានយោគយល់ អធ្យាស្រ័យទៅវិញ ទៅមក ។

៦. ព្រះសង្ឃទាំងពីរគណៈ បានសំរេចព្រះទ័យជាឯកច្ឆ័ន្ទថា ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ គណៈសង្ឃទាំងពីរត្រូវតែបន្តពង្រឹងការឯកភាព សាមគ្គីភាពឱ្យកាន់តែជិតស្និទ្ធក្នុងស្មារតីភាតរភាព គោរព ស្រឡាញ់ដោយស្មោះ និងទៀងត្រង់ ឥតមានគំនិតបៀតបៀនយកប្រៀបលើគ្នាឡើយ ។

៧. អង្គមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំលើកទី ៩ នេះ បានធ្វើសំណូមពរដោយទទូចឱ្យមានការប្រជុំរួមជាប្រវត្តិសាស្ត្ររបស់មន្ត្រីសង្ឃពុទ្ធសាសនិកកម្ពុជាទាំងពីរគណៈដូចនេះ បានប្រព្រឹត្តទៅជាទៀងរាល់ឆ្នាំ អស់កាលជាអង្វែងតទៅ

៨. អង្គមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំលើកទី ៩ សូមថ្លែងអំណរព្រះគុណ និងភក្តីភាពយ៉ាងជ្រាលជ្រៅចំពោះព្រះករុណាជាម្ចាស់ជីវិត និងសម្តេចព្រះរាជអគ្គមហេសី ទ្រង់ជាអគ្គសាសនូបត្ថម្ភក៍ និងសូមថ្វាយព្រះពរមហាប្រសើរគ្រប់ប្រការ សូមទ្រង់ប្រកបដោយពុទ្ធពរទាំង ៥ ប្រការ អស់កាលនិរន្តរ៍ ។

***

# សេចក្តីជូនដំណឹង

" កម្ពុជសុរិយា " មានកិត្តិយស និងមានសេចក្តីរីករាយ សូមជម្រាប សាធារណជនថា « **ពុទ្ធិកសមាគម កម្ពុជរដ្ឋ** » ត្រូវបានរៀបចំបង្កើតឡើងវិញ និងចាប់ផ្តើមធ្វើសកម្មភាពបំរើឧត្តមគតិរបស់ខ្លួន ដើម្បីជាគុណប្រយោជន៍ដល់ការអភិវឌ្ឍន៍ពុទ្ធសាសនា និងសង្គមជាតិយើង ចាប់ពីត្រីមាសទី ៤ ឆ្នាំ ២០០០ នេះតទៅ ដោយមានទីស្នាក់ ការបណ្តោះអាសន្ន នៅក្នុងក្រសួងធម្មការ និងសាសនា ។

ក្នុងប្រវត្តិរបស់ខ្លួន, " ពុទ្ធិកសមាគមកម្ពុជរដ្ឋ " គឺជាសមាគមដំបូងគេមិនរកកម្រៃ, មិនបំរើនិន្នាការនយោបាយគណបក្ស, មិនរើសអើង ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៥២ ឋិតក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះមហាក្សត្រ ជាទីសក្ការៈ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបំរើឧត្តមប្រយោជន៍សង្គមជាតិ និងពុទ្ធសាសនា តាមរយៈការផ្តល់អាហារូបករណ៍ដល់សមណនិស្សិតបញ្ជូនអោយទៅបន្តការសិក្សានៅបរទេស និងតាមរយៈសកម្មភាពចូលរួមក្នុងប្រជាសង្គ្រោះ ក្នុងការផ្សព្វផ្សាយសាសនា វប្បធម៌ អក្សរសាស្ត្រ ព្រមទាំងថែរក្សា ការពារប្រពៃណី ទំនៀមទម្លាប់ល្អ របស់ជាតិយើង ។ មកដល់ថ្ងៃ ១៧ មេសា ១៩៧៥, សកម្មភាព និងអត្ថិភាពផ្ទាល់របស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ ត្រូវបានបញ្ចប់ រលាយរលត់ រហូតមកដល់ពេលនេះ ដោយសារសង្គ្រាមក្នុងប្រទេស !

ដោយនឹកស្តាយស្នាដៃ និងតម្លៃគតិបណ្ឌិតរបស់បុព្វបុរសយើងដែលបានបង្កើត " ពុទ្ធិកសមាគមកម្ពុជរដ្ឋ " ឡើងវិញ ដើម្បីបំរើឧត្តមប្រយោជន៍ជាតិ និងពុទ្ធសាសនា និងដោយមានបំណងស្តា និងពង្រីងឧត្តមគតិនេះឡើងវិញ ដើម្បីអភិវឌ្ឍន៍ព្រះពុទ្ធសាសនា និងសង្គមជាតិឱ្យរីកចំរើន ទើបមានព្រះសង្ឃ និងពុទ្ធសាសនិក

សាសនិកជនមួយក្រុមបានស្ម័គ្រព្រះទ័យ និងស្រុះស្រួលចិត្តផ្តើមរៀបចំលក្ខន្តិកៈសមាគមជាថ្មី ដើម្បីប្រើជាគោលមាគ៌ាដឹកនាំ " ពុទ្ធិកសមាគមកម្ពុជរដ្ឋ " ឡើងវិញ ។ ពុទ្ធិកសមាគមកម្ពុជរដ្ឋ នឹងចេញមុខបង្ហាញខ្លួនជាសាធារណៈ ចាប់ផ្តើមបំពេញបេសកកម្ម បំរើសាសនា និងសង្គមជាតិ តាមគន្លងរបស់បុព្វបុរសខ្លួន ពីពេលនេះតទៅ !

" កម្ពុជសុរិយា " មានអំណរសាទរណាស់ ចំពោះការកើតមានឡើងវិញនៃ " ពុទ្ធិកសមាគមកម្ពុជរដ្ឋ " ដែលជានិមិត្តសញ្ញាមួយដ៏ល្អ បើកផ្លូវទៅរកការភ្ជាប់ទំនាក់ទំនងជាមួយ « ពុទ្ធិកសមាគមពិភពលោក (The World Fellowship of Buddlhists) » ឡើងវិញ ។

ប្រជាពលរដ្ឋយើងជាច្រើននៅចាំបានថា ប្រទេសកម្ពុជាធ្លាប់ជាសមាជិកស្ថាបនិកមួយនៃពុទ្ធិកសមាគមពិភពលោក ដែលត្រូវបានបង្កើតឡើងនៅប្រទេសស្រីលង្កា តាំងពីឆ្នាំ ១៩៥០, ហើយធ្លាប់បានរៀបចំទទួលបើកសន្និសីទលើកទី ៦ នៃពុទ្ធិកសមាគមពិភពលោក នៅសាលចតុមុខ ទីក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៦២ ក្រោមព្រះបរមរាជូបត្ថម្ភ និងព្រះរាជាធិបតីភាពព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ។

តាមរយៈការកើតឡើងវិញនេះ " ពុទ្ធិកសមាគមកម្ពុជរដ្ឋ " នឹងមានលទ្ធភាពទទួលសមាជិកភាពក្នុងពុទ្ធិកសមាគមពិភពលោកឡើងវិញដោយស្រួល ហើយក៏ជាច្រកមួយដ៏ប្រពៃ អាចនាំសង្គមជាតិ និងពុទ្ធសាសនាកម្ពុជា ចូលរួមក្នុងសកម្មភាពពុទ្ធសាសនាសកលលោក ឬពុទ្ធសាសនាក្នុងឆាកអន្តរជាតិ !

អាស្រ័យហេតុនេះ " កម្ពុជសុរិយា " សូមផ្សព្វផ្សាយដំណឹងអំពីការកើតមានឡើងវិញ នៃ " ពុទ្ធិកសមាគមកម្ពុជរដ្ឋ " និងសូមអំពាវនាវដល់ប្រជាពលរដ្ឋ

កម្ពុជា ទាំងព្រះសង្ឃ ទាំងគ្រហស្ថ មេត្តាជួយឧបត្ថម្ភគាំទ្រ « ពុទ្ធិកសមាគមកម្ពុជរដ្ឋ » ដែលទើបចាប់កំណើតឡើងវិញនេះ ដោយសេចក្តីសប្បុរស សទ្ធាជ្រះថ្លា និងការស្ម័គ្រចិត្តរួមចំណែកក្នុងការអភិវឌ្ឍន៍ពុទ្ធសាសនា និងសង្គមជាតិ តាមរូបភាពដូចតទៅ :

- ចូលរួមជា *ជនកសមាជិក* : សមាជិកអ្នកបង្កើត ឬស្ថាបនា - បង់ភាគទានដំបូង ២០.០០០៛០០ ( ពីរម៉ឺនរៀល ) និងបង់ជាបន្តបន្ទាប់រៀងរាល់ខែ ក្នុងមួយខែ ១.០០០៛០០ ( មួយពាន់រៀល ) ។

- ចូលរួមជា *កម្មិកសមាជិក* : សមាជិកមានឆន្ទៈល្អ មានសន្តានចិត្តស្មគ្រជួយរួមចំណែកការងារសមាគម ទាំងកាយវាចាចិត្តគ្រប់កាលៈទេសៈ - បង់ភាគទាន ១.០០០៛០០ ( មួយពាន់រៀល ) ក្នុងមួយខែ ជារៀងរាល់ខែ ។

- ចូលរួមជា *ជាសាទិកសមាជិក* : សមាជិកដែលមានសេចក្តីជ្រះថ្លា មានការពេញចិត្តនឹងសកម្មភាពរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ ប៉ុន្តែ ពុំមានលទ្ធភាពជួយជាសកម្ម ទាំងកាយវាចាចិត្ត អាចបង់វិភាគទានតាមសទ្ធាជ្រះថ្លា ពុំមានកំណត់ពេលវេលា និងចំនួនថវិកា ឬទេយ្យវត្ថុឡើយ ។

កំណត់សំគាល់ :

សូមបញ្ជាក់ជូនថា : ការចូលរួមជា *ជនកសមាជិក ព.ស.ក.* ត្រូវផុតកំណត់នៅថ្ងៃមហាសន្និបាត ដែលនឹងប្រារព្ធធ្វើនៅក្នុងកំឡុងខែមករា ឆ្នាំ ២០០១ ។ ឯការចូលរួមជា *កម្មិកសមាជិក ព.ស.ក.* និង *ជាសាទិកសមាជិក ព.ស.ក.* នៅតែទទួលចូលជារៀងរហូត ពុំមានកំណត់ពេលវេលាឡើយ ។

កម្ពុជសុរិយា



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

នាយកការផ្សាយ : **ខួន ហ៊ាន់ចន្ទី**

និពន្ធនាយក : **ខៀវ បញ្ញាវុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង**, លោក **ម៉ែន ប្រាង**,

លោក **ខង់ សុផារ៉ា**, លោក **ផន់ ហ៊ុន**,

លោក **មៀច ប៉ុណ្ណ**, លោក **ពិ ប៊ុន្ទីន**

គណៈកម្មការពិគ្រោះ

យោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សារឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា
- លោក បណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោក បណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិត្យ-សភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ ។
- The publication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា

• ទុក្ខកើតព្រោះអញ ( ភិក្ខុ ងិន ភេន ឥន្ទបញ្ញោ ) ........ ១

## II. អក្សរសាស្ត្រទូទៅ និងអក្សរសិល្ប៍ខ្មែរ

• គុណកថា ( ព្រឹទ្ធាចារ្យ ឆេង ផុន ) ........ ១៦
• សាកលភាវូបនិយកម្ម និងដំណើរវប្បធម៌ខ្មែរ ( បណ្ឌិត ឆយ យីហ៊ាង ) ........ ១៨
• ស្មារតីខ្មែរ និងព្រះពុទ្ធសាសនា ( ត ) ( អ្នកស្រីបណ្ឌិត ខ្លូត ធីតា ) ........ ៣៧
• សិលាចារិក ( វង់ សុធារ៉ា ) ........ ៤៧
• ព្រះវិស្ណុ ( ធន់ ហ៊ិន ) ........ ៦០
• រឿងសសបណ្ឌិត និងពួកចាំសីល ( ឱម ខែម ) ........ ៦៦
• នាយកធម៌ ៦ យ៉ាង ( ភិក្ខុ សាយ សុខ ហេង ) ........ ៧១
• ពោះបាយបិណ្ឌ ( មៀច ប៉ុណ្ណ ) ........ ៧៤
• កួច និងជីវិតរស់នៅរបស់ប្រជាជនខ្មែរ ( ចិន ទិរិទ្ធិ និង នួន សោភ័ណ ) ........ ៧៦
• អំពីជនជាតិកួយ ( មៀច ប៉ុណ្ណ ) ........ ៨៦

## III. កំណត់ និង ប្រវត្តិការណ៍

• សេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ ក្រសួងធម្មការ
និងសាសនា , ........ ៩៤
• សេចក្តីសម្រេចស្តីពីការតែងតាំងនិពន្ធនាយកទស្សនាវដ្តីកម្ពុជសុរិយា ........ ៩៧

## IV. ទំព័រមិត្តអ្នកអាន :

• មិត្តអ្នកអានជាទីមេត្រី ........................................ ៩៩

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

# ទុក្ខក្នុងព្រះអភិធម្ម

ដោយភិក្ខុ ខិន ភេន ឥន្ទប្បញ្ញោ
វត្តពោធិវង្ស ប្រទេសបារាំង

### ទុក្ខគឺជាអ្វី ?

ការធន់នៅដដែលមិនបាន នៃសង្ខារធម៌ទាំងឡាយទាំងពួង គឺវាត្រូវតែប្រែប្រួល ផ្លាស់ប្តូរសភាពទៅតាមហេតុបច្ច័យហៅថា ទុក្ខ ។ ម្យ៉ាងទៀតសេចក្តីលំបាកក្នុងកាយ ឬសេចក្តីលំបាកក្នុងចិត្តហៅថា ទុក្ខ ។

## ទុក្ខមាន ៣ យ៉ាង

### ១ . ទុក្ខក្នុងព្រះត្រៃលក្ខណ៍

ទុក្ខក្នុងព្រះត្រៃលក្ខណ៍ សំដៅយកការធន់នៅដដែលមិនបាន នៃសង្ខារទាំងឡាយទាំងពួង ទោះជាឧបាទិន្នកសង្ខារ គឺសង្ខារមានចិត្តដូចជា ផ្ទះ រទេះ រថយន្តជាដើមក្តី ឬជាដំបូក ភ្នំ បឹង ស្ទឹង ជាដើមក្តី ។ សង្ខារគឺអ្វីដែលបច្ច័យប្រជុំគ្នាកើតឡើងវត្ថុរួមផ្សំគ្នាក្តី ធម៌រួមផ្សំគ្នាក្តី ហៅថា សង្ខារបានទាំងអស់ ។ សង្ខារគ្រប់ប្រភេទទាំងអស់ ទោះបីមានចិត្តអាស្រ័យនៅក្តី មិនមានចិត្តអាស្រ័យនៅក្តី តែងតែប្រែប្រួលសភាពរបស់ខ្លួនម្តងបន្តិចៗ តាមហេតុបច្ច័យគ្រប់ពេលវេលាជាដរាប ឥតមានសង្ខារណា សូម្បីតែមួយអាចស្ថិតស្ថេរ គង់ធន់នៅដដែលបានឡើយ ។ ការគង់ធន់នៅដដែលមិនបាន នៃសង្ខារធម៌ទាំងឡាយទាំងពួងនេះហើយ ( មិនចាំបាច់

ចេះឈឺ ចេះយំស្រែកទេ ) លោកហៅថា ទុក្ខ គឺទុក្ខក្នុងព្រះត្រៃលក្ខណ៍ ។ ទុក្ខនេះ ស៊ីសេចក្ដីធំទូលំទូលាយជាងគេ គឺមានគ្រប់សង្ខារទាំងអស់ ( សាមញ្ញលក្ខណៈ ) ទាំងមានវិញ្ញាណ ( ចិត្ត ) ទាំងឥតវិញ្ញាណ ។

## ២. ទុក្ខក្នុងអរិយសច្ច

ទុក្ខក្នុងអរិយសច្ច សំដៅយកទុក្ខ ១២ កង គឺ ១. ជាតិទុក្ខ ការកើត ជាទុក្ខ ២. ជរាទុក្ខ ការចាស់គ្រាំគ្រាជាទុក្ខ ៣. មរណទុក្ខ សេចក្ដីស្លាប់ ជាទុក្ខ ៤. សោកទុក្ខ សេចក្ដីក្រៀមក្រំជាទុក្ខ ៥. បរិទេវទុក្ខ សេចក្ដីខ្សឹកខ្សួល ជាទុក្ខ ៦. ទុក្ខទុក្ខ សេចក្ដីលំបាកកាយជាទុក្ខ ៧. ទោមនស្សទុក្ខ ការអាក់អន់ចិត្ត ជាទុក្ខ ៨. ឧបាយាទុក្ខ ការតានតឹងចិត្ត ជាទុក្ខ ៩. អប្បិយេហិ សម្បយោគទុក្ខ ការជួបប្រសព្វដោយសត្វ និងសង្ខារ មិនជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ ១០. បិយេហិ វិប្បយោគទុក្ខ ការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ ១១. យម្បិច្ឆំ ន លភតិ តម្បិទុក្ខ ប្រាថ្នារបស់ណាមិនបាន នោះក៏ជាទុក្ខ ១២. សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធទុក្ខ ពោលដោយបំព្រួញ ឧបាទានក្ខន្ធទាំងប្រាំ ជាទុក្ខ ។ ទុក្ខក្នុងអរិយច្ចនេះ សំដៅយកទុក្ខរបស់ឧបាទិន្នកសង្ខារ គឺសង្ខារដែលមានចិត្ត មានវិញ្ញាណតែប៉ុណ្ណោះ មិនទូទៅដល់អនុបាទិន្នកសង្ខារផងទេ ប៉ុន្តែ វាមានសេចក្ដីទូលាយដល់ទុក្ខកាយ ទុក្ខចិត្ត ទុក្ខរូប ទុក្ខនាមផងដែរ ។ ទុក្ខនេះ ស៊ីសេចក្ដីបានខ្នាតកណ្ដាល ។

## ៣. ទុក្ខវេទនា

ទុក្ខវេទនា សំដៅយកចិត្តសោយអារម្មណ៍មិនសប្បាយក្នុងពេលដែលអាយតនៈខាងក្រៅគឺរូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មៈ ហើយកើតវិញ្ញាណ ។ កាលបើធម៌ ៣ គឺអាយតនៈខាងក្នុងអាយតនៈខាងក្រៅ និងវិញ្ញ ាណរួមគ្នាកើតបានជាផស្សៈ ទើបជាបច្ច័យឱ្យកើតវេទនា គឺសុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ។ ទុក្ខវេទនា សំដៅយកតែទុក្ខវេទនាមួយប៉ុណ្ណោះ មិនទូទៅដល់សុខវេទនា ឬ អទុក្ខម-

សុខវេទនាផងទេ ។ ទុក្ខវេទនានេះ ស៊ីសេចក្តីបានតូចជាងគេទាំងអស់ ។

## រូបភាពនៃទុក្ខ




ទុក្ខទាំង ៣ យ៉ាងនេះ វាជាប់ប្រទាក់ប្រទងគ្នា ពិបាកនឹងវែកញែកឱ្យដាច់ពីគ្នាណាស់ យើងត្រូវតែសិក្សាឱ្យបានដឹងច្បាស់ ។ ប៉ុន្តែ បើពួកគេសួរថាទុក្ខកើតព្រោះអញ សំដៅយកទុក្ខណា ? យើងត្រូវឆ្លើយថា សំដៅយកទុក្ខក្នុងអរិយសច្ច ព្រោះជាទុក្ខរបស់សង្ខារ ដែលមានចិត្តមានវិញ្ញាណ មានសេចក្តីសំគាល់ថា អញ ថារបស់អញ ។

## អញគឺអ្វី ?

តាមវចនានុក្រមខ្មែរ មានសេចក្តីពន្យល់ដូចតទៅនេះ : អញ ( អាញ់ ) បុ.ស. ខ្ញុំ ( ជាអញ្ញត្រសព្ទ ) ។ ពាក្យសម្រាប់ហៅខ្លួនឯង ជាសម្តីកូនក្មេង និយាយទៅរកកូនក្មេងផងគ្នា ឬមនុស្សចាស់និយាយទៅរកកូនក្មេង និយាយទៅរកមនុស្សស្មើភាពដែលស្និទ្ធស្នាល ឬក៏អ្នកធំនិយាយទៅរកអ្នកតូច ដោយស្និទ្ធស្នាល ឯងទៅចុះ អញមិនទៅទេ ! ... ។

អញគឺអ្វី ? ហេតុអ្វីក៏មិនសរសេរ « អាញ់ » ហើយបែរទៅជាសរសេរ « អញ » ដូចនេះទៅវិញ ពិបាករកហេតុផលណាស់ ។ សម្តេចព្រះសង្ឃរាជ

ជូន ណាត ព្រះបិតាវចនានុក្រមខ្មែរ ព្រះអង្គមិនបានអធិប្បាយទុកទេ ។ ខ្ញុំសន្និដ្ឋានថា អញ ប្រហែលជាក្លាយមកពីភាសាបាលិ « អញ្ញ » ប្រែថា ដទៃ ... ។ មនុស្សខ្លះយល់ឃើញថា មនុស្សយើងមិនមែនមានត្រឹមតែរូបកាយប៉ុណ្ណឹងទេ មានស្អីដទៃទៀតអាស្រ័យ នៅក្នុងរូបកាយនេះផងដែរ ។ ស្អីដទៃ ដែលអាស្រ័យនៅក្នុងរូបកាយនោះ គេហៅថា អាត្មន អត្តា អញ ឬព្រលឹង ។ អ្នកខ្លះយល់ឃើញវែងឆ្ងាយហួសពីដំណឹងទៀតថា អាត្មន អត្តា អញ ឬព្រលឹងឈឹង ព្រះជាម្ចាស់ស្ថានលើលោកប្រទានឱ្យមកវាជាសភាវៈទៀងទាត់ស្ថិតស្ថេរ មិនចេះស្លាប់រលត់រលាយបាត់បង់ទៅណាទេ បើរូបកាយថ្មីទៀត ចេះតែផ្លាស់ប្ដូររឿយៗ ទៅ ពេលណាវាស្អាតម៉ត់ចត់អស់កិលេស ហើយវានឹងចូលទៅអាស្រ័យ នៅរួមជាមួយនឹងបរមាត្មនឬព្រះព្រហ្មវិញ ។ គំនិតនេះហើយដែលនាំឱ្យកើតទិដ្ឋិ ( មិច្ឆាទិដ្ឋិ ) មានះ តណ្ហា ឬនិយាយថា តណ្ហាមានះទិដ្ឋិដូចនេះក៏មាន ។

ព្រះពុទ្ធសម្ដែងថា នៅក្នុងមនុស្សទាំងមូលមិនមាន អាត្មន អត្តា អញ ព្រលឹង ឬអ្វីៗទេ មានតែខន្ធប្រាំ ( រូប+នាម ) តែប៉ុណ្ណោះ ។ មនុស្ស ជាសង្ខារធម៌ជាខន្ធបញ្ចកៈ រួមប្រជុំនៃខន្ធប្រាំគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ រូប គឺធាតុមិនដឹង បានដល់ ដី ទឹក ភ្លើង ខ្យល់ខាងក្នុង វេទនា ធាតុដឹងសោយអារម្មណ៍ សុខ ទុក្ខ មិនទុក្ខមិនសុខ, សញ្ញា ធាតុដឹងកត់ចំណាំ រូប សម្លេង ។ល។ តូច ធំ ខ្មៅ ស វែង ខ្លី ជាដើម សង្ខារ ធាតុដឹងគិតគូរធ្វើល្អ អាក្រក់ វិញ្ញាណ ធាតុដឹងគឺឃើញ ឮ ជាដើម[១] ។ ខន្ធប្រាំបំប្រួញឱ្យខ្លីមាន ២ គឺ រូប និង នាម ។ រូប ចាត់ជា រូប, វេទនា សញ្ញា សង្ខារ វិញ្ញាណ ចាត់ជានាម ។ រូបកើតរលត់ដោយហេតុបច្ច័យ មានក្ដៅត្រជាក់ ជាដើម នាមកើតរលត់ដោយហេតុបច្ច័យដែរ តែមិនពឹងផ្អែកទៅ លើក្ដៅ

(១) ក្នុងពុទ្ធសាសនា ធាតុមានច្រើនយោគរ នានាធាតុ អនេកធាតុ សូម្បីជានាមធម៌ក៏រាប់ថាធាតុ កិលេស ក៏រាប់ថាធាតុ និព្វាន ក៏រាប់ថាធាតុដែរ ។

ត្រជាក់ជាដើមដូចរូបទេ ។ រូបនាម ឬខន្ធប្រាំ មិនមាននរណាជាអ្នកបង្កើតទេមិនមាននរណាជាម្ចាស់លើវាទេ វាកើតដោយអាស្រ័យហេតុបច្ច័យរបស់វា វាប្រែប្រួលនិងរលត់ទៅតាមហេតុបច្ច័យរបស់វាទាំងអស់ វាអត់ខ្លាច អត់ស្តាប់បង្គាប់បុគ្គលណាទេ វាប្រព្រឹត្តទៅតាមហេតុបច្ច័យតែប៉ុណ្ណោះ ។ អញ តាមសេចក្តីពិត វាគ្មានទេប៉ុន្តែ បើនិយាយ ជាបុគ្គលាធិដ្ឋាន អញ គឺខន្ធប្រាំ បើនិយាយជា ធម្មាធិដ្ឋាន អញគឺកិលេស វាគ្មានស្អីទៀតឯណានោះទេ ។ ប៉ុន្តែ មនុស្សល្ងង់ប្រកាន់ជឿស្មាន ៗ ថាក្នុងរូបមានអត្តា មានអញ ឬក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ មានអត្តា មានអញ ឬ យ៉ាងហោចណាស់ក៏ត្រូវមាន អត្តា នៅ ក្នុងខន្ធណាមួយដែរ ។ ជំនឿបែបនេះជាជំនឿមិនត្រឹមត្រូវ ចាត់ជា សក្កាយទិដ្ឋិ ។

## សក្កាយទិដ្ឋិ ២០

១. រូបំ អត្តតោ សមនុបស្សតិ យល់ឃើញរូបថាជាខ្លួន ( អត្តា ) ។
២. រូបវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានរូប ។
៣. អត្តនិ រូបំ សមនុបស្សតិ យល់ឃើញរូបក្នុងខ្លួន ។
៤. រូបស្មឹ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងរូប ។
៥. វេទនំ អត្តតោ សមនុបស្សតិ យល់ឃើញវេទនាថាជាខ្លួន ។
៦. វេទនាវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានវេទនា ។
៧. អត្តនិ វេទនំ សមនុបស្សតិ យល់ឃើញវេទនាក្នុងខ្លួន ។
៨. វេទនាយ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងវេទនា ។
៩. សញ្ញំ អត្តតោ សមនុបស្សតិ យល់ឃើញសញ្ញាថាជាខ្លួន ។
១០. សញ្ញាវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានសញ្ញា ។
១១. អត្តនិ សញ្ញំ សមនុបស្សតិ យល់ឃើញសញ្ញាក្នុងខ្លួន ។
១២. សញ្ញាយ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងសញ្ញា ។

១៣. សង្ខារេ អត្តតោ សមនុបស្សតិ យល់ឃើញសង្ខារថាជាខ្លួន ។

១៤. សង្ខារវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានសង្ខារ ។

១៥. អត្តនិ សង្ខារេ សមនុបស្សតិ យល់ឃើញសង្ខារក្នុងខ្លួន ។

១៦. សង្ខារេសុ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងសង្ខារ

១៧. វិញ្ញាណំ អត្តតោ សមនុបស្សតិ យល់ឃើញវិញ្ញាណថាជាខ្លួន ។

១៨. វិញ្ញាណវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានវិញ្ញាណ ។

១៩. អត្តនិ វិញ្ញាណំ សមនុបស្សតិ យល់ឃើញវិញ្ញាណក្នុងខ្លួន ។

២០. វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងវិញ្ញាណ[(២)] ។

កាលបើមានទិដ្ឋិដូចនេះហើយ មានៈសេចក្តីប្រកាន់ខ្លួន អតិមានៈការមើលងាយគេ នឹងកើតឡើងបន្តទៀត ។ មានៈ នេះ ខ្មែរយើងនិយមប្រើជា មានះ ។

## មានៈ សេចក្តីប្រកាន់ខ្លួន ៩ យ៉ាង

១. សេយ្យស្ស សេយ្យោហមស្មីតិ មានោ បុគ្គលអ្នកប្រសើរ មានសេចក្តីប្រកាន់ថា អញជាបុគ្គលប្រសើរជាងគេ ។

២. សេយ្យស្ស សទិសោហមស្មីតិ មានោ បុគ្គលអ្នកប្រសើរ មានសេចក្តីប្រកាន់ថា អញជាបុគ្គលស្មើនឹងគេ ។

៣. សេយ្យស្ស ហីនោហមស្មីតិ មានោ បុគ្គលអ្នកប្រសើរ មានសេចក្តីប្រកាន់ថា អញជាបុគ្គលថោកទាបជាងគេ ។

៤. សទិសស្ស សេយ្យោហមស្មីតិ មានោ បុគ្គលអ្នកស្មើមានសេចក្តី

(២) សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ ចូឡវេទល្លសូត្រ ៣២/១៤៧/២៩១ សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ទិដ្ឋិកថា ៧០/២០/៣៣

ប្រកាន់ថា អញជាបុគ្គលប្រសើរជាងគេ ។

៥. សទិសស្ស សទិសោហមស្មីតិ មានោ បុគ្គលអ្នកស្មើមានសេចក្ដីប្រកាន់ថា អញជាបុគ្គលស្មើនឹងគេ ។

៦. សទិសស្ស ហីនោហមស្មីតិ មានោ បុគ្គលអ្នកស្មើមានសេចក្ដីប្រកាន់ថា អញជាបុគ្គលថោកទាបជាងគេ ។

៧. ហីនស្ស សេយ្យោហមស្មីតិ មានោ បុគ្គលអ្នកថោកទាបមានសេចក្ដីប្រកាន់ថា អញជាបុគ្គលប្រសើរជាងគេ ។

៨. ហីនស្ស សទិសោហមស្មីតិ មានោ បុគ្គលអ្នកថោកទាបមានសេចក្ដីប្រកាន់ថា អញជាបុគ្គលស្មើនឹងគេ ។

៩. ហីនស្ស ហីនោហមស្មីតិ មានោ មានសេចក្ដីប្រកាន់ថា អញជាបុគ្គលថោកទាបជាងគេ[៣] ។

មានៈនេះ បើប្រកាន់ថាខ្លួនប្រសើរជាងគេ រមែងមើលងាយគេ មិនចង់ទាក់ទងជាមួយគេទេ ព្រោះគេថោកទាបជាងខ្លួន ។ បើប្រកាន់ថា ស្មើៗ គ្នា មិនបាច់ទាក់ទងគេទេ នាំឱ្យខាតពេលវេលា ព្រោះវាស្មើៗតែគ្នា ។ បើប្រកាន់ថាថោកទាបជាងគេ មិនបាច់ទាក់ទងជាមួយគេទេ យើងថោកទាប ថោកទាបតែយើងទៅ កុំទៅរវល់នឹងគេ មានៈសុទ្ធតែជាកិលេសនាំឱ្យបាក់បែក នាំឱ្យកើតទុក្ខទាំងអស់។

បើមានទិដ្ឋិសេចក្ដីយល់ឃើញដូចនេះ បើមានមានៈ សេចក្ដីប្រកាន់ខ្លួនដូចនេះ សេចក្ដីសម្គាល់ថារបស់អញ និងសេចក្ដីចង់បាន ដើម្បីអញ ក៏កើតឡើងរឿយៗ នេះ គឺតណ្ហា ។

(៣) ត្រៃបិដក ខុទ្ទកនិកាយ មហានិទ្ទេស តុវដ្ដកសូត្រ ៦៤/១០៣/១៤៩

## តណ្ហា ៣ យ៉ាង

១. កាមតណ្ហា ចំណង់ក្នុងកាម ចង់សប្បាយនឹង រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ។

២. ភវតណ្ហា ចំណង់ក្នុងភព ចង់កើត ចង់បាន បើបានហើយ ចង់ឱ្យនៅស្ថិតស្ថេរ ។

៣. វិភវតណ្ហា ចំណង់ក្នុងវិភព ចង់មិនបាន ចង់មិនជួប ចង់ឱ្យផុតពីអ្វីដែលជួបហើយ(៤) ។

## តណ្ហា ៦ យ៉ាង

១. រូបតណ្ហា ចំណង់ក្នុងរូប ។

២. សទ្ទតណ្ហា ចំណង់ក្នុងសម្លេង ។

៣. គន្ធតណ្ហា ចំណង់ក្នុងក្លិន

៤. រសតណ្ហា ចំណង់ក្នុងរស ។

៥. ផោដ្ឋព្វតណ្ហា ចំណង់ក្នុងផោដ្ឋព្វៈ

៦. ធម្មតណ្ហា ចំណង់ក្នុងធម្មៈ(៥) ។

## តណ្ហា ១០៨ យ៉ាង

តណ្ហាវិចរិតខាងក្នុង ១៨ បូកនឹងតណ្ហាវិចរិតខាងក្រៅ ១៨ ត្រូវជា ៣៦ ជាអតីតៈ ៣៦, ជាបច្ចុប្បន្ន ៣៦, ជាអនាគត ៣៦ បូករួម ត្រូវជា តណ្ហា ១០៨ យ៉ាង(៦) ។

---

(៤) វិនយបិដក មហាវគ្គ ៦/១៤/៣១ សុត្តន្តបិដក ទីឃនិកាយ ១៧/១៣៤/២៨៧ សុត្តន្តបិដក អង្គុត្តរនិកាយ ឆក្កនិបាត ៤៦/១០៦/៣២៥

(៥) សុត្តន្តបិដក ទីឃនិកាយ មហាសតិប្បដ្ឋានសូត្រ ១៧/១៣៥/២៩០ សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ ៣១/១០/៦

(៦) សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤៣/៤៩/១៧៩

ម្យ៉ាងទៀត អាយតនៈខាងក្នុង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ មនៈ ( ចិត្ត ) គុណនឹង តណ្ហា ៣ គឺ កាមតណ្ហា ភវតណ្ហា វិភវតណ្ហាត្រូវជា ១៨ ។ អាយតនៈខាងក្រៅ ៦ គឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មៈ គុណនឹងតណ្ហា ៣ គឺ កាមតណ្ហាភវតណ្ហា វិភវតណ្ហា ត្រូវជា ១៨ ។ ១៨+១៨=៣៦ តណ្ហា ។ ជាអតីតៈ ៣៦ ជាបច្ចុប្បន្ន ៣៦ ជាអនាគត ៣៦ បូករួមត្រូវជា តណ្ហា ១០៨ យ៉ាង ។ នេះ មតិរបស់លោកអ្នកប្រាជ្ញជំនាន់ក្រោយ ។

## អវិជ្ជា និង តណ្ហា

ធម៌ទាំង ២ នេះ កើតឡើងអាស្រ័យគ្នានឹងគ្នា លោកចាត់ជាមូល គឺជាឫគល់នៃសំសារវដ្ត ។ តណ្ហាកើតមកពីអវិជ្ជា អវិជ្ជាកើតមកពីតណ្ហា គឺព្រោះតែមានអវិជ្ជា សេចក្តីមិនដឹងច្បាស់ ងងឹតងងល់ជាឫសគល់ បានជានាំឱ្យកើតតណ្ហា ចំណង់ខ្លាំងក្លាឡើងហើយក៏ព្រោះតែ មានតណ្ហាចំណង់ខ្លាំង បានជាបិទបាំងជិតងងឹត មិនដឹងច្បាស់ គឺអវិជ្ជាកើតឡើង ។ អវិជ្ជា ជាអតីតមូល តណ្ហាជាបច្ចុប្បន្នមូល បើរលាយមូលទាំង ២ នេះ បាន សំសារវដ្ត ឈប់វិល រឿងត្រូវចប់ចូលនិព្វាន ។

## អវិជ្ជា សេចក្តីមិនដឹងច្បាស់

ភិក្ខុ ១ រូប ទូលសួរព្រះសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចំរើន អវិជ្ជា អវិជ្ជា នោះតើដូចម្តេច ? បុគ្គលប្រកបដោយអវិជ្ជា តើដោយហេតុយ៉ាងណា ?

ព្រះពុទ្ធត្រាស់ថា អវិជ្ជា គឺសេចក្តីមិនដឹងច្បាស់ បុគ្គលប្រកបដោយអវិជ្ជា គឺអ្នកមិនដឹងច្បាស់នូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនដឹងច្បាស់នូវហេតុនាំឱ្យកើត រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនដឹងច្បាស់នូវសេចក្តីរលត់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនដឹងច្បាស់នូវបដិបទាជា ដំណើរទៅកាន់ សេចក្តីរលត់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ម្នាលភិក្ខុ នេះ ហៅថា អវិជ្ជាបុគ្គលប្រកបដោយ

អវិជ្ជា ដោយហេតុយ៉ាងនេះ[៧] ។

## អញ្ញ នាំឱ្យកើតទុក្ខដូចម្តេច ?

១. បុគ្គលខ្លះ យល់ឃើញថា ខន្ធប្រាំគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអត្តា ជាអញ្ញ ឬយល់ឃើញថា ក្នុងខន្ធប្រាំ មានអត្តា មានអញ្ញ ។ យើងគប្បី សង្កេតពិនិត្យ ពិចារណាមើលឱ្យច្បាស់ តើសេចក្តីពិតរបស់ខន្ធប្រាំវាយ៉ាងម៉េច តើបុគ្គលអ្នកប្រកាន់ជឿថា មានអត្តា មានអញ្ញ មានបានប្រយោជន៍អ្វី ឬខូច ប្រយោជន៍អ្វីដែរ ព្រោះយល់ឃើញដូចនោះ ។

ក្នុងអនត្តលក្ខណសូត្រ ព្រះពុទ្ធសម្តែងថា រូបំ ភិក្ខវេ អនត្តា ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា ( គ្មានអត្តា គ្មានអញ្ញទេ ) ។ បើរូបជាអត្តា ជាអញ្ញ រូបមិនគប្បី មានចាស់ ឈឺ ស្លាប់ទេ បុគ្គលគប្បីមានអំណាចបង្គាប់បញ្ជារូប ឱ្យទៅជាយ៉ាង នេះ យ៉ាងនោះ បានតាមបំណងរបស់ខ្លួន ប៉ុន្តែ ព្រោះរូបជាអនត្តា គ្មានអញ្ញ បាន ជារូប ចេះតែប្រែប្រួលចាស់ ឈឺ ស្លាប់ តាមច្បាប់វាជាដរាបរៀង១ ទៅជា ធម្មតា ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏ជាអនត្តា គ្មានអត្តា គ្មានអញ្ញ តែងតែ ប្រព្រឹត្តទៅ តាមន័យដូចគ្នានឹងរូបនោះដែរ[៨] ។

សេចក្តីពិត រឿងខន្ធប្រាំនេះ វាគ្មានអត្តា គ្មានអញ្ញ ដូចជាព្រះពុទ្ធទ្រង់ សម្តែងទុកដូចនោះមែន ។ វាតែងតែប្រែប្រួល ចាស់ ឈឺ ស្លាប់ ជាធម្មតា គ្មាន បុគ្គលណាជាម្ចាស់លើវាបានទេ ។ កាលបើវាប្រព្រឹត្តទៅខុសបំណងរបស់មនុស្ស យ៉ាងនេះ បុគ្គលអ្នកប្រកាន់ជឿថា ខន្ធប្រាំមាន អត្តា មានអញ្ញ តែងតែកើតទុក្ខ សោកស្តាយកន្ទក់កន្តេញ ព្រោះតែជំនឿខុសរបស់ខ្លួននោះ ។ នេះហៅថា ទុក្ខកើត ព្រោះអញ្ញ ។

---

(៧) សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ ៣៩/២៧/៣១

(៨) វិនយបិដក មហាវគ្គ ៦/២០/៤០

២. បុគ្គអ្នកមានទិដ្ឋិយល់ឃើញថា មានអត្តា មានអញ តែងតែមាន មានះសេចក្តីប្រកាន់ខ្លួនមានប្រការផ្សេងៗ ។ អ្នកខ្លះប្រកាន់ជាតិ អ្នកខ្លះប្រកាន់គោត្រពូជពង្សវង្សត្រកូល អ្នកខ្លះប្រកាន់យសសក្តិ អ្នកខ្លះប្រកាន់ចំណេះវិជ្ជា អ្នកខ្លះប្រកាន់ទ្រព្យសម្បត្តិ ជាដើម ហើយប្រមាថមើលងាយអ្នកដទៃ ។ ឧទាហរណ៍ អញពូជឯកឧត្តម ... អ្អែង ពូជអ្នកស្រែ អាសម្រែ ... ។ គេមិនប្រកាន់តែមនុស្សប្រកាន់រហូតដល់ខ្មោច បើកូនអ្នកស្រែមានយសសក្តិ គេយកធ្វើប្តីបាន ប៉ុន្តែ បើឪពុកក្មេកគេស្លាប់គេមិនឱ្យយកអដ្ឋិធាតុ មកដាក់ក្នុងចេតិយរួមជាមួយនឹងអដ្ឋិធាតុឪពុកបង្កើតរបស់គេទេ គេថា ឯងពូជទាប ... នេះជារឿងដែលមានពិត ។ អញជានាម៉ឺនជាន់ចាស់ ឯងជាន់ក្រោយ ... អញមានសញ្ញាប័ត្រធំ ឯងអត់សញ្ញាប័ត្រ ... មិនប្រកាន់តែពួកគ្រហស្ថទេ ព្រះសង្ឃអង្គខ្លះ ក៏ប្រកាន់សម្បើមណាស់ដែរ គួរឱ្យឆ្អើម ... ។

ក្នុងបរាភាវសូត្រ ព្រះពុទ្ធសម្តែងថា

*ជាតិត្ថទ្ធោ ធនត្ថទ្ធោ          គោត្តត្ថទ្ធោ ច យោ នរោ*
*សញ្ញាតី អតិមញ្ញេតិ          តំ បរាភវតោ មុខំ ។*

អ្នកដែលអាងជាតិ អាងទ្រព្យស្តុកស្តម្ភ អាងគោត្រឧត្តមខ្លាំងហួសប្រមាណ ប្រមាថមើលងាយពួកញាតិសន្តាន នោះជាប្រធាននៃក្តីវិនាស[៥] ។

ក្នុងគម្ពីរធម្មបទដ្ឋកថា មានរឿងមួយគួរឱ្យពិចារណា ព្រះចៅបសេនទិកោសល នៃក្រុងសាវត្ថី ដោយមានបំណងឱ្យមានសេចក្តីស្និទ្ធស្នាលជាមួយនឹងព្រះពុទ្ធ បានបញ្ជូនទូតទៅទាក់ទង ស្នើសុំសក្យធីតា នៃក្រុងកបិលពស្តុ ១ ព្រះអង្គមកអភិសេកជាមួយអគ្គមហេសី ។

ស្តេចសក្យបានប្រជុំពិភាក្សាគ្នាថា ស្តេចបសេនទិកោសល មានឋានៈមិន

ស្មើនឹងស្តេចសក្យទេ បើយើងថ្វាយសក្យធិតាថ្លៃថ្លាទៅ វាមិនសមសក្តិគ្នាទេ ដូចនេះ ទើបសម្រេចថ្វាយធិតានៃសក្យមហានាម ឈ្មោះវាសភខត្តិយា ជាកូនកើតជាមួយទាសី ។

ព្រះចៅ បសេនទិកោសល សប្បាយព្រះទ័យដោយមិនបានជ្រាបសេចក្តីពិតនេះ ក៏រៀបអភិសេក វាសភខត្តិយា ជាអគ្គមហេសី ធំលើសអស់ស្រីទាំង ៥០០ នាក់ ។ ពេលក្រោយមក មិនយូរប៉ុន្មាន ព្រះនាងវាសភខត្តិយា បានប្រសូត្រព្រះរាជបុត្រាមួយព្រះអង្គ ថ្វាយព្រះនាមថា វិឌូឌភៈ ។ លុះមានព្រះជន្មបាន ៧ ព្រះវស្សា ព្រះរាជកុមារវិឌូឌភៈ ទូលសួរព្រះមាតាថា ព្រះមាតាមិនមានព្រះអយ្យកោ ព្រះអយ្យិកា ព្រះញាតិវង្សាទេឬអ្វី បានជាមិនឃើញមាននរណាផ្ញើបណ្ណាការជារបស់លេងមកឱ្យទូលបង្គំដូចព្រះរាជកុមារឯទៀតៗ សោះ ។ ព្រះមាតាឆ្លើយប្រាប់ថា ព្រះអយ្យកោ ព្រះអយ្យិកា និងព្រះញាតិវង្សាមានច្រើនណាស់ ប៉ុន្តែលោកនៅឆ្ងាយពេក បានជាមិនផ្ញើអ្វីមកថ្វាយ ។ លុះព្រះជន្មបាន ១៦ ព្រះវស្សា ព្រះអង្គម្ចាស់ វិឌូឌភៈ បានទូលស្នើសុំព្រះមាតា ដើម្បីស្តេចទៅក្រសាល ត្រកូលព្រះរាជវង្សាខាងព្រះមាតា ។ ព្រះមាតា ក៏ចេះតែឆ្លើយបណ្តោះបណ្តែដោយប្រការផ្សេងៗ ។ តមក ដោយយល់ឃើញថា មិនអាចនឹងទប់ទល់តទៅទៀតបាន ទើបព្រះមាតាយល់ព្រមអនុញ្ញាត តាមសេចក្តីស្នើសុំ ហើយក៏ចាត់ចែងផ្ញើលិខិតថ្វាយព្រះអយ្យកោ អយ្យិកា ដើម្បីទ្រង់ជ្រាបជាពតិមានជាមុន ។

ពួកស្តេចសក្យ កាលបើបានឮដំណឹងដូចនោះ បានពិគ្រោះគ្នាថា ដើម្បីកុំឱ្យសៅហ្មងទាក់ទងនឹងការគោរព វិឌូឌភៈ ស្តេចសក្យក្មេងៗ ត្រូវតែឱ្យចេញទៅកាន់ជនបទផ្សេងៗទាំងអស់ ។ វិឌូឌភៈ យាងទៅដល់ក្រុងកបិលពស្តុ បានជួបសុទ្ធតែស្តេចសក្យចាស់ៗ និងរៀមច្បងទាំងឡាយ ក៏ក្រាបថ្វាយបង្គំ ព្រះអយ្យកោ ព្រះអយ្យិកា ព្រះបិតុលា ព្រះមាតុលា ។ល។ គ្រប់ព្រះអង្គរៀយៗទៅ មិនឃើញមាន

ស្ដេចសក្យសូម្បីតែ ១ អង្គ ធ្វើសេចក្ដីគោរពក្រាបថ្វាយបង្គំដល់ខ្លួនវិញគ្មានឡើយ ទើបដណ្ដឹងសួរថា នៅទីនេះ មិនមានស្ដេចសក្យក្មេងៗទេឬ? គេឆ្លើយប្រាប់ថា ស្ដេចសក្យក្មេងៗមានដែរ ប៉ុន្តែមានភារកិច្ចចេញទៅកាន់ជនបទអស់ហើយ ។ ព្រះអង្គម្ចាស់វិឌូឌភៈ គង់ស្នាក់ក្រសាល ២, ៣ ថ្ងៃ គួរដល់ព្រះអធ្យាស្រ័យហើយ ក៏ក្រាបបង្គំលាត្រឡប់ទៅសាវត្ថីវិញ ។

ធ្វើដំណើរចេញទៅបានបន្តិច អាមាត្យម្នាក់ភ្លេចអាវុធរបស់ខ្លួន ក៏វិល ត្រឡប់មកយកអាវុធវិញ ពេលនោះ បានឃើញ បានឮនាងទាសីទាំងឡាយកំពុង តែយកទឹកលាយដោយទឹកដោះគោ លាងសំអាតទីកន្លែងដែលព្រះអង្គម្ចាស់ វិឌូឌភៈ គង់ ព្រមទាំងជេរប្រមាថថា ជាស្ដេចពូជអម្បូរនាងទាសីអប្រិយចង្រៃ បានជានាំឱ្យ លំបាកដល់ពួកយើងយ៉ាងនេះ ។ អាមាត្រក្រាបទូលសេចក្ដីនេះ ដល់ព្រះអង្គម្ចាស់ វិឌូឌភៈ សព្វគ្រប់ប្រការ ។ ព្រះអង្គម្ចាស់ វិឌូឌភៈ ចងគំនុំ ក្នុងព្រះទ័យថា ថ្ងៃនេះ គេយកទឹកលាយដោយទឹកដោះគោលាងប្រាសាទ ថ្ងៃក្រោយ បើអាត្មាអញ បានឡើងសោយរាជ្យ នឹងលាងប្រាសាទ ដោយឈាមនៃពួកសក្យវិញ ជាពុំខាន ។

បន្ទាប់ពីព្រះចៅបសេនទិកោសល សោយព្រះទិវង្គតទៅ ព្រះអង្គម្ចាស់ វិឌូឌភៈ ឡើងសោយរាជ្យស្នងព្រះបិតា ទ្រង់នឹកភ្នកដល់គំនុំចាស់ បានចាត់ចែង លើកកងទ័ព សំដៅទៅក្រុងកបិលពស្ដុ ព្រះសាស្ដាទ្រង់ជ្រាបនូវហេតុការណ៍នោះ បានស្ដេចយាងទៅគង់ ក្រោមម្លប់ដើមឈើមួយដើម ដែលមានស្លឹករេចៗ ។ ព្រះ ចៅ វិឌូឌភៈ ចូលទៅគាល់ ព្រមទាំងទូលសួរថា បពិតព្រះអង្គដ៏ចំរើន ដូចម្ដេច បានជាព្រះអង្គ មិនគង់ក្រោមម្លប់ដើមឈើដែលមានស្លឹកច្រើន ? ព្រះពុទ្ធ ត្រាស់ តបថា មហាបពិត្រម្លប់ញាតិត្រជាក់ជាងម្លប់ដើមឈើទៅទៀត ។ ព្រះចៅវិឌូឌភៈ យល់អត្ថន័យ ទើបបញ្ជាឱ្យកងទ័ពត្រឡប់វិញ ។ លើកទ័ពលើកទី ២ ក៏យ៉ាងនេះ ទៀត ។ លើកទ័ពលើកទិ ៣ ក៏យ៉ាងនេះទៀត ។ ព្រះពុទ្ធទ្រង់រំពឹងពិចារណាឃើញថា

កម្មរបស់ស្ដេចសក្យ មានទម្ងន់ធ្ងន់ណាស់ព្រះអង្គមិនអាចជួយទប់ទល់បាន ព្រះអង្គក៏ឈប់ស្ដេចយាងទៅគង់ក្រោមម្លប់ឈើនោះទៀតទៅ ។ ព្រះចៅវិឌូឌភៈ លើកទ័ពទៅលើកទី ៤ ចូលក្រុងកបិលពស្ដុយ៉ាងស្រួលសម្លាប់ស្ដេចសក្យ ជិតផុតពូជ ព្រោះស្ដេចសក្យកាន់សីល សូម្បីបាញ់ទៅគេ ក៏បាញ់បង្ហួស(១០) ។ ស្ដេចសក្យនៅសល់ខ្លះដោយសារ ១. គេយកស្មៅដើមបបុសមកអែប ពេលដែលគេសួរថា នេះសក្យឬ ? ឆ្លើយថា នេះស្មៅ នេះឬដើមបបុស សក្យស្មៅ សក្យបបុស ។ ២. សក្យពួកមហានាម ដែលត្រូវជាព្រះអយ្យកោ នៃព្រះចៅវិឌូឌភៈ ។

## មានះ នៃក្សត្រ

សងគំនុំរួចហើយ ព្រះចៅវិឌូឌភៈ ឱ្យគេរៀបចំព្រះស្ងោយជប់លៀងបានយាងសក្យមហានាម ព្រះអយ្យកោ មកសោយព្រះស្ងោយរួមគ្នា ។ សក្យមហានាមគិតថា បើអញមិនព្រមសោយរួម គេសម្លាប់ ទើបគិតរកឧបាយដោះស្រាយទៅស្រង់ទឹកសិន គេចរត់បាត់ទៅ ។ ខត្តិយោ អហំ ឥតិ មានោ ខត្តិយមានោ មានះ មានះរបស់ក្សត្រថា អញ ជាក្សត្រ ។ សេចក្ដីរាស្ត្រក្តីបើអត់មានធម៌ហើយ មានះដូចតែគ្នាទេ ប៉ុន្តែ ស្ដេចធ្លាប់ធំ ធ្លាប់សន្សំមានះ មកយូរហើយ មានះបែបក្រាស់ជាងបន្តិចដែរ ។

## ច្បាប់ព្រះរាជសម្ភារ

ចង់បុណ្យបានបាប ចចើងចង់លាភ វិវងបាត់ធនទៅ
មានះបាត់មិត្រ ឥតអ្នកជាផៅ ក្រេវក្រោធឃោរឃៅ
វិមែងបាត់អង្គ ។

(១០) កាន់សីល ម៉េចក៏មិនកាន់ធម៌ផង នៅតែមានមានះរឹងខ្លាំងម្ល៉េះ ។ កាន់សីល ត្រូវកាន់ធម៌ផង ទើបបានសីលធម៌ កាន់សីលត្រូវមានបញ្ញា ម៉េចក៏មិនប្រើបញ្ញាការពារខ្លួនផង ។ កាន់សីលរបៀបស្ដេចសក្យនេះ មិនគួរយកតម្រាប់តាមទេ ព្រោះកាន់សីលជ្រុល ភ្លេចធម៌ ភ្លេចបញ្ញា បានជាស្លាប់ជិតផុតពូជ ។

បើមានមានះហើយ ញាតិមិត្រចេះតែរស់ ចេះតែរេចរិលហើយ បើថែមក្រេវក្រោធឃោរឃៅទៀត បាត់អង្គតែម្តង ។ បាត់អង្គ មិនមែនបាត់ត្រឹមតែអវៈយវៈដៃជើងទេ ជីវិតក៏បាត់ដែរ ព្រោះអង្គ ប្រែថា ជីវិតក៏បាន ។ ទាំងអស់នេះលោកហៅថា ទុក្ខកើតព្រោះ អញ ។

* * *

*កុំកាន់សាសនាឱ្យជ្រុលជ្រុស ដល់ជាតិស្លាប់ហួសក៏មិនគិត*
*ស្មានថាខ្លួនឯងជាបញ្ញើត ពិតជាងមិត្តពាលសោះទេ ។*
*ព្រះពុទ្ធឱ្យធ្វើប្រយោជន៍ពីរ ប្រយោជន៍ដ៏វិប្រយោជន៍គេ*
*ម្តេចអ្នកមិនចេះគិតគ្នាន់គ្នេរ គិតតែរិះរេប្រយោជន៍ខ្លួន ។*

*ភិក្ខុ* **ខិន គេន** *គន្ធប្បញ្ញោ*

# គុណកថា

ប្រជាជនខ្មែរគ្រប់រូបតែងចាត់ទុកថាសម្តេចព្រះសង្ឃរាជ **ជួន ណាត** គឺជាវរជនអក្សរសាស្ត្រខ្មែរ ។ ហើយព្រះអង្គគឺជាតំណាងដ៏ខ្ពង់ខ្ពស់លើវិស័យវប្បធម៌អក្សរសាស្ត្រខ្មែរ ។ ព្រះអង្គបានរៀបចំជាក្បួនខ្នាតអក្ខរក្រមភាសាខ្មែរ ព្រមទាំងបានបន្សល់ទុកនូវស្នាដៃដ៏ធំធេងសម្រាប់កូនខ្មែរជំនាន់ក្រោយយកជាមូលដ្ឋានសិក្សាស្រាវជ្រាវ ។ យើងអាចសន្មត់ស្នាដៃដ៏ថ្លៃថ្លារបស់ព្រះអង្គនេះថាជា " គុណ " ដ៏លើសលប់មកលើកូនខ្មែរម្នាក់ៗនៃយើងគ្រប់ៗរូប ។

ក្នុងន័យដូចខាងលើនេះ ខ្ញុំសូមអនុញ្ញាតរៀបរាប់ត្រួសៗអំពីអត្ថន័យរបស់គុណ ។ តើអ្វីទៅដែលហៅថា " គុណ " នោះ ?

- គុណ ស្គាល់គុណ ដឹងគុណ សងគុណ និងរមិលគុណ ។

- អ្នកមាន[illegible]ុណ គុណទាំងឡាយតែងតែស្រឡាញ់គុណ ខំសងគុណ សន្សំគុណឱ្យបាន[illegible]ទុកចែកគេឯងគ្រប់ៗគ្នា ។

- ព្រះរាជាមានគុណ អ្នកដឹកនាំមានគុណ តែងតែផ្តល់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ដល់អ្នកក្រោម ។

- អ្នក " មេ " មានគុណ ម្តាយឪពុកមានគុណតែងផ្តល់សេចក្តីសុខសាន្តដល់កូនចៅក្នុងគ្រួសារ ។

- ព្រះសង្ឃឧបជ្ឈាយ៍ លោកគ្រូ អ្នកគ្រូ មានគុណ ព្រោះបានផ្តល់ចំណេះវិជ្ជា ផ្តល់បញ្ញា ផ្តល់សេចក្តីសុខស្ងប់ មិនរើសមុខ មិនរើសឋានៈ មិនរើសវណ្ណៈដល់មនុស្សសត្វគ្រប់ៗរូប ។

- អ្នកមានគុណតែងមានចិត្តគិតគេ ចិត្តព្រេកអរតាម ចិត្តជួយជ្រោម

អ្នកដទៃ មិនបំភ្លេច មិនបំផ្លាញ មិនមួលបង្កាច់គុណអ្នកដទៃ ។

- គុណជាអំពើល្អ អំពើល្អរបស់មេ របស់គ្រូ របស់ឪពុកម្តាយ ជាគំរូដ៏ល្អដល់អ្នកក្រោម ដល់អ្នកក្រោយធ្វើតាមទម្លាប់ល្អរបស់ជំនាន់ ទម្លាប់មានមារយាទ មានគំនិតថែរក្សាគុណ ថែរក្សាមរតក ថែរក្សាកេរ្តិ៍ មិនឱ្យក្លាយទៅជាជនឥតពូជព្រោះតែខ្វះគុណ ។

- សងគុណ និងតបស្នងសងគុណ គឺសងអំពើល្អ សងអំពើរបស់មេ គំនិតល្អ របស់គ្រូ ចិត្តល្អរបស់ឪពុកម្តាយ សងនៅពេលដែលខ្លួនមានគុណហើយត្រូវសងគុណចាស់ និងបុលគុណថ្មី ។

- សុភមង្គលរបស់មនុស្សស្ថិតនៅត្រង់ស្គាល់គុណគ្នា និងចេះសងគុណគ្នាទៅវិញទៅមក ។

- ជនរមិលគុណ គឺជនបំភ្លេចគុណ មួលបង្កាច់អំពើល្អរបស់អ្នកដទៃ មួយបដិសេធមួយ ត១គ្នាទៅ សង្គមពោរពេញទៅដោយអំពើអាក្រក់ព្រោះតែខ្វះគុណ ។

ដោយព្រឹទ្ធាចារ្យ **ឆេង ផុន**

ចូលរួមក្នុងបុណ្យខួបទី ៣០ នៃការចូលទិវង្គត

របស់សម្តេចព្រះសង្ឃរាជ ជួន ណាត **ជោតញ្ញាណោ**

# សាកលភាវូបនីយកម្ម និងដំណើរវប្បធម៌ខ្មែរ

## Globalization and the process of khmer culture

ដោយ **ឆយ យីហ៊ាខ**

បណ្ឌិតវិទ្យាសាស្ត្រទស្សនវិជ្ជា

## I. សេចក្តីផ្តើម :

កម្ពុជាបានឆ្លងកាត់មាគ៌ាដ៏ច្រើននៅក្នុងជីវិតរបស់ខ្លួន ដូចដែលប្រវត្តិសាស្ត្របានបញ្ជាក់ស្រាប់ ។ នៅក្នុងសម័យរុងរឿង ប្រជាជនមានសេចក្តីថ្លៃថ្នូរ និងមានវឌ្ឍនភាពដូចក្នុងសម័យមហានគរជាឧទាហរណ៍ ។ ផ្ទុយទៅវិញ នៅក្នុងសម័យអាប់ឱនប្រជាជនបាត់បង់កិត្តិយស និងអំណាចរបស់ខ្លួនដោយឆ្លងកាត់សង្គ្រាមយ៉ាងជូរចត់ខ្លោចផ្សា ។ នោះជាមេរៀនដែលគ្រប់ប្រទេសនៅក្នុងពិភពលោកសុទ្ធតែបានបញ្ជាក់ថា សង្គ្រាមជាប្រភពនៃគ្រប់គ្រោះមហន្តរាយ ។

ពេលនេះ ប្រទេសទាំងអស់នៅក្នុងពិភពលោករួបរួមសហការ និងកសាងមូលដ្ឋានសន្តិភាព ភាតរភាព និងមិត្តភាព ។ គំនិតឈ្លានពានលុកលុយពីប្រទេសមួយទៅប្រទេសមួយជាគំនិតអន់ថយ ។ នៅចំពោះមុខស្ថានការណ៍នេះ ប្រជាជនកម្ពុជាដ៏អង់អាចក្លាហានត្រូវតស៊ូយ៉ាងប្តូរផ្តាច់សំរាប់អត្ថិភាពរបស់ខ្លួនក្នុងពេលសព្វថ្ងៃផង និងសំរាប់មនុស្សជំនាន់ក្រោយផង ។ ប្រជាជនកម្ពុជាត្រូវតែគិតពិចារណាអំពីឱកាស ការប្រលងប្រណាំង និងចក្ខុវិស័យអនាគតដែលត្រូវចាប់ផ្តើមដោះស្រាយ ដោយមិនគ្រាន់តែនៅក្នុងចំណោមខ្មែរទាំងអស់គ្នាទេ តែត្រូវពិចារណា

ដោះស្រាយជាមួយប្រជាជនដទៃទៀតផង ។ ការពង្រឹង និងពង្រីកអត្ថិភាពរបស់ខ្លួនជាមួយប្រជាជាតិដទៃ ដើម្បីសន្តិសហវិជ្ជមាន គឺជាកត្តាចាំបាច់មិនអាចខ្វះបានឡើយ ។

ក្នុងឋានៈជាប្រទេសមួយស្ថិតនៅក្នុងប្រទេសតតិយលោក កម្ពុជាត្រូវខិតខំចងមិត្តជាមួយប្រទេសដទៃទៀត ជាពិសេសជាមួយសមាជិកនៃអាស៊ាន ( ASEAN ) ។ យោងតាមកំណែទំរង់គ្របវិស័យ យើងចង់កសាងកម្ពុជាមួយប្រកបដោយសណ្ដាប់ធ្នាប់ល្អ ។ ការផ្ដួចផ្ដើមដើម្បីបង្កើតសណ្ដាប់ធ្នាប់កម្ពុជាថ្មីនេះអាចនឹងត្រូវវាយតំលៃថា ជាអ្វីដែលប្រជាជនកម្ពុជារួមចំណែកពង្រឹងពង្រីកសិទ្ធិមនុស្ស សេរីភាព និងប្រជាធិបតេយ្យ ។ គំនិតនេះអាចទទួលជោគជ័យបានដោយអវត្តមាននៃហិង្សា ឬដោយវត្តមាននៃការអត់ឱន និងយុត្តិធម៌ ។ ការបណ្ដុះស្មារតីអត់ឱន យោគយល់គ្នាទៅវិញទៅមកនៅក្នុងសង្គមជាតិរបស់យើងជាកត្តាកំណត់ក្នុងការពង្រឹងអត្តសញ្ញាណជាតិឡើងវិញ បន្ទាប់ពីយើងបែកបាក់គ្នាអស់រយៈពេលជាច្រើនមក ។

ពេលនេះ ជាពេលដែលយើងត្រូវចោទសួរពីអ្វីដែលយើងត្រូវធ្វើដើម្បីមាតុភូមិរបស់យើង នៅចំពោះមុខទិសដៅរួមនៃសាកលលោក ។ ពិតណាស់ យើងមិនអាចរស់នៅឯកោបានឡើយ ។ ប្រសិនបើយើងបិទទ្វារ យើងនឹងស្លាប់ ។ យើងត្រូវបើកទ្វារចំហគ្រប់ទិសទី ។ ប៉ុន្តែនៅពេលដែលយើងបើកទ្វារចំហ ជ្រុងទាំងពីរ-ល្អ និងអាក្រក់-នៃសាកលភាវូបនីយកម្មពិតជាឈានជើងចូលមកដល់សង្គមយើង ។ យើងត្រូវក្លាហាន និងតស៊ូដើម្បីកាត់បន្ថយជ្រុងអវិជ្ជមាននៃសាកលភាវូបនីយកម្មដោយសារការប្រើប្រាស់វិចារណញ្ញាណរបស់យើង ។ ក្នុងករណីនេះ បើយើងមិនបើកទ្វារចំហក៏យើងស្លាប់ តែបើយើងបើកទ្វារចំហដោយខ្វះការពិចារណាក៏យើងស្លាប់ដែរ ។

## II. បរិបទពិភពលោក សាកលភាវូបនីយកម្ម សាកលនិយម និងការចំណុះគ្នាទៅវិញទៅមក

### *១ . បរិបទពិភពលោក*

សភាពឯកោដែលធ្លាប់មាននៅក្នុងសង្គមបុព្វកាល ឬនៅក្នុងសង្គមទាសភាពត្រូវរលាយបាត់បង់តាំងពីយូរយាណាស់មកហើយ ។ ទំនាក់ទំនងសាកលបាននឹងកំពុងរីករាលដាល ។ ពិភពលោកមានទំនោរទៅរកលក្ខណៈរួមមួយ មានទំនោរទៅរកទំនាក់ទំនងទៅវិញទៅមក និងសាកលភាវូបនីយកម្ម ស្ដីពីលក្ខខណ្ឌសេដ្ឋកិច្ច បច្ចេកវិទ្យា សង្គម និងវប្បធម៌ ។ ទិដ្ឋភាពដ៏សំខាន់នៃបំរែបំរួលខាងបច្ចេកវិទ្យា គឺជាបដិវត្តន៍ខាងទូរគមនាគមន៍ ។ គឺបដិវត្តន៍ទូរគមនាគមន៍នេះហើយ ដែលធ្វើឱ្យផែនដីរបស់យើងដូចជានៅរួញតូចត្រឹមតែជាភូមិមួយប៉ុណ្ណោះ ។ លោក សាពួរ រ៉ាសិច (Shapour Rassekh) បានសរសេរថា : « *ទិដ្ឋភាពដ៏សំខាន់នៃបំរែបំរួលខាងបច្ចេកវិទ្យាដែលកំពុងចោទឡើង គឺបដិវត្តន៍ដែលធ្វើឱ្យពិភពលោកមានទំហំត្រឹមតែជាភូមិធំមួយប៉ុណ្ណោះ* » ( ១ ទំព័រទី ១១ ) ។

ក្នុងករណីនេះ ប្រជាជាតិនីមួយៗអាចទទួលពត៌មានយ៉ាងឆាប់រហ័សដោយសារមធ្យោបាយទូរគមនាគមន៍ផ្សេងៗដូចជា សាតែលីត ( Satellites ) កុំព្យូទ័រ ( Computers ) វិទ្យុ ( Radios ) ទូរទស្សន៍ ( Televisions ) ហ្វាក់ និងអ៊ីមែល ( Fax and E-mail ) ទូរស័ព្ទចល័ត ( Mobile Phones ) និងបណ្ដាញអ៊ីនធឺណែត ( Network of Internet ) ជាដើម ។ ឧបករណ៍ទាំងនេះកំពុងជំរុញឱ្យមនុស្សក្នុងពិភពលោកមានទំនាក់ទំនងជាមួយគ្នាយ៉ាងឆាប់រហ័សដោយឥតគិតអំពីជាតិសាសន៍ និងពណ៌សម្បុរឡើយ ។

ដើម្បីគូសបញ្ជាក់បញ្ហានេះ លោក អង់តូនី ហ្គីដិន ( Anthony Giddens ) អះអាងថា : « *សាតែលីតពាណិជ្ជកម្មទី ១ ត្រូវបានបង្ហោះនៅក្នុង*

*ឆ្នាំ ១៩៦៩ ។ ឥឡូវនេះ មានសាតែលីតបែបនោះជាង ២០០ នៅលើផែនដី ហើយសាតែលីតនីមួយៗកំពុងទទួលពតិមានយ៉ាងច្រើន »* ( ១ . ទំព័រទី ១១) ។ នោះជាទំរង់មួយនៃសាកលភាវូបនិយកម្ម ។ វាគូសបញ្ជាក់អំពីការរីកចំរើន នៃបច្ចេកវិទ្យាដែលធ្វើឱ្យមនុស្សកាន់តែឈានទៅធ្វើជាម្ចាស់លើធម្មជាតិ និងលើសង្គម ។

*២ . សាកលភាវូបនីយកម្ម សាកលនិយម និងការចំណុះគ្នា*

យើងគួរបែងចែកថា អ្វីទៅដែលហៅថា សាកលភាវូបនិយកម្ម សាកលនិយម និងការចំណុះគ្នា ។

នៅក្នុងបណ្តាប្រទេសខាងលិច បញ្ញត្តិ *« សាកលភាវូបនីយកម្ម »* ( Globalization ) បានកើតឡើងយូរមកហើយ ។ ពាក្យនេះមិនមែនទើបនឹងកើតឡើងទេ ។ រ៉ូបែរ គីអូហាន ( Robert Keohane ) និងហ្សូហ្សិបណាយ (Joseph Nye ) អះអាងថា : « *សព្វថ្ងៃនៅពេលគេជជែកគ្នាអំពីសាកលភាវូបនីយកម្ម គេតែងតែយល់ថាសាកលភាវូបនីយកម្ម គឺជាបញ្ហាមួយថ្មី* » ( ៣ . ទំព័រទី ២ នៃ៨ ) ។ លោកទាំងពីរបានផ្តល់ឧទាហរណ៍ថា : « The Silk Road » ដែលធានា អះអាងអំពីទំនាក់ទំនងវប្បធម៌ និងសេដ្ឋកិច្ចរវាងពាណិជ្ជករអឺរ៉ុប និងពាណិជ្ជករអាស៊ី គឺជាសាកលភាវូបនីយកម្ម ដែលទើបនឹងចាប់ផ្តើមមុនដំបូង ( thin globalization ) ។ ឯសហប្រតិបត្តិការខាងទីផ្សារហិរញ្ញ វត្ថុរមសព្វថ្ងៃ គឺជាសាកលភាវូបនីយកម្មដែលមានដំណើរពេញលេញ ( thick globalization ) ។

*« សាកលភាវូបនីយកម្ម »* ជាពាក្យមួយដែលទើបនឹងលេចឡើងខ្ចីរខ្ចារនៅទស្សវត្ស ១៩៩០ ដូចពាក្យ *« ការចំណុះគ្នា»* ( Dependence ) ដែលលេចឡើងនៅទស្សវត្ស ១៩៧០ ដែរ តែបាតុភូតនៃសាកលភាវូបនីយកម្មមិនមែនថ្មីទាំងស្រុងឡើយ ។

លោកទាំងពីរបានបែងចែកច្បាស់លាស់នូវពាក្យទាំងបីគឺ : សាកលភាវូប

និយកម្ម សាកលនិយម និងការចំណុះគ្នា ។ លោកបង្ហាញឱ្យឃើញថា ពាក្យទាំងបីមានន័យខុសគ្នា ។ លោកពោលថា ៖ « *សាកលភាវូបនីយកម្ម និងការចំណុះគ្នាមិនមែនស្របគ្នាទាំងស្រុងទេ ។ ការចំណុះគ្នាសំដៅលើលក្ខខណ្ឌ និងសភាពនៃកិច្ចការ ។ វាអាចកើនឡើង ឬថយចុះដោយយោលទៅតាមកាលៈទេសៈ ។ សាកលភាវូបនីយកម្មសំដៅលើអ្វីកំពុងកើនឡើង .. ។ ចំណែកឯសាកលនិយមវិញ* ( Globalism ) *វាជាសភាពមួយនៃពិភពលោក ដែលក្នុងនោះមានបណ្ដាញ នៃការចំណុះគ្នាទៅវិញទៅមកនៅក្នុងចំងាយពហុទ្វីបដោយមានទំនាក់ទំនង ដែលកើតឡើងដោយឆ្លងកាត់បណ្ដូរសង្គម និងសេដ្ឋកិច្ច ។ ប៉ុន្តែការចំណុះគ្នាសំដៅលើផែនការដែលកត់សំគាល់ដោយផលដែលមានទៅវិញទៅមករវាងប្រទេសនានា ឬរវាងតួអង្គទាំងឡាយនៅក្នុងប្រទេសផ្សេងៗ* » ( ៣ .ទំព័រ ទី១នៃ៨ ) ។ បើតាមសំដីខាងលើនេះ យើងឃើញថា ពាក្យទាំងបីមានទំនាក់ទំនងបដិសំយោគជាមួយគ្នា និងជះឥទ្ធិពលទៅវិញទៅមក ។

ហ្វីលីព សឺរស៊ី ( Philip Cersy ) ពោលថា ៖ « *សាកលភាវូបនីយកម្មមិនមែនសុទ្ធតែជាការប៉ះទង្គិចដែលបង្កឡើងដោយការចំណុះគ្នាខាងសេដ្ឋកិច្ចជាមួយនឹងប្រព័ន្ធនយោបាយក្នុងស្រុក និងអន្តរកម្មរបស់រដ្ឋនានាឡើយ ។ វាជាការធ្វើឱ្យយល់ឡើងវិញនូវវិស័យវិទ្យាសាស្ត្រនយោបាយនិយាយរួម ( និងវិទ្យាសាស្ត្រសង្គមដ៏ទូលំទូលាយផងដែរ ) នៅលើមាតិដែលបានពន្យល់ទាំងខាងអំណាចប្រវត្តិសាស្ត្ររបស់រដ្ឋ ទាំងខាងការបញ្ជាក់ឱ្យឃើញច្បាស់នូវចរន្តនាដកម្មនៃបណ្ដាញសេដ្ឋកិច្ចនយោបាយ និងសង្គមដ៏ស្មុគស្មាញដែលមានប្រព័ន្ធពិភពលោកពោរពេញទៅដោយការផ្លាស់ប្ដូរសព្វថ្ងៃនេះ* ( ២ . ទំព័រទី ៦២៤ International Journal) ។ បើតាម **សឺរសិ** ( Cersy ) ការចំណុះគ្នាខាងសេដ្ឋកិច្ចគ្រាន់តែជាកត្តាមួយ នៃសាកលភាវូបនីយកម្មប៉ុណ្ណោះ ។ នៅមានកត្តា

ជាច្រើនទៀត ដែលធ្វើឱ្យសាកលភាវូបនីយកម្មលេចធ្លោឡើង ។

អង់តូនី ហ្គីដិន ( Anthony Giddens ) អះអាងថា : « *គឺជាការខុសឆ្គងមួយក្នុងការគិតថា សាកលភាវូបនីយកម្មទាក់ទងតែនឹងប្រព័ន្ធធំៗដូចជាទាក់ទងនឹងសណ្តាប់ធ្នាប់ហិរញ្ញវត្ថុពិភពលោកជាដើម ។ សាកលភាវូបនីយកម្មមិនមែនគ្រាន់តែជាអ្វីដែល « ស្ថិតនៅខាងក្រៅ » ដែលស្ថិតនៅឆ្ងាយពីបុគ្គលទេ ។ សាកលភាវូបនីយកម្មគឺជាបាតុភូតដែល « ស្ថិតនៅក្នុងទីនេះ » ផងដែរ ដែលកំពុងជះឥទ្ធិពលយ៉ាងខ្លាំងដល់ទិដ្ឋភាពបុគ្គលក្នុងជីវិតរបស់យើង* ( ១ . ទំព័រទី១២ ) ។ លោកបានបន្ថែមថា : « *សាកលភាវូបនីយកម្មមានលក្ខណៈនយោបាយបច្ចេកទេស និងវប្បធម៌ដូចលក្ខណៈសេដ្ឋកិច្ចដែរ ។ វាត្រូវបានទទួលឥទ្ធិពលមុនបង្អស់ដោយសារការអភិវឌ្ឍន៍នៅក្នុងប្រព័ន្ធទូរគមនាគមន៍ចាប់តាំងពីចុងទស្សវត្ស ១៩៦០ មកម្ល៉េះ* » ( ១ .ទំព័រទី១០ ) ។ លោកបានបញ្ជាក់អំពីវិសាលភាពនៃសាកលភាវូបនីយកម្មថា : « *សាកលភាវូបនីយកម្មកំពុងតាក់តែងរចនាសម្ព័ន្ធមាត៌ាដែលយើងកំពុងរស់នៅ និងឈានចូលជ្រៅទៅក្នុងរបៀបរបបរបស់យើង ។ វាធ្វើដំណើរមកពីលោកខាងលិច វាមានស្នាមដ៏ធំនៃអំណាចសេដ្ឋកិច្ច និងអំណាចនយោបាយរបស់សហរដ្ឋអាមេរិក និងបន្សល់ទុកនូវផលវិបាកដ៏ច្រើន ។ ប៉ុន្តែ សាកលភាវូបនីយកម្មមិនមែនគ្រាន់តែជាការគ្របសង្កត់ នៃលោកខាងលិចទៅលើប្រទេសដទៃប៉ុណ្ណោះទេ ។ វាធ្វើឱ្យប៉ះពាល់ដល់សហរដ្ឋអាមេរិក ដូចដែលសហរដ្ឋអាមេរិកធ្វើឱ្យប៉ះពាល់ដល់ប្រទេសដទៃដែរ* ( ១ . ទំព័រទី៤ ) ។

បើតាមទស្សនៈខាងលើនេះ យើងឃើញថា គ្មានរដ្ឋណាមួយដែលស្ថិតនៅក្រៅប្រព័ន្ធសាកលភាវូបនីយកម្មទេ ។ ប្រជាជាតិទាំងអស់ទោះចង់ក្តី ឬមិនចង់ក្តី ត្រូវតែមានទំនាក់ទំនងគ្នាខាងវិស័យសេដ្ឋកិច្ច បរិស្ថាន និងវប្បធម៌ ...ល... ។

ហេតុនេះ យើងមិនអាចទប់ដំណើរសាកលភាវូបនីយកម្មបានទេ ។ វាកំពុងតែជ្រៀតចូលមកក្នុងជីវភាពប្រចាំថ្ងៃរបស់យើង ធ្វើឱ្យយើងឃ្លាតចេញបន្តិចម្តងៗ ពីក្របខ័ណ្ឌជាតិទៅក្របខ័ណ្ឌអន្តរជាតិ ដែលមិនមានប្រទេសណាមួយជៀសផុតបានឡើយ ។

## III . ដំណើរវប្បធម៌ខ្មែរក្នុងយុគសម័យសាកលភាវូបនីយកម្ម

សមាសភាគនៃវប្បធម៌ខ្មែរ ( The components of khmer culture ) រួមមានអ្វីៗដែលទាក់ទងនឹងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ និយាយដោយឡែក និងប្រជាជនកម្ពុជានិយាយរួម ។ កាលណានិយាយអំពីវប្បធម៌ខ្មែរ យើងច្រើនតែនឹកដល់ស្ថាបត្យកម្មសម័យមហានគរ និងរបៀបរបបរស់នៅសម័យអង្គរ សម័យលង្វែក សម័យឧត្តុង្គជាដើមប៉ុណ្ណោះ ។ តាមពិត វប្បធម៌ខ្មែរគឺជារបៀបរបបរស់នៅ និងអ្វីៗដែលទាក់ទងនឹងការរស់នៅរបស់ប្រជាជនខ្មែរតាំងពីខ្មែរ ចាប់កំណើតឡើងរហូតមកដល់សព្វថ្ងៃនេះ ។

សង្គមកម្ពុជាធ្វើដំណើរទៅមុខរៀងរាល់វិនាទី ។ សមាជិកសង្គមនេះ ក៏កំពុងបោះជំហានទៅមុខរៀងរាល់វិនាទីដែរ ។ ហេតុនេះ វប្បធម៌ដែលជាជីវិតស្មារតីនៃប្រជាជនខ្មែរតែងធ្វើចលនាប្រែប្រួល និងរីកចំរើន ឬថយក្រោយតាមដំណើររុងរឿង ឬដំណើរអន់ថយនៃសង្គមកម្ពុជា ។

ក្នុងយុគសម័យនៃអន្តរកម្មពហុវប្បធម៌សព្វថ្ងៃនេះ ដែលកើតឡើងដោយសារសាកលភាវូបនីយកម្មសេដ្ឋកិច្ច វប្បធម៌ខ្មែរកំពុងតែប្រឈមមុខយ៉ាងស្វិតស្វាញជាមួយវប្បធម៌បរទេស ជាពិសេសជាមួយវប្បធម៌បស្ចឹមប្រទេស ដែលកំពុងហូរចូលមកក្នុងកម្ពុជា ដើម្បីអត្ថិភាពរបស់ខ្លួន ។ ប៉ុន្តែនៅក្នុងនិម្មិតកម្មសេដ្ឋកិច្ចសង្គមកម្ពុជា វិស័យសេដ្ឋកិច្ចដែលជាកត្តាកំណត់លើគ្រប់វិស័យទាំងអស់កំពុងតែទទួលឥទ្ធិពលយ៉ាងខ្លាំងពីសំណាក់សាកលភាវូបនីយកម្មសេដ្ឋកិច្ចពិភពលោក ។ រីឯ

វិស័យវប្បធម៌ដែលចំណុះវិស័យសេដ្ឋកិច្ចក៏មិនអាចជៀសផុតពីសំពាធនៃសាកលភាវូបនីយកម្មនេះដែរ ។

នៅក្នុងប្រទេសកម្ពុជា មានហាងលក់ទំនិញធំៗ ដែលក្នុងនោះមានសុទ្ធតែទំនិញបរទេស ។ យើងអាចឱ្យឈ្មោះថា នោះជាផ្សារវប្បធម៌រួម ។ ផ្សារវប្បធម៌រួមតែងលើកដំកើងសញ្ញាណនៃតំលៃវប្បធម៌រួម និងសញ្ញាណនៃផលិតផលណាមួយដែលមានលក់ពាសពេញពិភពលោក ។ គំនិតនេះជះឥទ្ធិពលទៅលើមនុស្សខ្មែររាប់ម៉ឺននាក់ដោយធ្វើឱ្យចំណូលចិត្ត និងអាកប្បកិរិយារបស់ខ្មែរមានលក្ខណៈប្រហាក់ប្រហែលគ្នា ឆ្ពោះទៅរករបៀបរស់នៅតាមអំពើចិត្តដែលគេចង់ ពោលគឺម្នាក់ៗចង់រស់នៅតាមទំនើងចិត្តរបស់ខ្លួន ។ ការកើនឡើងដោយគ្មានលំអានជាមុននៅក្នុងពាណិជ្ជកម្មរួម ការទិញ និងការលក់វត្ថុ និងសេវាផ្សេងៗនៅក្នុងប្រទេសកម្ពុជា បានបង្កើតឱ្យមានហាងទំនិញធំៗជាច្រើន ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយហាងទំនិញធំៗក្នុងពិភពលោក ។ ការទិញ និងការលក់ប្រទាក់គ្នាដោយឆ្លងតាមរយៈមធ្យោបាយផ្សាយពាណិជ្ជកម្ម ។ ទូរទស្សន៍ វិទ្យុ ទូរស័ព្ទ កាសែត ទស្សនាវដ្ដី សុទ្ធតែជាមធ្យោបាយដែលបានបំរើការងារផ្សព្វផ្សាយនេះ ។ តាមពិត សាកលភាវូបនីយកម្មនៃសេដ្ឋកិច្ចបានបង្កើតសាកលភាវូបនីយកម្មនៃការផ្សាយ ។ ទោះច្រើន ឬតិច ការផ្សព្វផ្សាយតែងផ្អែកលើអំណាច និងវប្បធម៌នៃប្រទេសអ្នកមាន ។ ទីផ្សារហិរញ្ញវត្ថុរួមបានបង្កើតបរិយាកាសថ្មីមួយ ក្នុងការស្វែងរកផលចំណេញឱ្យបានឆាប់រហ័ស ។ ទីផ្សារប្ដូរប្រាក់កំពុងមានទំនាក់ទំនងជាមួយការកេងកំរៃរូបិយវត្ថុដោយធ្វើយ៉ាងណាឱ្យបានចំណេញច្រើនជាអតិបរមា ។

ភាពមិនទៀងទាត់ក្នុងការបង្កើនមុខរបរ ដូចជាមុខរបរកសិកម្មជាដើម បានជំរុញឱ្យមានកន្លែងធ្វើការងាររួម ហើយបញ្ហានេះបណ្ដាលឱ្យមានការផ្លាស់លំនៅស្ថាននៃពលករស្ទើរពាសពេញប្រទេសកម្ពុជា ជាពិសេសការផ្លាស់លំនៅស្ថាន

របស់យុវវ័យ ។ គេធ្វើដំណើរពីជនបទមករស់នៅទីក្រុង និងធ្វើដំណើរពីទីក្រុងទៅរស់នៅឯបរទេស ដើម្បីលក់កំលាំងពលកម្មក្នុងពេលដែលកម្ពុជា នៅមានផ្ទៃដីទំនេរជាច្រើន ។

កំណែទំរង់សេដ្ឋកិច្ចតំរង់ទៅរកទីផ្សារតែងជំរុញឱ្យក្រុមហ៊ុនអន្តរជាតិនៅកម្ពុជាកាន់តែមានឥទ្ធានុភាពខ្លាំងឡើងៗ ។ ការណ៍នេះ កំពុងជំរុញឱ្យពលករខ្មែរជាច្រើនស្វែងរកការងារនៅក្នុងប្រទេស ឬស្វែងរកការងារនៅឯបរទេស ដោយបំភ្លេចចោលតាមបែបអចេតនានូវវប្បធម៌របស់ខ្លួន ។ នៅក្នុងលក្ខខណ្ឌមួយចំនួនម្ចាស់កម្មន្តសាលបង្ខំឱ្យពលករខ្មែរទាំងនោះធ្វើការក្នុងសភាពអមនុស្សធម៌ដោយបានទទួលបៀវត្សតិចតួចប៉ុណ្ណោះ ។

យើងអាចនិយាយថា នៅក្នុងសម័យសាកលភាវូបនីយកម្ម មនុស្សជាតិអាចឈានទៅរកវាសនារួមដែលកើតឡើងដោយសារបដិវត្តន៍បច្ចេកទេសខាងពត៌មាន និងគមនាគមន៍ ។ គួរចងចាំថា ក្រុមហ៊ុនអន្តរជាតិជាចំណុចសំខាន់នៃសាកលភាវូបនីយកម្ម ។ គឺក្រុមហ៊ុនអន្តរជាតិនេះហើយ ដែលក្លាយជាអ្នកគ្រប់គ្រងសេដ្ឋកិច្ច និងក្លាយជាកំលាំងនយោបាយនៅក្នុងសេដ្ឋកិច្ចពិភពលោក ។ ក្រុមហ៊ុនអន្តរជាតិតែងបង្កើនការប្រណាំងប្រជែង និងបង្កើនការក្បៀបសង្កត់លើគ្នាទៅវិញទៅមក ដើម្បីការពារអត្ថិភាព និងប្រាក់ចំណេញរបស់ខ្លួន ។ ការណ៍នេះជំរុញឱ្យពួកគេស្វែងរកយ៉ាងទទូចនូវទីផ្សារពលកម្មដែលមានតំលៃថោក ។ នៅក្នុងចំណោមទីផ្សារដែលមានតំលៃថោកនោះ កម្ពុជាមានតួនាទីមួយយ៉ាងសំខាន់ ។ ក្រុមហ៊ុនអន្តរជាតិជាច្រើនបានបង្កើតកម្មន្តសាល និងសេវាឧស្សាហកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ។ ជួនកាល គេពុំយកផលិតផលទាំងនោះបំរើឱ្យប្រជាជនកម្ពុជាទេ ។ ឧទាហរណ៍ : សំលៀកបំពាក់ជាច្រើនដែលបានផលិតនៅប្រទេសកម្ពុជា ត្រូវបានគេបញ្ជូនទៅលក់នៅឯបរទេស ។ ចំណែកប្រជាជនកម្ពុជាបែរជានិយមស្លៀកពាក់

« សំលៀកបំពាក់ជជុះ » ដែលនាំចូលពីបរទេសវិញ ។

The Structural Adjustment Programmes ( SAP ) អះអាងថា សាកលភាវូបនីយកម្មបានរួមចំណែកយ៉ាងធំក្នុងការបង្កើនបំណុល សេចក្ដីក្រលំបាក និងវិបត្តិសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ អង្គការនេះសង្កត់ធ្ងន់ថា ស្ថាប័នឥណទានទាយករួម ( The global creditor Institutions ) បាននឹងកំពុងបង្កើតបរិយាកាសដែលប៉ះពាល់យ៉ាងខ្លាំងដល់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រាក់ជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានប្រើប្រាស់ទៅលើទិសដៅនាំចេញ ។ សេដ្ឋកិច្ចក្នុងស្រុកចំណុះសេដ្ឋកិច្ចពិភពលោកទាំងស្រុង ។ ស្ថាប័នដែលមានអំណាចខ្លាំងដូចជា The International Monetary Fund, The world Bank, the world Trade Organization ជាដើម តែងផ្ដល់ទឡ្ហីករណ៍ថា «គ្មានផ្លូវណាផ្សេងទៀត» ឡើយ ( There Is No Alternative ) ។ ផលវិបាកដែលប្រទេសកំពុងអភិវឌ្ឍន៍បានទទួល គឺធ្លាក់ទៅលើផលិតករក្នុងស្រុក ដូចជាវណ្ណៈកម្មករ និងកសិករជាដើម ។ ដូចនេះផលិតករកម្ពុជាក៏កំពុងទទួលផលវិបាកនេះដែរ ។

គឺពិតជាត្រឹមត្រូវនៅពេលដែលគេអះអាងថា ប្រជាជនមួយចំនួនដែលស្ថិតនៅក្នុងវណ្ណៈកណ្ដាល និងវណ្ណៈអ្នកមាន មានការរីកចំរើននៅក្នុងសង្គមដែលមានការឆ្លងកាត់ទៅរកប្រព័ន្ធទីផ្សារសេរី ។ វណ្ណៈកណ្ដាល និងវណ្ណៈអ្នកមានថ្មីនេះពិតជាលទ្ធផលនៃសាកលភាវូបនីយកម្ម ។ ពួកគេធានាបង្កើតទីផ្សារ ដើម្បីនាំផលិតផលចូលមកក្នុងស្រុក ។ បើយើងនាំផលិតផលបរទេសចូលក្នុងស្រុកកាន់តែច្រើន សេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ដែលជាម្ចាស់ផលិតផលក៏កាន់តែរីកចំរើនដែរ ។

ជាការណ៍ដែលគួរឱ្យឆ្ងល់ណាស់នៅពេលដែលគេនិយាយថា ផលិតផលខ្មែរមិនមានស្តង់ដាអន្តរជាតិ ! នៅពេលណាក៏គេលើកតំកើងផលិតផលបរទេសដែរ ។ នេះមកពីខ្មែរបាត់បង់ជំនឿលើខ្លួនឯង បាត់បង់ជំនឿលើសង្គមរបស់ខ្លួនពី

ជំនាន់មួយទៅជំនាន់មួយ ។

យើងមានផ្សារទំនើបសំរាប់ផលិតផលបស្ចឹមប្រទេសតាំងពីជីដាក់ស្រែ និងម្ហូបកំប៉ុងជាដើម ។ កសិករទាំងអស់ស្ទើរតែបោះបង់ចោលការផ្សាំជីធម្មជាតិដែលមានគុណភាពខ្ពស់ ហើយស្រវាចាប់យកជីគីមីដែលមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ខ្លួន និងអាយុជីវិតនៃអ្នកប្រើប្រាស់ផលិតផលកសិកម្ម ។ សំលៀកបំពាក់ Levis Jeans និងស្បែកជើង Nike atheletic ជាដើម បានឈានជើងមកដល់កម្ពុជា ។ សំលៀកបំពាក់មួយសំរាប់មានតំលៃខ្ពស់ជាងច្រើនដង បើប្រៀបធៀបនឹងបៀវត្សដែលរកបានក្នុងមួយខែ ។ ឯការដើរចូលក្នុងសណ្ឋាគារ ខារ៉ាអូខេ ឬផ្ទះសំណាក់ខារ៉ាអូខេ បានក្លាយជាបញ្ហាសាមញ្ញនៅតាមទីក្រុង ជាយក្រុង និងទីរួមខេត្តនានា ។ ការភ្នាល់កីឡាប្រដាល់ និងកីឡាបាល់ទាត់ដែលមានទឹកប្រាក់រាប់ម៉ឺនដុល្លារក្នុងមួយសប្តាហ៍ត្រូវបានប្រព្រឹត្តនៅក្នុងទីក្រុងភ្នំពេញ ។

សភាពការណ៍នេះកំពុងជំរុញឱ្យប្រជាជនខ្មែរបោះបង់ចោលបន្តិចម្តងៗនូវវប្បធម៌បូរាណរបស់ខ្លួន ដោយឈោងចាប់ពហុវប្បធម៌ដែលកំពុងលុកលុយក្នុងសតិអារម្មណ៍របស់ជាតិ ។ ប្រជាជនមួយចំនួនធំយល់ថា មានប្រាក់គឺមានអ្វីៗទាំងអស់ ។ សព្វថ្ងៃ មានក្មេងជំទង់ និងយុវជនរាប់ម៉ឺននាក់ដែលកំពុងរស់នៅក្នុងបរិស្ថាននៃអ្នកមានពហុប្រព័ន្ធផ្សព្វផ្សាយ ។ ពួកគេមានលក្ខណៈរួមដូចគ្នា មានចំណង់ចំណូលចិត្តប្រហាក់ប្រហែលគ្នា និងមានទំនោរងាកចេញពីប្រពៃណីដូចគ្នា ។ គេកំពុងតែច្រានចោលកត្តាសកម្មនៃប្រពៃណីជាតិ ហើយស្រវាយកដោយសេចក្តីពេញចិត្តនូវកត្តាអកម្ម នៃវប្បធម៌ដែលហូរចូលមកពីខាងក្រៅ ដូចជា ៖

- ការលែងស្តាប់ដំបូន្មានឪពុកម្តាយ
- ការប្រើសំលៀកបំពាក់តាមទំនើងចិត្ត
- ការតុបតែងខ្លួន

- ការស្វែងរកដៃគូដើរកំសាន្ត
- ការពន្លត់កូនមុនមានអាពាហ៍ពិពាហ៍ពេញច្បាប់
- ការផ្លាស់ប្តូរសង្សារពីមួយទៅមួយ
- ការសំដែងសិល្បៈមួយចំនួន ដែលមិនគិតពីអត្ថន័យ នៃជីវិតប្រជាជន
- ការបំរើក្នុងភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ និងការបំរើសេវាផ្លូវភេទ
- ពាក្យសំដីចំអេសចំអាសលេងសើចបែរតំរង់ទៅរកសេចក្តីស្នេហាដើម្បីប្រាក់
- .... ល .... ។

កត្តាទាំងអស់នេះបង្ហាញឱ្យឃើញថា យើងកំពុងរត់តាមកំលាំងសម្ពារៈដែលជាផលិតផលនៃសាកលភាវូបនីយកម្មផ្សព្វផ្សាយ ដោយឥតបានប្រើវិចារណញ្ញាណថា ត្រូវទទួលយកអ្វី និងត្រូវបដិសេធអ្វីឡើយ ។ ការផ្សាយពាណិជ្ជកម្មបារីជាឧទាហរណ៍មានលក្ខណៈផ្ទុយស្រឡះពីវេជ្ជបញ្ហា ។ ដោយផ្អែកលើវិទ្យាសាស្ត្រវេជ្ជបណ្ឌិតអះអាងថា បារីបណ្តាលឱ្យខូចសុខភាព ។ ផ្ទុយទៅវិញ ដោយផ្អែកលើការបង់ពន្ធក្នុងការផ្សាយ អ្នកនាំពាក្យអះអាងថា បារីនាំឱ្យមានបញ្ញាភ្លឺថ្លា ។ ចំពោះបញ្ហាបារីតែមួយ ក្នុងពេលតែមួយមានការផ្សាយពីរបែបផ្ទុយគ្នា ពោលគឺ បារីបំផ្លាញសុខភាពផង និងបារីនាំឱ្យមានបញ្ញាភ្លឺថ្លាផង ។ គំនិតទីពីរជាគំនិតក្បត់វិទ្យាសាស្ត្រ ។ គេដឹង ! តែគេនៅតែបំពាន ព្រោះគេខ្លាចប្រាក់ ។ អ្នកមានខ្លះ គ្រាន់តែឃើញការផ្សាយម៉ូតសំលៀកបំពាក់នៅតាមទូរទស្សន៍នៃប្រទេសជិតខាងភ្លាម ក៏ប្រញាប់ប្រញាល់ទៅឱ្យជាងកាត់ដេរកាត់តាមម៉ូតសំលៀកបំពាក់នោះ តែក្នុងរយៈពេល ២ ឬ៣ ម៉ោងប៉ុណ្ណោះ ។ រីឯអ្នកក្រខ្លះរត់តាមបញ្ហានេះដែរ ព្រោះកុំឱ្យចាញ់អ្នកមានពេក ។ យុវជន និងក្មេងជំទង់នៅតាមទីក្រុង ក៏ដូចជានៅតាមជនបទមិនមានចំណូល

ចិត្តចំពោះការរាំវង់ រាំក្បាច់ រាំសារ៉ាវ៉ាន់ទេ គេចូលចិត្តអ្វីដែលហៅថា ការរាំញាក់រាំញាក់មិនត្រូវជ្រុង មិនដូចប្រភពដើម ។ នេះជាការរត់តាមគ្នាពីភូមិមួយទៅភូមិមួយ ពីស្រុកមួយទៅស្រុកមួយ ពីខេត្តមួយទៅខេត្តមួយដែលខ្វះចំណាត់តាំង ខ្វះការអប់រំដែលមានលក្ខណៈជាប្រព័ន្ធ ។

ម្យ៉ាងទៀតក្នុងការអប់រំ និងបណ្តុលបណ្តាះធនធានមនុស្ស គេច្រើនតែនិយាយថា ត្រូវរត់តាមសេដ្ឋកិច្ចទីផ្សារសេរី ។ ប៉ុន្តែគេភ្លេចនិយាយថា ត្រូវបង្កើនកត្តាសកម្មនៃសេដ្ឋកិច្ចទីផ្សារសេរី និងបន្ថយកត្តាអសកម្មរបស់វាទេ ។ ហេតុនេះធនធានមនុស្សដែលគេផលិតបានច្រើន ច្រើនតែអ្នកមានចំណេះវិទ្យាសាស្ត្រដែលខ្វះសីលធម៌ ។ ទស្សនវិទូបស្ចិមប្រទេសម្នាក់បានពោលយូរមកហើយថា ៖ « *វិទ្យាសាស្ត្រខ្វះមនសិការជាការបំផ្លិចបំផ្លាញព្រលឹងមនុស្ស* » ( Scince sans conscience n'est que ruine de l'ame ) ។ ការណ៍នេះបានបង្កើតផលអាក្រក់ជាច្រើនផ្សេងៗទៀត ដូចជា អំពើពុករលួយ ការកេងប្រវ័ញ្ច ការជេរប្រមាថការប្រើអំពើហិង្សា ការប្រើអកប្បកិរិយាច្រងេងច្រងាង ដែលក្នុងគ្រួសារខ្លះស្ទើរក្លាយទៅជាវប្បធម៌ទៅហើយ ។

អង្គការ Human Development Report បានធ្វើរបាយការណ៍នៅឆ្នាំ១៩៩៧ ថា សាកលភាវូបនីយកម្មបានលើកគំរូនៃការប្រើប្រាស់សំភារៈផ្សេងៗដូចជា រថយន្តប្រណិត និងភេសជ្ជៈជាដើមកំពុងតែក្លាយជាជំនក់ចិត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សទូទៅ ។ គំរូនេះកំពុងតែបំផ្លាញផលិតផលក្នុងស្រុកដែលប្រជាជនក្រីក្រកំពុងតែពឹងពាក់ ។ លោក រ៉ូបែរតូ វែរហ្សូឡា ( Roberto Verzola ) សង្គមវិទូហ្វីលីពីនពោលថា ក្នុងរយៈពេល ១០០ ឆ្នាំមុន មានអាណានិគមនិយម តែឥឡូវមានសាកលភាវូបនីយកម្ម ។ សព្វថ្ងៃ សាជីវកម្មរួមបានចូលមកជំនួសអំណាចអាណានិគមនិយម ។ លោកគូសបញ្ជាក់ថា នៅក្នុងបណ្តាប្រទេសកំពុង

អភិវឌ្ឍន៍ សាជីវកម្មរួមត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ធនធានធម្មជាតិ ធនធានមនុស្ស និងទ្រព្យសម្បត្តិជាតិ ។ ពួកគេប្តូរទីកន្លែងកសិករពីដីស្រែ ប្តូរទីកន្លែងកម្មករពីមុខរបរ និងប្តូរទីកន្លែងសហគមន៍ពីឫសគល់របស់វា ។ ពួកគេត្រូវទទួលខុសត្រូវចំពោះការបែកបាក់សហគមន៍ និងការបំផ្លិចបំផ្លាញបរិស្ថាន ដើម្បីបំរើដល់តំរូវការសំភារៈដើម និងមនុស្សដែលជាផលិតផលសំរាប់ផ្សាររួម ។ ផលវិបាកដែលប្រជាជនក្រីក្របានទទួល គឺអសន្តិសុខខាងម្ហូបអាហារ និងវិបត្តិបរិស្ថានដែលថ្ងៃក្រោយអាចអាក្រក់ជាងរបបអាណានិគមននិយមទៀតផង ។

ការរៀបរាប់ខាងលើនេះ មិនមែនជាការបដិសេធចំណុចល្អ នៃសាកលភាវូបនិយកម្មទេ ។ សាកលភាវូបនីយកម្មក៏មានចំណុចល្អរបស់វាដែរ ។ សាកលភាវូបនីយកម្មបច្ចេកវិទ្យាពិតជាធ្វើឱ្យពិភពលោករីកចំរើន ។ ប៉ុន្តែ របបបច្ចេកាធិបតេយ្យដែលយកបច្ចេកទេសទៅធ្វើនយោបាយមិនបានបំរើសង្គមមនុស្សឡើយ ។ វាគ្រាន់តែជារបបមួយដែលបំរើអ្នកមានមួយចំនួនតូចប៉ុណ្ណោះ ។

នៅចំពោះមុខសភាពការណ៍បែបនេះ ដើម្បីរក្សាតំលៃដើមរបស់ខ្លួន វប្បធម៌ខ្មែរត្រូវស្ថិតនៅក្នុងសតិអារម្មណ៍ប្រជាជនកម្ពុជាគ្រប់រូប ។ វាត្រូវតែស្តែងឡើងតាមរយៈសកម្មភាពប្រចាំថ្ងៃ ដូចជាតាមរយៈពាក្យសំដី ឥរិយាបថ ពិធីបុណ្យ និងសំលៀកបំពាក់ជាដើម ។ សំលេងខ្លុយអាចពិរោះដល់ត្រចៀកមនុស្សចាស់ តែអាចមិនពិរោះដល់ត្រចៀកយុវជន ។ ប៉ុន្តែ ទោះពិរោះក្តី ឬមិនពិរោះក្តី ក៏គួរតែក្រអៅបេះដូងរបស់មនុស្សខ្មែរត្រូវបានជ្រួតជ្រាបដោយសំលេងខ្លុយខ្មែរ ប្រសិនបើមិនចង់ឱ្យសំលេងខ្លុយនោះរលាយសាបសូន្យ ។ យើងនឹងបាត់បង់សម្បត្តិវប្បធម៌ហួលជ្រលក់ល័ក្ខខ្មែរដែលខ្មែរបានធ្វើសំភារៈដើមដោយខ្លួនឯង ប្រសិនបើយើងមិនរិះរកមធ្យោបាយឧបត្ថម្ភអ្នកត្បាញហូលទេ ។

## IV . ការប្រលងប្រណាំងដើម្បីជោគជ័យទាំងអស់គ្នា

យើងបានរស់នៅរាប់សតវត្សមកហើយ ដែលមុជចូលជ្រៅទៅក្នុងវប្បធមិសង្គ្រាម ក្នុងវប្បធមិដែលហេតុផលនៃកំលាំងបាយឈ្នះលើកំលាំងនៃហេតុផល ។ គឺមិនមែនជាការពន្យល់ឱ្យយល់ទេ តែជាការយកឈ្នះ ។ ឈ្នះដោយសារយើងប្រើគ្រប់មធ្យោបាយ ។ តើយើងទទួលផលចំណេញអ្វីខ្លះ ? តាមការពិត នោះជាហេតុផលមួយដែលបញ្ជាក់ថា យើងខាតបង់ទាំងអស់គ្នា ។ ទាំងអស់គ្នាសុទ្ធតែខាតបង់ ។

យើងបានចំណាយរាប់សតវត្សមកហើយនូវថ្លៃសង្គ្រាម និងជីវិតមនុស្សដែលជាតំលៃខ្ពស់បំផុត ។ ឥឡូវនេះ យើងត្រូវចេះចំណាយថ្លៃសន្តិភាពម្តងវិញ ។ ប៉ុន្តែ តើយើងត្រូវធ្វើយ៉ាងណានៅចំពោះមុខសាកលភាវូបនីយកម្មនេះ ?

ពិតណាស់ សាកលភាវូបនីយកម្ម និងទំនើបភាវូបនីយកម្ម បានធ្វើឱ្យពិភពលោកមានការរីកចំរើន ។ វាបានរួមចំណែកលើកតំកើងស្តង់ដារួមសំរាប់មនុស្សជាច្រើន លើកតំកើងការប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ។ ប៉ុន្តែនៅក្នុងដំណើររបស់វា សាកលភាវូបនីយកម្ម និងទំនើបភាវូបនីយកម្មមានជ្រុងអាក្រក់ជាច្រើនដូចជាការចុះថយខាងសីលធមិជាដើម ។ ឯប្រព័ន្ធសង្គមដែលធ្លាប់មានរបៀបរៀបរយកំពុងក្លាយជាប្រព័ន្ធសង្គមដែលខ្វះរបៀបរៀបរយវិញ ។ ចលាចលសង្គម និងអំពើពុករលួយ ដែលរត់តាមកំលាំងសំភារៈសុទ្ធសឹងជាកូនបង្កើតរបស់វា ។

នៅក្នុងស្ថានភាពបែបនេះ យើងត្រូវប្រលងប្រណាំងដើម្បីឆ្លើយតបចំពោះឱកាសថ្មីសំរាប់ការលេចឡើងនៃវប្បធមិរបស់ប្រជាជាតិនានាលើសាកលលោក ។ ដោយសារការលេចឡើងនៃវប្បធមិនោះ អត្តសញ្ញាណ នៃប្រជាជាតិនានាអាចត្រូវបានធានាខាងផ្លូវកាយ និងត្រូវបានលើកកំពស់ខាងសោភណភាពទាំងបុគ្គល

និងសង្គមទាំងនៅក្នុងប្រទេស និងក្នុងពិភពលោក ។ យើងប្រឡងប្រណាំងដើម្បីធ្វើឱ្យន័យនៃអត្តសញ្ញាណសីលធម៌មានវឌ្ឍនភាព ដោយស្ថិតនៅក្នុងបរិបទពហុវប្បធម៌ ដែលក្នុងនោះភាពផ្សេងគ្នា និងពហុភាពមានកំលាំងច្រើន ហើយពន្លឺសហប្រតិបត្តិការមានកំលាំងជាងការរុជអាលឱ្យមានជម្លោះ ។ យើងប្រឡងប្រណាំងដើម្បីឱ្យបុគ្គល និងប្រជាជាតិទាំងអស់រីកចំរើននៅក្នុងបរិបទពិភពលោកថ្មី និងជៀសវាងយ៉ាងណាកុំឱ្យមានសង្គ្រាមកើតឡើង ។

លោក សាង ហ្ស៊ីនហាន ( Sang Jin Han ) ពោលថា : « *សេដ្ឋកិច្ចនៅសតវត្សទី ២១ ត្រូវបានធ្វើនិទស្សន៍ទុកជាមុនថា ជាសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ។ គេបានទាយទុកមុនផងដែរថា សេដ្ឋកិច្ចផ្អែកលើពុទ្ធិនោះមានស្ថេរភាព និងមានលក្ខណៈរស់រវើក* » ( ៤ - ទំព័រទី១៤ ) ។ ទិដ្ឋភាពនៃសេដ្ឋកិច្ចផ្អែកលើពុទ្ធិ គឺការពង្រឹងសារៈប្រយោជន៍នៃមូលធនមនុស្ស ។ អ្វីដែលមានលក្ខណៈសារវន្ត ដើម្បីការរីកចំរើននៃសេដ្ឋកិច្ចនាសតវត្សទី២១ គឺមិនមែនមូលធនមនុស្សដែលមានអំណាចខាងកំលាំងបាយទេ តែជាមូលធនមនុស្សដែលមានបញ្ញាច្នៃប្រឌិត ។

ទន្ទឹមនោះដែរ យើងគួររំលឹកឡើងវិញនូវគ្រោះថ្នាក់ដែលគួរជៀសវាង ។ គ្រោះថ្នាក់ធ្វើឱ្យសង្គមមួយឃ្លាតឆ្ងាយពីអតីតកាលរបស់ខ្លួន គឺខុសពីលក្ខណៈពិសេសដំបូងនៅក្នុងអរិយធម៌ឧស្សាហកម្មទំនើប ។ គ្រោះថ្នាក់មានពីរបែបសំខាន់គឺ គ្រោះថ្នាក់ដែលកើតឡើងដោយធម្មជាតិ និងគ្រោះថ្នាក់ដែលកើតឡើងដោយមនុស្សផ្ទាល់ ។ ការខុសគ្នារវាងគ្រោះថ្នាក់ទាំងពីរបែបនេះមានដូចខាងក្រោម :

- នៅក្នុងវប្បធម៌បុរាណ និងនៅក្នុងសង្គមឧស្សាហកម្មដំបូង មនុស្សមានការភ័យព្រួយចំពោះគ្រោះថ្នាក់ដែលកើតឡើងដោយធម្មជាតិខាងក្រៅ ដូចជាការមិនបានប្រមូលផល ទឹកជំនន់ ជំងឺរាតត្បាត និងទុរ្ភិក្សជាដើម ។ នេះហើយហៅថា គ្រោះថ្នាក់ដែលធម្មជាតិខាងក្រៅបានប្រព្រឹត្តមកលើសង្គមមនុស្ស ។

• សព្វថ្ងៃ នៅក្នុងករណីមួយចំនួន យើងមិនសូវព្រួយបារម្ភអំពីអ្វីដែលធម្មជាតិបានប្រព្រឹត្តមកលើយើងទេ តែយើងគួរព្រួយបារម្ភយ៉ាងខ្លាំងអំពីអ្វីដែលយើងបានប្រព្រឹត្តទៅលើធម្មជាតិវិញ ។ នេះហើយហៅថា គ្រោះថ្នាក់ដែលមនុស្សបានប្រព្រឹត្តទៅលើធម្មជាតិ ។

ក្នុងការប្រៀបធៀបនេះ យើងឃើញថា សព្វថ្ងៃ មានការឆ្លងកាត់ពីឧត្តមានុភាពនៃគ្រោះថ្នាក់ដែលបង្កឡើងដោយធម្មជាតិមកលើសង្គមមនុស្ស ទៅដល់ឧត្តមានុភាពនៃគ្រោះថ្នាក់ដែលបង្កឡើងដោយសង្គមមនុស្សទៅលើធម្មជាតិវិញ ។ គ្រោះថ្នាក់ទី ២ នេះ តែងធ្វើឱ្យវប្បធម៌នៃប្រទេសនីមួយៗរង្គោះរង្គើរហូតដល់បាត់បង់សញ្ញាណដើមរបស់ខ្លួន ប្រសិនបើយើងមិនប្រុងប្រយ័ត្ន ។

នៅចំពោះមុខគ្រោះថ្នាក់ខាងលើ យើងដែលជាពលរដ្ឋកម្ពុជាគួរពង្រឹងពង្រីកបន្ថែមទៀតនូវសហប្រតិបត្តិការ ដើម្បីអភិវឌ្ឍវិស័យវប្បធម៌នៃប្រទេសនីមួយៗ ដោយរក្សាធាតុដើមរបស់ខ្លួនផង និងអាចរស់នៅក្នុងពហុវប្បធម៌ផង ។ ការពង្រឹងឆន្ទៈអត្តនោម័ត និងប្រើអំណាចទាំងកំរោល ដើម្បីលុបបំបាត់កត្តាអសកម្មនៃវប្បធម៌បរទេស ឬ « វប្បធម៌ពាណិជ្ជអាវាសែ » មិនអាចប្រព្រឹត្តទៅបានទេ ។ បញ្ហាសំខាន់ គឺការអប់រំឱ្យខ្មែរភ្ញាក់រឭកឡើងវិញតាមរយៈការពង្រឹងវិន័យសីលធម៌ តាមរយៈការសំដែងសិល្បៈ តាមរយៈប្រលោមលោកជាដើម ។

ការទប់ស្កាត់ចំណូលចិត្តដែលមិនសមស្រប ដែលបំផ្លិចបំផ្លាញប្រពៃណីជាតិ ដូចជាគំនិតដែលអះអាងថា : « កូនធំហើយ ម៉ែឪមិនបាច់ណែនាំច្រើនពេកទេ » « កុំទូលផែនដីម្នាក់ឯង » « សម័យនេះជាសម័យយន្តហោះ មិនមែនជាសម័យរទេះគោទៀតទេ » « មានលុយគឺមានអ្វីៗទាំងអស់ » « បើមាត់ហោប៉ៅនៅខាងលើលុយជាបញ្ហាធំបងបំផុត » ... មានអត្ថន័យយ៉ាងសំខាន់សំរាប់ឱ្យវប្បធម៌របស់យើងមានអត្ថិភាពរឹងមាំជាមួយនឹងពហុវប្បធម៌ ដែលឈានចូលមកពីខាងក្រៅ ។

កូនធំកូនតូចសុទ្ធតែមានសិទ្ធសេរីភាព តែការប្រើសិទ្ធិសេរីភាពមិនអាចឃ្លាតឆ្ងាយពីការទូន្មាន ការណែនាំរបស់ម៉ែ ឪ ឡើយ ។ របៀបរស់នៅតាមសម័យយន្តហោះ ជាកត្តាសំខាន់ តែក៏មិនគួរបំភ្លេចរបៀបរស់នៅតាមបែបរទេះគោដែរ ។ ប្រាក់ជាកត្តាចាំបាច់សំរាប់ជីវិតប្រចាំថ្ងៃ តែមិនគួរចាត់ទុកប្រាក់ជាចៅហ្វាយរបស់ខ្លួនឡើយ ។

## IV . សេចក្ដីសន្និដ្ឋាន

ប្រទេសនីមួយៗមានវប្បធមិដោយឡែករបស់ខ្លួន ។ ជនជាតិនីមួយៗមានវប្បធមិដោយឡែករបស់ខ្លួន ។ នៅក្នុងប្រទេសមួយដែលមានសញ្ជាតិច្រើនក៏មានវប្បធមិច្រើនដែរ ។ ដើម្បីរួមរស់ជាមួយគ្នាបាន ជនជាតិទាំងនោះត្រូវទទួលស្គាល់ភាពដោយឡែកផង និងទទួលស្គាល់ភាពរួមផង ។

នៅក្នុងពិភពលោកដែលមានប្រជាជាតិដ៏ច្រើន ពហុវប្បធមិកំពុងតែឆ្លងកាត់គ្នាទៅវិញទៅមក ។ វប្បធមិបស្ចឹមប្រទេសកំពុងទន្រ្ទានចូលមកក្នុងប្រទេសដទៃទៀត តែទោះបីតិច ឬច្រើន បស្ចឹមប្រទេសក៏ទទួលឥទ្ធិពលវប្បធមិនៃប្រទេសដទៃវិញដែរ ។ ការឆ្លងគ្នារវាងវប្បធមិ និងវប្បធមិជាកត្តាបវានុម័តនៅក្នុងយុគសម័យសាកលភាវូបនីយកម្មនេះ ។

ដំណើរសាកលភាវូបនីយកម្ម ដែលកំពុងមានវិសាលភាពទូលំទូលាយតែងមានជ្រុងល្អ និងជ្រុងអាក្រក់របស់វា ។ សេចក្ដីក្លាហាននៃប្រជាជាតិនីមួយៗក្នុងការបន្ថយឥទ្ធិពលនៃជ្រុងអាក្រក់របស់វាពិតជាធ្វើឱ្យវប្បធមិរបស់ខ្លួនរស់នៅប្រកបដោយលក្ខណៈថ្មៃប្រឌិត ។ ប៉ុន្តែ ការបន្ថយឥទ្ធិពលនៃជ្រុងអាក្រក់នោះ ត្រូវតែប្រព្រឹត្តទៅក្រោមវិចារណញាណប្រកបដោយវិធីវិទ្យាសាស្ត្រ ។ កង្វះវិធីវិទ្យាសាស្ត្រ កង្វះបញ្ញា ប្រមូលផ្ដុំសំរាប់ដំណោះស្រាយតាមជំហាននីមួយៗ អាចបណ្ដាលឱ្យវប្បធមិខ្មែរលិចបាត់បន្តិចម្ដងៗ ។

ពលរដ្ឋម្នាក់ៗ ត្រូវមានសេចក្ដីទទួលខុសត្រូវដូចដែល ហ្សង់ ប៉ូលសាត្រ

(Jean Paul Sartre) បានអះអាងថា : « *មនុស្សទទួលខុសត្រូវគ្រប់នាទី ។ មនុស្សទទួលខុសត្រូវអ្វីៗទាំងអស់នៅចំពោះមុខអ្នកទាំងអស់គ្នា ។ គេរែកពុន ពិភពលោក ទាំងមូលនៅលើស្មារបស់គេ* » ( L'homme est responsable à toute minute. Il est responsable de tout devant tous. Il porte le poids du monde entier sur ses épaules ) ( ៦ _ ទំព័រទី ១៤១ ) ។

## ឯកសារពិគ្រោះ


1 - Anthony Giddens : *Runaway world,* Profile Books Ltd. London 1999

2 - Philip.G. Cersy : *Globalization and other stories:* The reach for a new paradigm for international relations, International Journal, Volume II N· 4, Autumn-1996.

3 - Robert O. Keohane and Joseph S.Nye Jr : *Globalization:* What 's new? What's not ? (And so What?) Sprint,2000-3/23/2000,

4 - Sang Jin Han : *Economy and Human Resources in the 21st century* (the Academy of Korean study) (no date)

5 - Shapour Rassekh : *Education et Culture de la Paix,* IBE data UNESCO, 1996

6 - Jacqueline Russ : *Histoire de la philosophie de Socrare à Foucault,* Hatier, Paris, 1985

# ស្មារតីខ្មែរ និងព្រះពុទ្ធសាសនា

( ត )

ដោយអ្នកស្រី **ខ្លូត ធីតា**
បណ្ឌិតទស្សនវិជ្ជា

## ៤ . ការវិវត្ត នៃលទ្ធិព្រះពុទ្ធសាសនានៅកម្ពុជា

រួចមកហើយយើងឃើញថា ព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើងតាំងពីសតវត្សទី៣ មុន គ.ស ម្ល៉េះ សាសនានេះបានចាក់ឫស ព្រមទាំងមានការវិវត្តរបស់ខ្លួនតាំងពីពេលនោះរហូតមក ហើយមកដល់សព្វថ្ងៃនេះនៅតែមានអត្ថិភាព និងមានការរីកចំរើនរបស់ខ្លួនយ៉ាងរឹងមាំ [១] ។

ការវិវត្តនៃលទ្ធិព្រះពុទ្ធសាសនានៅកម្ពុជា បានធ្វើឱ្យយើងកាន់តែយល់ច្បាស់តាមដំណាក់កាលនៃប្រវត្តិសាស្ត្រនីមួយៗ ។ ព្រះពុទ្ធសាសនាមានឥទ្ធិពលខ្លាំងទៅលើស្ថាប័នទាំងឡាយ នៃសង្គមខ្មែរយើង ។ ប៉ុន្តែ ទន្ទឹមនឹងការសិក្សាពីការវិវត្តនៃលទ្ធិព្រះពុទ្ធនេះ ចាំបាច់ក៏យើងត្រូវតែសិក្សាពីការវិវត្តខ្លះៗ នៃលទ្ធិព្រហ្មញ្ញសាសនាផងដែរ ព្រោះថាសាសនាទាំងពីរនេះសឹងតែមានវត្តមាន និងរីកចំរើន

---

(១) លោកបណ្ឌិត ឆ សេង ព្រះពុទ្ធសាសនា និងសង្គមខ្មែរ ភ្នំពេញ ១៩៩៤ ទំព័រ ៥២

ប្រហាក់ប្រហែលគ្នាដែរ ។ ពេលគឺពេលខ្លះព្រះពុទ្ធសាសនា រីកចំរើនជាងពេលខ្លះព្រហ្មញ្ញ សាសនារីកចំរើនជាង ឬផ្ទុយទៅវិញអាស្រ័យចំណង់ចំណូលចិត្តថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋ ។ ពេលខ្លះ គេសង្កេតឃើញសាសនាទាំងពីរនេះហាក់រលាយចូលគ្នា ពេលខ្លះហាក់មានទំនាស់គ្នាគួរសមដែរ ។

ខាងក្រោមនេះ យើងសូមលើកយកការវិវត្ត នៃលទ្ធិព្រះពុទ្ធ ( ព្រះពុទ្ធសាសនា ) មកធ្វើការសិក្សា តាមដំណាក់កាលនីមួយៗ ដូចខាងក្រោមនេះ ។

*ក . សម័យបុរេប្រវត្តិសាស្ត្រ*

នៅសម័យបុរេប្រវត្តិសាស្ត្រ មុនសតវត្សទី១ នៃ គ.ស ព្រះពុទ្ធសាសនា បានចូលមកដល់ប្រទេសកម្ពុជាយើងហើយ តែការវិវត្ត និងការរីកចំរើនយ៉ាងណា នោះយើងពុំអាចដឹងបានច្បាស់លាស់ទេ ព្រោះយើងពុំអាចរកឃើញឯកសារ ឬការកំណត់ណាមួយដែលយើងអាចវាយតំលៃ ឬធ្វើការសន្និដ្ឋានបានឡើយ ព្រោះឯក-សារទាំងនោះបានបាត់បង់តាមសម័យកាល ។ ទោះយ៉ាងណាក៏ដោយ ក៏យើងសន្និដ្ឋានថា ព្រះពុទ្ធសាសនា នៃសម័យបុរេប្រវត្តិសាស្ត្រនេះគឺជាពន្លកត្រួយទ្រទ្រង់ជំរុញការវិវត្ត នៃសម័យកាលក្រោយៗទៀត ។

នៅសម័យបុរេប្រវត្តិសាស្ត្រ មុនសតវត្សទី១ នេះ ឯកសារខ្លះបញ្ជាក់ថា ជនជាតិខ្មែរយើងគោរពព្រះពុទ្ធសាសនាបែបនិកាយថេរវាទ ( ហីនយាន ) ហីនយានបុរាណ ។

*ខ . សម័យនគរភ្នំ*

ពីសតវត្សទី១ រហូតដល់ពាក់កណ្តាលសតវត្សទី៦ ការវិវត្តនៃលទ្ធិព្រះពុទ្ធសាសនានៅសម័យនេះ យើងបានពឹងផ្អែកទៅលើសិលាចារឹកបដិមាករ និងឯកសារចិន គេបានមកតាមរយៈកំណត់ហេតុកត់ត្រារបស់ជនជាតិចិនឈ្មោះ **កាំង ថៃ** និង **ចូ យីង** ដែលគេបានមកទស្សនាប្រទេសកម្ពុជាយើង នៅសម័យនគរភ្នំគឺ ពាក់

កណ្ដាលសតវត្សទី៣ នៃ គ.ស ។

ផ្អែកលើកាកសំណល់ និងរូបបដិមាករ ដែលគេបានរកឃើញនៅ កំពង់ផែអូកែវ ជាកំពង់ផែដ៏ល្បីល្បាញមួយរបស់ខ្មែរនៅសមុទ្រនៃប្រទេសនគរភ្នំ ត្រង់ឈូងសមុទ្រថៃសព្វថ្ងៃ ។ កំពង់ផែអូរកែវនេះ ជាកំពង់ផែអន្តរជាតិរបស់ខ្មែរ ដែលមានលក្ខណៈងាយស្រួលក្នុងការស្រូបយកអ្នកដំណើរសមុទ្រពីបណ្ដាប្រទេសជិតខាងនៅលើសកលលោក ។ ទីនេះមានទំនាក់ទំនងពាណិជ្ជកម្មជាមួយបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ ជាមួយកំពង់ផែនៅប្រទេស ឥណ្ឌា ប្រទេសអ៊ីរ៉ង់ និងបណ្ដាកំពង់ផែនៅតាមសមុទ្រ មេឌីទែរ៉ាណេ នាសម័យនោះផង ។ ដោយសារភាពងាយស្រួលរបស់កំពង់ផែនេះ ជនជាតិខ្មែរយើងធ្លាប់បានទំនាក់ទំនងជាមួយជនជាតិផ្សេងៗ ព្រមទាំងបានទទួលវប្បធម៌របស់បណ្ដាប្រទេសផ្សេងៗទាំងនោះទៀតផង ។

ដោយសារមូលហេតុនេះ ទើបប្រទេសកម្ពុជាយើងត្រូវបានគេហៅថាជាទីប្រជុំជននៃសិល្បៈ ( Le Camboge est le carrefour des Arts ) ។ វត្ថុតាងច្រើនទៀតដែលគេបានឃើញនៅកំពង់ផែអូកែវនេះ មានកាកសំណល់ផ្សេងៗ ដូចជាព្រះពុទ្ធរូប រូបិយវត្ថុជាតិ រ៉ូម៉ាំង ជាតិឥណ្ឌា និងតួអក្សរព្រហ្មី ។ ផ្អែកលើសិលាចារឹកនៅ វ៉ូកាញ់ ( ញ៉ាត្រាង ) ក្នុងប្រទេសវៀតណាមសព្វថ្ងៃ យើងសង្កេតឃើញថា ព្រះពុទ្ធសាសនាបានរីកចំរើនយ៉ាងខ្លាំងក្នុងរាជ្យព្រះបាទ **ហ្វាន់ម៉ឹន** គឺព្រះបាទ **ស្រីមារៈ** នាសតវត្សទី២ នៃ គ.ស ។ តាមអត្ថន័យនៃសិលាចារឹកនេះបញ្ជាក់ថា ព្រះរាជាប្រទេសនគរភ្នំក្នុងគ.សទី២ ព្រះនាមស្រីមារៈពិតជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភដ៏មហិមាមួយអង្គយ៉ាងឆ្នើម ។ ព្រះអង្គត្រាស់បង្គាប់ឱ្យចារឹកទុកដើម្បីអនុស្សាវរីយ៍ ។ រាជត្រកូលបរមវង្សជ្រះថ្លាចំពោះព្រះពុទ្ធសាសនាយល់ច្បាស់នូវគតិ ដំណើរអន្ទោលស្លាប់នៃសត្វលោកក្នុងវដ្ដសង្សារតាមបែបព្រះពុទ្ធសាសនាទ្រង់ប្រកបដោយមេត្តាករុណាចំពោះសត្វលោក ហើយត្រាស់បង្គាប់ឱ្យបរិច្ចាក

ព្រះរាជ្យទ្រព្យផ្ទាល់ព្រះអង្គធ្វើទានទុកជាសារៈប្រយោជន៍ទៀតផង ។ ទីបំផុតព្រះអង្គផ្តាំទុកថា « សូមព្រះរាជាសោយរាជ្យតំណទៅមុខទៀតឱ្យប្រតិបត្តិតាមព្រះរាជប្រកាសនេះ ដើម្បីប្រយោជន៍ធំដល់សត្វលោក » ។

តាមឯកសារចិន នៃព្រះរាជវង្ស ត្សី ( Tsi ) បានដំណាលថា ក្នុង ព.ស ទី១១ នៃគ.សទី៥ មានព្រះរាជានគរភ្នំមួយព្រះអង្គព្រះនាម **កៅ ជេដូ** ឬ **ចូ យេប៉ាម៉ូ** ( ហៅតាមភាសាចិន ) គឺព្រះបាទ **កៅណ្ឌិន្យជ័យវរ្ម័ន** ឬ **កោណ្ឌញ្ញជ័យវរ្ម័ន** ។ កាលដើមឡើយព្រះរាជអង្គនេះ គោរពសាសនាព្រាហ្មណ៍ តែក្រោយមកព្រះអង្គទ្រង់គោរពព្រះពុទ្ធសាសនាវិញ ។ ព្រះអង្គទ្រង់បានបញ្ជូនភិក្ខុ **សាក្យ នាគសេន** ជាតិឥណ្ឌាឱ្យទៅកាន់ក្រុងចិនប្រមាណគ.ស ៤៨៤ ដោយមានទាំងដង្វាយទៅថ្វាយស្តេចក្រុងចិនព្រះនាម **វូ ធីជេ** ។ ព្រះសង្ឃអង្គនេះបានថ្វាយពតិមានដល់ព្រះចៅក្រុងចិនពីស្ថានភាពប្រទេសនគរភ្នំ និងពីសាសនាដែលមានការរីកចំរើននៅក្នុងនគរភ្នំ ។ នេះមានន័យថា ប្រជាពលរដ្ឋខ្មែរគោរពព្រះ-ពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង តែព្រះពុទ្ធសាសនារីកចំរើនរុងរឿងណាស់ដោយមានភិក្ខុសាមណេរយ៉ាងច្រើនក្រៃលែង ហើយការប្រតិបត្តិតាមពុទ្ធវចនៈយ៉ាងរឹងតឹង ហើយប្រពៃ ៗណាស់ទៀត ។ ពេលព្រះភិក្ខុ **សាក្យ នាគសេន** ត្រឡប់មកវិញព្រះចៅក្រុងចិន បានសុំផ្ញើដង្វាយជាច្រើនមកថ្វាយព្រះចៅនគរភ្នំវិញ ។ នេះដោយព្រះសង្ឃខ្មែរយើងបានគោរពវិន័យព្រះពុទ្ធសាសនាបានល្អ ។

លោក **ត្រឹង ងា** ជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រខ្មែរម្នាក់ដ៏ជំនាញ ក៏បានបញ្ជាក់ឱ្យដឹងថា នៅសម័យនគរភ្នំនេះ ព្រះពុទ្ធសាសនាមានភាពរុងរឿង ជាពិសេសនៅសតវត្សទី៥.៦ ក្នុងរជ្ជកាលព្រះបាទ **កៅណ្ឌិន្យជ័យវរ្ម័ន** និង **រុទ្រវរ្ម័ន** ។ បើតាមឯកសារខ្លះទៀតថា នៅគ.ស ៥០៣ ព្រះបាទ **កៅណ្ឌិន្យជ័យវរ្ម័ន** ដែល

ទ្រង់បានបញ្ជូនរាជទូតឱ្យយកព្រះពុទ្ធរូបធ្វើពីផ្កាថ្មសមុទ្រ និងវត្ថុផ្សេងៗជាច្រើនទៀត ទៅថ្វាយស្តេចក្រុងចិន ព្រមទាំងបានបញ្ជូនភិក្ខុខ្មែរពីរអង្គទៀតគឺភិក្ខុ **សង្ឃបាល** មួយអង្គ និងភិក្ខុ **មន្ទ្រសេន** មួយអង្គ ដែលជាអ្នកប្រាជ្ញចេះត្រៃបិដក និងចេះបកប្រែភាសាបរទេសច្រើនភាសាឱ្យទៅប្រែត្រៃបិដក តាមការនិមន្តឱ្យទៅជួយប្រែរបស់ព្រះចៅក្រុងចិនព្រះនាម **ឡូ** នៃព្រះរាជវង្ស **លាង** ។ ភិក្ខុទាំងពីរអង្គនេះបានជួយទៅប្រែភាសារអស់ ១៦ ឆ្នាំ ហើយបានធ្វើការនៅ ៥ ការិយាល័យ ។

ក្នុង គ.ស ៥៣៩ មានព្រះមហាក្សត្រព្រះនាម **រុទ្រវរ្ម័ន** ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានប្រតិបត្តិតាមពុទ្ធោវាទយ៉ាងហ្មត់ចត់ ។ ក្នុងរជ្ជកាលនៃព្រះមហាក្សត្រអង្គនេះ ប្រទេសកម្ពុជាមានព្រះកេស ១ អង្គ ( ឬមួយសរសៃ ) ប្រវែង ៣ ម៉ែត្រ ជាព្រះបរមសារីរិកធាតុ ក្រោយពីបានដំណឹងនេះស្តេចចិនបានបញ្ជូនភិក្ខុ **ចេ-យុន-ប៉ាវ** ឱ្យតាមរាជទូតខ្មែរមកដណ្តើមព្រះបរមសារីរិកធាតុនោះយកបាត់រហូតទៅ[១] ។

ព្រះចៅក្រុងចិនមានការស្ងើចសរសើរយ៉ាងខ្លាំង ចំពោះព្រះសង្ឃជួយប្រែព្រះត្រៃបិដកបានសម្រេច ព្រមទាំងបានចាត់ទុកថា ជាព្រះគ្រូទៀតផង ។ សេចក្តីប្រែរបស់ព្រះថេរៈទាំងពីរព្រះអង្គនេះ មានសេសសល់រហូតមកដល់សព្វថ្ងៃនៃព្រះត្រៃបិដកចិន ។ ក្នុង ,ដែលសម្តេចព្រះបាទ **នរោត្តម សីហនុ** ទ្រង់ស្តេចយាងទៅប្រទេសចិននាឆ្នាំ ១៩៥៦ សមាគមពុទ្ធសាសនាចិន បានយកគម្ពីរនោះទៅថ្វាយព្រះអង្គទតមើល ដើម្បីបញ្ជាក់ថា មិត្តភាពរាប់អានគ្នារវាងខ្មែរ និងចិនមានអាយុតាំងពីជាង ១៥ ស.វ មកហើយ ។ ឆ្នាំ ១៩៦៦ សម្តេចសង្ឃរាជ **ហួត តាត**

(១) លោក ត៊ិន តាំណេកង ( បណ្ឌិតប្រវត្តិវិទ្យា ) ប្រវត្តិសាស្ត្រព្រះពុទ្ធសាសនានៅកម្ពុជា ភ្នំពេញ ១៩៩៨ ទំព័រ ៦៦

បាននិមន្តទៅចូលរួមសន្និបាទនៅទីក្រុង **កូឡុំបូ** ព្រះអង្គបានទទួលសៀវភៅដែលព្រះសង្ឃខ្មែរពីរអង្គបានបកប្រែនៅប្រទេសចិននោះដែរ ( តាមខ្ញុំដឹងផ្ទាល់ពីសម្តេច ហួត តាត នាឆ្នាំ ១៩៦៩ សន្ទនាព្រះធម៌ជាមួយខ្ញុំនាវត្តឧណ្ណាលោម ) ។

សរុបមកឃើញថា នៅសម័យនគរភ្នំ ព្រះពុទ្ធសាសនាមានការវិវត្ត និងរីកចំរើនយ៉ាងសន្ធឹកសន្ធាប់ណាស់ដែរ ។ ព្រះពុទ្ធសាសនានាសម័យនោះជាព្រះពុទ្ធសាសនាបែបហីនយាន និយមភាសាសំស្ក្រឹតដែលនាំចូលមកតាំងពីស.វទី៣ ឬទី២មុន គ.ស ដោយព្រះភិក្ខុ **សោណត្ថេរ** និង **ឧត្តរត្ថេរ** ។ មកដល់ពាក់កណ្តាលស.វ ទី៦ នៃការវាយលុករបស់ **ចេនឡា** មកលើអាណាចក្រនគរភ្នំព្រះពុទ្ធសាសនាហីនយានក៏នៅមានភាពរុងរឿងនៅឡើយ ។ លុះមកដល់ចុងស.វទី៧ នៃសម័យចេនឡាទើបចុះអានុភាពបន្តិចម្តងៗ ។ នៅសម័យនគរភ្នំ យើងសង្កេតឃើញមានសាសនាមួយទៀតមានការរីកចំរើនផងដែរ ដោយពុំគិតពីជំនឿដើមរបស់ជនជាតិខ្មែរយើងផងទេ គឺលទ្ធិសាសនាព្រាហ្មណ៍ ។ សាសនាព្រាហ្មណ៍ ត្រូវបានគេគោរពបូជាចំពោះ **ព្រះឥសូរ ព្រះវិស្ណុ** និង **ព្រះព្រហ្ម** ។ នៅខាងដើមសម័យនគរភ្នំ គណៈឥសូរនិយមទំនងជាមាឋានៈជាសាសនាផ្លូវការផង ដោយយោលទៅលើឯកសារចិន ដែលបញ្ជាក់ថា ព្រះរាជាតែងយាងឡើងលើភ្នំ **ម៉ូតាន** ដើម្បីបូជាចំពោះ **ព្រះមហេស្វរៈ** ( ព្រះឥសូរ ) យើងឃើញមានភស្តុតាងជាច្រើនដូចជាបដិមាវិស្ណុ និងអវតាជាច្រើននៅតំបន់ **ភ្នំដា** អង្គបុរីខេត្តតាកែវជាដើម ។ ទន្ទឹមនឹងនោះគេក៏សង្កេតឃើញមានព្រះពុទ្ធរូប និងទេវរូបជាច្រើនទៀតនៅតំបន់ភ្នំដានោះដែរ ។ នេះបញ្ជាក់ថា នៅសម័យនគរភ្នំមានសាសនាធំពីរ ដែលត្រូវប្រជាពលរដ្ឋខ្មែរយើងគោរពបូជា ប៉ុន្តែព្រះពុទ្ធសាសនាមានការរីកចំរើនជាង ។

*គ . សម័យចេនឡា*

សម័យនេះកើតនៅពាក់កណ្តាលសតវត្សទី៦ ដល់ចុងសតវត្សទី៨ ។ ចេនឡាជាឈ្មោះ សាមន្តរដ្ឋមួយរបស់ចក្រភពនគរភ្នំ ។ ការបះបោរនេះបានប្រតិបត្តិទៅក្រោមការដឹកនាំរបស់ក្សត្រព្រះនាម **ភវវរ្ម័ន** ជាបុត្ររបស់ **វីរវរ្ម័ន** និងជាចៅរបស់ព្រះបាទ **រុទ្រវរ្ម័ន** ។ ក្រោយពេល ដែលបានទទួលជ័យជំនះ ប្រទេសខ្មែរយើងនាពេលនោះបានប្រែឈ្មោះពីចក្រភពនគរភ្នំមកចេនឡាវិញ ។ ក្រោយមកទៀតនៅដើមស.វ ទី៨ ( រដ្ឋចេនឡានេះត្រូវបានបែកបាក់គ្នាជាពីរទៀត គឺ **ចេនឡាទឹកលិច** ឬ ( ដីទឹក ) និង **ចេនឡាដីគោក** ) ។ ចេនឡាទឹកលិច សំរាប់សំគាល់លើទឹកដីដែលនៅខាងក្រោមរាប់ពីល្បាក់ខោនមកដល់មាត់សមុទ្រ ។ ចំណែកចេនឡាដីគោកសំរាប់សំគាល់វិសាលភាពទឹកដីដែល ស្ថិតនៅខាងលើ គឺនៅខាងជើងភ្នំដងរែក[១] ។

នៅសម័យចេនឡានេះ ព្រះពុទ្ធសាសនាហីនយាន ( ថេរវាទ ) បានរីកចំរើនក្នុងសម័យនគរភ្នំនោះត្រូវបានចុះអានុភាពរបស់ខ្លួនបន្តិចម្តងៗ តែពុំសាបសូន្យភ្លាមទេ ។ គេប្រទះឃើញព្រះពុទ្ធរូបនៅស្រុក ព្រៃកប្បាស ដែលសាងឡើងនៅស.វទី៧ ព្រមទាំងសិលាចារឹកជាច្រើនទៀត ។ បើតាមឯកសារស្រាវជ្រាវខ្លះថា ចុងស.វទី៨ ព្រះពុទ្ធសាសនាមហាយាន ឬព្រះពុទ្ធសាសនាអាចារិយវាទ ដែលនិយមភាសាសំស្ក្រឹតបានចូលមកដល់ប្រទេសខ្មែរយើង ហើយរីកលូតលាស់មកដល់ ស.វទី១៣ នៃសម័យអង្គរ ។ គេបានរកឃើញសិលាចារឹកមួយផ្ទាំងទៀត ចុះកាលកំណត់ ៧៩១ នៅប្រាសាទ **ភាវគៀម** ក្នុងខេត្តសៀមរាប ដែលអាចចាត់ទុកជាសក្ខីភាពមួយចាស់ជាងគេ នៃព្រះពុទ្ធសាសនាមហាយាននៅស្រុកខ្មែរយើង ។

(១) លោកករណៀត ធ តោ ព្រះពុទ្ធសាសនា និងតម្កល់ខ្មែរ ភ្នំពេញ ១៩៩៤ ទំព័រ ៦៧

ឯកសារនេះ បាននិយាយពីការកសាងបដិមាពោធិសត្វលោកេស្វរៈជាពោធិសត្វមួយព្រះអង្គ ដែលគេនិយមជាងគេនៅស្រុកខ្មែរយើងសិលាចារឹកមួយទៀតនៅវត្តប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ( ពីដើមជាខេត្តបាភ្នំ ) និយាយពីការថ្វាយទាសៈចំពោះព្រះពោធិសត្វ ៣ អង្គគឺ **សស្តៈ១ មៃត្រេយ១** និង**អវលោកិស្វរៈ១** លោកអាម៉ូនីញ៉េថា សិលាចារឹកនេះនៅក្នុងសតវត្សទី៦ ទី៧ (១) ។ ក្នុងសិល្បៈចំលាក់បុរាណសិល្បករខ្មែរ យើងច្រើនឆ្លាក់រូបពោធិសត្វនេះ ជារូបបុរសមានវ័យក្មេងមានព្រះហត្ថបួនកាន់ផ្កាឈូក ខ្សែផ្កាំ គម្ពីរ និងដបទឹក ( សូមកុំច្រឡំនឹងព្រះវិស្ណុ ដែលមានព្រះហត្ថបួនដែរ តែកាន់ផ្កាឈូកកងចក្រ គទា និងសង្ខ ) ។ លក្ខណៈស្រួលចំណាំចំពោះព្រះពោធិសត្វលោកេស្វរៈ គឺនៅលើព្រះសិររបស់ព្រះ-អង្គមានរូបព្រះពុទ្ធ **អាមីតាភៈ** ។ ប៉ុន្តែ គេមិនសូវជួបប្រទះរូបបដិមាករពោធិសត្វលោកេស្វរៈច្រើនប៉ុន្មានទេ ។ គេបានប្រទះឃើញនៅក្រមួនសរនៅកម្ពុជាក្រោមមួយទៀត នៅប្រាសាទតាគៀមសៀមរាប និងគេប្រទះឃើញនៅប្រាសាទទន្លេបាទីខេត្តតាកែវ ។ ទោះបី ព្រះពុទ្ធសាសនាមហាយាន ដែលជាសាសនាចំណូលថ្មីមានការរីកចំរើនក៏ដោយ ក៏គេនៅតែឃើញមានមន្ត្រី និងប្រជាពលរដ្ឋខ្មែរខ្លះមួយចំនួនគោរពព្រះពុទ្ធសាសនាហីនយានផងដែរ ។

ចំពោះលទ្ធិព្រហ្មញ្ញសាសនាវិញ នៅក្នុងសម័យចេនឡានេះ គេសង្កេតឃើញមានការគោរពបូជាចំពោះគណៈផ្សេងៗដូចជា :

- គណៈសិវៈ មានឋានៈជាសាសនាផ្លូវការ ចំពោះព្រះរាជាទាំងអស់ចាប់តាំងពីព្រះបាទ ភវវរ្ម័នទី១ និងប្អូនជីដូនមួយរបស់ព្រះអង្គ **ចិត្រ សេន** មកសុទ្ធតែបានធ្វើការកសាងលិង្គព្រះឥស្វរសំរាប់ជាទីសក្ការៈបូជាផងដែរ ។ គេបានរកឃើញ

(១) G- goedè, Histoire omcieme des Etats hindouisès d' Extrême Orient, p. 90 et suvre

សិលាចារឹកពីរផ្ទាំងរបស់ព្រះបាទ ភវវរ្ម័ន ដែលមួយផ្ទាំងគឺសិលាចារឹកភ្នំបន្ទាយនាង នៅតំបន់មង្គលបុរិ ខេត្តបាត់ដំបង បាននិយាយពីការកសាងលិង្គព្រះឥស្វរ ។ ក្នុងរាជព្រះបាទ ភវវរ្ម័ន ដដែលព្រះអង្គ **ចិត្រ សេន** នេះឯងបានកសាងផ្ទាំងសិលាចារឹកសំស្ក្រឹតខ្លីៗ ជាច្រើននិយាយពីការកសាងលិង្គនៅតាមបណ្តោយទន្លេមេគង្គ ក្នុងខេត្តក្រចេះ ស្ទឹងត្រែង និងនៅខាងលិចបុរិរម្យ ។ មកដល់រាជ្យព្រះអង្គផ្ទាល់ព្រះបាទ **ចិត្រ សេន** ( ព្រះបាទមហេន្ទ្រវរ្ម័ន ) ព្រះអង្គទ្រង់បានកសាងសិលាចារឹកផ្សេងៗទៀតនៅត្រង់ទន្លេមួន និងនៅសុរិន្ទ និយាយពីការកសាងលិង្គគិរិសៈ និងរូបគោនន្ទិក្នុងឱកាស ដែលព្រះអង្គបានធ្វើសង្គ្រាមវាតទីកដីជាបន្តពីព្រះរៀមឆ្ពោះទៅទិសខាងលិច និងខាងត្បូង ។

គ.ស ៦៦៤ មានព្រះមហាក្សត្រមួយព្រះអង្គព្រះនាម **ជ័យវរ្ម័នទី១** ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយព្រះអង្គបានបំបួសព្រះរាជបុត្រពីរអង្គជាភិក្ខុក្នុងព្រះពុទ្ធសាសនា ដើម្បីឱ្យបានជាព្រះញាតិព្រះពុទ្ធសាសនា ភិក្ខុមួយរូបព្រះនាម **រតនភាណុ** និងមួយអង្គទៀតព្រះនាម **រតនសិង្ហៈ** ។

រវាងស.វខាងលើនេះ ព្រះពុទ្ធសាសនាបានចំរើនរុងរឿងណាស់ ព្រះពុទ្ធរូបជាព្រះបដិមាកររចនាបានផ្សាយទូទៅក្នុងទីផ្សេងៗ ។

សរុបមក យើងសង្កេតឃើញថានៅក្នុងសម័យចេនឡានេះ មានសាសនាច្រើនដែលប្រជាពលរដ្ឋខ្មែរយើងគោរពបូជានៅលាយឡំគ្នាគ្រាន់តែតិចច្រើនជាងគ្នាប៉ុណ្ណោះ ។ ដោយឡែកព្រះពុទ្ធសាសនាហីនយាន ដែលជាសាសនាមួយក្នុងចំណោមសាសនាទាំងអស់ ហើយបានចាក់ឫសមុនគេនោះ មានការរីកចំរើននៅសម័យនគរភ្នំនោះបានចុះអានុភាពបន្តិចម្តងៗនៅសម័យចេនឡា តែពុំមែនសាបរលាបភ្លាមៗនោះទេ ។ ក្រោយពេលព្រះពុទ្ធសាសនា ហីនយានចុះអានុភាពព្រះពុទ្ធសាសនាមហាយានបានមកជំនួសវិញម្តង ។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១

( គ.ស ៦៥៧-៦៨១ ) មានសិលាចារឹកពីរ[១] មួយគង់នៅវត្តព្រៃវៀរ (គ.ស ៦៦៤) ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ( ពីដើមហៅ ខេត្តបាភ្នំ ) បានចែងទុកថា មានភិក្ខុពីរអង្គជាបងប្អូនបង្កើតជាតិជាក្សត្រ ចេញទ្រង់បព្វជា ហើយគង់នៅវត្តព្រៃវៀរនេះ ។ វត្តព្រៃវៀរ ជាវត្តមួយបរមបុរាណតាំងពីកាលនោះរហូតមកដល់សព្វថ្ងៃ ។ នៅចេនឡាមានប្រជាជនច្រើនកាន់ព្រះពុទ្ធសាសនា ។ អ្នកស្រុកធ្វើស្រែចំការ ... ។

នៅសម័យចេនឡា យើងឃើញថា ពុទ្ធសាសនាលទ្ធិមហាយានរុងរឿង តែមិនសូវមានរូបពោធិសាត់លោកេស្វរះទេ មានមួយនៅខេត្តត្រមូនស មានមួយទៀតនៅប្រាសាទតាកៀម ( សៀមរាប ) ។ ឯព្រះពុទ្ធសាសនាថេរវាទក៏មិនមែនសាបសូន្យដែរ ។

*( នៅមាន ត )*

(១) A. Barth, inscription du Cambode p.60 et suiv

# សិលាចារឹកថ្មី Ka 17 នៅប្រាសាទអំពិល ខេត្តឧត្តរមានជ័យ

## A New Inscription Ka 17 at Prasat Ampil, Uttor Mean Chey province

ចន់ សុធារ៉ា

សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

នៅក្នុងដំណើរសង្កេតការណ៍មួយ នៅតំបន់អំពិល នាថ្ងៃ២៥ខែកក្កដាឆ្នាំ១៩៩២ បណ្ឌិត មីសែល ត្រាណេ បានឃើញសិលាចារឹកផ្ទាំងនេះ នៅក្នុងប្រាង្គកណ្ដាលនៃប្រាសាទអំពិល ដែលមានប្រាង្គបីធ្វើអំពីឥដ្ឋ សព្វថ្ងៃនៅក្នុងភូមិពងទឹក ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ[1] ដែលពេលនោះ ស្ថិតនៅក្រោមការកាន់កាប់របស់ភាគីចលនាតស៊ូហ៊្វុនស៊ិនប៉ិចរបស់សម្ដេចព្រះ នរោត្តម សីហនុ និងអ្នកអង្គម្ចាស់ នរោត្តម រណឫទ្ធិ ។ តាមលោក ម. ត្រាណេ បានអោយដឹងទៀតថា ដើម្បីថែរក្សាបេតិកភណ្ឌជាតិមួយផ្ទាំងនេះ គេបានដឹកវាជម្លៀសចេញពីតំបន់ប្រយុទ្ធគ្នាជាញឹកញាប់ ពីកន្លែងមួយទៅកន្លែងមួយ ។ ចុងក្រោយបង្អស់ គេបានដឹកយកមកទុកនៅមន្ទីរអភិរក្សដ្ឋានអង្គរ នៅខេត្តសៀមរាប ។ ក្នុងវេលាបំលាស់ទីជាច្រើនលើក លើផ្លូវដ៏លំបាកលំបិនធ្វើអោយផ្ទាំងចារឹកបាក់ជាពីរ និង បែកថ្មផ្នែកខាងក្រោមបន្តិច ដែលដាច់អក្សរនៅបន្ទាត់ក្រោមប្រហែលបីបួនព្យាង្គ។

---

[1] Voir, Michel Tranet, *Découvertes Récentes d'Inscriptions Khmères,* dans *SOUTHEAST ASIAN ARCHAEOLOGY 1994,* éditée par Pierre-Yves Manguin, p. 110.

អត្ថបទចារឹកមានចំនួន៤០បន្ទាត់[២] លើបន្ទះស្តម្ភថ្មភក់ទំហំ កំពស់០.៨៦ម និង ទទឹង០.៣៧ម ជាភាសាសំស្ក្រឹត ២៦បន្ទាត់ ភាសាខ្មែរ១៤បន្ទាត់ ។ ភាសាសំស្ក្រឹត ៨បន្ទាត់ខាងដើម ត្រូវរបេះបុបមិនអាចអានបាន ដោយសារធម្មជាតិបំផ្លាញ ។ ចំពោះការសិក្សាពេលនេះ យើងលើកយកតែផ្នែកភាសាខ្មែរ ចំណែកភាសាសំស្ក្រឹត យើងគ្រាន់តែសរសេរជា(transliterate)អក្សររ៉ូម៉ាំង និងខ្មែរសម័យថ្មីប៉ុណ្ណោះ ។

អត្ថបទភាសាខ្មែរបានអោយដឹងថា នៅឆ្នាំ៩២៩មហាសករាជ[៣] ថ្ងៃព្រហស្បតិ ៩រោជខែផល្គុណ គឺត្រូវនឹងដើម ខែមីនាគ.ស.១០០៧ ព្រះបាទជយវីរវម៌(ទេព) ស្តេចយាងក្រសាលនៅស្រះស្រង់ នៃព្រះជយេន្ទ្រនគរី ដើម្បីរាជានុញ្ញាតអោយ ម្រតាញខ្លោញ វិជយេស្វរវម៌ថ្វាយស្លោកអគ្គរានេះ ក្រោយពីប្រើមន្ត្រីម្នាក់នាម ម្រតាញខ្លោញ វាគីស្វរវម៌ សូធ្យលិខិតថ្វាយជាព្រះសណ្តាប់ ទ្រង់សព្វព្រះរាជហឫទ័យ ក៏ត្រាស់បង្គាប់ អោយមន្ត្រីជាច្រើនរបស់ព្រះអង្គ បង្កើតស្ថាបនកម្មនៅស្រុកស្តារ[៤] រួចចារឹកលិខិតនេះ ទុកនៅទីនោះតែម្តង ។

ប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ នាដើមសតវត្សរ៍ទី១១ មានភាពច្របូកច្របល់វឹកវរ ដោយសារវិបត្តិរាជបល្ល័ង្ក ។ មានព្រឹត្តិការណ៍ដណ្តើមអំណាចគ្នា យ៉ាងហោចណាស់រវាងស្តេចបីអង្គ គឺជយវីរវម៌ សូរ្យវម៌ទី១ និង សូរ្យជយវម៌[៥] នៅក្រោយពេល

[2] M. Tranet mentions as 35 lines totally, cf, op. cit.

[3] He reads 949 Saka (1027A.D.) cf, op. cit.

[4] ស្រុកស្តារ គឺត្រូវនឹងតំបន់នៃភូមិពងទឹក ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យសព្វថ្ងៃ ។

[5] តាមចារឹកទើបរកឃើញនៅគោកក្លាង K. 1128 (or Ka 59) ខេត្តបុរីរម្យ ប្រទេសថៃ កាលពីឆ្នាំ១៩៨៤ ដែលបានអោយដឹងថា នៅមហាសករាជ៩៣៤ គឺ គ.ស.១០១២ មានព្រះរាជាមួយអង្គនាម ស្រីសូរ្យជយវម៌្មទេវ សោយរាជ្យនៅតំបន់នោះ ។

ព្រះបាទជយវម៌ទី៥ ចូលទិវង្គត ជាពិសេស ក្រោយការបាត់ខ្លួនរបស់ព្រះបាទឧទយា-ទិត្យវម៌ទី១ ដែល ជារជ្ជទាយាទទើបតែបានឡើងសោយរាជ្យប៉ុន្មានខែប៉ុណ្ណោះ ។

លោក អេត្យេន អេយម៉ូនីញ៉េ និងលោក លូ ហ្វីណូត៍ធ្លាប់បានអះអាងថា ព្រះបាទជយវីរវម៌ និង ព្រះបាទ សូរ្យវម៌ទី១ ជាព្រះរាជាតែមួយអង្គ ។ ចំណែកលោកសឺដេស បានយល់ឃើញផ្ទុយគ្នាទៅវិញ តាំងពីឆ្នាំ១៩៣៤ ។ក៏ប៉ុន្តែមកដល់ឆ្នាំ១៩៦៤ នៅពេលលោកសិក្សាអំពី ចារឹកប្រាសាទបេង K.989 ធ្វើអោយលោកមានការរារែក ដោយសារ ភស្តុតាងបានងាកទៅរកអ្វី ដែលអាចារ្យរបស់គាត់ធ្លាប់បានអះអាង គឺថា នាមព្រះមហេសី និង សេនាបតីម្នាក់ របស់ព្រះរាជាទាំងពីរអង្គនេះដូចគ្នា ហើយរាល់ពត៌មានស្តីអំពីអត្ថិភាពរបស់ព្រះអង្គទាំងពីរ ដែលគេបានរកឃើញ ហាក់ដូចជានៅខណៈជាមួយគ្នា នៅក្នុងតំបន់ក្បែរៗគ្នា ឬ តំបន់ជាមួយគ្នា ។ ជាពិសេស សិលាចារឹកប្រាសាទបេងនេះតែម្តង ដែលចារឹកដោយសេនាបតីរបស់ព្រះរាជាទាំងពីរអង្គ នាម កំស្តែងស្រី *នរបតិន្ទ្រវម៌* ដែលត្រូវជាបងប្អូន ប្រុសរបស់ភរិយា( ទេវី=ទេពី) នៃព្រះរាជាទាំងពីរអង្គ នាមកម្រតេងអញស្រី *នឫបតិន្ទ្រលក្ស្មី* ។ តាមអត្ថបទផ្នែកភាសាសំស្ក្រឹតថា *នឫបតិន្ទ្រលក្ស្មី* ជាមហេសី[la reine, K. 989A: 26]របស់ព្រះបាទ *ជយវីរវម៌* ចំណែក អត្ថបទភាសាខ្មែរថា ព្រះនាង ដែលជាកូនរបស់ស្តេញព្រៅ ជាទេវីរបស់ព្រះបាទសូរ្យវម៌ទី១ [K. 989B: 31] ។

ចំពោះ ព្រះនាម *សូរ្យវម៌* លោក Aymonier ថា បានលេចឡើងមកជំនួសនៅមុនឆ្នាំ១០០៦ ហើយចាប់ពីពេលនោះមក គេលែងឃើញមានព្រះនាម *ជយវីរវម៌*[6] ។

---

[6] Voir, K. 989, inscrit d'après de l'ordre de Sa Majesté Sûryavarman I, située dans le srok de Phnom Srok, datée en 930 Saka, G. Coedès,

ទោះបីជាយ៉ាងណា អ្នកប្រវត្តិសាស្ត្រទាំងអស់ មិនទាន់ឯកភាពតាមទស្សនៈនេះនៅឡើយ ។ ដោយសារមានពត៌មានជាច្រើនស្តីអំពីការប្រយុទ្ធប្រឆាំងគ្នា នៅមុនពេលព្រះបាទសូរ្យវម៌ទី១ ឡើងសោយរាជ្យជាស្ថាពរនៅទីក្រុងអង្គរ នាឆ្នាំ១០១១ គ.ស. ។ម្យ៉ាងទៀត ឋានន្តរនាមរបស់ព្រះរាជាទាំងពីរព្រះអង្គនេះ ខុសគ្នាស្រឡះ គឺព្រះបាទសូរ្យវម៌ មានឋានន្តរនាមថា *ធូលិវ្រះបាទកម្រតេងកំត្វនអញស្រី (សូយ៌្យវម៌្មទេវ)* ចំណែកព្រះបាទជយវីរវម៌ មានឋានន្តរនាមថា *ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រី(ជយវីរវម៌្មទេវ)* ។

តាមភស្តុតាងពត៌មាននៃសិលាចារឹកនេះមួយទៀត អាចបញ្ជាក់បានថា ព្រះបាទជយវីរវម៌មានអត្ថិភាពនៅលើរាជបល្ល័ង្កក្រុងអង្គរនៅឡើយ រហូតមកដល់ខែមីនា គ.ស.១០០៨ ។

ខាងក្រោមជាអត្ថបទសិលាចារឹកទាំងស្រុង ជាអក្សរសម័យសព្វថ្ងៃ

| | | |
|---|---|---|
| ១-៨ | ------------------------------------------ | |
| ៩ | ---(ទ្វិទគ្ន--វរូបឱទគ្ឃគស្យា)--- | ទិវ្យា-------ប្រតិមា------- |
| ១០ | --ព្យា--ជស្យ(ចិ)វិរិន្ទរិតិ------ | ស្យា---------តិវា---ិតុស្មិន |
| ១១ | -ប្រាត្ញជាភិរម(លាភិរន្ទន-ាភិ) | ស្យា-រ-(កា)រវសតិសតិ-ត្រ-ជ្យ |
| ១២ | -ប្រាន្ទយស្សរិជយេគ្ទរវម៌្មមន្ត្រី- | ត្រិមាន្ទុបេគ្វរ(ក្ឫបោទិតតុត្ថចេម្ទះ) |

conservée au musée de Vat Po Veal, dans *Inscriptions du Cambodge*, Vol. VII, pp. 166-8 et *Articles sur le Pays Khmer* tome II, Paris 1992, éditée par Claude Jacques, p. 73.

១៣ --ព្រាធ្យធម្មិនិធិ(រកមនិម្មុនិនា) និត្តិន្តតា(នសគតំ)វីរិធាទ្វរេមុ

១៤ កាលាគសះកិលមហាសនននម្តស័ស្ដា នេតាន្សិតា(ម)ហាសមាហិកទិវ្យទេ

១៥ ឯកាទគាលយ(និ)ជាន្យ(ធ)បន្ទបេន្ទ្រេ ស័ស្ដាប្យកទ្ទលមយំសកិរិចការ

១៦ កន្យា(មាត្តិាទិ្វាន---យុះតិទ្ធជា)ក្សាលយានៅ្តលសិង្ហៅសូយិ្យា

ទៅសប្រយាតេយមទិវសយុ

១៧ តេកីតលរ(កន្ទ)សាទ្វ នេគេទិកគិន្ទ្រលោកេវវ៉ា

យុគលវិលៃស្សារមាហ្វួត្យភូមេ

១៨ (ទ្ទំ)វាង្គិត្តិបិតូន្តាន្សវប--នុបមាស្ដាបិយាមាសមានី ។

តស្នែតុយិ្យាទិតន្ត្រិវជតកនក

១៩ តាម្រោបភោគាះ----ក្សៅយា(នាកតេទ្វេត)ទនុស-

មហិមាន្ទេ(នុ)វ្នំមហាថាន

២០ ។ (មិធាន្យសមស្តំសចត)-----(ជិវមោទត្វាធម្មឃេបាល--ល-

- ប្បមាវនមិមំយាន---ៃ-)

២១ ត្រីមាន(-ននយ)----ត្យ------ នម(ដេ)ស្សុរបាលិនាយ--

២២ ធិស្តិណ្ណិស័យ--------យិ្យ --មិត្វាប្រតិម្ពតឥនាធិបគាសនេន--

២៣ (ោ-ៗ----ៗ--ធ-ន្រ្ទទគិប្រតិតា) យាធ្យាគតា(មុ)និបុរស្សធនាវធិតិ

២៤ បគ្នា( ចូនាភិភប្ចថុ) សិន្ទវធិរបុរាប្ដា គម្ពិរធារសិរិតស្បតីសោត្ថវេភូះ

២៥ ចន្ទ្រា-( នោវធិវទាច្ចិធុទ្ធ្វ------ មាទ្យារប្រ---ជាិ-ប្រ( គាតោិ---ូ

២៦ កេទាជេន្ទ្រាវ៉ាកាង្ហិង---តិរិ្វទិស្ទះ ក្រោញ្ញ( ប្ញូវ៉ាគ៍-

មហាទមិ-ាឃជទិត) ។

២៧ ។០ ។៩២៩គកនវមិរោចផាល្គុណវ្ហហស្បតិវាំរនុធូលិវ្រះបាទកម្រតេងអញ្ញ គ្រីជ

២៨ យវិរវម្ម័ទេវស្តាចវ្រះចំវ៉ាតវ្រះក្រលាស្រោងវ្រះជយេន្ទ្រគិរិបិម្រតាញ្ញខ្លោ

២៩ ញគ្រិវិជយេគ្វរវម្មិថ្វាយគ្លោកប្រគស្តនេះវ្រះស្វេយករុណាប្រេម្រតាញ្ញខ្លោញ្ញ

៣០ គ្រីវ៉ាគិគ្វរវម្មិគុណទោមទគ៌ិឱ្យ( ប) ន្លេយវ្រះបន្ទូលម( ន) តាបរោហប្រេចារប្រ

៣១ គស្តនេះប្រេទៅស្ថាបនាអាយស្រុកស្ដារនាវ្រះបុន្យទៃ( យ) ។ អ្នៅនាវ្រះបន្ទូល

៣២ ម្រតាញ្ញខ្លោញ្ញគ្រីប្ញូថីវិន្ទ្រវម្មិគុណទោមទគ៌ិ ស្តេងអញ្ញតវាញ្ញវ្យាងម្រតាញ្ញ

៣៣ ខ្លោញ្ញគ្រីលក្សិ្មន្ទ្រវម្មិខ្លោញ្ញគ្លាងនាត្រីណិម្រតាញ្ញខ្លោញ្ញគ្រីវិក្រមវម្មិស្រុក

៣៤ ( ធុ) សោម្រតាញ្ញខ្លោញ្ញគ្រីសត្យវម្មិម្រតាញ្ញខ្លោញ្ញវ្យាបារបាសខ្មៅម្រតាញ្ញ

៣៥ ខ្លោញ្ញតង្វេយម្រតាញ្ញខ្លោញ្ញត្រវ៉ាងខ្ពុងខ្លោញ្ញវលបុរាញ្ញខ្លោញ្ញ( គា) មាលា

៣៦ ការ ។ខ្លោញ្ញវលសិន្ទូរ ។ខ្លោញ្ញមុខបត្រការខ្លោញ្ញវលស្តុកជ្វិកខ្លោញ្ញអាភម

៣៧ ខ្លោញ្ញវលកុលវៅខ្លោញ្ញជ្វាលវ្រះបីថធារិ ។ខ្លោញ្ញវលតប-រវ្វល ។០ ។

៣៨ ( ស្រេ) វ្រះកម្រតេងអញ្ញគ្រីវិជយេគ្វរោទយ( គិវ) តិខ្មេតស្រេបិងស្មុចសុវណ្ណិ

៣៩ --ជ្រលោងតិប្ជូវិស្នុច ។បិងអាសវ៉ាស( មាលិកេល) ។ជ្រលោង( អំ)ឪម( បព្ចំ)

៤០ -----( សនច) ។ចំនបតនោត ។គុភាទិប ។០ ។ស្រេតិណ្ហែចបិង---រ-ា---

## អត្ថបទជាអក្សររ៉ូម៉ាំង

1-8 -----------------------------------------------------------------

9- ---[dvidaçc--rarūpaḍhadaçcçasyā]----
divyā------pratimā---------------

10- --yā--jassa[rthi]vavindariti------------
s sā---------tivā---------mitusmina

11- -prātmajābhirama[lābhiranūna-ābhi]
s sā--e-[kā]ravasatisati-tra--jya

12- -prānvayassavijayeçvaravarmma
mantrī- çrimān dṛpeçvara [kṛpoditatutgaceṣṭaḥ]

13- --sādhya dharmmanidhi [rekamanimmuninā]
n kirttin tatā[nasaçataṃ]vividhādvareṣu

14- kālāçasaḥ kilamahāsananaṣtasāsṭhā
netānpitā[ma]hasamāhikadivyade

15- ekädaçālaya[ni]jānya[dha]pandapendre
sāsṭhāpyakadḍhala mayaṃsakaricakāra

16- kanyā [mārggārddhavāna---yuḥtidṛphā]kṣālayāntaula
sinhau sūryyādausapra- yāteyamadivasayu

17- tekītalak[entḥa]sāddha neçedikaçindralokevavā
yugalavilaissāramāhṛtyabhūme

18- [rddaṃ]vān kīrtti pitūntānyavapa—nupamāsṭhāpiyāma-
¯samānī // tasmai turyyādi tantrīrajatakanaka

19- tāmropabhoçāḥ-------kyaughā[nākatedveta]danusa-
mahimāndhe[nu]vṛndaṃ mahārthān

20- // [midhānyasamastaṃsacata]-----[jimodatvādharmmaṃ
ghepāla--la-ppamārana- mimaṃyāna-----dai]

21- çrīmān a[-nanaya]-------------tya----------nama[je]ssura pālanāya--
22- dhistirṇnasāya--------------ūryya ----mitvā pratiṣṭha ta inādhipaçāsanena--
23- [r-o-----ya--dha-ndradaçipratitā] yādhyāgatā[mu]nipurasyadhanāvadhiti
24- paççā[ccanābhibhapṛthu]sindhvavadhira purāptā gambhira dhāra saritas safisottarebhuḥ
25- candrā-[novadhivadācçidhudṛ-ti-i---- mādyārapra---jā-ipra[gāgo-i--i-la
26- kedājendrāvākānnin---tirvva disṭhaḥ kroñca[plavāça-imahādami-āyajadita] //
27- /o/ 929 çaka navami roc phālguṇa vṛhaspativāra nu dhūli vraḥ pāda kamrateṅ añ çrī ja (28) yaviravarmmadeva stāc vraḥ caṃvāt vraḥ kralā sroṅ vraḥ jayendragiri pi mratāñ khlo (29) ñ çrī vijayeçvaravarmma thvāy çlok praçasta neḥ vraḥ svey karuṇā pre mratāñ khloñ (30) çrī vāgiçvaravarmma guṇadoṣadarçi oy [pa]nley vraḥ pandval ma[n] gāp roh pre cār pra (31) çasta neḥ pre dau sṭhāpanā āy sruk sgār nā vraḥ punya dai[y] ° [a]nau nā vraḥ pandval (32) mratāñ khloñ çrī pṛthivindravarmma guṇadoṣadarçi steṅ añ tarāñ rvyāṅ mratāñ (33) khloñ çrī lakṣmīndravarmma khloñ glāṅ nā trīṇi mratāñ khloñ çrī vikramavarmma sruk (34) [dhu]so mratāñ khloñ çrī satyavarmma mratāñ khloñ vyāpāra pās khmau mratāñ (35) khloñ taṅbey mratāñ khloñ travāṅ khluṅ khloñ vala purāñ khloñ [gā] mālā (36) kāra ° khloñ vala sindūr ° khloñ mukha patrakāra khloñ vala stuk jvik khloñ ābhaṣa (37) khloñ vala kul vo khloñ jnvāl vraḥ pīthadhāri ° khloñ vala tap -ra [a]val /o/
38- [sre] vraḥ kamrateṅ añ çrī vijayeçvarodaya[çiva] ti khnet sre piṅ smuc suvarṇna

39- ---- jraloṅ ti pūrvva smuc ° piṅ āsvās [māli kel] ° jraloṅ [aṃ]aum[pabvaṃ]

40- -------[sanac] ° daṃnap tanot ° çubhādipa /o/ sre ti rṃnoc piṅ -------au-----

## សេចក្តីបកប្រែ

៨-២៦ ភាសាសំស្ក្រឹត

(២៧-២៩) (នៅ)មហាសករាជ ៩២៩ ថ្ងៃព្រហស្បតិ ទី៩រោច (ខែ)ផល្គុណ ព្រះ-ករុណាព្រះបាទជយវីរវរ្ម័ទេព ស្តេចទ្រង់ព្រះចំពាត[៧] ស្រះស្រង់[៨] នៃព្រះជយេន្ទ្រនគរី ដើម្បីអោយម្រតាញខ្លោញស្រីវិជយេស្វរវម៌ថ្វាយលិខិតនេះ ។

(២៩-៣១) ព្រះអង្គទ្រង់ព្រះសណ្តោស[៩] មានព្រះបន្ទូលប្រើអោយម្រតាញខ្លោញស្រី វាគីស្វរវម៌(មន្ត្រីខាង)សន្តិសុខ អានព្រះលិខិតនេះ[១០] បន្ទាប់មកព្រះអង្គសព្វព្រះ

---

[7] *ចំវាត* មកពីពាក្យ "ច្វាត ឬ ឆ្វាត្ត" [JANNER 1981: 93] សម័យថ្មីថា "ច្រវ៉ាត់" ឬ "ឆ្វាត់" ឬ ឆ្វាត់ឆ្វែង ឆ្វាត់ឆ្វៀល(*វចនានុក្រមខ្មែរ*. ១៩៦៧ ទំព័រ ២៤៣) ។ ដូច្នេះ *ចំវាត់* នេះមានន័យថា យាងក្រសាល ឬ ដើរកំសាន្ត ឬ ដើរក្រឡឹងមើល ។

សណ្តាននៃពាក្យនេះ មានពាក្យ "ចង្វាត" ដែលខ្មែរប្រើប្រាស់ជាធម្មតានៅសម័យមុនអង្គរ និងអង្គរ សំរាប់សំគាល់ សីមា ព្រំប្រទល់ ឬ ខ្សែក្រវ៉ាត់នៃព្រំប្រទល់ដែន ដែលជាកម្មសិទ្ធិ ឬ ទីកដីចំណុះរបស់ស្ថាប័នណាមួយ ឬមន្ត្រីណាម្នាក់ ។ ពាក្យនេះ យើងឈប់ប្រើប្រាស់នៅក្នុងភាសាយើងទៅហើយ ប៉ុន្តែសៀមបានខ្ចីយកទៅប្រើរហូតដល់សព្វថ្ងៃ ដែលមានន័យសំគាល់ ដែនដីរដ្ឋបាលថ្នាក់"ខេត្ត" ។

[8] *ព្រះក្រលាស្រោង* គឺ ទីកន្លែងដែលព្រះរាជាស្រង់ទឹក ឬ មុជទឹក ។

[9] *ព្រះស្ងោយករុណា* មកពី ព្រះ - សោយ - ករុណា = ព្រះអង្គសព្វព្រះទ័យ ទ្រង់ព្រះករុណា ។

ហឫទ័យ[១១]នឹងរឿងនេះ[១២] ក៏ប្រើអោយគេចារឹក[១៣]ទុក (ជាបន្ទាប់ព្រះអង្គ) ប្រើអោយគេស្ថាបនា (ប្រាសាទថ្វាយអាទិទេព) នៅស្រុកស្ពារ' នៅពេលនោះ (ដើម្បីទុកជា) ព្រះបុណ្យមួយផ្នែកទៀត ។

(៣១-៣៧) នៅនឹងកន្លែង នាពេលដែលព្រះអង្គមានព្រះបន្ទូល (មាន) ម្រតាញខ្លោញស្រី ឬថិរិន្ទ្រវម៌ (មន្ត្រីខាង) សន្តិសុខ ស្តេងអញតរាញវ្យាង[១៤] ម្រតាញខ្លោញស្រីលក្ស្មីន្ទ្រវម៌ ជាមេឃ្លាំងថ្នាក់ទី៣ ម្រតាញខ្លោញស្រីវិក្រមវម៌ (ចៅហ្វាយ) ស្រុក (ធុ) សោ ម្រតាញ ខ្លោញស្រីសត្យវម៌ ម្រតាញខ្លោញវ្យាបារ[១៥]បាសខ្មៅ ម្រតាញខ្លោញតង្កេយ ម្រតាញខ្លោញត្រពាំងខ្ពស់ ខ្លោញពលបុរាញ ខ្លោញគា (ជាតម្រួតខាង) កិច្ចការក្រងផ្កា[១៦] ខ្លោញពលសិន្ធូរ (ខ្លោញ) មេតម្រួតខាងរៀបចំឯកសារ ខ្លោញពលស្តុកជ្ជិក

---

10 *បន្លេយ* គឺត្រូវនឹងពាក្យសព្វថ្ងៃថា *បន្លឺ* ដែលមានន័យថា: បញ្ចេញសំលេងអោយលាន់ឮខ្លាំងឡើង (*វចនានុក្រមខ្មែរ*, ១៩៦៧ ទំព័រ ៥៧៤ និង នួន ប៊ុត. *វចនានុក្រមខ្មែរ* ១៩៥៤ ទំព័រ ៣៨៥) ។

11 *គាប* សព្វថ្ងៃ *គាប់* មានន័យថា ត្រូវ ឥតខុស ឥតទាស់ (វចនានុក្រមខ្មែរ, ទំព័រ ១៥៧) ។

12 *រោហ* អានថា រោះ មានន័យថា រឿង បញ្ហា អ្វីដែលកំពុងកើតឡើង និងប្រព្រឹត្តទៅ... ។

13 *ប្រេចារ* មានន័យថា ប្រើអោយគេចារឹក

14 *ត្រាញ់រវ្យេង* មកពីពាក្យ *តរាញ* = ព្រៃរបោះ + វ្យាង = ឈ្មោះរុក្ខជាតិ (ដើមរវៀង) POU 1992: 214]

5 *វ្យាបារ* = នៅជាប់ក្នុងមុខតំណែង ឬកាតព្វកិច្ច [Ibid, 461] ។ *បាសខ្មៅ* ជាឈ្មោះស្រុកមួយដែលគេប្រទះឃើញជាញឹកញាប់ នៅក្នុងសិលាចារឹកសម័យអង្គរ ។

16 *មាលាការ* = អ្នកក្រងផ្កា [Ibid, 373] *បត្រការ* = អ្នករៀបចំឯកសារ ។

ខ្លោញអាភស ខ្លោញពលកុលវោ ខ្លោញឈ្នួល[១៧] ទទួលបន្ទុកខាងទឹកផឹក[១៨] ខ្លោញពលតប-រអ្វូល ។០។

(៣៨-៤០) ស្រែព្រះកម្រតេងអញស្រីជយេស្វរោទយសិវ តិថីខ្មៅត[១៩] (មាន)ស្រែបិងស្មុច សុវណ្ណិ----ជ្រលងទិស បូពិនៃស្មុច ។ បិងអាសវាស(មាលិកេល) ។ ជ្រលង(អំ)ឪម(បព្ញំ) ----(សនច) ។ ទំនប់ត្នោត ។ សុភាទិប ។ តិថីរនោច ស្រែបឹង-----វ-ៀ--- ។

## ឯកសារពិគ្រោះ


1- CŒDÈS, Georges
1937-66 *Inscriptions Du Cambodge,* Vol. I-VIII, (8 volumes), Paris,
1989-92 *Articles sur le Pays KHMER,* tome I-II, (2 volumes), éditée par Claude Jacques.

2- Manguin, Pierre-Yves
1994 *SOUTHEAST ASIAN ARCHAEOLOGY,*

3- Monier Monier Williams
1995 *A Sanskrit English Dictionary,* New Delhi.

4- N. JANNER, Philip


[17] *ជ្វាល* គឺត្រូវនឹងពាក្យ ល    ។

[18] បីថធារិ មកពីពាក្យ "បីថ" មានន័យថា ទឹក, ទឹកសំរាប់ផឹក និង "ធារិ" មានន័យថា កំណាន់ការកាន់, អ្នកកាន់ ឬ អ្នកទ្រ ។[Monier, 1995, p. 514, 629]

[19] វែសទាំងនេះ ជាអំណោយចំពោះអាទិទេព ហើយរាល់ផលិតផលដែលបានពីការដាំដុះលើដីទាំងនេះ ក្លាយជាស្បៀងសំរាប់ផ្គត់ផ្គង់ប្រាសាទនៅអំឡុងពេលខ្នើត( ១៥ថ្ងៃរៀងរាល់ខែ) ។

1981 *Lexicon of Dated Inscriptions,* Hawaii

5- POU, Saveros

1989-96 *Nouvelles Inscriptions du Cambodge I-II,* EFEO, Paris.

1992 *DICTIONNAIRE VIEUX-KHMER-FRANÇAIS-ANGLAIS, Paris,* Cedoreck.

6- SAHAI, Sachchidananda

1970 *Les Institutions Politiques et l'Organisation Administrative du Cambodge Ancien (VI^e-XIII^e siècles),* Paris.

7- នួន ប៊ុត

១៩៥៤ *វចនានុក្រមខ្មែរ*. ភ្នំពេញ

8- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ (ជួន ណាត)

១៩៦៧ *វចនានុក្រមខ្មែរ*. ភ្នំពេញ

# អត្ថបទដើមនៃសិលាចារឹកប្រាសាទអំពិល Ka 17



# ព្រះវិស្ណុ



ចម្លងពីសៀវភៅ Khmer Sculpture and the Angkor Civilization

ដោយលោកស្រី M. Giteau

បើយោងតាមការអះអាង នៅក្នុងគម្ពីរឫគវេទ ព្រះវិស្ណុមិនមែនជាព្រះអាទិទេពថ្នាក់លើគេបង្អស់ទេ ។ ព្រះអង្គគឺជាការសម្ដែងចេញ ឱ្យមានរូបរាងនៃថាមពលព្រះអាទិត្យ ពោលគឺព្រះអង្គមានកំណើតមកពីថាមពលព្រះអាទិត្យ ។ មានការពណ៌នាពីព្រះអង្គថា ទ្រង់ឈានតែបីជំហ៊ានវែងៗ កាត់តំបន់ទាំង ៧ នៃលោកសន្និវាសនេះ ហើយព្រះអង្គទ្រង់គ្របដណ្ដប់លើវត្ថុទាំងឡាយនឹងពន្លឺរបស់ព្រះអង្គ ។ ជំហានទាំងបីត្រូវគេវិភាគថា ជាការសម្ដែងឱ្យឃើញជាពន្លឺបីយ៉ាង ដែលចែកចេញជាភ្លើង ផ្លេកបន្ទោរ និងព្រះអាទិត្យ ឬមួយវិញទៀតគឺជាទិសម្គាល់ទាំងបីនៃព្រះអាទិត្យ ក្នុងវេលាថ្ងៃរះ វេលាថ្ងៃកំពុងចែងចាំងពន្លឺ និងវេលាថ្ងៃលិច ។ មាន

ពេលខ្លះ ព្រះអង្គត្រូវចូលរួមគ្នាជាមួយនឹងព្រះឥន្ទ្រ ។ គេតែងហៅព្រះអង្គថាជា" អ្នកគ្រប់គ្រងរក្សា ដែលមានជោគជ័យជារហូត " ។ នេះគឺជាលក្ខណៈពិសេស ដែលបង្ហាញថា ព្រះអង្គមានមហាតេជានុភាពខាងថែរក្សា ។ នៅក្នុងគម្ពីរមនុ គេឃើញមានការនិយាយទៅដល់ព្រះវិស្ណុដែរ ក៏ប៉ុន្តែ គេដូចជាពុំឃើញមានការចាត់ទុកព្រះអង្គថា ជាព្រះអាទិទេពដ៏ជាកំពូលដូចនៅក្នុងគម្ពីរឫគវេទនោះទេ ។ ប្រភពនៃអក្សរសាស្ត្រខ្លះថ្លែងថា ព្រះវិស្ណុគឺជាព្រះអាទិទេពថ្នាក់ទីពីរ ក្នុងចំណោមអាទិទេពធំៗទាំងបីព្រះអង្គ ជាតំណាងនៃសត្វគុណ គឺមេត្តាធម៌ និងសេចក្តីល្អ ឬអំពើល្អ ដែលបង្ហាញចេញមក ជាអនុភាពនៃការថែរក្សា ការពារជាស្វយម្ភូ ( គឺការកើតមានឡើងដោយឯងៗ ) និងជាវិញ្ញាណ ដែលតែងតែចូលជ្រួតជ្រាប សាយភាយគ្រប់ទីទាំងអស់ ។ គឺក្នុងន័យនេះ ដែលអ្នកធ្វើសក្ការៈចំពោះព្រះអង្គ គេតែងភ្ជាប់ព្រះអង្គទៅនឹងសារធាតុនៃទឹកដែលសាយគ្រប់ទិសទីទាំងអស់ មុនពេលការកើតឡើងនៃលោកនេះឡើង ។ នៅក្នុងលក្ខណៈនេះ គេហៅព្រះអង្គថា " ព្រះនារាយណ៍ " បានន័យថា " ដែលត្រាច់ចរលើទឹក " ហើយត្រូវគេតំណាងតួព្រះអង្គដោយរូបរាងជាមនុស្សដេកលក់ នៅលើពស់មួយ ឈ្មោះសេសៈ ( ឬអាទិសេសៈ ) អណ្តែតនៅលើទឹក ។ កាលណាលោកសន្និវាសត្រូវរលាយ ព្រះអង្គនឹងសន្មតយករូបភាពបែបនេះដែរ ។ ជនទាំងឡាយ ដែលគោរពព្រះវិស្ណុ តែងតែទទួលស្គាល់ថា ព្រះអង្គគឺបុគ្គលដ៏ឧត្តុង្គឧត្តម ខ្ពង់ខ្ពស់បំផុត ព្រោះគេជឿថា អ្វីៗទាំងអស់សុទ្ធតែកើតមកពីព្រះអង្គ ។ មានប្រភពខ្លះនិយាយថា ព្រះអង្គជាព្រះប្រជាបតិ ( អ្នកបង្កើត ) និងជាព្រះអាទិទេពដ៏កំពូលតែមួយព្រះអង្គគត់ ។ ក្នុងន័យនេះ ព្រះអង្គត្រូវមានលក្ខខណ្ឌបី គឺទី១ លក្ខខណ្ឌជាព្រះព្រហ្មា ឬអ្នកបង្កើតលោកដ៏សកម្ម ដែលត្រូវតំណាងដោយការសន្មតថា ព្រះអង្គប្រសូតចេញមកពីផ្កាឈូក ដែលដុះលើផ្ចិតព្រះវិស្ណុ ក្នុងពេលដែលព្រះអង្គកំពុងសិងលក់ ហើយអណ្តែតនៅលើទឹក ។ ទី២ ព្រះវិស្ណុផ្ទាល់របស់

ព្រះអង្គ គឺជាអ្នករក្សាការពារ ក្នុងរូបរាងជាអវតារ ដូចជាព្រះក្រឹស្ណា ។ ទី៣ ព្រះសិវៈ ដែលមានព្រះនាមមួយទៀតថា ព្រះរុទ្រៈ គឺជាអ្នកមានអានុភាពខាងបំផ្លាញ ដែលតាមប្រភពខ្លះថា ប្រសូតចេញមកពីព្រះនលាដ ( ថ្ងាស ) របស់ព្រះព្រហ្ម ។ អំពីការរក្សាការពារ និងការផ្ដល់ឱ្យមានឡើងវិញ នូវអានុភាពរបស់ព្រះវិស្ណុនោះ មានករណីស្ដែងចេញឱ្យឃើញ នៅលើលោកយើងនេះ នូវរូបរាងនានា ដែលគេតែងហៅថា អវតារ ។ នៅក្នុងអវតាររបស់អាទិទេពនោះ ត្រូវមានចំណែកណាមួយ ដែលប្រកបដោយខ្លឹមសារជាអាទិទេពចូលទៅ ជាតំណាងរូបជាមនុស្ស ឬជាអធិធម្មជាតិ ហើយមានអានុភាពផុតវិស័យនៃមនុស្សធម្មតា ។ អវតារទាំងនោះស្ដែងចេញជារូបរាងមក ក៏ដើម្បីកែប្រែ ឬកម្ចាត់នូវអំពើអាក្រក់ធំៗ ឬបង្កើតឱ្យមានអំពើល្អដ៏ធំៗ នៅក្នុងលោក ។ អវតារទាំងអស់ មានចំនួន ១០ អង្គ ប៉ុន្តែមានប្រភពខ្លះបានបង្កើនចំនួនដល់ទៅម្ភៃពីរអង្គ ខ្លះទៀតថា មានចំនួនរាប់មិនអស់ទេ ។ អវតារទាំងដប់ត្រូវបានទទួលការលើកតម្កើងឱ្យមានកិត្តិយស ក្នុងនោះអវតារទី ៧ និងទី ៨ គឺព្រះរាម និងព្រះក្រឹស្ណា ត្រូវបានលើកតម្កើងថា ជាមហាវីរជន ដែលចេះទទួលមរភាព ព្រមទាំងបានទទួលនូវការគោរពបូជា ដែលគេចាត់ទុកជាមហាទេពតា ។ ដោយឡែកព្រះក្រឹស្ណាត្រូវគេលើកតម្លៃថា ជាព្រះវិស្ណុ ដែលបានសម្ដែងចេញមកផ្ទាល់ព្រះអង្គតែម្ដង ហើយក៏ត្រូវបានទទួលនូវប្រជាប្រិយ និងការគោរពយ៉ាងទូលំទូលាយ ។ ព្រះជាយារបស់ព្រះវិស្ណុ គឺព្រះនាងល័ក្សី ឬក៏ហៅតាមព្រះនាមមួយទៀតថា ព្រះនាង " ស្រី " ជាទេពធីតា នៃជោគលាភ ឬជោគវាសនា និងសិរីសួស្ដី ។ ឋានសួគ៌របស់ព្រះវិស្ណុមានឈ្មោះថា " វេកុណ្ឋ " ស្ថិតនៅលើភ្នំព្រះសុមេរុ ( ប្រភពមួយទៀតថា ស្ថិតនៅក្នុងមហាសាគរខាងជើង ) ។ ព្រះអង្គមានសត្វគ្រុឌជាយានជំនិះ ។ គេតំណាងព្រះអង្គ ដោយយុវជនរូបស្រស់ម្នាក់សម្បុរខៀវ ទ្រង់ព្រះពស្ត្រដូចព្រះមហាក្សត្រិយ៍ពីសម័យបុរាណ ។ ព្រះអង្គមានព្រះហស្តបួន ព្រះហស្តមួយ

កាន់ស័ង្ខ ព្រះហស្តមួយទៀតកាន់កងចក្រ ព្រះហស្តទីបីកាន់មោងមានបន្លាឈ្មោះ " កោមោទកី " និងព្រះហស្តទីបួនកាន់ផ្កាឈូកមួយទង ។ ព្រះអង្គមានកៅទណ្ឌ (ធ្នូ) មួយឈ្មោះថា" សារង្គ " និងព្រះសែង ( ដាវ ) មួយឈ្មោះ " នន្ទកៈ " ។ នៅលើព្រះឱរារបស់ព្រះអង្គមានបន្តោងពេជ្រ និងនៅកព្រះហស្តមានខ្សែដៃពេជ្រ ។ ជួនកាលគេតំណាងព្រះអង្គដោយពណ៌នាថា ព្រះអង្គគង់លើផ្កាឈូកមួយទង មានព្រះនាងល័ក្សិ្មគង់នៅក្បែរផង ឬក៏ទ្រង់ទម្រេតលើស្លឹកឈូក ។ ជួនកាលគេតំណាងព្រះអង្គដោយសន្មតថា ព្រះអង្គទម្រេតលើពស់ឈ្មោះសេសៈ ឬគង់លើមហាបក្សា ជាជំនិះរបស់ព្រះអង្គ គឺគ្រុឌ ។ ព្រះអង្គទ្រង់មានព្រះនាមផ្សេងៗជាច្រើន ខ្លះថាមានព្រះនាម ដល់ទៅ ១.០០០ ដូចជាព្រះអច្យុត, ព្រះអនន្តសយនា, ព្រះអនន្ត, ព្រះចតុភុជ, ព្រះក្រឹស្ណៈ, ព្រះទាមុទរ, ព្រះគោវិន្ទ ឬព្រះគោបាល, ព្រះហរិ, ព្រះជលសយិន, ព្រះកេសវៈ, ព្រះមធុសូទន៍, ព្រះលក្សិ្មបតី, ព្រះមាធវៈ, ព្រះមុកន្ទ, ព្រះនរៈ, ព្រះនារាយណ៍, ព្រះបញ្ចាយុទ្ធ, ព្រះបទមនាភា, ព្រះបិតម្ពរ, ព្រះបុរុសៈ, ព្រះបុរុសុត្តម ព្រះវសុទេវៈ, ព្រះវេកណ្ឋនាថ, ព្រះយជ្ញនេសៈ, ព្រះយជ្ញនេស្វរៈ ។

## ព្រះវិស្វកម្ម

វិស្វកម្ម ឬវិស្វក័ម្មន-ព្រះវិស្វកម្ម ជាមហាស្ថាបត្យករនៃលោកសន្និវាស ដែលប្រកបដោយប្រតិដ្ឋញាណ ដ៏សែនខ្ពង់ខ្ពស់ហួសពីការយល់ដឹងរបស់មនុស្សជាតិ ។ គម្ពីរឫគវេទបានពណ៌នាថា ព្រះអង្គជាទេពតាមានព្រះនេត្រទិព្វ អាចមើលឃើញអ្វីៗបានទាំងអស់ ដោយសារព្រះអង្គទ្រង់មានព្រះនេត្រ ព្រះភ័ក្ត្រ ព្រះហស្ត ព្រះបាទា នៅសព្វទីកន្លែងនៃដងខ្លួនរបស់ព្រះអង្គ ។ ក្នុងកាលព្រះអង្គបង្កើតឱ្យបានជាឋានសួគ៌ និងផែនដីនុ៎ះ ព្រះអង្គទ្រង់រចនារាងនៃឋានទាំងពីរ ដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់ ។ ព្រះអង្គជាបិតា ជាអ្នកបង្កើត ជាអ្នកកំណត់ ជាអ្នកស្គាល់ យល់ ដឹង

អំពីលោកទាំងអស់ជាអ្នកប្រទានឈ្មោះអស់ទេពតាផងទាំងឡាយ ។ តាមអត្ថបទស្ថូត្រទាំងពីរបទនៅក្នុងគម្ពីរឫគវេទដដែលនោះ មានការនិយាយថា ព្រះអង្គត្រូវធ្វើការបូជាខ្លួនឯងផ្ទាល់ ដែលក្នុងករណីនេះ មានសេចក្តីពន្យល់ថា " ព្រះវិស្វកម្ម ជាបុត្ររបស់ព្រះភូវ៉ន " ដំបូងបង្អស់ទ្រង់បានប្រគល់ជូននូវលោកទាំងមូលមានទាំងពិធីបូជាជាទូទៅមួយផង ហៅថា " សព្វមេធ " រួចហើយក៏បញ្ចប់ពិធីនេះ ដោយមានការគោរពបូជាខ្លួនព្រះអង្គផ្ទាល់ ។ បើតាមរឿងនិទាននៅក្នុងសម័យវីរកថា ព្រះវិស្វកម្ម មិនមែនគ្រាន់តែជាមហាស្ថាបត្យករប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គក៏ជាសិប្បករ និងជាយន្តការីខាងផ្នែកការជាង ជាទូទៅ របស់ពួកទេពតា ហើយក៏ជាអ្នកផលិតគ្រឿងសព្វាវុធថ្វាយពួកទេវតាផងដែរ ។ គឺព្រះវិស្វកម្មនេះហើយ ដែលបានផលិតអាវុធឈ្មោះ " អគ្នីយាស្ត្រ " និងបានបង្ហាត់បង្ហាញវិជ្ជាមួយឈ្មោះថា " ស្ថាបត្យវេទ " ជាវិជ្ជាផ្នែកខាងស្ថាបត្យកម្ម និងខាងយន្តកម្ម ។ មានវីរកថាខ្លះនិទានថា ព្រះអង្គជាអម្ចាស់ ឬជាមេនៃសិល្បៈ ជាអ្នកផលិតវត្ថុសិប្បកម្មចំនួនមួយពាន់មុខ ជាវឌ្ឍកី ( ជាង សំណង់ ) របស់ពួកទេវតា ជាអ្នកឧត្តុង្គឧត្តម លើសិប្បករទាំងអស់ ។ ទ្រង់បាន កសាងរថ ដែលអាចហោះនៅលើមេឃបានសម្រាប់ពួកទេវតា ។ នៅក្នុងរឿងរាមាយណៈ មានការនិទានថា ព្រះវិស្វកម្មបានកសាងទីក្រុងលង្កាឱ្យពួកយក្ស និងបិសាច និងបានបង្រៀនស្វាមួយឈ្មោះ នល ឱ្យចេះសង់ស្ពានធ្វើពីថ្មបណ្តែតទឹក ឆ្លងកាត់សមុទ្រពីប្រទេសឥណ្ឌាចុងខាងត្បូង ទៅកាន់កោះលង្កា ដោយដាក់ឈ្មោះថា " រាមសេតុ " ។ មានរឿងបុរាណមួយនិទានថា ព្រះវិស្វកម្មជាបុត្ររបស់ព្រះប្រភាស ជាមួយព្រះជាយារូបស្រស់ ហើយប្រកបដោយគុណសម្បត្តិដ៏ពិសេស ព្រះនាម យោគសិទ្ធា ។ ព្រះប្រភាសជាទេវតាទី ៨ ក្នុងចំណោមទេវតា ៨ អង្គ ដែលនៅគង់គាល់ជាប់ជាមួយព្រះឥន្ទ្រា ។ ព្រះវិស្វកម្មមានបុត្រីមួយអង្គព្រះនាមសញ្ញា ។ ព្រះនាងបានរៀបអភិសេកជាមួយព្រះសុរិយា ( ព្រះអាទិត្យ ) ។ ប៉ុន្តែ

ដោយហេតុតែព្រះនាងមិនអាចទ្រាំទ្របាន នឹងបំណែកនៃកម្មរស្មីរបស់ព្រះសុរិយា បានព្រះវិស្វកម្មក៏ដាក់ព្រះសុរិយាលើម៉ាស៊ីនក្រឡឹងរបស់ព្រះអង្គ រួចកាត់កាំរស្មីរបស់ព្រះសុរិយានោះចេញអស់ ១ភាគ ៨ទៅ ។ បំណែកនៃកម្មរស្មីទាំងអស់ក៏ធ្លាក់មកលើផែនដី ដែលព្រះវិស្វកម្មយកមកធ្វើជាថាស សម្រាប់ព្រះវិស្ណុមួយ, ច្បូកសម្រាប់ព្រះសិវៈមួយ, អាវុធរបស់ព្រះកុវេរៈមួយ, លំពែងរបស់ព្រះ កត្តិកីយ៍មួយ ( ទេវតានៃសង្គ្រាម ) ព្រមទាំងអាវុធផ្សេងៗទៀត សម្រាប់ពួកទេវតា ទាំងឡាយ ។ គេតែងតំណាងព្រះវិស្វកម្ម ដោយការនិទានថា ព្រះអង្គធ្វើឱ្យកើតបានជារូបភាពដ៏ធំនៃព្រះជគន្នាថ ( គឺព្រះវិស្ណុ ឬក៏អាចថា ព្រះក្រឹស្ណាក៏បាន ) ។ ព្រះជគន្នាថ ត្រូវបានទទួលកិត្តិយស និងការគោរពបូជារហូតមកដល់សព្វថ្ងៃនេះ នៅតាមតំបន់នានានៃប្រទេសឥណ្ឌា ដូចជានៅក្នុងរដ្ឋបីង្គ័ល និងជាពិសេសនៅក្នុង ក្រុងមួយឈ្មោះ " បុរី " នៃរដ្ឋឱរិស្សា ដែលមានទីកន្លែងសម្រាប់ពិធីបូជានេះធំជាងគេ ដូចជាពិធីបុណ្យ " ស្នានយាត្រា " និងបុណ្យ " រដ្ឋយាត្រា " នៅក្នុងខែ ជេស្ឋ និងខែអាសឍជាដើម ។ ដោយសារព្រះអង្គមានសមត្ថភាពពូកែខាងច្នៃប្រឌិត ព្រមទាំងបង្កើតអ្វីៗឱ្យមានឡើងនុ៎ះ ជួនកាលគេក៏ចាត់ទុកព្រះអង្គថា ជាព្រះប្រជាបតិមួយអង្គដែរ ។ ព្រះអង្គមានព្រះនាមផ្សេងៗទៀតថា ការុ ( ជាង ឬអ្នកមានទឹកដៃ ) តក្សកៈ ( អ្នកកាត់ឈើ ) ទេវវឌ្ឍកៈ ( ជាងសំណង់របស់ពួកទេវតា ) ។

រៀបរៀងដោយ **ធន់ ហិន**

* * *

# រឿង
# សសបណ្ឌិត និង ពួកសត្វចាំសីល

**ឱម ខែម**

ដកស្រង់ និងរៀបរៀង

រឿងនេះ មានសំដែងនៅក្នុងសុត្តន្តបិដក ត្រង់បុចិមន្តវគ្គ ចតុក្កនិបាតថា កាលព្រះបរមសាស្តានៃយើងគង់នៅក្នុងវត្តជេតពន ទ្រង់សំដែងប្រារព្ធនឹងកុដុម្ពិក៍ម្នាក់ដែលនៅក្នុងក្រុងសាវត្ថី ។ កដុម្ពិក៍នេះជាអ្នកមានសទ្ធា បានចាត់ចែងនិមន្តព្រះសង្ឃ ៥០០ អង្គ មានព្រះពុទ្ធជាប្រធាន មកថ្វាយទានគ្រប់មុខ ឥតខ្វះអ្វីឡើយ ។ លុះរួចរាល់ភត្តកិច្ច ព្រះសាស្តាទ្រង់ធ្វើអនុមោទនាថាៈ " *ការឱ្យទានបែបនេះ ត្រូវតាមក្រសែពួកអ្នកប្រាជ្ញអំពីជំនាន់ដើម ដែលអាចលះជីវិតឱ្យជាទានដល់ស្មូមទាំងពួងបាន* " ហើយទ្រង់លើករឿងនោះមកសំដែង ដូចតទៅនេះ :

ក្នុងកាលកន្លងហើយ ព្រះរាជាព្រះនាមព្រហ្មទត្ត សោរាជសម្បត្តិក្នុងក្រុងពារាណសី ។ សម័យនោះ ព្រះពោធិសត្វយោនយកកំណើតជាសត្វទន្សាយ នៅអាស្រ័យក្នុងដងព្រៃមួយ ដែលមានជើងភ្នំព័ទ្ធម្ខាង មានស្ទឹងម្ខាង ម្ខាងទៀតមានស្រុកបច្ចន្តគ្រាម ។ នៅក្នុងដងព្រៃនោះ មានសត្វស្វា ១ ចចក ១ និងភេ ១ ជាសំឡាញ់នឹងគ្នា បាននៅរួមជាមួយគ្នានឹងសសបណ្ឌិត ( ទន្សាយពោធិសត្វ ) ដែរ សុទ្ធតែជាបណ្ឌិត គឺជាសត្វចេះដឹង, តែងនាំគ្នាស្វែងរកអាហារតាមទីកន្លែងតែរៀង១ខ្លួន លុះវេលារសៀលល្ងាចទើបមកជួបជុំគ្នា ។ ចំណែកទន្សាយពោធិសត្វវិញ តែងពន្យល់ធមិ អាចិ និងឱ្យឱវាទដល់សត្វទាំង ៣ ថា " *អ្នករាល់គ្នាត្រូវឱ្យទាន*

ត្រូវរក្សាសីល ត្រូវធ្វើឧបោសថកម្មតាមកាល កុំបីខានឡើយ " ។ សត្វទាំងនោះលុះទទួលឱវាទហើយ ក៏ចូលទៅជ្រកសំងំនៅក្នុងគុម្ពឈើជាលំនៅឋានតែសព្វខ្លួន ។

ថ្ងៃមួយជាខាងក្រោយមក ទន្សាយពោធិសត្វក្រឡេកមើលទៅលើមេឃ បានឃើញព្រះចន្ទភ្លឺក្នុងផ្ទៃអាកាស ក៏ប្រាប់សត្វទាំង ៣ ថា " *ស្អែកនេះ ជាថ្ងៃត្រូវរក្សាឧបោសថ អ្នកទាំងអស់គ្នាចូរសមាទានសីល និងត្រូវរក្សាឧបោសថសីល ព្រោះអ្នកដែលរក្សាសីល ហើយឱ្យទានផង រមែងបានផលច្រើន ដូច្នេះ កាលបើមានស្មូមណាមួយដើរមកដល់ អ្នកត្រូវតែឱ្យអាហារដែលមានឱជារស* " ។ សត្វទាំង ៣ ទទួលព្រមតាម ហើយក៏ទៅជ្រកដេកនៅក្នុងកន្លែងរបស់ខ្លួនទីទៃពីគ្នា ។ លុះព្រឹកព្រាងឡើងបណ្តាសត្វទាំង ៤ នោះ សត្វភេក៏ត្រាច់ទៅរកអាហារពីព្រលឹម ដើរអើតឆើតៗ សំដៅទៅកាន់ឆ្នេរទន្លេគង្គា ។ គាប់ជួនពេលនោះ មានព្រានសន្ទូចម្នាក់បានត្រីឆ្អិន ៧ កាត់យកវល្លិដោតជាចង្កោមកប់ទុកក្នុងដីខ្សាច់ទៀបមាត់ច្រាំងទន្លេគង្គា ហើយដើរចុះទៅយកត្រីខាងក្រោមទន្លេទៀត ។ ឯភេ លុះធំក្លិនត្រី ក៏កកាយដីខ្សាច់អូសត្រីនោះយកមក ហើយស្រែកសួរ ៣ ដងថា " *ត្រីនេះមានម្ចាស់ឬទេ ?* កាលមិនឃើញមានម្ចាស់ ក៏ពាំយកទៅទុកនៅគុម្ពឈើជាលំនៅ រងចាំកាលគួរនឹងបរិភោគ រួចដេកពិចារណាសីលរបស់ខ្លួនសិន ។ ឯសត្វចចក បានចេញទៅរកអាហារដែរ ស្រាប់តែទៅពើបពះប្រទះនឹងសាច់ជ្រូងចពីរចង្កាក់ ទាំងទន្សងឆ្អើរ ១ និងទឹកដោះខាប់ ១ ដប ដែលអ្នកស្រែម្នាក់បានដាក់ក្នុងខ្ទម ក៏ស្រែកបន្លឺ ៣ ដងថា " *របស់ទាំងនេះមានម្ចាស់ឬទេ ?* " លុះមិនឃើញមានម្ចាស់ ក៏ពាក់ខ្សែដែលចងដបទឹកដោះនឹងក មាត់ពាំសាច់ជ្រូងច និងទន្សងឆ្អើរ យកទៅទុកក្នុងគុម្ពឈើជាលំនៅខ្លួន គិតថាចាំដល់ពេលគួរសឹមបរិភោគ ហើយពិចារណាសីលរបស់ខ្លួនដែរ ។ ឯពានរវិញក៏ចូលទៅកាន់ដងព្រៃ បេះបានស្វាយទុំយកមកទុកក្នុងគុម្ពឈើជាលំនៅខ្លួន ហើយគិតថា ចាំដល់ពេលទើបបរិភោគ ក៏ដេកពិចារណាសីលរបស់ខ្លួនដែរ ។

ថ្លែងឯសសបណ្ឌិត គិតថា " *ចាំដល់ពេលស្រួល អញនឹងចេញទៅស៊ីស្មៅចិញ្ចៀន តែបើមានពួកស្មូមដើរមកកាន់សំណាក់នៃអញ អញនឹងឱ្យស្មៅដល់គេម្ដេចកើត ស្នូម្បីតែល្ង ឬ អង្ករជាដើម ក៏អញគ្មានដែរ, ប៉ុន្តែ បើស្មូមដើរមកមែន អញនឹងឱ្យសាច់សរីរៈរបស់អញពុំខានឡើយ* " ។ ដោយអំណាចតេជះសីលរបស់ព្រះពោធិសត្វ លំនៅនៃសក្កទេវរាជក៏ក្ដៅ ។

ខណៈនោះ ក៏ចុះមកសាកល្បងសសបណ្ឌិត ដោយដើរចូលទៅលំនៅសត្វភេ, ភេឃើញក៏សំដែងការរាក់ទាក់ និងសុំឱ្យតាព្រាហ្មណ៍ទទួលអាហាររបស់ខ្លួន ហើយធ្វើសមណធម៌ចុះ ។ ឥន្ទ្រព្រាហ្មណ៍តបវិញថា " *ល្អហើយចៅតា ! ចូរទុកទៅសិនចុះ* " ហើយគាត់ក៏ដើរហួសទៅកាន់លំនៅសត្វចចកទៀត ។ ឯចចកលុះឃើញព្រាហ្មណ៍មកដល់ ក៏ពោលពាក្យរួសរាយមករកថា :

" *តាព្រាហ្មណ៍អើយ ! ភត្តាហារដែលគេនាំមកក្នុងពេលយប់ គឺសាច់ជ្រូចពីរចង្កាក់, ទន្សងឆ្អើរ ១ និងទធិ ១ ដប របស់អ្នករក្សាស្រែឯណោះ ដែលនៅជិតខ្ញុំ ខ្ញុំមានតែរបស់ប៉ុណ្ណេះ ស្ទូមអញ្ជើញពិសារវត្ថុទាំងនេះ ហើយនៅធ្វើសមធម៌ក្នុងដងព្រៃចុះ* " ។

ឥន្ទ្រព្រាហ្មណ៍គ្រាន់តែទទួលពាក្យអំណរហើយ ក៏ដើរហួសទៅកាន់លំនៅសត្វស្វាទៀត ។ ឯពានរ កាលឃើញព្រាហ្មណ៍មកដល់ ក៏និយាយសំណេះសំណាលរកតាព្រាហ្មណ៍ថា :

" *តាព្រាហ្មណ៍អើយ ! ខ្ញុំមានតែវត្ថុប៉ុណ្ណេះ គឺផ្លែស្វាយទុំ ទឹកត្រជាក់ នឹងម្លប់ឈើត្រជាក់ ជាទីរីករាយចិត្ត ស្ទូមអញ្ជើញតាពិសាររបស់ទាំងនេះ ហើយនៅធ្វើសមណធម៌ក្នុងដងព្រៃចុះ* " ។

លំដាប់នោះ ឥន្ទ្រព្រាហ្មណ៍ពោលពាក្យទទួលអំណររួចហើយ ក៏ដើរហួសទៅដល់លំនៅទន្សាយពោធិសត្វ ហើយថ្លែងប្រាប់អំពីសេចក្ដីត្រូវការចង់បរិភោគ

អាហារ ហើយរក្សាឧបោសថសីលនៅទីនេះ ។ ឯទន្សាយបណ្ឌិត កាលឮពាក្យនោះ ហើយនិយាយថា: *"តាព្រាហ្មណ៍អើយ ! តាអញ្ជើញមកកាន់សំណាក់របស់ខ្ញុំ ដើម្បីអាហារនេះជាការប្រពៃហើយ, ដ្បិតក្នុងថ្ងៃនេះ ខ្ញុំនឹងបានឱ្យទានដែលខ្ញុំមិនធ្លាប់ឱ្យ តែបើតាជាអ្នករក្សាសីល មិនធ្វើបាណាតិបាតទេ ចូរតាទៅជញ្ជូនឧសមកបង្កាត់ភ្លើងឱ្យបានជារងើក ហើយមកប្រាប់ខ្ញុំវិញ ខ្ញុំនឹងលោតទម្លាក់ខ្លួនត្រង់កណ្ដាលរងើកភ្លើងនោះ, កាលបើសរីរៈសាច់របស់ខ្ញុំឆ្អិនហើយ ចូរតាយកមកពិសា ហើយធ្វើសមណធម៌ចុះ "*។

តមក ទន្សាយពោធិសត្វចរចាជាមួយនឹងព្រាហ្មណ៍ តទៅទៀតថា : *«ទន្សាយមិនមានល្ង មិនមានសណ្ដែកបាយទេ សូម្បីតែអង្ករក៏គ្មានដែរ សូមអញ្ជើញតាពិសាសាច់ខ្ញុំដែលឆ្អិនដោយភ្លើងនេះ ហើយនៅធ្វើសមណធម៌ក្នុងដងព្រៃនេះចុះ "*។

វេលានោះ ព្រះឥន្ទ្រក៏តាក់តែងគំនរភ្លើង ១ គំនរ សុទ្ធតែរងើកដោយទេវានុភាព ហើយមកប្រាប់ពោធិសត្វវិញ ។ ទន្សាយបណ្ឌិតក៏ក្រោកចាកទីដំណេក ដើរសំដៅទៅឈរជិតរងើកភ្លើង ហើយនិយាយថា *"ប្រសិនបើមានពួកសត្វល្អិតនៅជ្រកត្រង់ចន្លោះរោមរបស់យើង សូមកុំឱ្យស្លាប់ឡើយ "* ទើបរលាស់ខ្លួន ៣ ដង ស្រេចហើយក៏ដាក់សរីរៈទាំងស្រុងឱ្យជាប្រមុខនៃទាន គឺលោតទម្លាក់ខ្លួនចុះទៅលើគំនររងើកភ្លើងដែលកំពុងឆេះច្រាលឆ្អៅ ដោយចិត្តរីករាយ ដោយឥតរុញរា ដូចសត្វរាជហង្សចុះមកទំលើគំនរផ្កាឈូកក្រហម ។ គួរឱ្យស្ងើចណាស់ សូម្បីតែរណ្ដៅរោមសរីរៈរបស់ពោធិសត្វក៏ឥតក្ដៅ ឬឆេះដោយភ្លើងឡើយ គឺបែរជាត្រជាក់ ដូចជាគេចូលទៅក្នុងគំនរទឹកសន្សើមវិញ ។ លំដាប់នោះ ទន្សាយបណ្ឌិតស្រែកសួរព្រាហ្មណ៍ថា : *"តាព្រាហ្មណ៍អើយ ! តាធ្វើភ្លើងឱ្យត្រជាក់អ្វីម្ល៉េះ ? សូម្បីតែរណ្ដៅរោមរបស់ខ្ញុំ ក៏ឥតក្ដៅឡើយ ម្ដេចបានជាយ៉ាងនេះ ?* ។ ឯឥន្ទ្រព្រាហ្មណ៍

ឆ្លើយតបថា " *ឱ ! ចៅបណ្ឌិតអើយ ! ខ្ញុំឯងមិនមែនព្រាហ្មណ៍ គឺជា ព្រះឥន្ទពិត ខ្ញុំមកនេះដោយចង់ល្បងមើលទេតើ* " ។ ពោធិសត្វក៏បន្លឺសីហនាទតបថា " *បពិត្រ ទេវរាជ ! កុំថាឡើយព្រះអង្គម្នាក់ឯង បើទុកជាលោកសន្និវាសមកទាំងមូលមក ចង់ល្បងមើលទានរបស់ខ្ញុំក៏ដោយ ត្រង់របស់អ្វីដែលខ្ញុំមិននឹកចង់ឱ្យនោះ គ្មាន ទេ* " ។ លំដាប់នោះ សក្កទេវរាជពោលថា " *ម្នាលសសបណ្ឌិត ! គុណរបស់អ្នក ចូរតាំងនៅប្រាកដអស់ ១កប្បចុះ* " ហើយក៏ច្របាច់ពូតថ្មភ្នំបញ្ចេញជ័រយកទៅគូស វាសជាសសលក្ខណៈ ( គំនូរសត្វទន្សាយ ) ភ្ជាប់នឹងមណ្ឌលព្រះច័ន្ទ រួចហើយនាំ ពោធិសត្វទៅឱ្យដេកនៅក្នុងកន្លែងដដែល មុនហោះទៅកាន់ទេវលោកវិញ ។

ឯសត្វបណ្ឌិតទាំង ៤ រូបបានព្រមព្រៀងគ្នា មានចិត្តស្មោះសរនឹងគ្នា បាន ញុំាងសីលរបស់ខ្លួនឱ្យពេញបរិបូរណ៌ ព្រមទាំងរក្សាឧបោសថ លុះអស់ជីវិតទៅ ក៏ បានទៅកើតក្នុងស្ថានសួគ៌ទាំងអស់គ្នា ។

ព្រះសាស្តាទ្រង់សំដែងប្រជុំជាតកថា : សត្វភេក្នុងជាតិនេះបានមកជា អានន្ទ, សត្វចចកបានជាមោគ្គល្លាន, សត្វស្វាបានជាសារីបុត្ត, ព្រះឥន្ទបានជាអនុរុទ្ធ, ឯសសបណ្ឌិតបានជាតថាគតហ្នឹងឯង ។

# នាយកធម៌ ៦ យ៉ាង

( បទពំនោល )

| | | |
|---|---|---|
| នាយកធម៌ប្រែសេចក្តី | ចេញពីបាលី | ន័យថាជាធម៌អ្នកធំ ។ |
| លោកឱ្យកាន់ចិត្តនិយម | មើលគ្រប់និគម | ធំថែរាស្ត្រប្រជាណា ។ |
| ប្រកាន់តាមពុទ្ធដីកា | រាស្ត្របានសុខា | ថ្លាភ្លឺត្រចាស់ពណ្ណរាយ ។ |
| ធម៌នេះលោកបានបរិយាយ | សូមលើកបកស្រាយ | រ៉ាយរ៉ាប់តាមមាតិកា ។ |
| • ទីមួយលោកហៅ ឥក្ខណា | ឱ្យឃើញហេតុការណ៍ | ថារាស្ត្រសុខទុក្ខម្តេចខ្លះ ។ |
| បើរាស្ត្រមានទុក្ខខ្លាំងណាស់ | រកកិច្ចប្តូរផ្លាស់ | ដាស់រាស្ត្រឱ្យចេះរកស៊ី ។ |
| រកការចែកមុខនាទី | តាមដោយវិធី | ពីកិច្ចជំនាញនោះផង ។ |
| គឺមានដោះស្រាយបំណង | រកការធ្វើផង | ផ្សេងតាមកិរិតនៃខ្លួន ។ |
| យើងត្រូវប្រកាន់តាមក្បួន | កុំបីលោក់ខ្លួន | ពូនសុខតែឯងឡើយណា ។ |
| ឱ្យមានធម៌ព្រហ្មវិហារ | ដល់រាស្ត្រប្រជា | គ្នាបានសុខសួស្តីដែរ ។ |
| • ទីពីរខមាបកប្រែ | បាលីជាខ្មែរ | តែថាឱ្យមានខន្តី ។ |
| លះចិត្តទោសៈអប្រិយ៍ | ទោះទាំងពាក្យអ្វី | គឺមិនស្ទុះតាមគេចាក់ ។ |
| ឬមួយកើតរឿងអប្បលក្ខណ៍ | ឱ្យយើងទោសៈ | ស្ម័គ្រចិត្តរកហេតុសិនទៅ ។ |
| កុំលោតច្រឡោតមួម៉ៅ | ភ្លើងឆេះសន្ធៅ | ក្តៅក្នុងបេះដូងអាត្មា ។ |
| ត្រូវយកធម៌មកពិចារណ៍ | ខុសត្រូវក្តីណា | ត្រាតិតបានឃើញសេចក្តី ។ |
| • ទយាលោកថាទីបី | បកប្រែសេចក្តី | ន័យនេះលោកថាស្រឡាញ់ ។ |
| ឱ្យគិតរិះរេរអស់អញ | យើងត្រូវគ្នេរកាញ់ | នូវផ្លូវអគតិធម៌ ។ |
| មិនត្រូវលំអៀងញាប់ញ័រ | កាន់ក្តីស្មោះសរ | ចរតាមផ្លូវជាកណ្តាល ។ |
| ចំពោះរាស្ត្រទាំងអម្បាល | ធំល្អត្រកាល | ស្រាលដោយលំអៀងចិន្តា ។ |

• ទីបួនជាគិរិយា   ពាក្យនេះប្រែជា   ភ្ញារភ្ញាក់ក្តីរឭកខ្លួន ។

ចេះដឹងមើលឃើញច្បាប់ក្បួន   តាមដោយចំនួន   ខ្លួនជាអ្នកធំលើសជន ។

មិនសាងអំពើណាស៊ុន   ដែលនាំឱ្យអន់   ជនជាតិគេតិះដៀលផង ។

ត្រូវគិតក្តីហេតុសៅហ្មង   កុំចេះតែក្រេង   ចងរឿងដែលមានពាក្យពោល ។

ធម៌ខ្ញុំតែងបទពំនោល   ព្រះពុទ្ធលោកពោល   គោលដៅមន្ត្រីរាជការ ។

• ទីប្រាំហៅឧដ្ឋានា   ប្រែបទអក្ខរា   ថាន័យសេចក្តីតបតាម ។

ព្រះពុទ្ធលោកឱ្យព្យាយម   កិច្ចការក្នុងនាម   តាមខ្លួនធំតួនាទី ។

នោះលោកចែកជាបទពីរ   គឺកម្មវិធី   ទីមួយនោះមានឧស្សាហ៍ ។

ស្វះស្វែងក្នុងកិច្ចស្ថាបនា   ឱ្យថ្កើងរដ្ឋា   ថ្លាថ្លៃរុងរឿងឧត្តម ។

កសាងផ្លូវជាតិតូចធំ   គ្រប់ស្រុកនិគម   កុំឱ្យខ្វះឧបាយយាន ។

សង់សាងនូវសាលារៀន   កូនចៅគ្រប់ឋាន   រៀនសូត្រលើកស្ទួយប្រទេស ។

បង្កើនអប់រំចំណេះ   កូនចៅរៀនចេះ   នេះនាំជាតិថ្កើងថ្លៃថ្លា ។

នឹងផ្នែកវិជ្ជាសាសនា   ក៏ត្រូវប្រឹងស្តារ   នាទីអស់មន្ត្រីធ្វើ ។

ឱហាតខិតខំមើលលើ   ជនសាងអំពើ   ធ្វើខុសអប់រំប្រដៅ ។

ដែលសាងអំពើហ្មងសៅ   ជ្រុលជ្រួសភ្លាត់ផ្លូវ   ត្រូវរកឧបាយទាញទប់ ។

ដោះស្រាយសេដ្ឋកិច្ចបានគ្រប់   ចម្រើនលើសលប់   ឱ្យគ្រប់សម្បូរជាក់ស្តែង ។

កសិកម្មក៏ប្រឹងចាត់ចែង   គ្រប់ទីកន្លែង   ស្វែងរកឧស្សាហកម្ម ។

បរិស្ថានតាមដោយនិគម   សំអាតថែទាំ   ខំរកមូលធនចូលស្រុក ។

បង្កើនអភិវឌ្ឍន៍គ្រប់មុខ   ឱ្យរាស្ត្រផុតទុក្ខ   សុខសប្បាយមានសន្តិភាព ។

ព្យាយាមចាត់ចែងរាប់រៀប   ដាក់ឫកសុភាព   រៀបខ្លួនឱ្យបានប្រពៃ ។

ចាកបាបទាំងតូចធំក្តី   ចិត្តតាមធម៌បី   ស៊ីតាមកម្មបថសុចរិត ។

• ប្រាំមួយដែលព្រះទ្រង់ឫទ្ធិ   ទ្រង់មានគំនិត   ពិតទ្រង់ជាសាស្តាសត្វ

សិរិភាគៈចែងចាត់ ចែកចាយអារកាត់ ចាត់តាមគន្លងធម្មា ។
ចែកចាយរបស់គ្រឿងភស្តុភារ ធនធាននានា ភស្តុភារឱ្យរាស្ត្រផុតភ័យ ។
ប្រកាន់ខ្ជាប់ធម៌នេះនៃ ដែលព្រះចក្រី ស្ដីទុកមកឱ្យយើងស្ដាប់ ។
ព្រះសង្ឃគ្រហស្ថគួរគាប់ ធម៌នេះជាច្បាប់ រាប់តាមមាតិកានោះ ។
ប្រាំមួយលើកមកពិគ្រោះ សម្រាប់អ្នកខ្ពស់ ឈ្មោះនាយកធម្មា ។
បើមានក្នុងប្រទេសណា នឹងបានសុខា ជាស្រុកខ្ពស់របស់លោកិយ ។
រីងមាំអភិវឌ្ឍន៍បុរី ឥតមានមោះមៃ ភយន្តរាយសូន្យហោង ៕

ភិក្ខុ **សាយ សុខហេង** ( សុខាវហាត្ថេរ )
វត្តឧណ្ណាលោម, ភ្នំពេញ

*ខន្តីប្រធាន ប្រសើរលើសទាន*
*ធំក្រៃកន្លង ជាមេរបស់ផល*
*របស់កុសលផង កប្រមចិត្តចង*
*បានសីលខន្តី ។*

សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ
ចន្ទត្ថេរោ **ជួនណាត់ ហ៊ុន**

# បោះបាយបិណ្ឌ

ដោយ មៀច ប៉ុណ្ណ

១. មេឃមីរខ្មៅអាប់សព្វទិសា រដូវវស្សាភ្លៀងជោគជាំ
ផ្គរពេលរសៀលឮគ្រាំៗ ដាស់ខ្មែរឱ្យខំដាំស្ទូងដក ។

២. សត្វចាបដូនតាក៏មកដល់ ហិចហើររចល់ទៅគ្រប់ច្រក
ខំមកទាន់ពេលមិនដែលខក យាសយំលោតហក់លើព្រឹក្សា ។

៣. រដូវដាក់បិណ្ឌផ្ញើមគ្គផល បញ្ជូនកុសលទៅដូនតា
គ្រប់គ្រួលែលកស្បៀងអាហារ រៀងរាល់អាត្មាទៅឯវត្ត ។

៤. នាំនំចំណីបង្អែមចេក ចិន្តាសែនត្រេកយ៉ាងប្រាកដ
ប្រគេនព្រះសង្ឃបច្ច័យភត្ត នេះពិតជាកតញ្ញូតា ។

៥. លោកបានចែកឋានលោលោកិយ ព្រលឹងឃ្លាតខ្ចីរយាត្រា
ទៅកើតឋាននាយដឹងយ៉ាងណា កើតជាមនុស្សាប្រេតអវិចី ។

៦. កូនចៅដៅចិត្តឧទ្ទិសផល បញ្ជូនទៅដល់បុព្វការី
ទោះចាប់កំណើតកើតជាអ្វី សូមផលនិស្ស័យជួយយោងយូរ ។

៧. ឱ្យបានទៅកើតសុគតិភព សូមជួបប្រសព្វនឹងឋានសួគ៌
រួចហើយសូមប្រសិទ្ធិពរ សិរីបវរដល់កូនចៅ ។

៨. ប្រសិនបើភ្លាត់ជាតិកំណើត ទៅកើតជាប្រេតនៅភពក្រៅ
យើងខ្ញុំញាតិមិត្តរីតសោកសៅ អាណិតញាតិផៅដែលអភ័ព្វ ។

៩. ទើបខំស្ទុះស្ទាទាំងប្រុសស្រី ធ្វើនំចំណីប្រសើរគាប់
នោះគឺបាយបិណ្ឌតាមទម្លាប់ បវេណីភ្ជាប់ពីព្រេងព្រឹទ្ធ ។

១០. នៅពេលម៉ោងបួនជូនទៀបភ្លឺ សូរស្គរបន្លឺទាំងងងឹត
លាន់ឮគ្រូងៗដាស់ញាតិមិត្ត ឱ្យតិតរេរិះបោះបាយបិណ្ឌ ។

១១. គឺបាយដំណើបលាយល្ងខ្មៅ ត្រូវពូតផ្តុំក្រោយដាំឆ្អិន
ដាក់ថាសឬតុជាមុនសិន សឹមយកសាជីមកគ្របបិត ។
១២. ចរចូលទៅក្នុងឋានសាលា សូត្រនមស្ការតាមក្រមក្រឹត្យ
កម្សាង់អញ្ជើញសង្រួមចិត្ត វេរភត្តជូនផលដល់ដូនតា ។
១៣. លុះចប់ស្រេចហើយក្រោកចាកទី ទៅតាមពិធីលោកអាចារ្យ
ប្រាប់ប្រុងដល់យើងគ្រប់អាត្មា ចេញក្រៅសាលារៀបក្បួនហែរ ។
១៤. ព្រះសង្ឃទូងស្គរពុំឈរឈប់ ទូង១គម្រប់បួនឥតបែរ
អ្នកបោះបាយបិណ្ឌដើរតាមដែរ ដើរហែរជាក្បួនមានសណ្តាប់ ។
១៥. អាចារ្យឧទ្ទិសដង្ហោយហៅ អស់ប្រេតក្នុងក្រៅមកប្រញាប់
ទទួលបាយបិណ្ឌឆ្ងាញ់ចំណាប់ សេពសោយឱ្យឆាប់មុនថ្ងៃរះ ។
១៦. ព្រោះប្រេតទាំងនោះអាក្រាតកាយ ពេលថ្ងៃពួនបាត់ខ្មាសគេណាស់
ខ្លួនអត់ខោអាវនឹងបូរផ្លាស់ ស្ទើរចរហ៊ានសចូលព្រៃវិញ ។
១៧. ស្គរទូងអន្លង់ឮធ្ងន់១ ចាស់ក្មេងរំងយន់ចិត្តកន្ទេញ
កន្ទក់ឱរ៉ាសែនទោម្នេញ អាសូរប្រេតចេញតែពេលយប់ ។
១៨. ដៃចាប់បាយបិណ្ឌបោះបាចទៅ វាចាហាហៅញាតិឥតឈប់
មកទទួលទានឱ្យបានគ្រប់ ហូបឱ្យស្កល់ស្កប់ចម្អែតកាយ ។
១៩. បាចបោះដុំបាយគ្រប់បីជុំ ដាក់ទៅតាមមុមទិសទាំងឡាយ
ប្រាំបីទិសពិតពុំឃ្លាតក្លាយ ចែកចាយដោយចិត្តផ្ចិតមេត្តា ។
២០. នេះហើយគឺប្រពៃណីខ្មែរ ធ្លាប់តែធ្វើមកតាមតម្រា
ត១គ្នារៀងជាធម្មតា ជូនដល់ដូនតាបុព្វការី ។
២១. មិនអាចខកខានធ្វើពិធី ព្រោះប្រពៃណីធំពេកក្រៃ
ទោះក្រលំបាកយ៉ាងណាក្តី ថៃធ្វើឱ្យបានលំអានចាស់ ។

# ក្លូចនិងជីវិតរស់នៅរបស់ប្រជាជនខ្មែរ

ដោយ ចិន ធីរិទ្ធិ, នួន សោភ័ណ



## I - សេចក្តីផ្តើម :

ប្រទេសកម្ពុជាជាប្រទេសមួយ ដែលមានអាកាសធាតុក្តៅហើយសើម ដែលជាកត្តាដ៏សំខាន់ដល់ការលូតលាស់នៃរុក្ខជាតិគ្រប់ប្រភេទ ។ ព្រៃឈើដែលគេឃើញមានដុះច្រើនជាងគេ គឺនៅតំបន់ខ្ពង់រាបតាមដងទន្លេមេគង្គ និងតំបន់ភ្នំ ។ ដោយសារកម្ពុជាយើង សម្បូរទៅដោយធនធានធម្មជាតិបែបនេះហើយ ទើបធ្វើអោយប្រជាជនខ្មែរយើងនៅសម័យដើម ច្រើនពឹងផ្អែកទៅលើធម្មជាតិសំរាប់ញ៉ាំងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនអោយប្រព្រឹត្តទៅបាន ដូចជា ចូលព្រៃកាប់ឈើ យកមកសង់ផ្ទះ

ធ្វើជាជំរក បេះផ្លែឈើ, បន្លែ, មើមដំឡូង, មើមក្ដួច បរបាញ់សត្វព្រៃ ធ្វើជាចំណីអាហារ តាមទំនៀមទំលាប់ របស់ប្រជាជនខ្មែរ ។

ប៉ុន្តែសព្វថ្ងៃនេះ ការកាប់ព្រៃឈើ និងការបរបាញ់បំផ្លាញសត្វព្រៃ ត្រូវបានច្បាប់របស់រដ្ឋហាមឃាត់ ព្រោះរបរទាំងនេះធ្វើអោយប៉ះពាល់ដល់បរិស្ថានធម្មជាតិ ដែលធ្វើអោយប្រទេសកម្ពុជាជួបប្រទះនូវគ្រោះធម្មជាតិ មានភាពរាំងស្ងួត, ទឹកជំនន់...។

កាលពីសម័យដើម ប្រជាជនខ្មែរ នៅពេលដែលជួបប្រទះគ្រោះទុរ្ភិក្សបណ្ដាលមកពីសង្គ្រាម, ភាពរាំងស្ងួត, ទឹកជំនន់ ពួកគាត់តែងតែបបួលគ្នាចូលព្រៃ ដើម្បីស្វែងរកបន្លែ, ផ្លែឈើ, មើមដំឡូង, មើមក្ដួច យកមកច្នៃ និងចំអិនធ្វើជាចំណីអាហារ ។ បច្ចុប្បន្ន ប្រជាជនខ្មែរយើងមួយចំនួនមិនបានដឹងពីសារប្រយោជន៍នៃមើមក្ដួចថា អាចយកមកបរិភោគបណ្ដោះអាសន្ន នៅពេលជួបប្រទះគ្រោះទុរ្ភិក្សនោះឡើយ ។

ដូចនេះ អត្ថបទនិយាយអំពីក្ដួច គឺចង់បង្ហាញអំពីទំនៀមទំលាប់របស់ខ្មែរសម័យដើមក្នុងការច្នៃមើមក្ដួច ដើម្បីយកមកចំអិនធ្វើជាចំណីអាហារជំនួសបាយអង្ករ ព្រោះមើមក្ដួចសំបូរដោយម្សៅ សារជាតិអាមីដុង ( Amidon ) ខ្ពស់អាចទ្រទ្រង់រូបរាងកាយដល់ប្រជាជនខ្មែរយើងបាន និងមានអត្ថប្រយោជន៍ផ្សេងៗ ជាច្រើនទៀត ព្រមទាំងបានបញ្ជាក់ពីទំនាក់ទំនងរបស់សហគមន៍ និងបរិស្ថានធម្មជាតិ ។

## II ៖ ទ្រង់ទ្រាយរុក្ខជាតិក្ដួច

### ១៖ ទ្រង់ទ្រាយក្ដួច :

-ដើម : ដើមរបស់ក្ដួចមានលក្ខណៈជាវល្លិមានបន្លាស្រួចៗ ដូចបន្លាត្រសក់ ហើយមានថ្នាំង ដែលក្នុងថ្នាំង មានប្រវែងប្រហែលពី៣០ទៅ៤០សង់ទីម៉ែត្រ ។

នៅត្រង់ចំនុចថ្នាំងនិមួយៗ មានដុះចេញនូវសន្លឹក និងផ្កា ។ ដើមរបស់ក្ទួចមានពណ៌ពីរបែប ទី១ពណ៌ស្វាយក្រមៅ ប្រៀបដូចសំបកផ្លែទំពាំងបាយជូរព្រៃ ពណ៌នេះ គឺគេសម្គាល់ថា ជាក្ទួចដំណើប ។ ទី២ ពណ៌បៃតង គឺគេសម្គាល់ថាជាក្ទួចខ្សាយ ។

-សន្លឹក : ស្លឹករបស់ក្ទួចមានសណ្ឋានផែកជាបី ហើយស្រួចខាងចុង និងមានទ្រនុងរឹង ។ ស្លឹករបស់ក្ទួចមានពណ៌បៃតងហើយមានរោមខ្ចីៗ និងមានក្លិនក្រពុល ។

-ផ្កា : ផ្ការបស់ក្ទួចវាដុះចេញពីថ្នាំងជាមួយស្លឹក ។ ផ្កានេះមានពណ៌សរាងតូចល្អិត និងមានទងទ្រវែង ហើយមានក្លិន ក្រពុលស្រាល ។

-ផ្លែ : ផ្លែរបស់ក្ទួចមានទំរង់បីជ្រុង ប្រហាក់ប្រហែលផ្លែស្លី ។ ផ្លែក្ទួចមានពណ៌បៃតង ។ ពេលផ្លែវាចាស់ វាប្តូរទ្រង់ទ្រាយបះកន្ទុយឡើងលើ ។ ក្នុងមួយចង្កោមមានប្រមាណពី១០ទៅ២០ផ្លែ ។ ក្នុងផ្លែនីមួយៗ មានគ្រាប់សំប៉ែតៗចំនួន៣គ្រាប់ ពេលផ្លែក្ទួចទុំ វាផ្ទុះធ្លាក់គ្រាប់មកលើដី។ នៅរដូវភ្លៀងធ្លាក់គ្រាប់នេះអាចដុះលូតលាស់បាន ។

-មើម : មើមរបស់ក្ទួចមានរាងមូល ខ្លះទ្រវែង ទៅតាមសណ្ឋានដី ដែលអំណោយផលដល់ការចុះមើម ។ សំបកមើមក្ទួចមានពណ៌គគីស្រដៀងសំបកដំឡូងដៃខ្លា មានឫសស្ទេញស្ទាញព័ទ្ធជុំវិញមើម ដូចជាឫសឫស្សី ។ ក្ទួចមានមើមព័ទ្ធជុំវិញដើម ក្នុងមួយដើមមានមើមចំនួនពី១មើមទៅ៨មើម ។ មើមនីមួយៗដុះចេញពីគល់តែមួយ ។ សាច់មើមក្ទួចមានពីរប្រភេទ គឺសាច់ពណ៌លឿង និង ស ហើយមានក្លិនក្រពុល និងរមាស់ទៀតផង ។

**២‿ប្រភេទក្ទួច :**

ក្ទួចមានពីរប្រភេទ :

-ក្លូចខ្យាយ : ដើមរបស់ក្លូចខ្យាយមានពណ៌បៃតង ហើយធំជាងដើមក្លូចដំណើប ។ ចំពោះសណ្ឋានស្លឹក គឺមានលក្ខណៈដូចគ្នា មិនថាដំណើប ឬខ្យាយឡើយ ។ មើមរបស់ក្លូចខ្យាយមានសំបកពណ៌តត់ដូចក្លូចដំណើបដែរ តែសាច់របស់មើមក្លូចខ្យាយមានពណ៌ស ដូចសាច់ប៉ិតក់ ។

-ក្លូចដំណើប : ដើមរបស់ក្លូចដំណើបមានពណ៌ស្វាយក្រមៅ ដូចសំបកផ្លែទំពាំងបាយជូព្រៃ ។ មើមរបស់ក្លូចដំណើបច្រើនតែចុះរាក់ៗឬស៊ើៗមើលឃើញនៅលើដី ។ សំបករបស់ក្លូចដំណើបដូចក្លូចខ្យាយដែរ តែសាច់មើមក្លូចដំណើបមានពណ៌លឿងខុសពីក្លូចខ្យាយ ។

## III . តំបន់ដែលមានក្លូច :

១-ទីកន្លែង : ក្លូចជារុក្ខជាតិវល្លិ គ្មានដៃនៅត្រង់ចំនុចថ្នាំង ដូចវល្លិននោងទេ ដូចនេះការដុះលូតលាស់របស់វា គឺវាអាស្រ័យពឹងពាក់ទៅលើរុក្ខជាតិផ្សេងៗដើម្បីងាយស្រួលដល់វល្លិរបស់វារុំពទ្ធ័ វារឡើងមែកឈើ ។ វល្លិរបស់វាពទ្ធ័ពីឆ្វេងទៅស្តាំ ។ រុក្ខជាតិក្លូចគេឃើញមានដុះនៅតាមតំបន់ភ្នំ តំបន់ព្រៃរបោះ និងនៅតាមតំបន់ខ្ពង់រាប ។ រុក្ខជាតិក្លូចគេអាចយកមកដាំនៅក្បែររបងផ្ទះ ដែលមានទីខ្ពស់មិនលិចទឹក ។

ក្លូចអាចដុះនៅតាមកន្លៀតថ្ម ឬដុះនៅលើដីបន្តិចបន្តួចលើផ្ទាំងថ្ម ប៉ុន្តែក្លូចដែលដុះនៅតាមកន្លៀតថ្ម មិនមានមើមធំ ឬមូលដូចក្លូចដែលដុះនៅលើដីធម្មតានោះទេ មើមរបស់វាមានរាងសំប៉ែត ហើយជាផលលំបាកដល់ការជីកយកមើម ។ ចំណែកឯក្លូចដែលដុះនៅលើផ្ទាំងថ្មដែលមានដីបន្តិចបន្តួចនោះពុំមានមើមធំទេ ហើយជីវិតរបស់វា ក៏មិនអាចរស់បានយូរអង្វែងដែរ ។

២-ជីវិតក្រាំង : ក្លួចជារុក្ខជាតិដែលមានដើមទោល ( ១ដើម ) ។ វាអាច គោរទាំងដើម គោរទាំងមើម តែគល់របស់ក្លួចមិនអាចស្លាប់ទេ ទោះបីជានៅរដូវណាក៏ដោយ ។ បើគេចង់ដាំក្លួចគេពុំសូវយកគ្រាប់ឬកូនក្លួចមកដាំនោះទេ គេច្រើនតែយកគល់របស់វាទៅដាំ ព្រោះគល់របស់ក្លួចឆាប់លូតលាស់ និងចុះមើមរហ័សជាងការដាំកូន និងដាំគ្រាប់ ។

អ្នកករបរក្លួចតែងមានទំលាប់មួយ គឺក្រោយពេលគាស់មើមក្លួចហើយ ពួកគាត់ច្រើនតែយកគល់របស់ក្លួចនេះទៅកប់កន្លែងដើមវិញ ព្រោះគល់នេះពេលរដូវភ្លៀងឆ្នាំក្រោយនឹងផ្តល់ផលបន្តទៀត ។ គេមិនអាច យកចំណែកនៃមើមក្លួចណាមួយយកទៅដាំដុះទេ ។

-គោរមើម : មើមរបស់ក្លួច ដល់រយៈពេលណាមួយជាកំណត់ វាត្រូវស្មុះអស់ ហើយវានៅតែឫសស្មោញស្មាញ ដូចជាស្មាញនទោងជាប់ជាមួយគល់របស់វា ។

បន្ទាប់មក ពេលរដូវភ្លៀវធ្លាក់ វាក៏ចាប់ផ្តើមផ្តុចមើមថ្មីនៅជុំវិញគល់របស់វាវិញ ។ មើមដែលគោរច្រើនលើក ច្រើនសារ ធ្វើអោយមើមក្រោយមានផលកាន់តែច្រើន ។ ការគោរមើមមិនមានរយៈពេលកំណត់ច្បាស់លាស់ទេ គឺអាស្រ័យទៅលើតំបន់និងអាកាសធាតុ ។ បើអាកាសធាតុក្តៅ ឬមើមនៅននលគកលើដី មិនមានស្លឹកគ្របទេ ធ្វើអោយមើមនេះឆាប់គោរ តែបើមើមដែលនៅម្លប់ក្នុងព្រៃហើយមិនជាំទឹក ធ្វើអោយការគោរមើមមានរយៈពេលយូរ ។

-គោរដើម : ដើមរបស់ក្លួច ចាប់ផ្តើមស្វិតពីចុងមកគល់នៅសល់ដើមប្រវែងប្រហែល ២ម៉ែត្រ ពីដី វាក៏ចាប់ផ្តើមដុះចេញនូវដើមថ្មីរុំពទ្ធ័ដើមចាស់នេះ ។ ដើមរបស់ក្លួចច្រើនគោរនៅ រដូវប្រាំង ។

## IV . ការស្វែងរកក្លួច :

ការរុករកមើមក្តួចភាគច្រើនប្រជាជនរស់នៅតាមតំបន់ភ្នំ ជើងភ្នំ និងខ្ពង់រាប ។ ពេលគេជួបប្រទះគ្រោះទុរ្ភិក្ស ពួកគាត់តែងបបួលគ្នីគ្នាក្នុងគ្រួសារ ឬជាក្រុមនាំគ្នាទៅជីកមើមក្តួចនៅតំបន់ភ្នំ ឬតំបន់ ដែលពួកគេធ្លាប់ទៅរក ដូចជាប្រជាជននៅស្រុកគិរីវង្ស ខេត្តតាកែវ បានអោយឈ្មោះទួលមួយថា ( ព្រៃក្តួច ) ។

ឧបករណ៍ដែលពួកគាត់យកទៅជាមួយសំរាប់រកក្តួច គឺមាន កាំបិត ចបជីក ការុង... ។

១-ការរកក្តួច : គេស្វែងរកមើលទៅលើដើមឈើ ហើយសំឡឹងរកសន្លឹក និងដើមរបស់ក្តួចដែលរុំពទ័តាមមែកឈើ ។ បន្ទាប់មកគេតាមដានរហូតដល់គល់របស់វា ។ នៅពេលដែលគេឃើញគល់របស់វា គេយកឈើចាក់មើលមើម ថាតើមានមើមធំ ឬតូច តិច ឬច្រើន ។ បើមើមនេះនៅតូចគេទៅរកផ្សេងទៀត ។

២-ការធ្វើក្តួច : ពេលគេយកមើមក្តួចមកពីព្រៃ គេលាងទឹកអោយជ្រះដី ។ ក្រោយមកគេយកទៅចិតសំបកចេញ បន្ទាប់ពីចិតសំបករួច គេយកទៅលាងទឹករួចហាន់ ឬឈូសជាបន្ទះស្តើងៗ ហើយយកទៅដាក់ក្នុងកូនពាងរួចរោយអំបិលជាស្រទាប់ៗ ហើយផ្អាប់ទុកចោលមួយយប់ ។ លុះព្រឹកឡើងគេធ្វើការស្រង់ក្តួចចាក់ដាក់ក្នុងកញ្ជើរ ឬល្អីយកទៅសំអាតសារជាតិពុលនៅកន្លែងផ្លូវទឹកហូរ តែគេមិនអាចយកក្តួចទៅសំអាតនៅកន្លែងដែលមានទឹកនឹង ដូចជាស្រះ ត្រពាំងដែលគេប្រើប្រាស់ប្រចាំថ្ងៃទេ ព្រោះធ្វើឱ្យអ្នកដែលយកទឹកទៅប្រើប្រាស់មានគ្រោះថ្នាក់ (ពុល) ។ ពេលគេយកក្តួចទៅកន្លែងទឹកហូរ គេជាន់ឬ ជ្រាវច្របាច់ទាល់តែឃើញទឹកឡើងថ្លា ហើយទុកចោលក្នុងស្រែ ឬផ្លូវទឹកហូរឆ្លងកាត់ក្នុងរយៈពេលមួយយប់ មួយថ្ងៃ ។ ការទុកចោល

នេះគេឧស្សាហ៍ទៅជ្រាវ ឬច្របាច់លាងពីបី ទៅបួនដង ដើម្បីអោយសារជាតិពុលហូរទៅតាមទឹក ។ ក្រោយមកគេឃើញមាន ក្តាម ខ្យង ខ្ចៅ ត្រីចង្វា ឬត្រីក្រឹមចូលក្នុងកញ្ជើរ ឬល្អីក្តួចដែលត្រាំពន្លិចក្នុងទឹក ។ ពេលនោះគេសន្និដ្ឋានបានថា ក្តួចដែលគេធ្វើកន្លងមកអស់នូវសារជាតិពុលហើយ ។ ក្រោយមកគេច្រកក្នុងការុងចងមាត់អោយជិតរួចយកទៅដាក់លើគ្រែរនាប ហើយយកដុំថ្ម ឬត្បាល់កិនម្សៅសង្កត់ពីលើ ដើម្បីអោយទឹកហូរស្រក់ចេញពីក្តួចដែលនៅក្នុងការុងប្រៀបដូចយើងកិនម្សៅអង្ករ រួចសង្កត់ច្រោះអោយអស់ជាតិទឹកនោះដែរ ។ នៅពេលស្រក់ទឹកអស់ពីការុង យើងចាក់ដាក់ចង្អេរ ឬកន្ទេលស្លឹកត្នោត រួចយកមកសំដិលហាលថ្ងៃអោយក្រៀម ទើបគេអាចរក្សាទុកបានយូរ ។ ប៉ុន្តែក្តួចនៅសើមយកមកដាំបាយ មានរសជាតិឈ្ងុយឆ្ងាញ់ជាងក្តួចហាលក្រៀម ។

ក្នុងការធ្វើក្តួចនេះគេហាមប្រាមចំពោះអ្នកដែលទើបសំរាលកូនរួច គឺមិនអាចមកហាន់ក្តួច ឬមកជ្រាវច្របាច់ក្តួចបានទេ ព្រោះក្តួចធ្វើអោយរមាស់ដៃ ក្លិនរបស់វាក្រពុលអាចធ្វើអោយអ្នកកូនខ្ចីទាស់បាន ។ ហេតុនេះ អ្នកដែលទើបសំរាលកូនរួចមិនអាចមកធ្វើក្តួចបានទេ ។ ប៉ុន្តែអ្នកទើបសំរាលកូនអាចបរិភោគបាយឬបង្អែមក្តួចដោយមិនមានបញ្ហាទាស់ ឬផ្តល់ផលប៉ះពាល់ផ្សេងៗ ដល់សុខភាពឡើយ ។

## V – សារប្រយោជន៍រុក្ខជាតិក្តួច

-<u>ធ្វើចំណីអាហារ</u> : នៅពេលប្រជាជនខ្មែរជួបប្រទះ នឹងគ្រោះទុរ្ភិក្សដោយសារទឹកជំនន់...គឺគេយកមើមក្តួចមកធ្វើជាអាហារជំនួសបាយ ឬយកមកដាំលាយជាមួយអង្ករ។ រុក្ខជាតិក្តួចមិនមែនមានតម្រូវការតែនៅពេលជួបប្រទះគ្រោះទុរ្ភិក្សប៉ុននោះទេ ទោះបីជាសម័យដែលសម្បូរស្រូវអង្ករហើយក៏ដោយ ក៏ប្រជាជនខ្មែរ

នៅតែទៅរកមើមក្ដួចមកធ្វើជានំចំណី បង្អែម ជាដើម ជាពិសេសនៅតាមតំបន់ដាច់ស្រយាលតំបន់ភ្នំ ឬតំបន់ដែលនៅឆ្ងាយពីទីផ្សារ ដូចជាបច្ចុប្បន្ននេះ នៅភូមិខ្ទាវ ឃុំព្រៃអំពក ស្រុកគីរីវង្ស ខេត្តតាកែវ ប្រជាជនបានទៅរកក្ដួចមកដាំបាយ និងធ្វើជានំចំណីបានជាច្រើនបែបច្រើនយ៉ាង ព្រោះមើមក្ដួចសម្បូរដោយម្សៅសារជាតិអាមីដុង និងមានរសជាតិឈ្ងុយឆ្ងាញ់ថែមទៀតផង ។

-ធ្វើឱសថ : ទោះបីជាបច្ចុប្បន្នមានការរីកចំរើនផ្នែកខាងគីមីសាស្ត្រ ឱសថសាស្ត្រ ដែលបាននឹងកំពុងនាំចូលមកពីបណ្ដាប្រទេសជឿនលឿនមួយចំនួនលើពិភពលោកក៏ដោយ ក៏ប្រជាជនខ្មែរយើងតែងតែមានជំនឿ ទៅលើឱសថបូរាណដែលផ្សំអំពីសំបក សន្លឹក ត្រួយ ដើម ឫស វល្លិ មើម...រុក្ខជាតិសម្រាប់ព្យាបាលរោគដែរ ។ ដូចជាម្សៅមើមក្ដួចគេអាចយកមកសូន ជាមួយទឹកឃ្មុំអាចកែរោគបញ្ចុះព្រូន ផ្សះដំដៅគ្រុនក្ដៅ គ្រុនចាញ់ ... ។

-ធ្វើម្សៅលាបមុខ : កាលពីសម័យដើមគេច្រើនតែយកម្សៅក្ដួចមកផ្សំជាមួយទឹកខ្ទឹមចន្ទន៍ធ្វើម្សៅលាបមុខសំរាប់ប្រើក្នុងពីធីផ្សេងៗ ដូចជាមានពិធីបុណ្យទាន ឬប្រើសម្រាប់អ្នករបាំ អ្នកល្ខោន អាយ៉ៃ យីកេ និងអាចប្រើក្នុងពិធីរៀបអាពាហ៍ពិពាហ៍...។ តួយ៉ាងដូចជានៅខេត្តកោះកុងនាពេលបច្ចុប្បន្ននេះក្នុងពីធីចូលម្លប់កូនក្រមុំ គឺគេនៅថែរក្សាទំនៀមទម្លាប់ដោយគេប្រើម្សៅលាបមុខធ្វើអំពីម្សៅមើមក្ដួចនេះផងដែរ ។

-ធ្វើថ្នាំកំចាត់សត្វល្អិត : យើងដឹងហើយថា ក្ដួចគឺជារុក្ខជាតិពុល ដូចនេះគេអាចយកមើមរបស់ក្ដួចទៅលាយផ្សំជាមួយទឹកនោម និងថ្នាំជក់ ធ្វើជាថ្នាំសម្លាប់សត្វល្អិត បាញ់លើបន្លែឬរុក្ខជាតិផ្សេងទៀតដែលត្រូវសត្វល្អិតបំផ្លាញ ជំនួសថ្នាំគីមីសាស្ត្របាន ។ ហើយថ្នាំដែលផ្សំអំពីមើមក្ដួចនេះគឺវាមិនមានផលប៉ះពាល់ដល់

បរិស្ថានធម្មជាតិខ្លាំងដូចថ្នាំគីមីសាស្ត្រទេ ហើយវាក៏មិនធ្វើឱ្យប៉ះពាល់ដល់សុខភាព អ្នកបរិភោគនូវបន្លែ ផ្លែឈើទាំងនោះដែរ ។

## VI – សហគមន៍មនុស្ស និងបរិស្ថានធម្មជាតិ

ជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សតែងតែពឹងពាក់ទៅលើបរិស្ថានធម្មជាតិ ជា កត្តាសំខាន់ ។ ការកាប់បំផ្លាញព្រៃឈើ គឺធ្វើឱ្យដីអត់ជីវជាតិអន់គុណភាព ព្រមទាំង បង្កការហូរច្រោះនាំដីខ្សាច់ចូលស្រែ ។ គ្មានព្រៃ ភ្លៀងមិនសូវមាន ជួបភាពរាំងស្ងួត មិនតែប៉ុណ្ណោះការកាប់បំផ្លាញដើមឈើ គឺធ្វើឱ្យរុក្ខជាតិផ្សេងៗទៀត ដែលរស់ អាស្រ័យដើមឈើ ដូចជាវល្លិដំឡូង វល្លិក្ដួច ....... មិនអាចលូតលាស់បាន ។ ហេតុនេះ ក្នុងព្រៃរបោះ ដែលគ្មានដើមឈើ គឺធ្វើឱ្យអស់វល្លិ ។ ការបាត់បង់វល្លិគឺធ្វើឱ្យបាត់បង់នូវ រុក្ខជាតិបៃតងដែលរួមចំណែកផ្ដល់នូវសម្រស់ធម្មជាតិមួយក៏វិត ពិសេសជាងនេះទៅ ទៀត គឺរុក្ខជាតិវល្លិវាផ្ដល់នូវអនុផលដល់ប្រជាពលរដ្ឋជាច្រើនដូចជា ធ្វើឱសថបូរាណ ធ្វើជាអាហារ ធ្វើជារបស់របរប្រើប្រាស់ ជាដើម ។

នៅពេលដែលគេចូលទៅក្នុងព្រៃឬតំបន់ភ្នំ ក្នុងបំណងកាប់ឈើយកមកធ្វើ ផ្ទះ ឬតម្រូវការផ្សេងៗ គឺចាស់បូរាណ ដែលស្គាល់វល្លិក្ដួច គាត់តែងតែណែនាំឱ្យក្មេងៗ ឬអ្នកដែលមិនស្គាល់ និងប្រាប់អំពីសារប្រយោជន៍របស់វា ដើម្បីឱ្យមនុស្សជំនាន់ ក្រោយយល់ពីតំលៃ ហើយចេះថែរក្សាកុំឱ្យក្ដួចផុតពូជ ។

ទោះបីក្ដួចជារុក្ខជាតិវល្លិក៏ដោយ តែវាមានគុណប្រយោជន៍ណាស់ គឺមិនត្រឹមតែយកមកធ្វើជាអាហារ ឬឱសថប៉ុណ្ណោះទេ វាថែមទាំងបានរួមចំណែកក្នុង ការញ៉ាំងបរិស្ថានអោយមានពណ៌បៃតងស្រស់បំព្រងទៀតផង ។ ហេតុនេះហើយនៅ ពេលដែលគេកាប់គាស់គល់ឈើ ឬកាប់ដើមឈើ ប្រទះនូវវល្លិក្ដួច គេរមែងរក្សាវាទុក ឬយកទៅកប់កន្លែងថ្មី ព្រោះនៅពេលដែលគេបានឃើញក្ដួច គឺតែងស្រមៃនឹកដល់ អតីតកាល ដែលខ្លួនធ្លាប់បានជួបនឹងគ្រោះទុរ្ភិក្ស ឬមានគ្រោះអាសន្នផ្សេងៗ គឺមានក្ដួច

នេះហើយដែលជួយឱ្យជីវិតគេបានរស់ដល់សព្វថ្ងៃ ។ ពីមុនប្រជាពលរដ្ឋរស់នៅតាមតំបន់ព្រៃរស់បានសុខស្រួលដោយសារតែអនុផលព្រៃឈើ ។ នេះជាចំណុចមួយដែលបង្ហាញឱ្យឃើញពីទឹកចិត្តស្រលាញ់ព្រៃឈើរបស់ពួកគាត់ ។

សំខាន់មួយទៀត គឺការទប់ស្កាត់បទល្មើសព្រៃឈើក្នុងសហគមន៍ បើមានសមាជិកនៅក្នុងសហគមន៍ លួចកាប់ឈើ ឬបំផ្លាញរុក្ខជាតិផ្សេងៗ ដើម្បីរុករានដីព្រៃចំណែកណាមួយនោះ ពួកគេសុំឱ្យអាជ្ញាធរ ឬរុក្ខាប្រមាញ់ជួយអប់រំ និងណែនាំជននោះ ។ បានសេចក្តីថាគាត់មិនចង់ឱ្យព្រៃនោះបាត់បង់វិញទេ ។ តែនៅមានប្រជា-ពលរដ្ឋគាត់នៅឆ្ងាយពីសហគមន៍ អាចចូលកាប់ដោយគាត់មិនដឹងពីច្បាប់ទំលាប់ ។

## សន្និដ្ឋាន

ក្នុងកាលៈទេសៈធម្មតា ក្លូចជារុក្ខជាតិមួយ ដែលគេមិនសូវចាប់អារម្មណ៍ប៉ុន្មានឡើយ ។ ប៉ុន្តែវាដើរតួនាទីសំខាន់នៅពេលដែលស្រុកកើតទុរ្ភិក្សអត់បាយ ។ ពេលនោះទើបគេដឹងថា រុក្ខជាតិនេះមានគុណប្រយោជន៍ មិនអន់ជាងបាយប៉ុន្មានឡើយ ។ ការស្គាល់រុក្ខជាតិក្លូចគឺពិតជាមិនអត់ប្រយោជន៍ទេ ។ ទោះបីវាជារុក្ខជាតិប្រភេទវល្លិ៍ក្តី ក៏វាមានចំណែកក្នុងការញ៉ាំងបរិស្ថានឱ្យមានលក្ខណៈស្រស់បំព្រងធ្វើឱ្យដីជក់ជាតិសើមបានយូរ និងផ្តល់នូវអាកាសធាតុត្រជាក់ ធ្វើឱ្យអាកាសធាតុបរិសុទ្ធ ក៏ដូចជាបង្កើតឡើងនូវទេសភាព គួរជាទីចាប់ចិត្តចាប់អារម្មណ៍ សផងដែរ ។

មានព្រៃមានក្លូច មានជីវិត ។ មានព្រៃមានសត្វបក្សាបក្សី ម្រឹគីម្រឹគា ។ ក្លូចផ្សាភ្ជាប់នឹងព្រៃដែលជា ប្រភពនៃជីវិតខ្មែរ ។

ដូចនេះវាជាការសំខាន់ណាស់ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និងពង្រឹងការការពារបរិស្ថាន ដើម្បីឱ្យមានការអភិវឌ្ឍន៍និរន្តរភាព ។ រាជរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃបានបង្កើតច្បាប់ស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិដើម្បីកាត់បន្ថយ អ្វីដែលជាផលប៉ះពាល់លើបរិស្ថានធម្មជាតិ ។

# អំពីជនជាតិកួយ[១]

នៅក្នុងប្រទេសកម្ពុជាយើង មានជនជាតិជាច្រើន ដូចជាភ្នង ជង កួយ ស្ទៀង រដែ ស្អូច ព័រ ជាដើម ។ ពួកនេះចូលចិត្តរស់នៅតំបន់ព្រៃភ្នំ ឆ្ងាយពីសង្គមស៊ីវិល័យ ។ ជនជាតិទាំងនេះ មានរបៀបរបបរស់នៅ ភាសា ប្រពៃណី និងទំនៀមទម្លាប់ប្លែកៗ គ្នា ។ នៅពេលនេះខ្ញុំសូមលើកយកជនជាតិកួយ នៅខេត្តកំពង់ធំ មកជម្រាបជូនដូចតទៅ ៖

## ១. អំពីទម្រង់រូបរាង និងសម្លៀកបំពាក់

ក. *កួយប្រុស* ៖ មានរូបរាងប្រហែលខ្មែរនៅស្រុកលើដែរ បបូរមាត់ក្រឹម សម្បុរសណ្ដែកបាយ ស្លៀកខោខ្លី ឬសំពត់ចងក្បិន ពាក់អាវតាមសម័យនិយមខ្លះ ឬអាវបំពង់ពណ៌ខ្មៅ ។ សម្ដីនិយាយច្រើនបង្អួសចុងឃ្លា ។ តាមការកត់សម្គាល់ កួយច្រើនមានចិត្តប្រែប្រួលនិយាយមិនសូវទៀងទាត់ ។ ចង់ទប់ទល់ពួកនេះ ទាល់តែប្រកាន់ភាពម៉ឺងម៉ាត់ទើបសម្រេច ហើយកោតញញើត លែងហ៊ានធ្វើផ្ដេសផ្ដាស ។

ខ . *កួយស្រី* ៖ ទម្រង់រូបរាងមិនខុសពីស្រីខ្មែរយើងប៉ុន្មានឡើយ ។ ស្រីៗទុកសក់បួងគ្រប់គ្នា តែផ្នួងមានទំហំតូច ប្រហាក់ប្រហែលនឹងផ្នួងពួកបារគូ ។ គេនិយមស្លៀកសំពត់សម្លុយ ឬចងក្បិន តែក្បិនគេច្រើនរិតកប់ដល់គល់ភ្លៅ ។ ស្រីចាស់ ច្រើនតែយកអាវមកចងពាតរិតដងខ្លួន គេមិនសូវពាក់ទេ ។ កួយគេមុំពាក់អាវជានិច្ច ។ ហើយជួនកាលមានថែមដណ្ដប់ក្រម៉ាពីលើអាវទៀតផង ។ គេពាក់តែង

( ១ ) មានចែកជាពីរភាសា គឺកួយដែក និងកួយដឺរ ជនជាតិនេះច្រើនរស់នៅខេត្តកំពង់ធំ ក្នុងស្រុកកំពង់ស្វាយ ស្រុកសណ្ដាន់ ស្រុករវៀង ឃុំនីពេជ្រ ជាដើម ។ លោកមេឃុំនីពេជ្រ បានសរសេរឯកសារនេះ តាមសំណូមពររបស់លោកចាងហ្វាងពុទ្ធសាសនបណ្ឌិត្យ តាមលិខិតលេខ 1131 IB ចុះថ្ងៃទី ២២ . ០៧ . ១៩៩៨

លំអខ្លួនដោយពាក់ខ្សែកប្រាក់ ឬ ពាក់ចារុំដោតខ្សែអំបោះ ។ នៅកដៃមានពាក់កងប្រាក់ ឬស្ពាន់ស ។ ពួកនាងស្រឡាញ់អង្កាំលើសអ្វី១ទាំងអស់ ។ គេយកមកពាក់ធ្វើខ្សែក ឬខ្សែដៃ ។ ម្រាមដៃសឹងលំអដោយចិញ្ចៀនប្រាក់ ឬស្ពាន់ តែពុំមានដាំត្បូងទេ ។ ក្រមុំ១ និយមយកផ្កាឈើក្រអូបមកសៀតត្រចៀក ឬសៀតផ្នួងសក់ដើម្បីលើកសម្រស់ ។ ស្រីកួយមានទំនៀមទម្លាប់ចោះត្រចៀកពាក់ក្រវិល ឬការដែរ ។

## ២. អំពីជំនឿសាសនា៖

ក្រៅពីជឿលើអារុក្ខអារក្សអ្នកតា ជនជាតិកួយក៏ជឿហើយកាន់ព្រះពុទ្ធសាសនា[(១)] ផងដែរ ។ មានវត្តកួយមួយសម្រាប់ស្រុកកំពង់ស្វាយ និងស្រុករវៀងដែលមានព្រះសង្ឃសុទ្ធតែជាជនជាតិកួយបួសនៅក្នុងវត្តព្រៃទទឹងនោះ ។ តាមការបញ្ញត្តិរបស់វិន័យ លោកសង្ឃកួយមិនអនុញ្ញាតឱ្យនិយាយភាសាកួយឡើយ ។ ការប្រាស្រ័យទាក់ទងគ្នាគ្រប់យ៉ាង ត្រូវនិយាយជាភាសាខ្មែរ ។ ទាល់តែចាកសិក្ខាបទមកជាគ្រហស្ថវិញ ទើបនិយាយភាសាកំណើតបាន ។

## ៣. អំពីសិល្បៈ៖

ជនជាតិកួយគ្មានបទចម្រៀងប្រចាំពូជសាសន៍ទេ ។ គេច្រៀងតាមតែបទចម្រៀងខ្មែរ ។ ក្រៅពីនេះ កួយចេះផ្លុំប៉ីពកប្រគំបទពិរោះលន្លង់លន្លោច និងផ្លុំប្រកួកស្នែងជាបទងាយ១ ឬវាយអង្គុច ។ សំឡេងអង្គុចមិនមែនគ្រាន់តែប្រគំសាច់ភ្លេងប៉ុណ្ណោះឡើយ ប៉ុន្តែក៏អាចប្រើជាសញ្ញាឆ្លើយឆ្លងរវាងក្រមុំ និងកំលោះទៀតផង ។

(១) ជនជាតិកួយចូលឆ្នាំ នៅថ្ងៃជាមួយគ្នា និងខ្មែរយើង ។ គេលេងល្បែងសព្វសារពើដូចខ្មែរសុទ្ធសាធ ប៉ុន្តែរយៈពេលចូលរបស់គេ គឺ ១ខែ ។ មានធ្វើពិធីចូលឆ្នាំ និងពិធីចេញឆ្នាំ ។ ក្នុងចន្លោះថ្ងៃចូល និងចេញ គេលេងល្បែងកំសាន្តផ្សេង១ ដោយមិនរវល់ចាប់កាន់ការងារអ្វីទាំងអស់ ។ ខ្ញុំដឹងអំពីរបៀបរបបនេះនៅពេលខ្ញុំទៅជំរឿននៅភូមិកួយក្នុងកំលុងឆ្នាំ១៩៦០

## ៤. អំពីរអក្សរសាស្ត្រ និងភាសា :

ជនជាតិកួយគ្មានអក្សរទេ ។ អ្នកបួសក្នុងព្រះពុទ្ធសាសនារៀនតែអក្សរខ្មែរ ហើយសូត្រធម៌ជាបាលី ប្រែជាខ្មែរដូចព្រះសង្ឃយើងដែរ ។ ភាសានិយាយរបស់គេ ស្រដៀងគ្នានឹងចាម និយាយខ្មែរ ។

### ភាសានិយាយ

| ពាក្យខ្មែរ | ពាក្យកួយ |
|---|---|
| ត្រី | កា |
| ឆ្កែ | ច |
| ប្រាក់ | ផ្រាក់ |
| ស៊ីបាយ | ចាដូយ |

ការរាប់ចំនួន មានពាក្យអាចយកមកប្រើប្រាស់បានតែពី ១ ទៅដល់ ២៩ ។ ចាប់ពី ៣០ ឡើងទៅ ប្រើតាមពាក្យខ្មែរទាំងអស់ ។

## ៥. អំពីរបរកសិ

ដើម្បីចិញ្ចឹមជីវិត ជនជាតិកួយប្រកបរបរកសិកម្មជាមូលដ្ឋាន ។ គេធ្វើស្រែ ២ ឬ ៣ កន្សែរ១ភូមិ ធ្វើរបៀបលេង១សោះតែខាន ។ គេនិយមធ្វើចម្ការតាមរបៀបកាប់ព្រៃដុត រួចដាំស្រូវ ពោត សណ្តែកទ្រើង ល្ង ល្ពៅ ននោង ។ ដំណាំផ្សេង១ត្រូវបានដាំចម្រុះគ្នានៅក្នុងចម្ការតែមួយ ។ ក្រឡាផ្ទៃនៃចម្ការ

មានពី ១ ទៅ ២ ហិកតា ។ គ្រួសារនិមួយៗចិញ្ចឹមគោញី ១ ឬ ២ ចិញ្ចឹម មេមាន់ ២ ឬ៣ ក្បាល ។ ក្រៅពីរបរធ្វើស្រែចម្ការ ជនជាតិកួយរកស៊ីកាប់ឈើ ចាំងជាហុប ធ្វើទូក ត្បាញឫស្សី ឬផ្តៅ ធ្វើដំបូលរទេះ ធ្វើគ្រស[1] ចន្លុះ ដងជ័រទឹក បេះជ័រចុង បោចវល្លិ៍ ផ្តៅ ដំដែកធ្វើកាំបិត ពថៅ ដឹង ។ល។ ស្រីៗត្បាញរវៃអំបោះ ជួនកាលធ្វើសូត្របន្តិចបន្តួចផងដែរ ។ ប្រុសៗចូលចិត្តបរបាញ់ ដាក់អន្ទាក់ ទាក់សត្វព្រៃ ព្រោះពួកនេះប៉ិនប្រសប់នឹងស្គាល់ដានសត្វគ្រប់យ៉ាង ។

## ៦. អំពីទីលំនៅ :

កាលណាកាប់ព្រៃរួចហើយ គេយកភ្លើងទៅដុតឱ្យឆេះទៅជាផេះ ។ គេនាំគ្នាទៅសង់រោងតាមពួកក្រុមដូចនៅឯភូមិដែរ ។ រោងនៅចម្ការក៏ដូចនៅភូមិ មានប្រវែងទទឹង ៣ ទៅ ៤ ម៉ែត្រ បណ្តោយ ៥ ទៅ ៦ ម៉ែត្រ ។ សសរខ្ទមធ្វើពីឈើប៉ុនៗចុងភ្លៅ ឬប៉ុនកំភួនជើង ដាំញឹកស្អេកជិតៗគ្នា ធ្វើជាចន្ទល់ ។ ខ្ទមទាំងនោះមានកម្ពស់ពី ១,៦០ម ទៅ ១,៨០ម ។ រនាបធ្វើពីកូនឈើតូចៗត្រង់ៗ ដែលក្រងរែងនឹងវល្លិ៍ ឬចម្រៀកផ្តៅឱ្យជាប់គ្នាជាកម្រង ។ ចង្ក្រាននៅលើផ្ទះសម្រាប់ស្ល ដណ្តាំ ។ ឯចង្ក្រាននៅក្រោមផ្ទះ សម្រាប់បង្កាត់ភ្លើង អាំង អ្នើរ ទាំងយប់ ទាំងថ្ងៃ ។ គេយកស្លឹកផ្តៅសោម[2] មកតម្រៀបចងក្រងជាផ្ទាំងៗសម្រាប់ប្រក់ដំបូល ។ ជណ្តើរ ជួនមាន ជួនគ្មាន ។ ដើម្បីឡើងលើផ្ទះ គេយកឈើសណ្តូកមកដាក់តងលើមាត់ទ្វារខ្ទម ផ្អែករាងទ្រេតបន្តិច ។ ជញ្ជាំងផ្ទះមិនមានភាពតត់មត់ជិតមិតប៉ុន្មានទេ ។ ដូច្នេះ អ្នកផងអាចមើលឃើញអ្វីៗនៅក្នុងផ្ទះទាំងអស់ ។

---

(១) ប្រដាប់ប្រដាដងទឹក ធ្វើពីឫស្សី (រាងដូចកញ្ជើជើង) ខ្ចុកម្រ័ក្សណ៍កុំឱ្យលេចទឹក និងដើម្បីប្រើបានយូរ ។

(២) សោមដូចគ្នានឹងផ្តៅដែរ តែស្លឹកវាញឹកហើយធំជាង ។ ស្លឹកសោម និងធាងពុំមានប្រើដូចផ្តៅទេ ។ គេយកស្លឹកសោមនឹងធាងមកតម្រៀបហើយដេរក្រងជាផ្ទាំងៗសម្រាប់ប្រក់ផ្ទះ ។

## ៧. លក្ខណៈពិសេសរបស់ជនជាតិក្លួយ

ជនជាតិក្លួយមានចំណុចខ្លាំងពីរយ៉ាង គឺ :

ក). ពួកគេខាងដើរលឿន ទាំងស្រី ទាំងប្រុស ហើយមានអំណត់អត់ធន់ ។ គេអាចទូល រែករបស់ធ្ងន់ៗក្នុងដំណើរទៅកាន់ទីឆ្ងាយបាន ដោយពុំសូវអស់អន់អ្វីប៉ុន្មានឡើយ ។ ល្បឿនដែលក្លួយដើរ ស្មើនឹងល្បឿនដែលខ្មែរយើងរត់ត្រឹកៗ ។

ខ). ពួកគេខាងមិនខ្លាចខ្មោចព្រាយបិសាច មិនខ្លាចសត្វសាហាវ មានខ្លាដំរីជាដើម ។

## ៨. ប្រពៃណីផ្សេងៗរបស់សាសន៍ក្លួយ

ជនជាតិក្លួយខ្លាចជំងឺណាស់ ។ កាលបើជំងឺឆ្លងចូលមករាតត្បាត ហើយបណ្ដាលឱ្យមានមនុស្សស្លាប់ ពីរ ឬបីនាក់នោះ អ្នកស្រុកទាំងអស់នាំគ្នារត់ចោលភូមិទៅនៅដោយព្រៃ បែកខ្ញែកគ្នាអស់ ។ ទាល់តែជំងឺនេះបានកន្លងផុតទៅ ទើបវិលត្រឡប់ចូលមកនៅក្នុងភូមិវិញ ។ ខ្លះទៀតទៅបាត់រហូតឥតវិលវិញទេ ។

កំលោះក្លួយមិនសូវស្រវាស្រទេញរវៀសរវៃក្នុងការងារទេ ។ ពេលយប់គេតែងនាំគ្នាទៅលួកក្រមុំៗ ។ សូមជម្រាបថា ក្រមុំក្លួយទាំងអស់ កម្រមានដោះនៅបរិសុទ្ធណាស់ ដោយហេតុពួកកំលោះមកលូកលេងរៀងរាល់យប់ ។ ក្រមុំក្លួយមានទម្លាប់បុកអង្ករ ឬស្រូវ យកដៃគ្នានៅផ្ទះណាមួយ ដែលគេបានណាត់គ្នាទុកជាមុន ។ ស្រីៗបុកអង្ករក្នុងចង្វាក់ញាប់រន្ថើន ។ ដើម្បីឱ្យលាន់ឮសំឡេងអង្រែងខ្ទរទៅបានឆ្ងាយ គេជីកលុងដីពីក្រោមបាតត្បាល់ ។ នៅពេលស្រីៗប្រជុំគ្នាបុកអង្ករ ពួកកំលោះនាំគ្នាមកចោមរោម និយាយសាសងលូកលេង ពាក្យពេចន៍ផ្ដោះផ្ដងស្នេហា ។ កាលណាស្រីៗបុកអង្កររួចហើយ គេបែកគ្នាទៅដេកតាមផ្ទះរៀងខ្លួនៗ ។ ឯប្រុសៗក៏តាមទៅលូកដោះនារីណាដែលគេបានដឹងចិត្តគ្នាទៅវិញ ទៅ

មករួចហើយ ។ ពួកកំលោះលួកដៃតាមប្រហោងជញ្ជាំង ឬប្រហោងរនាប ហើយស្ទាបដោះក្រមុំកួយលេងយ៉ាងយូរ ទាល់តែឱពុកគេគ្រហែមទើបដើរផយចេញ ។ មួយសន្ទុះក្រោយមក ក៏ត្រឡប់មកលួកវិញទៀត ។ បើស្រីមិនស្រឡាញ់ប្រុសទេ វាមិនព្រមឱ្យប្រុសនោះ លួកលាន់វាទេ គឺវាមានឧបាយកលដេកឱ្យឆ្ងាយពីប្រហោងរនាប ឬប្រហោងជញ្ជាំង ធ្វើមិនឱ្យប្រុសលួកបាន ។ ផ្ទុយទៅវិញបើគេស្រឡាញ់គ្នា ត្រូវរ៉ូវគ្នាហើយនោះ កញ្ញាបណ្តោយឱ្យប្រុស កំណាន់លួកកំសាន្តតាមចំណង់ ។

កំលោះខ្មែរក៏ចង់ទៅបន្លំលួកក្រមុំកួយដែរ ប៉ុន្តែគេពិបាកឆ្លៀតឱកាសណាស់ ។ ទាល់តែមានពិធីបុណ្យខ្មោច លេងទាយល្បែងផ្កាប់ផ្ងា ដោយបោះសេនក្រហម ហើយភ្នាល់គ្នាទាយរូប ដែលនៅលើសេន ។ បើកំលោះឈ្នះល្បែងនោះ អាចមានសិទ្ធិប្រឡូកប្រឡែង ដណ្តើមដោះយកខ្សែក ឬក្រម៉ាពីក្រមុំៗ ហើយឆ្លៀតឱកាសនោះ លួកលាន់ ឈ ចិត្ត ។ បើដឹងចិត្តគ្នាហើយ អាចទៅលួកគេនៅពេលយប់បាន ដោយពុំមានឧបសគ្គឡើយ ។

" កាលពីកំឡុងឆ្នាំ ១៩៥៦-៥៧(១) * ខ្ញុំបានឮមិត្តភក្តិខ្ញុំខ្លះៗ ដែលទៅធ្វើ

---

(១) តាំងឆ្នាំ ១៩៥៤ ដល់ ១៩៧០ ខ្ញុំត្រូវបានចាត់តាំងឱ្យទៅបង្រៀននៅខេត្តកំពង់ធំ ដែលនៅទីនោះខ្ញុំមានមិត្តភក្តិជាច្រើនដែលត្រូវបានចាត់ឱ្យទៅបង្រៀននៅស្រុករវៀង ជាំក្សាន សណ្តាន់ ហើយនិយាយប្រាប់ខ្ញុំអំពីការលួកក្រមុំកួយ និងទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិកួយ ។

( * ) កាលពីឆ្នាំ ១៩៦០ រូបខ្ញុំបានត្រូវចាត់តាំងឱ្យទៅជំរឿនប្រជាជននៅតំបន់ស្រុកកំពង់ស្វាយលើ ជាប់នឹងស្រុកសណ្តាន់ ។ ខ្ញុំបានចូលទៅភូមិកួយជាច្រើន មានភូមិស្មៀវាលវែង គោល ដែលជាភូមិធំៗ មានសុទ្ធតែជនជាតិកួយរស់នៅ ។ ពេលជំរឿន ត្រូវយកខ្មែរម្នាក់ដែលចេះភាសាកួយធ្វើជាអ្នកបកប្រែ ។ ខ្ញុំបានកូតទ្រឱ្យពួកកួយស្តាប់ ពួកវាសរសើរថាខ្ញុំកូតទ្រពិរោះពេកណាស់ ពិរោះជាងពួកវា ។

ជាគ្រូបង្រៀននៅខេត្តកំពង់ធំនៅភាគខាងជើង ( ដាំក្បាន រវៀង សណ្ដាន់ ... ) និយាយរឿងរ៉ាវផ្សេងៗ ទាក់ទងទៅនឹងប្រពៃណីទំនៀមទម្លាប់ជនជាតិកួយ ប្រាប់ឱ្យខ្ញុំបានដឹង ពិសេសអំពីការលួកក្រមុំកួយនេះតែម្ដង ។ ក្រមុំកួយតែងចាប់ចិត្តស្រឡាញ់គ្រូកំលោះៗជាតិខ្មែរ ដែលទៅបង្រៀននៅតំបន់ស្រុកភូមិកួយ ។ ពិសេសគ្រូកំលោះខ្មែរ ក្ដាប់បានចំណុចខ្សោយរបស់ក្រមុំកួយ គេបានទិញខ្សែអង្កាំធ្វើជាជំនូនស្នេហ៍ចំពោះក្រមុំជនជាតិ ទាក់ទាញចិត្តនារីឱ្យស្រឡាញ់ខ្លួន ។ នៅពេលយប់ ទាំងកំលោះកួយ ទាំងកំលោះខ្មែរជាគ្រូបង្រៀន បានត្រាច់ចរក្នុងរាត្រីស្វែងរកគូរមេត្រី លូកដៃស្ទាបសុដន់កម្សាន្តចិន្ដា ។ ជួនកាល ការស្រឡាញ់គ្នានេះមិនព្រមស្ថិតនៅត្រឹមការលូកលេងដោះនៅរាល់ៗយប់នោះទេ គឺមានការជ្រុលជ្រួសរហូតដល់រួមរក្សខាងផ្លូវភេទជាមួយគ្នាទៀតផង ។ ក្នុងករណីនេះ ប្រសិនបើឪពុកម្ដាយខាងស្រីដឹងការណ៍ គេហៅខាងប្រុសមកសួរថា ៖ តើ "សែនចេញ" ឬ "សែនចូល"?[១] ។ សែនចេញគឺជាពិធីចាត់ចែងឡើង ដើម្បីជម្រាប និងសុំទោសព្រលឹងដូនតាកួយ កុំឱ្យប្រកាន់កូនចៅ ដែលជ្រុលជ្រួសភ្លាំងភ្លាត់ខាងរឿងស្នេហា ហើយមិបាច់យកគ្នាជាប្ដីប្រពន្ធក៏បាន ។ ពិធីសែនចេញមានរណ្ដាប់មួយបែបដោយឡែក .... ។ តែបើសែនចូលវិញ គឺជាពិធីរៀបអាពាហ៍ពិពាហ៍ពេញទីតែម្ដង ដែលគេតែងចាត់ចែងធ្វើទៅតាមប្រពៃណីទំនៀមទម្លាប់ជនជាតិកួយ ។ ពួកគ្រូដែល

---

(១) សែនចេញ គឺគ្រាន់តែសែនជម្រាប និងសុំទោសព្រលឹងដូនតា កុំឱ្យប្រកាន់ខឹងចំពោះការជ្រុលជ្រួសភ្លាំងភ្លាត់របស់កូនស្រី រួចហើយមិនយកគ្នាជាប្ដីប្រពន្ធទេ តែត្រូវឈប់រកអាក់ទងតទៅទៀត ។

(*) សែនចូល គឺរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីកួយ ដោយមានរណ្ដាប់រណ្ដាភត្តុភារតាមទំនៀមទម្លាប់តាមពូជសាសន៍ជាតិគេ រួចហើយរួមរស់នៅជាប្ដីប្រពន្ធតរៀងទៅ ។ ខ្ញុំស្ដាយណាស់, ដោយពុំបានស្រាវជ្រាវដឹងអំពីរបៀបរៀបចំរណ្ដាប់ភត្តុភារតាមប្រពៃណីពិធីរៀបការនេះ ។

ត្រូវជាមិត្តភក្តិខ្ញុំ និយាយទៀតថា ៖ កូនក្រមុំកួយខ្លះ ស្អាតមែនទែន សម្រស់គេមិនចាញ់កូនក្រមុំខ្មែរឡើយ ។ តែពួកគេមិនដាច់ចិត្តយកមកធ្វើជាប្រពន្ធពេញច្បាប់ ព្រោះមានក្តីបារម្ភពីរយ៉ាង ៖

- ក្រែងមិនអាចចូលចុះ ក្នុងសង្គមស៊ីវិល័យ
- ក្រែងឪពុកម្តាយមិនយល់ស្របជាមួយផង ព្រោះជាអ្នកស្រុកព្រៃ

ដូច្នេះរាល់ការថ្លោះធ្លោយ ជាប់ជំពាក់អន្ទាក់ស្នេហ៍ជាមួយក្រមុំកួយ គេតែងតែជ្រើសរើសយកពិធីសែនចេញជាដរាប ។ តាមស្មាន ពិធីនេះត្រូវចំណាយប្រាក់មិនហួសពី ២០០ ឬ៣០០ ( ក្នុងជំនាន់នោះ )ឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ ការលេងសើចបែបនេះ ជាមួយនឹងស្នេហាពិតៗនោះ មិនមែនជាប្រការល្អប៉ុន្មានឡើយ ។ វាគឺជាការយកកាំបិតទៅឆូតសាច់បេះដូង ឱ្យឈឺចាប់ទទេៗតែប៉ុណ្ណោះ ។ តើអាចមានប្រពៃណីល្ងកលេង របៀបនេះទៀតឬទេ នៅក្នុងសហ-គមន៍ជនជាតិកួយ ? ។ មតិទូទៅស្មានយល់បានថា ទោះបីនៅតំបន់ដាច់ស្រយាលឆ្ងាយពីទីប្រជុំជនយ៉ាងណា ក៏អារ្យធម៌ទំនើបបានហូរចូលទៅដល់តំបន់ព្រៃភ្នំទាំងនោះខ្លះៗ ជាមិនខាន ។ ហើយកុលសម្ព័ន្ធកួយ ក៏ដូចជាជនជាតិភាគតិចដទៃទៀត នៅកម្ពុជា ពិតជាបានតាមប្រកៀកប្រកិតនឹងជនជាតិខ្មែរដែរ ។ ទាំងសម្លៀកបំពាក់ ទាំងភាសា ទាំងប្រពៃណីទំនៀមទម្លាប់ផ្សេងៗ ពិតជាមានការវិវត្តិប្រែប្រួលទៅរកវឌ្ឍនភាព ជាពុំខាន ។

កែសម្រួលពាក្យពេចន៍ឃ្លាឃ្លោង
និងបន្ថែមអត្ថន័យ ដោយ

**មៀច ប៉ុណ្ណ**

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ ២០៦ កធស/សរ

# សេចក្ដីសំរេច
# ស្ដីពីការបែងចែក ភារកិច្ចថ្នាក់ដឹកនាំ
# ក្រសួងធម្មការ និង សាសនា

## រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកម ០១៩៦.១៩ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងធម្មការ និង សាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/១១៩៨ ចុះថ្ងៃទី ០៦ ធ្នូ ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងឥស្សរជន ១៣២ រូប ជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- ដើម្បីធានានិរន្តរភាព នៃការងាររបស់ក្រសួង

## សំរេច

**ប្រការ១ :** ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រី ទទួលបន្ទុកគ្រប់គ្រង និងដឹកនាំរួមរាល់កិច្ចការក្នុងក្រសួង និងដោយឡែកទទួលបន្ទុកគ្រប់គ្រង និងដឹកនាំ នាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និងអធិការដ្ឋាន ។

- ឯកឧត្តម **អ៊ុន ថិសាអ៊ីម** រដ្ឋលេខាធិការ ទទួលពិនិត្យឯកសារលិខិតបទដ្ឋានរបស់ក្រសួង និងទទួលបន្ទុកគ្រប់គ្រងនឹងដឹកនាំ អគ្គនាយកដ្ឋានធម្មការ ។
- ឯកឧត្តម **ឈន ទៀម** រដ្ឋលេខាធិការ ទទួលពិនិត្យឯកសារលិខិតបទដ្ឋានរបស់ក្រសួង និងទទួលបន្ទុកគ្រប់គ្រងដឹកនាំពុទ្ធសាសនបណ្ឌិត្យ, ពុទ្ធិកមហាវិទ្យាល័យព្រះស៊ីហនុរាជ និងអធិការដ្ឋានពុទ្ធិកសិក្សា ។
- ឯកឧត្តម **អ៊ីស្មាឯល ឧស្មាន** អនុរដ្ឋលេខាធិការទទួលសម្របសម្រួលការងារ នាយកដ្ឋាន ពាហិរសាសនា ។
- ឯកឧត្តម **ដោក ណារិន** អនុរដ្ឋលេខាធិការ ទទួលសម្របសម្រួលការងារ អធិការដ្ឋានពុទ្ធិកសិក្សា ។
- ឯកឧត្តម **គ្រួច សារី** អនុរដ្ឋលេខាធិការ ទទួលសម្របសម្រួលការងារនាយកដ្ឋានស្រាវជ្រាវអប់រំផ្សព្វផ្សាយធម៌ទេសនា និងនាយកដ្ឋានធម្មការ ។
- ឯឧត្តម **សៅ ប៉ន** អនុរដ្ឋលេខាធិការ ទទួលសម្របសម្រួលការងារពុទ្ធសាសនបណ្ឌិត្យ ។
- ឯកឧត្តម **ហ្សាការីយ៉ា អាដាម** អនុរដ្ឋលេខាធិការ ទទួល

សម្របសម្រួលការងារអធិការដ្ឋាន ។

**ប្រការ ២ :** រាល់ការងារដែលមានស្មុគស្មាញ ត្រូវរដ្ឋមន្ត្រីជាប្រធានស្ថាប័ន រដ្ឋលេខាធិការទាំងពីរ អនុរដ្ឋលេខាធិការ សម្របសម្រួល និងអង្គភាពជំនាញ ប្រជុំពិគ្រោះដោះស្រាយបញ្ហាតាមនីតិវិធី ។

**ប្រការ៣ :** សេចក្តីសំរេចណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ចាត់ទុកជានិរាករណ៍ ។

**ប្រការ៤ :** ឯកឧត្តមក្នុងប្រការ ១ អគ្គនាយកដ្ឋានធម្មការ " នាយកដ្ឋានធម្មការ នាយកដ្ឋានស្រាវជ្រាវអប់រំផ្សព្វផ្សាយធម៌ទេសនា, នាយកដ្ឋានពាហិរសាសនា " នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ, អធិការដ្ឋានពុទ្ធិកសិក្សា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ, ពុទ្ធសាសនបណ្ឌិត្យ, អធិការដ្ឋាន និងមន្ទីរធម្មការ និងសាសនា គ្រប់ខេត្តក្រុង ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៥ :** សេចក្តីសំរេចនេះមានអានុភាពគតិយុត្តិ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០០*

**រដ្ឋមន្ត្រី**

**ជា សាវឿន**

**ចម្លងជូន :**
- សម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន

" ដើម្បីថ្វាយ និងគោរពជូនជ្រាប "
- គ្រប់សាលាខេត្ត-ក្រុង " ដើម្បីជូនជ្រាប "
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និងសាសនា**
លេខ ២៥៩ កធស

*ភ្នំពេញ, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០០*

# សេចក្ដីសំរេច

## រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក. ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និង សាសនា ។
- បានឃើញអនុក្រឹត្យលេខ ៤០២ អនក្រ. កត. ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញប្រកាសលេខ ២៥៧ របស់ក្រសួងចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្ដីពីរចនាសម្ព័ន្ធ ការិយាល័យក្រោមឱវាទនាយកដ្ឋាន និងអង្គភាពមូលដ្ឋានចំណុះក្រសួងធម្មការ និងសាសនា ។
- អនុលោមតាមការងារចាំបាច់របស់ក្រសួង ។

## សំរេច

**ប្រការ១** : តែងតាំងលោក **ខៀវ បញ្ញាវុឌ្ឍ** បច្ចុប្បន្នប្រធានការិយាល័យគ្រប់គ្រងនៃពុទ្ធសាសនបណ្ឌិត្យ ឱ្យទទួលបន្ថែម ជានិពន្ធនាយកនៃទស្សនាវដ្ដីកម្ពុជសុរិយា និងការងារបោះពុម្ពសៀវភៅពុទ្ធសាសន-បណ្ឌិត្យ ជំនួសលោក **ឱម ខែម** ។

**ប្រការ២** : ចំណុច **ខ** និង **គ** ប្រការមួយនៃសេចក្ដីសំរេចស្ដីពីគណៈកម្មការទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៨៨ កធស.បព ចុះថ្ងៃទី ២៤ មេសា ២០០០ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** : ខុទ្ទកាល័យ, នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ, នាយកដ្ឋានធម្មការ, នាយកដ្ឋានពាហិរសាសនា, នាយកដ្ឋានឃោសនាអប់រំផ្សព្វផ្សាយធម៌ទេសនា, អធិការដ្ឋានពុទ្ធិកសិក្សា, ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ, អធិការដ្ឋាន និងសាមីជន ត្រូវអនុលោមតាមសេចក្ដីសំរេចនេះ ឱ្យបានល្អ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន** :

- ឯកឧត្ដម រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ
- គ្រប់អង្គភាពចំណុះក្រសួង
  ( ដើម្បីជ្រាបជាពត៌មាន )
- ដូចប្រការមួយ ( ដើម្បីអនុវត្ត )
- ឯកសារ. កាលប្បវត្តិ

**រដ្ឋមន្ត្រី**

**ជាសារឿន**

ទំព័រមិត្តអ្នកអាន




# មិត្តអ្នកអានជាទីមេត្រី

ទស្សនាវដ្ដីកម្ពុជសុរិយា បានបោះពុម្ពជាលើកដំបូងក្នុងឆ្នាំ ១៩២៦ ចេញពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលកាលណោះជាមជ្ឈមណ្ឌលអប់រំសិក្សាស្រាវជ្រាវតែមួយគត់របស់ជាតិ ។

ដោយសារសង្គ្រាមនៅក្នុងអំឡុងឆ្នាំ ៧០ ទស្សនាវដ្ដីនេះ បានផ្អាកសកម្មភាពមិនអាចដំណើរការបាន ។

បច្ចុប្បន្ននេះ ទស្សនាវដ្ដីកម្ពុជសុរិយាបានបន្ត និងរក្សាតួនាទីរបស់ខ្លួនពីមុនមក ដូចដែលមិត្តអ្នកអានបានឃើញនៅនឹងដៃនេះស្រាប់ ។ យើងខ្ញុំប្រមែប្រមូលអ្នកចេះដឹងដែលសេសសល់ពីស្លាប់ និងបញ្ញវន្តជំនាន់ក្រោយ ដើម្បីពួតដៃគ្នាស្ថាបនា

ទស្សនាវដ្ដីនេះ អោយមានសារៈប្រយោជន៍ចំពោះអ្នកសិក្សាស្រាវជ្រាវ និងកូនខ្មែរជំនាន់ក្រោយ ។

ក្នុងន័យនេះ សូមមិត្តអ្នកអានគិតថា ទស្សនាវដ្ដីកម្ពុជសុរិយា ជាទស្សនាវដ្ដីរបស់កូនខ្មែរគ្រប់រូប ។ មិត្តអ្នកអានមានឱកាសជានិច្ចក្នុងការរិះគន់ កែលំអ ផ្ដល់មតិ ផ្ដល់អត្ថបទស្រាវជ្រាវ ទាក់ទងនឹងសាសនា អក្សរសាស្ត្រ សិល្បៈ រឿងរ៉ាវប្រវត្តិសាស្ត្រ ប្រពៃណីទំនៀមទំលាប់ខ្មែរ ដែលបានកកាយរកឃើញ ។

**ទំព័រមិត្តអ្នកអាន** រង់ចាំទទួលចុះផ្សាយអត្ថបទរិះគន់ កែលំអ និងអត្ថបទឆ្លើយតប រាល់ចម្ងល់របស់មិត្តអ្នកអានជានិច្ច ។

*ទស្សនាវដ្ដីកម្ពុជសុរិយា*

*តម្កើងការអាននឹងបានចេះ ពង្រីកចំណេះធំទូលាយ*
*បណ្ឌិតក្បៀកជិតពាលឃ្លាតឆ្ងាយ ពិតជាមិនងាយតាមគេញ្ជោះ ។*
*អត្តសញ្ញាណខ្លួនស្គាល់ច្បាស់ ទើបមិនប្ដូរផ្លាស់រហ័សហួស*
*ពូជខ្មែរធ្លាប់តែមានកេរ្តិ៍ឈ្មោះ ខ្មែរមិនត្រូវរស់ជាអ្នកខ្លៅ ។*

**ខៀវ បញ្ញាវុឌ្ឍ**

# កំណែពាក្យខុស

| ល.រ | ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|---|
| ១ | ឧបាយាទុក្ខ | ឧបាយាសទុក្ខ | ២ | ៨ |
| ២ | ប្រេប្រួល | ប្រែប្រួល | ១០ | ១២ |
| ៣ | ជាមួយអគ្គមហេសី | ជាអគ្គមហេសី | ១១ | ២០ |
| ៤ | សេចក្ដីរាស្ដ្រក្ដី | ស្ដេចក្ដីរាស្ដ្រក្ដី | ១៤ | ១៣ |
| ៥ | សន្ទត់ | សន្ទត | ១៦ | ៦ |
| ៦ | ចិត្តជួយជ្រោម | ចិត្តជួយជ្រោមជ្រែង | ១៦ | ២០ |
| ៧ | ជូន ណាត **ជោតញ្ញាណោ** | **ជួន ណាត** ជោតញ្ញាណោ | ១៧ | ១៦ |
| ៨ | យូរយា | យូរយារ | ២០ | ៥ |
| ៩ | បណ្ដុលបណ្ដោះ | បណ្ដុះបណ្ដាល | ៣០ | ៥ |
| ១០ | អកប្បកិរិយា | អាកប្បកិរិយា | ៣០ | ១៣ |
| ១១ | មាឋានៈ | មានឋានៈ | ៤២ | ១៤ |
| ១២ | រូបពោធិសាត់ | រូបពោធិសត្វ | ៤៦ | ៧ |
| ១៣ | ឥតខ្វះអ្វកឡើយ | ឥតខ្វះអ្វីឡើយ | ៦៦ | ៨ |
| ១៤ | សន្ទច | សន្ធូច | ៦៧ | ១០ |
| ១៥ | ទន្សាយមនិមានល្វ | ទន្សាយមិនមានល្វ | ៦៩ | ៩ |
| ១៦ | អារម្មណ៍សផងដែរ | អារម្មណ៍ផងដែរ | ៨៥ | ១៦ |